ភម្ពមសុទិយា

LIBRARY

ទស្សនាវិដ្ឋី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែកក្កដា លេខ ៣

ព.ស. ២៤៩៨ – គ.ស. ១៩៥៥



ធម្ពាសនយា

ទស្សនាវដ្ឋី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា		ទំព័រ
— ធម្មានុធម្មប្បដិបត្តិកថា	ព្រះមហា ថោង -យុ	៤៨៣
— បញ្ញាសជាតក ភាគទី ៣ (តមក)	បណ្ឌិតមហា ឈឹម -ស៊ុម	៤៩១
ផ្នែកអក្សរសាស្ត្រ		
— និទានសុភាសិត	ព្រះមហា ម៉ៅ-ទាន់	៥០១
— រឿងសៅរសោយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ឹង-ប៉ម ...	៥០៦
— រឿងសាមកុក (តមក)	ឧកញ៉ា នូ- កន	៥១៦
— ដំណឹងតាមឲ្យល់ក្នុងកន្ទារៈ (តមក) ...	លោក ផេង-ជ្រីវ	៥២៦
— រឿងបល្ស៍ង្គទិព្យ (តមក)	លោក វ៉ាយ- ប៊ុក	៥៣៥
កំណត់នឹងប្រវត្តិការណ៍		
— ពិធីហែព្រះសារីរិកធាតុនៅព្រៃនគរ	ព្រះញាណកោសលញាណ-ឈឹន	៥៤៣
— របៀបសិក្សានៃសាលាបាលីជាន់ទ្ពស់ ...	ពុទ្ធសាសនបណ្ឌិត្យ	៥៥៤

មួយឆ្នាំមាន ១២ ស្យៀវភៅ — ដំឡៃជាវ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: *Page*

— Dhammanudhammappatipatti-katha . . . . . *Brah Moha THONG-YU* . . *483*

— Pannasajataka-vol. 3 (suite) . *M. CHHIM-SOUM* *491*

PARTIE LITTERAIRE:

— Nidanasubhasita . . . . . *Brah Moha MAO-KHANN* . *501*

— Le « SAU-SOY » ou l'Influence saturnienne (suite) . . . *Brah Moha PEUNG-PAM* . *506*

— Histoire de SAMKOK (suite) . . *Oknha NOU-KAN* *516*

— Le souffle du désert (suite) . *M. PHENG-CHRIV* . . . *526*

— Les trente deux récits du TRONE (suite) . . . . . *M. RAY-BUC* *535*

NOTES ET CHRONIQUES:

— Réception des Reliques Sacrées à Saigon . . . . . *Vén. NHEAN-CHHOEUN* . *543*

— Programme d'Etudes de l'Ecole Supérieure de pali . . . . . *Institut Bouddhique* *554*

Prix d'abonnement annuel (comprenant 12 numéros) 210$00



ផ្នែកសាសនា

ធម្មានុធម្មប្បដិបត្តិកថា

ព្រះមហាឃោង-យុ វិត្ត សរាវ៉ន

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមេ តមេសទីកោមំ សុជសោអបនាបសុ

សុបិអធសិតិបុរិ សិជកុកោកគោទជ ។

ខ្ញុំព្រះករុណា សូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨ ព្រះអង្គ គឺព្រះតណ្ហង្ការ: ព្រះមេធង្ការ: ព្រះសរណង្ការ: ព្រះទីបង្ការ: ព្រះកោណ្ឌញ: ព្រះមង្គល: ព្រះសុមន: ព្រះរេវត: ព្រះសោភិត: ព្រះអនោមទស្សី ព្រះបទុម: ព្រះនារទ: ព្រះបទុមុត្តរ: ព្រះសុមេធ: ព្រះសុជាត: ព្រះបិយទស្សី ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថ: ព្រះតិស្ស: ព្រះបុស្ស: ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះកកុសន្ធ: ព្រះកោនាគមន: ព្រះកស្សប: ព្រះគោតមសម្មាសម្ពុទ្ធ ដោយសេចក្តីគោរព ។

ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា

ដោយពាក្យសច្ចនេះ សូមសិរីសួស្តីជោគជ័យមង្គល កើតមានជល់ពពួកពុទ្ធបរិស័ទ គ្រប់ ៗ កាលកុំបីឃ្លៀងឃ្លាត ! ។

បន្ទាប់អំពីកិរិយានមស្សការនេះទៅ ខ្ញុំព្រះករុណា អាត្មាភាពនឹងប្រារព្ធសំដែងព្រះសទ្ធម្មឈ្មោះ "ធម្មានុធម្មប្បដិបត្តិ" តទៅ ។ តែមុន នឹងលើកយកធមិនេះមកសំដែង សូមអធិប្បាយសម្រួលសេចក្តីបន្ទិចដូចតទៅនេះ ៖

បណ្តាមនុស្សសត្វតាំងឡាយដែលកើតមកក្នុងភាជនលោក រមែងមានការប្រព្រឹត្តិផ្សង ។ ត្នាគឺ ខ្លះប្រព្រឹត្តតាមធមិ ខ្លះមិនប្រព្រឹត្តតាមធមិ ឬខ្លះប្រព្រឹត្តតាមដែរ ប៉ុន្តែនៅស្ទាកគំនិត មិនមានសន្ទុះល្បឿនទៅមុខទៀត ដោយគិតឃើញថា: ការអនុវត្តិតាមសាសនធមិនេះ តែត្រឹមប៉ុណ្ណោះឯង, ត្មានគុណជាតិអ្វីឲ្យវិសេសលើសជាងការប្រព្រឹត្តិបែបនេះទៅទៀតទេ, អ្នកប្រព្រឹត្តធមិបែបនេះឈ្មោះថា មិនញ្ចាំងប្រយោជន៍របស់ខ្លួនឲ្យបានលូតលាស់ជាសាធារណៈទូទៅដល់មនុស្សជាតិគ្រប់ត្នាទេ ។ ជនខ្លះទៀត ប្រព្រឹត្តតាមធមិពិត ។ តាំងប្រាថ្នាឲ្យកើតប្រយោជន៍ដល់មនុស្សជាតិគ្រប់ប្រាណ បានស្បើយចាកទុក្ខបំភ្លឺភ្នែកមនុស្សក្នុងលោកឲ្យស្គាល់គុណ, ទោស, ខុស, ត្រូវ, បុណ្យ, បាប, ប្រេត, នរក, ហើយនឹងសេចក្តីចំរើន - មិនចំរើន តែងចូបប្រទះឃើញផលានិសង្សដែលកើតមកពីការប្រព្រឹត្តិស្មោះត្រង់ ចំពោះធមិដែលពិតប្រាកដនោះឬក៏បានបង្ហាញ ពន្យល់ត្នីត្នាឲ្យចេះដឹង យល់ចូលចិត្ត ស្តាប់បានថាការប្រព្រឹត្តិបែបនេះ បែបនោះ ជាគុណជាទោស; មិនឲ្យស្ទាក់ស្ទើរទញ់តុះគំនិតក្នុងការអនុវត្តិទៅតាមធមិពិតប្រាកដនោះឡើយ តាំងដឹងច្បាស់ថា អាត្មាប្រព្រឹត្តតាមធមិនេះ ឈ្មោះថាប្រព្រឹត្តធមិត្រូវ បើ

អាត្មាអញប្រតិត្តត្រូវតាមធម៌ល្អ ដែលអ្នកប្រាជ្ញទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើម ប្រាប់ប្រតិត្តមកនោះ នឹងបានសេចក្តីសុខប្រាសចាកទុក្ខគ្រប់យ៉ាង ក្នុងជាតិបច្ចុប្បន្ននេះ នឹងបរលោកនាយជាពុំខាន មិនធ្លាក់ទៅសោយទុក្ខឡើយ ។

សមដូចគាថាជាពុទ្ធភាសិតក្នុងធម្មបាលជាតកថា:

ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ធម្មចារឹ ។

ប្រែថា "ធម៌រមែងរក្សាបុគ្គលអ្នកប្រតិត្តទូវធម៌, ធម៌ដែលបុគ្គលសន្សំទុកល្អហើយ រមែងនាំមកនូវសេចក្តីសុខ, (ភាពនៃការនាំមកនូវសេចក្តីសុខ) បែបនេះឯង ជាអានិសង្សក្នុងធម៌ដែលបុគ្គលសន្សំហើយដោយប្រពៃ, បុគ្គលអ្នកប្រតិត្តតាមធម៌ រមែងមិនទៅកាន់ទុគ្គតិឡើយ" ។

ការប្រតិត្តិធម៌មួយបែបទៀត ចាត់ជាឧត្តមគតិ តួយ៉ាងដូចជាព្រះបរមគ្រូរបស់យើង ក្នុងពេលដែលកំពុងគ្រប់គ្រងពជសម្បត្តិនោះ ឈ្មោះថាទ្រង់ប្រតិត្តធម៌ដែរ, ប៉ុន្តែធម៌នោះ នៅច្រឡូកច្រឡំដោយសេចក្តីសៅហ្មង គឺថារកចរិយារបស់ធម៌ដែលព្រះអង្គប្រតិត្តនោះ ឲ្យមានខ្លឹមសារមានរសពិតប្រាកដពុំបាន រកជាប្រយោជន៍ដល់មនុស្សសត្វទាំងអស់ទៅក្នុងបរលោកនាយគ្មាន, មានប្រយោជន៍តែក្នុងបច្ចុប្បន្នម្យ៉ាង ហើយ

មិនតាំងបានត្រប់ត្នាផង; ព្រោះហេតុនេះហើយ បានជាទ្រង់ទំលាកលះ
ប្រាណ របស់ព្រះអង្គចេញទៅកសាងមហាកិនិស្ត្រមណ៍ តាំងពាក់
កណ្តាលអធ្រាត្រស្ងាត់មានសេះកណ្ឋកៈជាពាហនៈ មានធន្នាមាត្យជា
អ្នកកំជរជូនដំណើរព្រះអង្គចេញទៅ ដើម្បីបពូជ្ជាបួសស្វែងរកធម៌ពិត
ប្រាកដនោះ, លុះស្វែកដណ្តប់ត្រៃចីវរជាទង់ជ័យព្រះអរិយៈ នៅប្រប
ស្ទឹងអនោមានទីលើផ្ទៃរឿបាច់នោះ ហើយដល់ថ្ងៃទី ៨ ស្តេចយាងដោយ
ព្រះបាទាផ្ពោះសំដៅទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត រួចស្តេចទៅ
គង់ក្នុងញកបណ្ឌវបពិតធ្វើកត្តកិច្ច រួចបានសន្ទនាជាមួយនឹងព្រះបាទពិម្ពិ-
សារៈម្ចាស់ផែនដីក្រុងរាជគ្រឹះ ។ ព្រះចៅទ្រង់បានទូលអារាធនាថាៈ បើ
ព្រះអង្គបានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណវេលាណា សូមមេត្តា
និមន្តមកប្រៅសញ្ជាមមុនគេកុំខាន ។ ព្រះទសពលញ្ញាណទ្រង់ទទួល
ប្តេជ្ញានោះ ដោយតុណ្ហីភាព ហើយលុះតពីនោះមកទ្រង់បានទៅកាន់
សំណាក់អាឡារៈនឹងឧទកតាបសតាំងពីររូប, ព្រះអង្គបានរៀនយកនូវបរិ-
កម្មភាវនាក្នុងសមាបត្តិតាំង ៨ តែតាបសតាំងពីររូបនេះមានឈានទៅទាក់
ទើរនៅត្រឹមហានព្រហ្មលោករកទីបំផុតទុក្ខ ពោលគឺព្រះនិព្វាន ដែល
ពិសេសក្រៃលែងជាងហានព្រហ្មលោកគ្មាន ដោយយល់ឃើញថា គ្មាន
អ្វីហួសពីព្រហ្មលោកទៅទៀតទេ, ម្ចាំ៉ះហើយក៏ទញ់កើលតំនិតទើរត្រឹម
នោះឯង ។ ចំណែកព្រះបរមគ្រូរបស់យើង ទ្រង់មិនពេញព្រះទ័យ
ត្រឹមប៉ុណ្ណោះទ្បើយ ព្រោះទ្រង់យល់ឃើញថា ការប្រព្រឹត្តិរកធម៌ពិត
ប្រាកដនោះមិនមែនអស់ហើយត្រឹមហានព្រហ្មលោកនេះទេ, គង់នៅមាន

គុណជាតិប្ដរសអ្វីមួយដែលកើតពីការប្រព្រឹត្តិតាមធម៌ពិត ហើយឲ្យសុខ ជាកំរៃលែងកើតចាស់-ឈឺ-ស្លាប់រកទីបំផុតទុក្ខចប់ចុង-ដើមឃើញពុំខាន ឡើយ, លុះទ្រង់មិនទញ់ព្រះទ័យផ្ចុះហើយ ក៏លាតាបសទាំងពីររូប ឆ្ពោះទៅឯរុវេលប្រទេស ទំព្យាយាមប្រព្រឹត្តតាមរកធម៌ពិតអស់ ៦ វស្សា ត្រាតែបានត្រាស់ជាព្រះអរហំសម្មាសម្ពុទ្ធប្រាកដឡើងក្នុងលោក ដោយបុណ្យបារមីធម៌ដែលព្រះអង្គសាងសន្សំទុកដោយល្អ រមែងនាំសុខ មកប្រគល់ឲ្យចំពោះព្រះអង្គឥតមានល្អៀង ថែមទាំងព្រះអង្គផ្សាយធម៌ វិន័យទុកឲ្យយើងប្រតិបត្តិតាមធម៌ពិតនោះ ជាប្រយោជន៍ផ្ទូវលោកនឹងផ្ទូវ ធម៌រាល់គ្នាទៀត ។

ហេតុនេះ យើងជាពុទ្ធបរិស័ទទាំងឡាយគួរតែប្រព្រឹត្តធម៌ឲ្យប្រវិត ព្រោះការប្រព្រឹត្តិ ប្ដសន្សំធម៌ល្អមកជាក់ខ្ជួន ឈ្មោះថាបានដើរទៅតាម ផ្ទូវមជ្ឈិមាបដិបទា គឺអដ្ឋង្គិកមគ្គ (ផ្ទូវមានអង្គ ៨) ជាដំរាយដែលបណ្ឌិត ទាំងឡាយ មានព្រះសម្ពុទ្ធជាដើមធ្លាប់បានប្រព្រឹត្តតាម ជាផ្ទូវញ្ញាំងមារ នឹងសេនារបស់មារឲ្យវង្វេងក័ន្តកាំង គួរយើងជាពុទ្ធសាសនិកជន ដើរ ឲ្យសមតាមពុទ្ធបំណង ដូចមានពុទ្ធកាសិតក្នុងគម្ពីរធម្មបទដ្ឋកថា ត្រង់ ធម្មដ្ឋវគ្គថា:

ឯតញ្ហិ តុម្ហេ បដិបជ្ជថ មារសេនប្ឈមោហនំ
ឯតញ្ហិ តុម្ហេ បដិបន្នា ទុក្ខស្សន្តំ ករិស្សថ

ប្រែថា "អ្នកទាល់គ្នា ត្រូវដើរទៅតាមផ្ទូវមានអង្គ ៨ ន៉ុះចុះ ជាផ្ទូវ

ដែលញ៉ាំងមានទឹងសេនាបតីមានឈ្មោះ, ព្រោះថាបើអ្នកពាល់គ្នាដើរ
ទៅតាមផ្លូវហ្នឹងហើយ ទឹងធ្វើផ្លូវព្រះនិញានជាមិនខាន" ។

អធិប្បាយថា: បណ្តាផ្លូវទាំង៤យ៉ាង ដែលពួកសត្វដើរទៅមកដោយ
ដើរ ឬយានដំទិះសត្វក៏ថ្លៃ បើទុកជាផ្លូវនោះស្អាតស្រួល ក៏គង់មាន
ឧបសគ្គគ្រប់យ៉ាងមានចោរ, បន្ទា, ក្រួសជាដើមក៏មាន. ឯផ្លូវ
ដែលព្រះបរមសាស្តា ទ្រង់ត្រាស់ឲ្យពុទ្ធសាសនិកទាំង៤យ៉ាងជាបរិស័ទ
ធ្វើដំណើរទៅនោះ ហៅថា មជ្ឈិមាបដិបទា ផ្លូវប្រតិបត្តិយ៉ាង
កណ្តាលមិនតឹងពេកមិនធូរពេក ដូចខ្សែជួរព្រួតដែលគេតឹងឲ្យល្មម មាន
សូរស័ព្ទសម្លេងពីរោះ មុខគួរឲ្យចាប់ចិត្តដល់អ្នកស្តាប់; មិនមែនដូចផ្លូវ
ធម្មតានោះទេ, មជ្ឈិមាបដិបទា ដំណើរផ្លូវនៃសេចក្តីប្រតិបត្តិយ៉ាងមធ្យម
នោះ អាចញ៉ាំងមនុស្សសត្វ-ទេពតាក្នុងត្រៃភពឲ្យភ្ញៀវចេញចាស់ប្រាសចាក
អវិជ្ជាសេចក្តីងងឹតល្ងង់ខ្លៅបាន, ផ្លូវដែលប្រកបដោយអង្គ ៨ នោះគឺ:

១- សម្មាទិដ្ឋិ (សេចក្តីយល់ត្រូវ), ២- សម្មាសង្កប្បៈ (ការ
តម្រិះត្រូវ), ៣- សម្មាវាចា (ពាក្យសំដីត្រឹមត្រូវ), ៤- សម្មាកម្មន្តៈ
(ការងារត្រឹមត្រូវ), ៥- សម្មាអាជីវៈ (ការចិញ្ចឹមជីពជន្មត្រឹមត្រូវ),
៦- សម្មាវាយាមៈ (ព្យាយាមត្រឹមត្រូវ), ៧- សម្មាសតិ (ការរលឹក
ឃើញត្រូវ), ៨- សម្មាសមាធិ (ការតាំងចិត្តឆ្ងាប់ខ្ជួនត្រូវ) ។

អង្គមគ្គទាំង ៨ នេះ មិនបានអធិប្បាយឲ្យគ្រប់ទាំងអស់ទេ សូម
អធិប្បាយតែអង្គទី ១, ទី ៣, ទី៨ ។

អង្គទី ១– សម្មាទិដ្ឋិ (សេចក្តីយល់ត្រូវ) ចែកចេញជាពីរប្រការ, ប្រការទី ១ គឺយល់ត្រូវក្នុងផ្លូវលោក, ប្រការទី ២ គឺយល់ត្រូវក្នុងផ្លូវធម៌ ។ ឯការយល់ត្រូវក្នុងផ្លូវលោកនោះ គឺការយល់ថាកើតមកជាពលរដ្ឋក្នុងប្រទេសនីមួយ ។ ត្រូវគោរពកោតខ្លាចច្បាប់សម្រាប់ផែនដី, យល់ថាគួរតែស្រឡាញ់គ្នាព្រួតកម្លាំងគ្នាកសាងប្រទេសជាតិឲ្យថ្ពំថ្ពើងរុងរឿង, យល់ថាគួរតែដឹកចម្លងជាតិជូចគ្នាឲ្យចេះដឹង នឹងយល់ឃើញថាត្រូវគោរពសាសនា, មហាក្សត្រ ជាប្រមុខរបស់ជាតិឲ្យពេញទី ។ ការយល់ឃើញយ៉ាងនេះ ហៅថាយល់ឃើញត្រូវក្នុងផ្លូវលោក ។ គួរប្រជាជាតិទាំងឡាយ សន្សំការយល់ឃើញបែបនេះ ឲ្យកើតមានក្នុងសន្ធានឲ្យបានគ្រប់គ្នាឡើង ។

ឯការយល់ត្រូវក្នុងផ្លូវធម៌នោះ គឺការយល់ថាសត្វដែលកើតមកក្នុងសង្សារវដ្តនេះតែងស្លាប់ទៅវិញ កាលដែលស្លាប់ទៅមានតែបុណ្យបាបទេដែលទៅជាប់ជាមួយនឹងខ្លួន ដូច្នេះ អាត្មាអញមិនត្រូវការប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្តឡើយ ។

អង្គទី ៣– សម្មាវាចា (ពាក្យសំដីត្រឹមត្រូវ) គឺពាក្យសំដីដែលនិយាយត្រឹមត្រូវតាមច្បាប់, មិននិយាយផ្តសផ្តាសដែលរកគោលរកចារឹកគ្មាននោះទេ; មួយវិញទៀត សំដីដែលត្រូវនិយាយទៅរកមនុស្សជាតិជូចគ្នា ត្រូវតែពោលជាសុភាសិតាវាចា (ពាក្យជាសុភាសិត) មិនត្រូវពោលជាទុព្ភាសិតាវាចា (ពាក្យជាទុព្ភាសិត) ឡើយ, ព្រោះទុព្ភាសិតាវាចាមិនហុចផលប្រយោជន៍ដល់អ្នកស្តាប់ប្ជឲ្យបានចំរើនឲ្យជាតិ

ថ្ងៃថ្នូរទេ ។ សុភាសិតាវាចា ទើបបានចំរើនផលដល់អ្នកស្តាប់ បានរស់រានមានជីវិតតទៅអនាគត សមដូចពុទ្ធកាសិតថា សច្ចំ រៃ អមតាវាចា "ពាក្យពិតជាពាក្យមិនចេះស្ងាប់" ។

ហេតុនេះ យើងកើតមកទាន់ពុទ្ធសាសនាគួរពេញចិត្តនាំគ្នានិយាយតែពាក្យណាដែលមានប្រយោជន៍ក្នុងផ្លូវធម្ម នឹងផ្លូវលោកដើម្បីជាប្រយោជន៍ជនជាតិជាមួយគ្នា គឺត្រូវនិយាយឲ្យចំរើនដល់សីលធម្មិនឹងវឌ្ឍនធម្មិក្នុងព្រះនគរតទៅ ។

អង្គទី ៨- សម្មាសមាធិ ការតាំងចិត្តឆ្ជាប់ឆ្ជួនត្រូវនោះ គឺយើងជាអ្នករាប់អានព្រះពុទ្ធសាសនាទាំងគ្រហស្ថទាំងបព្វជិត គួរតែតាំងចិត្តឲ្យមាំគោរពធម្មិស្រឡាញ់ធម្មិឧបណ្ណុះធម្មិ ជាពាក្យប្រៀនប្រដៅទាំងផ្លូវលោកផ្លូវធម្មិឲ្យពិតប្រាកដ ពុំគួរធ្វើចិត្តឲ្យយ្ជៀងយ្ជាតចាកការតាំងចិត្តត្រូវនោះឡើយ ព្រោះការតាំងចិត្តត្រូវជាគុណនាំមកនូវប្រយោជន៍សេចក្តីសុខ-ចំរើនក្នុងផ្លូវលោកនឹងផ្លូវធម្មិដោយពិត ។

អយំ ធម្មទេសនា សផ្ទេបេន សម្មតា

ធម្មិទេសនា ដែលសំដែងមកនេះ សូមសន្មតថាចប់ដោយបំប្រួញតែប៉ុណ្ណោះ ឯវំ ។

បញ្ចាសជាតក

ភាគទី ៣

បណ្ឌិតមហា ឈឹម - សុីម សាស្ត្រាចារ្យ

នៅសាលាថាលីដាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅដាភោទបព្វជិតឆ្នាំ ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

សុវណ្ណកុមារជាតក ទី ១៥

លោកអាចារ្យ ជង - សមិទ្ធ ក្រុមដំនុំព្រៃព្រៃបឹងក

ប្រែពីថាលី

(តមក)

ព្រះបាទសុវណ្ណកុមារ ទ្រង់ទតឃើញពួកពលដូច្នោះហើយ ក៏ទ្រង់ព្រះចិន្តាថា "មនុស្សទន់ខ្សោតាំងឆ្ងាយ ដែលបានសម្បត្តិធំសេចក្តីសុខធំឫទ្ធិដ៏ច្រើនយ៉ាងនេះ ប្រាកដជាបានដោយតេជៈបុណ្យ មិនមែនបានដោយតេជៈអ្វីដទៃឡើយ, បើដូច្នោះមានតែអាត្មាអញ ឲ្យពួកពលធ្វើបុណ្យសិនទើបគួរ, ព្រោះបុណ្យរមែងរក្សាបុគ្គលអ្នកធ្វើឲ្យផុតពីសេចក្តីអន្តរាយបាន" លុះទ្រង់ព្រះចិន្តាដូច្នោះហើយ ទើបទ្រង់ឲ្យធ្វើចង្ការទន្លេបណ្តាបតបរដំបែថ្មថ្លា ព្រមទាំងគ្រឿងសេនាសនៈឲ្យទៅមន្តព្រះកុសង្ឃមកប្រគេនរៀបរយទានគោរហើយ ឲ្យសាងភត្តកេតិយ, ព្រះបរមគ្រូទ្រង់ព្រះចិន្តាថា "បើដំណើរបស់អាត្មាបានសម្រេចដូចប្រាថ្នា ក៏ជាការស្រួលល្អ, បើពុំបានសម្រេចទេ ក៏អាត្មាអញនឹងបានសម្បត្តិ ៣ ប្រការក្នុង

ភពតាំងពួងដែរ" ហើយទ្រង់ក៏យកព្រះពុទ្ធព្រះធម៌ព្រះសង្ឆជាទីពឹង
ទីរលឹក សមាទានសីលស្តាប់ធម៌ទេសនា រៀបគ្រឿងភ្ជ្រាបូជា ឲ្យទាន
ជាយទឹកនំចំណីសំពត់អាវស្បែនឹងរថដំរីគជសាជាដើម ហើយទ្រង់ជ្ជូច
ទឹកស្នោទកអធិដ្ឋានថា ពួកសត្វតាំងឡាយ មានញាតិសន្តានជាដើម
ដរាបដល់សត្វក្នុងអវីចីនរក សូមឲ្យរួចផុតចាកទុក្ខទោសតាំងពួង, ឲ្យជាន
សុខត្រប់ប្រការក្នុងភពតាំង ៣, តាំងពួកពលសេនីយ៍សេនាបតីនាម៉ឹន
សព្វមុខមន្ត្រីតាំងអស់ ក៏សូមឲ្យជានសេចក្តីសុខរួចចាកទុក្ខតាំងពួងជា
ដរាបតរៀងទៅ ដោយតេជះនៃសេចក្តីអធិដ្ឋានទោះ ក៏ពួកសត្វក្នុងអជាយ
តាំងឡាយ ជានរួចចាកទុក្ខហើយសោយសម្បត្តិជាសុខក្នុងពិភពតាវត្តឹង្ស
មានពួកទេពអប្សរជាច្រើនកោដិចោមរោមជាបរិវារ; ញាតិឯណាដែល
ជានកើតក្នុងទេវលោកស្រាប់ហើយ ក៏រិតតែជានសោយសេចក្តីសុខជា
ភិយ្យោភាព ក្រៃលែងជាងដើមតទៅ ។

ព្រះជាទសុវណ្ណកុមារ ទ្រង់ស្តេចទៅដល់ត្រើយសមុទ្ទ ជាមួយនឹង
ពួកពលសកលយោធា លុះវេលាពាក់កណ្តាលរាត្រី ទើបព្រះនរបតី
ទ្រង់ព្រះចិន្តាថា ស្តេចភដេសុររាជ មានអានុភាពអំណាចយ៉ាងណាទៅ
អេះ? ។ លុះទ្រង់កំពុងមានព្រះតម្រិះដូច្នេះ ក៏ពិភពសម្តេចព្រះតន្ទ្រាធិរាជ
បញ្ចេញឧណ្ហាការក្តៅខុសប្រកតី ដោយតេជានុភាព នៃព្រះជាទសុ-
វណ្ណកុមារពោធិសត្វនោះ ។ លុះសក្កទេវរាជទ្រង់អាវដ្ឋនាការពិចារណា
ជ្រាបហេតុនោះសព្វត្រប់ហើយ ពុំយូរឡើយក៏ទ្រង់ចុះមកកាន់សំណាក់
ព្រះសុវណ្ណកុមារ ព្រះហត្ថាកាន់ធ្នូព្រះតន្ទ្រ ព្រមតាំងកូនសរ ៥ ផង

មកហៅព្រះសុវណ្ណកុមារថា ហៃមហាបុរស, ចូរអ្នកក្រោកឡើង, យើងនឹងឲ្យអាវុធមុះមុតបំឡែក ដែលអាចញ្ញាំញីនូវសត្រូវបច្ចាមិត្រតាំងពួងបាន; សរតាំង ៥ នេះ សរ ១ ចាញ់បានចម្បាយ ១ យោជន៍អាចកាត់ក្បាលមនុស្សទេវតាតាំងពួងបាន, សរ ១ ទៀត អាចនិម្មិតជាយានជំនិះបាន, សរ ១ ទៀត អាចនិម្មិតជាវិមានផុះលើអាកាស, សរ ១ ទៀត កើតជាភ្នក់ភ្លើង, សរ ១ ទៀត អាចមុតមនុស្សសត្វដល់ទៅគ្រប់ ៧ ថ្ងៃ ទើបស្ងាប់ ។

ព្រោះហេតុនោះបានជា ព្រះដ៏មានព្រះកាគទ្រង់ត្រាស់ថា សរ ១ អាចកាត់ក្បាលពួកជនបាន, សរ ១ និម្មិតជាយានជំនិះ, សរ ១ និម្មិតជាវិមាន សរ ១ កើតជាភ្នក់ភ្លើង, សរ ១ អាចមុតអស់ ៧ ថ្ងៃ ទើបប្រល័យជីវិតឲ្យស្ងាប់ ។

ព្រះឥន្ទ្រាធិរាជត្រាស់ថា យើងឲ្យតន្ទុធនុ ព្រមតាំងកូនសរ ៥ ដល់ព្រះអង្គ ចូរព្រះអង្គទទួលយកចុះ ។ ព្រះពោធិសត្វក៏ទទួលយកដោយសេចក្តីត្រេកអរសាទរចំពោះអាវុធនោះក្រៃពេក ។ លុះសក្តទេវរាជប្រទានអាវុធនោះស្រេចហើយ ទើបស្តេចទ្រង់ត្រាស់ជាគាថាថា

ជយេហិ ត្វំ មហារាជ សព្វដ្ឋានេសុ បាកដោ
បតុទ្ទីបេសុ មនុស្សា តុយ្ហំ អាណា ភវិន្តុ តេ

បពិត្រមហារាជ, សូមព្រះអង្គទ្រង់មានជ័យជំនះឈ្នះអស់សត្រូវ, សូមឲ្យព្រះរាជតេជះរបស់ព្រះអង្គប្រាកដទៅសព្វទិសទី លើបណ្តាជនជាតិជាមនុស្សក្នុងទ្វីបតាំងបួន, សូមឲ្យព្រះរាជអាជ្ញារបស់ព្រះអង្គមានសព្វៗកាល ។

សក្កទេវរាជ ទ្រង់ប្រទានពរស័ព្ទសាធុការហើយ ក៏ត្រឡប់ទៅ
កាន់ឋានរបស់ព្រះអង្គវិញ ។ ត្រានោះ ព្រះមហាសត្វទ្រង់ត្រួតពួក
ពលដែលប្រជុំគ្នាជាពួកជាកង យើញមានរបៀបរៀបរយស្លួលល្អ
ហើយទើបទ្រង់នាំចុះកាន់សំពៅនៅវេលាប្រកបដោយនក្ខត្តឫក្សល្អ បើក
លឿនស្វៅទៅក្នុងសមុទ្ទជលសា ។ ត្រានោះ ពួកសមុទ្ទទេវតា ក៏នាំ
គ្នាហោះធ្វេធ្វានាំផ្ទូវព្រះពោធិសត្ត ខ្ទះចាត់ស្បៀងលៀងពួកពល
សកលយោធា, ខ្ទះចូលអង្គុយត្រៀបត្រា តាល់ព្រះពោធិសត្វដោយ
សេចក្តីគោរព ។ ពួកពលទាំងឡាយប្រកបដោយសេចក្តីសុខសប្បាយ
គ្មានអន្តរាយអ្វីឡើយ ។ កាលព្រះបរមចមភពទ្រង់ជានដល់ត្រើយ
ខាងនាយហើយ ក៏ជោះកងទ័ពសំចតនៅក្នុងទ៉ីនោះទ្រង់បញ្ជូនរាជទូត
ឲ្យទៅទូលព្រះជាទភដេសុររាជ ។ រាជទូតនោះទៅដល់ហើយ ក៏
ក្រាបទូលព្រះជាទភដេសុររាជថា បពិត្រព្រះរាជសម្ភារ, ព្រះជាទ
សុវណ្ណកុមារម្ចាស់យើង ជាព្រះរាជបុត្ររបស់ព្រះរាជាធិរាជ ទ្រង់ជា
មហាវីរបុរស មានអំណាចអាចញ៉ាំញ៉ីពួកស្តេចជាសត្រូវបច្ចាមិត្រជាន
ឥតមានញាញ៉ីតត្រឹមតែសរ ១ របស់ព្រះអង្គ ក៏អាចកំទេចនគរនឹងវិទ្រត
ដែននេះជានដែរ, ឥឡូវនេះទ្រង់ស្តេចមកដល់ ជាមួយនឹងពួកពល
សកលយោធា, ប្រើដូច្នោះ សូមព្រះអង្គស្តេចទៅម្នីម្នា ទៅអង្វរការទៀប
ព្រះជាទា សូមអាយុជីវិត, ឬមួយបើព្រះអង្គអាងមហិទ្ធិឫទ្ធិ ក៏សូម
ព្រះអង្គទ្រង់ឆិតរៀបចំត្រឿងចម្បាំង ចេញទៅតតាំងប្បាំងគ្នាចុះ ។
ចំណែកខាងព្រះបរមពោធិសត្ត ក៏ថ្វៃងសរ ១ ប្រើទៅជាអាវុធទូតទៀត

បង្គាប់សរនោះថា ម្នាលសរដ៏ចំរើន, ចូរឯងទៅបិតនៅក្សែរគុម្ពត្រចៀក
ស្តេចកដេសុរាជហើយប្រាប់ថា នែស្តេចកំណាច, បើប្រស្តែងមិន
រាសរៃទៅថ្វាយបង្គំព្រះបាទាព្រះម្ចាស់យើងទេ, យើងនឹងកាត់ក្បាល
ប្រស្តែងឯងយកទៅថ្វាយព្រះម្ចាស់យើងមិនខាន ។ សរនោះក៏ធ្វើតាម
ព្រះរាជបញ្ជា ។ ព្រះបាទកដេសុរាជនោះ លុះព្ធដូច្នោះហើយ ក៏ក្រេវ
ក្រោធពិរោធមហិមា ដូចជានាគរាជដែលគេប្រហារកន្ទុយដោយដំបងដែក
មានសេចក្តីកិតក៏យក្រែពេក, ប៉ុន្តែខំធ្វើកិរិយាកំឡាក្រទីក្រទាមានព្រះ
ដំរាស់ត្រាស់ហៅពួកអាមាត្យដែលក្ខាហានសំខាន់ៗ មកប្រជុំប្រឹក្សាណែន
ណាន់ពេញក្នុងទីព្រះលានហើយត្រាស់ថា អាដែងសុរណ្ណកុមារ ជាអ្នក
ប៉ុនប្រសប់ដោយសិល្បឥន្ទធ្នូ ជាមនុស្ស ១ មានអានុភាពប្រើន, ប៉ុន្តែ
ថ្វីបើដល់ម្ទ៉ោះ ក៏យើងនៅតែមិនចាញ់វា ។ ពួកអ្នកនគរទាំងអស់ ក៏
ជ្ឋែលជ្រើមភ្ញាក់ផ្អើលតែរាល់ៗ ត្នា ។ ក្ងនសរដែលជារាជទូត ក៏ត្រឡប់
មកទូលព្រះពោធិសត្វតាមពាក្យដែលខ្ជួននិយាយ ។ ទើបព្រះពោ-
ធិសត្ត ទ្រង់ថ្ងៃងសរ ១ ទ្រៀត ដែលអាចកាត់សក់ជនានុជន ។ សរ
នោះក៏ស្ទុះទៅកាត់សក់អ្នកនគរ ធ្វើឲ្យត្រងាលត្រងិលវិលអាក្រក់ទាំង
អស់ត្នា ហើយម្ទីម្ទាវិលមកចូលក្នុងបំពង់របស់ខ្ជួនវិញ ។ ពួកក្នុងព្រះ
បរមរាជវាំងក្តីអ្នកនគរទាំងអស់ក្តី ក៏ជាទុក្ខម្ទេញ កើតមានសេចក្តីអ្រៀន
ខ្ចាស ដើរក៏មិនស្រណុក អង្គុយក៏មិនសុខ មើលតែមុខត្នាព្ជួយចិត្ត ។
លំដាប់នោះ មហាបុរស ទ្រង់ថ្ងៃងសរ ១ ទៅទ្រៀត ។ សរនោះក៏កើត
ជាយាន មានសេះ មានរាជរថសុទ្ធសឹងតែថ្ម៉ៗ មានភ្ងងរបាំតូរ្យតន្ត្រី

មានស្រីអប្សរអង្គុយក្នុងរាជរថនោះ, ហ៊ាបហោះទៅប្រទក្សិណខាងក្រៅ
នគរបីជុំ ។ ពួកអ្នកនគរទាំងតូចទាំងធំ ព្រមទាំងព្រះរាជាមានសេចក្តី
ភ៉ាតភ័យតក្តមា អង្គុយឧបហត្ថាសម្ងំស្ងៀម ។ លំដាប់នោះ ព្រះ
មហាបុរស ទ្រង់ថ្វៃងសរ ១ ទៀត ដែលអាចបង្ក្រីតជាក្រើង ត្រាន់តែ
យឹតផ្គងឡើងក៏ព្ទស្សរសន្ធឹកជូចរន្ទះអស្សនី ។ ក្ងនសរនោះក៏ស្ទុះច្រៀវ
ច្រៃបញ្ចេញរស្មីកើតជាអណ្ណាតក្រើង ឆេះឡើងសន្ធោសន្ធៅ សំដៅទៅ
ក្រឡឹងខាងក្រៅនគរ ៣ ជុំ ហើយចូលទៅក្នុងបំពង់ព្ទញ្ចាបស់ខ្លួនវិញ ។
ឯពួកអ្នកស្រុកអ្នកនគរទាំងអស់គ្នា លុះឃើញហេតុអស្ចារ្យមិនធ្លាប់មាន
ជូច្នោះ ក៏ភ៉ាតភ័យមហ៊ាមា ស្ទុះស្ទាឧបក្ងនឧបប្រពន្ធទន់ជង្គង់ដេកជួល
យំខ្សឹកខ្សួលតែរៀងខ្លួន ។ ឯព្រះបាទសីហឡរាជទ្រង់មានព្រះជាតិជា
អ្នកបឹងរឹងរូស ធ្លាប់មានព្រះរាជហប្ចទ័យក្ងៀវក្ងា ទោះបីភ៉ាតភ័យយ៉ាង
ណា ក៏ទំថ្វៃងព្រះរាជឧង្ការថា នេះជាអានុភាពរបស់សុវណ្ណកុមារនោះ,
ប៉ុន្តែទុកជាដល់ម្លោ៉ះ ក៏គង់តែអញមិនទាន់ចាញ់ ។

ឯព្រះមហាបុរស ទ្រង់មិនប្រទុស្ថសោះ ព្រោះព្រះអង្គមានព្រះរាជ-
ហ្ប្ចទ័យអាណិតអាសូរករុណា ទ្រង់ យីញទំនងគ្ងរនឹងចាប់ព្រះរាជានោះ
បាន ហើយជ្រាបដោយព្រះប្រាជ្ញាញាណថាមានសេនាបតីចម្បង ៦
នាក់ត្រូវស្ងាប់ក្នុងរាង ៧ ថ្ងៃទើបក្សត្រថ្ងៃទ្រង់បញ្ជូនរាជទូតទៅទៀត ។
រាជទូតនោះ ទៅក្រាបបង្គំទូលព្រះបាទសីហឡរាជថា "រៀលារសៀល
ថ្ងៃនេះ ព្រះបាទសុវណ្ណកុមារនឹងថ្ងៃងសរឲ្យត្រូវចំនគរនេះពុំខាន ។
ព្រះបាទសីហឡរាជ ទ្រង់បានត្រាស់បង្គាប់ឲ្យពួកសេវកាមាត្យ រៀបចំ

ពាក់គ្រឿងគ្រែពាំងអស់គ្នា ។ ក្នុងព្រះនគរកើតកោលាហលដ្រួល ច្របល់ជាមួយគ្នា ឥតនរណានៅស្ងៀមបាន ។

លំដាប់ពីនោះមក ព្រះបាទសុរិណ្ណកុមារ ទ្រង់បញ្ជូនទូត ១ ទៅ ទៀត ។ ទូតនោះទៅក្រាបបង្គំទូលព្រះកាសីហរ៉ាជថា បពិត្រព្រះ រាជសម្ភារ, បើទ្រង់នៅស្រឡាញ់សរីរាង្គកាយរបស់ព្រះអង្គទៅទៀយ ទេ សូមទ្រង់កុំច្បាំងជាមួយនឹងយើងទៀយ; បើទ្រង់ពុំដឹងសោត, សូមទ្រង់ចាំទុកចុះ, សារមុខជានឹងមុតអគ្គសេនាបតីពាំងពីរនាក់ពុំខាន; បើទុកជាបងគ្រឿងគ្រែយ៉ាងណា, ក៏គង់តែស្លាប់ក្នុងរវាង ៧ ថ្ងៃជាប្រាកដ ។ គ្រានោះ ព្រះកាសីហរ៉ាជ ទ្រង់ចង់ជ្រាបហេតុនោះ ទើប ទ្រង់ឲ្យបងគ្រឿងគ្រែ រុំស្បែក រុំសំពត់ ព័ទ្ធសរីរសេនាបតីពាំង ២ នាក់ ហើយទ្រង់ឲ្យអ្នកយកដង្កូវចិញ្ចឹងដោយក្តារ ក្រាស់ៗ ប្រាំពីរស្រទាប់ ។ ព្រះពោធិសត្វ ទ្រង់ថ្លែងសារ ១ ទៀតដែលអាចពុះប្លុងយកបាន, បង្គាប់សារនោះថា នែបរាជ័ចំរើន, អ្នកចូរទៅចាក់ប្លុងយសេនាបតីពាំង ២ នាក់ ដែលបងគ្រឿងគ្រែអង្គុយក្នុងព្រះពាជមន្ទីរ តាមសេចក្តីអាច របស់អ្នកចុះ ។ សារនោះក៏ស្ទុះទៅក្នុងព្រះពាជពិភព ៣ ដុំ បន្ទាប់ឆ្លង ខ្លួរស្ទុះសំដួសទ្រឹកដូចជាខ្នុះអស្សនី ។ អ្នកខនតីក៏តក់ត្រយ ខ្លុះបាន ស្លឹ ខ្លុះបានបង្អែរ មកត្រូបក្បាល រត់ទៅពួនសម្ងំនៅជាយទីតែនគោះ ។ សារនោះ កំមុតទម្លាយជ្រាយក្តារប្រហារដល់ដួងប្លុងយនៃសេនាបតីពាំង ២ នាក់នោះ ដួលដេកស្លាប់ក្នុងព្រះពាជមន្ទីរ ។ ព្រះពាជាសីហរ៉ាជ: បាន ឃើញហេតុអស្ចារ្យដូច្នោះ ក៏មានព្រះពាជប្លុងយកតក់ស្លុតរន្ធត់

ខ្ញុំ ទើបទ្រង់ត្រាស់ចំពោះអាមាត្យទាំង ឮថា បើយើងមិនចេញ
ទៅសូមជីវិតទេ, មុខជាបណ្តាក្រុងនឹងយើងទាំងអស់គ្នា ស្ងាប់វិនាស
អសារឥតការមិនខាន: បើដូច្នោះ គួរតែយើងប្រគល់នគរព្រមទាំងដែន
ឲ្យគេ សូមរស់តែជីវិតប៉ុណ្ណោះក្រែងជួនជាបាន ។ អាមាត្យទាំងប៉ុន្មាន
ក៏ព្រមព្រៀងគ្នាក្រាបបង្គំទូលតបព្រះរាជទ្រង់ថា "ទុបាយដែលព្រះអង្គ
ទ្រង់ត្រាស់មកនេះ គួរមែនហើយ" ។ ទើបព្រះរាជាទ្រង់យកមាស
ប្រាក់តែវកង៏ពៃឥន្ទ្រសូរ្យកាណរតន៍ផង ជារ៉ែនប្រការក្សត្រទ្រង់ស្តេច
ចេញទៅជាមួយនឹងអាមាត្យទាំង ឮ ចូលទៅគាល់ព្រះបាទសុវណ្ណ-
កុមារ លើកកស្តុការបណ្តាការទាំងអស់ថ្វាយ, ឧនកាយក្រាបលើផែនដី
ព្រះបន្ទូលត្រាស់ថា

ឧ ឆោ ទិដ្ឋោ តិតោ បុព្វេ ឧ សុតោបិ ឧ កស្សបិ
ឯវំ តេជោ មហាបុញ្ញោ តាទិសោ ច មហីតលេ ។
ឧគរំ រដ្ឋញ្ច[1] សកលំ បាណាញ្ច តុម្ហាកញ្ចេវ
ទទាមិ តេ មហារាជ យាចាមិ ជីវិតំ តុវំ ។

បពិត្រព្រះអង្គជាឥស្សរាធិបតី, ព្រះបរមសិរីតេជានុភាព នឹង
បុញ្ញាភិនិហារខ្ញុំងឹអស្ចារ្យដល់ម្ល៉េះ, លើផែនដីនេះខ្ញុំព្រះអង្គ
ពុំដែលឃើញ ពុំដែលឮទេ តាំងតែពីកាលណាមុនៗដរាប
មកដល់ថ្ងៃនេះ ។ ខ្ញុំព្រះអង្គសូមថ្វាយនគរនឹងដែនព្រែដែន

---

[1] ឧគរំ រដ្ឋញ្ចាតិបិ បាឡិ ។

ព្រមទាំងបណ្ណាប្រជាជនសត្ពនិករ ចំពោះព្រះអង្គទាំងអស់
សូមរស់តែជីវិត ។

ព្រះបរមពោធិសត្ត ទ្រង់ត្រាស់ប្រកែកថា បពិត្រព្រះម្ចាស់ផែនដី, ទីក្រុងព្រះនគររដ្ឋរាជបុរី សូមឲ្យគង់នៅជារបស់ព្រះអង្គជដែលចុះ, សូមទ្រង់កុំកំយ, សូមទ្រង់មានសេចក្តីសុខសម្រាន្ពកំសាន្ពព្រះរាជហ្ចូទ័យឲ្យស្រួលចុះ ខ្ញុំមិនមានកំហឹងខឹងក្រោធនឹងព្រះអង្គទេ, ខ្ញុំមិនមកដណ្ណើមយករាជសម្បត្ពិ នឹងដែនរបស់ព្រះអង្គទេ, ខ្ញុំប្រាថ្នានឹងចាប់យកត្រឹមតែដួងហ្ចូទ័យរបស់ព្រះអង្គប៉ុណ្ណោះទេតើ ។

ព្រះបាទកដេសុរ: ព្រះចៅដែនសីហឡ: ទ្រង់ព្រះសវនាការព្ធ ព្រះរាជឡង្ការនោះហើយទ្រង់ញាប់ញ័រអស់ព្រះអង្គាវយវ: តក់ស្ទុតកិតកំយ មានព្រះសេទោហូរចេញសស្រាក់ ។ ព្រះពោធិសត្ធទ្រង់ទស្សនាការយើញព្រះរាជាសីហឡ: កំពុងមានសេចក្តីញ័រញាក់ ក៏ទ្រង់មានព្រះរាជ-ហ្ចូទ័យអាសូរករុណា ទើបមានព្រះរាជឡង្ការថា បពិត្រមហារាជ, សូមព្រះអង្គកុំខ្ចាច, កុំញាប់ញ័រ, សូមដំកល់ព្រះអង្គឲ្យសុខសំរាន្ពកំសាន្ពព្រះរាជហ្ចូទ័យឲ្យស្រួលចុះ, បពិត្រព្រះចមជន, ខ្ញុំត្រូវការតែដួងហ្ចូទ័យរបស់ព្រះអង្គ មិនមែនត្រូវការរបស់អ្វីដទៃសូម្បីបន្ពិចបន្ពួចទេ; បពិត្រព្រះបាទកដេសុរ:, សូមព្រះអង្គទ្រង់ជ្រាបថា ការចាប់យកដួងហ្ចូទ័យនោះ មិនមែនជាការពុះវះយកជុំសាច់បេះដូងរបស់ព្រះអង្គទេ, គឺសូមឲ្យតែព្រះអង្គមានសេចក្តីស្រឡាញ់ចំពោះខ្ញុំ, សូមឲ្យខ្ញុំមានសេចក្តីមេត្រីរាប់អានចំពោះព្រះអង្គបានសព្ធកាលទៅផងប៉ុណ្ណោះ; បពិត្រមហារាជ,

ធម្មតាការគាន់យកនូវដួងហ្លួងប្លុកទ័យនៃជនដទៃ ជាតិដូដែលអ្នកផងធ្លើបាន ដោយកម្រណាស់; បានជាថាដូច្នោះ ព្រោះបុគ្គលដែលអនុគ្រោះដល់ជនដទៃ គោរងតំណត់ចាប់ដួងហ្លួងប្លុកទ័យឲ្យបានជាមុនទើបនឹងអាចឲ្យជនដទៃនោះ ប្រព្រឹត្តនូវអំពើដែលជាប្រយោជន៍បាន ព្រមទាំងហាមប្រាមជនដទៃនោះឲ្យវៀរចាកអំពើអាក្រក់ក៏បានដែរ; បុគ្គលអ្នកអនុគ្រោះនោះ ឈ្មោះថាមហាមិត្រ, ទុកជាតែវិជ្ជាមណី ក៏មិនស្មើនឹងមហាមិត្រនោះដែរ, ព្រោះហេតុនោះ បានជាអ្នកប្រាជ្ញទាំងឡាយសំដែងថា

បិត្តាមណិ សព្វមណិវិសេដ្ឋោ មណិបិត្តា ឆាម ឆាបិ សមេតិ
បិត្តាមណិ បិត្តិតមេវ ទត្វា ឆោ បិត្តិតាយ ហិតមេវ មិត្តោ។

តែវិជ្ជាមណី ប្រសើរវិសេសជាងតែគាំនអស់, ប៉ុន្តែតែវិជ្ជាមណី ក៏មិនស្មើនឹងមហាមិត្រ, ព្រោះតែវិជ្ជាមណីឲ្យសម្រេចប្រយោជន៍ តាមចិត្តគិតត្រឹមតែក្នុងបច្ចុប្បន្នជាតិនេះប៉ុណ្ណោះ នឹងឲ្យសម្រេចរហូតដល់អនាគតជាតិផងពុំបានឡើយ; ឯមហាមិត្រ ទើបឲ្យសម្រេចប្រយោជន៍តាមចិត្តគិតបានសព្វកាល; បុគ្គលឯណា តាំងនៅក្នុងមិត្តធម៌ គឺស្តាប់បង្គាប់យកដម្រាប់តាមពាក្យកល្យាណមិត្រ, បុគ្គលនោះរមែងជាឥស្សរៈក្នុងលោកនេះផង រមែងបាននូវមហាសម្បត្តិក្នុងលោកខាងមុខផង ។ មួយយ៉ាងទៀត បុគ្គលដែលបិតនៅក្នុងមិត្តធម៌រមែងបានទទួលសេចក្តីសរសើរក្នុងបច្ចុប្បន្នភពនេះផង បាននូវសុគតិក្នុងសម្បរាយភពផង ។ (អនុត)

ផ្នែកអក្សរសាស្ត្រ

ឧទានសុកាសិត

ព្រះមហាឧត្តមវិជ្ជា មៅ-ទាន់

រៀបរៀង

"អ្នកប្រាជ្ញយល់ការណ៍ រមែងតាំងខ្លួនបានដោយទ្រព្យជា
ដើមទុនសូម្បីតិចតួច ដូចគេបង្ការត់ភ្លើងដែលតូច ដូច្នោះ" ។

សេចក្តីគិតតាំងខ្លួន គឺធ្វើខ្លួនឲ្យមានឡាក់ហានល្មមជាទីពឹងពំនាក់
របស់ខ្លួនឯង ប្ដូរបស់អ្នកដទៃបានផងនោះ ជាសេចក្តីគិតដ៏ល្អ ហើយ
ដែលតែងមានដូចគ្នាគ្រប់ ៗ រូប រៀរលែងតែមនុស្សខ្លះ ដែលឆ្លាប់តែ
ពឹងអ្នកដទៃរហូត មិនមានគំនិតគិតទីពឹងខ្លួនឯងនោះ ហើយដែលទាង
ក្រោយមក ច្រើនតែមានគតិតែម្យ៉ាងដូចគ្នាដោយច្រើន គឺជាមនុស្ស
អនាថា មិនមានទីពឹង ចួនកាលក្លាយទៅជាមនុស្សពាលទូចកាចប្រព្រឹត្ត
អាក្រក់ ផ្តេសផ្តាសក៏សឹងមាន ។

ក៏ឯអង្គដែលជាហេតុឲ្យតាំងខ្លួនបាននោះ ពោលដោយខ្លីមាន ៤ គឺ
ភាពជាអ្នកឈ្លាសរាងវៃ មានសេចក្តីអង់អាចចេះប្រកបការងារឲ្យសមគួរ
ដល់ទកាសនឹងកាលសម័យ ១ ទ្រព្យដើមទុន ១ ។ បណ្តាហេតុ ៤ ប្រការនេះ
ប្រការទាងដើម ចាត់ជាអង្គគុណដ៏សំខាន់ក្រៃលែង ព្រោះមានតួយ៉ាង
ជាក់ស្តែងថា មនុស្សអ្នកឈ្លាសរាងវៃល្អសូម្បីមានទ្រព្យជាដើមទុនត្រឹម

កាកណិកមួយ ដែលមានតម្លៃតិចជាងគេបំផុត ប្រហែលនឹងសេន១ប៊ុណ្ណោះ
ក៏អាចកសាងខ្លួនហូតទៅជាសេដ្ឋីបានមានរឿងតំណាលដូចតទៅនេះ ៖

ក្នុងក្រុងពារាណសី រាជធានីនៃដែនកាសី មានសេដ្ឋីម្នាក់ ឈ្មោះ
ចូឡកសេដ្ឋីជាអ្នកឈ្វាសចេះដឹងសារព័ន៌មិត្ត ថ្ងៃមួយត្រឡប់អំពីទីគំនាល់
ព្រះរាជាមក ឃើញកណ្តុរងាប់មួយនៅផ្លូវថ្នល់ ពិនិត្យមើលឫក្សពារក្នុង
ខណៈនោះ ហើយពោលឡើងថា "កុលបុត្រអ្នកមានចក្ខុ អាចនឹងកាន់
យកកណ្តុរនេះទៅធ្វើជាដើមទុន មានកិរិយានឹងប្រកបការងារបាន" ។
កុលបុត្រកំសត់ម្នាក់ ហៅ "ចូឡកន្តេវាសិក" ជាអ្នកបំរើរបស់សេដ្ឋី បាន
ឮពាក្យរបស់សេដ្ឋីនោះហើយ គិតថា "បើលោកមិនដឹង លោកនឹងមិន
ពោល" ក៏កាន់យកកណ្តុរនោះទៅ លក់ឲ្យដល់អ្នកចិញ្ចឹមឆ្មាម្នាក់នៅ
ភូមិផ្សារមួយកន្លែង បានទ្រព្យមួយកាកណិកហួយកកាកណិកនោះ ទៅ
ទិញស្ករនឹងទឹកដឹកមួយក្អម ឃើញពួកមាលាការត្រឡប់មកពីព្រៃ ក៏
ឲ្យស្ករមួយដុំៗ ម្នាក់ ហើយឲ្យទឹកដឹកមួយចោយៗ នាយមាលាការបាន
ឲ្យផ្កាដល់គេម្នាក់មួយក្តាប់ៗ ដោយតម្លៃផ្កានោះ ស្មើកន្លើង គេទិញស្ករ
ហើយនឹងទឹកមួយក្អមយកទៅដល់សួនផ្កាតែម្តង, ថ្ងៃនោះពួកមាលាការ
បានរំលែកផ្កាកន្ទុះៗ ជាច់ឲ្យដល់គេ ។ ដោយៗចាយនេះ មិនជាយូរ
ប៉ុន្មាន គេរកទ្រព្យបាន ៨ កហាបណៈ ។

ថ្ងៃមួយ មានក្មេងខ្សល់ កំណាត់ឈើមែកឈើនឹងស្វឹកឈើ ត្រូវ
ខ្សល់ចោកបំបាក់ធ្លាក់ក្នុងសួនព្រះរាជា អ្នកថែចាំសួន គិតរកៗចាយនឹង
ជញ្ជូនយកទៅចោលមិនទាន់ ចូឡកន្តេវាសិកទៅដល់ទីសួននោះនិយាយ

ទឹងអ្នកវក្សាសួនថា "បើលោកឲ្យមែកឈើនឹងស្ទឹកឈើទាំងអស់នេះដល់ខ្ញុំ ខ្ញុំនឹងជួយដញ្ជូនចេញឲ្យអស់" អ្នកថែសួនក៏ទទួលថា "យកទៅចុះ ចៅ" គេទៅកាន់ពួកក្មេងដែលកំពុងលេង ចែកស្ករហើយសុំឲ្យជួយដញ្ជូនមែកឈើនឹងស្ទឹកឈើចេញ បានអស់ដោយមួយរំពេច ឲ្យគេទុកក្បែរខ្លោងសួន ។ ពេលនោះ ស្តេចធ្មាំងព្រះកជា គ្រាច់ដើរកន្ទុះសដើម្បីជុតកាជនៈដើរបស់ស្តេច ឃើញគំនរមែកឈើនោះ ក៏សុំទិញអំពីគេ ។ ថ្ងៃនោះបូឡកន្ទេរសិកលក់ទុះសបានទៀប ១៦ កហាបណៈ រួមទាំងកាជនៈផ្សេង ។ មានពាងទឹកជាដើមទៀត ៥ មុខ ។ កាលមានទៀប ២៤ កហាបណៈហើយគេក៏រៃរកផ្លូវដើម្បីធ្វើឲ្យកើតផលតទៅ ក៏បានតាំងពាងទឹកផឹកមួយពាងក្នុងទីមិនឆ្ងាយអំពីខ្លោងក្រែង បំរុងបំរើអ្នកប្រតស្មៅ ៥០០ នាក់ដោយទឹកផឹក ។ អ្នកប្រតស្មៅទាំងអស់នោះ ពោលនឹងគេថា "នែសំឡាញ់! អ្នកមានទុបការៈដល់យើងច្រើន យើងនឹងធ្វើអ្វីដល់អ្នកបានខ្លះ?" ។ គេតបថា "កាលណាកំប្លុងរបស់ខ្ញុំកើតឡើងសឹមធ្វើ" ។ គេគ្រាច់ដើរទៅមក ។ បានធ្វើសេចក្តីសំនៀងស្មាលជាមួយនឹងអ្នកប្រកបការងារទាំងចំណែកផ្លូវគោក និងចំណែកផ្លូវទឹក ។ អ្នកប្រកបការងារផ្លូវគោកបានប្រាប់ដល់គេថា "ស្អែកនេះ ឈ្មួញសេះនឹងនាំសេះ ៥០០ មកដល់ព្រះនគរនេះ ។ គេក្តុំដំណឹងនោះហើយ ទៅរកអ្នកប្រតស្មៅ ពោលថា "ស្អែកនេះ ពួកលោកឲ្យស្មៅដល់ខ្ញុំម្នាក់មួយចាប់ចុះ នឹង កាលបើខ្ញុំមិនទាន់បានលក់ស្មៅទេ សុំពួកលោកកុំអាលលក់ស្មៅរបស់ខ្លួន" អ្នកប្រតស្មៅទាំងនោះក៏ទទួលពាក្យ ហើយប្រតស្មៅ ៥០០ ចាប់ មកបោះទុក

ត្រង់ទ្វារផ្ទះរបស់ចូទ្បកន្ពេវាសិក ។ ឈ្ឆ្ញាសេះត្រាច់ដើរទៅពេញក្រុង មិនបានអាហារសំរាប់សេះ ទើបឲ្យទ្រព្យដល់ចូទ្បកន្ពេវាសិក មួយពាន់កហាបណៈ ទទួលយកស្មៅ ៥០០ បាច់នោះទៅ ។ តពីថ្ងៃនោះមក មិនបានប៉ុន្មានថ្ងៃសំឡាញ់អ្នកប្រកបការងារធ្ងូវទឹក បានប្រាប់ដល់ចូទ្បកន្ពេ-វាសិកថា "សំពៅធំមកដល់កំពង់ហើយ" ។ ចូទ្បកន្ពេវាសិកប្រញាប់ធ្វៀតឧកាសភ្ជាម គេគិតឃើញឧបាយហើយ ទើបជួលរថមានបរិវារត្រប់ព្រមដោយថ្ងៃឈ្នួល ៨ កហាបណៈ ទៅកាន់កំពង់នាវាយ៉ាងហ៊ុកហ៊ាក់ ដាក់សន្សាម៉ៅទំនិញទាំងសំពៅទុកដោយចិញ្ចៀនមួយវង់ ហើយទៅ បាំងវាំងនអង្ពុយនៅក្នុងទីមិនឆ្ងាយ បង្គាប់មនុស្សរបស់ខ្លួនទុកថា "កាលណាឈ្ឆ្ញាខាងក្រៅមក ពួកអ្នកចូរធ្វើជាប្រាប់ដល់ត្នាត ។ មកទំរាំនឹងដល់ខ្ញុំក៏ឲ្យបាន ៣ ត" ។

ដឹងដំណឹងថា សំពៅមក ពាណិជប្រមាណ ១០០ នាក់ មកអំពីពាវាណសីដោយប្រាថ្នានឹងទទួលរបស់ នាយសំពៅប្រាប់ថា "លោកទាំងឡាយមិនបានទេ ឈ្ឆ្ញាធំក្នុងទិនោះគេម៉ៅប្រចាំទុករួចស្រេចហើយ" ។ ពាណិជទាំងនោះ ក៏ទៅរកចូទ្បកន្ពេវាសិក ។ មនុស្សរបស់ចូទ្បកន្ពេវាសិក ក៏បង្គាប់ដល់ត្នាឲ្យចូលទៅចែងដំណឹងឲ្យចូទ្បកន្ពេ-វាសិកដឹង ដល់ ៣ តតាមដែលបានណាត់ទុក ។ ពួកពាណិជទាំងមួយរយនាក់នោះឲ្យទ្រព្យម្នាក់ៗមួយពាន់កហាបណៈ ជាភាគចូលហ៊ុនឲ្យសំពៅជាមួយនឹងគេ ហើយឲ្យម្នាក់ៗសុំទិញហ៊ុនរបស់គេទៀត ធ្វើទំនិញឲ្យជារបស់ខ្លួនតែមួយចំណែក ។ ចូទ្បកន្ពេវាសិកកាន់យកទ្រព្យ ៤ សែនកហា-

បណ:មកកាន់ពាក្យណាសីដោយត្រិះរិះឃើញថា ខ្លួនគួរជាអ្នកកតញ្ញូ ទើប
ឲ្យដង្ហែនទ្រព្យមួយសែនកហាបណ:ចូលទៅរកសេដ្ឋី ។ សេដ្ឋីសួរថា
"នែបា! ទ្រព្យនេះទៅរកបានយ៉ាងណា? ។ គេដំណឹងថា "ខ្ញុំបាទតាំង
ទៅក្នុងចុងជើងសមុទ្រ ក៏បានកន្លែងវាងដ៏ធំវិសេសឯង" ហើយក៏ដំណាលរឿងទាំងពួង ចាប់ដើមតាំងអំពីឃើញកណ្តុរឆាប់ ។
ចូរឮកសេដ្ឋីត្រិះរិះថា "ឥឡូវមិនគួរបណ្តោយក្មេងបែបនេះ ឲ្យឆ្ងាត់ទៅ
ក្នុងកណ្តាប់ដៃអ្នកដទៃទៅទេ" ហើយក៏លើកបុត្រីដែលមានវ័យចំរើនឲ្យ
ជាគូ ប្រគល់ឲ្យជាម្ចាស់របស់ទ្រព្យទាំងអស់ ។ លុះអំណើះអំពីសេដ្ឋី
ទៅ គេក៏បានទទួលដំណែងសេដ្ឋីកន្លែងព្រះនគរនោះ ។

រឿងនេះ គោះបំជារឿងបរម្បរាមានសណ្ឋានការណ៍ក្នុងផ្លែរឿងខ្លះ
ដូចជាមិនគួរទើបប្រព្រឹត្តទៅបានកន្លងសម័យនេះ ព្រោះផ្សែងសម័យគ្នាក៏
ពិត ប៉ុន្តែរឿងនេះគង់ឈរត្រជាងឲ្យឃើញសេចក្តីពិតជាមួយកន្លែងដែរ
ដែលគង់ជាសេចក្តីពិតបំតេរៅ គ្រប់សម័យមិនបានផ្លាស់ប្តូរ គឺសេចក្តីពិត
ត្រង់ដែលថា:

"អ្នកប្រាជ្ញយល់ការណ៍ រមែងតាំងខ្លួនបានដោយទ្រព្យជា
ដើមទុនសូម្បីតិចតួច ដូចគេបង្កាត់ក្តីដែលតូច ដូច្នោះ ។

(ចូរឮកសេដ្ឋីជាតក អប្បមាទវគ្គឯកនិបាត)

រឿងសៅរសោយ

(សិសោរជាតក)

ព្រះមហាឧត្តមរិដ្ឋា ផលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមតម្រាយសាស្ត្រាស្វ៊ីកវិត

(តមក)

សោយសេចស្តេចប្រតល់ នូវសំណល់សល់នោះណា
ពួកស្នំនាំយាត្រា ថ្វាយកញ្ញាធីតាស្រី
រៀបរាប់សព្វកិរិយា ការភោក្តាមហាចក្រី
ព្រះនាងផ្ទៀងស្តាប់ខ្នី ហើយក្សត្រីថ្ងៃពិនិត្យ ។
ទតអស់ភ័ស្តុចំណី យល់សេចក្តីតាមន័យពិត
សុទត្តវ័តន៍រវមិត្ត នាងតន់តិតក្នុងចិត្តថា
"អ្នកនេះ ចះចាប់សោយ នូវព្រះស្វោយដោយរាបសា
ដូចជាព្រះបិតា នៃអាត្មាអញឯងស្មោះ ។
នេះជាក់មិនអ្នកឧត្ត់ មិនទុរតតអំណត់សោះ
រូបប្រាណក៏ត្មានខ្ចោះ មើលមិនទាស់ភ្នែកសោះណា
ត្បូរជាកូនមហាក្សត្រ មានសម្បត្តិក្តាត់ចេស្តា
ព្រោះត្រប់សព្វកិរិយា បង្ហាញថាជាមហាក្សត្រ" ។
តិតក្នាងនាងសេដី ឲ្យទាស៊ីយ្មាតឧីចាត់
ប្រាសលាងរោងត្រូថ្ងាត់ ហើយចាត់ក្រាលកំរាលផង

សេចស្រាប់ទើបរៀបចំ ទីបន្ទំសមកន្ទង
ថ្វាយថ្វាត់ក្សត្រច្បាស់ច្បង តាមបំណងផងក្សត្រី ។
លុះលន់យន់ជិតយប់ នាងត្រឡប់ប្រាប់ទាសី
ឲ្យសើរើបេញឱ្ន ន្ទូរកំរាលក្រាលបេញថ្វាត់
ឲ្យទុកនៅដដែល តែកន្ទេល ១ ថ្វាយក្សត្រ
លុះលន់យប់យន់ស្ងាត់ ទើបវរ៉ាតន៍ចាត់ទាសី ។
ឲ្យចូលទូលចៃចង់ ប្រលោមអង្គវង្សចក្រី
ព្រះអង្គទ្រង់ដេរស្ពី ពួកទាសីវិក្រកន្ទង
ព្រឹកព្រាងទើបនាងគន់ ចាត់ភោជនធុនស្ទៅហ្ទង
ឲ្យស្រីទាសីផង នាំទៅផ្គងថ្វាយក្សត្រា ។
ស្តេចយល់ផលចំណី ទើបចក្រីទ្រង់ស្ពីថា
"ភោជនធុននេះណា អញភោក្តាម្តេចទៅវ៉ុ
ព្រោះហេតុកេទអាហារ សព្វប្រការទាំងនេះឱ្ន
ឆ្ងរតែមនុស្សប្រុស-ស្រី ជាទាសីធីទើបសម
ច្នេះហងតោងប្រញាប់ យកបេញធាប់កុំសម្ងំ"
ព្ទុច្នោះក៏អស់ស្នំ វិលបង្គំចមវរល៉ាក្ខណ៍
ទើបអង្គអនង្គស្រី ប្រើទាសីទាំងពីរនាក់
ឲ្យចូលពោលរាក់ទាក់ លោមចមចក្រដោយមាយា ។
ទាសីឱ្ន៉ាតំរង់ ទៅចៃចង់អង្គរាជា
លលេងផ្សេង ៗ ត្នា តែរាជាមិនរវល់

សុំនោះអស់ដំរេះ រៃក្រអេះទៅមណ្ឌល
ចូលទូលដល់និមិល ឲ្យទ្រង់យល់ផលនេះនៃ ។
"បពិត្រវរមិត្តពោ សូមយាងទៅធាប់ ៗ រៃ
ដ្ឋិតតាត់ក្រោធខ្ញាំងក្រៃ ត្លរឲ្យកំយក្រៃប្រមាណ
កាលតាត់យល់នាងហើយ តាត់គង់ស្ឋើយល្ហើយពុំខាន
ហើយនាងគង់នឹងបាន ពោលស្មោះស្មានតាមចិន្តា" ។
ក្សត្រីស្រីវរលក្ខណ៍ ទ្រង់ស្តាប់ដាក់ដូច្នេះណា
នាងយកពរពស្ត្រា តែងកាយាល្អប្រិមប្រិយ
លាបប្រេងតែងដោយម្សៅ ហើយនាងហៅនូវទាស
លីលាម្ទីម្ទាខ្ទី ហៃក្សត្រីស្រីកល្យាណ ។
លុះដល់យល់បរម ទើបប្រណម្យបង្គំថ្មាន
ទសពលយល់កល្យាណ ចូលមកថ្មានហានចក្រី
ស្តេចអរអំណរសល់ ទើបទសពលបន្ទូលខ្ទី
"ហៃប្អូនស្ងួនប្រិមប្រិយ នាងប្រណីបងណាស់ណា ។
នៅនាត្រាលើកមុន នាងធ្វើគុណធ្ងន់ខ្ញាំងក្ខា
លុះក្រោយស្រីធីតា ធ្វើទោសាឲ្យបងខឹង
ឲ្យបងរងខ្មាសគេ ទុក្ខសែនទ្វេណាត្រលឹង
តែទោះអស់ទាំងម្ចឹង បងក៏ខឹងស្រីពុំបាន ។
បងនៅតែនឹកគិត ថាវរមិត្តរ័ត៍ក្សត្រក្សាន្ត
មានគុណពន់ប្រមាណ ប្រៀបពុំបានទេប្អូនស្រី

ព្រោះបង់កំពុង្ព្រួយ ឋានស្រីជួយស្ងួយឡើងខ្ទី
ឲ្យឋានក្សាន្តសុខី សព្វកត្រីទិនទិវា ។
បង្ត្រូវវតតបស្ថង គុណន្ធនល្អង់ពុំរង់ក
វតជ្សិតបុត្រកវិយា ញាតិនានារបស់បង
ព្រាត់ទៅគ្នាននៅជិត ច្ចេះវរមិត្តអាណិតផង
កុំបីស្រីមួហ្ម៉ង ឲ្យខ្ជនបង់នៅផង៉ណ៉ា ! ។
ថ្ងៃក្រោយបង់នឹងធ្វើ សព្វអំពើតាមធីតា
សង់គុណតន់វិញ្ញណា លុះដល់ត្រាជីវ៉ាក្សយ"
សុទត្តវ៉ត៍ន៍កញ្ញា ស្តាប់វាចាមហាក្សត្រថ្ងៃ
ទើបថ្ថមលោមព្រះទិយ ឲ្យដៀស្ថជ័យឋានក្តីស្ឃើយ ។
"បពិត្រព្រះចក្រី សូមប្រណីថ្ងៃខ្ញុំអើយ
កុំក្រោធពិរោធឡើយ ខ្ញុំខុសហើយណ៉ាព្រះបង
ព្រះស្ងាយសោយគ្រប់មុខ ខ្ញុំចាត់ទុកស្រេចជាម្ពង
មួយទៀតបើព្រះបង ទ្រង់ប៉ុនប៉ង់បំណងអ្វី ។
គង់ឋានតាមឋាថ្ថា ជូចបិន្ទាណ៉ាចក្រី
ខ្ជនខ្ញុំព្រិមទាស៊ី នឹងឃ្នាតខ្ទីគ្រប់រវលា"
សុទត្តនឹងក្សត្រថ្ងៃ ត្រាស់ប្រស៊ីយគ្នានឹងគ្នា
ពន្ធេចរាជមាយា តបតគ្នាជាហេតុនឹយ ។
ពេលនោះស្រស់បវរ ញ្ចាំងកូធរឲ្យអរក្រៃ
តម្រេកត្រេកព្រះទ័យ ហើយស្រីថ្ងៃវិទូលថា

"ខ្ញុំម្ចាស់សូមចមចក្រ ឡើងដំណាក់ស្នាក់កាយា
ហើយទ្រង់គង់សុខា តាមប្រាថ្នាណ៉ាព្រះបង" ។
ស្តាប់ចប់នរបតី នាំក្សត្រីខ្មីតំរង់
ឡើងគង់ក្នុងវតម្ពង តាមបំណងផងកល្យាណ
ដល់ក្នាងនាងក្សត្រី លើកចំណីថ្វាយក្សត្រក្សាន្ត
ស្តេចសោយព្រះស្វាយថ្ពាន ហើយទើបបានចូលរួមកាយ ។
រួមផ្ទំនឹងម៉ុមស្រី ស្រស់ពិសីស្រីធោមធាយ
ផ្តកផ្ទិតប្រកិតកាយ សុខសប្បាយឥតបីហ្មង
កាលណោះស្រស់ក្សត្រី ស្ងរស្វាមីដោយទំនង
"ខ្ញុំម្ចាស់សូមព្រះបង ប្រាប់ដើមទងប្អូនផងក" ។
ហេតុម្តេចក៏ស្តេចបាក មកលំបាកយ៉ាកអាត្មា
ទុរគតឲ្យត់ច្នេះណា សូមក្សត្រាប្រាប់ប្អូនផង"
ស្តេចស្តាប់ស័ព្ទនិរមល ទើបទសពលបន្ទូលស្នង
ប្រាយប្រាប់សព្វដើមទង តាមទំនងពុំលាក់ឡើយ ។
ថា "ខ! ឆ្ងរឲ្យសៅ ស្ងួនធោមធ្វៅពៅបងអើយ
បងនឹកវព្ទកហើយ ទ្រូងគ្មានស្បើយល្ហើយទេស្រី
កាលបងត្រងសម្បត្តិ ជាមហាក្សត្រក្តាត់បារមី
សេនាមហាកវី ពស្តេមន្ត្រីកៃកនូង ។
កាលនោះអស់ហោព ម៉ើលជតាអាត្មាបង
ពិនិត្យពិតហើយហោង ទើបហោរផងផ្តងទូលខ្មី

ថា "មានព្រះសៅរ៍សុទ្ធ ជាទេវបុត្រផុតបារមី
ចាកពីសួតាិស្រី ជ្រែកបារមីនៃបងណា ។
បងអាងកម្ចាំងខ្ជូន មិនតាមធ្នូនក្សួនហោក
អាងច្បាំងអាងខ្ចាំងក្ចា អាងចេស្តាបារមីថ្ពាន
ប្រឹងប្រែងតែតែងពល ចាំតទល់ឲ្យជល់ប្រាណ
ព្រោះតិតតំនិតស្មាន ថាសៅរ៍មានសណ្ឋានអង្ត ។
តិតកែតែរៀបទ័ព ត្រៀងប្រជាប់ត្រប់ផ្ចិតផ្ចង់
តិតថាបើឃើញអង្ត នឹងតំរង់ប្រឡងយុទ្ធ
តែលុះថ្ងៃនោះណា ក្សួនហោកហៅមហាធុត
ព្រោះត្រូវសៅរ៍ទេវបុត្រ ចាកច្យុតផុតសួតាិ ។
មកបិតជួងចិត្តបង ពិតជាម្ពងណាល្អងក្ចា
ហេតុតែពៀរវេក កម្មនានាពីមុនឲ្មី
ឲ្យបងវង្វេងប្រាណ ក្ចេចសីលទានគ្មានជឹងអី
ក្ចេចខ្ជូនសូន្យស្មារតី ដេញកាប់ឲ្មីតែពលឯង ។
ចេញពីទីសីមា តែឯកាមហាចំបែង
កណ្តោចខ្ចោចកណ្តែង ក្ចេចកន្ទែងវង្វេងជាន
ពុំយល់ស្គាល់មាតាិ ដែលលីលាយាត្រាថ្ពាន
វិលទៅលំនៅហាន រែងព្ជួយប្រាណប្រមាណក្រៃ ។
ជាប់មកនឹងអាត្មា តែទ័នថ្ចាកំជរដៃ
មកុដមាសទកាសក្រៃ នឹងសេះថ្ងៃ ៣ នោះណា

ឧកឡើងមិនបង់ស្តី ត្មានបំណីអ្ហីភោក្តា
ត្រាច់លង់ក្នុងព្រឹក្សា យូរឡៅរ៉ាទើបផុតព្រៃ ។
បានដល់រាល ១ ក្ងូរ មានស្រែស្រូវនៅច្រើនក្រៃ
មានប្រុស ១ នោះនៃ មកវំពៃចាំស្រូវហោង
ហើយមានធ្តែ ១ ណា ធីបាយរាអស់ជាម្ពង
រាបែរយើញឯបង ទើបរាយថងបងខ្ចាំងក្ងា ។
រាថាបងនេះខ្មី ល្ងូចបាយត្រីធីភោក្តា
រាចោទបំពោតថា ឯបងណាឥតដឹងសោះ
រីមកុដផុតដួងចិត្ត ក្ងាយទៅពិតឥតមានខ្ជោះ
ជាសំណុំបាយស្មោះ កម្មអ្ហីម្ចោ៉ះណាស្រស់ស្រី ។
យើញហេតុភេទចំហុត បងដោះមកុដរតន៍ពិស
ឲ្យរាជាស្រេចខ្មី រាប្រណីលែងរាយបង
ចេញពីទីនោះទៅ ដោយមុខខ្មៅសែនសៅហ្មង
លំបាកយ៉ាកកន្ងង ព្រោះកម្មបងណ៉ាល្អងណ៉ា ។
គិតថាពុំយូរឡើយ គង់បានស្បើយល្ហើយឧរា
តែកម្មចាំផ្តាសា ឲ្យទុក្ខាទៀតជាម្ពង
មានចោរឯណាក្ងូរ ល្ងូចិច្ចូតស្រូវយកទៅហោង
ម្ចាស់ស្រែយើញឯបង រាវាយចងឥតប្រណី ។
ព្រះខ័ន្ធកាន់នោះរា ក្ងាយទៅជាកណ្តៀរខ្មី
យើញច្មោះបងអស់ស្តី ផលកម្មអ្ហីត្រែច្មេះណា

ភបានព្រះទ៉ានហ៊ីយ ទើបភស្សីយល្ហើយទោសា
បង្ហានក្សាន្ត្តទភ រួចជ៉ាក ១ ត្រាទៀត ។
បង្ក៏ចរទៅមុខ ទំវែកលុករុកជ្រកជ្រៀត
តែកម្មចាំឈ្ងបធ្ងៀត មកបៀនបៀតទៀតណាស្រី
មនុស្សម្នាក់ស្ងាក់ចាប់បង ហ៊ីយភយថងបងឥតបី
ថាបងជង្អម្រិយ ជាចោរឡ៊ីលួចគោភ ។
រីសេះទីនាំងពិត ល្អពេញចិត្តឥតគណនា
ប្រែកាយក្ងាយទៅជា គោផងភ្ជាប្រាកជជាក់
លុះភបានសេះហ៊ីយ ទើបភស្សីយល្ហើយទោស:
ខ្ជួនបងធ្ងងមរណ: រួច ១ រត្តណាកល្យាណ ។
បង្ក៏ចរយាត្រា អនាថាឯកាប្រាណ
យូរសល់ទើបជល់ឋាន អាភមមានលោកច្រើនវិក
បង្ចូលទូលថេរ: សូមលោកភាក់ស្នាក់អាស្រ័យ
ទៅនោះលុះយូរវិថ្ង លោកកែវិទទល់បងជា ។
ខ្ជួនបងចង់ប្ជសស្នាក់ ទៅពឹងពាក់ព្រះសាសនា
ព្រះសង្ឆអង្គសាវកា ក៏ករុណា មត្តាបង
តែកម្មចាំផ្ត្តន្ធា ពុំឃ្ងាតឃ្ងាធ្ងាយជាម្ត្តង
មុនបួសនោះខ្ជួនបង យកត្រឿងផងទៅបោកគក់ ។
ជាំធ្នាំងតាំងក្រាក់ខ្នុរ រំដាស់ស្ងោរហ៊ីយជ្រលក់
ច្របាច់ឈ្ងេចញ៊ីញក់ រវល់រក់ឯក្រៅវត្ត

ពេលនោះប្រុស ៥ នាក់ ចូលគគាក់មកជាក់ទាត់
ដាល់បង់ថង់រាយរាត់ ចោមឡោមព័ទ្ធតប្រណ៉ ។
រាចោទបំពោតថា បង់នេះណាមហាអប្រិយ
ជាចោរលួចគោខ្នី ឃើញសាក្សីនៅដៃច្បាស់
ហេតុតែពៀរអកុសល តាមឲ្យផលយល់រហ័ស
ចីវរកឹក្រឡះ ជាបន្ទះស្បែកគោរា ។
រាវាយបង់ឥតលោះ តែពេលនោះចួនគ្រោះជា
ចានសង្ឆគ្រប់អង្គា ជួយជានាទើបរាលែង
ខ្លួនបង់ពង់ជាលជំ សង្ឆតូចធំជួយជ្រោមជ្រែង
ថែទាំថ្នាំប្រដែង អស់កាលវែងទើបបង់ជា ។
ទ្រាំនៅតទៅមុខ ក្រែងពុំសុខទុក្ខអង្គា
ទើបបង់ផ្គងវន្ទា សង្ឆនានាលាយាត្រា
ត្រាច់ចរយូរតិចទៅ ជល់លំនៅខូមយាយតា
សូមកាក់ស្នាក់អាត្មា ពីរយាយតាមិនថាអ្វី ។
បង់ស្នាក់កាក់ទីនោះ តែតឹមោះគ្រោះអប្រិយ
ព្រឹកព្រាងស្ទាងឡើងខ្នី បង់ឥតបីស្មានឡើយហោង
ត្រាប់ពូជផង់យាយតា ចាត់ទៅណាអស់ជាម្ពង
តាយាយស្តាយកន្ទង ទើបឆែកបង់តួកាយា ។
ពេលនោះទម្រង់ពេជ្រ ដែលចង់រៃជាយកូសា
ក្ទាយជូចត្រាប់ពូជណា ទើបយាយតាក្រោជាក្រៃ

ចាប់បងសំពងដំ វាយជាក់ចិតសំចីយ
អស់ចិត្តលុះល្ហិតល្ហៃ ទើបងាកដៃលែងវាយបង ។
បានពូជហើយក៏ដេញ ឲ្យបងចេញពីនោះហោង
បងគ្រំជាំពុរពង មុខមួហ្នងកន្ទងក្រៃ
បងសោតក៏អត់ឃ្ងាន ដើរសូមទានគ្រាន់អាស្រ័យ
កាត់ដងរំលងព្រៃ ស្ទើរៗក្ស័យណាថ្ងៃអ៊ីយ ។
ហេតុគុណបុណ្យកុសល បងបានដល់យល់គ្រាណាត្រើយ
អស់ទុក្ខបានសុខស្ឃើយ ទ្រូងស្ហៃល្ហើយត្រោះបួនស្រី"
ស្ពេចថ្ងៃងមែងហេតុផល ប្រាប់និរមលតតសល់អ្ហី
បានជ្រាបសព្វសេចក្តី ក៏ក្សត្រីអស់សង្ការ ។

(មានត)

វាទ:របស់អ្នកប្រាជ្ញជប៉ុនឈ្មោះ កិនយ៉ូអូតា :

"នៅក្រោមហានសួគ៌ (គឺមនុស្សលោក) នេះ មានមហាសម្ឆត្តិដ៏សំខាន់យ៉ាងក្រៃលែង ៣ ប្រការ គឺ ភរិយា, កាំភ្លើង, ព្រះសង្ឆ" ។

ប្រៃបាកទស្សនាវដ្តីទាវសាសនាភាសាថៃ

អ្នកប្រៃ: ចាប - ពិន

រឿងសាមកុក

កណ្ឌទី ២១

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសប៉ើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ចូធូជជិកស្សរថា បើខ្ជូនមិនបានទៅប្រឹក្សាគ្នានៅផ្ទះតាំងសុិនទេ ចុះ ព្រៃសដែលសរសេរអក្សរនឹងឈាមនោះ សេចក្តីដូចម្តេចខ្ទះ? ។ នាហ្ចឹន ទាំង ៤ នាក់ធ្វើយថា ព្រៃសដែលសរសេរសេចក្តីដូចម្តេចខ្ទះ នោះខ្ញុំ បាទមិនបានដឹងយើញទេ ។ ចូធូក៏បង្គាប់ឲ្យយកខ្ជូនទេងតងដែលជា បាវតាំងសុិននោះចញមកប្រទល់មុខគ្នា ទេងតងក៏ធ្វើយថា នាហ្ចឹន ទាំង ៤ នាក់នេះហើយដែលបានទៅរួមគំនិតគិតគ្នាលើផ្ទះតាំងសុិន ។ នាហ្ចឹនទាំង ៤ មិនទទ្ជូល ។ ទេងតងធ្វើយថា ដើមដំបូងជូហុកទៅរក តាំងសុិនមុន លុះជូឡាន់, តាំងអ៊ុប, ដោហ្ជន, ម៉ាថេងឡើងទៅក្រោយ ជូហុកខ្ទាចក៏ស្ទុះចូលទៅពួនក្នុងរាំងនន រួចតាំងសុិនយកឡាយព្រះហស្ត

ដែលសរសេរនឹងព្រៃសនោះមកឲ្យមើល ហើយនិយាយគ្នាព្រមព្រៀងគំនិតគិតការនោះថា នឹងធ្វើអន្តរាយដល់មហាឧបរាជ ដូហុកទើបចេញមកនិយាយជាមួយគ្នាទៀត តាំងសុំនទីឆ្នាំនៅ ៥ នាក់ ក៏ធ្វើសំបុត្រចុះនាមទុកជាមួយគ្នា ហេតុម្តេចអ្នកតាំង ៤ នៅមិនទទួល? ។ ដូហុកជំរាបបប្ញូថា ខ្ញុំតឆនេះលបសហាយនឹងកំយោតួចតាំងសុំន លុះតាំងសុំនចាប់បានឲ្យវាយផ្តាលរួចដាក់ច្រវាក់ទុក ខ្ញុំតឆមានចិត្តអាឃាតព្យាបាទតាំងសុំន លួចតាមកបាន ក៏យកសេចក្តីបង្គាប់មកប្តឹងពោលទោសតាំងសុំនថានឹងគិតប្រទូសរ៉ាយមកមហាឧបរាជ សូមកុំឲ្យមហាឧបរាជជឿស្តាប់ពាក្យវាជាមនុស្សអាក្រក់ ។

ប្ញូថា ព្រោះខ្លួនវាមិនបានប្ញូលគំនិតគិតជាមួយនឹងខ្លួនវាល់គ្នាបានជាខ្លួនថាវាជាមនុស្សអាក្រក់ ឯត្រង់តាំងសុំនគិតឲ្យកៀតប្តឹងយកថ្នាំពិសមកឲ្យយើងផឹក នោះខ្លួនតាំង ៤ នាក់ដឹងឮឃើញដែរឬទេ? ។ នាហ៊ុនតាំង ៤ ក៏ឆ្លើយថា ខ្ញុំបាទមិនបានដឹងទេ ។ ប្ញូថា "រឿងតាំងអស់នេះខ្លួនមិនទទួលដឹងសោះ បើដូច្នោះយើងនឹងស៊ើបសួរតទៅទៀត បើបានសេចក្តីដូចយើងដឹង យើងនឹងប្រហារជីវិតខ្លួនតាំង ៤ នាក់ចេញ" ថាហើយក៏បង្គាប់ថាហានថា រាល់នេះយប់ហើយ ឲ្យយកនាហ៊ុន ៤ នាក់ទៅដាក់គុកទុកឲ្យឆាប់ខ្លួន ។ ថាហានក៏ចាប់ខ្លួននាហ៊ុនតាំង ៤ ទៅធ្វើទោសតាមបង្គាប់ប្ញូ ។

លុះព្រឹកឡើង ប្ញូក៏នាំថាហានទៅសួរតាំងសុំនឯផ្ទះ តាំងសុំនដឹងក៏ចេញមកទទួលប្ញូឡើងទៅអង្គុយទីសមគួរ ។ ប្ញូក៏សួរតាំងសុំនថា

ពីម្សិលមិញយើងឲ្យមកអញ្ជើញអ្នកទៅស៊ីលៀង ហេតុម្តេចបានជាអ្នក
មិនទៅ? ។ តាំងស៊ុនឆ្វើយតបថា ខ្ញុំបាទឈឺមិនទាន់ជា ប៉ើនឹងទៅ
ក្រែងរោគបណ្តាលឡើងវិញ ។ ចូឆូស្សរថា ដែលអ្នកឯងថាឈឺនោះ
យើងក៏ដឹងអស់ហើយ មិនមែនឈឺដោយរោគអ្វីក៏ទេ គឺអ្នកឯងឈឺ
ចិត្តជ្សិតគិតការមិនសម្រេចជូចប្រាថ្នា ។ តាំងស៊ុនបានស្តាប់ដូច្នោះ ក៏
ឥយស្ងុតស្ងារតីមិនឆ្វើយថាជូចម្តេចសោះ ។ ចូឆូក៏ស្សរតាំងស៊ុនថា សេច-
ក្តីដែលកៀតបុឹងគិតធ្វើប្រទូសក៉យជល់យើងនោះ អ្នកឯងដឹងឬទេ? ។
តាំងស៊ុនឆ្វើយថា ខ្ញុំបាទមិនដឹងសោះ ។ ចូឆូអស់សំណើចហើយថា
ខ្ជូនមិនដឹងក៏ជាហើយ ។ ចូឆូក៏ប្រើទាហានឲ្យទៅនាំកៀតបុឹងមកឯផ្ទះ
តាំងស៊ុន ។ កាលកៀតបុឹងមកជល់ក្រឡេកយើញចូឆូ ក៏ស្រែកដេរថា
អាសត្រូវរាជសម្បត្តិ អាឯងឲ្យនាំអញមកនិយាយការអ្វីទៀត ។

ចូឆូក៏និយាយនឹងតាំងស៊ុនថា ពួកម៉ាកផងខ្ជូនដែលរួមគំនិតគិតការ
ជាមួយគ្នានឹងធ្វើប្រទូសក៉យយើងនោះ ៥ នាក់ ឥឡូវចាប់បាន ៤ នាក់
ហើយ យើងជាក់គុកទុក តែម្នាក់ទៀតនៅមិនទាន់បានខ្ជូន ។ តាំងស៊ុន
ថា ខ្ញុំបាទនឹងបានគប់គិតនឹងអ្នកឯណាក៏ទេ ។ ចូឆូក៏ស្សរកៀតបុឹងថា
នរណាប្រើឯងឲ្យយកថ្នាំពិសទៅជាក់ឲ្យអញផឹក? ។ កៀតបុឹងថា នរណា
នឹងបានប្រើអញក៏ទេ ។ ចូឆូខឹងណាស់ឲ្យវាយកៀតបុឹងម្តងទៀតយ៉ាង
ខ្ទាំង ។ តាំងស៊ុនយើញចូឆូឲ្យវាយកៀតបុឹងដូច្នោះ ក៏បង្កើតឲ្យក្តៅក្នុង
ចិត្តជូចអង្ពុយលើគំនរគ្រើង ។ ចូឆូក៏ស្សរកៀតបុឹងទៀតថា ពីដើមម្រាម

ដៃឯងត្រប់ ១០ ហេតុម្តេចនៅសល់តែ ៩? ។ ក្រៅតបុឹងថា អញកាត់ម្រាមដៃអញ ១ ចេញ សច្ចាស្បថថា នឹងសម្ងាប់អាឯងឲ្យបាន ។

ចូធូចឹងណាស់ ទើបបង្គាប់ឲ្យតាហានកាត់ម្រាមដៃក្រៅតបុឹងអស់តាំង ៩ ហើយ និយាយថា ឯងកាត់ម្រាមដៃអស់ ១ ឯងនៅធ្វើអញមិនបាន ឥឡូវអញឲ្យកាត់ម្រាមដៃឯងអស់ ៩ ទៀត ឯងត្រូវចំតិតធ្វើអញឲ្យបានតាមតំនិតឯងចុះ ។ ក្រៅតបុឹងថា មាត់អញនៅមានអណ្ណាត អញក៏នៅល្មមនឹងដេវម៉ែអាឯងបានទៀត ។ ចូធូក៏បង្គាប់តាហានឲ្យកាត់អណ្ណាតក្រៅតបុឹង ។ ក៏ស្រែកថា អាឯងកុំធ្វើឲ្យអញលំបាកពេកឡើយ ស្រាយអញចេញចុះអញនឹងបញ្ចេញសេចក្តីតាំងអស់ឲ្យដឹង ។ ចូធូបានស្តាប់ក៏យាត់ហាមតាហាន ហើយបង្គាប់ឲ្យស្រាយចំណងចេញ ។ ក្រៅតបុឹងក្រោកឡើងបែរមុខទៅរកព្រះបរមរាជវាំង ហើយក៏ក្រាបថ្វាយបង្គំព្រះមហាក្សត្រថា "ខ្ញុនទូលព្រះបង្គំជាខ្ញុំផែនដី ឥឡូវមានអាខ្មាំងសត្រូវវាធ្វើឲ្យចលាចលជល់រាជសម្បត្តិ ទូលព្រះបង្គំជាខ្ញុំតិតនឹងទំនុកបំរុងផែនដី ដើម្បីបំផ្ងាញរំលាយអាខ្មាំងឲ្យបានតែមិនសមតាមសេចក្តីប្រាថ្នា" ថាហើយក៏ប្រាកក្បាលនឹងសសរសិលាបែកស្ងាប់នៅទីនោះ ។ ចូធូឃើញដូច្នោះ ក៏ឲ្យតាហានពន្ធះសាច់ក្រៅតបុឹងចេញជាដុំ ។ ហើយកាត់ក្បាលយកទៅដោតផ្ចាលកណ្ណាលផ្ទូវជាទីប្រជុំជន ។

ហើយចូធូក៏ប្រើតាហានទៅយកខ្ញូនទេងតងមក ហើយស្សរតាំង-ស៊ុនថា អ្នកឯងស្គាល់ឈ្មោះអានេះឬទេ? ។ តាំងស៊ុនឃើញទេងតងច្បាស់ក៏នឹកចឹងណាស់ ទើបប្រាប់ចូធូថា "អានេះជាបាវខ្ញុំបាទជា

មនុស្សពុំដូន តែតប្រទូសព្រាយលួចប្រពន្ធខ្ញុំបាទ ។ ទើងពុកវាមិនបាន" ហើយតាំងសុំនកំហូតក្រមីលើកឡើងទើងកាប់ខ្ចងតង ។ ចូធ្លូក៏ឲ្យ-ហានដណ្តើមយកក្រមីបាន ហើយនិយាយថា ខ្ចងតងនេះជាដើមចោទ តៅពោលទោសថា ខ្ញុំទើងនាហ្នឹងមានឈ្មោះ ៥ នាក់ រួមគំនិតគិតគប់គ្នាទើងប្រទូសព្រាយយើង ឯនាហ្នឹងដែលនៅក្នុងក្រុង ៤ នាក់នោះយើងចាប់ខ្លួនបានហើយ បានពិចារណាសួរកំឆ្លើយទទួលតាមពាក្យសត្យ, ដែលខ្ញុំនមកធ្វើជាទីគិតសម្រាប់ចោទផងខ្លួនចេញនោះ ខ្ញុំគិតទើងបំ-បាត់កស្តុតាងសូន្យទៅឬអី ។ តាំងសុំនថា ខ្ញុំបាទនឹងបានគប់គិតនឹងអ្នកឯណាច្បងប្រទូសព្រាយលោកគំរេ ។

ចូធ្លូក៏បង្គាប់ឲ្យហានឲ្យឡើងទៅរើមើលលើផ្ទះតាំងសុំន បានសំបុត្រដែលសរសេរចុះព្រះនាមដោយលោហិតនឹងព្រៃស ហើយនឹងសំបុត្រដែលចុះឈ្មោះសញ្ញាសច្ចាស្បថនឹងគ្នានោះ នាំមកឲ្យចូធ្លូទទួលយកមកមើលសំបុត្រចាំង ២ ច្បាប់ ក៏ដឹងច្បាស់ជាសំបុត្រកូនព្រៃសនោះជាឲ្យព្រះហស្តព្រះចៅហៀនតេ តាស់បង្គាប់ឲ្យធ្វើ សំបុត្រដែលសញ្ញាចុះឈ្មោះនោះមានឈ្មោះខ្លៅពីផង ហើយចូធ្លូថា "អាពួកនេះឧបមាដូចជាសត្វតិរច្ឆាន គួរឬមតប្រទូសព្រាយអញ" ទើបឲ្យហានរឹបយករបស់ទ្រព្យតាំងសុំនអស់ពីលើផ្ទះ ហើយឲ្យចាប់យកខ្លួនតាំងសុំនទើងកូរយាបុត្រស្មើគ្រប់ក្បាលពួកចាំងប្តីន្នាន នាំទៅដល់ផ្ទះចូធ្លូ ក៏យកសំបុត្រចាំង ២ ច្បាប់នោះបង្ហាញឲ្យតើប្រឹក្សាចាំងពួងមើល ហើយថា ព្រះចៅហៀនតេតិតឲ្យធ្វើប្រទូសព្រាយយើងជាអ្នកមានគុណចំណាច់ ឥឡូវយើង

ត្រូវនីរទេសចេញពីរាជសម្បត្តិ ចាត់យកពួជព្រះរាជវង្សដែលមានសតិបញ្ញាមកតាំងជាម្ចាស់ផែនដីជំនួសវិញ តើអ្នកតាំងអស់គ្នានឹងយល់ឃើញប្រការម្តេច? ។

ផ្រៀយ៉ុកផ្ទើយថា សព្វថ្ងៃនេះរាជការក្នុងទីក្រុងនឹងអាណាចិត្រទាងក្រៅតាំងពួង ក៏ជាកម្មសិទ្ធិនៃលោក ព្រោះលោកផ្ទើការអ្វីក៏កាន់យកព្រះរាជតម្រាស់ព្រះចៅហ្រានតេជាប្រមាណ នាហ្នឹងសព្វមុខមន្ត្រីក្នុងក្រុងនឹងចិត្រក្រៅ ក៏នៅកោតក្រែងបង្ការប់បញ្ជាលោកតាំងអស់ គ្រានេះផែនដីក៏នៅមិនតាន់រាបតាប ដែលលោកនឹងឲ្យនីរទេសព្រះចៅហ្រានតេចាករាជសម្បត្តិនោះ បើដឹងទៅដល់អាណាចិត្រទាងក្រៅហើយ ក៏គង់នឹងលើកកងទ័ពចូលមកឈូប់ប្រសព្វគ្នា ផ្ទៃអន្តរាយដល់លោកៗ ក៏នឹងមានសេចក្តីលំបាក, ដែលឈ្វាំបាទដំរាបលោកដូច្នេះ សូមឲ្យលោកត្រិះរិះមើលតាមការណ៍ឆ្លរចុះ ។

ចូធូយល់ត្រូវផង ក៏បង្ការប់តាហានតាំងពួងឲ្យទៅចាប់កវិយាបុត្រនឹងបក្សពួកនាហ្នឹង ៤ នាក់នោះនាំមក ហើយឲ្យយកឈ្ជួនតាំងសុិនទឹងនាហ្នឹង ៤ នាក់ នូវកវិយាបុត្រស្ម៉ីត្របក្សពួក ប្រហែល ៧០០ ឡាយនាក់ទៅប្រហារជីវិតក្រៅកំពែងក្រុងហ្ចីតោ ។ នាហ្នឹងមុខមន្ត្រីនូវអាណាប្រជានុរាស្ត្រតាំងឡាយឃើញដូច្នោះ ក៏មានសេចក្តីអាណិតអាណាថយំយែកស្រក់ទឹកត្នែករាល់គ្នា ។ ឧណ:កាលចូធូសម្ចាប់តាំងសុិនទឹងប៉ក្សពួកចេញអស់ហើយ ក៏នៅមិនអស់កំហឹង ទើបសៀតក្រប៉ីចូលទៅក្នុងព្រះបរមរាជវាំង ឡាថ្នា

ដើម្បីនឹងសម្ងាប់នាងតាំងគុយហ៊ុយ់ជាប្អូនតាំងសុិន ដែលជាព្រះស្ទុំព្រះ
ចៅហ្រ្វនគេ ។

ចំណែកព្រះចៅហ្រ្វនគេត្រាស់ប្រឹក្សានឹងព្រះនាងហុកហ្យ ជាព្រះ
អគ្គមហេសីនឹងនាងតាំងគុយហ៊ុយថា "យើងឲ្យសំបុត្រទៅតាំងសុិនជា
យូរខែហើយ នៅមិនទាន់បានសេចក្តីជាយ៉ាងម្តេចសោះ" ទទួលក្រ-
ឡេកទៅឃើញចូធូសៀតក្រប៊ីដើរចូលមក ព្រះចៅហ្រ្វនគេសួតព្រះទ័យ
ត័យណាស់ មិនបានត្រាស់ថាប្រការម្តេច ។ ចូធូមិនបានថ្វាយបង្គំតាមសម
ត្ថរ ក៏និយាយទូលព្រះចៅហ្រ្វនគេថា តាំងសុិនគិតប្រទូសរ៉ាយទូលព្រះ
បង្គំជាខ្ញុំ ព្រះអង្គទ្រង់ជ្រាបឬទេ? ។ ព្រះចៅហ្រ្វនគេបានស្តាប់ចូធូសួរ
ដូច្នោះ ទើបក្ងែងត្រាស់ថា តាំងតុះធ្វើការអាក្រក់នឹងផ្ទៃនដី គេបបួលគ្នា
សម្ងាប់ចេញហើយ ហេតុម្តេចមហាឧបរាជមកថាតាំងតុះគិតប្រទូសរ៉ាយ
ទៀត ។ ចូធូទើបស្រែកយ៉ាងខ្ជាំងថា ទូលព្រះបង្គំទូលថា តាំងសុិនគិត
ប្រទូសរ៉ាយដល់ទូលព្រះបង្គំជាខ្ញុំ ហេតុម្តេចទ្រង់យករឿងតាំងតុះដែល
ស្ងាប់ទៅហើយនោះមកប្រារព្ធវិញដូច្នេះ? ។ ព្រះចៅហ្រ្វនគេបានឮចូធូ
ស្រែកដូច្នោះក៏សួតព្រះទ័យហើយត្រាស់ថា តាំងសុិនគិតប្រទូសរ៉ាយប្រ-
ការម្តេចនោះយើងមិនបានដឹងទេ ។ ចូធូថា ព្រះអង្គសរសេរអក្សរដោយ
លោហិតឲ្យទៅតាំងសុិននោះគ្ងេចអស់ហើយឬ? ។ ព្រះចៅហ្រ្វនគេ
ក៏មិនត្រាស់តបថាប្រការម្តេច ។

ចូធូក៏បង្គាប់ពេជ្ឈឃាដឲ្យចាប់នាងតាំងគុយហ៊ុយ ដែលជាប្អូន
តាំងសុិនយកទៅសម្ងាប់ ព្រះចៅហ្រ្វនគេត្រាស់ថា នាងតាំងគុយហ៊ុយ

មានគកិបាន ៥ ថ្ងៃមកហើយ មហាឧបាជចូរឈ្វេងយល់មកដល់យើង
កុំបីសម្ងាប់នាងនោះឡើយ ។ ចូធូថា ព្រះអង្គឲ្យតាំងសុិនគិតប្រទូសក៉ាយ
ទូលព្រះបង្គំជាខ្ញុំ ដោយសារមានទេពតាជួយទូលព្រះបង្គំជាខ្ញុំ ទើប
បានដឹងការទាំងពួងមិនឲ្យទូលព្រះបង្គំជាខ្ញុំដល់នូវសេចក្តីស្ងាប់ ប្រសិន
ព្រះអង្គនឹងយកស្រីម្នាក់នេះទុកតទៅមុខ គង់នឹងមានអន្តរាយដល់ទូល
ព្រះបង្គំជាខ្ញុំពុំខាន ។ ព្រះនាងហុកហៅអគ្គមហេសីមានព្រះសវនីយ៍
នឹងចូធូថា មហាឧបាជអាណិតទៅចុះកុំអាលសម្ងាប់នាងតាំងគុយហ៊ុយ
ឡើយ ចូរយកទៅដាក់គុកទុកក្នុងផ្ទះតែជាក់សិន បើប្រសិនប្រិសូត
បុត្រវួចកាលណាសិមសម្ងាប់ចេញចុះ ។ ចូធូតបថា នឹងយកឈាម
សរសៃរាទុកធ្វើអ្វី បើបុត្ររាធំឡើងរាក៏មិនលែងធ្វើបាបព្យាបាទប្រទូស-
ក៉ាយដល់ទូលព្រះបង្គំឡើយ ។ នាងតាំងគុយហ៊ុយក៏អង្វរកវចូធូថា បើ
មហាឧបាជមិនទុកជីវិតខ្ញុំទេ សុំកុំឲ្យកាប់ខ្ញុំនឹងអាវុធឲ្យលំបាកឡើយ
ចូរយកថ្រៃសមកចងវិតកឲ្យស្ងាប់តាមប្រកតីចុះ ។ ចូធូក៏ឲ្យយកថ្រៃស
មកធ្វើតាមពាក្យនាងថា ។ ព្រះហៅហ្ងនតេក៏ទ្រង់ព្រះកន្សែងសោកា
ហើយត្រាស់នឹងនាងតាំងគុយហ៊ុយថា ខ្ជួននាងនឹងស្ងាប់ទៅហើយក៏កុំបី
មានកំហឹងខឹងគុំគួននឹងយើងឡើយ ។ ព្រះហៅហ្ងនតេនឹងព្រះនាង
ហុកហៅនាងតាំងគុយហ៊ុយសោកាពិលាប អាឡោះអាល័យគ្នាទៅវិញ
ទៅមក ។ ចូធូយើញដូច្នោះក៏ថ្រៃកគំហកថា " គប់គិតគ្នានឹងធ្វើប្រ-
ទូសក៉ាយគេ លុះគេចាប់បានមកធ្វើជាយំថ្រៃកអាឡោះអាល័យគ្នា "
ហើយចូធូក៏បង្គាប់ពេជ្ឈយាជឲ្យយុំនាំខ្ជួននាងតាំងគុយហ៊ុយ ចេញទៅ

ដល់ក្រៅទ្វារព្រះបរមរាជវាំង ឲ្យយកព្រៃសចង់រិតបំពង់កទាល់តែដាច់ ឧ្យល់ស្ងាប់ ។ ចូធូបង្គាប់នាហ្នឹនសព្វមុខមន្ត្រីខាងក្រុមវាំងនឹងខន្ធីថា "ចាប់តាំងពីត្រឹមនេះតទៅ កុំឲ្យពួកព្រះរាជវង្សចេញចូលទៅមកខាងក្នុងព្រះបរមរាជវាំង បើអ្នកណាចង់ចូលចេញឲ្យយកសេចក្តីប្តឹងយើងជាមុន បើយើងយល់ព្រមទើបចេញចូលបាន បើក្នាក់ឆារណាមិនហាមប្រាមដូច្នេះទេ យើងនឹងឲ្យចុះទោសប្រហារជីវិត" ហើយបង្គាប់ចោ-ហងឲ្យប្រិដុំទាហាន ៣ ពាន់ កាន់កាប់ក្សាព្រះបរមរាជវាំងនឹងទ្វារ កុំឲ្យព្រះរាជវង្សចូលទៅខាងក្នុងបាន ។

ចូធូក៏ចេញមកផ្ទះហើយប្រឹក្សានឹងផៀយ៉ុកថា តាំងសុិននឹងពួក ៥ នាក់ដែលគិតប្រទូសរ៉ាយយើងនោះ យើងក៏សម្ងាប់ចេញអស់ហើយ នៅតែឡៅពិនឹងម៉ាថេង យើងនឹងគិតផ្ទើប្រការម្តេច ទើបនឹងបានខ្ជួនមកសម្ងាប់ចេញ? ។ ផៀយ៉ុកផ្ទើយថា ម៉ាថេងដែលទៅនៅស្រុកសែលៀងនោះមានទាហានច្រើនណាស់ បើលោកនឹងលើកទ័ពទៅវាយយកវេលានេះ ស្រុកយើងក៏ជាកន្ទល់ជ្រាយ សូមឲ្យលោកចាត់រកអ្នកមានដំរេះប្រាជ្ញាទៅបញ្ចុះបញ្ចូលម៉ាថេងឲ្យត្រឡប់ចូលមកស្រុកវិញ កុំឲ្យដឹងខ្ជួនទាន់ថាលោកសម្ងាប់តាំងសុិននឹងគូកនោះឡើយ បើគិតដូច្នេះហើយខ្ញុំបាទយល់ឃើញថា ម៉ាថេងមិនទាន់ដឹងការណ៍ក៏នឹងចូលមកមិនខាន រួចសិមលោកឲ្យចាប់ខ្ជួនសម្ងាប់ចេញនឹងបានដោយឆ្មាយ ឯឡៅពីនោះទៅនៅស្រុកឈីជីវប្រមូលសេនាទាហាននឹងចាំទទួលកងទ័ពលោក ឥឡូវទាហានអ្ជិនសៀវនឹងទាហានយើងក៏នៅតាំងរាំងរាគ្នានៅតំបន់គ្ជរត មុខ

ជាឡៅពីនឹងឲ្យមានសំបុត្រឡៅតិតនឹងអ្ជិនសៀវឲ្យជាពួកជាមួយគ្នា បើ
លោកលើកកងឡីពឡៅឡាំងនឹងឡៅពីវេលាណា តង់អ្ជិនសៀវនឹងលើក
មកវាយយកក្រុងហ្ជ្ជិតោជាប្រាកដ នរណានឹងតឡល់នឹងអ្ជិនសៀវក៏កម្រ
ក្រវិក្រណាស់ ។ ចូធូតបថា ឡៅពីនោះជាមនុស្សមានសតិបញ្ញា បើ
នឹងបង្អង់ឲ្យយូរការក៏នឹងមានកំឡាំងច្រើនឡើង ឧបមាដូចកូនសត្វបក្ស
កំពុងតែជុះក្រាស មិនទាន់មានស្លាបនឹងហើរ បើយើងនឹងស្លៀមទុកឲ្យ
នៅក្នុងសម្បុកដូច្នេះ កាលណាជុះរោមនឹងស្លាបត្រមហើយក៏នឹងហើរឡៅ
ផ្ទូវធ្វាយបាន ទោះនឹងប្រាថ្នាចាប់ខ្ជួនក៏កម្រណាស់ អ្ជិនសៀវនោះមាន
ទាហានច្រើនក៏មែន តែជម្រៃះប្រាជ្ញាតិច ទោះនឹងតិតការអ្ជិ យើងមិន
ត្រូវខ្លាច ។

(មានត)

សូមដាស់ត្រឿន :

ក្នុងសម័យនេះ ប្រទេសយើងមានទូតនឹងជនផ្សេងប្រទេស ដែលរាប់
អានព្រះពុទ្ធសាសនា ផ្ទូចភូមា ខ្មែរ ឥណ្ឌៀដាដើម ចូលមកនៅជាច្រើន,
ក្នុងក្នុងយើង គេមកនៅយូរ ។ ទៅ គេអាចដឹងសេចក្តីប្រព្រឹត្តរបស់បព្វជិត
យើង បានយ៉ាងដាក់ច្បាស់នឹងភ្នែកគេ ការលបើយើញបព្វជិតក្នុងសាសនា
យើងប្រព្រឹត្តមិនល្អ គេកំតិះដៀល, បើគេយើញប្រតិបត្តិល្អ គេកំនាំទៅសរ-
សើរប្រាប់គ្នាឯស្រុកគេ ។

ប្រែបាកទស្សនាវដ្ត៉ីទាវសាសនាភាសាខែ

អ្នកប្រែ: ចាម - ពិន

ដំណើរតាមខ្សែក្នុងកន្លែង:

លោក ផេង-ជ្រឿ សរស្ត្រីបារាំងនៅសាលាគរុកិច្ចភ្នំពេញ

ប្រែពីភាសាចាក់ដែងមកជាភាសាខ្មែរ

(តមក)

គេឃើញពួកបរិស័ទ្ធនាំគ្នាដើរដង្ហែទៅក្នុងខ្ទមបូជនីយដ្ឋានម៉ែត ប្រកបដោយចិត្តរីករាយបរិសុទ្ធដូចជាកាលដែលគេដាយើងពីដើម នាំគ្នាចេញពីគ្រប់ប្រកល្បកក្នុងប្រទេសអឺរ៉ុប ដង្ហែគ្នាដើរដើរដងទៅ កាន់ហ៊ីរុយហ៊ីរាឡែមទៅកាន់ក្រុងរោម ដូច្នោះដែរ ។

ហេតុនេះ គឺជាពិធីមួយដ៏អ៊ុកអធិក បើកាលណាពួកឯកសិទ្ធិឃុនទៅកាន់ទីម៉ែត ហើយត្រឡប់មកកាន់កូមិវិញ ។

ក្នុងទុកាសដ៏ទុឡារិកនោះ នៅត្រង់ទីធ្លាមួយយ៉ាងធំ មានប្រជុំអ្នកលេងល្បែងផ្សេងៗ ជាច្រើន រឿងនេះជាលេះដល់ស្រែ ប្រុស ចាស់ក្មេង កំឡោះ ក្រមុំ នាំគ្នាទៅស្តាប់ក្លេង ស្តាប់ចម្រៀង មើលគេកំរែកទឹងលេងល្បែងគ្រប់ដំពូក ដែលត្រូវចំណុចដូងវិញ្ញាណផងមនុស្សបុព្វាប្រទេស ព្រោះអ្នកលេងច្រើនតែច្រៀងភត្តិរឿងរឭកស្រុកកំណើត ។

ពេលព្រឹកនោះ បងប្អូនស្រី។ ម៉ូស្មាម៉ុលសួរនាងឡីឡាដែលហាក់ដូចជាកំពុងស្ទង់ចិត្តកូដអារម្មណ៍ណាមួយថា:

"ឡីឡា! មិនទៅអណ្តូងទឹកទេឬ ព្រឹកនេះ?" ។

នាងក្រមុំញញឹមៗរួចយកក្រមាខ្លួរហើយនាំគ្នាចាំងអស់ដើរចេញទៅ។ នាងឡីឡាស្រងូតស្រងាត់ ព្រោះឃើញអ៊ីស្មាអ៊ីលដូចជាមានចិត្តច្រឡំក្តួ

ឡេកឆ្នងអារម្មណ៍ដទៃ ។ នាងមិនដឹងបំណងរស្សីមនឹងយោបល់ដែលនាំ
ឲ្យអ៊ីស្មាអ៊ីលព្រួយ ។ នាងនឹកដោយសេចក្តីស្រងេះស្រងោចម្តងៗ ថា
ប្រហែលមានថ្ងៃណាមួយ នាងនឹងត្រូវឃ្ងាតចេញពីគេហស្ថានលោកតា
អៃយ៉ាដដែលបានចួបសេចក្តីសុខ នឹងត្រូវខានឃើញមុខអ៊ីស្មាអ៊ីលដែល
នាងប្រតល់ដួងព្រលឹង ជាតួសេចក្តីស្នេហាដ៏ធំរបស់នាង ។ កាលណា
នាងនឹកដូច្នេះឡើង វាហាក់ដូចជាស្ទើរនឹងរលួយថ្ងៃមប្រមាត់ ។ កាល
នារីទាំងឡាយឡេដល់ទីប្រជុំ ហើយបានឃើញតាចាស់ម្នាក់វាចាក់ក្សាច់
ញាក់មុខ ពោះកំប៉ោង គេនាំគ្នាសើច រួចដើរសន្សឹមៗ ហួសឡេកន្ទែង
អណ្តូងទឹកចាស់មួយដែលតាំងនៅចុងខាងនាយកន្ទែងរឿណរង្ត មានកូន
អម្ពិលទឹក នឹងដើមកូឡាបដុះព័ទ្ធជុំវិញ ។

វេលាដែលនារីដទៃកំពុងគ្រាបធ្វើវ្ហីលើមាត់អណ្តូង អាត់តែប្រុង
ស្តាប់ចម្រៀងដំអូញនៃពួកអ្នកគ្វេង មានស្ត្រីចាស់ម្នាក់ស្ទៀកពាក់សាក
ត្រាក តាមរបៀបប្រទេសអាហ្វ្រិក សក់ឆ្មារលើប ពាក់រង្ងង់ស្ពាន់
ពីលើផ្ទួង ដើរចូលមកជិតនាងឡីឡា ។

មុនដំបូង ឡីឡាថយក្រោយ តែយាយនោះញញឹមមកវកហើយ
និយាយថា:

–"កុំខ្ជាចអី នាងក្រមុំ យាយឥតមានរករឿងធ្វើការអាក្រក់អ្វី
ដល់នាងទេ ។ នែមាសពៅ ហេតុអ្វីក៏នាងស្រងូតស្រងាត់អីម្ទេះ?
ទុកឲ្យយាយទាយព្រេងវាសនាឲ្យមើល" ។

ឡីឡា សំឡឹងយាយមេអាបដោយសេចក្តីងឿងឆ្ងល់ ស្ត្រីនេះមើល

ផ្ទុះដល់ចិត្តខាងក្នុងរបស់នាងជាប្រាកដ ដ្ឋិតតាត់ថាត្រូវត្រង់នាងត្រួយ ។ ពេលនោះ ឡីឡា ផ្ទើអាការច្រេមច្រុំ ចំណែកប្អូននឹងប្អូនស្រីជីដូនមួយ នៃអ៊ីស្នាអ៊ីលអាល័យតែចាក់សោឲ្យអ្នកច្រៀងផឹក ។ នារីទាំងនេះ ប្រហែលនឹងយាត់នាង ឡីឡា មិនឲ្យទៅតាមយាយមេអាបទេ ប្រសិន បើដឹង ថ្ងីដ្ឋិតស្រី ។ តែងចូលចិត្តជឿទំនាយ ។

ម្យ៉ាងទៀត នាងឡីឡានឹកថាប្រហែលជានឹងមិនមានគ្រោះថ្នាក់ អ៊ីទេ នៅកណ្ណាលហ្ងូងមនុស្សឈូធរ រួចទើបនាងដើរតាមយាយមេ អាបរហូតដល់ក្រៀនកន្ទែងមួយតូច ជាច្រកនៅខាងក្រោយកំពែងចាស់ ពីបុរាណមួយ ទីនោះជាកន្ទែងសំណាក់អាស្រ័យសំចតរបស់យាយ អាហ្ងិក ។ នាងឡីឡា ហុចដៃទៅឲ្យយាយចាស់ ។ ចាប់ដៃ ហើយហាក់ ដូចជាសំឡឹងសង្កេតខ្សែដៃយ៉ាងយូរ ទើបទាយថា:

– " នាងឯងនឹងមានគូសង្សារត្រមទាំងសេចក្តីសុខដ៏ប្រសើរ ។ កុំខ្វាច អ្នកនោះស្រឡាញ់នាងណាស់ ។ មានថ្ងៃណាមួយ គេនឹង នាំនាងឯងចេញទៅនៅទីដ៏ទៃ ឆ្ងាយពីស្រុកនេះ" ។

សំដីផងយាយអាបបំពេញចិត្តនាងក្រមុំដោយសេចក្តីសប្បាយ ។ ក្នុងទំនាយនោះ នាងចូលចិត្តថាប្រាកដជានិយាយពីអ៊ីស្នាអ៊ីលហើយ ព្រោះនាងចង់ឲ្យការណ៍ដែលនាងប្រាថ្នាសម្រេចតាមបំណង ។

យាយអាហ្ងិក សូង់សំដីទៅប្រហែលជាបានការ ក៏និយាយថែម ទៀតថា:

" ល្ងាចនេះ ពេលយប់ស្ងាត់គេដេកអស់ ចូរនាងមកចាំក្សែរ

អណ្ណូងនេះកុំខាន ។ គូស្នេហារបស់នាងនឹងមកចួប ហើយនឹងនិយាយ ប្រាប់សេចក្តីប្រដិព័ទ្ធរបស់គេដល់នាង កុំភ័យបារម្ភអ្វី ឥតមានមនុស្ស ក្នុងផ្ទះណាគន់មើលឡើយ" ។

សំដីខាងក្រោយនេះ រិតតែបញ្ជាក់គំនិតនាងឡើឡាឲ្យសន្និដ្ឋានថា ប្រាកដជាអីស្នាអ៊ីលហើយ ។ លុះនាងឡើឡាត្រឡប់មកចួបនឹងនារីជា គូកនរិញនាងពំងនេះធ្ងល់ពេក ដោយឃើញឡើឡារីកកាយស្រស់ប៉ៃប្រ ។ គេចូលចិត្តឥតសង្ស័យថាប្រាកដជាពិធីនេះហើយ ដែលធ្វើឲ្យឡើឡាមាន ទឹកមុខស្រស់សប្បាយ ។ នារីពំងឡាយក៏ត្រឡប់រិលចូលទៅកាន់ទី លំនៅដោយអស់សំណើចរៀងខ្លួន អំពីរឿងផ្សង ៗ កើតមានក្នុងពិធី បុណ្យដែលបានឃើញ ។

ខណៈនោះ គ្រាន់តែនាងឡើឡាចេញផុតភ្ងាម យាយមេអាបលប ចូលទៅខាងក្រោយគុម្ពកូឡាប ដែលរស្សីមពួននោះ គេដើបឡើងហើយ ស្ទូរថា:

– "ដូចម្តេចទៅ?" ។

យាយអាបធ្វើយថា:

– "ឧត្រះតេជៈគុណអើយ នាងនេះស្ងូតដូចកូនពពែទើបនឹងកើត ហើយខ្ញុំបានប្រាប់ឲ្យនាងមកត្រង់អណ្ណូងទឹកក្នុងយប់នេះ" ។

សេចក្តីសប្បាយរីកកាយចាំងរស្មីចេញតាមក្នែករស្សីម ៗ ស្រែក ហើយបោះប្រាក់មួយស្បោងពេញទៅឲ្យយាយអាបថា:

– "ហ៉ ! លោកយាយ អញ្ជើញយកចុះ !" ។

យាយអាបអាត់តែនស្រែវាសើសច្រាក់ រស្មីមាត់ថយចេញជាប្រ-ញាប់ដើរដំហានវែង ។ ទៅឆ្ងាយបាត់ ។ យាយអាបនឹងក្បាលដល់ដី ហើយស្រែកឱ្យពរថា:

— "សូមព្រះអាឡស់រក្សាអ្នក! សូមព្រះអាឡស់ស្ថិតនៅក្នុងខ្លួនអ្នក! សូមព្រះអាឡស់ប្រសិទ្ធិឱ្យអ្នកមានអាយុយឺនយូរ!" ។

យាយអាបស្រែកឱ្យពរតាល់តែមើលរស្មីលែងឃើញ អ្នកកំព្រាះដើរបត់តាមផ្លូវតែងទៅបាត់ ។

យាយអាប ទោះចំណាស់ប៉ុណ្ណឹងហើយ ក៏អាចសុះក្រោកឡើងបានក្រាមដើរប្រញោបប្រញាប់ ចូលតាមផ្លូវមួយតូចនៅប៉ែកខាងទិសឆ្ពុយគ្នានឹងផ្លូវដែលរស្មីមើរទៅ ។ យាយអាបដើរមិនបង្អង់រហូតដល់ភ្លាត្រង់ ហើយគេចចូលក្នុងតឿមមួយនៅត្បែរវាលខ្សាច់ មានលក់គ្រឿងស៊ីផឹកគ្រប់យ៉ាងគឺ នំផ្អែម កាហ្វេ ទឹកឧទ្រឹក ទឹកស៊ីរ៉ូ ។

នៅត្រង់ក្រលៀតតឿមនោះ មានមនុស្សប្រុសម្នាក់អង្គុយលើស្បែកចៀមកំពុងបឺតបារី ។ មានឈ្លួសម្នាក់ស្លៀកខោខ្លី ស្រែមដើងសូត្រពណិស៊ីជម្ពូក្បាលពាក់ក្រែនេះ ឆ្គុយងើកភរាភ្លើកលើកន្ទេលមួយ ។

កាលដែលយាយចាស់ចូលទៅ អ្នកបំរើនេះក៏មិនកំរើកខ្លួន ។ យាយអាហ្វែកចាំបានទូរមនុស្សដែលគាត់មករក គឺអ្នកដែលកំពុងជក់បារីនោះឯង ។ អ្នកនេះងើបក្បាល ហើយធ្វើសញ្ញាឱ្យយាយចាស់ចូលមក ។ គាត់ចូលមកជិតអង្គុយលើស្បែកចៀមជាមួយគ្នាឯប ហើយក៏យកក្រាប់ថ្ពាប់ទូរកិច្ចដែលខើបនឹងកន្ទេលទៅហើយ ខឹងនាងឡឺឡាដែល

ត្រូវមកត្រង់កន្ទេងអណ្ណូង រៀលាយប់នេះដើម្បីជួបនឹងរស្យីម ។ គាត់
និយាយយ៉ាងតិច ។ ដោយក្បត់ការទំនុកទុកចិត្តនៃបេនអាប់ជាឡេះ ព្រោះ
គាត់បានរង្វាន់សុទ្ធតែប្រាក់ ចំណែកតាឡិបបានសុទ្ធតែមាសមួយស្បោង
ពេញ ។ ធម្មតាជាតិស្ត្រី យាយអាបក៏ជួបស្ត្រីទាំងឡាយដទៃដែរ តែង
ត្រូវការមាសប្រាក់ពន់ពេក កម្រជាអ្នកសន្តោសណាស់ឡើយ ។

* * *

ពេលរសៀលនេះ លោកតាអៃយ៉ាង អាក់ខានពុំបានអានធម៌
(ក្ប៉ាន់) ដែលលោកត្រូវមើលរាល់ថ្ងៃ ព្រោះលោក មូហាម្មេដ ណា-
ប៊ីប៊ី ជាវរសេនីយត្រីនៃកងទ័ពតូចនៅកាស៊ិ-ការាប៊ូល៊ី ត្រូវការចង់ជួប ។

លោកវរសេនីយ៍នេះអញ្ជើញមក មានពួកនាយទាហានជាច្រើន
ជូនមកផង ដើម្បីជួបសន្ទនាការនឹងលោកតា កាអ៊ីត ហើយនឹងចង់ដឹង
ឲ្យច្បាស់នូវដំណើររដ្ឋាភិបាលនៃកុងស្តង្ទីណុប ដែលអាចពឹងលើសេចក្តី
ស្មោះស្ម័ត្រនឹងការយកចិត្តទុកដាក់នៃមេភូមិនេះ ដែលមានអានុភាពដ៏ធំ
ក្នុងតំបន់ តើបែបណា ?

មុក្តារមកឲ្យដំណឹងដល់អ៊ីស្មាអ៊ីលថា :

– "លោកឥពុកមានប្រសាសន៍ហៅបង ដើម្បីចេញទៅទទួល
ជាកិត្តិយសជូះ នូវពួកនាយទាហានតួរតីដែលមកចង់ជួបនឹងលោក" ។

អ៊ីស្មាអ៊ីលព្រមទៅទាំងទើសទាល់ ។

គេមិនមែនមិនសប្បាយនឹងលោកឥពុកទេ តែគេមិនចូលចិត្តនឹងពួក
តួរតី ។ គេដឹងថាគេមិនចូលចិត្តជាច្រើននឹងប្រជាជនតួរតី គឺជាសាសន៍

មិនសុចរិត ឆ្នើងឆ្មៃយដ៏ឃ្នង មិនសុខុម:ស្មេហាណាមួយដែលសំដែងឲ្យឃើញចំពោះជាតិអ៊ីតាលីដែលជាអ្នកលុកលុយសង្កត់សង្កិនដូចគ្នា ។ អ៊ីស្មាអ៊ីលមានបំណងថា សាសន៍អារ៉ាប់ត្រូវនៅជាអព្យាក្រឹត្យ ក្នុងសង្គ្រាមរវាងប្រជាជនពីរ ។

ម្យ៉ាងទៀត អព្យាកតភាពនេះ គឺជាលក្ខន្តិកៈមួយដែលគេបានស្នើឲ្យក្នុងកិច្ចសញ្ញាចុះចូលដែលអារ៉ាប់ពាំងឲ្យយកបានសម្រេចនៅចំពោះមុខនៃពួកតួរគីហើយ ។

ពេលនោះ អ៊ីស្មាអ៊ីល ទំអត់ត្រាំទៅសំដែងមុខនៅក្បែរលោកឧត្តមកងសាលកិត្តិយស ហើយតាមទំនៀមស្រុក គេត្រូវនិនាំនាយ-ហានតួរគី ម្នាក់ម៉ដង ។

លោកមូហាម្មេដ ណាប៉ប៉ា ចូលកងឋនូប៉ខ្លួលភ្ញៀវបន្ទាប់លោកតាអៃយ៉ាជ ។ ពួកអ្នកបំរើលើកទឹកតែក្រអូប ផ្លែទំពាំងជូរពណ៌ក្រមៅមានរសផ្អែម ប៉ុន្តែផ្លែពុត្រា ជាក់លើថាសធ្ងាក់ នាំមកជូនគ្រប់គ្នា ។

កាលណាកិច្ចគួរសមចំពោះគ្នាទៅវិញទៅមកធ្លើរួចហើយ លោកមូហាម្មេដណាប៉ប៉ា ជានាយទាហានចាស់ជាងគេ ជាមនុស្សម៉ាំងទាំងប្រៃតែអំណាចយកតែសិទ្ធិនៃអ្នកមានកំឡាំងមកប្រើ ហានិយាយដាំងថា:

- "អញ្ជើញបងឯងឲ្យដឹង: រស្មីមេន អាប់ជាឲ្យចូលដៃជាមួយនឹងយើងហើយ គេធ្វើជានាយត្រួតទាហាននៅក្នុងកាស៊ី - ការចូលឥឡូវគេកំពុងរៀបចំកន្លែងចាំស្វាគមន៍ពួកខ្ញុំ" ។

អ៊ីស្មាអ៊ីលស្រែកឡើងថា:

– "ធ្វើបែបនេះ ជាការក្សត់!" ។

លោកមូហាម្មេដណាប៊ីប៊ី បែរមុខចំអ៊ីស្មាអ៊ីល ហើយសួរថា:

– "ចូរឯងប្រាប់យើងមកមើល តើហេតុដូចម្តេច?" ។

អ៊ីស្មាអ៊ីលធ្វើយប្រាប់ថា:

– "ខ្ញុំដូចជាចាំថា: ក្នុងសញ្ញាចុះចូលរបស់យើង មានន៉ិយាយអំពីអព្យាកតកាពក្នុងនោះវិញទេ ពេលណាបើមានជំលោះកើតឡើងរវាងរដ្ឋាភិបាលរបស់លោកនឹងរដ្ឋាទិបាលនៃជនបរទេស" ។

នាយទាហានតួរគីសើចចំអក សំដែងទឹកមុខម៉ឺងម៉ាត់ រួចតាំងន៉ិយាយដោយ សំដីច្បាស់ ៗ ថា:

– "ចូរឯងដឹងច្បាស់ថា អព្យាកតកាព គេចុះឲ្យតែមាននៅលើក្រដាសប៉ុណ្ណោះទេ ។ គឺជាសំដីដែលអ្នកន៉ិយាយការណ៍ចេះតែប្រឌិតឲ្យតែមានឡើង!

"នែ អ៊ីស្មាអ៊ីល បេន អៃយ៉ាដ ឯងត្រូវដឹងថា ក្នុងពេលមានជំលោះគេចាប់មិត្រភ័ក្តិដែលនៅជាមួយបញ្ជូលឲ្យជួយជងហើយ អ្នកណាមិនចូលជាមួយនឹងយើង ៗ យើងទុកអ្នកនោះជាសត្រូវនឹងយើង, ហ្នឹងហើយគឺជាច្បាប់ចម្បាំង!

រស្សីមបានបង្ហាញសេចក្តីក្លាហាននឹងចិត្តស្មោះសរឲ្យយើងឃើញហើយ ។ យើងសង្ឃឹមថាដល់វេនឯង ៗ នឹងទៅជាមួយនឹងយើងមិនខាន!" ។

អ៊ីស្មាអ៊ីលបែបចង់មិនយល់ព្រម តែលុះសំឡឹងទៅទឹកមុខឧត្ថកគេ ៗ ក៏ឈប់ស្ងៀមទៅវិញ ។

លោកតា កាអ៊ីត នៅសៀមឈឹង, ការសៀមនេះជាអាវុធមួយដ៏គួរឥយនៃជាតិអ្នកបូពាិប្រទេស, ក្នែកលោកអង្ករកូន ប្រាប់ថាត្រូវប្រយ័ត្ន, ទើបអ្នកកំទ្បោះបែរមករកនាយទាហានហើយឧនគំនាប់ឲ្យសញ្ញាថាយល់ព្រមតាម ។

*

* *

នៅឧកាសជាមួយគ្នា ក្នុងភូមិដែលរស្យ៉ីមបេនអាប់ជាឡះនៅ ក្នុងសង្កាត់នោះបរិបូណិដោយផូះលក់ទំនិញ មានមនុស្សម្នាក់មកស្លូរកចង់ចូបនឹងមេសង្កាត់ ។

រស្យ៉ីមបង្គាប់ថា:

– ត្រូវឲ្យគេចូលមក!

លុះក្រៀវចូលដល់ រស្យ៉ីមសួរថា:

– តាឡិប ត្មានរឿងអ្វីប្ងែកទេឬ?

– ត្មានទេ ចៅហ្វាយ! ប៉ុន្តែយប់នេះ ខ្ញុំនឹងនាំនាងឡ៉ីឡាមកជូន!

រស្យ៉ីមញឹម ៗ ដោយនឹកថាបំណងរបស់ខ្ជូនទឹងសម្រេច ។

– ល្អហើយឯងត្រូវនាំវាទៅឯអណ្ណូង អញនឹងឲ្យរង្វាន់ដល់ឯងទៀត!

*

* *

(មានត)

រឿងបល្ស័ង្ហាទិព្យ សាមសិបពីររឿង

រឿងព្រេងតណ្ឌៀ

លោកសមិន ម្ចាត្យ៍ងជម: តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

និទាននៃរូបទេពនិម្មិតទីប្រាំ

ព្រះមហាក្សត្រកោជ: ទ្រង់សម្រេចក្នុងព្រះទ័យថា នឹងប្រកាសឲ្យ ដ្ឋើនូវមុទ្ធាភិសេកទ្រង់ឲ្យសោយរាជ្យជាស្តេចពេញលក្ខណ: ទ្រង់ស្តេចទៅកាន់បល្ស័ង្ហទិព្យដោយមានព្រះរាជទីប្រឹក្សាជាបរិវារហែហមផង ។ លុះទ្រង់យាងទៅជិតបល្ស័ង្ហនោះ រូបទេពនិម្មិតទីប្រាំក្រាបទូលថា "បពិត្រ ព្រះមហាក្សត្រកោជ: សូមទ្រង់ព្រះសណ្ឌាប់ទូលបង្គំ ព្រះមហាក្សត្រ អង្គណាដែលនឹងគង់នូវលើរាជបល្ស័ង្ហព្រះបាទវិក្រមទិត្យបាន លុះត្រាតែ មហាក្សត្រអង្គនោះមានព្រះទ័យសប្ឋុរសដូចព្រះបាទវិក្រមទិត្យ" ។ ព្រះមហាក្សត្រកោជ: ទ្រង់មានបន្ទូលសួរទៅរូបទេពនិម្មិតនោះថា "ព្រះទ័យសប្ឋុរសនៃព្រះបាទវិក្រមទិត្យយ៉ាងណាទៅ?" ។ រូបទេពនិម្មិតទីប្រាំក្រាបទូលថា "បពិត្រមហារាជ! សូមមហារាជទ្រង់ព្រះសណ្ឌាប់ចុះ"! ។

នៅក្នុងទីក្រុងអវន្តី ព្រះបាទវិក្រមទិត្យទ្រង់គង់នៅលើរាជបល្ស័ង្ហ កណ្ឌាលព្រះរាជទីប្រឹក្សា ទ្រង់កំពុងចាត់ការផ្សេង ៗ ក្នុងព្រះរាជអាណា-

ចក្រ, ក្នុងពេលនោះនាយឧត្សានបាលបានចូលមកដល់ទ្វារព្រះរាជមន្ទីរ ហើយពោលទៅកាន់នាយទ្វារបាលថា "ត្រូវតែខ្ញុំចូលទៅតាល់ព្រះមហា-ក្សត្រ, អ្នកចូរក្រាបបង្គំទូលព្រះមហាក្សត្រឲ្យខ្ញុំផង" ។ ក្នុងពេលនោះ នាយទ្វារបាលក៏ចូលមកថ្វាយដំណឹងនេះចំពោះព្រះមហាក្សត្រ ហើយ ក៏នាំនាយឧត្សានបាលចូលទៅ ។ នាយឧត្សានបាលបានយកដៃទាំងពីរ លើកត្រឹមក្បាលថ្វាយបង្គំព្រះមហាក្សត្រ ហើយក្រាបទូលថា "សូម ទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំសូមថ្វាយនូវដំណឹងមួយចំពោះទ្រង់ គឺសព្វថ្ងៃដើមស្វាយ ដូង ស្វា ក្រូចធ្មារ ក្រូចពោធ៏សាត់ ចម្បាក: អសោក: កិមសុក: ម្ទិះ ត្នោត តមាល: សាល: បិយាល: កទលិ កក្តល: លពន្ធ ក្រវាញ កតល៉ កុន្ទ: ទមនក: សរុបគឺរុក្ខាទាំងអស់ ដែលដុះនៅក្នុងព្រះរាជឧត្សានកំពុងមានត្រួយខ្ចី ផ្ការ ផ្លែ គឺពេលត្រូវ ព្រះអង្គទ្រង់យាងទៅក្រសាល ក្នុងព្រះរាជឧត្សាននេះ" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្ឋាប់នូវសេចក្តីក្រាបបង្គំទូលរបស់នាយ ឧត្សានបាល ទ្រង់ក៏យាងទៅទីនោះ មានក្រុមព្រះរាំនី (ស្នំ) ព្រម ទាំងតាសាតាស៊ីនឹងនាងនាដកាដាច្រើនហែហមជាព្រះរាជបរិវារ ។ លុះ ទ្រង់យាងទៅដល់ព្រះរាជឧត្សាន ហេតុតែទ្រង់ប៉ុនប្រសប់ខាងចុម្ពិតនា-ការ (ឧបថើប) ព្រះសម្ងួលនឹងរបាំ ព្រមទាំងទ្រង់ព្រះពស្ត្រដ៏ធើតធោម ល្បែងផ្សេង ៗ ការប្រឡែងលេង នឹងអាកប្បកិរិយាប្លែក ៗ ក៏យាងទៅ ជាមួយពួកស្រីស្នំដែលមានរូបធោមលោមពណ៌ស្រស់ប៉ព្រង បេះបុប្ជា ឬ ក្រសាលក្នុងតង្គាឬប្រៀង ឬ គង់លើ (អង្រឹង) ឬយាងទៅពួនក្នុង

ឧម្ពោតបុប្ជាកទលី ឬបំពេញបំណងនៃស្រីស្នំទាំងនោះ ។ នេះហើយ ដែលព្រះមហាក្សត្រវិក្រមទិត្យ ទ្រង់ក្រសាលលេងសប្បាយដោយព្រះ រាជតម្រេកជាលោកិយក្នុងរដូវកាល ។

ក្នុងព្រៃនោះ មានតាបសម្នាក់បានចំរើនអត្តកិលមដ្ឋានុយោត (គឺ ការធ្វើខ្លួនឲ្យលំបាក) ជាយូរណាស់មកហើយ បានមកទស្សនានូវព្រះរាជ-ទ្យានដែរ ។ ដល់ត្រាច់មើលក្នុងទីនោះ តាបសក៏មានតំនិតប្រែប្រួល ។ ព្រះមហាក្សត្រទ្រង់ត្រាស់សួរថា (ទ្រយោគី! ដោយហេតុអ្វីបានជាអ្នក ចូលមករកយើងក្នុងទីនេះ? ។ យោគីនោះក្រាបបង្គំទូលថា "បពិត្រ មហារាជ! ទូលបង្គំបានប្រព្រឹត្តធ្វើបាបរូបកាយនេះនៅក្នុងព្រៃអស់កាល យូរហើយ ។ ឥឡូវនេះ អាទិទេពដែលទូលបង្គំបួងសួង បានអនុត្រោះ ទូលបង្គំជាយ៉ាងក្រៃលែង ហើយបង្គាប់ទូលបង្គំថា "ចូរឯងទៅគាល់ព្រះ បាទវិក្រមទិត្យចុះ, ទ្រង់នឹងបំពេញនូវសេចក្តីប្រាថ្នារបស់ឯងមំនឲាន" ព្រោះហេតុដូច្នោះ បានជាទូលបង្គំចូលមកគាលព្រះអង្គ" ។

ព្រះបាទវិក្រមទិត្យ ទ្រង់ព្រះសណ្ឋាប់នូវស័ព្ទរាចាយោគីនោះហើយ ទ្រង់មានព្រះតំរិះថា "យោគីនេះ, ដោយមិនបានយល់ច្បាស់លាស់នូវ នំយសាស្ត្រ ក៏លះបង់ចោលសមាធិកម្មដ្ឋាន, យោគីនេះ ទៅជាអ្នកមាន ទុក្ខក្នុងខ្លួន មានតណ្ហាប្រាថ្នាចង់បានសប្បាយក្នុងកិលេសកាម បើ យោគីនេះ មានទុក្ខមែន ត្រូវអញបំពេញនូវបំណងនៃអ្នកដែលមានទុក្ខ" ដល់ទ្រង់ព្រះតំរិះយ៉ាងដូចនេះ ទ្រង់ក៏សម្រេចក្នុងព្រះទ័យថា "នៅ កណ្ឋាលទីក្រុង ទ្រង់នឹងត្រាស់បង្គាប់ឲ្យគេសងគេហដ្ឋានដ៏វិចិត្រ" លុះ

ជាងសង់ហើយទ្រង់ព្រះរាជទានទៅយោគីនោះ ។ ទ្រង់បានព្រះរាជ-
ទាននូវកញ្ញាមួយរូបជាត់ដែលមានពាក់គ្រឿងអលង្ការគ្រប់យ៉ាង, ភូមិ
មួយរយ, គោគទ្រព្យជាច្រើន, ទាសានឹងទាសី, គោញី, ក្រមី,
ជំរី, សេះ ។ល។ ដល់សម្រេចកិច្ចហើយ ព្រះអង្គទ្រង់សុពណិបាទ
មានបុត្ទានុភាព ទ្រង់ហោះទៅលើអាកាស ចូលទៅក្នុងព្រះរាជធានី
លឿនជូចព្រះពាយ ។ ចំណែកឯយោគីនោះ ក៏គ្រកត្រអាលតាមចិត្ត
ចំណងគ្រប់ប្រែបគ្រប់យ៉ាង នៅក្នុងទីនោះ ។

រូបទេពនិម្មិតទីប្រាំ បានក្រាបបង្គំទូលមហារាជគោជ:ថា "បពិត្រ
មហារាជ: ! បើទ្រង់មានព្រះទ័យសប្បុរសស្មើនឹងព្រះបាទវិក្រមទិត្យ,
ទ្រង់អាចគង់នៅលើបល្ថ័ង្ក្ទិព្ទនេះបាន" ។

ក្នុងពេលនោះ, ព្រះមហាក្សត្រគោជ: ក៏ទ្រង់យាងចេញអំពីទី
នោះទៅ ។

* * *

និទាននៃរូបនិម្មិតទីប្រាំមួយ

ព្រះមហារាជគោជ: ទ្រង់បានសម្រេចព្រះរាជហ្ឫទ័យម្ពងទ្រៀតថា
នឹងចាត់ឲ្យគេធ្វើមុត្ទាភិសេកទ្រង់ឲ្យសោយរាជ្យពេញលក្ខណ: ទ្រង់ក៏
យាងតម្រង់ទៅកាន់បល្ថ័ង្ក្ទិព្ទនោះ ។ ក្នុងពេលនោះ រូបទេពនិម្មិតទី ៦
សើចហើយក្រាបបង្គំទូលថា: "បពិត្រព្រះមហារាជ សូមទ្រង់ជ្រាប:
អ្នកណាមួយបានធ្វើសប្បុរិសទាំនជួយឧបត្ថម្ភអ្នកដទៃ ជូចព្រះបាទវិក្រម-
ទិត្យ អ្នកនោះទើបអង្គុយនៅលើបល្ថ័ង្ក្ទនេះបាន" ។ ព្រះមហារាជគោជ:

ទ្រង់មានបន្ទូលសួរថា "ចុះការជួយឧបត្ថម្ភអ្នកជវិទនៃព្រះបាទវិក្រមទិត្យ
នោះយ៉ាងណាទៅ?" ។ រូបទេពនិម្មិតទីប្រាំមួយនោះក្រាបបង្គំទូលថា
"សូមទ្រង់សូមយកវីរកាពមកជាមូលដ្ឋានក្នុងកិច្ចការដែលទ្រង់ព្រះតម្រិះ
ព្រះបាទវិក្រមទិត្យទ្រង់សោយរាជ្យសម្បត្តិ នៅទីក្រុងអវន្ទី ទ្រង់បាន
ត្រួតត្រាប្រទេសឯទ្រៀតជាច្រើន ។ ប្រជារាស្ត្រដែលនៅក្នុងកូមិកាតនៃ
អធិប្រទេសរបស់ព្រះអង្គ បានប្រតិបត្តិនូវករណីយកិច្ចតាមវណ្ណៈតប់ៗ
ត្នា មិនដែលប្រមាទសោះឡើយ, ពួកនេះបានប្រព្រឹត្តតាមឧវាទនៃ
សាស្ត្រ, លះបង់នូវអំពើទុច្ចរិត ព្យាយាមតែជួយត្នាទៅវិញទៅមក ។ នៅ
អវសាននៃជីវកាព, អ្នកទាំងអស់នេះ មិនបានស្តាប់នូវស័ព្ទវាចាថា ពាក្យ
ភូតភរកុហក គឺបដិសេធជាអហង្ការ មិនជឿនូវជីវកាពអនាគត ហើយ
ជោយយល់រូបកាយនេះ មិនអាចស្ថិតស្ថេរនៅយូរប៉ុន្មាន, ក៏ពិចារណាជា
និរន្តរ៍នូវវិធីប្ដមធ្យាបាយ ដែលទៅកាន់ព្រំលឹងធំ គឺព្រះអាទិទេព ។

នៅក្នុងទីក្រុងនោះ មាននាយពាណិជម្នាក់ឈ្មោះ ធនទត្ត
(Dhanadatta) ។ ធនទត្តនេះ ជាសេដ្ឋីមានកោតទ្រព្យជាច្រើនអស្ចារ្យ
សូម្បីតែទ្ធូនតាត់ក៏មិនដឹងនូវចំនួននៃកោតទ្រព្យនោះឡើយ, ហើយតាត់
មានវត្ថុជាច្រើនបែប, វត្ថុណាដែលត្មាននៅទីក្រុងឯទ្រៀត តាត់មាន
ទាំងអស់ ។ មានមួយថ្ងៃ ធនទត្តគិតថា "ការធ្វើអំពើល្អសម្រាប់
យកទៅប្រើប្រាស់ក្នុងបរលោក បើអញត្មានព្យាយាមរកនូវគុណធម៌
ទាំងនេះទេ តើជោគវាស្នាអញក្នុងកាលជាអនាគតយ៉ាងណាទៅ?" ។
គំនិតនេះតាត់បានកំណត់ក្នុងចិត្តតាត់ស្រេច, តាត់ក៏ចំណាយកោតទ្រព្យ

នោះ ចែកទៅជាទានដោយចិត្តសប្ប្យរសជាយ៉ាងក្រៃលែង, រួចតាត់ក៏
អញ្ជើញទៅទស្សនានូវស្រះពិសិដ្ឋ ។ ដល់តាត់មើលលេងកំសាន្តនូវ
ស្រះពិសិដ្ឋទាំងនោះ, តាត់ ទៅដល់កោះមួយនៅក្នុងសមុទ្រ ។ ភៅទី
នោះ មានបូជនិយដ្ឋាននៃអាទិទេពមួយនៅជិតបូជនិយដ្ឋាននោះ មាន
បឹងមួយ, ហើយនៅទិសទាំងបួននៃបឹងនោះមានតិរវិថី(១)មួយ ក្រាល
សុទ្ធតែត្សូងនឹងថ្មកែវ ។ តាត់បានឃើញនៅទីនោះ នូវស្ត្រីម្នាក់មានរូប
ធោមលោមពណិស្អាតអស្ចារ្ស នឹងបុរសម្នាក់ល្អដូចទេវតា, តែក្បាលអ្នក
ទាំងពីរគេកាត់ដាច់; ក្បាលនេះស្ថិតនៅដោយឡែក, ហើយនៅជិតក្បាល
នោះមានថ្មមួយ(២) ដែលគេចារិកអក្សរទុកថា "បើបុគ្គលណាមានចិត្ត
សប្ប្យរស កាត់ក្បាលខ្ជូនបូជាទៅអាទិទេព មនុស្សប្រុស - ស្រីទាំងពីរ
នោះអាចមានជីវិតឡើងវិញបាន" ។ ធនទត្ត បានឃើញនូវរឿងរ៉ាវប្លែក
អស្ចារ្សដូចនេះ ក៏ចេញពិបឹងនោះវិលត្រឡប់មកកាន់គេហដ្ឋានវិញ ។

មានមួយថ្ងៃ, ក្នុងកិច្ចសន្ធនាការជាមួយព្រះមហាក្សត្រ ធនទត្ត
បានក្រាបបង្គំទូលព្រះអង្គនូវរឿងរ៉ាវខាងលើសព្វគ្រប់ ។ ព្រះអង្គទ្រង់
ព្រះសណ្ឌាប់នូវសំព្ធរាចានៃធនទត្ត, ទ្រង់មានព្រះទ័យធ្ងល់ពន់ពេក
ហើយមានព្រះបន្ទូលថា "ធនទត្ត, អ្នកទៅជាមួយនឹងយើងកាន់ទីនោះ
យើងចង់យើញរបស់ប្លែកនោះយ៉ាងណាទៅ?" ។ ព្រះមហាក្សត្រិយ៍

---

១ តិរវីថី គឺផ្លូវក្បែរមាត់ប្រាំងនៃបឹងនោះ ។ ២ ទម្លាប់សរសេរនៅលើថ្មនេះ គឺពិត
ព្រោះគេបានឃើញសិលាចារិកមានជាច្រើនកន្លែងប្រហែលជា ៥០ ឆ្នាំមកហើយ, មិនមែនមាន
តែប្រទេសជណ្ឌៀនោះទេ ប្រទេសណាក៏មានដែរ ។

ទ្រង់សម្រេចដោយព្រះអង្គឯងដូចនេះ ទ្រង់ក៏យាងទៅជាមួយនឹងធនទត្ត
កាន់ទីនោះ ។ ដល់ទ្រង់យាងទៅដល់, ទ្រង់បានទតយល់ឆ្វឹងក៉វដូច
ជា ធនទត្ត បានក្រាបទូលទ្រង់ពីមុន ។ រួចទ្រង់ព្រះតម្រិះដូចនេះថា
"អ្នកដែលគេទុកកជាទត្តមបុរស តែងលះបង់ជីវិតរបស់ខ្លួន ដើម្បី
ប្រយោជន៍អ្នកដទៃ, បើអញបូជាជីវិតអញ, រូបនៃបុគ្គលទាំងពីរទាំង
បុរសស្ត្រី នឹងមានជីវិតរស់នៅឡើងវិញ នេះជាសកម្មភាពដ៏ទត្តម; ត្រូវ
តែប្រព្រឹត្តបែបនេះជាជាច់ខាត, បើទុកជាគេថ្នាក់ថ្នមរូបយ៉ាងណា គេក៏
មិនអាចរួចផុតពីសេចក្តីស្លាប់, បើគេធ្វើការដើម្បីប្រយោជន៍អ្នកដទៃ
គេអាចទទួលមរណភាព តែដល់ទៅក្នុងបរលោក គេបានដោតរាសនា
ដ៏ប្រសើរ" ។

ព្រះបាទវិក្រមទិត្យ ទ្រង់មានព្រះចិន្តាដូចនេះ ទ្រង់យាងទៅសេង់
ព្រះទទក: ក្នុងបឹងនោះ រួចទ្រង់លើកព្រះទ័នថ្ងា ដើម្បីនឹងកាត់ព្រះសីរ
ព្រះអង្គ, តែក្នុងពេលនោះអាទិទេព បានចាប់ព្រះហស្តព្រះអង្គទុក
ហើយក្រាបទូលថា "ទមហារាជ ព្រះអង្គជាទត្តមបុគ្គល ទូលបង្គំសប្បាយ
ចិត្តនឹងទ្រង់ពន់ពេក ។ ចូរមហារាជមានព្រះរាជបំណងចង់សូមអ្វីពីទូល
បង្គំ។ នឹងធ្វើឲ្យសម្រេចបាន" ។ ព្រះមហាក្សត្រទ្រង់មានបន្ទូលតបទៅ
នឹងអាទិទេពវិញថា "ទអាទិទេព, បើព្រះអង្គចង់អនុគ្រោះចំពោះយើង,
សូមឲ្យព្រះអង្គធ្វើឲ្យមនុស្សទាំងពីរនាក់ ទាំងបុរសស្ត្រីឲ្យមានជីវិតឡើង
ហើយប្រគល់រាជបល្ង័ង្គឲ្យអ្នកទាំងពីរសោយរាជ្យជាស្តេចនៅទីនេះ ។ អា
ទិទេពទ្រង់ព្រះសណ្តាប់នូវមហារាជមានព្រះទន្ទ្រារដូចនេះ ទ្រង់ក៏ក្រាបទូល

ថា ឧមហារាជវិក្រមទិត្យ ទ្រង់ជាមហាបុរស, ដើម្បីនឹងធ្វើប្រយោជន៍ចំ-ពោះជនដទៃ ទ្រង់គិតនឹងធ្វើពលិកម្មនូវជីវិតទ្រង់" ។ ហើយអាទិទេព នោះក៏ធ្វើឲ្យមនុស្សទាំងពីរនាក់ទាំងបុរសនឹងស្ត្រីឲ្យមានជីវិតរស់ឡើងវិញ ហើយប្រគល់រាជសម្បត្តិឲ្យសោយនៅទីនោះ រួចក៏បាត់ពីទីនោះទៅ ។ ដោយសេចក្តីអនុគ្រោះនៃអាទិទេព មនុស្សប្រុស-ស្រីនោះ ដូចជាមនុស្ស ដេកលក់ក្រោកឡើងដោយមានគេទៅជាស់ក្រោកឡើង ។ គ្រឲ្យប់ទៅជា ព្រះមហាក្សត្រ នឹងព្រះអគ្គមហេសីនៅទីនោះ ។ ចំណែកព្រះមហាក្សត្រ វិក្រមទិត្យ ទ្រង់យាងត្រឲ្យប់ទៅកាន់ព្រះរាជធានីវិញ ។

រូបទេពនិម្មិតទីប្រាំមួយពោលបន្ទៃមថា "មហារាជសូមទ្រង់ ជ្រាបចុះ អំពើនេះហើយដែលនាំឲ្យព្រះមហាក្សត្រវិក្រមទិត្យទ្រង់អាច គង់នៅលើបល្ស៍ឯទិព្យនេះបាន" ។

ព្រះបាទភោជ: ទ្រង់ជ្រាបច្បាស់ថាទ្រង់គ្មានគុណសម្បត្តិបែបនេះ ទ្រង់ក៏យាងចេញពីបល្ស៍ឯទិព្យនេះទៅ ។

*

* *

(មានត)

កំណត់ធឹងប្រវត្តិការណ៍

ពិធីហៅព្រះសារីរិកធាតុ

ពីប្រទេសសិរីលង្កា មកព្រៃនគរ

ព្រះញាណកោសល ញាណ - ឈឹន រៀបរៀង

ពិធីហៅព្រះសារីរិកធាតុនេះបាត់ជា ៥ ផ្នែកដូចមានខាងក្រោមនេះ

- ១ – និយាយពីហេតុដើម
- ២ – និយាយពីរបៀបតាំងតុសក្ការៈ
- ៣ – និយាយពីពិធីហៅព្រះសារីរិកធាតុ
- ៤ – និយាយពីកោដ្ឋមាស - ប្រាក់
- ៥ – និយាយពីកម្មវិធីបុណ្យ

១ – ហេតុដើម

កាលពីក្នុងឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ គ.ស. ១៩៥៣ នោះ ព្រះមហានារទត្ថេរកោះលង្កា បាននិមន្តព្រះសារីរិកធាតុមកដំកល់ទុកនៅវត្តជេតពនព្រៃនគរជាដើម ។ កាលនោះក្រុមពុទ្ធបរិស័ទអ្នកជ្រះថ្លាជាច្រើននៅដែនកូស័ងស៊ីន មានលោក សឹង - ថាយ - ផ្ទៀងជាតំណាង បានស្នើសុំឲ្យព្រះថេរៈអង្គនេះ និមន្តព្រះសារីរិកធាតុមកឲ្យយើងខ្ញុំបានមួយអង្គផង ។ ពីត្រឹមឆ្នាំនោះរហូតមក ទើបនឹងសម្រេចថាបានព្រះសារីរិកធាតុក្នុងថ្ងៃអង្គារ ២ រោចខែចេត្រឆ្នាំមមីធស័ក ព.ស. ២៤៩៧ (១៩ មេសា ១៩៥៥) នេះ ។

២- របៀបតាំងតុសក្ការ:

ពិធីរៀបចំតាំងតុសក្ការ:នេះ មុខគួរឲ្យស្តាយណាស់ ព្រោះវត្ត ចន្ទរង្សីមានទីចង្អៀតពេកមិនល្មមនឹងការតាក់តែង ។ សម្ប៉ីយ៉ាងនោះ ក៏ដោយ ក៏គង់លោកសឹង-ថាយ-ង្វៀង អាចចាត់ការល្មមគួរជាទីជ្រះ ថ្លាបាន តាមបន្ទាល់ជូចបានជកស្រង់តោលៗ ខ្ញុះមករៀបរៀងក្នុងទីនេះ ៖

មុនដំបូងលោកដំណាង មានលិខិតប្រគេន-ជូនដំណឹងទៅខែត្រ នានានៅដែនកូសំងស៊ីនអំពីរឿងបុណ្យ នៅថ្ងៃអង្គារ ១២ រោចខែចេត្រ ឆ្នាំមមីធស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃ ១៩ មេសា ឆ្នាំ ១៩៥៥ នេះ ។

លុះដល់កំណត់ថ្ងៃជូចខាងលើនេះហើយ ទើបគណ:កម្មាធិការ នាយកចាត់វិធានការជូចមានតទៅគឺ:

ក) រួមខែត្រព្រែកប្រស្សឹ, ខែត្រនេះមានតាំងតុសក្ការ:១ នៅ ខាងទិសនិរតីវត្ត ឈមមុខមកខាងកើត ចារឹកអក្សរធំៗ លើផ្ទាំងសំពត់ ពណិលឿងជាសញ្ញាឈ្មោះខែត្រនឹងថែមពាក្យថា "ជយោ! ព្រះសារីរិក-ធាតុ" ។ ឯខាងក្នុងសាលសឹងពាសពិតានសំពត់ពីខាងលើ ចងស្ទឹក ឈើផ្តាឈើស្រស់ខៀវស្រងាត់ រំលេចជួងក្ងើងអគ្គិសនីក្ងឺព្រោងព្រាត ជូចពន្ធឹផ្តាយបញ្ចេញរស្មីតាមស្រទាប់ពពក ។

សសរទាំងឡាយត្រប់ៗ ស្ទែង សឹងស្រោបស្ទឹកឈើស្រស់ហើយ ពន្ធេចពណ៌ផ្តាក្រជាសក្ងឺរន្ទាល មុខគួរឲ្យចង់ក្រឡេកមើលមិនជាក់ក្នែក ហើយតែងទង់ជាតិនឹងទង់សាសនា តាមលំដាប់ជួរសសរពីខាងមុខ ។

ផ្ទៃសាលាឆាឆក្រោម គេរៀបតុ-កៅអីត្រប់ៗ ល្វែងសម្រាប់ទទួលបណ្ណាជន ដែលមកធ្វើសក្ការៈព្រះសារីរិកធាតុនឹងសម្រាប់ព្រះសង្ឆគង់ ។

ត្រង់តុតាំងសក្ការៈសឹងរចនាចាក់ចេក ភាពបុស្ឋុកមានស៊ុមទ្វារជា ៤ សណ្ឋាន មានកំពូលស្រួច ហើយតាំងសុទ្ធតែរបស់មានជំទ្បែប្ទែក ៗ ផ្សេង ៗ ទោះជារបស់ទំនើបក្តី របស់បូរាណក្តី មានចានជ្ជាន់ពែងរូបចម្ទាក់ជាដើម ជារបស់ចុះសម័យ ។ ល ។

លោកអ្នកចាត់ការដំណាងខែត្រនេះ បែកខាងព្រះសង្ឆយើញមានលោកត្រូ ជ្រាក់ ចៅអធិការវត្តពោធ៏សិរី, លោកត្រូ មៀច ចៅអធិការវត្តកំពង់ស្ពាន, លោកមហាឧត្តមវិជ្ជាចាច់-ជ្រាជ្ស; ប៉ែកខាងត្រហស្ទមានលោក ចាច់លី (ពលជ្ជាលត្រី) ក្នាក់ផាររាជការ យៀកណាមនឹងគណៈកម្ទការខែត្រ មានអ្នកអាចារ្យកងជាដើម ជាមួយនឹងក្រុមពុទ្ធបរិស័ទ្ធទាំងឡាយ ។

ខ) រួមខែត្រក្រម្ជនស, ខែត្រនេះ មានតាំងតុសក្ការៈ ១ នៅទិសបស្ចិមព្ធដ៏ខាងក្រោយសាលាជំនុំរបស់វត្ត; ការរៀបចំស្រដៀងគ្នាមានសរសេរអក្សរធំ ៗ លើជ្ជាំងសំពត់ជាសញ្ញាជូចខែត្រឯទៀតដែរ ។ លោកអ្នកចាត់ការដំណាងខែត្រនេះ ប៉ែកខាងព្រះសង្ឆយើញមានព្រះតេជព្រះគុណមេគណខែត្រក្រម្ជនស នឹងគណៈកម្ទការរបស់លោកទាំងព្រះសង្ឆទាំងត្រហស្ទជាច្រើន ។ ល ។ ។

គ) រួមខែត្រព្រះត្រពាំង ខែត្រនេះ មានតាំងតុសក្ការៈ ១ ក្នុងសាលាជំនុំរបស់វត្តនៅទិសនិរតីនៃព្រះវិហារ មានសរសេរអក្សរធំ ៗ

លើផ្ទាំងសំពត់ជាសញ្ញាសម្រាប់ខែត្រនោះ ។ លោកអ្នកចាត់ការតំណាងខែត្រ ប៉ែកខាងព្រះសង្ឃឃើញមានព្រះតេជព្រះគុណ អនុគណវត្តចេកជំជាប្រធាន ទឹងសហការីរបស់លោកគឺ លោកមហាថាប់-ជាត់ វត្តពិស៊ី, លោកគ្រូសូត្រ ស៊ុជាន់, លោកគ្រូសូត្រ ហាស់ វត្តពោធិ៍សាលភជ, ប៉ែកខាងគ្រហស្ថឃើញមានអ្នកអាចារ្យ ចៀង សំភប់វត្តពិស៊ី ទឹងគណៈកម្មការសម្រាប់ខែត្រនោះ ។ ល ។ ។

ឃ) រួមខែត្រពល់សារ, ខែត្រនេះ មានតាំងតុសក្ការៈ ១ នៅទិសបស្ចិមនៃព្រះវិហារ មានគណៈកម្មការខែត្រតាំងព្រះសង្ឃចាំងគ្រហស្ថជាច្រើននាក់ចាត់ចែងបុណ្យមានសរសេរអក្សរធំៗ លើផ្ទាំងសំពត់ជាសញ្ញាសម្រាប់ខែត្រដូចទីឯទៀតដែរ ។ ល ។ ។

ង) រួមខែត្រឃ្លាំង, ខែត្រនេះ មានតាំងតុសក្ការៈ ១ នៅខាងទិសឧត្តរនៃព្រះវិហារ មានសរសេរអក្សរធំៗ ជាសញ្ញាសម្រាប់ខែត្រដែលលោកអ្នកចាត់ការតំណាងខែត្រ មានព្រះតេជ-គុណព្រះនាមអិម ចៅអធិការវត្តពោធិ៍ជាអ្នកបំញ្ជាការ ជាមួយទឹងគណៈកម្មការខែត្រនោះ ។ ល ។ ។

ច) ទីក្រុងព្រៃផគរ, មានពុទ្ធបរិស័ទជាតិកម្ពុជាទឹងយៀកណាមមកពីចំណុះវត្តចំងបីគឺ: វត្តចន្ទរង្សី ១, វត្តពោធិ៍រង្សី ១, វត្តជេតពន ១ រួមគ្នាតាំងតុសក្ការៈជាមួយគ្នា នៅខាងទិសទក្សិណនៃព្រះវិហារ ។ មានមន្ទីរយោសនាការ ១ ទៀតនាស្លែងជាន់ក្រោមត្រង់កុដិចាក់បេតុងល្អស្អាត

នៅខាងត្បូងព្រះវិហារដែរ មានប្រាសាទតូចមួយ ដែលមានលោក សឹង-ថាយ ផ្ទៀង ជាប្រមុខ អ្នកចាត់ចែងការ ។ ល ។ ។

ឯខាងកើតព្រះវិហារថ្មី មានតាំងតុសក្ការៈសម្រាប់ដាក់ព្រះសារីរិកធាតុពីខាងមុខបង្អស់ ដែលមានគូឈើវិសេសពីរអមសងខាងសម្រាប់ទទួលថាវិញ្ញាណធាតុជាពុទ្ធបូជា មានគ្រាលអាសនៈគឺកន្ទេល ព្រំល្អ។ ពេញតាំងព្រះវិហារសម្រាប់ព្រះសង្ឃគង់ ។

៣ – ពិធីបែងព្រះសារីរិកធាតុ

ពីរសៀលចំណតអាកាសយានឆ្ពោះវត្តចន្ទរស្មីព្រៃនគរវេលាម៉ោង ១៣ ថ្ងៃសៅរ៍ ២ កើតខែពិសាខឆ្នាំមមែសប្តស័ក ព. ស. ២៤៩៨ (២៣ មេសា ១៩៥៤) ព្រះនាវខ្ចោរ នាំព្រះសារីរិកធាតុ ឆ្ពោះមកពីសិង្ហបុរីសំដៅព្រៃនគរ, វេលានោះពួកព្រះសង្ឃបែកខាងក្នុងចេញ មានព្រះវិនយសង្ឃរក្ស-កឹង សាស្ត្រាចារ្យសាលាជាឡីជាន់ខ្ពស់, ព្រះគ្រូប៉ាង វត្តសាកម៉ែន, ព្រះគ្រូ ថាញ់ ចៅអធិការវត្តតេនាកម, ព្រះមេគណ អនុគណ ចៅអធិការឧបជ្ឈាយ៍ ដែលនិមន្តមកអំពីនានាខែត្រនៅកម្ពុជាក្រោមនឹងព្រះសង្ឃចិនយួន ព្រមទាំងពុទ្ធបរិស័ទបព្វជិតគ្រហស្ថទាំងប្រុសស្រី ពាក់សែនៗនាក់ ដែលមានគណៈប្រតិភូខ្មែរនិងគណៈកម្មការព្រៃនគរ ជាអ្នកត្រួតត្រានាំគ្នារង់ចាំនៅចំណតអាកាសយាន ។

លុះអាកាសយានចតឈប់ស្ងួលបួលហើយ ព្រះសង្ឆ ៤-១០ អង្គ ចូលទៅទទួលព្រះសារីរិកធាតុនាំហែចេញមក ព្រះសង្ឆច្រើនអង្គ ឈរតម្រៀបជាពីជួរអមសងខាងផ្លូវ តាំងពីអាកាសយានដរាបដល់រថយន្ត ដែលមានត្រឿងតាំងភាពបុស្ស្ពុកសម្រាប់ដំកល់ហែ មានអាចារ្យពីររូប ស្ងៀកពាក់សកាន់ក្ងស់ចាំងថ្ងាយ ។

ឯក្ស្ងនហែជូចមានខាងក្រោមនេះ

ក) ទោចក្រិយានយន្ត (ម៉ូតូស៊ីក (motocycle) ៣ គូ ជិះបរ សន្សឹម ៗ យោងមុខ ។

ខ) រថយន្តតូច ៗ ប៉ី សម្រាប់គណៈ ប្រតិភូនឹងគណៈកម្មការអ្នក ចាត់ក្ស្ងន ។

គ) រថយន្តភាពបុស្ស្ពុកដំកល់ព្រះសារីរិកធាតុ មានអាចារ្យចាំង ក្ងស់ថ្ងាយ ។

ឃ) អ្នកកាន់ផ្ទាំងសំពត់ចារឹកអក្សរសម្រាប់ក្រុមនីមួយ ៗ ដែលបាន មកហែជាចន្ទោះ ៗ ។

ង) អ្នកកាន់ទង់សាសនាដើរអមទាំងសងខាងតាមលំដាប់លំដោយ ត្នា, ក្រុមព្រះសង្ឆសូត្រនមស្សការ និមន្តជាប់ជាមួយនឹងរថបុស្ស្ពុក, ក្រុមគ្រហស្ថដើរតម្រៀបជាជួរ ៗ ហែតាមក្រោយ អ្នកខ្ទះកាន់ផ្ការ៉ី អ្នក ខ្ទះកាន់ទៀនធូបមានបណ្តោយប្រវែង ៥ គីឡូម៉ែត្រ, រថយន្តតូច ធំជា ច្រើនបើកតាមក្រោយ មនុស្សអ្នកឈរមើលក៏ឈរត្រៀបត្រាគ្រប់ថ្នល់

ត្រប់ប្រកល្ហកទាំងស៊ីវិល-ទាហាននឹងមន្ត្រីរាស្ត្រជាតិយៀកណាមនៅក្រុងត្រៃនគរនោះ ។

ចម្ងាយពីចំណតអាកាសយានមកអស់រយៈវេលា ៥ មោ៉ង គឺពីមោ៉ង ១៣ ដល់មោ៉ង ១៨ ទើបបានដល់វត្តចន្ទរង្សី ។

៤– កោដ្ឋដំកល់ព្រះសារីរិកធាតុ

កោដ្ឋនេះ មានពីរប្រភេទគឺ: កោដ្ឋប្រាក់ពីខាងក្រៅ ១ ស្ពូបមាសនៅខាងក្នុង ១ ។

កោដ្ឋប្រាក់ មានទំហំ ០ម៉ា,៥០ ប្លូនជ្រុង មានកំពស់ពីត្រឹមដើងកោសឡើងដល់ក្បាំង ០ម៉ា,៥០ មានកំពូល់ពីត្រឹមក្បាំងឡើង ០ម៉ា,៥០ រួមកំពស់ ១ ម៉ែត្រគត់ មានកញ្ចក់ទាំង ៤ ជ្រុង សណ្ឋានដូចទូធម្មតា, រួមទម្ងន់ប្រាក់ចំនួន ១៨ គីឡូក្រាម, ប្រាក់ទាំងនេះបានមកអំពីសញ្ចាលង្ការទាំងពួងដែលចាស់ត្រាំត្រាបាក់បែកខ្ទះ ។

ស្ពូបមាស រាងមូលមានទំហំ ០ម៉ា,៦០ រាស់ត្រង់កណ្ណាលមានកំពស់បល្ទ័ង្ក ០ម៉ា,១០ នឹងទំហំបល្ទ័ង្ក ០ម៉ា,១០ គំរបកំពូលមានទំហំ ០ម៉ា,១០ មានកែវចរណៃមូលក្ដាប់នឹងកំពូល រួមកំពស់ស្ពូបប្រមាណ ០ម៉ា,៦៥ មានដើងពានមាសសុទ្ធតូច ១ តក្ដាប់នឹងបល្ទ័ង្កសម្រាប់ដំកល់ព្រះសារីរិកធាតុ រួមទម្ងន់មាសចំនួន ០គ.ក្រ.៦៣០ មាសទាំងនេះបានមកអំពីសញ្ចាលង្ការទាំងពួងដែលចាស់ត្រាំត្រាបាក់បែកខ្ទះ ។

កោដ្ឋនេះជាស្នាដៃជាងដែលល្បីឈ្មោះនៅក្រុងភ្នំពេញគឺ លោក

ជា-ប្ជុង ទីប្រឹក្សាជាតិ ក្រសួងព្រឹទ្ធ្យសភា អ្នកចាត់ចែងការ ទាំងបានជួយប្រាក់ជាច្រើនក្នុងការកសាងកោដ្ឋនេះ នឹងលោក ទ្រៀង-ឆៅ ទីឧកញ៉ាបំណានប្រើជាគ្រូរចនាដើមវិទ្យផុតលេខ អ្នកតាក់តែងក្សូរក្សាច់ ហើយចាត់ការធ្វើដរាបដល់បានសម្រេច ។

ឯអ្នកម្ចាស់កោដ្ឋ គឺក្រុមពុទ្ធបរិស័ទ បព្ទជិតគ្រហស្ថក្នុងវិទត្រ ទាំងឡាយនៅកម្ពុជាក្រោម មានលោកសឹង-ថាយ-ង្វ្រង ជាអ្នកផ្តើម ។ លុះដល់ម៉ោង ១៦ ថ្ងៃសុក្រ ១ កើតវិទឆ្នាំដដែល ទេបព្រះញាណកោសល ញាណ-ឈឹន ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ លោក ល្ងៃ-ហុង មេហាងកុមារពេទ្យនៅផ្សារធំថ្មីគ្នំពេញ លោក ហាប់-ញាណ អតីតចៅហ្វាយស្រុកកិត្តិយសបម្រើរបស់លោក សឹង-ថាយ-ង្វ្រង ទៅទទួលយកកោដ្ឋអំពីលោក ជា-ប្ជុង បម្រុងនឹងនាំយកទៅឯត្រៃនគរ ។ ដល់ព្រឹកឡើងម៉ោង ១០ នឹង ៣០ ថ្ងៃសៅរ៍ វិទ ឆ្នាំដូចខាងលើ ទេបព្រះញាណកោសល, កុមារពេទ្យ, ព្រះមហាប៉ាង-ខាត់ បាននាំកោដ្ឋនោះឆ្ពោះថ្ពានត្រៃនគរ ។ ម៉ោង ១៨ នឹង ៣០ បាននិមន្ត-អញ្ជើញទៅដល់វត្តចនូរង្សី ជាបន្ទាប់រវលាដែលគេហៃព្រះសារីរិកធាតុមកដល់វត្តនេះដែរ ។ បណ្តាក្រុមពុទ្ធបរិស័ទជាច្រើនពាន់នាក់រង់ទន្ទឹងមើលផ្ទូរ លុះដឹងថាកោដ្ឋមកដល់ហើយ ក៏មានសេចក្តីសោមនស្ស រីករាយឥតឧបមា អ្នកខ្ចះទះដៃស្រែកហ៊ោ អ្នកខ្ចះទទួលសាធុ! អ្នកខ្ចះ ស្រែកជយោ! ប្រគេនស័ព្ទសាធុការពរអឹងកងចំពោះលោកទាំង ៣ រូប

ជូចមាននាមខាងលើ រួចហើយនាំឡើងទៅកាន់ព្រះវិហារ ដំកល់ព្រះ
សារីរិកធាតុកុងត្រានោះឯង ។

៥ – និយាយអំពីកម្មវិធីបុណ្យ

ថ្ងៃទី ១: នៅថ្ងៃ ៦ ៣ ៦ ឆ្នាំមមែសប្ពស័ក ព.ស. ២៤៩៨ (២៤-
មេសា ១៩៥៥) លោកសឹង ថាយ-ផ្ទៀង ឲ្យប្រជុំពុទ្ធបរិស័ទនៅវត្ត
ចន្ទរង្សី ព្រៃនគរ (ចែកកាតព្ទកិច្ច) ។

ថ្ងៃទី ២: នៅថ្ងៃ ៧ ៣ ៦ ឆ្នាំមមែសប្ពស័ក ព.ស. ២៤៩៨ (២៣
– ៤ – ៥៥) ។ មោ៉ង ១៣ ទទួលព្រះសារីរិកធាតុនៅទីធ្លាចំណត
អាកាសយានព្រៃនគរ ។ មោ៉ង ១៨ ហែព្រះធាតុទក្សិណព្រះវិហារ
វត្តចន្ទរង្សី ។ មោ៉ង ១៨, ៣០ អញ្ជើញកោដ្ឋឡើងកាន់ព្រះវិហារ
ដំកល់ព្រះសារីរិកធាតុ, បន្ទាប់មកព្រះនារទត្ថេរ លោករៀបរាប់ប្រវត្តិ
ដំណើរមកកាន់ទីក្រុងព្រៃនគរ ។ មោ៉ង ១៩ បើកឧកាសឲ្យពុទ្ធបរិស័ទ
ចូលធ្វើគារវកិច្ចចំពោះព្រះសារីរិកធាតុ ។ មោ៉ង ២០,៣០ គណកម្មការ
និមន្តព្រះនារទត្ថេរ សំដែងធម៌ទេសនាជាភាសាអង់គ្លេស, ព្រះមហា
ប៉ាង-ទាត់ ក្រុមដំនុំព្រះត្រៃបិដក ប្រែជាភាសាខ្មែរ, កិក្ខុ គូ-ផ្ទៀង ប្រែជា
ភាសាយៀមណាម ដល់មោ៉ង ២៤ អធ្រាត្រទើបចប់ ។ បន្ទាប់មកពួកអ្នក
ក្លេងប្រគំតូរ្យដន្ត្រី ល្បែងរាំវង់ ល្បែងផ្សេងៗ ច្រើនប្រភេទដរាបដល់ភ្លឺ ។

ថ្ងៃទី ៣: នៅថ្ងៃ ១ ៣ ៦ ឆ្នាំមមែសប្ពស័ក ព.ស. ២៤៩៨
(២៤-៤-៥៥) ។ មោ៉ង ៨ ប្រជុំពុទ្ធបរិស័ទដង្ហែព្រះសារីរិកធាតុ

មួយអង្គទៀតពីវត្តចន្ទរង្សីទៅកាន់វត្តព្រះសង្ឆចិន ប៉ែកខាងមហាយាន
នៅផ្សារធំ (ចើ-ឡើង (Chò-Lớn) ព្រៃនគរ ។ ម៉ោង ១៣ ១៤
ពុទ្ធបរិស័ទចូលធ្វើគារវកិច្ចទៀត ។ ម៉ោង ១៦ គណៈកម្មការនិមន្តព្រះគ្រូ
ថាញ់ ចៅអធិការវត្តរតនារាម ក្នុំពេញ សំដែងធម៌ទេសនាជាភាសា
យៀកណាម ប្រែបេញជាភាសាកម្ពុជា, ដល់ម៉ោង ១៨ ទើបចប់ ។
ម៉ោង ១៩ ប្រគេនកេសជ្ជៈព្រះសង្ឆតាមលំដាប់សាលបុណ្យ ។ ម៉ោង
២០,៣០ គណៈកម្មការនិមន្តព្រះញ្ញាណកោសល ញ្ញាណ-ឃីន សំដែង
ធម៌ទេសនាអំពីប្រវត្តិព្រះសារីរិកធាតុនឹងព្រះធាតុខ្មាតធំ-តូច របស់ព្រះ
គោតមបរមគ្រូជាអម្ចាស់នៃយើង, រវាង ៤០ នាទីទើបចប់ធម៌ទេសនា ។
ម៉ោង ២១,៣០ ព្រះមហាប៉ាង-ខាត់ សំដែងធម៌ទេសនាតទៅទៀត អំពី
ពុទ្ធគុណនឹងចរិយារបស់ព្រះអង្គដរាបដល់យប់ជ្រៅ ។ បន្ទាប់ពីនោះពួកអ្នក
ល្បែងគ្រប់ប្រភេទលេងមហោស្រពជាដើម ដរាបដល់ភ្លឺដូចយប់មុន ។ ។

ថ្ងៃទី ៤ នៅថ្ងៃ ២ ៤ ៦ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៥-
៤-៥៥) ។ ម៉ោង ១០,៣០ ព្រះញ្ញាណកោសល, ព្រះមហាប៉ាង-ខាត់
ព្រះគ្រូ ថាញ់ ចៅអធិការ វត្តរតនារាម, នឹងកុមារពេទ្យលូវ ហុង រិលត្រ
ឡប់ទៅក្នុំពេញវិញ ។ រវលាយប់នោះ ព្រះរិន័យសង្ឆរ រាជ-កឹង ព្រះ
គ្រូ វ៉ាង នៅចាត់ការបុណ្យតទៅ មួយយប់ទៀត ។ លុះដល់ថ្ងៃអង្គារ ៥
កើតខែពិសាខឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៦-៤-៥៥) ទើបធ្វង
សម្រេចកិច្ច ។ រឿងហេព្រះសារីរិកធាតុនេះ នៅមានបញ្ហាស្មុកស្មាញ

បង្សៃតជាសេចក្តីវិសេសជាងនេះប្រើនណាស់ ប៉ុន្តែអ្នកនិពន្ធជកស្រង់
យកតែតោល ។ មកបាវិកទុកក្នុងទីនេះជាសេចក្តីសង្ខេបដើម្បីនឹងឲ្យកើត
សទ្ធាជ្រះថ្លាត្រឹមបុំណ្ណោះ ។

មុននឹងបញ្ចប់ សូមសរសើរគ្នាក់ផ្ទារប្រតិកូស្ថានប្រទេសកម្ពុជាប្រ-
ចាំនៅក្រុងព្រៃនគរដែលមានលោកស៊ុំ ហ្រ៊ង អតីតសេនាបតីជាប្រមុខ
នឹងលោកស៊ឹង ថាយ-ង្ហ៊ង តំណាងប្រជាជនខ្មែរកម្ពុជាក្រោម លោក
ទាំងនេះ អាចពុសពារចាត់ការបុណ្យរបៀបសាសនាក្នុងចំណោមប្រទេស
យ្យៀកណាមឥតឲ្យមានរឧស្ថាន នឹងត្រូតត្រាពុទ្ធបរិស័ទរាប់សែននាក់
ឥតមានមោះមៃទ្បើយ ។

សូមថ្វាយស័ពួសាធុការពរចំពោះបរមក្សត្រប្រទេសទាំងពីរ នឹង
រជ្ជាភិបាលរបស់ទ្រង់ឲ្យបានតាំងនៅជាស្ថាពរអស់កាលដ៏លង់ ។ សូម
ឲ្យពុទ្ធបរិស័ទទាំងបញ្ចជិត ត្រហស្ថ នាចំណោមហ្រាព្រះសារីរិកធាតុនេះ
ជាដើម ឲ្យបានសម្រេចផលជាន់ខ្ពស់គួរតាមប្រាថ្នាក្នុងឥធលោកនឹង
បរលោក សូមមានសម្បត្តិព្រះនិញ្ចានជាអវសាន ។

របៀបសិក្ឃានៃសាលាបាលីជាន់ខ្ពស់

ដែលផ្ទាស់នាមថា "គ្រឹះស្ថានមធ្យមសិក្សានៃពុទ្ធសាសនា"

ពុទ្ធសាសនបណ្ឌិត្យ ស្រង់បាកព្រះរាជក្រិត្យ

តាមព្រះរាជក្រិត្យលេខ ២៦៥ ន.ស ចុះថ្ងៃទី ១៨ ឧសភា ឆ្នាំ ១៩៥៥ ព្រះករុណាជាអម្ចាស់ជីវិតលើត្យូង ទ្រង់ត្រាស់បង្គាប់ដូចមានខាងក្រោមនេះ ៖

ដើម្បីផ្សព្វផ្សាយមធ្យមសិក្សា នៃព្រះពុទ្ធសាសនា ហើយនឹងបណ្តុះបណ្តាលសិស្សទាំងឡាយ ឲ្យចូលទៅរៀននៅមហាវិទ្យាល័យពុទ្ធសាសនា របៀបរៀបចំនឹងរបបសិក្សានៃសាលាបាលីជាន់ខ្ពស់ ដូចដែលមានកំរិតហើយ តាមព្រះរាជក្រិត្យលេខ ១០៣ ន.ស. ចុះថ្ងៃទី ១៧ មីនា ១៩៥២ ត្រូវកែប្រែនឹងបំពេញដូចតទៅ:

សាលាបាលីជាន់ខ្ពស់ នឹងមាននាមថា "គ្រឹះស្ថានមធ្យមសិក្សានៃពុទ្ធសាសនា" ។

យានភាសាគឺភាសាជាតិ ។ របៀបបង្រៀនសព្វយ៉ាង លើកលែងតែជីវភាសាចេញ ត្រូវបង្រៀនជាខ្មែរ ។

ថិរវេលា នៃកិច្ចសិក្សាមានកំណត់ ៤ ឆ្នាំ ។ លក្ខខ័ណ្ឌនៃការចូលរៀននឹងការប្រឡងពិនិត្យ ដែលមានធ្វើនៅចុងឆ្នាំទី ៤ នៅតែប្រតិបត្តិតាមព្រះរាជក្រិត្យដូចខាងលើ ដោយត្រាន់តែយោលទៅរកការកែប្រែដែលមានបញ្ញត្តិក្នុងប្រការដូចតទៅ ។

ក្នុងករណីដែលសិស្សបានប្រឡងជាប់នៅវេលាក្រោយឆ្នាំទី ៤ នោះ

ការសិក្សាត្រូវមានការបំញ្ជាក់វិជ្ជា ដោយសញ្ញាប័ត្រមធ្យមសិក្សានៃពុទ្ធ-
សាសនា ។

ប៉ុន្តែសញ្ញាប័ត្រ នឹងត្រូវចេញឲ្យអ្នកប្រឡងជាប់បាន លុះត្រាតែ
បានអប់រំបន្ថែមមួយឆ្នាំទៀត នៅកន្លែងរៀនវេលានេះ សិស្សដែលប្រឡង
ជាប់ ត្រូវតែបំពេញវិជ្ជាខាងការបង្ហាត់បង្រៀន ឬខាងរបៀបរៀបចំ
សាលារៀនទៀត ។

ការហាត់ធ្វើការនេះ មិនមែនតម្រូវដល់សិស្សអ្នកប្រឡងជាប់ ដែល
ប្តូរថ្នាក់បន្តវិជ្ជាមហាវិទ្យាល័យនៃពុទ្ធសាសនាឡើយ ។

វិញ្ញាសាទាំងឡាយនៃការប្រឡងប្រជែង ដែលបានចែងខ្លឹមក្នុង
ប្រការ ១៥ នៃព្រះរាជក្រឹត្យខាងលើនេះ ត្រូវបន្ថយចំនួនមកនៅត្រឹមតែ
៤ មុខវិញ ៖

	មេគុណ	កំណត់ពេល
ទី ១ – សរសេរតាមសូត្រជាភាសាខ្មែរ ចំនួន ១៥ បន្ទាត់	២	១ ម៉ោង
ទី ២ – ប្រែអត្ថបទពីបាលីមកជាខ្មែរចំនួន ១៥ បន្ទាត់ ទៅ ២០ បន្ទាត់ ជាកន្លែងពីគម្ពីរអដ្ឋកថាធម្មបទ	៣	២ –
ទី ៣ – បញ្ហាវិន័យ ពីរគឺ ១ សម្រាប់កិក្ខុ, ១ សម្រាប់សាមណេរ	២	២ –
ទី ៤ – ការគិតបតុព្យូធលេខ	២	២ –

មុខវិជ្ជាបង្រៀនមានកំណត់ទុកក្នុងតារ៉ាងដូចខាងក្រោមនេះ៖

មុខវិជ្ជាបង្រៀន			ចំនួនម៉ោងរាល់សប្តាហ៍
ឆ្នាំទី ១ –	កាសាប្រចាំថ្នាក់	ចាលី	៨ ម៉ោង
		ខ្មែរ	១ –
	ជីវកាសា	ចាវាំង ជាកាតព្វកិច្ច (តាមជ្រើស)	៥ –
		អង់គ្រេស ឥតបង្ខំ (តាមជ្រើស)	២ –
	ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ	ប្រវត្តិសាស្ត្រ	២ –
		ភូមិសាស្ត្រ	១ –

		ចំនួនម៉ោងរាល់សប្តាហ៍
	គណិតសាស្ត្រ	៥ ម៉ោង
	វិទ្យាសាស្ត្រ ធម្មជាតិនឹងអនាម័យ	២ –
	ចំណេះវិជ្ជាទូទៅ: លោកនីតិ	១ –
ឆ្នាំទី ២ –	កាសាប្រចាំថ្នាក់	ចាលី	៦ –
		ស្មំស្ត្រឹត	៣ –
		ខ្មែរ	១ –
	ជីវកាសា	ចាវាំង ឬ	ជាកាតព្វកិច្ច (តាមជ្រើស) ៥
		អង់គ្រេស	ឥតបង្ខំ ៦
	ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ	ប្រវត្តិសាស្ត្រ	១ –
		ភូមិសាស្ត្រ	១ –
	គណិតសាស្ត្រ		៤ –

មុខវិជ្ជាបង្រៀន			បំនួនម៉ោងរាល់សប្តាហ៍
ឆ្នាំទី ៣ — កាសាប្រចាំថ្នាក់		ធម្មជាតិនឹងអនាម័យ	១ ម៉ោង
		ទិទ្យាសាស្ត្ររូបនិយម	២ —
		គីមី	១ —
		ចាលី	៦ —
		សំស្ក្រឹត	៣ —
		ទ្វេរ	១ —
ជីវកាសា	ចាវាំងឬ	ជាកាតព្វកិច្ច (តាមជ្រើស)	៥ —
	អង់គ្លេស	ឥតបង្ខំ (តាមជ្រើស)	២ —
ប្រវត្តិសាស្ត្រ · ភូមិសាស្ត្រ		ប្រវត្តិសាស្ត្រ	១ —
		ភូមិសាស្ត្រ	១ —
គណិតសាស្ត្រ			៤ —
ឆ្នាំទី ៤ — កាសាប្រចាំថ្នាក់		ធម្មជាតិនឹងអនាម័យ	១ —
		ទិទ្យាសាស្ត្ររូបនិយម	១ —
		គីមី	១ —
បំណោះវិជ្ជាទូទៅ: សាសនប្រវត្តិ			១ —
		ចាលី	៥ —
		សំស្ក្រឹត	៣
		ទ្វេរ	១ —

មុខវិជ្ជាបង្រៀន				បំនួនម៉ោងរាល់សប្តាហ៍
ជីវកាសា	បាវាំងឬ	ជាកាតព្វកិច្ច	(តាមជ្រើស)	៤ –
	អង់គ្លេស	ឥតបង្ខំ	(តាមជ្រើស)	៦ –
ប្រវត្តិសាស្ត្រ - ភូមិសាស្ត្រ		ប្រវត្តិសាស្ត្រ	.....	៦ ម៉ោង
		ភូមិសាស្ត្រ	.....	១ –
គណិតសាស្ត្រ			.....	៤ –
វិទ្យាសាស្ត្រ		ធម្មជាតិនឹងអនាម័យ	....	១ –
		វិទ្យាសាស្ត្ររូបនិយម	....	១ –
		គីមី	.....	១ –
ចំណេះវិជ្ជាទូទៅ		លោកនីតិ	.....	១ –
		អរិយធម៌ខ្មែរ	(សិល្បខ្មែរ)	១ –

កម្មវិធីពិស្តារសម្រាប់ធ្នាំសិក្សានីមួយៗ នឹងសម្រាប់មុខវិជ្ជាបង្រៀន នីមួយៗ នឹងត្រូវរៀបរៀងដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងធម្មការ តាមសេចក្តីស្នើសុំនៃគណកម្មការពិសេស ១ ក្រម ដែលបានតែងតាំងឡើងដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងធម្មការដែរ ។

វិញ្ញាសាសរសេរនៃការប្រឡងពិនិត្យយកសញ្ញាប័ត្រ ដែលមានចែងទុកក្នុងប្រការ ២១ នៃព្រះរាជក្រិត្យលេខ ១០៣ ន.ស. ចុះថ្ងៃទី ១៧ មីនា ១៩៥២ នោះ ត្រូវមានកំរិតត្រឹម ៧ ដូចតទៅ ។

លេខរៀង	វិញ្ញាសា	មេគុន	រយៈពេល
១ –	ប្រែពីបាលីមកជាខ្មែរ ឬពីខ្មែរទៅជាបាលី	៣	២ ម៉ោង

លេខរៀង	វិញ្ញាសា	មេគុន	រយៈពេល
២	ប្រែពីសំស្ក្រឹតមកជាខ្មែរ ឬពីខ្មែរទៅជាសំស្ក្រឹត	២	២ ម៉ោង
៣	ប្រែពីអង់គ្លេស ឬចាក់ឥមមកជាខ្មែរ ឬពីខ្មែរទៅជាអង់គ្លេសឬចាក់ឥម	២	២ —
៤	អធិប្បាយអំពីលទ្ធិព្រះពុទ្ធសាសនា (អកិចធម្មវិនិយ)	៣	៣ —
៥	ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ	២	២ —
៦	គណិតសាស្ត្រ	២	២ —
៧	វិទ្យាសាស្ត្រ	២	២ —

លុះប្រឡងពិនិត្យរួចហើយ គណៈកម្មការត្រូវធ្វើបញ្ជីឈ្មោះបេក្ខជនម្នាក់ៗដែលប្រឡងហើយ ទៅសុំសេចក្តីយល់ព្រមរដ្ឋមន្ត្រីក្រសួងធម្មការ ។ បេក្ខជនដែលបានពិន្ទុចំនួនគាំងអស់ត្រឹម ១៦០ ឬលើសពីនេះទុកជាបានប្រឡងជាប់ ។

សញ្ញាប័ត្រដូចមានចែងទុកក្នុងប្រការ ២៣ នៃព្រះរាជក្រឹត្យដែលបានចង្អុលខាងលើត្រូវបុះខ្ទេសតាមចំនួនពិន្ទុដូចតទៅនេះ ។

ពីពិន្ទុ	១៦០	ទៅ	១៧៦	ម៉ដ្យម
ដ	១៧៧	ទៅ	២០៨	ល្អបង្គួរ
ដ	២០៩	ទៅ	២៤០	ល្អ

ពីពិន្ទុ ២៤១ ទៅ ២៧២ ល្អណាស់

ជ ២៧៣ ទ្បើងទៅ ល្អវិសេស

បេក្ខជនអាចសុំអនុញ្ញាតនៅរៀនក្នុងថ្នាក់ទី ៤ មួយឆ្នាំតទៅទៀតបាន ដោយសេចក្តីយល់ព្រមពីចាងហ្វាងផង ដើម្បីនឹងបានប្រឡងចេញនៅឆ្នាំតទៅ ។

បេក្ខជនដែលប្រឡងធ្លាក់ អាចសុំចូលទៅប្រឡងទៀតបាន នៅពេលបើកសម័យប្រឡងតទៅ ក្នុងហានៈជាបេក្ខជនស្ងំយរិន ។

របបសិក្សា ដែលកំរិតទុកក្នុងព្រះរាជក្រឹត្យនេះ នឹងចូលជាធរមានគិតពីថ្ងៃទី ១ កុម្ភៈ ១៩៥៥ តទៅ ។

ប៉ុន្តែសិស្សថ្នាក់ទី ២ ទី ៣ នឹងទី ៤ (ឆ្នាំ ១៩៥៥ - ៥៦) នឹងត្រូវបន្តវិជ្ជាទៅតាមរបបចាស់រហូតដល់អវសាននៃការសិក្សារបស់ខ្លួន ។

ភម្ពសទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែសីហា លេខ ៨

ព.ស.២៤៩៨ – គ.ស. ១៩៥៥



(ឯ ២)

ទង្គមសនិយា

ទស្សនាវដ្ដី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

ហ្រាះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា — *ទំព័រ*

— សិប្សកថា ..... ព្រះយោសធម្ម ម៉ុង - សែស .. ៥៦៣

— បញ្ញាសជាតក ភាគទី ៣ (តមក) .... បណ្ឌិតមហា ឈឹម - ស៊ុម ៥៧៤

ផ្នែកអក្សរសាស្ត្រ

— ការទស្សនានិម្មាបនកម្មខ្មែរ ..... លោកញ៉ែម - ទិម ៥៨៨

— រឿងសាមកុក (តមក) ..... ឧកញ៉ា នូ - កន ៦០១

— ដំណឹងតាមឱ្យល់ក្នុងកន្ទារ: (តមក) ... លោក ផេង - ដ្រីវ ៦១០

— រឿងបល្ស៍ង្គទិព្យ (តមក) ..... លោក ភ៉យ - ប៊ុក ៦២០

កំណត់នឹងប្រវត្តិការណ៍

— ប្រវត្តិវត្តបទុមវតីភជវភរាម ..... ឃុនបណ្ណានុរ៍ក្ស ប៊ូ - ប៊ូ ៦២៩

— ពិធីបុណ្យវិសាខបូជា នៅក្រុងភ៉ាសឹងតោន. លេខាធិការ ញ៉ែម - ទិម ៦៣៧

មួយឆ្នាំមាន ២១ ស្យៀវភៅ — ដំឡៃជាវ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Sippakatha	*Vén. MENG-SES*	563
— Pannasajataka-vol. 3 (suite) .	*M. CHHIM-SOUM*	574

PARTIE LITTERAIRE:

— Regard sur l'Architecture-khmère	*M. NHEM-KHEM* . . .	588
— Histoire de SAMKOK (suite) . .	*Oknha NOU-KAN*	601
— Le souffle du désert (suite) .	*M. PHENG-CHRIV* . . .	610
— Les trente deux récits du TRONE (suite)	*M. RAY-BUC*	620

NOTES ET CHRONIQUES:

— Historique de Vat Botum Vaddey Reachavararam	*M. BOU-PO*	629
— Visakh bochéa à Washington .	*M. NHEM-KHEM* . . .	637

Prix d'abonnement annuel (comprenant 12 numéros) 210$00

ផ្នែកសាសនា

សិប្បកថា

ព្រះឃោសធម្ម ម៉ឺង-សៃស វត្តមហាមន្ត្រី

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ ដង)

សូមនមស្ការបំពោះព្រះភគវន្តមុនី ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឆ ដោយសេចក្តីគោរព) ។

ឧកាសនេះ អាត្មាភាពសូមសំដែងអំពីសិប្បកថា តាមទំនងដែលមានមកក្នុងមង្គលសូត្រព្រមទាំងអដ្ឋកថា ល្មមជាផ្ទូវប្រតិបត្តិនៃពុទ្ធបរិ-ស័ទទាំងឡាយ ។

ហត្ថកោសល្ជ សេចក្តីធ្វៀវធ្វាសបុិនប្រសប់ខាងការងារដោយដៃគឺចេះធ្វើការកើតបានល្អត្រឹមត្រូវល្មមគេប្រើប្រាស់បាន ហៅ សិប្ឆ:ប្ឋ សិល្ឆ: ។ សិប្ឆ:នេះ បើសំរេចហើយជាការគាប់ប្រសើរក្នុងលោកជាហេតុឲ្យបានទ្រព្យសម្បត្តិសក្តិយសខ្ពង់ខ្ពស់ នឹងមានកិត្តិស័ព្ទល្អផ្សាយទៅសព្វទិស ។

ឯសិប្ឆ:នោះមាន ២ ប្រការ គឺ: អនាគារិយសិប្ឆ:= សេចក្តីធ្វៀវធ្វាសបុិនប្រសប់ដោយដៃរបស់អ្នកបួស ១, អាគារិយសិប្ឆ:= សេចក្តីធ្វៀវធ្វាសបុិនប្រសប់ដោយដៃរបស់គ្រហស្ថ ។

អនាគារិយសិប្ស: នោះ មានសេចក្តីថា ភិក្ខុក្នុងសាសនានេះ មានប្រាជ្ញាល្ហាសវៃ ចេះធ្វើការងារធំដុំ នឹងការងារបន្ទាប់បន្សំ ដល់ពួកសព្រហ្មចារីបាន ។ ចេះលៃលកកាត់ដេរជ្រលក់ត្រៃចីវរ ធ្វើសមណបរិក្ខារឯទៀត ៗ មានសំពត់និសីទនៈ សំពត់ងូតទឹកភ្ជៀងនឹងវៃត្រតាំងជាដើម ត្រឹមត្រូវតាមបញ្ញត្តិ ចេះបូកបាយអលាបទឹកកំបោរចតិយ ចេះធ្វើខ្សឹនចេតិយ ខ្សឹនព្រះពោធិព្រឹក្សធ្វើរាងឧបោសថជាដើម ហៅថាការងារធំដុំ; ភិក្ខុចេះធ្វើកន្ទែងសម្រាប់លាងដើង វត្ថុសម្រាប់ជូតដើងជាដើម ហៅថា ចេះធ្វើការងារបន្ទាប់បន្សំ ។ ការចេះដឹងបែបនេះ ហៅថា នាថករណធមិ គឺធមិធ្វើនូវទីពឹងដល់ខ្លួន គឺបានសេចក្តីរាប់អានអំពីសំណាក់ឧបជ្ឈាយ៍អាចារ្យនឹងព្រះថេរៈធំ ៗ ឯទៀត, ទាំងឧបាសកឧបាសិកា ក៏ប្រើនស្រឡាញ់រាប់អានភិក្ខុបែបនេះ តែងទំនុកបំរុងបូជាដោយបច្ច័យទាំង ៤, ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា សិប្ស: បែបនេះជាមគ្គលដ៏ឧត្តម ។

ឯ អាគារិយសិប្ស: សេចក្តីធ្វៀវធ្ងាសបុិនប្រសប់ខាងការងារដោយដៃរបស់ព្រះហស្ថនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា ជាមង្គលដ៏ឧត្តម ចំពោះការងារណា ដែលផុតអំពីការបៀតបៀនសត្វដទៃ ឃ្វាងអំពីផ្ទូវអកុសលទាំងពួង គឺការងាររបស់ជាងកែវ ជាងមាស ជាងប្រាក់ ជាងស្មិត ជាងឥដ្ឋ-កំបោរ ជាងឈើ ជាដើម ។ សិប្ស:នេះបានជាព្រះអង្គទ្រង់សំដែងថាជាមង្គល ព្រោះជាហេតុឲ្យបានផលប្រយោជន៍ក្នុងលោកនេះ ដូចមានរឿងរ៉ាវតទៅនេះ ៖

ពោធិរាជកុមារ ជាព្រះរាជបុត្រព្រះបាទពិម្ពិសារ បានជួលជាន ឈើម្នាក់ ឲ្យសាងប្រាសាទ ១ ខ្នង ឈ្មោះ ពោកនទប្រាសាទ ប្រែថា "ប្រាសាទឈូកក្រហម" ។ ប្រាសាទនោះល្អកៃលែងជាងប្រាសាទ ឯទៀតៗ ជាប្រាសាទធ្នើមក្នុងព្រះនគរ ។ រៀលាសាងជិតហើយស្រេច ពោធិរាជកុមារមានព្រះបន្ទូលសួរជាងឈើថា ជាងឯងឆ្ងាប់ធ្វើប្រាសាទ បែបនេះ ច្រើនជងច្រើនត្រាណាស់មកហើយ ឬក៏ទើបនឹងធ្វើតែម្តង នេះទេ ? . . .

ជាងឈើក្រាបទូលថា ទើបនឹងធ្វើតែម្តងនេះទេ ។ ពោធិរាជកុមារ ទ្រង់ព្រះដំរិះថា "ជាងនេះទើបតែនឹងធ្វើប្រាសាទ ១ នេះ ល្អម្ទ៉ះទៅ ហើយ តទៅមុខទៀតជាងនេះមុខតែធ្វើប្រាសាទឲ្យគេឯទៀតៗ ល្អជាង ប្រាសាទអញមិនខាន បើដូច្នោះគួរអញសំឡាប់ជាងនេះចោលចេញ ឬ ក៏កាត់ដៃចោល ឬធ្ពៀលក្នែកវាចេញ ទើបបាន" ។ លុះគិតហើយក៏ មានព្រះបន្ទូលប្រាប់រឿងនោះដល់មាណពម្នាក់ឈ្មោះសញ្ជិកាបុត្រ ជា មិត្រសំឡាញ់របស់ខ្លួន ។ សញ្ជិកាបុត្រមានសេចក្តីអាណិតអាសូរដល់ ជាងឈើ ក៏និយាយប្រាប់ដំណើរនោះសព្វគ្រប់ដល់ជាងឈើ ដោយ ស្លាត់កំបាំង ។

ជាងឈើក៏រកឧបាយនឹងដោះខ្លួនឲ្យរួចអំពីសេចក្តីវិនាស ។ លុះដល់ ពេលតពីនោះមក ពោធិរាជកុមារមានព្រះបន្ទូលសួរថា ប្រាសាទស្រេច ហើយឬនៅ ? ។ ជាងឈើក្រាបទូលថា "មិនទាន់ស្រេចទេ នៅច្រើន ណាស់" ហើយក្រាបទូលឲ្យរកឈើស្រាយ ៗ ស្ងួតៗ ជាច្រើនមកឲ្យ

ហាមឃាត់ថា កុំឲ្យមនុស្សណាមួយចូលទៅក្នុងប្រាសាទនោះឲ្យសោះ
រៀរលែងតែកវិយាខ្ជូនមួយដែលនាំយកអាហារទៅឲ្យ ។

ជាងឈើក៏ធ្វើសកុណយន្ត គឺយន្តហោះមានសណ្ឋានជូចសត្ចបក្សី
ដោយឈើស្រាយទាំងនោះ នៅខាងក្នុងប្រាសាទ ។ ឯយន្តហោះរបស់
ជាងឈើនោះ មានរូបភាពជូចសត្ចបក្សីត្រុឌ ។ ជាងឈើបង្គាប់កវិយា
ឲ្យលក់ជូរទ្រព្យសម្បត្តិទាំងអស់យកសុទ្ធតែមាសនឹងប្រាក់រៀបចំជំណើរ
ទុកជាស្រេច លុះសំរេចសកុណយន្តហើយ ក៏នាំកវិយានឹងកូនឡើងជិះ
សកុណយន្តយកមាសប្រាក់នឹងទ្រិព្យឯទ្រៀតដែលស្រាលៗ ជារបស់ផង
ខ្ជូនជាក់ក្នុងសកុណយន្តបើកសកុណយន្ត ហោះចេញតាមបង្អួចប្រាសាទ
ទៅកាន់ប្រទេសត្រៃហិមពាន្ត ទៅចុះត្រង់ទីកន្ទែង ១ ដ៏សមគួរ បាន
សាងទីក្រុង ១ ត្រង់កន្ទែងនោះ ។ លុះនៅក្នុងទីក្រុងនោះយូរៗ ទៅ
ជាងឈើបានសោយ្យរាជ្យជាស្តេចក្នុងនគរនោះ ព្រះនាមថា កជ្ជរាហនរាជ
បានថ្ពុំថ្ពើងរុងរឿងជរាបដល់អស់ព្រះជន្ម ។

សំដែងរឿងនេះដើម្បីញ៉ាំងសាធុជនឲ្យជ្រាប អំពីកំឡាំងហត្ថកោ-
សល្ប សេចក្តីធ្វៀរធ្ងាសបុិនប្រសប់ដោយដៃដែលហៅថាសិប្ប:នោះអាច
ឲ្យប្រយោជន៍គឺសេចក្តីសុខចំរើនសក្តិយសទ្រព្យសម្បត្តិ ក្នុងលោកនេះ
ពិតប្រាកដ ។

ន័យមួយទ្រៀត ក្នុងកម្ពុជរដ្ឋយើងនេះអ្នកកាន់ព្រះពុទ្ធសាសនាមាន
ចំនួនច្រើន អ្នកខ្ចះមានសេចក្តីសង្ស័យជដែកគ្នាថា ខ្មែរយើងធ្វើបុណ្យ
ធ្វើទានច្រើនជាងគេ ហេតុអ្វីក៏ក្រខ្សត់ទ្រព្យសម្បត្តិជាងគេ? ជាតិដទៃ

គេមិនសូវធ្វើបុណ្យធ្វើទានទេ ឯះគ្មានធ្វើសោះ ហេតុអ្វីក៏គេប្រើនមានទ្រព្យសម្បត្តិជាងយើង?

សូមធ្វើយតបប្រស្នានេះ ឲ្យយើញថាបុណ្យក៏ព្ធត្រៃងសំណាងនឹងសិប្យៈមានលក្ខណការណ៍ផ្សេងគ្នានេះ ដូចមានសេចក្តីតទៅនេះ:

ព្រះសព្ធញ្ញុពុទ្ធទ្រង់ជ្រាបហេតុផលសព្ធត្រប់ ទ្រង់សំដែងមង្គលសូត្រត្រង់គាថាទី ២ ត្រង់មង្គលទី ៥ ថា បុព្ធេ ច កតបុញ្ញតា ការកសាងបុណ្យកុសលអំពីជាតិមុនៗមក ក៏ជានជាមង្គលក្នុងបច្ចុប្បន្ននេះ គឺបរិបូណិ ដោយទ្រព្យសម្បត្តិសក្តិយសដ៏ខ្ពង់ខ្ពស់ក្នុងលោកនេះ ។ ព្រះអដ្ឋកថាចារ្យលោកទាញរឿងក៉វមកអាង ដូចមានតទៅនេះ ព្រះបាទកាកវណ្ណតិស្សមហារាជ បានសោយរាជ្យ ក្នុងរោហណជនបទ ទីក្រុងឈ្មោះមហាត្រាម, លុះទ្រង់សោយព្រះទីវង្គតទៅ មានព្រះរាជបុត្រ ១ ព្រះអង្គ ព្រះនាម ទុដ្ឋគាមណិអភ័យ សោយរាជ្យស្នងព្រះបិតាឡើង ។ សម័យជាខាងក្រោយ ព្រះបាទទុដ្ឋគាមណិអភ័យ ទ្រង់ស្តេចយាងបេញអំពីរោហណជនបទ ទ្រង់ធ្វើតតស្តេចទមិឡ ១ ព្រះអង្គ ព្រះនាមឯឡារៈ ហើយទ្រង់បានឡើងជាឯករាជ្យ ទ្រង់គង់នៅក្នុងក្រុងអនុរាធបុរីក្នុងលង្កាទ្វីប ។ ក្នុងត្រាកាលដែលព្រះសម្ពុទ្ធបរិនិព្វានហើយកន្ធងទៅបាន ៣៧២ ឆ្នាំ ព្រះបាទទុដ្ឋគាមណិអភ័យមានបុណ្យអស្ចារ្យមានកំណប់ទ្រព្យជាប្រើនផុសឡើងសំរាប់ព្រះអង្គ ក្នុងទិជុំវិញនៃក្រុងអនុរាធបុរីព្រោះបានកសាងបុណ្យកុសលទុកមកអំពីជាតិមុន ។

១– ខាងកាគទិសឲ្លាសានប្រមាណ ៣ យោជន៍អំពីក្រុងអនុរាធបុរី

ក្នុងស្រុកមួយឈ្មោះអាវរវរដិត្រាម មានដុំមាសជាច្រើនប្រវែង ១ ចំអាម ក៏មាន ១ អង្ពុលីក៏មាន ផុសឡើងលើផ្ទៃផែនដីប្រមាណ ១៦ កវិស ។

៦- ខាងភាគទិសឯកើតប្រមាណ ៧ យោជន៍ ក្នុងជនបទ ១ ឈ្មោះតម្ពបិដ្ឋិ ត្រើយខាងនាយនៃស្ទឹងគង្គា មានទង់ដែងជាច្រើនផុសឡើងលើផ្ទៃផែនដី ។

៧- ខាងភាគទិសអាគ្នេយ៍ ប្រមាណ ៦ យោជន៍ ក្នុងស្រុក ១ ឈ្មោះរាបីត្រាម មានកែវមណីជាច្រើនផុសឡើងលើផ្ទៃផែនដី ។

៦- ខាងភាគទិសឯត្ឈូងប្រមាណ ៨ យោជន៍ ក្នុងអម្ពដ្ឋកោលជនបទ មានប្រាក់ផុសឡើងក្នុងគុហា ១ ។

៥- ខាងភាគទិសឯលិច ប្រមាណ ៥ យោជន៍ ក្នុងកំពង់ ១ ឈ្មោះ៖ រុរេល: មានកែវមុក្តាជាច្រើន ទំហំប៉ុនផ្ទែកន្ទួតត្រៃឆ្នាតធំ មានទ្រង់ត្រាយជូចផ្ទែកន្ទួតត្រៃចំនួន ៦០ រទេះធំ ព្រមទាំងកែវប្រពាឡផងផុសឡើងនៅលើគោក ។

៦- ខាងភាគទិសឯជើង ប្រមាណ ៧ យោជន៍ អំពីអនុរាធបុរី មានកែវមណី ៦ ដុំ មានសម្ឈុ ជូចផ្កាត្រកៀត ប្រវែង ១ ចំអាម ៦ ធ្នាប់ ទំហំប៉ុនថ្មសំរាប់កិនយ៉ាងតូច ផុសឡើងនៅលើផ្ទូកឡាប់ ក្នុងស្ទឹងតូច ១ ដែលហូរកាត់ស្រុក ១ ឈ្មោះបេឡិរាបិកត្រាម ចុះទៅក្នុងបឹង ១ ។

មនុស្សទាំងឡាយដែលបានឃើញមាសជាដើមផុសឡើងជូច្នោះក៏ នាំគ្នាមកក្រាបបង្គំទូលព្រះបាទទុដ្ឋគាមណិអភ័យ ។ ក៏មានព្រះរាជឧស្ការត្រាស់បង្គាប់ឲ្យដឹកនាំជញ្ជូនមកជាក់ជាព្រះរាជទ្រព្យក្នុងព្រះឃ្ទាំងរបស់

ព្រះអង្គ ។ នេះជាផលរបស់បុណ្យ ក៏ព្ចកេតសំណាងព្រះមហាក្សត្រ
អង្គនេះ ទ្រង់បានកសាងទុកមកអំពីជាតិមុន មិនមែនកើតដោយកំឡាំង
ព្យាយាមប្ដវិជ្ជាសិល្បសាស្ត្រ ក្នុងបច្ចុប្បន្ននេះទេ ។

ឯសិប្ប: មង្គលទី ៨ គាថាទី ៣ ក្នុងមង្គលសូត្រនេះ ដូចបាន
សំដែងមកហើយខាងដើមនោះ និយាយចំពោះតែអំពីវិជ្ជាសិល្បសាស្ត្រ
ដែលសំរេចហើយក្នុងបច្ចុប្បន្ននេះ អាចឲ្យផលប្រយោជន៍ក្នុងបច្ចុប្បន្ននេះ
ដូចជាព្រះបាទកដ្ឋវាហនរាជនោះឯង ។

មនុស្សក្នុងលោកនេះ ទោះជាតិណាក៏ដោយ ប្រទេសណាក៏ដោយ
ដែលមានទ្រព្យសម្បត្តិថ្ពុំថ្ពើងរុងរឿង មិនមែនសុទ្ធតែសំរេចមកអំពីការ
កសាងបុណ្យកុសលអំពីជាតិមុនទាំងអស់ទេ សំរេចមកអំពីវិជ្ជាសិល្ប-
សាស្ត្រក្នុងបច្ចុប្បន្ននេះក៏មានដោយច្រើន; ព្រោះហេតុនោះហើយបានជា
ប្រទេសធំ ៗ ឯទៀត គេខំប្រឹងប្រែងរៀនវិជ្ជាគ្រប់មុខបានចេះដឹងច្រើន
បានទៅជាអ្នកមានទ្រព្យសម្បត្តិច្រើនថ្ពុំថ្ពើងរុងរឿងជាងប្រទេសដែលល្ងង់
ខ្លៅ ។ មួយយ៉ាងទៀតមានសំដែងក្នុងគម្ពីរព្រះពុទ្ធសាសនាក្នុងទិ ឯទៀតថា
បុគ្គលអ្នកមានបុណ្យក៏ព្ចច្រើន តែងអនោលចាប់កំណើតកើតក្នុងត្រកូល
ស្ត្ពុកស្ត្ពមក្នុងប្រទេសធំ ៗ សមនឹងបុណ្យដែលខ្ជួនបានកសាងទុកមក ។
ប៉ើមកកើតក្នុងត្រកូលខ្សត់ខ្សោយក្នុងប្រទេសតូច ៗ ដែលក្រីក្រទ្រព្យធន
ធ្ងើម្ពេចនឹងសមតាមទំនងបុណ្យក៏ព្ចនោះ ។

ម្យ៉ាងទៀត អ្នកដែលប្រកបដោយវិជ្ជាសិល្បសាស្ត្រ មិនត្រឹមតែ
បានផលប្រយោជន៍ក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះទេ, ប៉ើបានជួបប្រទះនឹងស្រែ

បុណ្យល្អ ចានបណ្តុះពូជបុណ្យទៅក្នុងវិស្រែបុណ្យនោះ នឹងចានផលប្រយោជន៍ច្រើនក្នុងបវរលោកទៀតផង ចានសំរេចប្រយោជន៍ដ៏ឧត្តមគឺមគ្គផលនិញ្ញានផងទៀត ដូចមានរឿងពាក្យតទៅនេះ ។

ក្នុងកាលកន្លងទៅហើយ ឯកោ នឡកាវេ មានជាឯតគ្បាញកនៃលបបុសម្នាក់នៅក្នុងនគរពារាណសី; ថ្ងៃ ១ ជាងនោះដើរទៅកាន់វិស្រែចានជួបនឹងព្រះបច្ចេកពុទ្ធ ១ ព្រះអង្គ កំបង្គាប់ថាសកម្មកឲ្យទៅធ្វើការងារក្នុងវិស្រែ, ឯអាត្មាឯងត្រឡប់មកផ្ទះវិញនិមន្តព្រះបច្ចេកពុទ្ធឲ្យឆាន់កន្លងផ្ទះ ហើយក៏និមន្តទៅកាន់ឆ្នេរទន្លេគង្គា ទៅជាមួយនឹងកូនប្រុសម្នាក់ផង, ចានសង់បណ្ណសាលា គឺសាលាប្រក់ស្លឹក ១ ខ្នង យកឈើទុម្មរធ្វើជាដើងជញ្ជាំង យកកន្ទេលបបុសធ្វើជាជញ្ជាំង ធ្វើទីបង្អែមន ១ ផង, និមន្តព្រះបច្ចេកពុទ្ធឲ្យគង់នៅក្នុងបណ្ណសាលានោះអស់ ៣ ខែ ។ ជនពាល ២ នាក់ គឺបិតានឹងបុត្តប្រុសចានប្រគេនត្រៃចីវរដល់ព្រះបច្ចេកពុទ្ធ ដែលគង់ចាំវស្សារួចហើយ ចានគោរពវាប់អានចំនុកបំរុងបូជាព្រះបច្ចេកពុទ្ធ ៧ ព្រះអង្គដទៃទៀត ដូចព្រះបច្ចេកពុទ្ធ ១ អង្គមុននោះដែរ ។ ជនពាល ២ នាក់ គឺបិតានឹងបុត្តប្រុសលុះធ្វើមរណកាលទៅក៏ចានទៅកើតក្នុងពិភពតាវត្តឹង្ស សោយទិព្វសម្បត្តិក្នុងឧកាមាវចរសួគ៌ ជាអនុលោមនឹងបដិលោម ។

ចំណែកទេវបុត្តជាបិតាស្ថិតនៅក្នុងទេវលោកដដែល ឯទេវបុត្តជាបុត្តប្រុស ក៏ច្យុតចុះមកចាប់កំណើតក្នុងផ្ទៃនាងសុមេធាទេវី ជាមហេសីនៃព្រះចានសុរុចិរាជក្រុងមិថិលា ដែនវិទេហៈ គ្រប់កំណត់ ១០ ខែ

កំប្រសូតមក គេថ្វាយព្រះនាមថា មហាបនាទកុមារ, លុះមានព្រះជន្មាយុ ១៦ ឆ្នាំ កំបានសំរេចវិជ្ជាសិល្បសាស្ត្រគ្រប់ប្រការ ។ ព្រះពុទ្ធបិតាទ្រង់គ្រាស់បង្គាប់ពួកវត្ថុវិជ្ជាចារ្យ គឺអាចារ្យដែលចេះមើលទីដីសង់ផ្ទះថា អ្នកពាល់គ្នាចូរនាំយកជាងមកសាងប្រាសាទឲ្យកូនរបស់អញ អញនឹងអកិសេកកូនអញឲ្យសោយរាជ្យ ។ ពួកវត្ថុវិជ្ជាចារ្យក៏ទទួលព្រះពុទ្ធាវរហើយពិចារណាមើលប្រទេសផែនដីដោយសព្វគ្រប់ កំកើតក្តៅរំជួលដល់អស្នាព្រះឥន្ទ្រាធិរាជ ១ រំពេច ដោយអានុភាពបុណ្យរបស់មហាបនាទកុមារនោះ ។ ព្រះឥន្ទ្រាធិរាជទ្រង់ជ្រាបការណ៍នោះសព្វគ្រប់ ទ្រង់ប្រើព្រះវិស្សកម្មទេវបុត្រឲ្យចុះមកសាងប្រាសាទថ្វាយមហាបនាទកុមារ ។

ព្រះវិស្សកម្មទេវបុត្រក៏កៀសខ្លួនជាមេជាង មកកាន់សំណាក់ពួកជាងបញ្ជូនពួកជាងឲ្យត្រឡប់ទៅកាន់ស្ថានលំនៅវិញខ្លួន ហើយយកដំបងវាយផែនដី ក៏ស្រាប់តែមានប្រាសាទកែវ ៧ ប្រការ មានសណ្ឋាន ៤ ជ្រុងស្មើគាត គឺទទឹងកន្ទុះយោជន៍ បណ្តោយកន្ទុះយោជន៍ កំពស់ ២៥ យោជន៍ មានជាន់ ៧ ផុសឡើងមួយរំពេច ។ មហាបនាទស្តេចគង់នៅជាសុខសម្រាន្តក្នុងប្រាសាទកែវជាអស្ចារ្យនោះ បានធ្វើបុណ្យមានទានជាដើម ។ លុះទ្រង់សោយព្រះទិវង្គតទៅក៏បានទៅកាន់ស្ថានសួគ៌វិញ ។ ប្រាសាទនោះក៏ស្រុតលិចចុះទៅក្នុងទន្លេគង្គា ។ គេបានសាងទីក្រុងមួយ ឈ្មោះបយាគប្បតិដ្ឋាន ចំត្រង់ជណ្តើរប្រាសាទនោះ មានស្រុកមួយឈ្មោះកោដិគ្រាម នៅចំត្រង់កំពូលប្រាសាទ

នោះ ។ លុះដល់មកក្នុងពុទ្ធុប្បាទយើងនេះ នឡការទេវបុត្រជាកូននោះ
ក៏ច្យុតអំពីទេវលោក មកកើតជាកូននៃកទ្ធិយសេដ្ឋី ក្នុងទីក្រុងកទ្ធិយ:
គេឲ្យឈ្មោះថា កទ្ធជិកុមារ ។ ត្រានោះព្រះដ៏មានព្រះភាគ គង់នៅ
ក្នុងវត្តជាតិយាវ៉ន អាស្រ័យនៅទីក្រុងកទ្ធិយ: ។ ពួកជនដែលនៅ
ក្នុងទីក្រុង បាននាំគ្នាសាងមណ្ឌបសម្រាប់ធ្វើទាន ត្រង់កណ្ណាលទីក្រុង
ហើយថ្វាយទានដ៏ច្រើន ។ ព្រះសាស្តាទ្រង់ធ្វើកត្តកិច្ចរួចហើយទ្រង់ធ្វើ
អនុមោទនាក្នុងមណ្ឌបនោះ ។ កទ្ធជិកុមារក៏ចូលទៅតាល់ព្រះសាស្តា
បានស្តាប់ធម៌ក៏បានសម្រេចអរហត្តផល ហើយទៅកាន់វត្តជាមួយនឹង
ព្រះសាស្តាចូលបួសបានឧបសម្បទាជាភិក្ខុ ។ ព្រះសាស្តាទ្រង់គង់ក្នុង
វត្តជាតិយាវ៉ននោះបាន ៧ ថ្ងៃ ទ្រង់ស្តេចទៅកាន់ចារិកបានស្តេចទៅដល់
កោដិត្រាម លុះធ្វើកត្តកិច្ចរួចហើយ ក៏ធ្វើអនុមោទនា ។ កទ្ធជិត្ត្រ
កាលដែលកំពុងធ្វើអនុមោទនា ក៏ចញ្ញទៅខាងក្រៅស្រុក អង្គុយចូល
ឈានក្រោមម្ទប់ឈើជិតគំពង់ទន្ទេគង្គា ដោយគិតថា "នឹងក្រោកឡើង
ក្នុងពេលដែលព្រះសាស្តាស្តេចយាងមក" ។ កាលដែលមានព្រះថេរ:
ចាស់ ៗ និមន្តមក មិនបានក្រោកឡើង លុះដល់ពេលដែលព្រះសាស្តា
ស្តេចយាងមកដល់ទើបក្រោកឡើងតែម្តង ។ ពួកភិក្ខុជាបុថុជ្ជននាំគ្នា
ពោលទោសកទ្ធជិត្ត្រ ថាមិនគោរពព្រះថេរ:ចាស់ ៗ ។ ព្រះសាស្តា
ទ្រង់ស្តេចទៅគង់លើទូកឃ្នាបមានព្រះបន្ទូលហៅកទ្ធជិត្ត្រឲ្យឡើងជិះទូក
ជាមួយនឹងព្រះអង្គ កទ្ធជិត្ត្រក៏ហោះឡើង ហើយចុះគង់លើទូក ១ ។
ព្រះសាស្តាមានព្រះបន្ទូលសួរក្នុងពេលដែលទូកទៅដល់ពាក់កណ្ណាល

ទេន្ទគន្ធា ថា នែកទ្ធជិ ព្រាសាទដែលលោកឌ្ឍាប់អាស្រ័យនៅ ក្នុងកាល
ដែលលោកសោយរាជ្យជាស្តេចឈ្មោះមហាបនាទនោះ តើនៅត្រង់កន្ទែង
ណា? កទ្ធជិត្ថេរក្រាបបង្គំទូលថា ព្រាសាទនោះលិចចុះទៅនៅត្រង់
កន្ទែងនេះ ។ លុះក្រាបបង្គំទូលហើយថ្វាយបង្គំព្រះសាស្តា រួចចុះទៅ
ដោយកំឡាំងបុទ្ធិយកម្រាមដៃថ្ពក់កំពូលព្រាសាទហោះទៅឲ្យដ៏អាកាស
បង្ហាញឲ្យឃើញរាល់គ្នាហើយលែងទៅវិញ ដើម្បីកាត់នូវសេចក្តីសង្ស័យ
របស់បុថុជ្ជន ។ ព្រាសាទនោះក៏ឌ្ឍាក់ទៅនៅត្រង់កន្ទែងដដែលវិញ គ្មាន
អន្តរាយឧចឧាតរហូតដល់មកសព្វថ្ងៃនេះ ។ ស្ងួរថា ព្រាសាទនោះហេតុ
អ្វីបានជាមិនទាន់អន្តរាយ? ឆ្លើយថា ដោយអានុភាពនៃនឡការទេវបុត្ត
ជាបិតាពីដើម ។ ព្រោះថានឡការទេវបុត្រនោះនឹងបានជាព្រះរាជា
ចក្រពត្តិព្រះនាមសង្ឆៈក្នុងអនាគត ព្រាសាទនោះនឹងផុសឡើងសំរាប់ព្រះ
រាជានោះ; ដោយហេតុនេះ បានជាមិនទាន់អន្តរាយ ។

សំដែងរឿងនេះដើម្បីបញ្ជាក់អំពីកម្ចាំងវិជ្ជាសិល្បសាស្ត្រដែលប្រ
កបដោយធម៌ បើបន្ទោនទៅរកបុណ្យកុសលនឹងមានផលប្រយោជន៍ទៅ
ក្នុងអនាគត នឹងថ្កំថ្កើងរុងរឿងក្នុងមនុស្សលោកនឹងទេវលោក បាន
សំរេចព្រះនិព្វានក្នុងជាតិជាទីបំផុត ។

អាត្មាភាពសំដែងធម៌មកនេះ ក៏សូមបញ្ចប់ត្រឹមតែប៉ុណ្ណេះ ឯវំ ។

បញ្ញាសជាតក

ភាគទី ៣

បណ្ឌិតមហា ឈឹម - សុិម សាស្ត្រាចារ្ស

នៅសាលាបាលីដាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្ជនឯង

កាលដែលនៅដាវោទបញ្ចដិតពី ព.ស. ២៤៨៦, ត.ស. ១៩៤៣

(តមក)

សុវណ្ណាកុមារជាតក ទី ១៥

លោកអាចារ្ស ឆង - សមិទ្ធ ក្រុមដំនុំព្រះត្រៃបិដក

ប្រែពីបាលី

(តចប់)

ព្រះសុវណ្ណកុមារពោធិសត្ត ត្រាស់សរសើរកល្យាណមិត្តដូច្នេះ, ហើយ កាលទ្រង់នឹងតិះដៀលនូវបាបមិត្ត ទ្រង់ត្រាស់ថា បពិត្រព្រះ រាជា, បុគ្គលពួកមួយ ពោលពាក្យសំដីល្អជា ពីរោះពិសា តែថាក្នុងដួង ចិត្តមានគំនិតផ្សេង; កាលបើជនដទៃមានសេចក្តីទុក្ខ, បុគ្គលនោះក៏ធ្វើ អាការៈហាក់ដូចជានឹងលះបង់ជីវិតខ្ជួន, ប៉ុន្តែជល់សំឡឹងរកប្រយោជន៍ ផ្ទាល់ខ្ជួនមិនយើញក៏ប្រែបែរជាធ្វើអាការៈផ្សេង លែងស្គាល់គ្នាឯងសោះ; បុគ្គលនោះ ឈ្មោះថាមនុស្សបាបកៃកែលែងជាងបុគ្គលបាបទាំងពួង; ក្នុង បច្ចុប្បន្នជាតិនេះ បុគ្គលនោះឥតមានសេចក្តីចំរើនទេ, អ្នកប្រាជ្ញចាត់ជា មនុស្សកំសត់កៃកែលែង, ជល់បរលោកនាយរមែងទៅរងទុក្ខធំ ក្នុងអវីចី ប្ចរលោហកុម្ភីនរក អស់កាលជាអង្វែង ។ ព្រោះហេតុនោះ បានជា អ្នកប្រាជ្ញសំដែងថា

យោ ធីរោ វិចរំ ករោ ហទយេ បន អញ្ញថា
អញ្ញោ ទុក្ខសមុប្ឈន្នេ បត្តោ កម្មេសុ កណ្ហិតោ
សនត្ថេ នេវិ ជានាតិ តស្ស ទោសំ កថិយតេ
សោ ច បាបតរោ បច្ចា លោហកុម្ភឹ បតិយតេ ។

បុគ្គលខ្ទះជាអ្នកមានប្រាជ្ញា ពោលរាចាផ្អែមត្រជាក់ហាក់ដូចជាមានសេចក្តីមេត្រី, ប៉ុន្តែក្នុងដួងហឫទ័យមានគំនិតផ្សេង, បុគ្គលនោះឯង កាលជនដទៃបានសេចក្តីទុក្ខធុរ: ក៏សំដែងអាការ:ហាក់ដូចជាមានសេចក្តីខ្ទះខ្ទែង ជួយប្រឹងប្រែងក្នុងកិច្ចការធុរ:នោះ, លុះបុគ្គលនោះសំឡឹងឃើញថាមិនជាប្រយោជន៍ ក៏ប្រែប្ររជាមិនស្គាល់គ្នាទៅវិញក៏មាន ប្រែរជាពោលថ្កោលទោសជនអ្នកមានទុក្ខធុរ:នោះវិញក៏មាន, បុគ្គលនោះ ឈ្មោះថាមនុស្សបាបអាក្រក់ត្រៃលែង រមែងធ្លាក់ទៅក្នុងនរកលោហកុម្ភី ក្នុងកាលជាខាងក្រោយពុំខាន, បពិត្រមហារាជ, ព្រោះហេតុនោះ សូមព្រះអង្គពិចារណាមើលនូវជនទាំងពីរពួកនោះ ហើយសូមប្រាប់ខ្ញុំតាមសេចក្តីពិតរបស់ខ្លួន, កុំប្រាប់តាមហេតុដែលប្រកបដោយមានះនឹងហេតុដែលប្រកបដោយកំយឡើយ ។

ព្រះបាទកដេសុរាជ ជាម្ចាស់ដែនសីហឡ: ទ្រង់រីករាយសប្បាយក្នុងព្រះរាជហ្ឫទ័យ ទូលតបសេចក្តីថា សាធុសាធុ-

មហារាជ បពិត្រមហារាជ, ពិរោះណាស់! ល្អណាស់! ព្រះរាជឧត្តារៈបស់ព្រះអង្គតំងអស់នេះ សុទ្ធតែជាសុភាសិត, ធម៌ដ៏ខ្ពង់ខ្ពស់យ៉ាងនេះ ឥតមានរណាដែលឲ្ម ដែលចេះឡើយ; ខ្ញុំសូមថ្វាយជីវិត ជួងហ្ចុទ៍យ នឹងសេចក្តីស្រឡាញ់ ព្រមតំងរាជសម្បត្តិតំងអស់ចំពោះព្រះអង្គ; បពិត្រព្រះអង្គជាអរិមទ្ធនរាជ, សូមព្រះអង្គទ្រង់ទទួលយកតាមសព្ទព្រះរាជហ្ចុទ៍យចុះ ។

ព្រះបរមពោធិសត្ត ទ្រង់ត្រាស់ថា បើពិតជាជូច្ចោះមែន, សូមព្រះអង្គទៅថ្វាយបង្គំព្រះរាជមាតាបិតារបស់ខ្ញុំ ជាមួយនឹងខ្ញុំចុះ ។ ព្រះបាទកេដសុរៈទទួលព្រមថា បពិត្រមហារាជ, ល្អហើយ ស្រួលហើយ, ប៉ុន្តែ សូមព្រះអង្គរង់ចាំ ទំរាំខ្ញុំចាត់ចែងដំណើរៈរួចស្រេចសិន ។ ព្រះពោធិសត្ទត្រាស់ថា អញ្ជើញទ្រង់ចាត់ចែងចុះ មហារាជ ។

លំដាប់នោះ ព្រះបាទកេដសុរាជ ព្រហៅដែនសីហឡៈ កាលបើបានព្រះរាជានុញ្ញាតជូច្ចោះហើយ ក៏ថ្វាយបង្គំលាព្រះពោធិសត្ទ មកកាន់ព្រះរាជនិវេសនដ្ឋាន ទ្រង់ចាត់ចែង ជ្រើសរើសរកយករាជនារីស្រីក្រមុំព្រហ្ម្ចារី បានចំនួន ១ ហ្ម៉ឺនប្រាំបីពាន់ មានសុជន់ក្សំក្រពុំជូចផ្ការបទុមរ៉ត្នសុវ៉ណ្ណ មានវង់ភក្ត្រផូរផង់ជូចអង្គព្រះចន្ទ ក្នុងថ្ងៃបណ្ណរសី មានសិរីជូចស្រីទេពអប្សរ មានបាទដៃបាទជើងសម្បុរលឿងស្រស់ល្អជូចជ្រលក់ទឹកល៉ក្ត មានទ្រតាកសាយត្រសុំសំណុំខ្ជូនស្ទើនល្អជូចរូបចម្ងាក់ ដែលគេធ្ងាក់ដោយដំបារមាស មានសរីរប្រាសចាកទោស ៦

ប្រែការ គឺមិនជាត់ពេក មិនស្គមពេក មិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនស្រពេក ជាទីត្រូវក្រឡេកឥតគន់នៃជនទាំងពួង មានសំដីពីរោះពិសាផ្អែមល្ហែមត្រជាក់ មានអាការៈហាក់ដូចញញឹមស្រស់ប៉ប្រឹមជានិច្ច; ពាក្យភ្លាមមួយៗនោះ មានភាសីស្រីបំរើ, មានរូបល្អស្រស់ប្រសើរ ១០ នាក់ៗប្រដាប់ដោយគ្រឿងភាគរណៈ ល្អស្រស់គ្រប់ប្រការ; ស្តេចបញ្ជូនឲ្យទៅបំរើព្រះបាទសុវណ្ណកុមារ ទៅតែប្រតាំងយប់ភាំងថ្ងៃ ។ តមកព្រះបាទកេសុរៈទ្រង់ត្រាស់បង្គាប់ សេនាគុត្តអាមាត្យថា ម្នាលអាមាត្យ អ្នកគ្រប់គ្រងចតុរង្គសេនា, ចូរអ្នករៀបពលសកលយោធាទាំង ៤ ពួកឲ្យគ្រប់គ្រាន់ ត្រូវឲ្យពួកយោធាទាំងនោះតែងកាយតាមថ្នាក់តាមជាន់ផ្សេងៗពីគ្នា ពួកមួយឲ្យតែងកាយពណ៌ក្រហមមានមុខខៀវ, ពួកមួយឲ្យតែងកាយពណ៌ខ្មៅមានមុខស, ពួកមួយឲ្យតែងកាយបៃបជាខាត ពួកមួយឲ្យតែងកាយបៃបជាត្នោ ពួកមួយឲ្យតែងកាយបៃបជាខ្ចី, ជាគោទសក ជាដំរី ជាសេះ ជារថសីហ៍ ជាក្របី ទាំងជាសត្វដទៃៗឲ្យមានគ្រប់ប្រការ ដៃកាន់គ្រឿងសស្ត្រាគ្រប់គ្នាភាំងអស់, ឲ្យតាក់គ្រឿងក្រែរប្រដាប់ដោយអាវុធគ្រឿងយុទ្ធនាការ; ពួកសេនាបតីភាំងឡាយ ត្រូវប្រដាប់កាយគ្រឿងអម្ពរវត្ថុសុវណ្ណ ដៃកាន់កូនសរចំពុះខ្មុំនឹងឆកាំភ្លើងឡើងជិះជំរំ; ពួកសេនាហត្ថី ត្រូវឲ្យមានគ្រឿងសំលៀកបំពាក់ថ្មីៗឡើងតាមលើដំរីរាជកុញ្ជរ; ពួកសេនាអស្សត្រូវឲ្យតែងកាយយ៉ាងល្អៗ ឡើងជិះលើខ្នងសាជិ; ពួកសេនារថ ត្រូវឲ្យមានគ្រឿងសម្រាំងយ៉ាងថ្មីៗសស្ងួត; ពួកពលបុត្រ ក៏ត្រូវឲ្យតាក់

តែងកាយដោយសំពត់ទិដ្ឋគ្រឿងអម្ពរវត្ថុសុវណ្ណ ដៃកាន់អាវុធផ្សេង ៗ ទីពែ ទៀងជិះលើដំរីរោកជតជសារ, ពួកអ្នកកូនត្រូវឲ្យលេងតាមចិបតាមបទ កុំឲ្យភ្លាត់ចង្វាក់, កូនយើកូនច្នាក ត្រូវឲ្យគោរពឲ្យខ្លួនកំទេរឲ្យខ្លួវភ្លូ, ចូរអ្នកឯងមីម្នាវៀបចំពលំរឲ្យបាន ១ ម៉ឺន, ចំពវថ ១ ម៉ឺន, ហើយអ្នកទាំងអស់គ្នានោះ ចូលទៅហែហមព្រះសុវណ្ណ-កុមារជាមួយនឹងខ្ញុំ ដើម្បីភោជ្ឈយបង្គំព្រះបរមពជា ។

ព្រះបាទកេសុរៈទ្រង់ចាត់ឲ្យរៀបដំណើរ អស់រៀលា ១ ខែ, កាលបើទ្រង់ពិនិត្យ ឃើញថាការងារទាំងអស់ មានរបៀបរៀបរយស្រួលហើយ ទើបទ្រង់ទៅគ្រាបបង្គំទូលព្រះពោធិសត្វ ។

គ្រានោះព្រះពោធិសត្វ ទ្រង់មានពជកញ្ញា ១ ម៉ឺនប្រាំពីរាន់ ប្រដាប់គ្រប់គ្រាន់ដោយគ្រឿងអម្ពរកស្កា ល្អដូចស្រីទេពកញ្ញា មូលមកគ្រៀបគ្រា ហែហមព្រះអង្គ, ទ្រង់ស្តេចទៅកណ្តាលពួកពជកញ្ញា ល្អដូចអគ្គីសម្តេចព្រះអមិន្ទ្រា គ្រាដែលស្តេចទៅកណ្តាលពួកទេពអប្សរ ពជកញ្ញាពួកខ្លះកាន់ចាមរ ពួកខ្លះកាន់ព័ន្លឹងដនី ពួកខ្លះអញ្ជើញព្រះសុវណ្ណភាជនៈ ពានព្រះស្រី ធូបព្រះឧស្ន ជាពួក ។; បន្ទាប់អំពីពជកញ្ញានោះមក មានពួកសេនាតំឡោះដំទង់ ទ្រទ្រង់គ្រឿងសំពត់អលង្ការរបនាដោយមាស មានដាវមាស ព្រះខ័នមាស គ្រឿងសស្ត្រាមាស ខែលមាស តម្រៀបគ្នាពេញពាស ហែហមព្រះអង្គ ។ បន្ទាប់ពីពួកសេនាតំឡោះនោះមក មានពួកពលរយោធា ជាមនុស្សក្លាលក្លៀវមជ្ឈិមវ័យ មានរូបឆ្អឹងសម្បើមល្អប្រពៃ ដៃកាន់លំពែងមាស ព្រះខ័នមាស

ខ្លះគាន់ជាវែកប្រាក់ លំពែងប្រាក់ ព្រះខ័នប្រាក់ ។ តពីនោះមក មានពួកសេនាដំរី, តពីសេនាដំរីមក មានពួកសេនាសេះ, តពីសេនាសេះមក មានពួកសេនារថ, តពីសេនារថមក មានពួកសេនាថ្មើរជើង, តពីសេនាថ្មើរជើងមក មានពួកអ្នកភ្ញាំងៗក្រៀវក្លា ហត្ថាគាន់ធ្នូ ដើរតម្រៀបជាគូៗកម្រាស់ ៣ យោជន៍ពីខាងក្រោយ ៣ យោជន៍ពីខាងឆ្វេង ៣ យោជន៍ពីខាងស្តាំ ។ ព្រះបរមពោធិសត្វ ទ្រង់មានសេនាចោមរោមជាបរិវារ ៣ យោជន៍ជុំវិញដូច្នេះហើយ · ទ្រង់ឡើងគង់លើខ្នងដំរីរាជគជេន្ទ ប្រកបដោយលក្ខណៈ ល្អបាក់ដូចជារូបតំនូរ ទ្រង់ចេញទៅកាន់ពេលមានន័ក្តត្ថុក្សត្ត ។ ចំណែកខាងព្រះបាទកេសុរាជ ក៏មានបរិវារហែហម ចេញទៅជាលំដាប់ខាងក្រោយបំផុត ។ ព្រះបរមពោធិសត្វ មានពួកសេនាដ៏ក្រៀវក្លា ចោមរោមជាបរិវារ ទ្រង់ស្តេចទៅកាន់កណ្តាលពួកសេនាល្អល្អះថ្លៃថ្លា ដូចជាសក្កទេវរាជ ដែលគង់លើដំរីឯកវណ្ណ មានពួកទេព្តាគាំគាន់ចោមរោមជាបរិវារ, ពុំនោះសោតទេ ដូចជាកំមេរុរាជ ដែលល្អចំរើញឆ្ងាចចេញទៅត្រង់កណ្តាលកំសត្តបរិកណ្ឌ ទីដ៏សម្បុស្ប័ន្ធ។ សូរស័ព្ទដំរី សូរស័ព្ទសេះ សូរស័ព្ទរថ សូរស័ព្ទពល សូរស័ព្ទតូរ្យតន្ត្រី ឮភ្ញាខ្ទរ ហាក់ដូចជាសន្ធឹកឮល់រំពងក្នុង ឬសន្ធឹកគ្រោមច្រុះស្រុតដែនដី ឬសន្ធឹកវន្ទរអសនីដែលកំរើកពីផ្ទៃបក្សីឮ ដាលលាន់ឮខ្ទរខ្ទៀវលើមេឃ ហាក់ដូចជាទឹងបំបែកក្តុបក្រឹតឮ, ឯបុទ្ធិអំណាចពលសេនាគាំងនោះ ក៏ភ្ញាំងចំរៃក្រៃប្លែកត្រកាល ហាក់ដូចជាទឹងកំទេចដែនប្រឹថពីគាំងមូល ដូច្នេះឯង ។ ព្រះពោធិសត្វទ្រង់គង់លើខ្នងដំរីសេតមង្គល ទ្រង់ព្រះពាជដំណើរ

ទៅដល់មហាសមុទ្រ ដោយសេចក្តីវេកយសប្បាយព្រះពុទ្ធហ្ន៎ ដ្ឋាន
បំផុត ទើបព្រះបរមគ្គជឲ្យរោះកងទ័ពសំបតនៅកន្លែងនោះអស់រលោ ប្រាំពីរ
ថ្ងៃដើម្បីឲ្យពួកពលសកលយោធាលេងស្រួលផ្សេងៗតាមប្រាថ្នា ។

ស៊ីហឬពាជា រំលឹកដល់ព្រះបុត្រទាំងពីរ ព្រះទៅដែនសីហឬ: កំចូល
ទៅក្រាបបង្គំគាល់ ក្នុងទីចំពោះព្រះភក្ត្រ ហើយក្រាបបង្គំទូលតឿនថា
បពិត្រព្រះអង្គសម្ពារ, ស្អែកនេះជាវេលាមានមនុត្តប្បុរស្ស គួរព្រះអង្គនាំ
ពួកពលនិករ ចុះឆ្លងមហាសមុទ្រសាគរទៅបានដោយស្រួល ។ ព្រះ
បោធិសត្វក៏ទ្រង់ទទួលថា សាធុមហាពាជស្អែមែនហើយមហាពាជ, ទើប
ទ្រង់ប្រាប់ដល់មេក្រុមពួកសេនា ។ គ្រានោះសមុទ្ទវេតាទឹងស្តេចនាគ
ទាំងឡាយក៏និម្មិតប្រាសាទរ័ត្នសម្រាប់ថ្វាយព្រះមហាសត្វនៅលើសុវណ្ណ-
នាវ; ព្រះពាជាក៏ទ្រង់ឡើងគង់លើប្រាសាទនោះ ជាមួយនឹងស្រីស្នំ
ក្រមការ ។ ព្រះបាទសីពេឡាពាជ ទឹងពពួកពលសកលយោធា ក៏ស្រែក
ថ្វាយជ័យ ៣ ដង ហើយក៏ចុះត្រសង់ឆ្លងទៅកាន់នាវ របស់ខ្លួនគ្រប់ៗ
គ្នា ។ ពួកសមុទ្ទវេតា ក៏ចាត់ការថែទាំរក្សាមហានាវទាំងអស់ ពុំឲ្យ
មានខាស់ មានសេចក្តីអន្តរាយឡើយ; មារុតទេវតាទាំងឡាយ ក៏បញ្ចេញ
ព្រះពាយុ ផ្សាយមកវិលវើយៗ រហើយសព្វកាយា នាំអស់សំពៅកែតា
ឲ្យលឿនដើរ ឥតឲ្យយឺតយ៉ាងឡើយ ។ សមុទ្ទវេតា តែងនាំកោដនាវា
មានទុជាវេ្ត្តមថ្លៃថ្លា មកថ្វាយព្រះពាជា លឿងអស់ពួកពលសកលយោធា
រាល់ទីពាក្រឹ ។ ពួកនាងសមុទ្ទកញ្ញា ក៏តែងកាយាស្រស់ថ្លាប្រពៃ ដៃកាន់ទិព្វមាលា ផ្សាយក្លិនសុគន្ធា មក

ថ្វាយព្រះពុទ្ធ ទើបចែកជូនដល់ពួកពល ។ ពួកសេនាចាំដណ្តើមយកតែតែ
រាល់ បានបរិភោគស្កប់ស្កល់សុទ្ធតែភោជនដ៏ថ្លៃថ្លា អ្នកណាចូលចិត្តសុក
ក៏ត្រេបផឹកតាមប្រាថ្នា ឥតមានខ្វះខាត, ជនចាំដណ្តើមសុទ្ធតែតែងខ្លួន
យ៉ាងស្អាត ស្អិតស្អាងដោយគ្រឿងគន្ធជាតិសៀតកងមាលា ខ្លះពាំ ខ្លះ
ប្រឹង ខ្លះសើច ខ្លះទះហត្ថា លេងកំសាន្តឡើងភ្លាវ លើសំពៅកែត្រា
ឥតមានក្តឹក ។

ចំណែកខាងព្រះមហាសត្វ ទ្រង់សោយទិព្វសម្បត្តិកងមហាសម្ភុ
មានសុទ្ធតែពាជទេពើ ជាស្រីមានរូបសោភ្លុតកាស មានយោងយាស
គួរជាទីអភិរម្យ ទ្រង់មានលំនាំហាក់ដូចជាក្តួងព្រះចន្ទ មានពន្លឺភ្លឺត្រចះ
បិតនៅកងទីស្ងាងស្រឡះ នាកណ្តាលហួងតាព ឬថាដូចជាសុវណ្ណ-
ហង្ស នៅត្រង់កណ្តាលហួងហង្សជាបរិវារ, ក្សត្រាទ្រង់ក្តួងសម្ភុទ្ធដុត
ប្រាំពីរថ្ងៃទើបដល់ត្រើយនាយ ហើយទ្រង់បញ្ជូនពាជទូត ឲ្យទៅក្រាប
បង្គំទូលព្រះវរពាជមាតាបិតា ។ ត្រានោះសម្តេចព្រះបរមពាជា ជាព្រះ
វរពាជបិតា ទ្រង់ចាត់ការឲ្យតែងព្រះនគរបវរពាជដ្ឋាន មានទំហំ ១២
យោជន៍ រួចឲ្យតែងពាជមគ្គាផ្លូវដែលចុះទៅមាត់សមុទ្រ ហើយទើប
ព្រះចមម្ពុជ ព្រមទាំងព្រះអគ្គជាយាមានពួកពាជចរិសឲ្យចោមរោមជាយស-
បរិវារ ទ្រង់ស្តេចយាត្រាដោយព្រះពាជឥណ្ឌរម្រែកបដោយមហិស្សរិយ-
យស ទ្រង់ចុះទៅទូលព្រះពោធិសត្វ ជាព្រះពាជបុត្រចម្បង ហើ
ត្រូវទាំងបួលមកកាន់ព្រះពាជធានី ។ ព្រះពោធិសត្វ ទ្រង់ក្រាបបង្គំថ្វាយ
ស្តេចកងដេសុវរពាជនឹងពួកពល ព្រមទាំងមាសភ្ញាក់ គ្រឿងរតនៈសព្វ

គ្រប់ប្រការ ចំពោះព្រះវរពុទ្ធមាតាបិតាដោយសេចក្តីគោរព ។ ព្រះ
វរពុទ្ធមាតាបិតា ទ្រង់ទទួលដោយសេចក្តីត្រេកអរថ្លា ហើយទ្រង់ព្រះពុទ្ធ-
ដីកាវស័ព្ទសាធុការ ចំពោះព្រះពោធិសត្វថា

បិរំ ជីរំ ភុរំ បុត្ត មា វិយោគោ បិយេហិ ច
ទុប្បត្តុ ភរំ សង្គិច្ច បង្ខោ ច តុទ្ធសោ យថា ។

ម្នៃបុត្រសម្លាញ់ ជាទីពេញចិត្តមាតាបិតា, សូមអ្នក
មានជន្មាយុយឺនយូរ អស់កាលជាអង្វែងវែងឆ្ងាយ, សូមកុំ
ឲ្យបែរបាំងឡើយដែលជាទីស្រឡាញ់ពេញចិត្ត ព្រាត់
ឆ្ងាត់ឡើយឡើយ, តម្រិះគំនិតដែលអ្នកនឹងគិតឡើងហើយ សូម
ឲ្យបានសម្រេចយ៉ាងឆាប់, សូមឲ្យអ្នកបានសេចក្តីចំរើនឆ្លើង
រឿងដូចព្រះចន្ទក្នុងថ្ងៃ ១៤ កើត ។

ព្រះវរពុទ្ធមាតាបិតា ទ្រង់ប្រទានពរស័ព្ទសាធុការយ៉ាងនេះហើយ
ទើបទ្រង់ព្រះពុទ្ធទានពរសម្បត្តិ ឲ្យព្រះបរមពោធិសត្វគ្រប់គ្រងតព្រះ
ពុទ្ធវង្សរៀងទៅ ។

គ្រានោះស្តេចតាំងអស់ក្នុងសកលជម្ពូទ្វីប បានជ្រាបអានុភាពរបស់
ព្រះមហាសត្វ ក៏មានសេចក្តីខ្លាចស្បថស្ញែងកោតខ្លែងគ្រប់ ។ ព្រះមន្ត្រី
ទំធ្លុតធ្លុដីដើរសើរសរសេរគ្រឿងបណ្ណាការ ដ៏ឧត្តមថ្លៃថ្លាទាំងរយទាំងពាន់
នាំមកក្រុសពន់ពូលថ្វាយបង្គំព្រះមហាសត្វ ហើយថ្វាយគ្រឿងបណ្ណាការ
តាំងអស់នោះចំពោះព្រះអង្គ ។ ថ្ងៃមួយ ព្រះរាជាតាំងអស់ នាំគ្នាចូល
ទៅបង្គំគាល់ ប្រដុំសម្រេចការតាំងព្រះពោធិសត្វជាអគ្គឯករាជ្យ ប្រគល់

អំណាចឲ្យជាឥស្សរក្នុងសកលដងមួយទីប ហើយថ្វាយតាំងជែនអាណាខ្លួន
បេះខ្លួនព្រមតាំងខ្លួនចំពោះព្រះពោធិសត្វ ចុះយ៉ាមតាំងខ្លួនជាអ្នកប្រតិបត្តិ
ដោយសេចក្តីគោរព ។ ព្រះពោធិសត្វក៏ទ្រង់ព្រះរាជទានគ្រឿងជប់
លៀងមានបណ្តាតាហារជាដើមផង គ្រឿងអលង្ការកស្តាល្អផ្ទែកៗជាអនេក
ប្រការផង ចំពោះពួកព្រះរាជានឹងពួកពលយោធាតាំងអស់ តាមសមគួរ
ដល់ឋានៈនៃអ្នកដែលត្រូវទទួល, ដោយហោចទៅសូម្បីតែអ្នកឃ្វាលដំរី
ក៏ព្រះចក្តីទ្រង់ព្រះរាជទានច្បាក់មាសជាច្រើនគប់ៗគ្នាដែរ ។ ក្នុងទី
ក្រុងពារាណសីតាំងមូល ដែលមានទំហំ ១២ យោជន៍ ពុំតែសូរស័ព្ទរំងំ
ដែលគេច្រំដោយក្លែងតូរ្យតន្ត្រី នឹងសូរសំឡេងមនុស្សប្រុសស្រីច្រៀង
ពំធ្លើយឆ្ងល់គ្នា, អស់តាំងលែងក៏ឮគ្រប់ប្រការ ក៏មានឥតសល់ចន្លោះ,
មហាជនក្នុងជែនតាំងអស់ ក៏មានសេចក្តីសុខក្សេមក្សាន្ត ឥតមានអ-
ន្តរាយឥតមានហេតុមិនជាទីពេញចិត្តបន្តិចបន្តួចសោះ ដោយអំណាចពាជ-
តេជៈព្រះមហាបុរស ដែលផ្សាយទៅប្រកបដោយធម៌ ។

ថ្ងៃមួយ ពួកព្រះរាជាតាំងអស់ ចូលទៅគុនព្រះសីរគំនាប់ ធ្លុះ
អញ្ជលីថ្វាយបង្គំ ចំពោះព្រះបរមពោធិសត្វ ដែលទ្រង់គង់លើរតនបល្ល័ង្ក
ហើយក្រែងសេចក្តីសរសើរព្រះពោធិសត្វថា

យើងខ្ញុំព្រះអង្គតាំងអស់គ្នា បានឃើញបុញ្ញសិរី ដែល
ផ្សាយទៅសព្វទិដ្ឋដែនដី ក៏សំគាល់ព្រះអង្គថាជាទេវរាជ ជា
ស្តេចទេវតាមានអំណាច ទៅក្នុងឋានតែត្រឹមឯ្ន ដែលពេញ
ដោយទេវសិរីដ៏ជាទិព្វ, បុគ្គលដែលមានជ័យជំនះឈ្នះគេ

ទាំងពាន់ប្រទេស មានតេជះដ៏វិសេស ផ្សាយទៅសព្វទិដ្ឋ
ប្រថពី ដូចសម្តេចព្រះភូមីជាម្ចាស់ជីវិតអង្គនេះ ឥតមាន្ទរណា
ដែលឃើញដែលព្ធទេ តាំងពីមុនៗ រៀងមក ។

ព្រះពោធិសត្ត ទ្រង់ឃាត់ស្តេចទាំងនោះថា

ខ្ញុំជាស្តេចធម្មតា មិនមែនជាព្រះឥន្ទ្រទេ ខ្ញុំមិនមែន
ជាទេវតា ដែលមានបុទ្ធិច្រើនទេ, អានុភាពធំ នឹងសេចក្តី
សុខយ៉ាងនេះ ប្រព្រឹត្តទៅបានដោយកម្ចាំងធមិទេតើ ។

ទើបស្តេចទាំងនោះក្រាបបង្គំទូលស្ងរ, ព្រះពោធិសត្តតបថា
ព្រះអង្គទ្រង់មានសេចក្តីរុងរឿង ដូចជាព្រះអាទិត្យដែល
កំចាត់ងងឹតឲ្យសាប់សូន្យទៅដោយរស្មីតើដោយបានបំពេញ
បុញ្ញកម្មដូចម្តេច? ។

ព្រះពោធិសត្តទ្រង់មានជាតិស្សរញ្ញាណ ទ្រង់ប្រកាស
បុព្វកម្មដែលព្រះអង្គបានធ្វើហើយថា

សូមព្រះអង្គទាំងឡាយចាំស្តាប់ពាក្យខ្ញុំ, ខ្ញុំបាន្ទូវសរីសម្បត្តិ
ប្រាកដដូច្នេះ ដោយបានធ្វើនូវបុព្វកម្មឯណា, បុព្វកម្មនោះ
គឺពីដើម ខ្ញុំជាអ្នកពោលនូវពាក្យតោរព, លះចង់នូវវេរាទាំង
ប្រាំប្រការ, ឥតមានចិត្តជាប់ចំពាក់ដោយសេចក្តីបុស្សា
ច្រវែណនិន្ទាជល់ន្រណា ។ ឡើយ, មិនមានសេចក្តីក្រោធ
មិនខ្ចល់ខ្ចាយក្នុងការងារឥតប្រយោជន៍, ខ្ញុំជល់នូវសេចក្តីសុខ
ប្រាកដដូច្នេះ ដោយបានធ្វើអំពើល្អដូច្នោះឯង ។

ព្រះបរមពោធិសត្ត ទ្រង់ប្រកាសបុព្វចរិតរបស់ព្រះ
អង្គជូច្នេះហើយ ទើបទ្រង់ប្រទានឧវាទតទៅទៀតថា
សប្បុរសទាំងឡាយអ្នកប្រាថ្នានូវសួស្ថីនឹងជ័យជំនះក្នុងលោក
នេះនឹងក្នុងលោកខាងនាយ ស្ថិតែលះបង់ជីវិត មិនត្រូវលះ
បង់វាចាល្អឡើយ, មិនត្រូវសម្ងាប់សត្ត, មិនត្រូវលួចលាក់
ធបំបាត់ទ្រព្យអ្នកដទៃ, មិនត្រូវប្រព្រឹត្តមោះពុំតាប់នឹងបុរស
ស្ត្រីដែលមិនមែនជាស្វាមីកិរិយារបស់ខ្លួន, មិនត្រូវនិយាយ
កុហក, ត្រូវវៀរបង់ចាកការបរិភោគគ្រឿងសើរឹង, ជន
ណាអាចធ្វើយ៉ាងនេះបាន, ជននោះរមែងបានន្ទូវសួស្ថី នឹង
ជ័យជំនះជូចសេចក្តីប្រាថ្នា បពិត្រក្សត្រទាំងឡាយបុគ្គលត្រូវ
តែពិចារណាឲ្យសេច សឹមធ្វើ, មិនត្រូវធ្វើដោយឥតពិចារ-
ណាឡើយ, យសនឹងកិត្តិស័ព្ទល្អ រមែងមានកុះករល្បីខ្ចាយ
ទ្ធរចំពោះព្រះរាជា ដោយសារតែមានសេចក្តីពិចារណា,
សូមព្រះអង្គទាំងឡាយរក្សាអាណាប្រជាជន ឲ្យត្រឹមត្រូវ
តាមរាជធមិ, សូមព្រះអង្គទាំងឡាយព្រះរាជទាន ព្រះរាជ-
ទ្រព្យឲ្យទៅជាទានរាល់ៗថ្ងៃ, សន្សំសេចក្តីល្អឲ្យរឿយៗ, កុំ
លុះអំណាចសេចក្តីកំណាញ់ឡើយ ។

ព្រះរាជាគ្រប់ព្រះអង្គ ទ្រង់ព្រះសវនាការ ស្តាប់ធមិទេសនាព្រះ
ពោធិសត្ថហើយ ទ្រង់មានព្រះរាជហ្ឫទ័យរិករាយ ទើបក្រាបបង្គំទទួល
ព្រះរាជឧត្តារថា

បពិត្រព្រះរាជសម្ភារ, យើងខ្ញុំព្រះអង្គទាំងអស់គ្នា សូមផ្ទើ
តាមព្រះរាជទង្ការ ដែលព្រះករុណាទ្រង់ត្រាស់រំលឹកទាំង
ប៉ុន្ទាននោះ ពុំហ៊ានប្រព្រឹត្តកន្ទង, ព្រះអង្គជាសាស្ត្រា ជា
ត្រូអាចារ្យរបស់យើងខ្ញុំព្រះអង្គទាំងឡាយ ញ៉ាំងយើងខ្ញុំព្រះ
អង្គទាំងឡាយ ឲ្យជល់ន្ទូវសុគតិកព ។

ព្រះបរមពោធិសត្ត ទ្រង់ព្រះរាជទានទរាទយ៉ាងនេះហ៊ីយ ទ្រីប
ទ្រង់បញ្ជូនព្រះបាទកដេសុររាជ នឹងព្រះរាជាទាំងនោះ ឲ្យត្រឡប់ទៅ
កាន់នគររបស់ខ្លួន ជាមួយនឹងពួកពលរបស់ខ្លួនត្រប់ចំនួនទាំងអស់ ។
ព្រះរាជាទាំងឡាយនោះមានព្រះរាជហ្ហ្ហ៉ទ័យត្រេកអរជាសោមនស្ស ទ្រីប
ថ្វែងសេចក្តីសរសើរព្រះមហាបុរសថា

ជំណើរដែលយើងទាំងឡាយបានមកកើតជាមនុស្សក្នុងជាតិ
នេះប្រកបដោយផលល្អណាស់, ទាំងជីវិតរបស់យើងក៏ជា
ជីវិតប្រកបដោយផលល្អដែរ ដោយហេតុតែបានកើតនៅ
ក្នុងអំណាចនៃព្រះរាជាដែលប្រកបដោយធម្មតេជះ ។

ព្រះរាជាទាំងនោះសរសើរដូច្នោះហ៊ីយ ក៏នាំពួកសេនាត្រឡប់ទៅ
កាន់នគររបស់អាត្មាទីទៃ ៗ រៀងខ្លួន ។ ចំណែកខាងព្រះបរមពោធិសត្ត
ទ្រង់ត្រប់ត្រងអាណាប្រជានុរាស្ត្រក្នុងជម្ពូទ្វីបទាំងមូលដោយមិនប្រើអាជ្ញា
មិនប្រើត្រឿងសស្ត្រា ។ ទ្រង់ចាត់ឲ្យសាងសាលាទាន ៦ ខ្នង គឺនៅ
ទ្រៀបទ្វារនគរទាំងបួន ៤ ខ្នង ត្រង់ពាក់កណ្តាលនគរ ១ ខ្នង ទ្រៀបទ្វារ
ព្រះរាជនិវេសន៍ ១ ខ្នង, ទ្រង់ចំណាយព្រះរាជទ្រព្យ ១ សែនកហាបណៈ

ឲ្យទានដល់សូមយាចកអ្នកកំសត់ទុគ្គតពាល ។ ថ្ងៃដែលបដិសន្ធិអស់ព្រះជន្មាយុ ទ្រង់សោយព្រះទិវង្គតរួចស្រេចព្រះជន្មទៅ ទ្រង់បានទៅកើតក្នុងឋានទេវលោក ជាមួយនឹងបរិវារទាំងឡាយ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ប្រទានឧទាហរណ៍ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ជនណាមួយ ទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី បើចង់បានជោគជ័យ សេចក្តីសម្រេច សេចក្តីសុខ ត្រប់ទីដម្បន់ទាំងអស់, ជននោះត្រូវបូជាត្រកអាចារ្យមាតាបិតា ដោយវត្ថុដ៏ប្រសើរ ហើយចំរើនបដិបត្តិអស់ជីវិត, មិនត្រូវប្រព្រឹត្តកន្ទុះសាសនា, មិនត្រូវធ្វើបញ្ចាវេរ ទើបបានទូវជោគជ័យ សេចក្តីសម្រេច សេចក្តីសុខសមគួរដល់សេចក្តីប្រាថ្នា ដូចជាព្រះសុវណ្ណកុមារនេះឯង ។

សត្ថា រំអង្គុសម្តេចព្រះបរមសពេជ្ឈសាស្តាចារ្យ ទ្រង់នាំព្រះធម្មទេសនានេះមកសំដែងសព្វគ្រប់ហើយ ទ្រង់ប្រកាសទូវអរិយសច្ចទាំង ៤ ប្រការ ចប់ស្រេចហើយ ភិក្ខុទាំងអស់ក៏បានសម្រេចមគ្គផលទីនៃ ។ មានសោតាបត្តិផលជាដើម; ទើបទ្រង់ប្រដុំជាតកថា ព្រះបាទគជសុរភក្នុងកាលនោះ លុះចរឹលរំដែមក បានជាសារីបុត្ត, ព្រះវរភមាតានៃព្រះសុវណ្ណកុមារ បានជា ព្រះនាងមហាមាយាទេវី, ព្រះវរភបិតាបានជាព្រះបាទសុទ្ធោទន, ព្រះភគ្គ បានជាអនុរុទ្ធ, ព្រះសុវណ្ណកុមារគឺជាតួអង្គព្រះតថាគតជាសាស្តាចារ្យនេះឯង ដែលទ្រង់សំដែងធម្មចក្រទៀបគល់ពោធិព្រឹក្ស; អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ សុវណ្ណកុមារជាតក ទី ១៥ តែប៉ុណ្ណោះ ។

ផ្នែកអក្សរសាស្ត្រ

ការទស្សនានិម្មាបនកម្មខ្មែរ

(Regard sur l'Architecture Khmère)

និពន្ធដោយលោក ហង់រ៉ - ម៉ាក្សសាល់, នាយកិត្តិយសផ្នែការនៅមន្ទីរ

ស្រាវជ្រាវបុរាណវត្ថុនៃសាលាបារាំងសៃសទាងបូពាំប្រទេស

អ្នកប្រែរៀបរៀង: ញ៉ែម - ទ៉ិម

លេខាធិការនៅពុទ្ធសាសនបណ្ឌិត្ស

ខ្ញុំមានសេចក្តីពេញចិត្ត នឹងពោលលាតបង្ហាញនូវទស្សនាការមួយ យ៉ាងសង្ខេបអំពីនិម្មាបនកម្មខ្មែរទូទៅ ។ ពាក្យប៉ុន្មានម៉ាត់នេះ មានផ្ទើ ឲ្យពួកបស្ចិមទិសភ្ញាក់ផ្អើលជាក្រៃលែង ។

ប្រាសាទខ្មែរតាំងឡាយ បើគេក្រឡេកមើលមួយគ្រូត, គេស្មានហាក់ដូចជាគំនរថ្មស្រុតបាក់បែក, ទាស់តែត្រង់ជុំសិលាតាំងនោះ សុទ្ធតែមានរូបភាពផ្សង ៗ ត្នាតាំងអស់ដូចជាថែវ (galerie), រាងទេព្តា (archipelle de cloître), កំពូលប្រាសាទជាប្រើនដែលកន្ទែងខ្ទះមានបរិ-វេណតូចល្មម ។ ដូច្នេះ ពួកអ្នកទៅមើលប្រាសាទអង្គរ, បើតាមព្យៀរ - ឡូទី ដំណាល, ត្រូវដើរយ៉ាងរួសរាន់តាមអ្នកមគ្គុទ្ទេសក៍ ដើម្បីមើលឲ្យបានសព្វគ្រប់កុំឲ្យយប់ទាន់, ស្ទាពីថែវមួយទៅថែវមួយ, ធ្ទងកាត់ព្រះលានជាប្រើន, ហើយត្រូវឡើងយ៉ាងខំទៅលើខឿនខ្ពស់ ៗ លើដំបូលតាមជណ្តើរ ៗ ចោត ៗ ហើយបាក់បែកកាំខ្ទះផង ជាហេតុឲ្យមានការលំ-

ជាកជាប្រើនដល់ពេលចុះមកវិញ ចំពោះជនណាដែលមានកេតវិលមុខ
ប្រចាំនៅនឹងប្រាណ ។

កាលដែលខ្ញុំពោលដូច្នេះ មានជនខ្ទះធ្ងល់សួរខ្ញុំថា ចុះបើមានការលំ-
ជាកដូច្នេះ តើមហាក្សត្រិយ៍នឹងបរិភារព្រះអង្គធ្វើដូចម្តេច ដើម្បីយាងចុះ
តាមជណ្តើរនោះជាន? ការធ្វើយាងាយសោះ ស្តេចនឹងបរិភារព្រះអង្គ
ឥតយាងចុះតាមជណ្តើរនេះទេ ព្រោះជណ្តើរនេះជាជណ្តើរឡើងពីទី
អាសនៈព្រះ ជនណាក៏ដោយមិនអាចចុះតាមផ្ទូវនេះជានឡើយ ។ មាន
តែព្រះសង្ឆនឹងអ្នករក្សាព្រះពុទ្ធអង្គប៉ុណ្ណោះទេ ដែលមានអំណាចចុះឡើង
តាមនោះជាន ។ សាសនាហិណ្ឌូតឹយ៉ាងដូច្នេះឯង ។

ប្រាសាទខ្មែរទាំងនោះបង្ហាញឲ្យយើញនូវអតិតកាលដ៏រុងរឿង, នៅ
ជំនាន់ដែលប្រទេសកម្ពុជាសម្បូរណ៍ទៅដោយផលានុផល, កិត្តិយសនឹង
កិត្តិគុណយ៉ាងល្បីល្បាញ ។ គឺជាជំនាន់ដែលក្សត្រខ្មែរជាមេចម្បាំងមួយ
យ៉ាងឯកនឹងជាមេបញ្ជាការយ៉ាងឈ្ទាសវៃសោយរាជ្យនៅលើអាណាចក្រ
ដ៏ធំទូលាយ ។

ក្សត្រទាំងនោះសុទ្ធតែបានសង់ប្រាសាទពាសពេញ ព្រោះមាន
ព្រះរាជធានីខ្ទះមានឈ្មោះថាអង្គរ ហិតនៅខាងជើងជំបន់ទន្ទេសាប ។

រាជធានីមួយ ។ មានស្នាមក្ទោះ, មានស្រះជីក, មានកំពែងព័ទ្ធ
ជុំវិញ ។ នៅកណ្តាលវត្ថុទាំងនោះហើយដែលគេឃើញប្រាសាទជា
ប្រើនសាងថ្វាយព្រះឥស្សរ, ព្រះវិស្ណុឬព្រះមហាសាវ័កនៃព្រះពុទ្ធ

(Grand sage du Bouddha) ។

ក្បត្តែមួយអង្គ។ តែងចង់ចាន់ថ្មាសាទមួយ។ ដើម្បីឧទ្ទិសចំពោះព្រះអាទិទេពដែលក្បត្តែអង្គនោះឯង ធ្វើជាតំណាងព្រះអាទិទេព ទៅលើលោកយើងនេះ ; ហើយសំខាន់បំផុតគឺទុកថាវត្តព្រះនាមព្រះអង្គនៅក្នុងថ្មាសាទនោះ ; ក្រោយពេលដែលព្រះអង្គទ្រង់ចូលព្រះសុរណ្ណកោដ្ឋទៅ ។ ត្រង់នេះតន្ត្រីឲ្យយើញថាប៉ែគេចូលទៅក្នុងផ្ទៃប្រទេសកម្ពុជា, គេនឹងឃើញថ្មាសាទជាច្រើនដែលគេស្មានប្រមាណជិតមួយភាគ៥ថ្មាសាទ ។ ពីដើមទៅកំឡុងសតវត្សទី ១២ ទី ១៣ ទំនងទី ១៤ ប្រទេសខ្មែរជាអាណាចក្រមួយមានឈ្មោះលាន់ឮខ្លាំងសុះសាយ, ជានគរឯកភាពមានផ្ទៃដីធំទូលាយ ក្រៃលែងគឺប្រទេសឥណ្ឌូចិនទាំងមូលរួមជាមួយនឹងប្រទេសសៀមប្រទេសលាវមួយផ្នែកៗទៀត ។

បណ្ដាអ្នកច្បាជ្ញទាំងឡាយ ដែលសរសេរអត្ថបទពីនិម្មាបនកម្មខ្មែរ, តាមការយល់របស់ខ្ញុំ មានតែអ្នកច្បាជ្ញម្នាក់ទេគឺលោក ហាវ៉ាំរី-មួហ្ស ដែលបានទិញន្នរឿងនេះក្បោះក្បាយជាងគេ ។ លោក ហង់រី-មួហ្ស ជាអ្នកច្បាជ្ញខាងធម្មជាតិបានធ្វើដំណើរការសេញក្នុងប្រទេសកម្ពុជា ។ ជាលើកដំបូងបង្អស់គឺនៅឆ្នាំ ១៨៥៩ លោកបានអញ្ជើញទៅដល់អង្គវត្ត រួចតមកលោកក៏យកវឿងនោះមកដំណាលច្បាប់ច្បាជាជន ឲ្យបានស្គាល់អង្គរវត្តគ្រប់ៗគ្នា ។ ប៉ុន្តែខ្ញុំសូមដំកបបន្ថែមថា ទៅលើទំព័រអត្ថបទទាំងនោះអ្នកនិពន្ធពុំបានពោលឲ្យហ្មត់ចត់អំពីប្រវត្តិនៃនិម្មាបនកម្មខ្មែរមានប៉ុន្មានទេ អ្នកនិពន្ធគ្រាន់តែបញ្ចេញទឹកចិត្តពោលស្ងើចសរសើរ ខ្លួវការចាប់អារម្មណ៍ចំពោះនិម្មាបនកម្មប៉ុណ្ណោះ ។ ដូច្នេះ អត្ថបទដែលពោលអំពី

និម្មាបនកម្មវិធី មានខ្លះសេចក្តីជាច្រើនមិនគ្រប់គ្រាន់ ដូចអត្ថបទដែលដំណាលពីប្រាសាទអង្គរនេះឡើយ ។

កាលនៅសតវត្សទី ១៣, មានចិនម្នាក់ឈ្មោះ ជាវ-តា-ក្វាន់ បានមកមើលអង្គរ, ធ្វើដំណើរទៅសុពញ្ញកន្លែបទេសខ្មែរ រួចបានសរសេររឿងនោះយ៉ាងសព្វគ្រប់ ។ អត្ថបទរបស់ ជាវតាក្វាន់ នេះ គេច្រើមួលខ្លះជាឯកសារមួយយ៉ាងឯកពោលអំពីដីរកាពប្រជាជនខ្មែរនៅពេលនោះ និងអំពីពិធីផ្សេងៗដែលគេនិយមធ្វើនៅក្នុងលានព្រះរាជវាំង ។ មានបងប្អូនខ្មែរជាច្រើនក៏បាននិយាយប្រាប់ខ្ញុំសព្វគ្រប់អំពីរបៀបរៀបការដីរកម្ម និងអំពីការរៀបការខ្មែរនៅសម័យនោះ ដោយបង្ហាញរូបភាពលើសិលាចារឹកៗទាំងនោះមិនប្លែកគ្នាពីរូបគំនូរ ដែលគេឆ្លាក់នៅលើផ្សារភ្ជាប ជាតិអេហ្ស៊ីបឡើយ ។

សាវតារក្នុងប្រទេសនិងរឿងព័ត៌មានក្នុងរដ្ឋការស្តេចនីមួយ ដែលតែងមានឡើងជាលំដាប់លំដោយតាំងពីសតវត្សទី ៧ រហូតមកទល់សតវត្សទីដំនាន់ដែលអាណាចក្រខ្មែរធ្លាក់ចុះអាប់អោនបន្តិចម្តងៗ ធ្វើឲ្យយើងស្គាល់បាន ដោយសារមានចារឹកនៅលើជញ្ជាំងប្រាសាទឬនៅលើគោលថ្មផ្សេងៗ ។ អក្សរចារឹកទាំងនោះជាសំស្លឹតឬជាអក្សរខ្មែរបុរាណ ។

មានអ្នកប្រាជ្ញខ្លះដូចជាលោកហ្សីលីព្វ-ស្តេន និងអ្នកស្រីកូម៉ាល់-ដឺរ៉ែមុយសាត់ ទើបអាចពោលវែកញែកសព្វគ្រប់អំពីការវិវត្តន៍នៃសិល្បៈខ្មែរដោយមានលក្ខណៈច្បាស់លាស់នៅគ្រប់រដ្ឋការកូត្រែនីមួយៗ ។ ដូច្នេះយើងក៏បានដឹងរឿងនោះយ៉ាងជាក់ច្បាស់ នៅគ្រប់ប្រាសាទទាំងឡាយក្នុងកម្ពុជរដ្ឋ ។

ដោយសារការស្វែងរកទាំងអម្បាលម៉ានេះ, គេសង្កេតឃើញ
បែបនិម្មាបនកម្មនៅសតវត្សរ៍ទី ៩ ជាឧទាហរណ៍ខុសគ្នាស្រឡះពីនិម្មាបន-
កម្មនៅសតវត្សរ៍ទី ១១ ឬទី ១២ ដូចគ្នានឹងនៅប្រទេសបារាំងបែបនិម្មាបន-
កម្ម៉ូម៉ាំងខុសគ្នាអំពីនិម្មាបនកម្មនៅជំនាន់ព្រះបាទល្វីទី ១៤ ឬ ល្វីទី ១៥ ។
តាមរឿងហេតុទាំងនេះ ឃើញថាប្រទេសកម្ពុជា ជាប្រទេសមានឥទ្ធិ-
ពលជាងប្រទេសឥណ្ឌាឬជ្ជា ព្រោះនៅលើប្រាសាទផ្សេង ៗ នៃប្រទេស
ឥណ្ឌា គេឃើញរូបចម្ងាក់តិចណាស់មិនដូចជានៅលើប្រាសាទខ្មែរទេ ។
អស់ពេលជាយូរមកហើយ គេតែងពោលថាសិល្បខ្មែរកើតមានតាំងពី
អតីតកាលដ៏អង្វែងមកម្ទើះ តែគេចាំសាវតារពុំច្បាស់ ។

ចំណែកខ្ញុំ ៗ បានជួបទេសចរជាច្រើនដែលខ្ញុំបាននិយាយប្រាប់អំពី
តាលបរិច្ឆេទយ៉ាងត្រឹមត្រូវនៃប្រាសាទអង្គរវត្ត ។ ខ្ញុំបានជំរាបប្រាប់គេថា
ប្រាសាទអង្គរកើតឡើងជំណាលគ្នានឹងជំនាន់ប្រទេសបារាំង កើតមានព្រះ
រិហារខាងសាសនា ។ ការដែលខ្ញុំនិយាយប្រាប់គេនោះត្រូវណាស់ បើ
ប្រសិនជានៅពេលដែលខ្ញុំកំពុងថ្ងៃងរៀបរាប់នោះ, ទេសចរអ្នកស្តាប់កំពុង
តែចោលអារម្មណ៍ទៅលើប្រាសាទខ្មែរ ។

ព្រះរិហារទាំងឡាយក្នុងប្រទេសកម្ពុជា ដែលគេសាងឧទ្ទិសចំពោះ
ព្រះឥស្សរ, ព្រះព្រហ្ម, ព្រះវិស្ណុ សុទ្ធតែមានកត់ចារិកជាសំស្ក្រឹតដែលជា
ប្ញរាណកាសានៃប្រទេសឥណ្ឌា ។ សំអាងទៅលើរូបចម្ងាក់ទាំងនេះគេ
អាចពោលបានថា និម្មាបនកម្មខ្មែរទាំងឡាយសុទ្ធតែចម្ងងឬយកតំរូតាម
សិល្បៈឥណ្ឌា ។ មានអ្នកខ្ទះហ៊ានទាំងពោលថា ជាងដែលសាងប្រា-

សាទអង្គរសុទ្ធតែពួកនិម្មាបនិក (Architectes) មកពីប្រទេសឥណ្ឌា ។ ប្រជាជនកាគប្រើនក៏ព្រមជឿតាម ថែមទាំងបានផ្សាយប្ដសរសេរថា និម្មាបនកម្មខ្មែរដែលមានកំណើតកើតចេញពីនិម្មាបនកម្មហិណ្ឌូនោះ គ្រាន់តែជានិម្មាបនកម្មរបស់ឥណ្ឌាទៅតាមអាណាទេត្តគេផង ។

ដែលពោលដូច្នោះមិនពិតសោះ ព្រោះខ្ញុំបានទាំងផ្ទើជំណើរកាត់ប្រទេសឥណ្ឌា ចាប់តាំងពីខាងជើងរហូតទៅខាងត្បូងប្រទេស ដើម្បីមើលប្រាសាទក្នុងនគរនោះ រួចខ្ញុំបានពិនិត្យយ៉ាងហ្មតចត់ទៅឃើញមានប្រាសាទខ្ទះល្អធើតមែន, ប៉ុន្តែជល់សង្កេតមែនទែនទៅឃើញតួរាងនឹងសណ្ឋានសិល្បខុសគ្នាស្រឡះពីសិល្បនៅប្រទេសខ្មែរ ។

ឧបមាដូចជានៅលើផ្ទៃប្រទេសឥណ្ឌា គើគេឃើញមានវិថីប្រាសាទយ៉ាងល្អវិចិត្រចូលទៅកាន់កន្ទែងអាសនៈព្រះកាត់ស្នាមក្ទោះ, កាត់ស្រះជីកមានបង្ហាន់ដែអមសងខាងធ្ទាក់ជារូបយក្សទ្រូបនាគរាជទេ ?

រូបកាពយ៉ាងសម្បើមនៃសិល្បខ្មែរនេះ បើប្រសិនជាគេសាងឡើងដើម្បីរំលឹកជល់រត្ទុអ្ទីមួយនោះ, គេអាចប្រៀបទៅនឹងវិថីហៅដ្ឋូម៉ូសចូលទៅក្នុងប្រាសាទអេហ្សិបបាន ។

បណ្ណាប្រាសាទខ្មែរមួយណាដូចមួយណា, ពួកទេសចរត្រូវប្រឹងដោយពេញកំឡាំងដើម្បីឡើងតាមជណ្ណើរធំ ៗ ទៅលើទឿនជាប្រើនជាន់ប្រើនថ្នាក់មានរាងដូចស្ពូបពិសិដ្ឋមួយ ។ គឺនៅលើកំពូលស្ពូបនោះហើយដែលគេសង់ទីអាសនៈជាន់ខ្ពស់ (Sanctuaire centrale) ។ រប្រៀបសិល្បខាងលើនេះគេពុំដែលឃើញទេនៅប្រទេសឥណ្ឌា តែចំពោះជនណា

ដែលបានទៅមើលប្រាសាទម៉ាយាសនៅប្រទេសអាមេរិកកណ្តាលនោះ។ ពុំអាចទប់ចិត្តមិនប្រដូចប្រាសាទខ្មែរយើង ទៅនឹងប្រាសាទតេអូកាល្ទីនៅមុិក្សិកបានឡើយ ។

មិនតែប៉ុណ្ណោះនៅមានការរចនារាយរងខ្ទះទៀតបញ្ជាក់ឲ្យយើញនូវការល្អធើតធាយនៃសិល្បខ្មែរប្រៀបទៅនឹងសិល្បឥណ្ឌា ។ ដូច្នេះតើនៅប្រទេសឥណ្ឌា គេអាចយើញមានរូបចម្ទាក់ក្បាច់ក្បូរមានបន្ទាត់ខ្ទាត់ខ្ទែងប្រទាក់រយេងរយោងដូចជាប្រាសាទអង្គរវត្តទេ? ដោយសារនៅចន្ទោះខ្ទះ នៃប្រាសាទដែលប្រកបដោយការរចនាយ៉ាងប្រិតប្រៀបបំផុតនោះ ដើម្បីធ្វើឲ្យលេចពីចម្ទាយនៃតួអាសនៈជាន់ខ្ពស់, ដោយសារវាលស្មៅរាបធំធេង, ដោយសាថ្ទុកទឹក, ស្រះជីក ប្រាសាទនោះធ្វើឲ្យវិញ្ញាណអ្នកមើលចាប់ចិត្តនឹកដល់វិមានវ៉ាវសែជាពន់ពេក ។

ឯផែនការសង់ប្រាសាទទៀត ក៏មានរបៀបរៀបរយសមរម្យល្អណាស់ប្រដូចទៅនឹងផែនការដែលគេរៀបតាំ៏អច្ចរិយវត្ថុ នៅសាលាវិចិត្រសិល្បៈនៃប្រទេសរ៉ូម នៅឆ្នាំ ១៨៩០ ។

ពោលដោយខ្ទីទៅ, នៅកុងនិម្មាបនកម្មខ្មែរនេះ• គេសង្កេតឃើញតំនិតរបៀបចិត្តធ្ងន់ធ្ងនៃសិល្បការខុសប្រែកពីប្រាសាទឥណ្ឌា ដែលមានរូបចម្ទាក់ស្ទើរតែពុំស្គាល់ជាអ្ទិ ។ តំនិតទេមរៈសិល្បការយើងនេះប្រហែលគ្នានឹងតំនិតពួកអ្នកប្រាជ្ញធំ។ នៅអ៊ីរ៉ុប ។ ដោយសារអង្គរវត្តជាស្នាដៃឯកនៃសិល្បខ្មែរ, គេអាចដឹងច្បាស់ថាអាណាចក្រខ្មែរពីដើមជាអាណាចក្រមានសាវតារយ៉ាងខ្ពង់ខ្ពស់ខាងសិល្ប ។ និម្មាបនកម្មខ្មែរ ប៉ើយើងពិនិត្យ

ឲ្យហ្មត់ចត់តាំងពីក្បាច់ល្អិតល្អោចបន្តិចបន្តួច រហូតដល់ក្បាច់ចម្ងាក់ធំៗ ឃើញថ្លែកគ្នាទាំងអស់ ។ មានប្រាសាទពីរទៀត គឺប្រាសាទ ទ ទ

ចម្ងាក់ទឹងពងអេក្សាច់ឃើញថានៅខ្ពើណាស់ គ្មានកន្លែងត្រង់ណាមួយ ដែលបង្ហាញឲ្យឃើញនូវចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់សោះ ។

ការរចនាដែលមានសណ្ឋានជាជ្រុង។ (art gothigue) លេចលយយ៉ាងខ្ពស់ត្រដែតទៅលើអាកាសនគរយ, មានកំពូលស្រួចគួច។ អមជុំវិញ គួរឲ្យល្អមើលមែន ប៉ុន្តែបើសង្កេតមើលបន្ទាត់ទទឹងបន្ទាត់ផ្តេកឃើញថាគ្មានច្រើនណាស់ ។ ផ្ទុយទៅវិញ ប្រាសាទគ្រឹកឥញ្ចិតទេសចរឲ្យចង់តែទស្សនាដោយសារតែប្រាសាទនោះមានបន្ទាត់ ចម្ងាក់សមល្មមហើយត្រង់។ មានសមាមាត្រជាមាត្រដ្ឋានមនុស្សលោកផ្ទើ, ប៉ុន្តែបើនរណាពោលថាជាស្នាដៃទេវតានោះគឺយល់ខុសស្រឡះទេ ។

ចំណែកទង្វាយបនកម្មប្លាក់ងនៅសតវត្សរ៍ទី ១ ទឹងទី ១៥ វិញ ដែលមាននៅទឹងវិហារខ្លះ បង្ហាញឲ្យឃើញថាមានជម្រៃថ្លៃថ្នូរមានខ្លឹមសារគ្រាន់បើដែរ ប៉ុន្តែពុំសូវសម្បើម, ពុំសូវទាញអារម្មណ៍ អ្នកផងឲ្យចង់ទស្សនាប៉ុន្មានទេ ។

ដូច្នេះចង្អុលឲ្យឃើញថា មួយចំណែកនៃទង្វាយបនកម្មខ្មែរកើតគំនិតចេញមកអំពីប្រាសាទតាំងពីយូរយែងដែលខ្ញុំបានកប់រៀបមកខាងលើនេះ ។ ប្រាសាទមានពងដូចស្លុប ដែលមានការរចនាងាយល្មមមិនពិបាកពេកមិនស្រណុកពេកបិតនៅឯបាតងនឹងគោះកែ ។

ក្បាច់រចនាដែលមានសណ្ឋានជ្រុង។ មូល។ បន្ទិចមានធ្លាក់នៅជុំវិញបរិវេណកំពូលប្រាសាទដែលលយក្លាប់ទៅនឹងហោរដៀង ពាក់ព័ន្ធជា

ច្រើនត្រួត ថែមទាំងបន្ថុបថ្មជាច្រើនពីលើដើម្បីបំពេញជ្រុងចម្ងាក់ នៅ-
ក្បាលសសរជាប់នឹងដំបូល ។

ជាលើកដំបូងគេយើញសិល្បក្រិក នៅនឹងអង្គរត្រង់ក្បាលសសរទី
ពីរ ជាប់នឹងក្បាលសសរទ្រដំបូលនៃប្រាសាទអង្គរវត្ត ដែលយើងស្គាល់
ជាក់ជាងគេ ។ ត្រង់នេះ ខ្ញុំមានបញ្ហាមួយចោទឡើងថា: ចុះហេតុដូច
ម្តេចបានជាសិល្បក្រិកព្ធសាយមកដល់តាមធ្មេរទន្ទេមេគង្គ? ។ មុននឹង
ធ្វើយសំនួរនេះ យើងត្រូវដឹងថាលោកអាឡិចសង់-ឡឺ-ក្រង់ ជាស្តេច
ប្រទេសម៉េដ្ទានៅខាងជើងប្រទេសក្រិកបាននាំយកទម្រង់សិល្បខ្ទះមកពី
ប្រទេសឥណ្ឌៀខាងជើងដូចជាព្រះពុទ្ធរូបជាដើមដែលគេនាំយកទៅស្រុក
គេនោះសុទ្ធតែធ្ងាក់ព្រះកន្ត្រទាំងអស់ បើមិនពួកក្រិកធ្ងាក់ក៏ពួកកូនសិស្ស
ជាងដែលរៀននៅសាលាក្រិកធ្ងាក់ដែរ ។ ហេតុដូច្នេះហើយបានជាព្រះ
ពុទ្ធរូបនៅប្រទេសក្រិកជាន់ដើម មានទ្រង់ទ្រាយប្រហែលគ្នានឹងរូបព្រះ
របស់គេឈ្មោះអាប់ប៉ូឡុង ។ រួចចាប់ពីប្រទេសឥណ្ឌៀមកតាមប្រទេស
អាស៊ីកណ្ណាល គេយើញមានបុរាណវត្ថុជាច្រើនដែលជាប់ទាក់ទងនឹង
សិល្បក្រិក, អ៊ីរ៉ង់, ពៀរ៉សង់ ហើយវត្ថុទាំងនោះមានសាយចូលទៅដល់
ប្រទេសចិននឹងប្រទេសជប៉ុន, រួចត្រឡប់ចេញពីប្រទេសទាំងនេះចូល
មកប្រទេសឥណ្ឌូចិន ។

ក្រៅពីនោះមានក្បាច់ក្សូរខ្ទះទៀតដែលនៅនឹងផ្នឹមទ្វារ ឬនៅលើ
សិលាចារិកនៃសិល្បខ្មែរជំនាន់សតវត្សរ៍ទី ៩ នឹងទី ១០ នោះមិនមែនឥត

ខ្ចឹមសារទេ គឺពិតជាមានខ្ចឹមសារហើយថែមទាំងល្បីល្បាញលាន់ញ្ចរន្ធឺ ប្រហែលគ្នានឹងវិហារបារាំងជំនាន់សតវត្សរ៍ទី ១៧ នឹងទី ១៨ ដែរ ។

ខ្ញុំសូមបញ្ជាក់ថាដែលខ្ញុំពោលនេះ គឺខ្ញុំពោលពីសិល្បខ្មែរនៅសតវត្សរ៍ទី ៩ នឹងទី ១០, ពីព្រោះនៅក្នុងសិល្បថៃនឹងសិល្បខ្មែរបច្ចុប្បន្ននេះមានក្បាច់ក្បូររាងផ្ការ៉ាក្រីដែលកើតឡើងនៅជំនាន់ល្ងីទី ១៥ នឹងល្ងីទី ១៦ លាយឡំគ្នាច្រើនណាស់ ។ ការនេះបញ្ជាក់ឲ្យឃើញថា កាលប្រទេសសៀមបញ្ជូនឯកអគ្គរាជទូតទៅកាន់ប្រទេសនោះក្នុងជំនាន់នេះ ។ លុះឯកអគ្គរាជ-ទូតនោះត្រឡប់មកវិញក៏បាននាំយកក្បាច់ក្បូរខ្ចះមកបំភ្ងឺប្រជាជនគេផង ។

ខ្ញុំសូមស្ងេះរឿងសិល្បតែប៉ុណ្ណេះ ។ បន្ទាប់ពីនេះខ្ញុំនឹងដំណាលពីប្រាសាទសិលាខ្មែរនៅអតីតកាល ដែលសព្វថ្ងៃមានសុទ្ធតែស្ងែជុះរុំពីទ្ធពាសពេញ ។

កាលជំនាន់ដើមប្រទេសខ្មែរជាប្រទេសថ្ពុំថ្ពើងរុងរឿងណាស់ មានក្សត្រប្រកបដោយទសពិធរាជធម៌សោយរាជ្យលើអាណាចក្រនេះ ដែលខ្ញុំនឹងអធិប្បាយដោយអន្ធើ ៗ ជូនជាសណ្តាប់ ។ នៅថ្ងៃផ្ងីបុណ្យខាងសាសនាឬបុណ្យផ្សង ៗ ទៀត, ព្រះភិក្ខុសង្ឆជាច្រើនបានជង្ហែព្រះពុទ្ធ-រូបកណ្តាលចំណោមប្រជាជននៅលើវិថីធំ ៗ ទាំងឡាយដែលសព្វថ្ងៃស្ងាត់សូន្យឈឹង ។ នៅពេលនោះគេសង្កេតឃើញព្រះមហាក្សត្រទ្រង់ប្រ-ជាប់ដោយសំលៀកបំពាក់មានរំយោលរំលេចយ៉ាងធើតធាយ ឥង់នៅកណ្តាលអស់អ្នកអស់នាងនឹងនាហ្នឹនសព្វមុខមន្ត្រី ។ ខាងមុខ មានពួកទាហានរក្សាព្រះអង្គ ស្ងៀកពាក់សំលៀកបំពាក់យ៉ាងធើតធាយកាន់ទង់-

ជ័យជាតិ ។ ខាងក្រោយ មានពួកស្រីបរិវារមីរដេរជាសដើរតាមក្សួន ។ សំឡេងតូរ្យតន្ត្រីលាន់ញ្ជរន្ធឹពាសពេញលាយឡំនឹងសូរស័ព្ទអំណរនៃប្រ-ជាជន ។ រីឯប្រាសាទតំងឡាយក្នុចាំងតែចះតែចែងក្រោមរស្មីព្រះអាទិត្យ ។ រឿងតំងនេះ ខ្ញុំបានជឹងពីអ្នកជំណើរចិនម្នាក់ ដែលខ្ញុំបានជំរាបពីមុននេះ ព្រោះគាត់បានទៅមើលពិធីនឹងក្សួនជង្ហែនោះផ្ទាល់នឹងក្នែកគាត់ ។

គាត់បានជំណាលបន្ថែមទៀតថា កំពូលប្រាសាទតំងនោះសុទ្ធតែធ្វើអំពីមាសប្រាក់នឹងស្ពាន់ សូម្បីតែបរិវេណកំពូលក្រោម ។ ក៏ស្រោបសន្ធឹកមាសឬប្រាក់ដែរ ។ តែសព្វថ្ងៃនេះនៅសល់តែស្នាមឡៅ ។ ទេជាប់នៅនឹងថ្ម ។ អំណាចក្សីតែខ្មែរពីដើមបានធ្វើឲ្យអ្នកផងកោតស្រប់ស្រែងចាំពុំក្នេចសោះទ្យើយ ។ ស្ទើរតែប់គ្នាធ្ងល់ថាចុះហេតុអ្វី បានជាជំនាន់ដែលប្រកបទៅដោយកិត្តិគុណ, ដោយរិទ្ធិអំណាច, សេចក្តីសុខសេចក្តីចំរើន, សម្ស្យរធនធានហូរហៀរនោះក៏ធាប់រិនាសម្ទ៉េះ? ខ្ញុំសូមជំរាបថា ដោយហេតុនៅពេលដែលស្រុកកើតចម្បាំងរាំងជល់នឹងសៀម ទ័ពសៀមក៏ចូលមកលុកលុយប្រទេសកម្ពុជា នៅសតវត្សរ៍ទី ១៦ នៅពេលនោះស្រុកខ្មែរទៅជាអត់ឃ្ងានរាំងរីងហួតហែងទឹកអស់ ។ ស្ទឹងបឹងបួតំងប៉ុន្មានគោកក្រញង់គ្មានសល់ ជាហេតុបណ្តាលឲ្យផលដំណាំដាំដុះផ្សង ។ រិនាសហិនហោចអស់ ។ ពេលនោះទ័ពសៀមក៏ពុំបានតាំងទីលំនៅ ។ អង្គរដែរពិតមែនតែស្តេចខ្មែរបានរត់គេចចេញហើយក៏ដោយ ។

ការខ្ទះទឹកប្រើប្រាស់នេះបង្ខំឲ្យប្រជាជនរត់ចោលទីលំនៅអស់ ជាទកាសបើកដៃឲ្យរុក្ខជាតិលការស្ងៃជុះគ្របសង្កត់លើប្រាសាទ្យុរាណ។ ទាំងនោះ, ចាក់ឬសពាសពេញចូលទៅក្នុងប្រាសាទបណ្តាលឲ្យជញ្ជាំងនឹងពិតានស្រុតបាក់បែកខ្ទេចខ្ទី ។ ព្រៃឈើមួយជុះយ៉ាងធំក្រាស់ជំនួសកន្ទែងដែលមនុស្សធ្លាប់លេងអ៊ូអរពីមុន ។

លុះមកដល់ឆ្នាំ ១៩០៨, ពេលដែលសៀមប្រគល់ខេត្រ់បាត់ដំបងនឹងសៀមរាបមកខ្មែរវិញ រាជការបារាំងសែសបានចូលមកដល់អង្គរវត្តរួចក៏បានកាប់ឆ្តាព្រៃផ្សៃ ដែលជុះចាក់ឬសរួតរិតប្រាសាទទាំងនោះអស់, ធ្វើឲ្យលេចឃើញតួប្រាសាទយ៉ាងល្អត្រចះ ។ ស្នាដៃសាលាបារាំងសែសខាងបូពាិប្រទេស បានបន្តការនេះតាំងពីពេលនោះរហូតមកទល់សព្វថ្ងៃ ហើយគេអាចសង្ឃឹមច្បាស់ថា ក្រឹ្តដំណែលយ៉ាងទត្តុង្គទត្តមគឺប្រាសាទ្យុរាណទាំងប៉ុន្មាននេះមុខជាជៀសរួចពីសេចក្តីអន្តរាយ នឹងសេចក្តីធ្វេសប្រហែសនៃប្រជាជនខ្មែរក្នុងការថែទាំអច្ចរិយវត្ថុនេះទៅអនាគតពុំខាន ។

ប្រែចេញពីសារពត៌មាន « កាមបូដ៍ » ចេញពីថ្ងៃ ១៩-៥-៥៥
លេខ ២៨៨៤ នឹងថ្ងៃ ២០-៥-៥៥ លេខ ២៨៨៥ ឆ្នាំទី ១២ ។

ឧកញ៉ារិបុលរាជសេនា ន្ធ-កន ប្រែជ្រៀបជ្រៀង

(តមក)

ជ្រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃផ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

កណ្ឌទី ៦៦

តាំងពីចូធូពិគ្រោះគ្នានឹងគុយកែទីប្រឹក្សា គិតលើកទ័ពទៅវាយឡៅពីចៅហ្វាយស្រុកឈីជីវ រហូតដល់ចូធូឲ្យសេះសិកថាវទៅតួនអ្ហីជាជំនិះ, សេះនេះដើរផ្លូវ ១ ថ្ងៃ ១ មុឹនសិ១ (គឺ ៤០១ ត.ម.) ។

ឧណ.នោះ ទទួលគុយកែចូលមក ។ ចូធូក៏ពិគ្រោះសួរថា យើងនឹងលើកកងទ័ពទៅប្បាំងនឹងឡៅពីនៅស្រុកឈីជីវខាងទិសឯកើត តែបារម្ភក្រែងខាងទិសឯជើងខ្វាចអ្ហិនសៀវជឹង នឹងលើកទ័ពមកសន្ធប់វាយយកក្រុងហ្ហិតោ តើអ្នកនឹងយល់យើញដូចម្តេច? ។ គុយកែធ្វើយថា ឯជំរេះប្រាជ្ញានឹងគំនិតអ្ហិនសៀវនោះ បើនឹងធ្វើការអ្ហីក៏រួសរាន់ណាស់ បើនឹងប្រើនរណាអ្ហិនសៀវក៏រមែងសង្ស័យមិនចុះចិត្តជឿអ្នកនោះ ប្រការ ១

ទៀតសេនាទាហានអ្ហិនសៀវក៏បែកខ្ញែកចិត្តគំនិតពីគ្នា បើប្រសិនណានឹង
លើកទ័ពមកវាយក្រុងហ្ចីតោមែន ក៏គង់មិនសម្រេចតាមគំនិត ឯឡៅពី
សោតក៏ទើបតែត្រឡប់ទៅនៅស្រុកឈីជីវ ហើយទាហានដែលជាប់តាម
ទៅក៏សុទ្ធតែទាហានរបស់យើង ដែលនឹងតិតការធ្វើសឹកសង្គ្រាមនោះ
មុខជាទាហានទាំងពួងមិនស្រុះចិត្តជាមួយគ្នាទេ បើយើងរង់បង្អង់ទុកឲ្យ
យូរទៅទៀត ឃើញថាទាហានទាំងនោះនឹងរួមគំនិតចូលគ្នា ហេតុនេះ
សុំឲ្យលោកបន្ទំលើកកងទ័ពទៅវាយស្រុកឈីជីវជាប្រញាប់ ។ ចូធូបាន
ស្តាប់ក៏ត្រេកអរណាស់ ធ្វើយតទៅគុយកែវិញថា "ដែលយើងសួរនេះ
គឺក្វែងសួរចង់ដឹងដម្រេះប្រាជ្ញានឹងគំនិតរបស់អ្នកទេ ឥឡូវនេះ អ្នកធ្វើយ
មកក៏ជូចគំនិតយើងដែលតិតទុកដែរ" ហើយចូធូក៏ផ្ទុំពលយោធាបាន
ប្រមាណ ៦០ ម៉ឺនលើកចេញចាកក្រុងហ្ចីតោ ។

ពេលនោះ មានបំរើសេះស៊ីបការណ៍ដឹងថាចូធូលើកទ័ពមក ក៏
ស្រូតរូតចូលទៅជំរាបស៊ុនខៀនក្នុងស្រុកឈីជីវថា ឥឡូវចូធូលើកទ័ពមក
ហើយ ។ ស៊ុនខៀនដឹងដូច្នោះ ក៏ទៅប្រាប់តួនអ្ហិនៅស្រុកហែហ្ចឺតាម
ដំណឹងនេះ ហើយឲ្យរៀបចំត្រៀមសេនាទាហានទុកឲ្យព្រម រួចស៊ុន
ខៀនក៏ហួសទៅស្រុកសៀវជាយទៀត ដើម្បីនឹងឲ្យដំណឹងឡៅពី ។ ដឹង
ដូច្នោះក៏និយាយថា "យើងនឹងឲ្យមានសំបុត្រទៅដល់អ្ហិនសៀវទៀត ឲ្យ
លើកកងទ័ពមកជួយទើបនឹងទប់ទល់តនឹងចូធូបាន" តិតហើយក៏សរសេរ
សំបុត្រចាត់ស៊ុនខៀនឲ្យនាំយកទៅឲ្យអ្ហិនសៀវ ។ ស៊ុនខៀនក៏ទទួល
នាំសំបុត្រទៅដល់ស្រុកតីជីវ ក៏ចូលទៅរកទៀនហង អធិប្បាយរ៉ាយ

រឿងឲ្យទៀនហង៍ស្តាប់ត្រប់ប្រការ ហើយថាចូរអ្នកជួយនាំខ្ញុំទៅជួបនឹង
អ្ជិនសៀវ ។ ទៀនហង៍បានស្តាប់ដូច្នោះ ក៏នាំស៊ុនទៀនចូលទៅដល់
អ្ជិនសៀវ ស៊ុនទៀនគំនាប់ហើយ ក៏ជូនសំបុត្រទៅឲ្យអ្ជិនសៀវ ។ មើល
ដឹងសេចក្តីហើយ ក៏មិនមានថាអ្វីសោះ ក្រែងធ្វើជាទុក្ខសញ្ជប់សញ្ជឹង ។
ទៀនហង៍យើញមុខអ្ជិនសៀវសៅហ្មងក៏សួរថា ថ្ងៃនេះខ្ញុំយើញមុខលោក
មិនសប្បាយ តើលោកវិតក្តពីអ្វី? ។ អ្ជិនសៀវធ្វើយថា យើងជិត
នឹងស្លាប់ទៅហើយ ទើបមិនមានសេចក្តីសប្បាយសោះ ។ ទៀនហង៍ថា
ហេតុម្តេចលោកចរចាជាពាក្យអពមង្គល? អ្ជិនសៀវថា ជីវិតយើង
នឹងដល់នូវសេចក្តីស្លាប់ក្នុងថ្ងៃនេះ ឬថ្ងៃស្អែកក៏មិនដឹងទ្បើយ យើង
វិតក្តនឹងបុត្រតាំង ៥ នាក់ យើញថាបុត្រតៅបង្អស់នោះ មានជម្រេះ
ប្រាជ្ញាត្រាន់បើ តែអាយុនៅក្មេងណាស់ ឥឡូវក៏មានជម្លឹយឹងង
ហេតុនេះ ទើបយើងមិនមានសេចក្តីសប្បាយនឹងគិតការអ្វីក៏មិនបាន ។
ទៀនហង៍តបថា មនុស្សតាំងអស់ក៏បានដឹងព្ទត្រប់គ្នាថា លោកជាធំ
បំផុតក្នុងអាណាវិចត្រទិសទត្តរ ហេតុម្តេចលោកមកគិតរួញរាញញើត
ហើយវាយខ្ជូនឯងឲ្យស្លាប់មុនឈឺដូច្នោះមិនគួរសោះ ឥឡូវចូធូលើកទ័ព
មកវាយស្រុកឈីជីវហើយ ឯស្រុកហ្ជូតោនោះមិនមានរណាទៅត្ជូត
ត្រាវក្សាជាមាំមួន ឡៅពីក៏មានសំបុត្រមកស៊ុំកងទ័ពលោកលើកទៅ
ជួយ បើលោកលើកកងទ័ពទៅវាយស្រុកហ្ជូតោ ត្រានេះមុខជានឹង
បានងាយណាស់ ។ អ្ជិនសៀវតបថា "យើងក៏ដឹងអស់ហើយថា
ត្រានេះនឹងបានចំណាប់ធ្វើការសឹក តែចិត្តរបស់យើងធុរៈនឹងបុត្រ បើ

បុត្រយើងមានសេចក្តីអន្តរាយជាខាងក្រោយហើយ ជីវិតយើងក៏នឹង
ស្លាប់ជាមួយ ប្រការ ១ ទៀតប្រសិនបើលើកទ័ពទៅតង់មិនមានជ័យជំនះ
ព្រោះហេតុមិនសប្បាយនោះឯង" រួចអ៊ីនសៀវក៏បង្គាប់ស៊ុនខៀនថា
ត្រានេះយើងមិនលើកទ័ពទៅទេ ឲ្យទៅប្រាប់ឡៅពីចុះ បើឡៅពី
អាប់ចុនវេលាណា ក៏រត់មករកយើង ។ នឹងជួយទំនុកបំរុងមិនឲ្យត្រួយ
លំបាកឡើយ ។

ទៀនហង់បានឡអ៊ីនសៀវនិយាយដូច្នោះក៏ខឹងណាស់ ទើបថា
"ស្តាយ ត្រានេះបានចំណាប់ល្អហើយ គួរប្ដមកគិតជាធុរៈរវល់នឹង
កូនតូចតាចដូច្នេះមិនគួរសោះ" ទៀនហង់ក៏ដកដង្ហើមធំហើយដើរចេញ
ទៅ ។ ស៊ុនខៀនក៏លាអ៊ីនសៀវត្រឡប់ទៅស្រុកសៀវជាយវិញ ហើយ
អធិប្បាយរាយរឿងឲ្យឡៅពីស្តាប់ត្រប់ប្រការ ។ ឡៅពីបានស្តាប់ក៏នឹក
តូចចិត្តរិតតែត្រួយបារម្ភខ្លាំងណាស់ ប្រឹក្សានឹងស៊ុនខៀនថា ចូធូលើក
កងទ័ពមកត្រានេះ យើងរិះគិតចេញច្បាំងយ៉ាងម្តេចឲ្យបាន ។

ត្រៀវហ៊ុយធ្វើយជំរាបឡៅពីថា ទ័ពចូធូលើកមកត្រានេះបើយើង
នឹងបង្អង់ទុកឲ្យយូរ ចូធូនឹងតាំងជាមាំមួនបានរិតតែមានកំឡាំងធ្វើការសឹក
យើងក៏លំបាក ព្រោះវេលានេះចូធូលើកចូលមកជិតស្រុកយើងហើយ
ពេលយប់នេះ ខ្ញុំបាទសុំយកអាសាលើកទាហានចេញទៅព័ទ្ធរាយកងទ័ព
ចូធូ កុំឲ្យតាំងបន្ទាយជាមាំមួនឲ្យបាន មុខជាចូធូនឹងថ្នោះការផង់យើង ។
ឡៅពីបានស្តាប់ក៏ថា "ប្អូនឯងពិដើមមក បងយល់ថាមិនចេះគិតអ្វីសោះ
មានតែថ្វីដៃច្បាំងខ្លាំងពូកែតែម្យ៉ាង បងទើបនឹងបានឃើញជម្រេះម្តង

កាលប្អូនធ្វើកលឧបាយចាប់ខ្ជូនឡៅតាយបាន ឥឡូវប្អូននឹងលើកពលទៅ
ព័ទ្ធវាយកងទ័ពចូធូមិនឲ្យតាំងជាមាំមួននោះ បងត្រូវចិត្តណាស់" ហើយ
ឡៅពីក៏បែងរំលែកពលយោធាត្រៀមទុកសម្រាប់ខ្ជូនឯង ១ កង ចាត់
ឲ្យតៀវហ៊ុយ ១ កង ។

ចំណែកចូធូកាលលើកទ័ពមកជិតស្រុកសៀវជាយហើយ ទទួល
កើតឧ្យល់ព្យុះបក់បោកខ្ទាំងណាស់ ដងទង់ជ័យចូធូដែលដោតលើរទេះក៏
បាក់ជាច់ចុះ ចូធូឃើញវិបរិតប្ដែកក៏បញ្ឈប់កងទ័ពតាំងបន្ទាយនៅទីនោះ
ហើយសួរទីប្រឹក្សាថា "ដែលមានឧ្យល់ព្យុះបក់មករលំបាក់ដងទង់ជ័យ
យើងជូច្នេះជាអាកេទល្អឬអាក្រក់ប្រការម្តេច? ។ ស៊ុនហុកធ្វើយថា
ថ្ងៃនេះកាចណាស់ មុខជាឡៅពីនឹងលើកទ័ពមកប្ដន់បន្ទាយយើងជាប្រា-
កដហើយ ។ ទទួលម៉ាកាយចូលមកដល់ទៀតជំរាបចូចូថា ឧ្យល់ពីទិស
ឯកើតបក់មកត្រូវដងទង់ជ័យបាក់នោះ ខ្ញុំបាទយល់ថា កណ្ណាលយប់នេះ
នឹងមានគេមកលុកបន្ទាយហើយ ។ ចូធូបានស្តាប់ស៊ុនហុកនឹងម៉ាយ
និយាយដូច្នោះ ក៏យល់ថាសំដីអ្នកទាំង ២ ត្រូវពាក្យគ្នា ទើបធ្វើយថា
ដែលបណ្ណាលឲ្យកើតឧ្យល់ព្យុះដូច្នេះ គឺទេពតាសំដែងហេតុឲ្យដឹង ព្រោះ
យើងមានបុណ្យវាសនា ។ ចូធូក៏ចាត់ចែងកងទ័ពជា ១១ កង កង ១
ឲ្យនៅរក្សាបន្ទាយ ៨ កងឲ្យនាយទាហានឯកលើកញ្ជាកចេញ ទៅពួន
បង្កប់នៅក្រៅបន្ទាយទាំង ៨ ទិស ហើឃើញកងទ័ពឆ្ងាំងលើកមកប្ដន់
បន្ទាយវេលាណា ក៏ឲ្យទាហានទាំង ៨ កងនោះវាយប្រសព្ធព័ទ្ធចូលមក,

២ កន្លៀតញែកគ្នាលើកទៅស្ទាក់នៅមាត់ផ្ទូវដែលនឹងទៅស្រុកឈីជីវ ១ កន្ត ទៅស្រុកហែហ្ទឹ ១ កន្ត ។

លុះពេលយាម ២ ឡៅពីនឹងតៀវហ៊ុយក៏លើកតាហានចេញទៅពីស្រុកសៀវផាយ ។ តៀវហ៊ុយក៏កំរើបចិត្តគិតថា គ្រាមុនអញ្ចាបានផ្ទើកលឧបាយចាប់ឡៅតាយបាន គ្រានេះឡៅពីក៏សរសើរតម្រេះប្រាជ្ញានឹងតំនិតរបស់អញប្រើនណាស់ តៀវហ៊ុយក៏ជិះសេះលើកតាហានជាកន្ទមុខចូលទៅវាយបូន់យកបន្ទាយចូធូ ។ តៀវហ៊ុយឃើញមនុស្សក្នុងបន្ទាយនោះតិច ហើយបានព្ទសំឡេងតាហានខាងក្រោយបន្ទាយស្រែកហ៊ោអឺងកងភ្ទើងក៏ធេះឡើងភ្ទឹពេញក្នុងបន្ទាយ ទើបគិតថា គ្រានេះប្រហែលចូធូគិតកលឧបាយទេជឹង ក៏នាំតាហានត្រឡប់ចេញមករកឡៅពី ទទួលជួបនឹងតៀវលៀវ,ទៅផូ,អ៊ីកិម,លីទៀន,ស៊ីឡុង,ងាក់ជិន,ហែហ្ជិទុន,ហែហ្ជិអៀន,លើកតាហានវាយប្រសព្ទខ្ទប់តំងសងខាងចូលមកគ្រប់តំង ៨ ទិស តាំងតែច្បាំងកាប់សម្ទាប់គ្នាជាកោលាហល ឯតាហានដែលតៀវហ៊ុយលើកមកនោះសុទ្ធតែតាហានដើមចូធូ ក៏បែកចូលទៅរកនាយរបស់វាតំង ៨ កន្ត សល់នៅតែតាហានស្ទិទ្ធខាងខ្ជូនប្រហែល ៤០.នាក់ប្ទាយ តៀវហ៊ុយច្បាំងទំលាយពេញកម្ទាំងតំងសងខាង ហើយតាហានតំង ៤០ ប្ទាយនោះដែកចេញទៅបាន ទើបគិតតែក្នុងចិត្តថា "នឹងទៅរកឡៅពីប្ទទៅស្រុកឈីជីវ ។ ឯស្រុកហែហ្ទឹវេលានេះក៏ទៅមិនបាន មុខជាតាហានចូធូនឹងនៅចាំស្ទាក់គ្រប់ផ្ទូវ" ទើបនាំតាហានតំងនោះឡើងទៅនៅលើកំពូលភ្នំបងអៀង ។

ឯឡៅពីនោះជិះសេះនាំតាហានលើកណូនតាមតៀវហ៊ុយទៅ លុះ

បានឮសំឡេងតាហានស្រែកហៅអីឯកង័តខ្លួបន្ទាយចូរចូលមក ខ្ញុំពីក៏ស្មានថា តៀវហ៊ុយចូលទៅបន្ទប់បន្ទាយនោះ តែទៅរិះគិតថាមុខជាចូរនឹងធ្វើកលឲ្យអន្តរាយមិនខាន ទម្លួលក្រឡេកឃើញហែហមខ្លួនបរាលចូលមក តាត់យកតាហានខ្ញុំពីបានប្រហែលពាក់កណ្តាល ខ្ញុំពីឃើញដូច្នោះក៏ទឹកចិត្តណាស់ ញាក់សេះបរចូលទៅតយុទ្ធនឹងហែហមខ្លួនទម្លួលហែហមអៀនលើកតាហានវាយប្រសព្វចូលមកទៀត ខ្ញុំពីក៏បរសេះចូលតតាំងច្បាំងដោះខ្លួន តាហានខ្ញុំពីក៏របួសស្លាប់ទៅខ្លះ រីលចូលទៅខាងកងទ័ពចូរខ្លះ សល់នៅតាហានដែលស្ថិតប្រហែល ៣០ ជ្វាយ ខ្ញុំពីក៏បរបរាលចូលតយុទ្ធដែកចេញទៅបាន គិតនឹងត្រឡប់ទៅស្រុកសៀវវិញ ក៏ក្រឡេកទៅឃើញពន្ធឹក្តៅងក្នុងស្រុកនោះធេងសន្ធោខ្លាំង ខ្ញុំពីក៏ដឹងថា កងទ័ពចូរចូលទៅវាយយកស្រុកនោះបាន ទើបត្រឡប់សេះនាំតាហានរត់ទៅផ្លូវស្រុកឈីដាវ ឃើញផ្លូវដែលបែកទៅខាងស្រុកហែហ្វី មានតាហានចូរខ្លះទៅស្ទាក់ទប់នឹងផ្លូវជាច្រើន ខ្ញុំពីគិតថាគ្រានេះចូរលើកទ័ពមកច្បាំងជាច្រើនណាស់ ខ្លួនអញនឹងតៀវហ៊ុយក៏បែកញែកគ្នាទៅវិញខ្លួនហើយ នៅតែតួនអ៊ូដែលរក្សាគ្រប់គ្រងក្នុងស្រុកហែហ្វីនោះ មិនដឹងជាបានសុខទុក្ខយ៉ាងណា ខ្ញុំពីត្រិះរិះឃើញថាអ្នកនៅសៀវបានផ្តាំនឹងស៊ុនវៀនថា បើអាប់ចុនវៀលណាក៏ឲ្យចូលទៅចុះនឹងដួយទុក្ខធួរនោះ គ្រានេះខ្លួនអញថ្វោះការជាខ្មាន់ហើយ គួរតែទៅអាស្រ័យនៅនឹងអ៊ូនសៀវសិនចុះ ដើម្បីនឹងបានសម្រាកខ្លួនគិតការតទៅទៀតលុះត្រិះរិះហើយ ខ្ញុំពីក៏នាំតាហានសេះទាំង ៣០ ជ្វាយនោះ បរស្រែត

រូតតាមផ្ទូវដម្រង់ទៅស្រុកតីជីវ ទទួលប្រទះនឹងលីទ្រនលើកទាហាន ស្ពាត់ទទឹងពីមុខ ឡៅពីក័យស្ទុតមិនបានគិតប្រយុទ្ធនឹងតតាំងក៏រលះរលាំង គេចដោះតែខ្ទួន ១ រត់រួចទៅ ចោលទាហានទាំងអស់នៅក្នុងចំណោមទ័ព លីទ្រនក៏ចូលទៅព័ទ្ធចាប់ទាហានឡៅពីទាំងអស់បាន ។

ខណៈកាលឡៅពីបំផាយសេះរត់ទៅនោះ ចេះតែស្រូតទាំងយប់ ទាំងថ្ងៃចម្ងាយផ្ទូវប្រហែល ១ ពាន់សិន (៦០ ត.ម.) លុះទៅដល់ស្រុកធ្រឹងជីវក៏ចូលទៅប្រាប់អ្នកចាំទ្វារថា យើងសុំចូលទៅចួបនឹងអ្ជិនថាំចៅ-ហ្វាយស្រុកដែលជាកូនអ្ជិនសៀវ ។ នាយទ្វារក៏នាំសេចក្តីទៅជំរាបអ្ជិន-ថាំ ។ មានសេចក្តីត្រកអរណាស់ក៏ចេញមកគំនាប់ហើយនាំខ្ទួនឡៅពីចូលទៅ ។ ឡៅពីក៏នាំរឿងរ៉ាវអធិប្បាយឲ្យអ្ជិនថាំស្តាប់គ្រប់ប្រការ ហើយថា យើងនឹងទៅអាស៍យនៅនឹងអ្ជិនសៀវជាបិតាអ្នក នឹងបានរិះ គិតកំចាត់ចូធូជាវាជសត្រូវឲ្យបាន ។ អ្ជិនថាំបានស្តាប់សព្វសេចក្តីពីរឿង ឡៅពីបែកទ័ពរត់មក ក៏ឲ្យមានចិត្តរិប្យយោគទុក្ខនឹកអាណិតឡៅពីពន់ ប្រមាណ ទើបឲ្យរៀបតុបាយទឹកជូនឡៅពីបរិភោគរួចក៏រៀបទីកន្ទែងឲ្យ ឡៅពីនិត្រ រួចអ្ជិនថាំតែងសំបុត្រទៅដល់បិតា តាមសំដីដែលឡៅពី និយាយឲ្យបំរើនាំសំបុត្រនោះទៅមុន ហើយចាត់ទាហានជូនខ្ទួនឡៅពី ទៅជាក្រោយ ។ បំរើសេះក៏បានទៅដល់ស្រុកតីជីវយកសំបុត្រនោះ ចូលទៅឲ្យអ្ជិនសៀវ ។ មើលដឹងសេចក្តីហើយក៏មានចិត្តសោមនស្សណាស់ នាំពលយោធាចេញមកចាំទទួលឡៅពីក្រៅស្រុក លុះឃើញឡៅពីទៅ ដល់អ្ជិនសៀវចូលទៅដឹកដៃឡៅពីមក អ្នកទាំង ២ ក៏គំនាប់គ្នាតាមទំនៀម

ហើយនាំឡៅពីចូលឡេជល់ទីគេហដ្ឋាន អ្ជិនសៀវនិយាយនឹងឡៅពីថា
អ្នកបានប្រើស៊ុនឧៀនមកស៊ុកងទ័ពខ្ញុំ ទ្ធលបុត្រវបស់ខ្ញុំមានជម្ងឺបានជា
ខ្ញុំមិនបានលើកទ័ពឡេជួយអ្នកៗ កុំគប្បីតូចចិត្តនឹងខ្ញុំឡើយ ខ្ញុំមាន
សេចក្តីវិតក្កគិតជល់អ្នកជាជរាប ឥឡូវអ្នកខូចស្រុកនឹងចូធូឡេហើយក៏
ជាការអក័ព្ទ ខ្ជូនអ្នកមិនស្ទាប់បានមកឃើញមុខគ្នានឹងខ្ញុំ វេលានេះជា
ក័ព្ទអ្នកក័ព្ទខ្ញុំៗ មានសេចក្តីត្រេកអរពន់ប្រមាណណាស់ ។

ឡៅពីធ្វើយថា គ្រានេះខ្ជូនខ្ញុំកំព្រាអនាថា ដែលអ្នកមានមេត្តាវាប់
អានខ្ជូនខ្ញុំៗ ក៏មានសេចក្តីត្រេកអរ សូមទទ្ធលគុណអ្នកទុក តឡេមុខខ្ញុំ
នឹងបានតបស្នងសងគុណអ្នកវិញ កាលពីដើមខ្ញុំក៏បានដឹងច្បាស់ថា ចិត្ត
ថ្វើមរបស់អ្នកមានធម្មិសប្បុរសរួសរាយរាប់អាន តែងឈប្តម្ភសេនាទា-
ហានមិនឲ្យអនាទរខ្ញុំក៏គិតថា នឹងមកជ្រកកោនពឹងបុណ្យអ្នក ឲ្យអ្នកប្រើ
ដើម្បីនឹងរិះគិតកំចាត់ចូធូចេញ ឥឡូវខ្ញុំបរាជ័យនឹងចូធូរត់មកតែខ្ជូន សូម្បី
ប្អូនរបស់ខ្ញុំទាំង៦នាក់នឹងគ្រប់គ្ជូ ក៏មិនបានដឹងជារស់ឬស្ទាប់យ៉ាងណា
ដែលខ្ញុំថ្ងោះការរត់មករកអ្នកតែម្នាក់ឯងដូច្នេះ មានសេចក្តីអាប់យសខ្មាស
គេខ្ទាំងណាស់ វេលានេះ ខ្ញុំក៏ស៊ុំផឹកទឹកពិតទូសច្ចាស៊ុនៅធ្វើការនឹងអ្នក
គ្រាតែសំរេចកិច្ចការ ។ អ្ជិនសៀវបានស្តាប់រាចាឡៅពីក៏ឲ្យមានចិត្ត
អាណ៉ាតនឹងស្រឡាញ់ពន់ពេក ទើបចាត់ចែងគ្រឿងបរិកោគនឹងឈបកោគ
ឲ្យជាច្រើន ហើយក៏តាំងតែឈបត្ទម្ភទំនុកបំរុងឡៅពីឲ្យនៅក្នុងស្រុកគីជីវ ។

(មានត)

ដំណឹងតាមខ្សែក្នុងកន្លែង៖

លោក ផេង-ជ្រៀ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាចាវ៉ាំងមកជាភាសាខ្មែរ

(តទៅ)

ម្ចាស់ក្រីក្រជណ្តើបចំពីក្រុង តាំងពីប៉ុន្មានម៉ោងរួចមកហើយ មនុស្សក្នុងផ្ទះលោកអែយ៉ាដហាក់ដូចជេកស្ងាត់ឈឹង ប៉ុន្តែដោយពន្លឺភ្លើងព្រាងៗ គេឃើញស្រមោលសស្ងុង ។ ដើរសន្សឹម ។ ក្រែមដើមឈើកន្ទុងសួន ហើយលបចេញតាមទ្វារតូចមួយ ។ គឺចាកជាមនុស្សក្នុងផ្ទះហ្នឹង ចានជាពួកបក្សដែលចិញ្ចឹមក្នុងក្រុងគ្មានភ្ញាក់ផ្អើល ដោយដំណើរនៃជនចាំងពីរអ្វីបន្តិចសោះ ។

លុះចេញផុតដល់ក្រៅរបង អ្នកចាំងពីរទំដើរញាប់ដើង ។ គេស្គាល់ច្បាស់ជានាងឡឺឡា ស្តើងក្រនាប់ ទទូរសំពត់ពណ៌ស នៅខាងមុខតាឡិប តាមរស្មីព្រះចន្ទចាំងមកពីចន្លោះពពក៖ នាងស្រីដើរមុន ។ តាឡិប បណ្តោយឲ្យឡឺឡាដើរទៅមុន ចម្ងាយប្រហែលពីរ-បីម៉ែត្រ គាត់ឈប់រួចផ្លែងស្តាប់ដូចជាឮសូរជើងដើរពីក្រោយ ។

តាឡិបនឹកថា ចាកជាមានមនុស្សឃើញ ! គេដើរតាមពីខាងក្រោយ ! លុះឈប់មួយសន្ទុះ ហើយដឹងថាឥតមានអ្នកណាតាមឡើយ ទើបគាត់ទំរួតដើរឲ្យខាន់នាងឡឺឡា ។

អ្នកចាំងពីរបានដល់កន្លែងមួយរំពេច ឃើញពងអណ្តូងស្ងួត ។ រីកធំដោយយប់ងងឹត ។

ខណៈនោះ តាឡិបកាន់ដៃនាងឡីឡានាំរហូតដល់គុម្ពសុំទ្រុមនៃ ដើមកូឡាបរួចខ្សឹបដាក់ត្រចៀកថា

– នៅឲ្យស្ងៀម ចាំត្រង់កន្ទែងហ្នឹងចុះ!

រួចសំឡឹងធ្វេង សំឡឹងស្តាំក្នុងទីងងឹត ទើបគាត់លូពីរបីម៉ាត់ផ្ទើត្រាប់ធ្កៃព្រៃឲ្យជាដំណឹង ។ មានមនុស្សម្នាក់លេចជ្រាងឡើង ចម្ងាយបីបួនម៉ែត្រ ចេញពីគុម្ពផ្ការមក យកសំពត់ត្របបិទមុខ ។ តាឡិបដើរចូលទៅជិត ។ អ្នកនោះសួរថា:

រានៅឯណា?

តាឡិបដំរាបដោយសំដីគួរសមថា:

– ន៉ុះ រាឈរនៅ ន៉ុះ!

មនុស្សនោះសើចស្ងៀញ ហើយនិយាយថា:

– អើ ប្រាកដមែន! បើដូច្នេះ ហ៏ យកវង្វាន់ឲ្យហើយទៅចុះ! យើងស្រេចការហើយ!

គេដកហូតប្រាក់មួយស្ឆាងពីខ្សែកវាត់ដែលមានកាំបិតស្នៀតមួយ សស្ងាចនឹងកាំក្ទើងពីស្ពូឡេមួយញ្ឆរនៅនោះ ហើយហុចឲ្យទៅតាឡិប ។

តាឡិបទទួលយកប្រាក់ ប៉ុន្តែតាត់ដូចជានៅប្រែមប្រុម ព្រោះដូចជាញ្ចឲ្យល់អ្ទីនៅនាគុម្ពឈើ ។ ជាទីបំផុត តាត់ដាច់ចិត្តទៅនាំនាងឡីឡាយកមកប្រគល់ឲ្យមនុស្សនោះ ។

ខណៈនោះ ក្ទើងកាមរាគធេះឡើង អ្នកនេះក៏សង្ត្រុបនាងនារីដូច

ជាសត្វសង្ត្រុបអំពា ។ សាច់នាងក្រំមុំក្តៅអ៊ុន ។ ផ្សាយក្ងិនក្រអូប ជា
ហេតុឲ្យគេញ៉ែរញាក់ដៃគេទាំងពីរ ។ គេឡនរកមុខនាងក្រមុំ, នាង
ស្រែកដោយសម្រែកគួរខ្ទាចថា:

- ជួយផង តាឲ្យិប!

នាងទើបនឹងដឹងច្បាស់ជារស្យីម ។

- អាកំសាក!

- អាក្សត់!

មុនដែលរស្យីមកំរើកដើបខ្លួន មុក្តារនឹងអ៊ីស្មាអ៊ីលស្ទុះមកដល់នៅពុ៉មុខ ។

នាងឲ្យីឲ្យាបង្រះ ហើយស្ទុះទៅឡបអ៊ីស្មាអ៊ីល ។

នាងយំហើយប្រាប់ថា:

ឡលោកនាយ! សូមកុំជឿ គេក្សត់ចិត្តខ្ញុំ?

អ៊ីស្មាអ៊ីលនាំនាងឲ្យីឲ្យាទៅប្រគល់ឲ្យតាឲ្យិបឯអណ្តូង រួចត្រឲ្យប់
មករករស្យីមវិញ ។

រស្យីមដកកាំបិតស្នៀតចេញ ស្រែកទាំងកំហឹង ហើយលោតសំដៅ
គូសត្រូវ តែមុក្តារ រហ័សក្ងែត ចាប់ដៃរស្យីមជាប់ កាំបិតក៏ធ្លាក់ចុះទៅដី:

- អាឯងឃ្ងាំចាំ!

អ៊ីស្មាអ៊ីលនិយាយដោយសំដីយ៉ាងម៉ឹងម៉ាត់ថា

- ទេ រស្យីម មិនគឺជាការឃ្ងាំចាំឲ្យើយ! អញត្រាន់តែចង់ដឹងការ
កំសាកផងអាឯងទេតើ ។ អញអាចសម្ងាប់អាឯងឥឡូរដូចត្រៃ ប៉ុន្តែណ្ហើយ
អញបន្ធូរឲ្យអាឯងផ្សងរាសនាចុងក្រោយ ក្នុងការប្រយុទ្ធតាមច្បាប់ ។

អ៊ីស្មាអ៊ីលចាប់ពីស្ពូឡេ រួចប្រាប់ទៀតថា:

- អាឯងយើញឬទេ ដើមត្នោតដុះនៅក្បែរកំពែងនុ+ះ កាលណា ទៅដល់កន្ទែងនុ+ះ យើងបាញ់ត្នា ខំប្រឹងដម្រង់ឲ្យមែនទែន ។

នាងឡីឡាស្រែកហៅដោយសំដីព្រួយខ្ទាំងថា:

- អ៊ីស្មាអ៊ីល !

ប៉ុន្តែ ជនទាំងពីរចេះតែដើរដម្រង់កំពែងនោះ គឺនៅក្រោយកំពែងនោះហើយដែលនាងឡីឡាបានស្ពាប់ទំនាយរបស់យាយមេអាប ។

សូរបាញ់ពីរកាំភ្លើងទម្ទុះរហសកាពនៃរាត្រី ។

មួយស្របក់ក្រោយមក គេយើញអ៊ីស្មាអ៊ីលដើរត្រឡប់មកវិញ ។

ខណៈនោះ នាងឡីឡាដែលមិនអាចនឹងទប់នូវសេចក្ដីអរបាន ក៏ស្ទុះទៅឧបតូសង្សារហើយនិយាយថា:

- អ៊ីស្មាអ៊ីល ! អ៊ីស្មាអ៊ីល !

នាងយំផង សើចផង ប៉ុន្តែមានគំនិតព្រួយមួយកើតឡើងក្នុងចិត្ត ។

- សូមបងកុំជឿថាខ្ញុំស្រឡាញ់រា ខ្ញុំស្មានជាបងទេតើ ដែលឲ្យខ្ញុំមកចួបនៅទីនេះ !

អ៊ីស្មាអ៊ីលឥតមាននិយាយថាអ្វី ។ គេចាប់នារីអោបហើយជញ្ជក់មាត់នាង ។ គូសង្សារទាំងពីរជញ្ជក់ត្នាទៅវិញទៅមកមួយ សបក់ នៅក្រោមរស្មីព្រះឬក្សស ។

* * *

វគ្គទី ៧

ស្រមោលនៃសេចក្ដីទុក្ខ

ព្រឹកឡើងនៃយប់ដែលមានរឿងហេតុ លោកតាអៃយ៉ាដកំពុងតែត្រួតត្រាមើលតាឡិបដែលបំពេញកិច្ចការ គឺថែរក្សាកូនសេះទើបនឹងកើតនៅនាកណ្ណាលទីធ្លាផ្ទះក្រាលថ្មីមថ្ម លោកស្រាប់តែភ្សាក់នឹងសំឡេងបរិទេវស័ព្ទនឹងស្ងូរមនុស្សដង្ហែសពតាមផ្លូវមុខផ្ទះ ។ លោកស្ទុះចេញទៅមើលបានឃើញមនុស្សបួននាក់សែងក្ដារម្ជូសត្របសំពត់ស ។

មានមនុស្សជាច្រើនពាក់អាវស្លៀកខោខ្លីដើរពីខាងមុខ ដែលលោកតាអៃយ៉ាដអាចសំគាល់បានថាជាពួកជនក្នុងផ្ទះ នៃអ្នកមានបណ្ណាស័ក្តិគួរសម ។

លោកស្ងូរអ្នកដង្ហែថា:

– ឈឺអី បានជាស្លាប់ ?

គេធ្វើយជំរាបមកវិញថា:

– ឧព្រះគុណកាអ៊ីដ គឺម្ចាស់យើងខ្ញុំ មានអ្នកណាគេសម្លាប់នៅក្សែរអណ្ណូងទឹក ។

លោកតាអ៊ីដបង្គាប់ថា:

– ចូរបើកមុខឲ្យអញមើលបន្តិច !

អ្នកសែងបន្ទន់ជង្គង់ ល្មមឲ្យក្ដារម្ជូសតាំងនៅតាមកំពស់ធម្មតា រួចទាស:ម្នាក់បើកសំពត់គំរបចេញ ។ មុខរស្សីមលេចឡើងនៅកណ្ណាលថ្ងៃ ស្លេកស្លាំងដោយអានុភាពនៃសេចក្ដីស្លាប់ ។ មានរន្ធតូចមួយត្រង់

ថ្ងាស់ ជាចនោះក្នែកទាំងពីរចង្អុលប្រាប់កន្ទែងដែលត្រាប់តាំក្ទើងចូលតាមនោះ ។ ត្រាប់ដែកនេះរត់តាមខ្លូ ហើយទំលាយនលាដ៍ក្បាលជ្ឋិតគេយើញមានឈាមកកនៅត្រង់កន្ធូតអូង ។

លោកតាអៃយ៉ាដព្រឹព្ធូចពេក តែអាការទឹកមុខមិនបានក្សត់គំនិតលោកខាងក្នុងឡើយ ។ លោកគំនាប់សព ហើយឲ្យពរថា:

– សូមឲ្យសន្តិសុខនៃព្រះអាឡស់ស្ថិតនៅនឹងអ្នកនេះ !

ក្ស្ជនដង្ហ៏ក៏ផ្ទើដំណើរតទៅទៀត ។

ខណៈដែលលោកបែរខ្ជូនដើម្បីចូលផ្ទះ លោកបានយើញអ៊ីស្មាអ៊ីលយរនៅពីមុខ ។ អ្នកកំឡោះមុខស្ងៃក មិនកំរើក ឈរសំឡឹងសព ។ លោកសំឡឹងមុខកូនប្រុសសព្ទ ។ មិនចេញស្ពី ប៉ុន្តែក្នែកលោកមើលផ្ទុះដល់ពោះវៀន ។ អ៊ីស្មាអ៊ីលយល់ច្បាស់ថា ឥពុកខ្ជូនដឹងនូវកលហកម្មនឹងការសម្ងាត់ នៃមរណភាពរបស់ស្សីមក្នុងពេលនេះប្រាកដហើយតែត្រាន់តែមិនដឹងថា បណ្ណាលមកពីហេតុអ្ទី ។ ជាទីបំផុតលោកប្រាប់ថា:

– ត្រឡប់ចូលទៅវិញ កូន !

លោកអៃយ៉ាដបិទទ្វារពីក្រោយគេ ។ ព្ទលោកថាតិច ។:

– ព្រះអាឡស់ធំណាស់ ព្រះអង្គដឹងទាំងអស់ នូវកិច្ចការដែលគេធ្ទើ !

រួចផ្ទើព្រងើយ ច្ឋូតពុកចង្ការទន់ល្មើយដែលលាងរាល់ព្រឹកក្នុងទឹកក្រអូប លោកគិតតែមើលតាឡិបដែលកំពុងថែកូនសេះទើបនឹងកើត ។

* * *

ពេលនោះ កងទាហានតួរតីដែលគេប្តឹងអំពីយាជកម្មដែលរស្យីម
បេនអាប់ជាឡះ បានទទួលរងបាបគ្រោះ ក៏នាំគ្នាធ្វើរឿងនោះឲ្យលេច
ច្បាស់ឡើង ។

មូហាម្មេដណាប៉ីបី ជាមនុស្សច្រណែនអំណាចក្នុងការត្រួតត្រាកង
ទ័ព ក្តៅក្រហាយចង់រកអ្នកដែលប្រព្រឹត្តបទល្មើសឲ្យឃើញ ព្រោះ
លោកចូលចិត្តថា ការណ៍នេះ គឺជាទោសផ្ទូវនយោបាយ ។ ដ្យិតច
រស្យីមបេនអាប់ជាឡះ ស្ទាប់ក្នុងយប់ថ្ងៃដែលលោកបានប្រគល់ការជំនួប
ក្នុងកិច្ចសង្ត្រាមនៃរដ្ឋាភិបាលកុងស្តង់ទីណុប គេទើបនឹងទទួលមុខងារ
ខាងការចាត់កងទ័ពក្នុងក្រុងកាស៍ ការាប៊ូលី ។

នាយទាហានតួរតី ហៅអនុសេនីយ៍ឯករបស់ខ្លួនមក គឺជានាយ
ទាហានម្នាក់ដែលធ្លាប់ចាត់ចែងព្រឹត្តិការណ៍ខាងកងក្រវែល ។ គឺជា
មនុស្សចិត្តត្រជាក់គិតអ្វីហើយមិនរួញរា ចេះទប់កំហឹងរបស់ខ្លួន ។ ក្នុង
ការកត់ហេតុរឿង លោកតែងមាននយោបាយបន្ទន់មានវិជ្ជាជ៍មុឹងម៉ាត់
ខាងពិនិត្យសំគាល់ មានសេចក្តីក្លាហានយ៉ាងជាច់ខាត គិតធ្វើអ្វីតែង
សម្រេច ទោះបីការណ៍នោះចង្អៀតជូចម្តេចក៏ដោយ ។ លោកនេះ
ស្គាល់យ៉ាងអស្ចារ្យនូវល្បេចក្រវេចក្រវៀន នូវកិច្ចពុតត្បុតនូវការលាក់
តំនួច ហើយជាក់ច្បាស់ជាងគេ នូវរហសាការញើតរញើមនៃពួក
អាវ៉ាប់ ដ្យិតលោកធ្លាប់នៅក្នុងប្រទេសរាជជាយូរអង្វែង ហើយបានឡើង
ងារស័ក្តិក៏ដោយសារកិច្ចខាងលើនេះ ។

លោកអនុសេនីយ៍ចាប់ធ្វើការអង្កេតភ្លាម ។ លោកអញ្ជើញទៅ

ការន់ផ្ទះរស្សីមបេនអាប់ជាឡះតែម្នាក់ឯង លាក់កាំក្រើងក្នុងហោប៉ាយ៉ាង ប្រយ័ត្នមិនឲ្យអ្នកណាឃើញ ។ លុះទៅដល់មុខផ្ទះ បរិទេវនសព្ទ សំឡេងសូត្រធម៌នៃពួកទាស: សំឡេងយំស្រែកនៃពួកស្រី ។ ធ្វើឲ្យលោក ចូលចិត្តថាសពមិនទាន់យកទៅកប់នៅឡើយ ។ លោកមិនទាន់ហាន ធ្វើការអង្កេត ព្រោះតាមច្បាប់ធម៌ក្សត្រ គេហាមផ្តាច់មិនឲ្យអ្នកណាពាល់ ក្រដាស ធ្វើកិច្ចការអ្វី ប៉ះសំលៀកបំពាក់ គឺថាវត្ថុអ្វីផងសពទាំងអស់ ក្នុងវេលាដែលបុគ្គលមិនទាន់ចេញផុតពីផ្ទះ ទៅកាន់កន្ទែងប៉ាធា ។ ទោះបី ស្លាប់ហើយក៏ដោយ ពេលដែលសពនៅលើផ្ទះ គេទុកជូចជានាយ ចៅហ្វាយនៅរស់ ។

.លោកអនុសេនីយ៍ឯកគិតថា បើគ្មានសំបុត្រស្នាមអ្វីមួយរបស់រស្សីម ដែលអាចនាំជួយបំភ្លឺផ្លូវនៃការអេង្កត ដោយហោចទៅ លោកអាចសួរ ពួកលាកុដិក (មនុស្សល្ងីល្ងើ) ក៏សឹងបាន ។ កាលដែលលោកទៅដល់ កន្ទែងដែលពួកស្រី ។ កំពុងយំទួញ លោកមិនមានរំភើបដោយការសោយ សោកនោះឡើយ ព្រោះលោកដឹងថាស្រីទាំងនោះយំដោយគេជួល ជ្យិត មុខងារគ្មាត្រូវតែយំជូច្នេះ ។ លោកចូលទៅគំនាប់សពរស្សីមដែលគេទើប តែបំពាក់ខោអាវថ្មី ខាងក្រោយដែលគេយករូបបុគ្គលទៅចំអាសទឹកអប់ ។ លុះធ្វើតារវកិច្ចហើយ លោកដើរហួសទៅផ្លាខាងក្នុង ដែលមានពួក លាកុដិកនៅនោះ ។ លោកប្រទះទាស៊ីមួយក្លាមជាទីគាប់ចិត្ត ជ្យិត លោកនឹកថាការល្ងែញល្ងើនឹងការមិនដឹងក្តីរបស់វា មុខតែនាំឲ្យវានិយាយ មិនហានកុហក លោកក៏សួរទាស៊ីនោះថា:

– ថ្ងៃម្សិលមិញ ឯងមានឃើញមនុស្សចំឡែកឬទេ? តើមានអ្នកណាមកលេងនឹងចៅហ្វាយឯងឬទេ?

នាងទាសីភ័យដោយឃើញឯកសណ្ឋានទ័ពត្រឹងឥស្សរិយយសមាសរបស់លោកអនុសេនីយ៍ឯក ហើយខ្លាចសាសន៍តួរតែផងដែលគេនាំគ្នាទុកដូចជាមហាចោរ ក៏មិនហានឆ្លើយ ។

លោកអនុសេនីយ៍ឯកនិយាយកំហែងថា:

– បើនាងឯងមិនឆ្លើយ អញឲ្យគេចាប់ដាក់គុកភ្លាម នាងឯងមុខជាត្រូវគេវាយកន់រហូតបែកឈាម ហើយគេហូតពោះរៀនចេញដូចខន្ធាឃ ។ បើនាងឯងនិយាយត្រង់ នាងឯងរួចខ្លួន ។

ការកំហែងនេះធ្វើឲ្យទាសីកំសត់ដាច់ចិត្តព្រមឆ្លើយ ។ នាងក្រាបថា:

– ម៉ម្សិលមិញ ខ្ញុំឥតបានឃើញអ្នកណាមកទេ! ខ្ញុំឃើញតែតាឡិបជាទាស:ចំរើលោកតាអែយ៉ាដម្ងាក់ឯងមក ។

– អស់ហើយឬ?

– ចា៎! លោកម្ចាស់ អស់ហើយ!

– ល្អ!

លោកអនុសេនីយ៍ឯងអួកមិនថា ។ រំលងនោះ លោកចោទសួរអ្នកបំរើឯទៀតជាច្រើន តែគ្មានយកតែនាម រួចលោកប្រញាប់ទៅឯផ្ទះលោកតាកាអ៊ុង ។ ចម្លើយរបស់នាងទាសី ដូចជាបើកការកំចាំងថ្ងៃដូនលោក ។

ឈ្មោះតាឡិប ! មនុស្សអ្នកបំរើលោកតាអៃយ៉ាង ! លោកនឹកដល់
កាលដែលលោកទៅលេងឯផ្ទះលោកតាកាអ៊ីដជាមួយនឹងចៅហ្វាយនាយ
រួចលោកនឹកមួយរំពេចដល់អាការថ្នាំងថ្នាក់ចិត្ត នឹងជាសត្រូវរបស់
អ៊ីស្មាអ៊ីល កាលគេប្រាប់ថារស្សីបេនអាប់ជាឡះ ចូលជាជំនួយដល់កង
ទំពត្ថរគីហើយ ។

លោកអនុសេនីយ៍នឹកទ្រៃតថា:

– អើ ! មែនហើយ ! មែនហើយ ! អញប្រហែលឃើញផ្ទូវហើយ?

* * *

ទ្វារផ្ទះលោកអៃយ៉ាងបើកចំហ ។ លោកអនុសេនីយ៍ឯកចូល
ដល់ទីធ្លាក្រាលអិដ្ឋថ្ងើមថ្ម បានប្រទះទាសៈម្នាក់ លោកបង្គាប់ឲ្យគេនាំ
ទៅរកម្ចាស់ផ្ទះ ។

លោកតាអៃយ៉ាង មានកូនប្រុសទាំងពីរនៅសងខាង កំពុងមើលធមិ
ក្ស៉ូវ៉ង់ក្នុងបណ្ណាល័យ ពន្ធឹរស្ទ្ធីយ៉ាងត្រជាក់ចាំងចូលតាមបង្អួច ក្ងិនខ្ទឹម
ចន្ទន៍ក្រអូបពេញទាំងបន្ទប់ ។ គឺហាក់ដូចគេមានតែចិត្តបរិសុទ្ធ នឹង
សុខកាពយ៉ាងបរិបូណិនៅក្នុងផ្ទះនោះ ។

លោកអនុសេនីយ៍ឯកនិយាយថា:

– កាអ៊ីដ ខ្ញុំមានការត្រូវធ្វើអង្កេតនៅផ្ទះលោកអំពីមរណកាព
រស្សីមបេនអាប់ជាឡះ ។

លោកតាកាអ៊ីដធ្វើយថា:

– ក្នុងផ្ទះយើង មានតែសេចក្តីបរិសុទ្ធ ។ (មានត)

រឿងបល្ស៉ង្ហងិញ សាមសិបពីររឿង

រឿងព្រេងតណ្ឌៀ

លោកសមិន ម្ចុតូនជម: តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

និទាននៃរូបទេពនិម្មិត ទីប្រាំពីរ

មានថ្ងៃមួយទៀត ព្រះមហាក្សត្រភោជ: ទ្រង់យាងទៅជិតបល្ស៉ង្ហ ទិញនោះ ដើម្បីនឹងទទួលរាជាភិសេក ។ ស្រាប់តែរូបទេពនិម្មិតទីប្រាំ-ពីរពោលថា "មហារាជភោជ:, សូមទ្រង់ព្រះសណ្ឋាប់, ស្តេចអង្គណា ដែលអាចតង់លើបល្ស៉ង្ហ ទិញនេះបាន លុះតែស្តេចអង្គនោះបានឈបត្ថម្ភ ជីវសត្វទាំងអស់ ដូចជាព្រះមហាក្សត្រវិក្រមាទិត្ស" ។ មហារាជភោជ: សណ្ឋាប់នូវវាចានៃរូបទេពនិម្មិតទីប្រាំពីរហើយ ទ្រង់មានព្រះបន្ទូលសួរ ទ្រង់ព្រះ: ទៅរូបទេពនិម្មិតនោះវិញថា "តើព្រះបាទវិក្រមាទិត្ស ទ្រង់បាន ជួយឈបត្ថម្ភជីវសត្វយ៉ាងណាខ្លះ?" ។

រូបទេពនិម្មិតនោះក្រាបបង្គំទូលមហារាជភោជ:ថា: "សូមទ្រង់ ព្រះសណ្ឋាប់អំពីចរិយាជាវីរភាពនៃព្រះបាទវិក្រមាទិត្ស ដូចតទៅនេះ ៖

ព្រះមហាក្សត្រវិក្រមាទិត្ស ទ្រង់បានសោយរាជសម្បត្តិនៅទីក្រុង អវន្ទី ។ មានមួយថ្ងៃ ទ្រង់មានព្រះរាជបញ្ជាទៅកាន់អាមាត្យថា: "ចូរ អ្នកត្រាច់ទៅកាន់ប្រទេសផ្សេង ៗ ហើយដល់អ្នកវិលត្រឡប់មកវិញ ចូរ អ្នកមកប្រាប់យើងអំពីស្ថានការណ៍ដែលអ្នកបានឃើញកុំខាន" ។

អាមាត្យបានទទួលព្រះរាជឧត្តារៈហើយ ក៏ត្រាប់ទៅកាន់ប្រទេសផ្សេង ៗ ទៅដល់ប្រទេសកស្មិរ ៗ នៅទីនោះ, មានសេដ្ឋីម្នាក់បានជីកស្រះមួយធំ តែគ្មានទឹក ៗ តមក គេបានព្ធសំឡេងស្រែកកណ្ណាលអាកាសថា "បើមានឧត្តមបុរសណាម្នាក់ បានបូជារូបកាយ ទើបស្រះនោះមានទឹក" ៗ ដល់បានព្ធសំឡេងនោះ សេដ្ឋីក៏បានយកមាសទម្ងន់ ១០ នាឡិមកលញ់ផ្ទើជាមនុស្ស ហើយបញ្ជ្ជរនៅមាត់ស្រះ រួចបានធ្ងាក់អក្សរលើសិលាចារិកថា "បើអ្នកណាមួយ អាចហ៊ានបូជារូបរបស់ខ្ជួនខ្ញុំនឹងផ្ទើអំណោយនូវមនុស្សមាសនោះ" ៗ បណ្ណាមនុស្សទាំងអស់ដែលទៅកាន់ទីនោះ, គ្មានអ្នកណាម្នាក់ព្រមសុខចិត្តផ្ទើពលិកម្មរូបរបស់ខ្ជួនសោះឡើយ, ដោយមិនមានកំឡាំងល្មមនឹងផ្ទើបានមនុស្សទាំងអស់នោះ ក៏ថយវិលត្រឡប់ទៅកាន់ទីដទៃរៀងរាល់ខ្ជួន ៗ

អាមាត្យរបស់ព្រះមហាក្សត្រវិក្រមាទិត្យ ដល់បានឃើញរឿងរ៉ាវទាំងនោះ ក៏វិលត្រឡប់ទៅកាន់ក្រុងអវន្តី ហើយយកសេចក្តីទៅក្រាបបង្គំទូលទ្រង់សព្វគ្រប់ប្រការ ៗ ព្រះបាទវិក្រមាទិត្យទ្រង់ព្រះសណ្ណាប់អាមាត្យពណិនាអំពីរឿងប្ងែកអស្ចារ្យ ទ្រង់ក៏មានព្រះរាជបំណងទៅកាន់ទីនោះ ហើយទ្រង់ក៏បានយាងទៅកាន់ប្រទេសកស្មិរ ៗ ដល់ពេលសាយណ្ហសម័យ, ទ្រង់ក៏យាងទៅកាន់ស្រះធំនោះ, ដោយកែងព្រះអង្គមិនឲ្យគេស្គាល់, រួចទ្រង់ថ្វាយបង្គំព្រះអាទិទេព ៗ ក្នុងពេលបទោសកាល (យប់) ទ្រង់បានផ្ទើអញ្ជលីរួចមានព្រះបន្ទូលទៅកាន់ព្រះអាទិទេពថា "ឧព្រះអាទិទេព ម្តេចក៏ព្រះអង្គផ្ទើឲ្យខ្ញុំខ្មាសគេ ហើយខ្ញុំប្រកាស

ថា "ព្រះអាទិទេពដែលសោយផ្ទៃតស្ពប់ស្ពល់តែលោហិតរបស់មនុស្ស ដែលគេយកមកធ្វើពលិកម្ម, ត្រូវតែសោយលោហិតរបស់ខ្ញុំកុំខាន" ។ ក្នុងពេលនោះ ព្រះបាទវិក្រមាទិត្យទ្រង់ក៏ហូតព្រះខ័នថ្វាកាត់ព្រះសូរង មួយរំពេច, តែព្រះអាទិទេពបានយកព្រះសូរងនៃព្រះបាទវិក្រមាទិត្យ មកតភ្ជាប់នឹងព្រះកាយហើយ ក្រាបបង្គំទូលទ្រង់ថា "សូមព្រះអង្គ ទ្រង់គង់ជាសុខចុះ, សូមទ្រង់មានព្រះរាជបំណងចង់បានអ្វី យើងខ្ញុំនឹង បំពេញតាមព្រះរាជហប្ចទ័យ" ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលតប ទៅនឹងព្រះអាទិទេពថា "ឧ ព្រះអាទិទេព, បើព្រះអង្គទ្រង់សព្វព្រះរាជ-ហ្ប្ចទ័យនឹងយើង, សូមព្រះអង្គទ្រង់យកទឹកមកបំពេញសែះធំនេះ ដើម្បី ជាប្រយោជន៍ដល់សត្វលោកទាំងអស់" ។

ព្រះអាទិទេពពោលថា "ព្រះអង្គមានព្រះទ័យស្មោះស្ម័ត្រនឹងព្រះ រាជការណីយកិច្ចដ៏មាំមួន, យើងព្រមព្រៀងអនុគ្រោះទ្រង់តាមព្រះរាជ-បំណង ។

លុះដល់បច្ចូសសម័យព្រឹកឡើង, ពួកប្រជាជនទៅនគរកស្ទិរបាន ឃើញសែះធំមានទឹកពេញ ។

រូបទេពនិម្មិតទីប្រាំពីរពោលបញ្ចប់ថា: "ឧ មហារាជភោជ: នេះ ហើយ ដែលជាព្រះរាជចរិយាជ៏វសេសនៃព្រះបាទវិក្រមាទិត្យ ក្នុងកិច្ច ស្រោចសែង់ជីវសត្វទាំងអស់ ។ បើទ្រង់មានព្រះរាជចរិយាបែបនេះ ទើបទ្រង់អាចគង់លើបល្ល័ង្ពទិព្យនេះបាន ។ មហារាជភោជ: លុះទ្រង់ ព្រះសណ្ពាប់នូវវាចានៃរូបទេពនិម្មិតទីប្រាំពីរ ហើយទ្រង់ព្រះតម្រិះថា

ទ្រង់មិនដែលមានសកម្មភាពបែបនេះសោះឡើយ, ហើយទ្រង់ក៏ព្រួយ
ព្រះរាជហឫទ័យពន់ពេកក្នុងថ្ងៃនោះ ។

*

* *

និទានដែរូបទេពនិម្មិតទីប្រាំបី

ពេលក្រោយតមក, មហារាជគោជ:ទ្រង់ព្រះពស្ត្រសម្រាប់រាជ្យ, រួចទ្រង់យាងចូលទៅជិតបល្ង័ង្ក្ទិព្យ ។ ក្នុងពេលនោះរូបទេពនិម្មិតទី ប្រាំបីពោលថា "បពិត្រព្រះមហារាជគោជ: ស្តេចអង្គណាមួយបំពេញ សេចក្តីបំណងអ្នកជទៃ ជូចជាព្រះមហាក្សត្រវិក្រមាទិត្យ, ស្តេចអង្គ នោះអាចគង់លើបល្ង័ង្ក្នេះបាន ។

មហារាជទ្រង់មានព្រះបន្ទូលសួរថា "តើមហារាជវិក្រមាទិត្យនេះ ទ្រង់បានបំពេញបំណងអ្នកជទៃយ៉ាងណាខ្ទះ? រូបទេពនិម្មិតនោះក្រាប ទូលថា "សូមព្រះមហារាជទ្រង់ព្រះសណ្ការប់, ទូលបង្គំនឹងក្រាបទូល ជូចតទៅនេះ ៖

ព្រះមហាក្សត្រវិក្រមាទិត្យ ទ្រង់សោយរាជសម្បត្តិនៅទីក្រុងអវន្ត្ថី ។ នៅទីក្រុងនោះមានបុរោហិតរបស់ទ្រង់ឈ្មោះ ត្រីបុរាការ (Tripurâkâr) មានបុត្រាម្នាក់ឈ្មោះ កមលាការ (Kamâlâkâr) បុត្រនេះល្ងង់ជាទីបំផុត ។ បុរោហិតនោះ ដោយយល់ថាបុត្រាខ្ទួនល្ងង់ជូច្នោះ, ក៏ចេះតែគិតក្នុង ចិត្តជានិរន្ត្ទ៍ ។ មានសម័យថ្ងៃមួយ បុរោហិតនោះបានឲ្យបុត្រានោះ អង្គុយជិតខ្ទួន ហើយក៏ទូន្មានថា ៖

"ឧ កូនអើយ, ចូរកូនស្តាប់ឥពុក, នៅក្នុងសង្សារវដ្ត ជីវសត្វនឹងបានមកកើតជាមនុស្ស លុះត្រាតែជីវសត្វនោះមានគុណធម៌ក្នុងខ្លួន ។

"ជីវសត្វដែលនឹងបានរូបកាយជាមនុស្ស ឬ មកកើតជាជាតិមនុស្ស លុះត្រាតែសត្វនោះបានរៀនន្ទូវវិជ្ជាសាស្ត្រ ។ បើមិនដូចនោះទេ. សត្វដែលមានទ្រង់ទ្រាយជាមនុស្សនោះ ដោយកិច្ចត្រឹមតែតវិយាបថ គឺ ដេក, អង្គុយ, ឈរ, ដើរ, បរិភោគ ។ល ។ ប៉ុណ្ណោះ គេមិនអាចយល់ច្បាស់ថា ជាមនុស្ស ឬក៏ជាសត្វតិរច្ឆានទេ ព្រោះសត្វតិរច្ឆានក៏មានការប្រព្រឹត្តិយ៉ាងនេះដែរ មនុស្សនោះគេទុកដូចជាសត្វតិរច្ឆាន ។ ចំណេះរបស់សត្វមិនមែនចំណេះរបស់មនុស្សទេ ។ ព្រោះហេតុដូចនេះ អ្នកណាដែលគ្មានចំណេះរបស់មនុស្ស, អ្នកនោះមិនមែនសត្វតិរច្ឆានឬ? ។ កូនឯងដឹងទេ ចំណេ់ះ (វិជ្ជា) ប្រសើរជាងរាជសម្បត្តិនៃព្រះមហាក្សត្រិយ៍, ព្រះមហាក្សត្រគេគោរពចំពោះតែក្នុងប្រទេសដែលទ្រង់សោយរាជសម្បត្តិ, មនុស្សមានវិជ្ជាគេគោរពមិនមែនតែត្រឹមក្នុងប្រទេសរបស់ខ្លួនទេ ប្រទេសឯទ្រៀតក៏គេគោរពដែរ ។ ចូរកូនដឹងថា វិជ្ជាសម្បត្តិវិសេសជាងសម្បត្តិដែលនៅក្នុងសង្សារ; ភោគសម្បីទនេះគេខ្ចាចចោរលួច, ភ្លើងឆេះ, អាជ្ញាស្តេចរឹបអូស ។ វិជ្ជាសម្បត្តិគេមិនខ្ចាចខូចខាតបែបនេះទេ ។ ហើយបើគេចាយសម្បត្តិដែលមានហើយ, សម្បត្តិនោះក៏អន្តរាយអស់ ។ ចំណែកខាងវិជ្ជាសម្បត្តិ បើទុកជាចាយយ៉ាងណាក៏ដោយ, ប្រាជ្ញស្ថិតនៅជានិរន្តរ៍មិនចេះអស់ ។ គេមិនអាចយកសម្បត្តិថ្មីមកជំនួសសម្បត្តិចាស់, តែវិជ្ជាសម្បត្តិស្ថិតនៅឥតប្រែប្រួល ។

ត្រូវកូនគិតថា "វិជ្ជាជាគ្រឿងអលង្ការដ៏ឧត្តមជាងគ្រឿងអលង្ការទាំងអស់ក្នុងលោក ព្រោះថាគ្រឿងអលង្ការនេះ ក្ខឹចាំងចែងសមតែក្នេងនឹងពួកជំទង់, ត្រង់មនុស្សចាស់មិនសមទេ ។ វិជ្ជាមានរស្មីក្ខឹចែងចាំងគ្រប់វ័យទាំងអស់ ។ ឧត្តរឲ្យអនិច្ចា, កូនឯងគ្មានវិជ្ជានេះសោះឡើយ, ព្រោះហេតុដូចនេះ ជីវភាពរបស់កូនឯង ទុកដូចជាស្ងាប់ ។ បើគេសួង់មើលនូវលទ្ធផល, ឥពុកពោលថា របស់ទាំងបីយ៉ាងគឺ 'គ្មានកូនប្រុស ១, មានកូនប្រុសតែស្ងាប់ទៅវិញ ១, មានកូនប្រុសបានរួចពីសេចក្តីស្ងាប់ហើយតែរស់នៅក្នុងលោកប្រកបដោយសេចក្តីលង្ងន់ឡៅ ១ ។ បើកូនប្រុសមានលក្ខណៈបែបនេះ, ការដែលគ្មានកូនប្រសើរ, ថាបើមានគួរសម្ងាប់ចោលល្អជាង ។ បើកូនប្រុសលង្ងន់ឡៅរស់នៅក្នុងពិភពលោកមិនជាការល្អសោះឡើយ ។ ព្រោះហេតុដូចនេះ បើកូនប្រុសមិនបានគិតនូវដោគវាសនារបស់ខ្លួនក្នុងអនាគតទេ ហើយទទួលមរណភាពទៅ, ទុក្ខរបស់ឥពុកដែលកើតឡើងដោយសេចក្តីស្ងាប់កូនឯងនេះ មាន តែរយៈវេលាមួយខែ ឬ ពីរខែប៉ុណ្ណោះ ។ ចំណែកកូនប្រុសដែលលង្ងន់ឡៅអាចធ្វើឲ្យបិតាមាតាកើតទុក្ខជាអនេកប្បការ ។ ព្រោះហេតុនេះ បានជាអញថា "ការសម្ងាប់កូនដែលលង្ងន់ឡៅប្រសើរជាង" ។

កមលាការបានស្តាប់ឧវាទនៃមាតា ក៏ធ្វើដំណើរទៅកាន់ប្រទេសដទៃ ដើម្បីនឹងសិក្សារៀនសូត្រនូវចំណេះវិជ្ជាទាំងឡាយ ។ បុរសនោះបានទៅដល់រដ្ឋកស្មិរ: ។

នៅកន្លែងនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ចន្ទ្រមូលី (Chandramauli) ជាអ្នកចេះសិល្បសាស្ត្រ ។ កមលាការបានទៅពឹងពាក់អាស្រ័យព្រាហ្មណ៍នោះដើម្បីនឹងយកលោកជាគ្រូបាអាចារ្យ ។

ចន្ទ្រមូលីព្រាហ្មណ៍ មានសេចក្តីពេញចិត្តនឹងកមលាការ ក៏បានឲ្យទៅបុរសនេះនូវសិទ្ធិមន្ត្រ (Siddhimantra) នៃព្រះនាងវៅធីតា, សារស្វតី (Sarasvati) (នាងវៅធីតាខាងភាសិល្បៈ) ។

ដោយអានុភាពនៃសិទ្ធិមន្តនេះ កមលាការទៅជាពហុសូត្រ ចេះដឹងវិជ្ជាជម្រៅជ្រៅបំផុត (សូមអានត្រង់និទានទី៥ បួន) ។

ក្រោយមក កមលាការ បានអញ្ជើញទៅកាន់ទីក្រុងកញ្ចិ (Kaircî) ។ នៅទីនោះ, លោកបានជួបប្រទះនឹងនាងកញ្ញាម្នាក់នាមនាង នរមោហិណី (Naramohini) (ប្រែថានារីដែលធ្វើបុរសឲ្យវង្វេង) ។ នាងនេះស្ថិតនៅគេហដ្ឋានតែម្នាក់ឯង, គ្មានបុរសណានៅជាមួយនាងទេ ។ ទ្វារគេហដ្ឋានរបស់នាងបើកជានិច្ចរាល់, ជាងធ្វើគេហដ្ឋាននោះគឺ វក្សៈ (អាវក្ស) ឈ្មោះ ទុរជ័យ (Durjaya) ។

វក្សៈនេះធ្លាប់មកកាន់ទីនេះពាល់ថ្ងៃក្នុងពេលព្រលប់ ។ បើជនណាចូលទៅក្នុងគេហដ្ឋាននោះ ហើយឈប់កាន់កាំងស្មារតី ដោយក្រឡេកទៅឃើញនាងកញ្ញានោះ, វក្សៈមកដល់ក្នុងពេលព្រលប់ ក៏ចរិតបុរសនោះទៅ ។ មានបុរសជាច្រើននាក់ បានទទួលមរណភាពបែបនេះ ។

កមលាការ បានដឹងច្បាស់នូវរឿងក៏រៀបចំនេះ ។ ក៏លុះត្រឡប់

ទៅកាន់ប្រទេសខ្លួនវិញ, ហើយយកសេចក្តីនេះទៅក្រាបទូលព្រះមហា-
ក្សត្រិយ៍វិក្រមាទិត្យសព្វគ្រប់ប្រការ, ហើយក៏ទូលបន្ថែមថា "សូម
ទ្រង់ព្រះមេត្តាជ្រាស, សូមទ្រង់ព្រះពជ្ឈានទូរនាងកញ្ញាដែលមានរូប
ឆោមលោមពណ៌ល្អប្រិមប្រិយនេះមកទូលព្រះបង្គំ" ។

ព្រះមហាក្សត្រិយ៍ទ្រង់តបទៅនឹងកមលាការថា "បំណងរបស់អ្នក
នឹងសម្រេចដូចសេចក្តីប្រាថ្នា" ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ស្តេចយាង
ទៅជាមួយនឹងកមលាការ ដល់កញ្ចុំបុរី, ជិតនាងកញ្ញានរមោហិណី ។
លុះទ្រង់ទតទៅឃើញនាងកញ្ញា, ទ្រង់ឥតមានរំភើបព្រះទ័យឡើយ,
ទ្រង់ស្ថិតនៅនឹង, មិនមានព្រះទ័យធ្លាក់ចុះទៅក្នុងកាមារម្មណ៍ទេ ។
ក្នុងពេលនោះ រ័ក្សៈមានបំណងចង់បរិភោគព្រះមហាក្សត្រិយ៍, ក្នុង
ពេលរក្សៈនោះស្រែកសង្ឃឹកដំបូង, ព្រះអង្គបានយកព្រះហស្តកាន់
ដងព្រះខ័នថ្វា ហើយបម្រុងតយុទ្ធនឹងរក្សៈនោះវិញ ។ ទ្រង់បានតស៊ូ
នឹងរក្សៈរហូតដល់ពិឃាដរក្សៈនោះបានជាបរិយោសាន ។

នាងកញ្ញានរមោហិណី មានចិត្តសោមនស្សពន់ពេក ដោយឃើញ
ព្រះអង្គទ្រង់ពិឃាដរក្សៈ (Râxasa) នោះបាន ។ នាងសរសើរព្រះ
អង្គជាអនេកប្បការ ហើយក្រាបបង្គំទូលថា "ន! ព្រះអង្គ, ទ្រង់បាន
ជួយខ្ញុំម្ចាស់រួចពីកណ្តាប់ដៃរក្សៈ ។ ទ្រង់បានជ្រាសប្រាណទូរជីវិត
ខ្ញុំម្ចាស់, ព្រោះហេតុដូចនេះ ខ្ញុំម្ចាស់សូមជ្រកកោនក្រោមម្លប់របស់
ព្រះអង្គ" ។ ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ទូរវាចានាងកញ្ញា
ហើយមានព្រះបន្ទូលតបថា "ន នាងកញ្ញា បើនាងចូលមកជ្រកកោន

នឹងយើង, ចូរនាងប្រុងចិត្តកក្តីចំពោះបុរសដែលយើងនឹងប្រាប់គឺ "កម-
លាការ" ជាសុមេធបុរស ហើយដែលយើងពេញចិត្តជាងគេ, ចូរនាង
យកបុរសនេះធ្វើជាប្តីចុះ, ចូរនាងគោរពថា បុរសនេះជាស្វាមីនាងតាំង
ពីថ្ងៃនេះតទៅ" ។ នាងកញ្ញាព្រមតាមព្រះរាជឡង្ការព្រះមហាក្សត្រិយ៍ ។

លុះដល់ព្រះអង្គទ្រង់បានប្រគល់នាងកញ្ញាចំពោះកមលាការ ព្រះ
បាទវិក្រមាទិត្យទ្រង់ស្តេចយាងវិលត្រឡប់មកកាន់ព្រះរាជធានិវិញ ។

កមលាការ បាននាំយកនាងកញ្ញា ដែលមានរូបឆោមលោមពណ៌
ស្រស់ប្រិមប្រិយ វិលត្រឡប់ទៅកាន់គេហដ្ឋានខ្លួនដែរ ។

រូបទេពនិម្មិតទីប្រាំបីទូលបន្ទែមថា "ឧ ព្រះមហាក្សត្រគោជ:,
តាមដែលទូលបង្គំក្រាបទូលមកនេះ ទ្រង់អាចជ្រាបហើយថា ព្រះបាទ
វិក្រមាទិត្យ ទ្រង់បានបំពេញបំណងអ្នកជទៃ ចំណែកព្រះអង្គវិញបាន
បំពេញបំណងអ្នកជទៃយ"ងនោះដែរឬទេ? បើទ្រង់មានទើបអាចតង់ទៅ
លើបល្ថ័ង្កទិព្យនេះបាន" ។ ព្រះបាទគោជ: ទ្រង់ព្រះសណ្តាប់នូវវាចានៃ
រូបទេពនិម្មិតទី ៨, ទ្រង់ក៏បានស្តេចយាងចេញពីទីនេះ ដោយព្រះហឫ-
ទ័យអៀនខ្មាសពន់ពេក ។

* * *

(មានត)

កំណាត់ធនធនប្រវត្តិការណ៍

ប្រវត្តិនៃវត្តបទុមវតីភជវភាម

ក្រុងកំពត

ឃុនបណ្ណាផ្សុក្សប្ប៊ូ-ប៊ូ រៀបរៀង

វត្តបទុមវតីភជវភាម ដែលតាំងនៅភូមិសង្កាត់លេខ ៤ ក្រុងកំពតសព្វថ្ងៃនេះ កាលដើមឡើយ ជាទីដំណែលវត្តចាស់បុពណាឈ្មោះថា "វត្តខ្ចបតាយ៉ង" កើតមានជាយូរអង្វែងជាង ៥០០ ឆ្នាំមកហើយដូចមានសេចក្តីកត់ត្រាក្នុងព្រះពជពង្សាវតារក្រុងកម្ពុជាធិបតី បច្ចុប្បសម័យខ្សែទី ៣ តាំងពីទំព័រលេខ ៨៣ រៀងទៅថា៖

កាលព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) បានសោយរាជសម្បត្តិហើយ ទ្រង់គង់នៅក្រុងនគរធំបាន ១៦ ឆ្នាំ ស្តេចចោះបង់ចោលក្រុងនគរធំមកសាងក្រុងថ្មីនៅឧលុបាសាន ក្នុងរវាងត្រីស័ក្ខរាទ្រង់គង់នៅក្រុងថ្មីនេះបានតែ ១ ឆ្នាំ ស្តេចចេញមកសាងក្រុងកំពតជាគ្រាដំបូង ក្នុងឆ្នាំចោះសប្តស័ក ព. ស. ១៩៧៨ គ. ស. ១៤៣៥ ។ គ្រាសាងក្រុងនោះ ព្រះអង្គគ្រាស់បង្គាប់ឲ្យជីកព្រែក, ឲ្យធ្វើផ្លូវថ្នល់, ឲ្យកសាងវត្តជាច្រើនទៅក្នុងក្រុង ដូចមានឈ្មោះព្រែកនឹងឈ្មោះវត្តនៅជាប់រហូតមកដល់សព្វថ្ងៃនេះ ។ ទ្រង់ឲ្យកសាងវត្តមួយនៅទិសខាងជើងព្រះបរមរាជវាំង ហៅថា "វត្តឧណ្ណាលោម" ជាវត្តគណៈមហានិកាយ ។ ទ្រង់ឲ្យកសាងវត្តមួយទៀតនៅទិសខាងត្បូងព្រះបរមរាជវាំង

ហៅថា "វត្តខ្ពបតាយ៉ង" ជាវត្តគណៈមហានិកាយដែរ តែសម័យនោះព្រះសង្ឆនៅមិនទាន់មាននាមថាមហានិកាយទេ ព្រោះសម័យនោះប្រទេសកម្ពុជាពុំទាន់កើតមានព្រះសង្ឆគណៈធម្មយុត្តិនៅឡើយ ។ វត្តទាំង ២ នេះ ទ្រង់ឲ្យកសាងដំណាលគ្នាក្នុងឆ្នាំកុរបញ្ចស័ក.ព.ស. ១៩៨៦ គ.ស. ១៤៤៣ ។

វត្តខ្ពបតាយ៉ង

ដើមហេតុដែលឲ្យឈ្មោះថា "វត្តខ្ពបតាយ៉ង" ព្រោះទីវត្តនោះកាលដើមឡើយជាដីចំការរបស់តាយ៉ង ហើយគាត់បានជីកខ្ពបមួយនៅពីខាងកើតចំការនោះផង ។ ឯទំហំទទឹងបណ្តោយទីវត្តខ្ពបតាយ៉ង ក្នុងច្បាប់ព្រះរាជពង្សាវតារពុំបានប្រាប់ទេ ។

វត្តបទុមវតីរាជវរារាម

ដើមហេតុដែលឲ្យឈ្មោះថា "វត្តបទុមវតីរាជវរារាម" នោះជួចមានសេចក្តីអធិប្បាយតទៅនេះ:

ចំណេរកាលពីព្រះបាទសម្តេចព្រះបរមរាជា (ពញ្ញាយ៉ាត) មកមានព្រះមហាក្សត្រប្រើនព្រះអង្គគង់នៅក្រុងភ្នំពេញ ជាប់រៀងរហូតមកដល់ព្រះបាទសម្តេចព្រះស្រីសុគន្ធបទ ។ ស្តេចបោះបង់ចោលក្រុងភ្នំពេញ ទៅសាងក្រុងថ្មីនៅទួលបាសាន ខែត្រស្រីសន្ធរ ក្នុងឆ្នាំធ្លូវសប្តស័ក ព.ស. ២៤០៨ គ.ស. ១៨៦៥ ។ ព្រះមហាក្សត្រអង្គក្រោយ ។ មកបានផ្ទាស់ទៅសាងទីក្រុងនៅក្នុងខែត្រផ្សេងទៀត ។ ជាប្រើន រហូតដល់សាងក្រុងឧត្តុង្គមានជ័យ ។

ចំណេរកាលពីនោះមកទៀត ព្រះបាទសម្តេចព្រះនរោត្តមទ្រង់គង់
នៅក្រុងឧត្តុង្គមានជ័យ, ទាងក្រោយព្រះអង្គបោះបង់ចោលក្រុងឧត្តុង្គ
ស្តេចមក សាងក្រុងភ្នំពេញ ជាគ្រាទីពីរ នៅឆ្នាំឆ្លូវសប្តស័ក ព. ស.
៦៤០៨ គ. ស. ១៨៦៥ ។ គ្រានោះ ទ្រង់បាននិមន្តសម្តេចព្រះ
សុគន្ធាធិបតី ប៉ាន គណៈធម្មយុត្តិពីវត្តសាលាគ្លូ(១) (វត្តអំពិលបី) ក្រុង
ឧត្តុង្គ ឲ្យមកគង់នៅវត្តឧបតាយ៉ង ដែលជាវត្តបទុមវតីសព្វថ្ងៃនេះ ហើយ
ទ្រង់និមន្តសម្តេចព្រះសង្ឃរាជ - ទ្រៀង គណៈមហានិកាយ ពីវត្តពុទ្ធ
ប្រាង្គណ៍ ក្រុងឧត្តុង្គ ឲ្យមកគង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

រឿងប្រែឈ្មោះវត្តឧបតាយ៉ង ឲ្យហៅថាវត្តបទុមវតីរាជវរារាមវិញ
អ្នកឧកញ៉ាមហាវិនិច្ឆ័យ នៅ រ៉ុតែត អាយុ ៩០ ឆ្នាំ នឹងព្រះពុទ្ធាចារ្យ
ភុល - ទេស ព្រះជន្ម ៦៤ ឆ្នាំ គង់នៅវត្តបទុមវតី បានជំណាលថា
"កាលសម្តេចព្រះសុគន្ធាធិបតី ប៉ាន និមន្តចេញពីវត្តសាលាគ្លូ ក្រុង
ឧត្តុង្គ មកគង់នៅវត្តឧបតាយ៉ង ក្រុងភ្នំពេញជាដំបូង គ្រានោះ វត្ត
ឧបតាយ៉ងជាទីវត្តចាស់បុរាណ គ្មានវិហារកុដិសាលាជាកេរ្តឹ៍ដំណែល
ចាស់នៅសេសសល់ទេ សូម្បីតែកិត្ទុប្ទសាមណេរ ១ អង្គក៏គ្មានដែរ ។
វត្តចាស់នោះក្លាយទៅជាទីព្រៃសុទ្ធសាធ ព្រោះអ្នកស្រុកបោះបង់ចោល
ជាច្រើនរយឆ្នាំមកហើយ ប៉ុន្តែ បានជាគេដឹងថាកន្លែងនោះជាទីវត្តចាស់
បុរាណ ដោយសារគេមើលច្បាប់ព្រះរាជពង្សាវតារផង គេសង្កេតមើល
ឃើញទីទ្លូលព្រៃមួយទ្ពស់ជាងគេផង ហើយនៅលើទ្លូលនោះមានរាង

---

១ ហៅតាមត្រឹមត្រូវថា វត្តសាលាគំនូរ ។ ឬហៅ សាលាគ្លូ ព្រោះមានសាលាពីរ ក៏បាន ។

ប្រ៉ក់ស្ទឹកមួយតូច បែបជារោងឧបោសថ ក្នុងរោងនោះមានព្រះជីវ ១ អង្គតូច នៅក្បែរព្រះជីវនោះមានផែនថ្មសន្ទឹកសីមា ១ ផ្ទាំង, នៅទិសខាងកើតមុខទួលនោះមានខ្ពបមួយតូចវែង ដែលខ្មោចតាយ៉ងតាត់ជីកយកទឹកស្រោចដំណាំតាត់, ឯទឹកក្នុងខ្ពបនេះមិនរីងស្ងួតទេ តែងជក់នៅយួបប្រាំងវស្សាហើយថ្ងាស្អាតផង អ្នកស្រុកជងយកទឹកក្នុងខ្ពបនេះប្រើប្រាស់បាន ។

ត្រានោះ ព្រះបាទសម្តេចព្រះនរោត្តមទ្រង់ត្រាស់បង្គាប់មេការ ឲ្យជឹកនាំយកឈើព្រះរាជទ្រព្យពីក្រុងឧត្តុង្គមកកសាង ព្រះវិហារ, កុដិ, សាលា នៅលើទីទួលនោះ ទ្រង់ឲ្យជីកតូស្នាមក្ទោះខាងជើង ខាងត្បូងនឹងខាងលិចវត្ត ដើម្បីយកអាចម៍ដីចាក់បំពេញពង្រីកទីទួលនោះឲ្យបានខ្ពស់ធំទូលាយជាងមុន នឹងទ្រង់ឲ្យជីកខ្ពបចាស់នោះឲ្យជ្រៅជាងមុនទៅទៀត រួចឲ្យធាំដើមឈូកក្នុងតូស្នាមក្ទោះទាំង ៣ ជុងវត្ត ។ លុះរៀបចំទីវត្តល្មមសមគួរហើយ ក៏ផ្ទើបុណ្យបញ្ចុះសីមាធ្ងងវិហារកុដិសាលា, រៀលានោះ បានប្រែឈ្មោះ "វត្តខ្ពបតាយ៉ង" ជា "វត្តបទុមវតីរាជ-វរារាម" វិញ ប្រែថា "វត្តមានឈូកជារបង ជាអារាមដ៏ប្រសើររបស់ព្រះរាជា" ជាប់រហូតមកជល់សព្វថ្ងៃនេះ ។

បានរកឃើញភស្តុតាងមួយទៀត: មានផែនថ្ម ១ ផ្ទាំងជាសន្ទឹកសីមាទិសបូព៌ ដែលគេជំកល់ទុកនៅមុខព្រះវិហារវត្តបទុមវតីសព្វថ្ងៃនេះ មានអក្សរចារឹកនៅថ្មសន្ទឹកសីមានោះថា "ពុ. ២៤១៤ មមែ នក្សត្រត្រីសកហេមន្តរតូ បុស្សមាគ សុក្កបក្ស ចតុទ្ទសី តិថីភុម្មវារ ជាបរិច្ឆេទកាល

កំណត់ទីត្រែងណោះ បានបង្កុះជាមហាសីមារួចហើយ ឯមហាសីមានេះ បន្ទាយ ៥ សិន ទទឹង ៤ សិន ។

«ប្រែ»[1]

បញ្ជាក់សេចក្តីក្នុងអក្សរចារឹកខាងលើនេះ ឲ្យដាយស្គាល់ថា ថ្ងៃ ៣ ១៤ ២ ឆ្នាំមមែ នក្សត្រត្រីស័ក ហេមន្តរដូវ ព.ស. ២៤១៤ ជាបរិច្ឆេទកាល កំណត់ទីត្រែងនេះបានបង្កុះជាមហាសីមារួចហើយ ឯមហាសីមានេះ បណ្តោយ ៥ សិន ទទឹង ៤ សិន[2] ។

តិតតាំងពី ព.ស. ២៤០៨ គ.ស. ១៨៦៥ ជាឆ្នាំដែលសម្តេចព្រះសុគន្ធាធិបតី ប៉ាន ចាប់ផ្តើមកសាងវត្តបទុមវតីជាដំបូងបំផុតមក ការរៀបចំតាក់តែងវត្តនេះចេះតែបានចំរើនកើនឡើងរៀងរាល់ឆ្នាំ ដូចមានកុដិ, សាលាទឹងបូជនីយដ្ឋានជាច្រើន គឺ

ព្រះភោធិព្រឹក្ស[3]

ព្រះបាទ សម្តេចព្រះនរោត្តម ទ្រង់ត្រាស់បង្គាប់មុខមន្ត្រីឲ្យធ្វើបុណ្យ សម្ពោធ ៣ ថ្ងៃជាំកូនព្រះពោធិព្រឹក្ស ដែលព្រះតេនសារត្តេរគង់នៅលង្កាទ្វីបនាំមកថ្វាយព្រះអង្គ នៅទីមុខវត្តបទុមវតី នៅថ្ងៃ ៣ ១០ ៣ ឆ្នាំកុរនព្វស័ក ព.ស. ២៤៣០ ច.ស. ១២៤៩ គ.ស. ១៨៨៧ ក្នុងសម័យនៃសម្តេចព្រះសុគន្ធាធិបតី ប៉ាន ។

---

១ ចំឡងតាមបែបអក្សរដែលគេចារឹកនៅថ្មសន្ធឹកសីមានោះ ។ ២ ពីរហត្ថត្រូវជា ១ ម៉ែត្រ, ២ ម៉ែត្រត្រូវជា ១ ព្យាម, ២០ ព្យាមត្រូវជា ១ សិន ។ ឯមហាសីមាវត្តបទុមវតីនេះ បណ្តោយ ៥ សិន ត្រូវជា ២០០ ម៉ែត្រ, ទទឹង ៤ សិន ត្រូវជា ១៦០ម៉ែត្រ ។ (វិចនានុក្រមខ្មែរ) ។ ៣ ស្រង់ពីច្បាប់ត្រែរាជពង្សាវតារក្រុងកម្ពុជា ។

ព្រះបេតិយអង្គធំ (១)

សម្តេចព្រះមង្គលទេពាចារ្យ អៀម ជានយោសនាពួកពុទ្ធ-
បរិស័ទកសាងព្រះចេតិយធំមួយអង្គក្នុងវត្តបទុមវតី ។ លុះកសាងរួច
ស្រេចហើយជានធ្វើបុណ្យបញ្ចុះព្រះបរមសារីរិកធាតុ ១ អង្គ និងព្រះ
អរហន្តធាតុ ១ អង្គ ដែលព្រះរតនសារត្ថេរនៅលង្ការទ្វីបនាំយកមកថ្វាយ
ព្រះជាទសម្តេចព្រះនរោត្តមក្នុងពេលជាមួយកូនព្រះពោធិព្រឹក្សនោះ ព្រម
ទាំងបញ្ចុះ ព្រះអដ្ឋិធាតុនៃសម្តេចព្រះសុគន្ធាធិបតី ជ៉ាន ផង នៅ
ថ្ងៃ ៤ ៦/១ ឆ្នាំរកាឯកស័ក ព.ស. ២៤៥២ ច.ស. ១២៧១ ត្រូវនឹងថ្ងៃ
ទី ៨ ខែមេ៉ គ.ស. ១៩០៩ ក្នុងរជ្ជកាលនៃព្រះជាទសម្តេចព្រះស៊ីសុវត្ថិ
(ព្រះបរមរាជានុកោដ្ឋ) ។

ព្រះវិហារថ្មី

សម្តេចព្រះមង្គលទេពាចារ្យ សុិក ជាមេគំនិតជានចាប់ផ្តើមរុះរើ
ព្រះវិហារចាស់ក្នុងវត្តបទុមវតីចេញ ហើយកសាងព្រះវិហារថ្មីតាំងពីក្នុង
ឆ្នាំធ្លូវនញស័ក ព.ស. ២៤៨០ គ.ស. ១៩៣៧ ក្នុងរជ្ជកាលនៃព្រះជាទ
សម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ។ លុះកសាងព្រះវិហារថ្មីនោះរួចស្រេច
ហើយ ជានធ្វើបុណ្យសម្ពោធិធ្លងនៅថ្ងៃ ៧ ៦/១ ៤ ឆ្នាំមមីចត្វាស័ក ព.ស.
២៤៨៥ ច.ស. ១៣០៤ ត្រូវនឹងថ្ងៃទី ២០ ខែមា៉ារ្ស គ.ស. ១៩៤២ ក្នុង
រជ្ជកាលនៃព្រះជាទសម្តេចព្រះនរោត្តម-សីហនុ-រ៉ាន និងក្នុងសម័យនៃ
សម្តេចព្រះសុធម្មាធិបតី អ៊ុង-ស្រី ។

---

១ ស្រង់ពីប្បាប់ព្រះរាជពង្សាវតារក្រុងកម្ពុជា ។

ក្រៅអំពីថាវរវត្ត ៣ យ៉ាងខាងដើមនេះ នៅមានកិច្ចការជាសំខាន់ប្រើនទៀត(១) គឺបានរៀបចំតាក់តែងទីខាងមុខវត្តបទុមវតីឲ្យស្អាតបាតសមរំល្អ, បានធ្វើកុដិធំ ៗ ជាប្រើនខ្នង, បានធ្វើទីបាំធា ៣ ខ្នង, បានធ្វើសាលាសំណាក់ ៦ ខ្នងនឹងសាលាកេសជ្ជៈ ១ ខ្នង, បានធ្វើស្រះឈូក ១ គូ, បានធ្វើសាលាបិណ្ឌ ១ ខ្នងនឹងសាលាបរិយត្តិធម្មវិន័យ ១ ខ្នង, បានរុះរើរោងជួងចាស់ធ្វើជាថ្មីឡើងវិញនៅកន្ទែងចាស់ដដែល, បានចាក់ដីបំពេញទីវត្តឲ្យរាបស្មើ ព្រមទាំងបានធ្វើកំពែងវត្តផង ។ ល ។ ការរៀបចំទីវត្តបានចំរើនឡើងរៀងរាល់ឆ្នាំ ដោយសារកម្ទាំងសទ្ធាជ្រះថ្ងានៃពួកពុទ្ធបរិស័ទទាំងឡាយ មានអ្នកឧកញ៉ាមហាមន្ត្រី ញ៉ឹក-នូវ ជាអ្នកទទួលការៈចាត់ការ បានចាប់ផ្តើមរៀបចំទីមុខវត្តនឹងក្នុងវត្តតាំងពី ព.ស. ២៤៨៥ គ.ស. ១៩៤២ ជាដើមរៀងមក ក្នុងសម័យនៃសម្តេចព្រះសុធម្មាធិបតី អ៊ុង-ស្រី ។

សេចក្តីបញ្ជាប

អាយុវត្តខ្ពបតាយ៉ង, ចាប់រាប់ពីត្រឹម ព.ស. ១៩៧៨ គ.ស. ១៤៣៥ ដែលចាប់ផ្តើមកសាងវត្តខ្ពបតាយ៉ងនៅសម័យសាងក្រុងកុំពេញគ្រាដំបូង រហូតមកដល់ ព.ស. ២៤០៨ គ.ស. ១៨៦៥ ដែលប្រែឈ្មោះវត្តខ្ពបតាយ៉ង ជាវត្តបទុមវតីវិញ នៅវេលាសាងក្រុងកុំពេញគ្រាទី ២ ឃើញបានចំនួន ៤៣១ ឆ្នាំ នេះជាអាយុនៃវត្តខ្ពបតាយ៉ង ។

---

១ ស្រង់ពីសេចក្តីរាយការរបស់អ្នកឧកញ៉ាមហាមន្ត្រី ញ៉ឹក-នូវ ។

អាយុវត្តបទុមវតី, ចាប់ពាក់ព័ន្ធនឹងឆ្នាំដែលតាំងឈ្មោះវត្តបទុមវតី រហូតមកដល់ ព.ស. ២៤៩៨ គ. ស. ១៩៥៥ បានចំនួន ៩០ ឆ្នាំ នេះជាអាយុនៃវត្តបទុមវតី ។ យក ៤៣១ ឆ្នាំបូករួមនឹង ៩០ ឆ្នាំត្រូវជា ៥២១ ឆ្នាំ នេះទុកជារយៈកាលនៃវត្តនេះ ដែលបានប្រតិស្ឋានមក ។

វិទ្យាទាក់ទងនឹងព្រះពុទ្ធសាសនា ដែលគួរស្គាល់:

សម្រាប់អ្នកស្រុកជប៉ុន គេកាន់ថា «ព្រះពុទ្ធសាសនា ជាសំពៅមាសរបស់វិឡានធម្មនៃជាតិ» ព្រោះអក្សរសាស្ត្រ ការស្ថាបនា ជាងឥដ្ឋ ជាងកំបោរ ជាងគំនូរ និងអ្នកតែងសៀវភៅ រហូតដល់ការតាំងផ្កាឈើ ឬល្ខោន ក៏កើតមកពីសាសនាទាំងអស់, ហេតុនេះ ទើបទុកជាការត្រឹមត្រូវហើយ ដែលឡកិត្តិយសចំពោះព្រះពុទ្ធសាសនាថា «ជាសំពៅមាសរបស់វិឡានធម្មនៃជាតិ» ព្រោះបានផ្តុំកយកសិល្បៈវិទ្យាការផ្សេងៗ មកកាន់ប្រទេសជប៉ុនជាច្រើនយ៉ាង ។

ចាកសៀវភៅ «ដោមមុខមែនពិតរបស់ជប៉ុន»

ប្រែចាកទស្សនាវដ្តីសាសនាភាសាបៃ

អ្នកប្រែ: ចាប - ពិន

យោបល់អ្នកប្រែ:

ខ្មែរយើងក៏ទុកព្រះពុទ្ធសាសនា ជាសំពៅមាសរបស់វិឡានធម្មនៃជាតិដូចជប៉ុនដែរ ព្រោះខ្មែរទាំងប្រទេសយល់ថា ព្រះពុទ្ធសាសនាមានវត្តអារាមជាមូលដ្ឋាន ជនណាបានចូលបួសជាបព្វជិត ឬជាគ្រហស្ថអាស្រ័យនៅក្នុងវត្ត តែងតែបេះអក្សរ បេះស្ថាបនា បេះគ្រឿងឥដ្ឋ កំបោរ បេះគំនូរ បេះតែងសៀវភៅ រហូតដល់បេះភ្លេង ឬបេះល្ខោន, មកពីវត្តជាទីផ្តុំកន្លែងវិសិល្បៈវិទ្យាទាំងនេះតាំងពីបុរាណកាលមក ។

ពិធីបុណ្យវិសាខបូជានៅក្រុងភ្នំពេញ

លោកលេខាធិការ ញ៉ែម-ទឹម

ប្រែអំពីសារពត៌មាន « កំពូជ » លេខ ២៨៩២ ឆ្នាំទី ១២
ចេញថ្ងៃ ៣០ ឧសភា ឆ្នាំ ១៩៥៥

កាលពីល្ងាចថ្ងៃសុក្រមុននេះ នៅមហាវិទ្យាល័យហាវ៉ាដ ពួកបព្វជិតនិងពួកពុទ្ធបរិស័ទនៅក្រុងភ្នំពេញ បានរួមគ្នាធ្វើបុណ្យប្រចាំឆ្នាំមួយ គឺបុណ្យវិសាខបូជា ។

បុណ្យនេះជាបុណ្យលើកទី ៣ ដែលគេធ្វើនៅក្រុងភ្នំពេញ ដោយសារពួកសមាគមមិត្តនៃពុទ្ធសាសនា ដែលមានចំនួនមួយភាគ ៥ នៃប្រជាជននៅក្រុងនោះជាអ្នកផ្តើម ។ បុណ្យនេះធ្វើឡើងដើម្បីគោរពចំពោះថ្ងៃដែលព្រះអង្គទ្រង់ប្រសូត ទ្រង់ត្រាស់ដឹងជាព្រះពុទ្ធ និងទ្រង់ចូលព្រះនិព្វាន ។

មានអង្គទូតជាច្រើនសាសន៍ ដែលតាំងនៅក្រុងភ្នំពេញ បានអញ្ជើញទៅរួមធ្វើពិធីនេះដែរ ។ ពិធីបុណ្យនេះបានធ្វើឡើងក្រោមអធិបតីភាពនៃសមាគមអប់រំខាងព្រះពុទ្ធសាសនានៃមហាវិទ្យាល័យ ។

សមាគមនេះ បានចាប់កំណើតឡើងបីឆ្នាំមកហើយ ដោយមានសមាជិកសុទ្ធតែជាអ្នកខ្នះខ្នែងជួយឧបត្ថម្ភហើយជាអ្នកចេះដឹងជ្រៅជ្រះខាងពុទ្ធសាសនាផង ។

មានជនម្នាក់តំណាងក្រុមនោះបាននិយាយថា ‘‘ឆ្នាំក្រោយសមាគមនេះនឹងបង្កើតឲ្យមានកម្មវិធីបង្រៀនខាងអក្សរសាស្ត្រ និងចាប់រៀន

ខាងព្រះពុទ្ធសាសនា ។ កាលពីមុនមានសាស្ត្រាចារ្យម្នាក់ដែលគេ
ជ្រើសរើសនៅនាក្រុងនោះ បានមកបង្រៀនភាសាបាលីប្រចាំថ្នាក់មួយ
បែបដែលគេនិយមប្រើក្នុងសម័យព្រះពុទ្ធគង់នៅឡើយ ដល់ពួកសមាជិក
នៃសមាគមនោះ ។ តំប៉ុន្តែការបង្រៀននោះអាក់ខានទៅវិញ ដោយ
សាស្ត្រាចារ្យនេះត្រូវផ្លាស់ទៅកាន់កន្លែងថ្មីទៀត ។

អ្នកតំណាងក្រុមនេះបានពោលបន្ថែមទៀតថា "ផ្នែកបាលីនៃ
ប្រទេសលង្កាបានធ្វើអំណោយជាសៀវភៅ មានអត្ថបទជាភាសាបាលី
ជាច្រើនដល់សមាគមនេះ ដូច្នេះការបង្រៀននឹងចាប់ផ្តើមឡើងវិញនៅ
ពេលខាងមុខនេះ ។

ការសន្និបាតក្នុងឆ្នាំនេះ ធ្វើទៅស្មានឯកអគ្គរាជទូតថៃនឹងទៅស្មាន
ឯកអគ្គរាជទូតកោះលង្កា ។

សព្វថ្ងៃនេះ សមាគមកំពុងខំខ្នះខ្នែងរៀបចំឲ្យមានការទស្សនាទៅ
កន្លែងឯទៀតឲ្យបានកាន់តែច្រើនក្នុងតំបន់នោះ ដើម្បីឲ្យសមាជិកមាន
ឱកាសនឹងផ្សាយពន្យល់លទ្ធិព្រះពុទ្ធសាសនា ដល់ប្រជាជនឯទៀត ។
ផង ។

លោកប្រធានាធិបតី អ៊ីសិនហូវ័រ បានទទួចឲ្យគេបញ្ជាក់អំពី
សេរីភាពនៃពុទ្ធសាសនាជូនលោកម្ចាស់ទៀត ។ មិនតែប៉ុណ្ណោះ លោកសុំ
ឲ្យពួកពលរដ្ឋអាមេរិកាំង "បញ្ជាក់អំពីច្បាប់ដែលជនម្នាក់ៗត្រូវមានសិទ្ធិ
នឹងដឿចំពោះសាសនាណាក៏ដោយ តាមសម្បជញ្ញៈរបស់ខ្លួន" ជូន

លោកម្ពង់ទៀតដែរ ។ លោកប្រធានាធិបតីបានពោលបំភ្ជឹថា "សេចក្តីបញ្ជាក់បន្ទែមនេះជាការមួយសំខាន់ណាស់ក្នុងសារតារ នៅពេលដែលប្រជាជនសកលលោកមិនព្រមទទួលស្គាល់សេរីភាពជនជទៃ" ។

សេចក្តីថ្វែងការណ៍របស់លោកប្រធានាធិបតី ដែលនៅក្នុងសារ-លិខិតមួយ គេបានយកទៅសូត្រនៅ រិល្ជីយ៉ាំស្ស្យរ នៅពេលដែលគេធ្វើពិធីបញ្ជាក់អំពី "ជំនឿរបស់ជនជាតិអាមេរិកាំងចំពោះសេរីភាពនៃលទ្ធិព្រះពុទ្ធសាសនា" ។ នៅពេលធ្វើនោះ គឺកាលពីថ្ងៃអាទិត្យមុននេះ លោកវេជ្ជបណ្ឌិតក្រាយសុន-ណ-ឥរ៉ក ប្រធាននៃមហាវិទ្យាល័យកូឡុំ-ប៉ីយ៉ាបានពោលចំពោះមុខប្រជាជនចំនួន ៣.៥០០ នាក់ថា សេរីភាពខាងសាសនាមិនអាចនឹងយ្ជាតបេញពីសេរីភាពឯកជនបានឡើយ" ។ លោកបានពោលអាងថា ដោយហេតុតែមានការចំរើនខាងផ្ទូវដឹកនាំនឹងក្នុងការទាក់ទងគ្នាទៅវិញទៅមកប្រជាជនគ្រប់នគរ ក្នុងសម័យឥឡូវនេះត្រូវតែបានទទួលព្រេងវាសនាប្ដអនាគតជូចៗគ្នា" ។ លោកបានអំពាវនាវ ឲ្យជនដែលមានធនួ:ល្អ ស្ថិប្ពូរនឹងច្បាប់ខាងផ្ទូវចិត្ត រួមតែមួយជាមួយគ្នានេះ" ។

លោកវេជ្ជបណ្ឌិត ឥរ៉ក បានពោលរំព្ធកអំពីច្បាប់បុរាណដែលស្ពីអំពីសេរីភាពស្ថិតនៅឯក្រុង រិល្ជីយ៉ាំស្ស្យរ ហើយនឹងអនុស្សាវរីយ៍ នៃវីរបុរសដែលបានផ្ទើមបង្ក្រីតសេរីភាព ហើយថែមទាំងបានតស្ថិដើម្បីការពារសេរីភាពនេះផង កាលក្នុងសតវត្សទី ១៨ ។

លោកបានពោលបន្ថែមទៀតថា "យើងត្រូវដោះស្រាយបញ្ហាសម័យនេះ ឲ្យដូចជារបៀបដែលវីរបុរសយើងមុន ។ លោកបានដោះស្រាយបញ្ហារបស់លោកកាលជំនាន់នោះដែរ" ។ សហប្រជាជាតិបានផ្ទើតុណបំណាច់ជាច្រើនអនេកដល់ប្រជាជនគ្រប់ប្រភេទ ហើយមានពោលថា ច្បាប់ធម្មនុញ្ញសហប្រជាជាតិសព្វថ្ងៃនេះ បានផ្ទើឲ្យមានការព្រមព្រៀងមួយយ៉ាងធំទូលាយណាស់ ។ ដូច្នេះយើងមិនត្រូវយល់ថា ធម្មនុញ្ញសហប្រជាជាតិជាថ្នាំសម្រាប់ដោះស្រាយបញ្ហាយើងសព្វថ្ងៃនេះ" ។

"យើងមានចិត្តប្រាថ្នានឹងបង្កើត (ថែរក្សា) ច្បាប់នេះមិនមែនមានចិត្តចង់រំលាយទេ ហើយបើយើងគ្រាន់តែទំព្យាយាមពង្រីកសាលាបង្រៀនរវាងប្រជាជាតិឲ្យកាន់តែមានចំនួនច្រើនឡើងប៉ុណ្ណោះ នោះយើងមិនអាចនឹងរកឃើញនូវផែនការសន្តិភាព នឹង សុខភាពសកលលោកបានឡើយ ដោយប្រាសចាកច្បាប់ទាងលើនេះ ។

នៅទីបញ្ចប់ លោកវេជ្ជបណ្ឌិតមានប្រសាសន៍ថា ការដោះស្រាយនៃបញ្ហាក្នុងថ្ងៃនេះ អាចទុកពិភាក្សាទៅពេលក្រោយទៀតបានយ៉ាងហ្មត់ចត់ ជាមួយនឹងបញ្ហាដែលជាប់ទាក់ទងក្នុងប្រទេស តែដែលសំខាន់ជាងគេ គឺបញ្ហាស្តីអំពីច្បាប់ទាងផ្លូវចិត្ត ។ គឺថាបើមានសតិសម្បជញ្ញៈទាងផ្ទើចិត្តឲ្យនឹងកុងជំនឿហើយ នោះយើងអាចរួមបញ្ហាទាំងពីរទាងលើនេះបាន ។

ភម្ពមសុទិយា

ទស្សនាវិដ្ឋី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខ្វែកញ្ញា លេខ ៩

ព.ស.២៤៩៨ – គ.ស. ១៩៥៥



ទស្សនាវដ្ត៉ី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

ប្រោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា		ទំព័រ
— សេចក្ត៉ីបរិសុទ្ធិនៅឯណា	ព្រះទេពសត្តា កិម - ត្ថ	៦៤៣
— ប្រស្នាធម៉ិ ៥ ១	ឃុនបណ្ណានុរ៉ក្ស ប៉ូ - ប៉ូ	៦៥២
— រឿងធម្មទ្ធជបណ្ឌិត	លោក គាំ - ឆ្ទុំ	៦៥៧
— បញ្ញាសជាតក ភាគទី ៤	បណ្ឌិតមហា ឈឹម - ស៊ុម	៦៦៨
ផ្នែកអក្សរសាស្ត្រ		
— និទានសុភាសិត	ព្រះមហា ម៉ៅ - ទាន់	៦៧៧
— រឿងសៅរសោយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៉ុង - ប៉ម ..	៦៨៣
— រឿងសាមកុក (តមក)	ឧកញ៉ា ន្ទ - កន	៦៩៣
— ដំណឹងតាមឡល់ក្នុងកន្ទារ: (តមក) ...	លោក ផេង - ជ្រីវ	៧០១
— រឿងបល្ស៉ង្ក ទិព្យ (តមក)	លោក ភ៉យ - ប៊ុក	៧០៩
កំណត់នឹងប្រវត្តិការណ៍		
— ពិធីសម្ពោទ្យប៉ើកសាលាបាលីរង		
វត្តព្រះព្រហ្មារ៉ត៍ន៍ទៃត្រសៀមរាប	ព្រះគ្រូអនុគុណ កែ អឿន ...	៧១៦

មួយឆ្នាំមាន ១២ សៀវភៅ — ជំទ្យៃជាវ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Parisuddhi	*Vén. TEM-TO*	*643*
— Prasna Dharma	*M. BOU-PO*	*652*
— Dhammaddhajapandit	*M. KAM-DOUM*	*657*
— Pannasajataka-vol. 4	*M. CHHIM-SOUM*	*668*

PARTIE LITTERAIRE:

— Nidanasubhasita	*Vén. MAO-KHANN* . . .	*677*
— Le « SAU - SOY » ou l'influence saturnienne (suite)	*Vén. PEUNG-PAM.*	*683*
— Histoire de SAMKOK (suite) . .	*Oknha NOU-KAN*	*693*
— Le souffle du désert (suite) .	*M. PHENG-CHRIV* . . .	*701*
— Les trente deux récits du TRONE (suite)	*M. RAY-BUC*	*709*

NOTES ET CHRONIQUES:

— Inauguration de l'Ecole Elémentaire de Pali de Vat Brah Prom Rat	*Vén. KER-OEURN*	*716*

Prix d'abonnement annuel (comprenant 12 numéros) 210,00

ផ្នែកសាសនា

សេចក្តីបរិសុទ្ធិនៅឯណា?

ព្រះទេពសត្តា កិម-ត្ថ

ក្រុមដំនំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

សេចក្តីបរិសុទ្ធិជាគួនឹងសេចក្តីមិនបរិសុទ្ធិ ។ សេចក្តីបរិសុទ្ធិគឺអ្វី? សេចក្តីបរិសុទ្ធិ គឺការស្អាតកាយ, ស្អាតវាចា, ស្អាតចិត្ត មិនសៅហ្មងដោយអំពើអាក្រក់ណាមួយដែលគួរឲ្យអ្នកផងតិះដៀលបាន ។ សេចក្តីមិនបរិសុទ្ធិគឺអ្វី? សេចក្តីមិនបរិសុទ្ធិមានដំណើរផ្ទុយគ្នានឹងសេចក្តីបរិសុទ្ធិដូចបាននិយាយមកហើយនេះ ។

មនុស្សប្រកេទណាក៏ដោយ ទោះជាន់ខ្ពស់ក្តី ជាន់កណ្តាលក្តី ជាន់ទាបក្តី ជាអ្នកចេះលៃលករៀបចំទុកដាក់កាយឲ្យសមរម្យទៅតាមហានៈរបស់ខ្លួន មិនប្រព្រឹត្តច្រឡើសបើស, ជាអ្នកអនុលោមតាមច្បាប់សម្រាប់ផ្ទូវលោកនឹងច្បាប់សម្រាប់ផ្ទូវធម្មិ ទាំងក្នុងទីចំពោះមុខទាំងក្នុងទីកំបាំងមុខ មិនប្រើកម្ចាំងកាយរំលោកឲ្យប្រព្រឹត្តទៅហួសហេតុហួសទំនងមានការប្រហារជីវិតសត្ថ នឹងការលួចលាក់ធក់ដណ្តើមរឹបជាន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយអយុត្តិធម្មិជាដើម, ជាអ្នកមានបុកពាសុកាពរាបសាល្អ ទាំងមានចរិយាធម្មិនឹងអបចាយនធម្មិចំពោះអ្នកដទៃមិនរើសមុខ យ៉ាងនេះជាដើមហៅថា កាយបរិសុទ្ធិ បរិសុទ្ធិដោយកាយ ។

មនុស្សណាមួយ កាលបើបញ្ចេញវាចានិយាយពីអ្វី វាចានោះឯងមិនដែលបៀតបៀន ឲ្យកើតសេចក្តីរន្ធត់ស្ងើចដល់អ្នកដទៃ ត្រូវនិយាយតែពាក្យណាដែលនាំឲ្យមានប្រយោជន៍, ជាវាចាសុភាពរាបសាពីកេរ មិនគ្រោះថ្នាក់ប្រកបមើលងាយអ្នកដទៃ, ជាសំដីគួរគេជ្រះថ្លា គួរគេចង់ស្តាប់ វាចាផុតពីវចីទុច្ចរិតទាំង ៤ យ៉ាង មិនឲ្យប៉ះពាល់ខួចសិទ្ធិអ្នកដទៃ យ៉ាងនេះជាដើមហៅថា វាចាបរិសុទ្ធិ បរិសុទ្ធិស្អាតដោយវាចា។

មនុស្សណាមួយ បានសង្រួមប្រឹងប្រយ័ត្នសំអាតចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ ឲ្យតាំងនៅក្នុងកុសលធម៌ ជ្រាសចាកមនោទុច្ចរិតទាំង ៣ យ៉ាង មិនបណ្តោយឲ្យចិត្តត្រេកត្រអាងលោភលន់ ឈ្នានីស ច្រណែនទន្ទឹងគេ យ៉ាងនេះជាដើម ហៅថា ចិត្តបរិសុទ្ធិ បរិសុទ្ធិស្អាតដោយចិត្ត ។

អ្នកដែលបានកើតមកមានជីវិតរស់នៅក្នុងលោកនេះ មានសញ្ញាតំណាមនុស្សនីមួយៗ គប្បីញ៉ាំងកាយ វាចា ចិត្ត ឲ្យស្ងប់រៀបរយល្អទៅតាមច្បាប់លោកនឹងច្បាប់ធម៌ដែលមានតំរិតពុកមក ពុំគួរបើកអំណាចបណ្តោយឲ្យកាយ វាចា ចិត្ត ប្រព្រឹត្តពាយឆាយតាំងនៅខាងត្រៃច្បាប់ឡើយ ព្រោះថាការដែលបានទទួលសុខកាត, រង្គានកាតនឹងជោគជ័យគ្រប់ដំណក្រមរបស់សត្វនីមួយៗ រមែងកើតអំពីកាយ វាចា ចិត្ត ដ៏បរិសុទ្ធល្អ, ឯការបានទទួលទុក្ខទោសគ្រោះថ្នាក់អពមង្គលគ្រប់ដំណក្រ តំរូវមែងកើតមកអំពីកាយ វាចា ចិត្ត មិនបរិសុទ្ធល្អដែរ ព្រោះកាយ វាចា ចិត្ត ទាំង ៣ នេះទុកដូចជាទ្វារសម្រាប់បើកទុកាសឲ្យសុខនឹងទុក្ខហូរចូលមក ឬថាជាប្រធានជាឧទ្ទេសមុខគ្រួសជាអ្នកបង្កហេតុឲ្យកើតសុខនឹងទុក្ខក៏ឃាន ។

ព្រោះហេតុនោះ សេចក្ដីបរិសុទ្ធិនឹងសេចក្ដីមិនបរិសុទ្ធិទាំងពីរនេះ ដែលកើតឡើងហើយរមែងឲ្យផលដល់បុគ្គលអ្នកធ្វើចំពោះខ្លួនឯង បើនិយាយតាមសាមញ្ញវោហារថា អ្នកណាធ្វើក៏ជារបស់អ្នកនោះ ឥតមានអ្នកណាធ្វើឲ្យអ្នកណាបរិសុទ្ធបុសៅហ្មងបានឡើយ ។ ប៉ែកខាងលទ្ធិព្រាហ្មណ៍មានសេចក្ដីប្រកាន់ថា អំពើបាបណាមួយដែលបុគ្គលធ្វើហើយ គេអាចលាងជំរះបណ្តែតបុបន្សាត់ចោលបានដោយធ្វើពិធីមានងូតទឹកជាដើម គឺក្នុងពេលដែលកំពុងងូតទឹកជំរះមន្ទិលកាយ បាបនោះឯងក៏ជ្រះស្អាតអណ្តែតរសាត់ទៅតាមខ្សែទឹកជាមួយនឹងមន្ទិលកាយដែរ ។ មានលទ្ធិដទៃខ្លះទៀតប្រកាន់ថា អំពើបាបណាមួយទោះបីធ្ងន់ក្ដី ស្រាលក្ដី ដែលបុគ្គលធ្វើហើយ គេអាចទៅលន់តួអង្វរករសូមខមាទោសចំពោះព្រះម្ចាស់សួត៍ ដើម្បីឲ្យព្រះម្ចាស់សួត៍នោះ ប្រោសប្រាណត្រាប្រណីលើកទោសកំហុសរបស់ខ្លួនចោលចេញបាន ដូចគ្នានឹងព្រះមហាក្សត្រម្ចាស់ផែនដីទ្រង់ប្រោសប្រាណលើកទោសព្រះរាជទានដល់អ្នកធ្វើខុស ឲ្យផុតចាកព្រះរាជអាជ្ញាដែរ យ៉ាងនេះជាដើម ។

ចំណែកខាងព្រះពុទ្ធសាសនា មានសេចក្ដីផ្ទុយគ្នានឹងលទ្ធិទាំងនោះថា អំពើបាបដែលបុគ្គលធ្វើដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង, មិនធ្វើបាបដោយខ្លួនឯង រមែងបរិសុទ្ធដោយខ្លួនឯង ។ សេចក្ដីបរិសុទ្ធិនឹងសេចក្ដីសៅហ្មង រមែងកើតចំពោះខ្លួនអ្នកធ្វើតែម្យ៉ាងប៉ុណ្ណោះ មិនមែនកើតអំពីហេតុដទៃឡើយ ។ បុគ្គលដែលសៅហ្មងព្រោះអកុសលកម្ម, ដែលបរិសុទ្ធចាកសេចក្ដីសៅហ្មង ព្រោះកុសលកម្មប្រកបដោយប្រាជ្ញា

ដែលយល់ត្រូវ ។ ជនណាពិចារណាឃើញច្បាស់ដោយប្រាជ្ញាថា ការ
ប្រព្រឹត្តិធ្វើអកុសលកម្មគឺអំពើជាអកុសលផ្សេងៗ មានសម្ចាប់សត្វនឹងល្មច
លាក់ឆក់ដណ្តើមកំហែង ឬប្រវ័ញ្ចន៍យកទ្រព្យសម្បត្តិរបស់គេដោយ
អយុត្តិធម៌ជាដើម អំពើទាំងនេះសុទ្ធតែជាកម្មមានទោសជាផ្ទូវអបាយ
មិនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ ហើយក៏លះបង់គឺ
មិនធ្វើអកុសលកម្មនោះតទៅទៀត ជននោះឈ្មោះថាជាអ្នកបរិសុទ្ធស្អាត
សូម្បីជាអ្នកមានសេចក្តីសៅហ្មងដិតជាមជាប់មកអំពីពេលមុនខ្លះ ព្រោះ
អកុសលកម្មដែលខ្លួនធ្វើដោយសេចក្តីប្រហែសធ្វេសធោតលូង់ខ្លៅ ក៏គង់
ត្រឡប់ទៅជាអ្នកបរិសុទ្ធស្អាតដោយសារកុសលកម្ម ដែលខ្លួនធ្វើក្នុង
កាលជាខាងក្រោយដោយពិត, សមដូចភាសិតថា:

យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ ឧប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោ វ បឌ្ឋិមា

អ្នកណាធ្វេសប្រហែសក្នុងកាលពីមុន លុះកាលជាខាងក្រោយមក
ក៏ងាកបែរទៅជាមិនធ្វេសប្រហែសវិញ អ្នកនោះឈ្មោះថា ធ្វើលោកនេះ
ឲ្យភ្លឺស្វាងរុងរឿង ដូចជាព្រះចន្ទដែលចេញផុតពីពពក ។

អធិប្បាយបញ្ជាក់ពុទ្ធភាសិតនេះថា ជនណាមួយ កាលពីពេលមុន
មក ជាអ្នកមានសេចក្តីធ្វេសប្រហែសវង្វេងជ្រុលធ្វើអំពើអាក្រក់ណាមួយ
ដោយកាយ វាចា ចិត្តដែលអ្នកប្រាជ្ញតែងវិះគន់ថាជាអំពើលាមកកខ្វក់សៅ
ហ្មងមិនស្អាត លុះកាលជាខាងក្រោយមក ក៏បែរជាក្រាក់គំនិតដឹងខ្លួនថា
ខុស ហើយលះបង់សេចក្តីធ្វេសប្រហែសវង្វេងដែលធ្លាប់តែប្រព្រឹត្តធ្វើ

អំពើអាក្រក់នោះ ៗ ចោលចេញ ហើយប្រព្រឹត្តធ្វើតែអំពើល្អ ដោយកាយ
វាចា ចិត្ត មានឲ្យទានរក្សាសីលជាដើម ជននោះឯងឈ្មោះថាធ្វើខ្លួនឲ្យ
មានពន្ធឺក្ខឺឲ្យបរិសុទ្ធស្អាត ទាំងកេរ្តិ៍ឈ្មោះរបស់ជននោះសោត ក៏ក្រអូប
ផ្សាយទៅកាន់ទិសទីទាំងពួងដោយសេចក្តីរុងរឿងក្នុងលោកនេះ ប្រៀប
ដូចជាព្រះចន្ទពេញវង់ដែលលឿនឃ្លាតចេញផុតពីមន្ទិល មានពពក
ជាដើមដូច្នោះឯង ៗ សេចក្តីដែលពណិនាមកប៉ុណ្ណោះនេះ ដើម្បី
បញ្ជាក់ឲ្យឃើញថា ក្រៅអំពីខ្លួនរបស់ខ្លួនឯង អ្នកណានឹងអាចធ្វើអ្នក
ណាឲ្យបរិសុទ្ធប្រសៅហ្មងនោះពុំបានឡើយ ៗ

មានជនពួកខ្លះក្នុងលោកនេះមានសេចក្តីយល់ថា សេចក្តីបរិសុទ្ធិនឹង
សេចក្តីមិនបរិសុទ្ធិសម្រេចមកតែអំពីចិត្ត សូម្បីកុសលក្តី អកុសលក្តី ក៏
សម្រេចមកតែអំពីចិត្តដែរ ប្រដំណើរទៅកាន់សុគតិក្តី ទៅកាន់ទុគ្គតិក្តី
ក៏សម្រេចមកតែអំពីចិត្តដែរ ហេតុនោះ យើងមិនចាំបាច់ធ្វើទេ ដូចជា
បុណ្យកុសលអ្វីផ្សេង ៗ យើងកុំចាំបាច់ធ្វើ ប្រកុំចាំបាច់ហាត់គិតទុកជាមុន
នាំឲ្យខាតទ្រ៉ព្យ ប្រនាំឲ្យរវល់ខាតវេលាទេ ចាំដល់ពេលណាដែលយើង
ត្រូវការសេចក្តីល្អគឺ បុណ្យ ប្រក៏ក្នុងពេលជិតស្លាប់សឹមយើងតាំងចិត្តឲ្យ
បរិសុទ្ធស្អាតល្អដើម្បីឈោងចាប់យកសុគតិតែម្តង ៗ អ្នកមានគំនិតយល់
ដូច្នេះ ប្រហែលជាស្មានថាចិត្តនេះជាធម្មជាត ងាយប្រដៅ ស្លួលហ្ចឹក
ហាត់ស្លួលពត់ជម្រង់ចង់ឲ្យទៅយ៉ាងណា ៗ ក៏អាចបំបែរបំបត់ក្លាម ៗ បាន
យ៉ាងនោះតាមបំណងខ្លួនទេដឹង ! ការយល់ដូច្នេះ មិនត្រូវបែប ទុសទំនង
មិនសមហេតុផលសោះឡើយ ៗ តាមពិតនោះ ធម្មជាតិទាំងពាយ៉ាង គឺ

កាយ វាចា ចិត្តនេះ មានលក្ខណៈពិបាកបង្ហាត់ទូន្មានប្រៀនប្រដៅឲ្យបានបែបបទដោយអាការផ្សេង ៗ ត្នាយ៉ាងនេះ គឺកាយដែលអាចធ្វើអ្វីទៅបានត្រប់យ៉ាង ដូចជាចេះសរសេរអក្សរស្អក្តី ចេះធ្វើគ្រឿងអលង្ការអំពីមាសនឹងប្រាក់សំរាប់តាក់តែងកាយនៃបុរសនឹងស្ត្រី ឲ្យមានក្សាប់ក្សូរក្ប៉ីរស្ងៃស្អក្តី ចេះគូររូបគំនូរដ៏រិចិត្រស្អក្តីដូច្នេះជាដើម លុះណាតែបានរៀនបានហាត់ឲ្យស្ទាត់ទុកជាមុន ទើបកាយនោះឯងអាចប្រើការឲ្យសម្រេចប្រយោជន៍ទៅបាន ៗ ចំណែកខាងវាចាគឺសំដីសោតទៀតក៏ប្រហែលត្នា ដូចជាចេះនិយាយការអ្វីឲ្យគេស្តាប់ឬក៏ចេះថ្វែងសុន្ទរកថាជាដើម ក្នុងទីប្រជុំជនមិនមានការទាស់ធ្គងទៅបាន លុះណាតែបានគិតហាត់អានឲ្យស្ទាត់ទុកជាមុនសិនដែរ ទើបវាចានោះឯងជាសំដីពីរោះចាប់ចិត្តដល់អ្នកស្តាប់គួរគេយកតម្រាប់តាម ៗ កាយនឹងវាចាទាំងពីរនេះជាធម្មជាតិមើលឃើញច្បាស់ដោយភ្នែក ស្តាប់ព្ទច្បាស់ដោយត្រចៀកម៉ែចគង់ពិបាកបង្ហាត់ទូន្មានម្ទ៉េះទៅហើយ ចំណង់បើចិត្តជាអតិសុខុមជាតល្អិតភ្នៃកែលែង ត្នានរូបពណិសណ្ឋានទ្រង់ទ្រាយអ្វីជាគ្រឿងប្រាកដសោះផង សមនឹងពិបាកទូន្មានយ៉ាងណាទៅទៀត, ហេតុនោះការទូន្មានហាត់ចិត្តឲ្យបានបែបបទបរិសុទ្ធិស្អាតនោះ មិនមែនជាការងាយទេកែជាទីបំផុត ព្រោះចិត្តនោះជាធម្មជាតល្អិតធ្មារហួសរិស័យនឹងប្រដូចមានសន្ទុះលឿនរហ័សភ្នៃកែលែងនឹងរកអ្វីមកប្រៀបឲ្យស្មើពុំបាន ជាធម្មជាតធាប់ប្រែប្រួល, ធាប់ញាប់ញ័រ, ធាប់ឃ្វេងឃ្វោង, ធាប់ធ្ងន្ធា ម្តងដូច្នេះ ម្តងដូច្នោះ នឹងចាប់ពត់តម្រង់ឲ្យត្រង់ល្អតាមបំណងរបស់ខ្លួនភ្លាម ៗ

នោះ បានដោយគ្រែពេកណាស់, មិនមែនជាការងាយស្រួលដូចជនពួកខ្លះ ដែលមានសេចក្តីយល់ឆ្គងដូចបានពោលមកហើយនោះទេ ។

ម្យ៉ាងទៀត មានជនពួកខ្លះយល់ថា សេចក្តីបរិសុទ្ធក្នុងដំរៀនរបស់មនុស្សម្នាក់ៗដែលកើតមកក្នុងលោកនេះ គឺមកអំពីមានជាតិគោត្រតែកូលពូជឥស្សរដ៏ខ្ពង់ខ្ពស់ ឬមកអំពីមានទ្រព្យសម្បត្តិច្រើន ទើបឈ្មោះថាជាសេចក្តីបរិសុទ្ធិស្អាតរបស់មនុស្ស ។ ការយល់ដូច្នេះទុកជាគំនិតយល់ឆ្គងខុសវង្វេងគ្មានធឹងសេចក្តីពិត បើតាមពិតមែននោះ គឺសេចក្តីបរិសុទ្ធិស្អាតនៅត្រង់កាយ វាចា ចិត្ត ដែលមិនប្រព្រឹត្តធ្វើអកុសលកម្មណាមួយ ទើបចាត់ឲ្យឈ្មោះថាជាសេចក្តីបរិសុទ្ធិស្អាតរបស់មនុស្សក្នុងទីនេះបាន មិនមែនបរិសុទ្ធ ព្រោះតែមានជាតិគោត្រតែកូលពូជឥស្សរដ៏ខ្ពង់ខ្ពស់នោះទេ មិនមែនបរិសុទ្ធព្រោះតែមានទ្រព្យសម្បត្តិច្រើននោះទេ, សមដូចព្រះពុទ្ធភាសិតថា:

កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ
ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា

សត្វទាំងឡាយ រមែងបរិសុទ្ធស្អាតដោយគុណធម៌ ៥ យ៉ាង(១)នេះគឺ: កម្ម ១ វិជ្ជា ១ ធម៌ ១ សីល ១ ជីវិតដ៏ឧត្តម ១ មិនមែនបរិសុទ្ធដោយសារគោត្រតែកូលឬដោយសារទ្រព្យសម្បត្តិទេ ។

គុណធម៌ទាំង ៥ យ៉ាងនេះ ជាសេចក្តីប្រតិបត្តិដុសខាត់ខាងផ្លូវកាយ

---

១ ធម៌ ៥ យ៉ាងនេះមានសេចក្តីអធិប្បាយក្នុងគម្ពីរ បរមត្ថមញ្ជូសាដីការសុទ្ធិមគ្គត្រង់សីលនិទ្ទេស ។

រាបា ចិត្ត របស់សត្វឲ្យបរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង មិនមែន
បរិសុទ្ធដោយហេតុដទៃឡើយ ។ ព្រោះហេតុនោះ ពុទ្ធសាសនិកជន
គួរជ្រាបថា បើប្រាថ្នាសេចក្តីបរិសុទ្ធិឲ្យកើតឡើងចំពោះខ្លួន ត្រូវតែខ្លួន
យើងប្រតិបត្តិធ្វើបំពេញកិច្ចផ្ទាល់ដោយខ្លួនឯង ឬសេចក្តីសៅហ្មងកើត
ឡើងដល់ខ្លួនហើយ ត្រូវតែខ្លួនយើងលាងជំរះសំអាតផ្ទាល់ដោយខ្លួន
យើង នឹងទៅពឹងពាក់រកអ្នកដទៃឲ្យគេធ្វើជំនួសខ្លួនពុំបានឡើយ, សេចក្តី
នេះប្រៀបដូចជនពីរនាក់ ជនម្នាក់បរិភោគអាហារធ្នែតស្កប់ស្កល់ហើយ
ឃើញជនម្នាក់ទៀតមិនទាន់បរិភោគអាហារសោះ កំពុងមានសេចក្តី
ស្រេកឃ្លាន ហើយចង់ចែកធ្នែតរបស់ខ្លួនទៅអ្នកដែលកំពុងឃ្លាននោះ
ឲ្យបានធ្នែតដូចខ្លួនផង តើជនធ្នែតនោះអាចបេះរំលែកធ្នែតចែកឲ្យទៅជន
ឃ្លាននោះខ្លះផងបានឬទេ? មួយទៀត ប្រៀបដូចជនម្នាក់កំពុងអន្ទះអន្ទែង
ដោយសេចក្តីស្រេកឃ្លាន បានឃើញជនម្នាក់ដើរចូលមកជិត ហើយចង់
ចែកឃ្លានរបស់ខ្លួនឲ្យទៅជនម្នាក់នោះ ឲ្យគេជួយឃ្លានដូចខ្លួនផង តើជន
ឃ្លាននោះនឹងអាចបេះរំលែកឃ្លានចែកឲ្យទៅជនឯទៀតឲ្យគេជួយឃ្លានខ្លះ
ផងបានឬទេ? តាមពិត ជនទាំងពីរនាក់គឺជនធ្នែតនឹងជនឃ្លាន នឹងបេះ
រំលែកធ្នែតនឹងឃ្លានឲ្យដល់គ្នានឹងគ្នាទៅវិញទៅមក ពុំបានសោះឡើយ
មានឧបមាយ៉ាងណា; ឯសេចក្តីបរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិនេះ រមែង
កើតឡើងអំពីខ្លួនរបស់ខ្លួនឯង អ្នកណាមួយ នឹងអាចបេះរំលែកសេចក្តី
បរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិ ឲ្យដល់គ្នានឹងគ្នាទៅវិញទៅមក ពុំបាន
សោះឡើយ ក៏មានឧបមេយ្យដូច្នោះឯង ។

ផលល្អនឹងផលអាក្រក់ ដែលលេចចេញមកពីសេចក្តីបរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិនៃកាយវាចាចិត្ត អាចបង្ហាញឲ្យឃើញជាក់ស្តែងក្នុងបច្ចុប្បន្ននេះដែលត្រូវទទួលសុខទុក្ខផ្សេងៗគ្នានោះ មិនចាំបាច់ទាញតួយ៉ាងមកចង្អុលក្បាច់ក្នុងទីនេះទេ សូមពិចារណាពិនិត្យសង្កេតមើល ដោយប្រាជ្ញាដ៏ជ្រាលជ្រៅនៅដុំវិញខ្លួន ក៏គង់ឃើញបានដោយមិនលំបាក ។

ហេតុនោះ ពុទ្ធសាសនិកជាអ្នកចង់បានសេចក្តីសុខនឹងសេចក្តីចំរើនឲ្យកើតមានដល់ខ្លួនគ្រប់វេលានោះ ត្រូវតែតាំងសតិគឺស្មារតីឲ្យយាមល្បាតប្រចាំនៅទ្វារកាយ វាចា ចិត្តជានិច្ច ដើម្បីទប់ពាំងអកុសលផ្សេងៗមានអភិជ្ឈានឹងគេមនស្សជាដើម កុំឲ្យចូលមកបៀតបៀនបាន; បើពុំដូច្នោះទេ មុខជានឹងត្រូវទទួលទុក្ខទោសគ្រោះថ្នាក់ណាមួយ តាមគួរដល់យថាកម្ម គាំងក្នុងបច្ចុប្បន្ននឹងបរលោក ព្រោះតែសេចក្តីមិនបរិសុទ្ធិនៃកាយវាចាចិត្តនោះឯងជាហេតុ ។

ពណ៌នាអំពីសេចក្តីបរិសុទ្ធិ ជាគូនឹងសេចក្តីមិនបរិសុទ្ធិ ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ឃុនបណ្ណាន់រក្ស ប៊ូ-ប៊ូ រៀបរៀង

១– សំនួរ: មានព្រះពុទ្ធភាសិត ១ បទថា "អត្តា ហិ អត្តនោ នាថោ ខ្លួនជាទីពឹងរបស់ខ្លួន" បើដូច្នោះ យើងកុំចាំបាច់យកព្រះរតនត្រ័យជាទីពឹងទៅឬអ្វី?

ចម្លើយ– មិនដូច្នោះទេ ព្រោះយើងត្រូវការធ្វើខ្លួនយើងឲ្យជាទីពឹងរបស់ខ្លួន ទើបយើងត្រូវតែយកព្រះរតនត្រ័យជាទីពឹង ដ្បិតថាខ្លួនយើងដែលនឹងយកជាទីពឹងរបស់ខ្លួនបាននោះ ត្រូវអាស្រ័យគុណធម៌សេចក្តីល្អរបស់ខ្លួន ។ ឯគុណធម៌សេចក្តីល្អនោះ មានគោលជាច្រើនយ៉ាងណាស់ ប៉ុន្តែ បើយើងបានយកព្រះរតនត្រ័យជាទីពឹងគុកជាឫសគល់ហើយ គុណធម៌សេចក្តីល្អដទៃៗ ក៏នឹងកើតឡើងតាមមកផង ទាល់តែក្លាយទៅជាអ្នកមានខ្លួនជាទីពឹងរបស់ខ្លួនបាន, ដោយមានហេតុផលយ៉ាងខ្លីប៉ុណ្ណេះ បានជាការដែលយើងយកព្រះរតនត្រ័យជាទីពឹង ឈ្មោះថាជាការធ្វើខ្លួនយើងឲ្យជាទីពឹងរបស់ខ្លួនបានដោយល្អ ។

២– សំនួរ: មនុស្សដែលតាំងខ្លួននៅក្នុងវាងចន្ទោះកណ្តាលបុណ្យ នឹងបាប គឺថាបុណ្យក៏មិនធ្វើ បាបក៏មិនធ្វើ លុះដល់គេស្លាប់ទៅហើយ តើគេនឹងបានទទួលសោយផលនៃការនៅក្នុងវាងចន្ទោះកណ្តាលបុណ្យ នឹងបាប ឬយ៉ាងណា?

ចម្លើយ– មនុស្សដែលតាំងខ្លួននៅក្នុងវាងចន្ទោះកណ្តាលបុណ្យ នឹងបាបដូច្នោះ គួរនឹងមានតែពួកកូនក្មេងដែលស្លាប់តាំងពីតូច ។ នៅ

មិនទាន់ដឹងក្តី បើគេរស់នៅរហូតដល់ធំដឹងក្តីហើយ មិនមានអ្នកណា
អាចនឹងតាំងខ្លួននៅក្នុងរវាងចន្ទោះកណ្តាលបុណ្យនឹងបាប អស់មួយជីវិត
បានឡើយ ជ្យិតមនុស្សគ្រប់រូបច្រើនតែធ្វើទាំងបុណ្យទាំងបាបលាយឡំ
គ្នា ប្រែកតែតិចប្រច្រើនប៉ុណ្ណោះ ។ ម្យ៉ាងទៀត បើអ្នកណាវៀរចាក
បាបបានហើយ អ្នកនោះក៏ឈ្មោះថាបានធ្វើបុណ្យ ដូចជាយើងមិន
សម្ងាប់សត្វជាដើម ក៏ឈ្មោះថាជាមនុស្សមានសីល ហៅថាសីលមយ-
បុញ្ញកិរិយាវត្ថុ, ក្រៅពីនេះ នៅមានផ្លូវឲ្យកើតបុណ្យដទៃ ៗទៀតដល់ ៩
ផ្លូវ ព្រោះហេតុនោះ កាលបើគេមិនធ្វើបាបដោយ កាយ-វាចា ហើយ
ក៏ឈ្មោះថាគេបានធ្វើបុណ្យនៅក្នុងខ្លួន ។ ប៉ុន្តែមានជនខ្ទះមិនធ្វើបាប
ដោយផ្លូវកាយវាចាក៏ពិត តែផ្លូវចិត្តគង់មានអាក្រក់ ដូចជាឈ្មោះ (ក) ប៉ុន
ប៉ង់នឹងសម្ងាប់ឈ្មោះ (ខ) ប៉ុន្តែ មិនបានឧកាសនឹងសម្ងាប់រហូតដល់អស់
មួយជីវិត ។ ការដែលឈ្មោះ (ក) សម្ងាប់ឈ្មោះ (ខ) មិនបាននោះក៏ឈ្មោះ
ថាមិនបានធ្វើបាប កាលបើគេមិនបានធ្វើបាបដូច្នេះ នឹងឲ្យឈ្មោះថាគេ
បានធ្វើបុណ្យផងដែរប្រទេ? ត្រូវធ្វើយថា ឈ្មោះ (ក) មិនបានសម្ងាប់ឈ្មោះ
(ខ) នោះ ក៏ត្រាន់តែផុតពីបាបផ្លូវកាយប៉ុណ្ណោះ ចំណែកចិត្តជាទុច្ចរិត
ឈ្មោះថាមនោទុច្ចរិតព្រោះមានតំនិតព្យាបាទប៉ង់នឹងសម្ងាប់ឈ្មោះ (ខ),
កាលបើចិត្តប្រកបដោយសេចក្តីអាក្រក់ដូច្នេះហើយ ឈ្មោះ (ក) នឹងបាន
រួចខ្លួនពីបាបម្តេចបាន ជាមនុស្សកណ្តាលម្តេចកើត ។ ចំណែកកូនក្មេង
ដែលស្ងាប់តាំងពីនៅតូច ។ មិនទាន់ដឹងក្តីនោះ ទើបឈ្មោះថានៅក្នុងរវាង
ចន្ទោះកណ្តាលបុណ្យនឹងបាប ព្រោះវាមិនទាន់ចេះធ្វើបុណ្យប្រធ្វើបាប

នៅជាឧកាសកម្មចាស់ដែលខ្លួនធ្លាប់ធ្វើពុកមកពីជាតិមុននោះ នឹងនាំបដិសន្ធិតទៅទៀតមិនចេះអស់ឡើយ ។

៣- សំនួរៈ ចុះព្រះអរហន្ត ដែលឈ្មោះថាបណ្តែតបុណ្យនឹងចាបចេញបានហើយនោះ តើនឹងចាត់ថាលោកនៅក្នុងចន្លោះតណ្ហាលបុណ្យនឹងចាបបានឬទេ ?

ចម្លើយ- មិនបានទេ ។ ព្រោះពាក្យថានៅក្នុងចន្លោះតណ្ហាលបុណ្យនឹងចាបនោះជាពាក្យចង្អុលឲ្យឃើញថា អាចនឹងធ្វើបុណ្យឬធ្វើចាបទៀតក៏បាន ។ ឯព្រះអរហន្តផុតចាកបុណ្យនឹងចាបតាំង ៤ យ៉ាងដាច់ស្រឡះពិតមែន បានជាលោកបានឈ្មោះថាលះបង់បុណ្យនឹងចាបផង បានឈ្មោះថាបណ្តែតបុណ្យនឹងចាបចេញផង មិនមែនលោកនៅក្នុងចន្លោះតណ្ហាលនៃបុណ្យនឹងចាបទេ ។

៤- សំនួរៈ ចុះបើព្រះអរហន្តលះបង់បុណ្យនឹងចាបបានហើយ ក៏ត្រូវតែឲ្យឈ្មោះថាលោកមិនធ្វើបុណ្យនឹងចាបមែនឬទេ ?

ចម្លើយ- មែនណាស់ហើយ ។ ព្រោះព្រះអរហន្តលោកមិនធ្វើបុណ្យនឹងចាបសោះ ។

៥- សំនួរៈ បើដូច្នោះ ការវៀរចាកចាបរបស់ព្រះអរហន្តនោះមិនពាប់បញ្ចូលក្នុងការធ្វើបុណ្យផងទេឬ ?

ចម្លើយ- មិនពាប់បញ្ចូលផងទេ ។ ព្រោះបើមានចាប (សេចក្តីអាក្រក់) ត្រូវតែមានបុណ្យ (របស់ដែលជួសលាងជម្រះសេចក្តីអាក្រក់ចេញ) ដូចជាវេលាមានរោគ ក៏ត្រូវតែមានថ្នាំកែ ថ្នាំត្រូវតែមានពុក

សម្រាប់ការពារពេត បំបាត់ពេតប៉ុណ្ណោះ បើគេមិនធ្លាប់មានពេតសោះ ធ្វើម៉េចគេនឹងដឹងពាក្យថាថ្នាំបាន ។ បុណ្យនឹងបាបក៏ដូច្នោះដែរ ជាគូច្បាបច្បាមគ្នាដោយត្រង់ ដ្បិតថាបើនៅមានបាបជាបណា សេចក្តីត្រូវការបុណ្យក៏នៅតែមានជាបនោះ ប៉ុន្តែ ព្រះអរហន្តលះបង់បាបបានជាប់ខាត ហើយលោកមិនត្រូវនៅជាប់ជំពាក់នឹងបុណ្យទៀតទេ ឬលោកមិនត្រូវធ្វើបុណ្យ ដើម្បីដុសលាងជម្រះបាបតទៅទៀតឡើយ ដោយហេតុនេះព្រះអរហន្ត ទើបឈ្មោះថាធុតបាបបុណ្យនឹងបាបទាំង ២ យ៉ាងជាប់ស្រឡះហើយ ។ ឯការធ្វើរបស់ព្រះអរហន្ត គ្រាន់តែជាកិរិយាប៉ុណ្ណោះ មិនពាប់ថាជាការធ្វើបុណ្យឬបាបទេ ព្រោះលោកមិនជាប់ជំពាក់ដោយការធ្វើសេចក្តីអាក្រក់ឬកំចាត់បង់សេចក្តីអាក្រក់ សឹងខុសពីបុថុជ្ជនអ្នកលះបង់សេចក្តីអាក្រក់មិនទាន់បានជាប់ស្រឡះ បានជាបុថុជ្ជនត្រូវតែធ្វើបុណ្យដើម្បីតែងដុសលាងជម្រះសេចក្តីអាក្រក់ចេញ ដូចបានអធិប្បាយមកនេះ ។

៦— សំនួរ ខន្ធ ៥ គឺរូប ១ វេទនា ១ សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ ដែលព្រះយោគាវចរត្រូវដឹងឲ្យច្បាស់លាស់, ត្រូវតែកំណត់ដឹង, មិនត្រូវលះបង់, មិនត្រូវបំបែរ, មិនត្រូវធ្វើឲ្យជាក់ប្បាស់ នោះតើមានអត្ថាធិប្បាយដូចម្តេច?

ចម្លើយ— អធិប្បាយថា ខន្ធ ៥ ជាទុក្ខ ។ របស់ណាជាទុក្ខ របស់នោះត្រូវតែកំណត់ដឹង មិនត្រូវលះបង់ទេ ព្រោះការលះបង់នោះ ត្រូវលះបង់ហេតុនៃទុក្ខគឺតណ្ហា មិនត្រូវលះបង់តួទុក្ខគឺខន្ធ ៥ ដែលជាផលទេ។

បើទុក្ខជាអ្នកណា ចំប្រឹងលះបង់ខន្ធ ៥ ឲ្យបានល្អតែដល់ស្លាប់ខ្លួនផង អ្នកនោះ
ក៏នៅតែលះបង់ទុក្ខមិនបានជាប់ស្រឡះដែរ ប្រៀបដូចកំដៅនឹងភ្លើង,
កំដៅជាផលរបស់ភ្លើង យើងមិនអាចនឹងលត់កំដៅដែលជាផលបានទេ
បើយើងមិនចង់ឲ្យក្តៅ យើងត្រូវតែលត់ហេតុគឺភ្លើងចេញ កំដៅទើបបាត់
សូន្យអស់ទៅ ។ ឯទុក្ខនោះយើងមិនត្រូវធ្វើឲ្យជាក់ច្បាស់ទេ ព្រោះមិន
មែនជានិកេត តម្រាំងមិនត្រូវចំរើនដែរ ព្រោះមិនមែនជាមគ្គ ។

ពាក្យដែលថា ខន្ធ ៥ ជាតួទុក្ខក្នុងអរិយសច្ច នឹងថាជាតួទុក្ខត្រូវតែ
កំណត់ដឹងនោះ មានគោលអាងក្នុងធម្មចក្កប្បវត្តនសូត្រថា "សង្ខិត្តេន
បញ្ចុបាទានក្ខន្ធា ទុក្ខា ដោយខ្លី ឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ" នឹង
ពាក្យថា "ឥទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យំ . . . អរិយសច្ច គឺទុក្ខនេះ
ត្រូវតែកំណត់ដឹង" ។ សូម្បីបាលីដែលជាព្រះពុទ្ធភាសិតក្នុងទីដទៃ
ដូចក្នុងសឡាយតនវិភង្គសូត្រ មជ្ឈិមនិកាយ ឧបរិបណ្ណាសក កំចង្អុល
ប្រាប់យ៉ាងច្បាស់លាស់ថា "ភិក្ខុទាំងឡាយ ! ធម៌ដែលត្រូវកំណត់ដឹង
ដោយបញ្ញាដ៏ក្រៃលែង តើដូចម្តេច ? គួរឆ្លើយថា "ឧបាទានក្ខន្ធទាំង ៥ គឺ
រូប ១ វេទនា ១ សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ ធម៌ទាំងនេះត្រូវកំណត់
ដឹងដោយបញ្ញាដ៏ក្រៃលែង ។

រឿងធម្មទូជបណ្ឌិត

ក្នុងគម្ពីរខុទ្ទកនិកាយ ទុកនិបាត

លោកគាំ-ឆ្ពុំ

លេខាធិការការិយាល័យសារមន្ទីរអាល់បែរសារូ

ប្រែនឹងរៀបរៀង

ក្នុងកាលដែលកន្ទងទៅហើយ នៅក្រុងពារាណសី មានព្រះរាជាមួយព្រះអង្គព្រះនាម យសបាណី ទ្រង់សោយរាជ្យប្រកបដោយធម៌ ។ ព្រះរាជានោះ មានសេនាបតីម្នាក់ឈ្មោះកាឡក: (ជាអ្នកជំរះក្តី), កាលនោះព្រះពោធិសត្វព្រះនាម ធម្មទ្ធជ: ធ្វើជាបុរោហិត, មានខ្មាន់ប្រកេសអ្នកស្ថិតស្ថាងព្រះកេសាម្នាក់ ឈ្មោះ ធត្តបាណី ។

ឯកាឡកសេនាបតី ជាអ្នកកាត់ក្តីស៊ីសំណូកហាក់ដូចជាស៊ីសាច់ខ្នងនៃរាស្ត្រផងដទៃ លុះបានសំណូកហើយទើបរកសរវៃកាត់ក្តី ធ្វើជនដែលពុំមែនជាម្ចាស់របស់ឲ្យបានជាម្ចាស់វិញ គឺធ្វើអ្នកចាញ់ឲ្យឈ្នះវិញ ។

ថ្ងៃមួយ មានបុរសម្នាក់ដែលសេនាបតីនោះកាត់ក្តីឲ្យចាញ់គេហើយ កំពុងតែផ្គងដៃឡើងពោលកន្ទក់កន្ទេញដើរចេញមកអំពីវិនិច្ឆយដ្ឋាន បានបួបនឹងព្រះពោធិសត្វកំពុងតែដើរទៅគាល់បម្រើព្រះរាជា បុរសនោះក៏ម្នីម្នាចូលទៅលុតជង្គង់គ្រាបទៀបបាទានៃព្រះពោធិសត្វ ហើយនិយាយជំរាបថា "ឧលោកម្ចាស់អើយ! មនុស្សប្រហែលយ"ងលោកមកប្រៀនប្រដៅនូវអាថិធម៌ដល់ព្រះរាជាយ"ងនេះហើយ កាឡកសេនាបតីនៅតែហ៊ានស៊ីសំណូកសូកអង្វរកាត់ក្តីពុំសុចរិតយុត្តិធម៌ ធ្វើអ្នកក្តីដែលពុំមែនជាម្ចាស់

ឲ្យជាម្ចាស់របស់វិញបាន" រួចហើយក៏ថ្វៃឥរៀបរាប់ប្រាប់អំពីជំណើរដែល
ខ្ជួនចាញ់នោះសព្វគ្រប់ដល់ព្រះពោធិសត្ត ។ ព្រះពោធិសត្តកើតមាន
សេចក្តីអាសូរករុណាណាស់ ក៏និយាយទៅនឹងបុរសនោះថា "ប្រើដូច្នោះ
ចូរអ្នកតាមយើងមកចុះ យើងនឹងជំរះកាត់ក្តីឲ្យអ្នក" ហើយក៏នាំបុរសនោះ
ទៅឯសាលាវិនិច្ឆ័យ រើជំរះក្តីនោះ ធ្វើអ្នកជាម្ចាស់ឲ្យបានជាម្ចាស់របសវិញ
ដោយយុត្តិធម៌ ។ ឯពួកមហាជនដែលមកប្រជុំគ្នាចាំមើលកុះករ ក៏ស្រែក
ឲ្យពរសព្ទសាធុការ, សូរសព្ទលាន់ព្ធទ្រហឹងអឹងកងរំពងដល់ព្រះរាជាៗ
ទ្រង់ត្រាស់សួរថា វ៉ីអមាត្យ ចុះសំឡេងអ្វីហ្នឹង? ។ ពួកអមាត្យក្រាបបង្គំទូល
ថា សូមទ្រង់ព្រះមេត្តាប្រោស ធម្មទ្ធជបណ្ឌិតជំរះក្តីដែលកាឡកសេនាបតី
កាត់ដោយពុំសុចរិតយុត្តិធម៌ រើជំរះកាត់ឲ្យបានជាសុចរិតយុត្តិធម៌ឡើងវិញ
សូរសព្ទនោះមិញជាសព្ទសាធុការពរអស់ពួកមហាជនក្នុងទីនោះឯង ។

ព្រះរាជាទ្រង់សព្ទព្រះរាជហ្ឫទ័យ ក៏ត្រាស់ឲ្យហៅព្រះពោធិសត្ត
មក ទ្រង់មានព្រះរាជឧត្តារថា ' តាំងពីថ្ងៃនេះទៅ ចូរអ្នកមកធ្វើជាចៅក្រម
វិនិច្ឆ័យកាត់ក្តីវិញចុះ យើងនឹងបានព្ធសំឡេងសព្ទសាធុការដែលជាសុ
ស្ឃែលដល់ត្រចៀកផង ឯសេចក្តីចំរើនក៏នឹងមានដល់មនុស្សលោកផង"
ទើបទ្រង់លួងលោមអង្វរព្រះពោធិសត្ត ដែលជាអ្នកពុំមានប្រាថ្នានឹងធ្វើ
ការនុ+ះសោះឲ្យទទួលព្រមមកអង្គុយក្នុងវិនិច្ឆយដ្ឋានសម្រាប់កាត់ក្តី ដោយ
សេចក្តីអាណិតអាសូរអ្នកក្តី ។ តាំងពីថ្ងៃនោះតទៅ ព្រះពោធិសត្ត
តែងទៅអង្គុយកាត់ក្តីធ្វើជនជាម្ចាស់ ឲ្យបានជាម្ចាស់វិញ ដោយសុចរិត
យុត្តិធម៌ (អ្នកក្តីបានសេចក្តីត្រេកអរ សុខចិត្តទាំងសងខាង) ។

ឯកាឡកសេនាបតី តាំងពីថ្ងៃនោះទៅក៏លែងបានលាកសក្ការ: ឥត
មានន្រណាគេរាប់រកសោះ ម្ងៃ៉ះហើយក៏កើតមានចិត្តទោមនស្សបុស្សា
ទើបចូលទៅក្រាបបង្គំទូលញុះញង់ព្រះរាជា ឲ្យយកទោសព្រះពោធិសត្ត
ថា បពិត្រព្រះមហារាជ, សូមទ្រង់ព្រះមេត្តាប្រោស ជ្ឈិតធម្មទ្ធជបណ្ឌិត
ជាមនុស្សអាក្រក់មានចិត្តក្សត់ប៉ុនប៉ងប្រាថ្នាយករាជសម្បត្តិ របស់ព្រះអង្ត
គ្រប់គ្រង ។ ព្រះរាជាទ្រង់ពុំជឿតាមបានហាមយាត់សេនាបតីថា អ្នកកុំ
និយាយយ៉ាងហ្នឹងទៀតឡើយ ។ ឯកាឡកសេនាបតីក៏ធ្វៀតរកឧបាយ
ក្រាបបង្គំទូលតទៅទៀតថា សូមទ្រង់ព្រះមេត្តាប្រោស បើព្រះអង្គពុំ
ទ្រង់ជឿតាមពាក្យទូលព្រះបង្គំទូលតាមពិតទេ សូមព្រះករុណាម្ចាស់
ជីវិតទ្រង់ចាំទតមើលតាមបង្ហ្ហូចក្នុងរវលាដែលធម្មទ្ធជបណ្ឌិត ដើរមកចុះ
មុខជានឹងបានឃើញប្រាកដថាធម្មទ្ធជបណ្ឌិតជាអ្នកធ្វើឲ្យអ្នកនគរទាំងអស់
នៅក្នុងកណ្តាប់ដៃខ្ជូន ។ លុះព្រះរាជាទ្រង់ទតទៅឃើញពួកបរិសទ្យ
ដែលមានរឿងក្តីទាំងប៉ុន្មានបានតាមចោមរោមធម្មទ្ធជបណ្ឌិតនោះហើយ
ក៏ទ្រង់ជឿសូងស្មោះអស់ពីព្រះទ័យដោយទ្រង់សំគាល់ថាជាបរិសទ្យទាំង
នោះជាចំណុះចុះចូលរបស់ធម្មទ្ធជបណ្ឌិតពិតមែន, ទើបទ្រង់ត្រាស់ស្ងរ
ទៅកាឡកសេនាបតីថា អើ! មែនហើយសេនាបតី បើយ៉ាងនេះតើយើង
នឹងធ្វើដូចម្តេចទៅហ៉ ។

សេនាបតី – សូមទ្រង់ព្រះមេត្តាប្រោស យើងត្រូវតែសម្ងាប់គាត់
ចោលទៅទើបគួរ ។

ព្រះរាជា – ចុះយើងនឹងសម្ចាប់ដូចម្តេចបាន បើគាត់ពុំមានទោស ធ្ងន់ជាទុទ្ធារិកអធិកអធម្មសមគ្ឆរនឹងសម្ចាប់សោះ ។

សេនាបតី – សូមទ្រង់ព្រះមេត្តាប្រោស, ឆាយទេ, មានទបាយ កលមួយ គឺយើងនឹងលើកយកអសយ្ហកម្ម (ការឆាវដែលគេមិនអាចធ្វើ កើត) បង្គាប់ឲ្យគាត់ធ្វើ កាលបើធ្វើមិនកើតឲ្យយើងទេ យើងនឹងបាន សម្ចាប់គាត់ព្រោះទោសនោះ ។

ព្រះរាជា – អើ! សេនាបតី ចុះយើងនឹងឲ្យគាត់ធ្វើអសយ្ហកម្មដូច ម្តេចទៅ? ។

សេនាបតី – បពិត្រព្រះមហារាជ ធម្មតាច្ឆារទុទ្យានដែលគេដាំ ក្នុងទីសារភូមិ លុះតែបានថ្ងៃរក្សាដោយល្អអស់បីបួនឆ្នាំ ទើបមានផ្ទែផ្កា បាន សូមព្រះអង្គត្រាស់ឲ្យហៅធម្មទ្ធជបណ្ឌិតនោះមកហើយទ្រង់មាន ព្រះបន្ទូលថា នែអ្នកបណ្ឌិត យើងឆ្ចាប់បានទៅក្រសាលលេងក្នុងទុទ្យាន ចាស់មកជាយូរហើយ ឥឡូវនេះយើងត្រូវការនឹងក្រសាលលេងក្នុង ទុទ្យានថ្មីវិញ រៀលាថ្ងៃស្អែកនេះហើយ យើងនឹងទៅក្រសាលទុទ្យាននោះ បើដូច្នេះ ចូរអ្នកទៅតាក់តែងកសាងធ្វើទុទ្យាននោះឲ្យយើងជាឆាប់ឲ្យទាន់ ក្នុងរៀលាថ្ងៃស្អែកនេះ, កាលបើព្រះអង្គទ្រង់បង្គាប់ឲ្យធ្វើយ៉ាងនេះហើយ គាត់មុខជាធ្វើពុំកើតឲ្យទាន់កាលបានឡើយ ម្ចា៉ះហើយយើងនឹងសម្ចាប់ គាត់ ព្រោះទោសនោះបានដោយស្រួល ។

ព្រះរាជាក៏ត្រាស់ឲ្យហៅព្រះពោធិសត្ចមកហើយ ទ្រង់មានព្រះរាជ-ឧស្ការបង្គាប់ថា នែអ្នកបណ្ឌិត យើងឆ្ចាប់ទៅក្រសាលលេងក្នុងទុទ្យាន

ចាស់មកជាយូរណាស់ហើយ ឥឡូវនេះយើងត្រូវការនឹងក្រសាលលេង
ក្នុងឧទ្យានថ្មីវិញ ថ្ងៃស្អែកនេះហើយយើងនឹងទៅក្រសាលឧទ្យាននោះ
ចូរអ្នកទៅតាក់តែងកសាងធ្វើឧទ្យាននោះឲ្យយើងជាធាប់ ឲ្យទាន់ក្នុងវេលា
ថ្ងៃស្អែកនេះ បើអ្នកធ្វើពុំកើតទាន់កាលវេលាទេ យើងនឹងយកទោស
អ្នកដល់ជីវិត ។

ព្រះពោធិសត្វយល់ច្បាស់ថា "ការណ៍នេះប្រាកដជាកាឡកសេនា-
បតីដែលពុំបានសំណូកឈ្នានីសដល់អញ ហើយក្រាបទូលញុះញង់ព្រះ
រាជាឲ្យសម្ចាប់អញដោយពិត" ទើបក្រាបបង្គំទូលស្នងថា "សូមទ្រង់
ព្រះមេត្តាប្រោសព្រះមហារាជ បើទូលព្រះបង្គំអាចនឹងធ្វើបាន, ថ្ងៃស្អែក
នេះគង់នឹងបានដឹងការណ៍" លុះក្រាបបង្គំទូលដូច្នេះរួចហើយ ក៏ក្រាប
បង្គំលាព្រះរាជាទៅផ្ទះបរិកោគកោជនដ៏បរិសុទ្ធ ហើយចូលទៅដេកលើ
ដំណេករំពឹងគិតរកឧបាយនឹងធ្វើឧទ្យាន ។

ខណៈនោះឯងក្តៅទៅដល់ព្រះឥន្ទ្រ ៗ ពិចារណាដឹងវាវចិត្តនៃព្រះ
ពោធិសត្វហើយក៏រវាសរវៃចុះមក ចូលទៅកាន់ស្វែងសិរី ស្ថិតនៅឯអា-
កាស ហើយសួរទៅព្រះពោធិសត្វថា នែអ្នកជាបណ្ឌិត ចុះអ្នកគិតពីរឿង
អ្វីហ្នឹង? ។

ពោធិសត្វ – ចុះអ្នកជាអ្វីមកសួរខ្ញុំ? ។

ព្រះឥន្ទ្រ – ខ្ញុំជាព្រះឥន្ទ្រ ណ៉ាអ្នក ។

ព្រះពោធិសត្វដឹងថាជាព្រះឥន្ទ្រហើយ ក៏ធ្វើយប្រាប់ជាប្រញាប់
ទៅវិញថា ព្រះរាជាប្រើខ្ញុំឲ្យទៅតាក់តែងកសាងធ្វើឧទ្យានថ្មីថ្ងាយឲ្យទាន់

ទឹងយាងទៅក្រសាលកន្លែងថ្ងៃស្អែកនេះ ខ្ញុំពុំដឹងធ្វើដូចម្តេចទឹងធ្វើឧទ្យាន
នោះឲ្យកើតភាន់ភាន ប្រាជាខ្ញុំពិតគិតកន្ទក់ការនេះ ។

ព្រះឥន្ទ្រ – នែអ្នកបណ្ឌិត អ្នកកុំព្រួយបារម្ភអ្វីឡើយ ចាំយើងទឹង
និម្មិតឧទ្យានថ្មីប្រហែលដូចជាព្រៃនន្ទនវនទឹងបិតុលតាវនឲ្យអ្នកបាន ចុះ
អ្នកត្រូវការឲ្យយើងនិម្មិតធ្វើកន្លែងណា ? ។ ព្រះពោធិសត្វប្រាប់ទីកន្លែង
ឲ្យព្រះឥន្ទ្រនិម្មិតធ្វើឧទ្យាន, ព្រះឥន្ទ្រនិម្មិតបានស្រេចហើយក៏ត្រឡប់
ទៅកាន់ទេវនគរវិញ ។ លុះព្រឹកឡើងព្រះពោធិសត្វបានឃើញឧទ្យាន
ដាក់ប្លាស់ហើយក៏ម៉ឺម៉ាទៅក្រាបបង្គំទូលព្រះពាជាថា សូមទ្រង់ព្រះ
មេត្តាប្រោសមហាពាជ ឧទ្យានទូលព្រះបង្គំបានធ្វើថ្វាយព្រះអង្គរួចជា
ស្រេចហើយ សូមព្រះករុណាម្ចាស់ជីវិតទ្រង់យាងទៅក្រសាលចុះ ។
ព្រះពាជាបានជ្រាបហើយទ្រង់តំយាងទៅជាមួយនឹងសេនាបតី បានឃើញ
ឧទ្យាននោះសឹងតែប្រដាប់ដោយព្រឹក្សាលតាជាតិគ្រប់ពណ៌ ជំរៅជាស
ដោយផ្កាផ្លែព័ន្ធព័ទ្ធដោយកំពែងមានពណ៌ដូចជាថ្មនោសិលាកំពស់ ១៨
ហត្ថ មានទ្វារនឹងប៉ម៉ាមនៅគ្រប់ទិស ព្រះពាជាឃើញហើយទ្រង់ត្រាស់សួរ
កាឡកសេនាបតីថា ធម្មទ្ធជបណ្ឌិតបានធ្វើឧទ្យានសម្រេចតាមយើងបង្គាប់
ហើយ ឥឡូវនេះ តើយើងនឹងធ្វើដូចម្តេចទៀត ? ។

សេនាបតី – សូមទ្រង់ព្រះមេត្តាប្រោស មហាពាជ ដើតាត់អាចធ្វើ
ឧទ្យានតែមួយយប់ប៉ុណ្ណោះក៏ភានហើយ នឹងមិនអាចយកពាជសម្បត្តិ
ឯណាបាន យើងត្រូវតែបង្គាប់ឲ្យតាត់ធ្វើអស្ចារ្យកម្មតទៀត ។

ព្រះពាជា – ចុះយើងឲ្យធ្វើដូចម្តេចទៀត ? ។

សេនាបតី – សូមព្រះអង្គទ្រង់បង្គាប់ឲ្យគាត់ដីកធ្វើជាស្រែបោក្ខរ-ណី សឹងដំហើយដោយកែវ ๗ ពណ៌តទៅទៀតចុះ ។

ព្រះពជាទ្រង់ទទួលព្រមតាមហើយ ក៏ត្រាស់ហៅព្រះពោធិសត្វមក មានព្រះពជនុដ្ឋាវថា នែអ្នកអាចារ្យ អ្នកបានធ្វើទុក្ខានឲ្យយើងរួចហើយ ត្រូវតែអ្នកធ្វើស្រែបោក្ខរណីជាកែវនៃកែវ ๗ ពណ៌ ឲ្យសមគួរដល់ទុក្ខានទុំនតទៅទៀត បើអ្នកពុំអាចនឹងធ្វើបានទេ យើងនឹងយកពោសអ្នកដល់ជីវិត ។

ព្រះពោធិសត្វ – សូមទ្រង់ព្រះមេត្តាប្រោស បើទូលព្រះបង្គំអាចធ្វើបាន នឹងធ្វើថ្វាយព្រះមហាពជតាមសព្វព្រះពជប្បទ័យ ។

វេលានោះ ព្រះឥន្ទ្រមកនិម្មិតស្រែបោក្ខរណីមានលំអដ៏លើសលុបមានកំពង់សំពប់ចុះទៅ ๑๐๐ មានជ្រុង ๑๐๐๐ សឹងដំរេរាសដោយផ្កាឈូក ๕ ពណ៌ ហាក់ដូចជាស្រែនន្ទនបោក្ខរណី ។ លុះព្រឹកឡើងព្រះពោធិសត្វបានឃើញស្រែបោក្ខរណីនោះជាក់ច្បាស់ហើយ ក៏ចូលទៅក្រាបទូលព្រះពជាថា សូមទ្រង់ព្រះមេត្តាប្រោស ស្រែបោក្ខរណីទូលព្រះបង្គំបានធ្វើថ្វាយព្រះអង្គរួចស្រេចហើយ ។

ព្រះពជាបានឃើញហើយ ទ្រង់ត្រាស់សួរទៅកាឡកសេនាបតីទៀតថា នែសេនាបតី ចុះយើងនឹងធ្វើដូចម្តេចទៀត? ។

សេនាបតី – សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គទ្រង់ប្រើអ្នកឲ្យធ្វើផ្ទះដំណាក់ឲ្យសមគួរដល់ទុក្ខានោះតទៅទៀត ។

ព្រះពជាទ្រង់ត្រាស់បង្គាប់ព្រះពោធិសត្វថា នែអ្នកអាចារ្យ ឥឡូវ

នេះត្រូវអ្នកធ្វើផ្ទះដំណាក់មួយ អំពីក្ដុកចាំងអស់ ឲ្យបានសមរម្យដល់ខ្លួន ទើបស្រេចក្នុងវណ្ណនេះតទៅទៀត បើអ្នកធ្វើពុំកើតឲ្យយើងខ្ញុំ យើងនឹងយកទោសអ្នកដល់ជីវិត ។

លោះនោះ ព្រះឥន្ទ្រមកនិម្មិតផ្ទះឲ្យព្រះពោធិសត្វទៀត ។ ព្រះពោធិសត្វបានឃើញផ្ទះនោះច្បាស់ជាក់ជហើយ ក៏ម្ចាស់ទៅក្រាបទូលព្រះរាជា។ បានឃើញហើយទ្រង់ត្រាស់សួរទៅកាឡកសេនាបតីថា ឥឡូវនេះយើងនឹងធ្វើដូចម្តេចទៀត សេនាបតី?

សេនាបតី – សូមព្រះមហាក្សត្រាស់ប្រើគាត់ឲ្យធ្វើកែវមណីឲ្យសមគួរដល់ផ្ទះនោះទៀតចុះ ។

ព្រះរាជាត្រាស់ហៅព្រះពោធិសត្វមកហើយទ្រង់បង្គាប់ថា នែអ្នកបណ្ឌិត ចូរអ្នកនិម្មិតធ្វើកែវមណី ឲ្យសមគួរដល់ផ្ទះដែលធ្វើអំពីក្ដុកនេះឲ្យយើងទៀត យើងនឹងបានដើរទៅក្រសាលទ្រានម្តង។ ក្នុងវេលាយប់ដោយសារពន្លឺកែវមណីនោះ បើអ្នកនិម្មិតធ្វើពុំកើតទេ យើងនឹងយកទោសអ្នកដល់ជីវិត ។

លោះនោះ ព្រះឥន្ទ្រមកនិម្មិតកែវមណីឲ្យព្រះពោធិសត្វទៀត ។ ព្រះពោធិសត្វបានឃើញច្បាស់ជាក់ជហើយ ក៏ម្ចាស់ទៅក្រាបទូលព្រះរាជា។ បានទតទៅឃើញហើយ ទ្រង់ត្រាស់សួរទៅកាឡកសេនាបតីថា នែសេនាបតី ចុះយើងនឹងធ្វើដូចម្តេចទៀត? ។

សេនាបតី – សូមទ្រង់ព្រះមេត្តាប្រោស ជម្ងឺជព្រាហ្មណ៍ខ្ញុំនេះជាមានទេវតាធ្វើឲ្យសម្រេចតាមសេចក្ដីប្រាថ្នារបស់គាត់ បើដូច្នេះ សូម

ព្រះអង្គប្រើគាត់ឲ្យនិម្មិតធ្វើនូវរបស់ណាដែលទៅតាមនិងនិម្មិតបាន ធម្មតាទៅតាមនុ៎ះជាមិនអាចនិម្មិតមនុស្ស ដែលប្រកបដោយអង្គ ៤ បានទេ ព្រោះហេតុនោះ សូមព្រះអង្គត្រាស់ប្រើគាត់ឲ្យនិម្មិតធ្វើនូវយានបាល (អ្នករក្សានូវយាន) ដែលប្រកបដោយអង្គ ៤ នោះតទៅទៀតចុះ ។

ព្រះពជាត្រាស់ហៅព្រះពោធិសត្វមកហើយ ទ្រង់មានព្រះពជនឱ្យវាចង្អាប់ថា នែអ្នកអាចារ្យ អ្នកបានធ្វើនូវយាន ស្រះបាក្តីណា ប្រាសាទធ្វើអំពីកូនទឹកកែវមណីជាពន្ធឹដល់នូវយានជាដើម នោះសឹងតែបានគ្រប់សព្វហើយ ឥឡូវនេះ ចូរអ្នកនិម្មិតធ្វើនូវយានបាលម្នាក់ដែលប្រកបដោយអង្គ ៤ ឲ្យរក្សានូវយានឲ្យយើងតទៅទៀត បើអ្នកនិម្មិតធ្វើពុំកើតទេ យើងនឹងយកទោសអ្នកដល់ដីវិត - ។

ព្រះពោធិសត្វក្រាបទូលថា "សូមទ្រង់ព្រះមេត្តាប្រោស បើទូលព្រះបង្គំរកបានថ្ងៃស្អែកនេះគង់នឹងបានជ្រាប" រួចហើយក្រាបថ្វាយបង្គំលាទៅផ្ទះបរិភោគភោជនាហារដ៏បរិសុទ្ធហើយក៏ចូលទៅកន្លែងដំណេកដេកលក់ទៅ លុះដល់វេលាព្រឹកព្រាងបច្ចូសសម័យក្រាក់ឡើងអង្គុយលើទីដំណេកគិតពិចារណាថា "ព្រះឥន្ទ្រជាស្តេចទៅតាសឹងតែបាននិម្មិតរបស់ដែលអាចនឹងនិម្មិតបានសព្វគ្រប់ហើយ ប៉ុន្តែទៅពុំអាចនឹងនិម្មិតនូវយានបាលដែលប្រកបដោយអង្គ ៤ បានឡើយ បើយ៉ាងនេះហើយអញនឹងទៅស្វាប់តែម្នាក់ឯងឥតទីពឹងក្នុងលៃព្រៃប្រសើរ ជាងសេចក្តីស្លាប់ក្នុងកណ្តាប់ដៃអ្នកដទៃ" ព្រះពោធិសត្វគិតដូច្នេះហើយពុំមានប្រាប់អ្នកឯណាមួយឲ្យ

ដឹងខ្លឹយ ចុះអំពីប្រាសាទហើយក៏ចេញទៅតាមទ្វារធំដើរចូលទៅកន្លែងអង្គុយរំពឹងពិចារណាធម៌របស់សប្បុរសតាមដើមឈើមួយ ។

ព្រះឥន្ទ្រជានដឹងហេតុនោះហើយក៏ក្លែងកេរជាថ្មើរម្នាក់ដើរចូលទៅរកព្រះពោធិសត្វហើយសួរថា "នែព្រាហ្មណ៍ អ្នកជាមនុស្សសុខុមាលជាតិធ្លាប់តែនៅជាសុខ តុំដែលឃើញទុក្ខលំបាកក្នុងកាលណាម្ល៉ងខ្លឹយ ឥឡូវនេះ អ្នកចូលមកអង្គុយនៅកន្លែងព្រៃធ្វើអ្វីហ្នឹង?" រួចហើយទើបសួរដោយព្រះគាថាតទៅទៀតថា:

សុខំ ជីវិតរូបោសិ រដ្ឋេ រិនមាគតោ
សោ ឯកកោ (អរញ្ញស្មឹ) រុក្ខមូលេ កបណោ វិយ ឈាយសីតិ ។

(នែព្រាហ្មណ៍) អ្នកធ្លាប់តែនៅជាសុខ ចេញចាលដែន (ដែលមានមនុស្សកុះករ) មកនៅកន្លែងព្រៃស្ងាត់តែម្នាក់ឯងដូចជាមនុស្សកំព្រាអង្គុយជញ្ជឹងរំពឹងគិតនៅទៀបគល់ឈើ កន្លែងព្រៃ តើអ្នកគិតដូចម្តេចហ្នឹង? ។

ព្រះពោធិសត្វឆ្លើយថា

សុខំ ជីវិតរូបោស្មិ រដ្ឋេ រិនមាគតោ
សោ ឯកកោ (អរញ្ញស្មឹ) រុក្ខមូលេ កបណោ វិយ ឈាយាមិ
សតំ ធម្មំ អនុស្សរន្តិ ។

ខ្ញុំធ្លាប់នៅជាសុខមែន ធ្លាប់ចេញចាលដែន (ដែលមានមនុស្សកុះករ) មកនៅកន្លែងព្រៃស្ងាត់តែម្នាក់ឯង ដូចជាមនុស្ស

កំព្រា អង្គុយជញ្ជឹងរំពឹងគិតទៀបតល់ឈើក្នុងព្រៃ ខ្ញុំនឹក
រំពឹងដល់ធម្មិរបស់សប្ប្យុរស(1) ។

ព្រះឥន្ទ្ធ - នែព្រាហ្មណ៍ បើគ្រាន់តែហេតុប៉ុណ្ណឹងសោះ ម្តេចក៏
អ្នកចាំបាច់មកអង្គុយគិតក្នុងទីនេះធ្វើអ្វី? ។

ពោធិសត្ត - ព្រះរាជាប្រើខ្ញុំឲ្យរកទយ្យានបាលដែលប្រកបដោយ
អង្គ ៤ ខ្ញុំពុំអាចនឹងរកមនុស្សដែលប្រកបដោយអង្គ ៤ នោះបាន បានជា
ខ្ញុំគិតថា ប្រយោជន៍អ្វីអញនឹងស្ថាប់ក្នុងកណ្ណាប់ដៃអ្នកដទៃ អញនឹង
ចូលទៅនៅក្នុងព្រៃស្ថាប់តែម្នាក់ឯងវិញប្រសើរជាង ខ្ញុំគិតដូច្នេះ បានជាខ្ញុំ
មកអង្គុយក្នុងទីនេះឯង ។

ព្រះឥន្ទ្ធ - នែព្រាហ្មណ៍ ខ្ញុំជាព្រះឥន្ទ្ធ ជាស្តេចនៃទេវតា ខ្ញុំបាន
និម្មិតទទ្យានជាដើមឲ្យអ្នករូបស្រេចហើយ ខ្ញុំពុំអាចនឹងនិម្មិតទយ្យានបាល
ដែលប្រកបដោយអង្គ ៤ បានទេ ប៉ុន្តែខ្មាន់ប្រកេសឈ្មោះធត្តបាណីអ្នក
ស្អិតស្អាងព្រះកេសានៃព្រះរាជារបស់អ្នកនោះ គាត់ប្រកបដោយអង្គ ៤
កាលបើអ្នកត្រូវការដោយទយ្យានបាល ចូរអ្នកទៅនិយាយនឹងខ្មាន់ប្រ-
កេសនោះឲ្យគាត់ធ្វើទយ្យានបាលចុះ មុខជានឹងបានពុំខាន ។ ព្រះឥន្ទ្ធ
ឲ្យឧវាទដល់ព្រះពោធិសត្ត លួងលោមកុំឲ្យខ្ជាចរូបហើយសក្តទេវរាជក៏
ត្រឡប់ទៅកាន់ទេវបុរីវិញ ។

(មានត)

---

1 លោកធម្មិ ៨ យ៉ាងគឺ លាភ, ពុំមានលាភ, យស, ពុំមានយស, និន្ទា, សរសើរ, សុខ, ទុក្ខ ហៅថាធម្មិរបស់សប្ប្យុរស, សប្ប្យុរសនោះបានដល់ព្រះពុទ្ធ បច្ចេកពុទ្ធ និងពុទ្ធ សាវក ដែលជាបណ្ឌិត ព្រោះសប្ប្យុរសទាំងនោះទុកជាលោកធម្មិទាំង ៨ នេះគ្របសង្កត់ក៏មិន កម្រើកញាប់ញ័ទ្បើយ (អដ្ឋកថា) ។

ប ញ្ញា ស ជាតក

ភាគទី ៤

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាចាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្ជនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

ក ន ក វ ណ្ណ ភ ជ ជាតក ទី ១៦

លោកអាចារ្យ នង - សមិទ្ធ វត្តលង្កា

ប្រែពីចាលី

ភ្ជ ត ប ុ ព្ជ ភិ ក្ខ ដ ក ន ក ប ិ ត្តេ នាម ន គ ដ ក ន ក វ ណ្ណោ
នាម រាជា ក ន ក ទេ រិ យាយ ស ទ្ធឹ ត ស្មឹ រ ជ្ជ ក ាដ ស ិ ។

ម្នាលភិក្ខុទាំងឡាយ, មានរឿងរ៉ាវពីព្រេងមកថា ក្នុងនគរកនកចិត្ត មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាម កនកវណ្ណ សោយរាជសម្បត្តិក្នុងនគរនោះ ជាមួយនឹងព្រះរាជទេពី ព្រះនាម កនកា ជាឯកអគ្គមហេសី បានជាមហិស្សរាធិបតីក្នុងផ្ទៃជម្ពូទ្វីបទាំងមូល ។ ទ្រង់មានបុរោហិតម្នាក់ចេះចប់សព្វសិល្បសាស្ត្រ ។ ថ្ងៃមួយ ក៏ទ្រង់មានព្រះរាជតម្រាស់ត្រាស់ហៅបុរោហិតនោះមកស្តរថា លោកអាចារ្យ, ក្នុងឆ្នាំនេះ តើមាននក្ខត្តបុក្សជាសុខប្ដជាទុក្ខ ប្ដក៏តើតកលិយុគពុំជួរកាលម្រៃបណា ? បុរោហិតបានស្តាប់ព្រះរាជឧង្ការ ក៏ក្រាបបង្គំទូលថា បពិត្រព្រះរាជសម្ការ, ក្នុងឆ្នាំនេះបានសេចក្តីចំរើនប្រើនល្អណាស់, ប៉ុន្តែដល់កន្ធង ១០ ឆ្នាំពីឆ្នាំនេះ

ទៅត្រូវពាំងក្រៀងអស់ចំនួន ១២ ឆ្នាំ សូម្បីតែទឹកមួយដំណក់ក៏គ្មានស្រក់មកជាប្រាកដ ។ ព្រះពាជាខ្ញុំសុតកង្ខ ព្រះពាជប្អូនឈ្មោះតិតក័យតក្កមាដូចជាគេជាញ់ដោយសរដែលលាបថ្នាំពិស មានព្រះពាជប្អូនឈ្មោះខ្ញុំទុក្ខទោមនប្ស ទ្រង់ព្រះចិន្តាថា "ពួកមហាជនទាំងនេះវិនាសអស់ហើយតើ! ជម្ងឺប្អូបសួទ្យហើយតើ! បើម្ដេចតើអាត្មាអញនឹងគិតធ្វើដូចម្ដេច?" លំដាប់នោះព្រះកូនរ ទ្រង់ឲ្យហៅពួកអាមាត្យទាំងឡាយមកប្រាប់ថា អ្នកពាល់គ្នាបូរម្ដីមាទៅយោសនាប្រាប់ពួកក្រស្ដេចជាកូនសកលជម្ងឺប្អូបថា អស់ពួកអាណាប្រជានុកស្ដេចាំងឡាយ ចូរអ្នកទំនុលខ្វាយក្លែរកស់សួងស្រែវាំងស្រែប្ញាងស្រែវស្យា ទាំងទីធំនាបទីទួល កុំឲ្យមានសល់បន្ទោះស្រែណាមួយឡើយ ។ កាលបើអាមាត្យទាំងឡាយយោសនាប្រាប់សព្វគ្រប់ដូច្នោះហើយ ឥតីនោះមកព្រះពាជាខ្ញុំគ្រាស់បង្គាប់ម្ដងទៀតថា អស់ពួកអាមាត្យទាំងឡាយ ចូរដើរទៅសព្វស្រុកតូចធំទិគមជនបទ កំណត់មើលចំនួនស្រែរបស់មនុស្សក្នុងស្រុកនោះៗ គ្រប់គ្នា ឲ្យដឹងថាស្រុកណាមានស្រែចំនួនប៉ុន្មាន ។ អាមាត្យទាំងនោះ ក៏ទំពេញទៅពិនិត្យ បានដឹងចំនួនស្រែហើយទើបត្រឡប់មកកាន់នគរ ក្រាបបង្គំទូលព្រះកូនរជាម្ចាស់ផែនដីវិញ ។ លុះឆ្នាំទី ១០ កន្លងទៅហើយ ក៏ពាំងក្រៀង សូម្បីតែ ១ ដំណក់ក៏គ្មានសោះ ។ ពួកមនុស្សក្នុងនគរទាំងអស់ ក៏កើតទុក្ខព្រួយខ្លោចផ្សា មនុស្សណាដែលមានសេចក្ដីស្រែកឃ្លានខ្លាំង ក៏ស្លាប់ស្គមច្រើនស្ងាប់ទៅក៏មានជាច្រើន; មនុស្សខ្លះក៏បង្គាជាពួក ១០០ នាក់ ក៏មាន ១,០០០ នាក់ក៏មាន ១០,០០០ នាក់ក៏មាន បបួលគ្នាធ្វើចោរកម្ម

ល្ងចប្ចន់ចាក់កាប់សម្ចាប់ត្នាដេរជាស, ក្នុងជម្ពូទ្វីប ធុំក្លិនអសោច៏ស្អុយ
សុទ្ធតែខ្មោច ដូចជាត្រៃស្មៈសានហានស្ងាត់ ។ លំដាប់នោះ ព្រះ
មហាក្សត្រទ្រង់ត្រាស់ចំពោះអាមាត្យទាំងឡាយថា ម្នាលអ្នកទាំងឡាយ
ក្នុងជម្ពូទ្វីបនេះ មានពួកផ្ទៃស្រុកផ្ទៃត្រាត្នាតក្អែក ខាំហែកសាកអសុក
ស៊ីជាអាហារ ឥឡូវនេះ បើយើងនាំនាងកុលធីតាទាំងឡាយទៅកាន់
ត្រៃ មិនយូរប៉ុន្មានទេ មុខជានឹងស្ងាប់ដូច្នោះមិនលែង ។ តពីនោះមក
សម្តេចព្រះបរមរាជាកនកវណ្ណ ទ្រង់តង់ក្នុងផ្ទៃប្រាសាទ ត្រាស់ហៅ
ពួកអាមាត្យមកប្រាប់ថា បើអ្នកទាំងឡាយចង់ទៅនៅទីណា ។ ចូរនាំបុត្រ
ភរិយាទៅតាមប្រាថ្នាចុះ ។ ពួកអាមាត្យទាំងនោះ ក៏ទូលតបព្រះរាជា
វិញថា បពិត្រព្រះរាជសម្ភារ, យើងខ្ញុំទាំងអស់ត្នា ពុំព្រមទៅណា
ចោលព្រះអង្គទេ, ស៊ូតែស្ងាប់ក្រោមព្រះបាទព្រះអង្គហើយ ។ លំដាប់
នោះព្រះរាជា ទ្រង់ព្រះរាជទានស្រូវអង្ករដល់ពួកមហាជននឹងពួកអាមាត្យ
រាល់ៗថ្ងៃ ដរាបតែស្រូវនោះនៅសល់បន្តិចបន្ពួច ទ្រង់ក៏បន្ទយ បែរជា
ព្រះរាជទានត្រឹមតែភោជនដល់កូនអ្នកនគរនឹងកូនអាមាត្យអស់ ៤ ខែទ្រៃត ។
ដល់ពេលក្រោយ ទ្រង់ទុកត្រាន់តែសោយជាមួយនឹងព្រះរាជបុត្រព្រះ
រាជទេពី បានត្រឹមមួយខែ ទ្រង់សំចៃទុកត្រាន់តែព្រះរាជបុត្រ ១ ព្រះអង្គ
ប៉ុណ្ណោះ ។

ខណៈដែលព្រះរាជានៅសល់អង្ករតែមួយនាឡិ ព្រះរាជទេពីបាន
ចំអិនទុកពុំទាន់បានសោយ ដូនជាមានព្រះបច្ចេកពុទ្ធ ១ អង្គតង់លើក្នំគន្ធ-
មាទន៍ មានអានុភាពធំ ដល់ត្រើយនៃប្រាជ្ញាញាណ បានប្រមើលមើល

នូវសត្វលោកដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្ធដផុតចក្ខុមនុស្សធម្មតាបានជ្រាប
ថា ពួកសត្វលោកនេះប្រមាទហើយតើហ្ន៉ ? សត្វលោកនេះប្រាកដជា
មិនដែលឲ្យទាន រក្សាសីល ចំរើនមេត្តាការនាសោះ, មិនដែលបូជា
ចំពោះព្រះពុទ្ធព្រះធមិព្រះសង្ឆទ្បើយ, មិនដែលចិញ្ចឹមមាតាបិតា គោរព
កោតក្រែងដល់ចាស់ព្រឹទ្ធាចារ្យ មិត្រសំឡាញ់ទ្បើយ, ពួកសត្វលោកនេះ
ពេញជាប្រមាទមែន, បើតែម្ទេះ។មុខជាកេតាព្យាធិកំយចរៃ គ្រីតជា
ច្រើនទ្បើងទៀតមិនខាន; ទើបព្រះបច្ចេកពុទ្ធនោះរំពឹងគិតតទៅទៀតថា
ម្នកណាហ្ន៉ ! ដែលអាត្មាអញគួរចេញទៅសង្ត្រោះបាន? ឃើញមានតែ
ព្រះបាទកនកវណ្ណរាជដែលជាពុទ្ធង្ក្ទរបណ្ណូលពុទ្ធវង្ស ទ្រង់នឹងបានត្រាស់
ជាព្រះពុទ្ធមួយអង្គក្នុងអនាគតកាល, បើដូច្នោះ គួរតែអាត្មាអញទៅ
សង្ត្រោះដល់ព្រះរាជានោះចុះ ។ ទើបព្រះបច្ចេកពុទ្ធនោះហោះទ្បើងលើ
អាកាសវេហាស៍, ព្រះរាជានៅក្នុងទីណា, ក៏ធ្ពោះព្រះកក្ត្រាសំដៅទៅទី
នោះ ។ អាមាត្យទាំងឡាយបានឃើញព្រះបច្ចេកពុទ្ធ ហោះធ្ពោះទៅត្រង់
ដូច្នោះ ក៏ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជសម្ភារ, ន៉ុះហ្ន៉ ប្រហែល
ជាយក្ស ហោះមកទំពាស៊ីយើងទាំងឡាយហើយដឹង? ព្រះរាជាទ្រង់ទត
ឃើញព្រះបច្ចេកពុទ្ធ ក៏ត្រាស់ព្រះរាជឧង្ការថា ម្នាលអ្នកទាំងឡាយ, មិន
មែនយក្សទេ, ព្រះបច្ចេកពុទ្ធទេតើ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធចុះចាក
អាកាស មកគង់ក្នុងទីចំពោះព្រះកក្ត្រព្រះរាជានោះ ។ ព្រះមហាក្សត្រ
បានឃើញព្រះបច្ចេកពុទ្ធ មានបាត្រទទេដូច្នោះ ទើបទ្រង់ព្រះចិន្តាថា
"លោកម្ចាស់អង្គនេះប្រាកដជាត្រូវការចង្ហាន់បិណ្ឌបាត, ចុះបើអាត្មា

អញឆ្លាក់ខ្លួនទៅជាមនុស្សកំសត់ទុគ្គិតដល់ម្ដេះ នឹងប្រគេនទានដូចម្ដេចបាន" ហើយគ្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានប្រើនតែប្រាក់មាសកែវមុក្តានឹងសំពត់ប៉ុណ្ណោះទេ, ចំណែកខាងអង្ក្រ សូម្បីតែមួយនាឡិក៏គ្មានដែរ ។ ព្រះបច្ចេកពុទ្ធក៏គង់នៅស្ងៀម ។ ព្រះរាជាលុះឃើញព្រះបច្ចេកពុទ្ធស្ងៀមដូច្នោះ ក៏ទ្រង់ត្រាស់យ៉ាងនេះថា "បពិត្រ៍ព្រះអង្គដ៏ចំរើន, ទក្ខិណេយ្យបុគ្គល រកបានដោយកម្រណាស់" ទើបទ្រង់ត្រាស់ហៅពួកមហាជនមកស្តរថា អ្នករាល់គ្នាមានបាយខ្ទះដែរឬ? ។ ព្រះនាងកនការាជទេពីទ្រង់មានព្រះរាជសវនីយ៍ទូលថា បពិត្រ៍ព្រះកស្តា, ខ្ញុំម្ចាស់បានចំអិនបាយចំនួនអង្ក្រមួយនាឡិដែរ ទុកបំរុងតែព្រះរាជកុមារ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនាងទេវីដូច្នោះហើយ ក៏ទ្រង់យកព្រះស្វាយចំណែកព្រះអង្គមក ទ្រង់ព្រះចិន្តាថា "បើប្រសិនណាជាអញបរិភោគអាហារទៅ ក៏មិនរស់នៅយូរប៉ុន្មានដែរ, ដូច្នោះគួរតែអាត្មាអញឲ្យទាន ព្រោះការឲ្យទានព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់សរសើរជាទីបំផុត" ហើយត្រាស់ជាបទព្រះគាថាថា

រិជ្ជុលតា យថា កាយោ តថា ភោគ្គោ អសារកោ
អសារកស្ស ភោគស្ស សារមាទាយ បណ្ឌិតោ ។

ម្នាលអ្នកទាំងឡាយអើយ, រូបកាយយើងនេះឥតខ្លឹមសារទេ, ក្លឹមក្លែតដូចជាផ្ទេកបន្ទោរដូច្នោះឯង, អ្នកមានប្រាជ្ញាត្រូវកាន់យកប្រយោជន៍ដែលមានខ្លឹមសារ អំពីភោគសម្បីទដែលជារបស់ឥតខ្លឹមសារនោះ ។

លុះទ្រង់ត្រាស់ដូច្នេះហើយ ទើបព្រះរាជាទ្រង់កាន់ឃកកាជន៍មាសដែលជាក់ពេញដោយបាយ ទ្រង់មានព្រះរាជហ្ហុទ័យព្រះសរីរាវយវៈផ្សព្វផ្សាយដោយបីតិ ចូលទៅកាន់សំណាក់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំទៀបព្រះបាទាទ្រង់ត្រាស់យ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចំរើន, សូមព្រះអង្គសង្គ្រោះដល់ខ្ញុំព្រះអង្គផងចុះ ចង្ហាន់បិណ្ឌបាតនេះ ទោះតិចក្តី ច្រើនក្តី ថោកទាបក្តី ថ្ងៃថ្ងាក្តី ដែលខ្ញុំព្រះអង្គប្រគេនដោយសទ្ធាជាសោមនស្ស សូមព្រះអង្គទទួលយកទាំងអស់ កុំទើសទាល់" ហើយទ្រង់ត្រាស់ជាបទព្រះគាថាថា

ឥមិនា ភត្តទានេន ន មយ្ហញ្ច ឧបទ្ទវិ
តេន សព្វភវេ ហោតិ ពុទ្ធោ ហោមិ អនាគតេ
សំសារេ សំសរន្តោបិ មា មយ្ហំ វិកលត្តតា ។

ដោយចំណែកផលនៃកត្តទាននេះ សូមកុំឲ្យខ្ញុំមានឧបទ្រពចង្រៃអ្វីឡើយ, ដោយចំណែកផលនៃកត្តទាននេះ សូមឲ្យខ្ញុំបានសមប្រកបដោយសម្បត្តិគ្រប់ប្រការ ក្នុងកពទាំងពួង, ដោយចំណែកផលនៃកត្តទាននេះ សូមឲ្យខ្ញុំបានត្រាស់ជាព្រះពុទ្ធក្នុងកាលអនាគត, បើខ្ញុំនៅអន្ទោលទៅក្នុងសង្សារវដ្ត ក៏សូមកុំឲ្យខ្ញុំមានសេក្តីខ្វះខាតដូច្នេះទៀតឡើយ ។

ព្រះបច្ចេកពុទ្ធទទួលកត្តហើយ ក៏អនុមោទនាជាបទព្រះគាថាថា

ឥប្ជិតំ បដ្ឋិតំ តុយ្ហំ ទិប្បមេវ សមិជ្ឈតុ
សព្វេ ប្ចរេន្តុ សង្កប្បា បន្ទោ បណ្ណរសោ យថា ។

សេចក្តីប្រាថ្នា ដែលអ្នកប្រាថ្នាហើយយ៉ាងណា ក៏សូមឲ្យ
សម្រេចដល់អ្នកធាប់រួសរាន់ទាន់ចិត្ត សូមដម្រិះត្រូវទាំងឡាយទាំងពួង
ពេញដល់អ្នកដូចជាព្រះចន្ទរះច្បាស់ក្នុងថ្ងៃ ១៥ កើត ។

ព្រះបច្ចេកពុទ្ធអនុមោទនាដូច្នេះហើយ ទើបសំដែងសរសើរផល
បុណ្យតទៅទៀតថា បុណ្យមានតំណូចតូចប៉ុនត្រាប់ល្ង ដែលបុគ្គល
ធ្វើដោយចិត្តជាញាណសម្បយុត្ត រមែងសម្រេចផលប៉ុនភ្នំព្រះសុមេរុ,
ពុំនោះសោតទេ ដូចជាពូជដែជ្ជម្ពូជអ្វី ។ ដែលដុះលូតលាស់ចំរើនឡើង
ជានិច្ចដូច្នោះឯង, ទានដែលបុគ្គលឲ្យហើយចំពោះទក្ខិណេយ្យបុគ្គល
ទាំងឡាយ ពុំដែលមានសេចក្តីអន្តរាយឡើយ, ទានដែលបុគ្គលមាន
ចិត្តជ្រះថ្លាប្រកបដោយសទ្ធាឲ្យហើយ ទោះបីអាក្រក់ក្តី ល្អក្តី ក៏សប្បុរស
ទាំងឡាយតែងសរសើរ, លុះតែទានដែលបុគ្គលឲ្យដោយវ៉ៀរចាកសទ្ធា
ទើបជាទានមិនសូវមានផលច្រើន ។

ព្រះបច្ចេកពុទ្ធ សំដែងសរសើរផលដូច្នេះរួចហើយ ក៏ហោះតាម
អាកាសទៅភ្នំគន្ធមាទន៍វិញ ។ លោកធាន់ចង្ហាន់នោះរួចស្រេច ក៏
មហាមេយបង្អុរភ្លៀងធ្លាក់មកក្នុងគណៈនោះ ដោយអានិសង្សទានរបស់
ព្រះរាជានោះឯង ។ លំដាប់នោះ ពួកមហាជនឃើញមហាមេយបង្អុរ
មកដូច្នោះ ក៏ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជសម្ភារ, ឆ្លរអស្ចារ្យ
ណាស់ព្រះអង្គ! មហាមេយបង្អុរភ្លៀងផ្គរកើតប្រាកដក្នុងថ្ងៃនេះ ក៏
ប្រាកដជាដោយសារតេជះទានរបស់ព្រះអង្គនោះឯង ។ ព្រះរាជាទ្រង់
ព្រះសណ្ឋាប់ហើយ ទ្រង់ត្រាស់ថា មហាមេយបណ្ឋាលឡើងដោយ

សារតែអានុភាពព្រះបច្ចេកពុទ្ធទេតើ ។ អាមាត្យទាំងឡាយក៏ក្រាបបង្គំទទួលព្រះរាជឧត្តរថា ពិតមែនព្រះអង្គ, មហាមេឃបង្អុរក្ងៀងធ្លាក់ក្នុងជម្ពូទ្វីបនេះដោយសារអានុភាពព្រះបច្ចេកពុទ្ធហ្នឹងឯង ។

មុខគ្ឆរឲ្យអស្ចារ្យ មុនជំបូងមហាមេឃបង្អុរក្ងៀងជំរះវត្ថុមិនស្អាត បង្ហូទម្លាក់ទៅក្នុងមហាសមុទ្ទ, តពីនោះមកបង្អុរផ្ការទិព្ធ, តពីនោះបង្អុរធ្លាក់សុទ្ធតែបង្អែម, ពួកមនុស្សជណ្តើមគ្នាបរិភោគគ្រប់គ្នា, តពីនោះបង្អុរសុទ្ធតែអង្ករអស់ប្រាំពីរថ្ងៃ, បង្អុរស្រូវអស់ប្រាំពីរថ្ងៃ, បង្អុរសំពត់ស្ងៀកអស់ប្រាំពីរថ្ងៃ, បង្អុរប្រាក់អស់ប្រាំពីរថ្ងៃ, បង្អុរមាសអស់ប្រាំពីរថ្ងៃ, បង្អុរកែវប្រាំពីរប្រការអស់ប្រាំពីរថ្ងៃ, កនកនគរក៏ចំរើនរុងរឿងល្អដូចជាទេវលោកក្នុងកាលនោះឯង ។

តមត្ថំ បកាសេន្ទោ សត្ថា អាហ សម្តេចព្រះបរមសាស្តាចារ្យ
កាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ថា

សទ្ធាបុព្វង្គមំ ទានំ អបិ កិញ្ចិ បិយេ កតំ
បសន្នា តីសុ កាលេសុ លភន្តិ តិវិធំ សុខំ
មានុស្សេសុ ផលំ ទេតិ សគ្គេសុ ច បរមំ សុខំ
តតោ ច និព្វានសុខំ សព្វទានេន លភតីតិ

ការឲ្យទាន មានសទ្ធាជាប្រធាន, ទោះបីវត្ថុបន្តិចបន្ទួច ដែលបុគ្គលឲ្យ ហ៊ីយចំពោះបុគ្គលជាទីស្រឡាញ់ ហ៊ីយបុគ្គលនោះមានសេចក្តីជ្រះថ្លាក្នុងកាលទាំង ៣ រមែងបានសេចក្តី

សុខ ๓ ប្រការ គឺសេចក្តីសុខក្នុងមនុស្សលោក សេចក្តីសុខក្នុងទេវលោក សេចក្តីសុខក្នុងព្រះនិព្វាន ។

អង្គសម្តេចព្រះទ្រង់ញាណ ទ្រង់នាំធម៌ទេសនាមកសំដែងហើយ ទ្រង់ប្រកាសសច្ចធម៌ ๔ ប្រការចប់សព្វគ្រប់ហើយ ទើបទ្រង់ប្រដុំជាតកថា ព្រះពជកុមារក្នុងកាលនោះ ចេរវិលរឹងមក ជានាគហុលកុមារ, អាមាត្យក្នុងកាលនោះ គឺសារីបុត្តជាធម្មទេសនាបតី, បុរោហិតក្នុងកាលនោះ គឺមោគ្គល្លាន, ព្រះនាងកនកាពជទេពីក្នុងកាលនោះ គឺនាងយសោធរា, ព្រះបាទកនកពជក្នុងកាលនោះ គឺតួអង្គអញ្ញតថាគត ជាលោកនាថហ្នឹងឯង ។ អ្នកទាំងឡាយចូរចាំទុកជាតកយ៉ាងនេះចុះ ។

ចប់ កនកវណ្ណរាជជាតក ទី ๑๖

ផ្នែកអក្សរសាស្ត្រ

ឧទានសុភាសិត

ការប្រដៅមនុស្ស

រឿងសតំបហារ (ការវាយ ១០០ រំពាត់)

ព្រះមហា មៅ-ទាន់ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

ការប្រដៅមនុស្ស ចួនកាលប្រើត្រឹមតែវាចាមួយយ៉ាង ក៏នៅមិនទាន់ឲ្យសម្រេចប្រយោជន៍បានសព្វគ្រប់ ព្រោះអ្នកស្តាប់មិនទាន់ជ្ឌតជ្រាបជូចបទរៀនពិតៗ របស់ជីវិតដែលធ្លាប់បានប្រទះមកដោយខ្ជួនឯង ។ ចង្អុលឲ្យឃើញងាយ ៗ ជូចប្រដៅក្មេងថា "កុំយកដៃទៅលូកក្តៅងលេងតែលូក ក្តៅងនឹងរលាកដៃ" ។ ដោយការពន្យល់តែត្រឹមប៉ុណ្ណោះ ក្មេងដែលមិនធ្លាប់បានស្គាល់ពិសរបស់ក្តៅងមកអំពីមុន ក៏មិនអាចជឿជាក់នូវពាក្យប្រដៅនោះបានទេ លុះតែកាលណាត្រូវក្តៅងរលាកដៃ ស្គាល់ពិសរបស់ក្តៅងដោយខ្ជួនឯងហើយ ទើបឃើញពិតតាមពាក្យរបស់ចាស់ទុំប្រដៅ ។

ការសិក្សាផ្ទូវលោក ដែលមានការល្បងពិសោធដោយរបស់ពិតជូចការល្បងវិទ្យាសាស្ត្រ ក៏ដើម្បីលទ្ធផល គឺសេចក្តីយល់ចូលចិត្តច្បាស់លាស់ ។

ទាងផ្ទូវព្រះពុទ្ធសាសនា ក៏រឹតតែឃើញទម្រង់ក្នុងរឿងនេះបាន

ដោយល្អណាស់ទៅទៀត ព្រោះព្រះសម្ពុទ្ធ ដែលជាកំពូលអ្នក
ប្រដៅ ទ្រង់តែងប្រដៅឲ្យសមហេតុសមផល ត្បូរដល់ចរិតអធ្យាស្រ័យ
នៃអ្នកស្តាប់, អ្នកស្តាប់ផ្ទាប់ចូលចិត្តរឿងអ្ទីស្ទិទ្ធស្ទំមកហើយ ក៏ទ្រង់
លើករឿងនោះទ្បើងជាតួយ៉ាងប្រៀបធៀប ដូចទ្រង់ប្រដៅអំពីរឿង
ប្រាវត្ថសេចក្តីព្យាយាមដល់អ្នកដែលផ្ទាប់ដេញពិណមកពីដើមថា បើ
ព្យាយាមខ្ទាំងហួសពេក ឬព្យាយាមធូរហួសពេកទៅ ក៏ដូចត្នាន៏ង
ខ្យៃពិណ ដែលគេរឹតឲ្យតឹងហួសពេក ន៏ងដាច់, បើធូរហួសពេក មិនព្ន;
ការប្រាវត្ថសេចក្តីព្យាយាមក៏គប្បីឲ្យប្រព្រឹត្តទៅតែល្មមប្រមាណ កុំឲ្យ
ខ្ទាំងហួស ទាល់តែធ្ទើរាងកាយឲ្យលំបាកក្តៅក្រហាយ កុំឲ្យធូរថយហួស
ទាល់តែរាងកាយទៅជាខ្ជិលច្រអូសឬទម្រន់ បើប្រព្រឹត្តឲ្យលៃល្មម
ប្រមាណហើយ ក៏ដូចខ្យៃពិណដែលរឹតតែយ៉ាងល្មមមិនឲ្យតឹងហួស
មិនឲ្យធូរហួស ទើបដេញព្ធពីរោះ ។

ភិក្ខុកំទ្បោះមួយរូប លង់ត៉និតស្រឡាញ់រូបធោមរបស់នាងសិរិមា
ដែលល្អស្រស់ រហូតដល់លែងធាន់ចង្ហាន់លែងសឹង ។ លុះនាង
សិរិមាអនិច្ចកម្មដោយរោគបច្ចុប្បន្ន ព្រះដ៏មានព្រះភាគ ត្រាស់សូមឲ្យ
ស្តេចផែនដីដំកល់សពនាងទុកសិន ទាល់តែហើមរលួយកុំអាលឲ្យដុត
ហើយឲ្យបា៉ាវស្តរប្រកាសប្រាប់មហាជនថា បើអ្នកណាត្រូវការចង់បាន
រូបនាងសិរិមា ឲ្យអ្នកនោះយកទ្រព្យប៉ុណ្ណោះប៉ុណ្ណោះមកចុះ ផ្តើមដាក់
តម្លៃយ៉ាងថ្ងៃបំផុត ហើយសម្រុតបន្ទយចុះមកយ៉ាងថោកបំផុត ទាល់តែ
ថា បើអ្នកណាត្រូវការក៏ន៏ងឲ្យទទេ ។ ដោយឥតឲ្យគិតតម្លៃសោះ

សូម្បីដូចនោះ ក៏ពុំមានអ្នកណាត្រូវការ ផ្ទុយគ្នាស្រឡះអំពីកាលដែល
នាងសិរិមាមានជីវិតរស់នៅ ។ ព្រះអង្គទ្រង់នាំកិក្ខុកំឡោះនោះទៅផង
ដែរ ដើម្បីឲ្យមើលសពនាងសិរិមាដែលកំពុង់តែហើមរលួយ មាន
ដង្ហូវរាវ មានទឹករងៃហៀរហូរ ។ នេះជាបទរៀនពិត ៗ ដែលធ្វើ
ឲ្យកិក្ខុនោះយើញសេចក្តីអសោចឹគ្ឆរឡើម យើញសេចក្តីមិនទៀងទាត់
ចំពោះរបស់ដែលខ្ជូនជ្ជាប់សំគាល់ថាល្អស្រស់នោះ ទាល់តែជាហេតុឲ្យ
កិក្ខុនោះមានស្មាតី លែងវង្វែងលង់គំនិតដូចកាលពីមុនទៀត ។

និទានដែលនឹងនាំមកពោលតទៅនេះ ក៏ដើម្បីឲ្យយើញសេចក្តី
សំខាន់នៃការប្រដៅ ដោយបទរៀនពិត ៗ ដូចពោលហើយនេះដែរ ។

ក្នុងអតីតកាល មានអ្នកប្រាជ្ញម្នាក់នៅក្នុងកុរជររដ្ឋ ជាអ្នកជំនាញ
ខាងក្សួនកាព្យ ព្ធដំណឹងថា ព្រះចៅកាសី ទ្រង់សព្វព្រះរាជហ្ជុទ័យ
ណាស់ក្នុងកាព្យយ្ជោង ក៏ធ្វើដំណើរទៅកាន់ក្រុងកាសី ដើម្បីចូលគាល់
លុះទៅដល់ទ្វារព្រះរាជវាំង អ្នកចាំទ្វារក៏ហាមឃាត់មិនឲ្យចូលសោះ អ្នក
កាព្យនោះ ក៏ទទូចអង្វរដោយពាក្យសិទន់ផ្អែមល្ហែមផ្សេង ៗ ទីបំផុត
ទាល់តែធ្មាំទ្វារពោលថា "បើអ្នកត្រូវការចូល លុះតែឲ្យអ្វីជារង្វាន់ដល់
យើងសិន, បើមិនដូចនោះ អ្នកនឹងខានបានចូលជាដាច់ខាត" ។
អ្នកកាព្យបានព្ធដូច្នោះ ទើបតបថា "ពេលនេះ តែមួយសេន ខ្ញុំក៏គ្មាន
ដែរ, ប៉ុន្តែណ្ហើយចុះ កាលបើខ្ញុំចូលទៅហើយបានរង្វាន់អ្វីអំពីស្តេច
សឹមខ្ញុំបែងចែករង្វាន់នោះឲ្យអ្នកពាក់កណ្តាល" ។ ធ្មាំទ្វារបានស្តាប់
មានសេចក្តីត្រេកអរ ទើបអនុញ្ញាតឲ្យអ្នកកាព្យនោះចូលទៅ ។ អំពើ

ដូចនោះ សឲ្យឃើញថា ឆ្មាំទ្វារជាអ្នកមិនខ្វៀងត្រង់ចំពោះមុខងារបស់ខ្លួន ។

អ្នកកាត្យ លុះចូលទៅដល់ទ្វារជាន់ក្នុង ក៏ត្រូវឆ្មាំទ្វារជាន់នោះហាមឃាត់ទុកទៀត ទាល់តែចុះសន្យាថា នឹងបែងចែកបរស់ដែលបានអំពីស្តេចឲ្យគេពាក់កណ្តាល ទើបបានអនុញ្ញាតឲ្យចូលទ្វារនោះទៅដល់ព្រះរាជាបាន ។ លុះចូលទៅដល់ ថ្វាយបង្គំហើយក៏ពោលសំលោកពាក្យកាត្យដ៏ពីរោះចាប់ចិត្ត ញាំងព្រះរាជហ្ឫទ័យព្រះរាជាឲ្យរីករាយយ៉ាងអស្ចារ្យ ។ ព្រះរាជាទ្រង់សព្វព្រះរាជហ្ឫទ័យចំពោះអ្នកកាត្យនោះ ទ្រង់ធ្វើសេចក្តីកោតគោរព ហើយត្រាស់ហៅមន្ត្រីមក ឲ្យព្រះរាជទានដំរីមួយជារង្វាន់ដល់អ្នកកាត្យដែលឈ្នះសង្វៀននោះ ។ អ្នកកាត្យបានស្តាប់ព្រះរាជឧង្ការ ទើបក្រាបទូលថា "ព្រះករុណាថ្លៃវិសេស ! ទូលព្រះបង្គំជាខ្ញុំ ធ្លាប់បានដំរីជាច្រើនលើកមកហើយ, ដូច្នេះ ពេលនេះ ដំរីឃើញថាមិនជាប្រយោជន៍ដល់ទូលព្រះបង្គំជាខ្ញុំប៉ុន្មាន, ទូលព្រះបង្គំជាខ្ញុំ ទូលសូមព្រះរាជទានរបស់ឯទៀតក្រៅពីដំរីវិញ" ។

ព្រះរាជាទ្រង់តបថា "អើអ្នកច្បាស ! លោកត្រូវការចង់បានរបស់អ្វីក៏ចូរថាមកចុះ បើយើងអាចឲ្យបាន យើងនឹងឲ្យ" ។ អ្នកកាត្យក្រាបទូលថា "ព្រះករុណាថ្លៃវិសេស ! បើព្រះអង្គទ្រង់ព្រះមេត្តាប្រោសព្រះរាជទានរង្វាន់ហើយ សូមទ្រង់ព្រះមេត្តាប្រោសឲ្យរាយទូលព្រះបង្គំជាខ្ញុំឲ្យទាល់តែគ្រប់ ១០០ រំពាត់ជារង្វាន់ចុះ, ទូលព្រះបង្គំជាខ្ញុំ ពុំប្រាថ្នារបស់អ្វីដែលព្រះអង្គមិនអាចព្រះរាជទានបាននោះទេ" ។ ព្រះរាជាមិនទ្រង់

ជាបំណងរបស់គេ ក៏ទ្រង់លំបាកក្នុងព្រះពជ្ឈដ៏យូរយ៉ាងខ្លាំង ទើបត្រាស់តបថា "លោកមហាកាឡ! លោកចូរឈប់និយាយរឿងវាយដោយរំពាត់ទៅ បើលោកត្រូវការមាសប្រាក់តែងឯណា ក៏ចូរប្រាប់មកចុះ យើងនឹងឱនឲ្យបានគ្រប់យ៉ាង"។ អ្នកកាឡក្រាបទូលថា "ព្រះសម្មតិទេព! បើទ្រង់ព្រះមេត្តាប្រោសញ៉ាំងសេចក្តីប្រាថ្នារបស់អ្នកកាឡតាំងឡាយឲ្យពេញបរិបូណ៌ហើយ ក៏សូមទ្រង់ព្រះពជ្ឈានវង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ដោយការវាយឲ្យតាលតែគ្រប់ ១០០ ចុះ, បើមិនដូចនោះទូលព្រះបង្គំជាខ្ញុំនឹងសូមថ្វាយបង្គំលា សូមសិរីសួស្តីចូរមានដល់ព្រះអង្គចុះ"។ កាលព្រះពជា មិនទ្រង់យើញផ្លូវដទៃ ដើម្បីញ៉ាំងសេចក្តីប្រាថ្នារបស់អ្នកកាឡឲ្យពេញបាន ទើបត្រាស់បង្គាប់ឲ្យនាយតម្រួត ចាត់ការដាក់ព្រះពជអាជ្ញា។ លុះតម្រួតរៀបចំនឹងវាយ អ្នកកាឡក៏ប្រាប់ថា "ឈប់បង្អន់មួយរំពេចសិនចុះលោក! នាយទ្វារពីរនាក់ ជាអ្នកត្រូវបានទទួលចំណែកនៃវង្វាន់នេះ ព្រោះខ្ញុំបានចុះសន្យានឹងគេទុកថា វង្វាន់ឯណាដែលខ្ញុំបានអំពីព្រះពជានោះ ពាក់កណ្តាលនឹងឲ្យដល់ឆ្នាំទ្វារទី ១, ពាក់កណ្តាលទៀតនឹងឲ្យដល់ឆ្នាំទ្វារទីពីរ, បើពុំដូចនោះទេ នឹងមិនបានចូលមកគាល់ឡើយ ហេតុនេះ សូមបានសេចក្តីសង្គ្រោះចៃកវង្វាន់ គឺការវាយខាងក្រោយនេះ ឲ្យដល់នាយទ្វារទាំងពីរមាក់នោះ ម្នាក់ពាក់កណ្តាលចុះ ដើម្បីកុំឲ្យខ្ញុំដែលបានប្តេជ្ញាហើយ នឹងខូចសច្ចៈ"។

ដោយការអង្វរករបស់អ្នកកាឡនោះ នាយទ្វារទាំងពីរនាក់ ក៏ត្រូវ

គេនាំខ្ជូនយកមកកុងទីចំពោះព្រះភ័ក្ត្រព្រះរាជា ហើយរាយខ្នងម្នាក់ ៥០ យ៉ាងធ្ងន់ ៗ . . . ៗ

ព្រោះសេចក្តីយ្ងាសវៃនៃអ្នកកាព្យនោះ ព្រះរាជានឹងមន្ត្រី មានសេចក្តីស្វើចកុងចិត្តយ៉ាងខ្ងាំង ក៏តាំងបន្ទៃមសេចក្តីរាប់អានចំពោះអ្នកកាព្យនោះយ៉ាងសន្ធឹក ៗ

នេះគឺជាបទរៀនពិត ៗ ដែលអ្នកកាព្យនោះប្រដៅមនុស្សលោកប៉ុន្ត្រកាលបើយកមកប្រៀបធៀបនឹងការប្រដៅ ដោយវិធីជូចគ្នា នៃព្រះពុទ្ធជាម្ចាស់វិញនឹងឃើញបានថា ព្រះអង្គមិនមែនជល់ទៅជាក់បទរៀនដែលជាហេតុឲ្យបុគ្គលត្រូវរងអាជ្ញាដ៏ធ្ងន់យ៉ាងនោះទេ; ការទូន្មានមនុស្សឲ្យបានល្អ របស់ព្រះអង្គនោះ គឺប្រើវិធីមិនឲ្យមានរបួសស្ងាកស្នាមដែលជាគ្រឿងសង្កេតមួយយ៉ាង រវាងការប្រដៅរបស់បុថុជ្ជន នឹងរបស់ព្រះអរិយ: ៗ

ចប់

រឿងសៅរ៍សោយ

(សិសោរជាតក)

ព្រះមហាឧត្ថមវិជ្ជា ជលញ្ញាណោ ប៊ុង - ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រាស្ទឹកវិត

(តមក)

បទពុំគោល

ពេលនោះស្រីស្រស់ធីតា នៅរួមវាសនា នឹងមហាក្សត្រាសិសៅរ៍ ។
លុះលង់ដល់ទ្រង់គកិទៅ ទើបរឿងស្រីពៅ ជ្រាបជ្រៅដល់ទៅមាតា ។
ជ្រាបក្ខាមនាងទោមនស្យា ទើបធ្វៀតយាត្រា ទៅទីធីតាជាត្រើយ ។
នាងសោកអមោកូឥតស្ស៊ីយ ធីតាម៉ែអើយ ម្តេចទ្ស៊ីយមកមានស្ថាមី ។
ទុរគតកំសត់អប្រិយ នេះគួរបុត្រី មានក្តីខ្ចាសរាស្ត្រទាំងឡាយ ។
ថោកខ្ជូនទាំងកូនទាំងម្តាយ នេះគឺកម្មកាយ នៃម្តាយនឹងកូនពុំខាន ។
ពីមុនម្តាយគន់គិតស្មាន ថាកូនកល្យាណ នឹងបានថ្ពើងថ្ពានឥតបី ។
គិតគ្នេរថាមេមានប្ពី មានបុណ្យបារមី សិរីប្រសើរស្មើគ្នា ។
ម្តាយងងនឹងបែងទ្រព្យា រេហ៍ពលយោធា ឲ្យជាសម្បត្តិរ៉ែតន៍ស្រី ។
នឹងបានថ្ពើងថ្ពានសិរី សោះខ្ចាសសេនីយ មន្ត្រីកវីទាំងឡាយ ។
តែនេះស្រីស្រស់ធោមធាយ គ្មានគិតចិត្តម្តាយ នាងក្ខាយជាមនុស្ស
ទុសក្រឹត្យ ។
នាងធ្វើអំពើតាមចិត្ត ទៅផ្អែកផ្តេកផ្ពិត រួមស្និទ្ធនឹងមនុស្សអស់ផ្ទូរ ។

ពុំខ្វាចអំណាចម៉ែឪ ធ្វើឲ្យអាស្រូវ ម៉ែត្រូវរងគ្រោះខ្ទាសគេ ។
នាងសោកអមោកូសែនទ្វេ រូចក្លាមនាងរ រិលទៅលំនៅអាត្មា ។
ឯវ៉តន៍សុទត្តកញ្ញា គ្រប់ទសមាសា ធីតាក៏ប្រិសូតបុត្រ ។
ឧរសស្រួចស្រស់បំផុត លក្ខណៈបវ៉សុទ្ធ ចំហុតដូចជាអយ្យកោ ។
ល្អល្អះត្រចះសេដ្ឋា ដូចជាទេវា ឆ្លូរតែស្នេហាពេកក្រៃ ។
ជ្រាបដល់កិន្នវត្តក្សត្រថ្ងៃ ធ្វើឲ្យកូវន៍យ រឹងក្រៃច្បោតក្រោធា ។
ស្តេចទ្រង់ឆិតក្នុងទ៍យា ខ្ទាសអស់មនុស្សម្នា ប្រជានុរាស្ត្រទាសផង ។
ឆិតថា "យើះ! អាដកទង ទ្រនង់យង់ឃ្នង រំលងកន្ទងអញ្ចឹ! ។
ពុំខ្វាចអំណាចបារមី ហ៉ានរួមប៉ែតី កូនស្រីសំឡាញ់អញឯង ។
បំពោតឥតកោតឥតក្រែង ឬកហំចំខ្ទង សំញ្ញែងហាក់ឯងចំណាប់ ។
ឲ្យនៅតទៅនាំអាប់ អញត្រូវទៅចាប់ មកកាប់សម្ងាប់វៃ ។" ។
ស្តេចអត់សង្កត់ព្រះទ៍យ ថ្ងៃមួយជ្រស្ឆជ៍យ រំពៃក្នុងចិត្តឆិតថា ។
"សុទត្តវរវ៉តន៍ធីតា ប្រសូតបុត្រា ជាតិជាយូរយារហើយហោង ។
អញសោតចង់ទតឃើញម្តង ឧរសនោះហោង រូបប្រាណសណ្ឋាន
ម្តេចទៅ" ។
ឆិតស្រេចសម្តេចចមចៅ ប្រើស្នំដែលនៅ ឲ្យទៅយកចៅមកណា ។
ស្នំផងត្រសងយាត្រា ចូលទូលធីតា កញ្ញាសុទត្តវ៉តន៍ស្រី ។
"បពិត្រវរមិត្តក្សត្រី ដ្ឋិតព្រះនរបតី ចក្រីប្រើខ្ញុំតាំងអស់ ។
ឲ្យមកនាំយកឧរស ទៅថ្វាយទ្រង់យស ចំពោះនឹងទតបានម្តង" ។
កាលនោះស្រីស្រស់ច្បាស់ច្បង ស្តាប់ស័ព្ទហើយហោង នួនល្អងឥត

ឃាត់ឡើយណា ។

នាងបែរមកផ្តេផ្តាំថា "នាងនាំបុត្រា កុមារឧត្តមឱ្ចុំឥៅ ។
ថ្វាយថ្វាត់មហាក្សត្រចមហៅ កុំឧកយូរនៅ នាងត្រូវធាប់យកមកឱ្ធ" ។
ព្ធហ្នោះគើបអស់ទាសី ទទ្ធលសវនីយ ឃ្ធាតឱ្ធីលាលាកចាកថាន ។
ចេញចាកដំណាក់មកថ្ពាន បីបុត្រកល្យាណ ប្រែប្រាណធ្ពោះថាន
រាំងដ័យ ។

លុះដល់ចូលតាល់ក្សវនីយ នាំបុត្រវៃ ។ ឃ្ធាតឱ្ធីថ្វាយថ្វាត់ក្សត្រា ។
ទសពលទតយល់ទត្តា ល្អតួកាយា ចក្រាស្នេហាឥតបី ។
ស្តេចត្រាស់ដម្រាស់ឥៅឱ្ធ "ហៃហៅពិសី ចូរមករកតាណាហៅ" ។
ត្រាស់ហ្នោះទ្រង់ស្ទុះសំដៅ ត្រកងព្រះហៅ មកឧបក្រសោបបមបី ។
រួបរឹតចុម្ពិតសិរសី ហើយគើបនរបតី ចក្រីដម្រាស់ត្រាស់ថា ។
"ហៅវ្រីយ! ចូរស្ឈើយទុក្ខា នៅនេះហើយណា ជីតារក្សាពិទ័ត្ត ។
ជីតានឹងប្រើសេវ័ក ឥៅនាំម្ពាយអ្នក មកនៅលំនៅបុរី ។
ត្រថាបិតាអ្នកឱ្ធ តាស្អប់ឥតបី មេត្រីប្រណីពុជាន ។
នឹងចាប់សម្ងាប់ពុំទាន ចូរហៅស្ទោះស្ទាន កុំក្រោធប្រឡោតនឹងតា" ។
ត្រាស់ស្រេចសម្ពេចក្សត្រា មានព្រះវាចា ឧឡារឲ្យជាងប្រញាប់ ។
ធ្វើអស់របស់ប្រដាប់ មាសប្រាក់សម្រាប់ ស្រេចស្រាប់រនូលប្រាលធ្ឋៅ ។
ក្សត្រក្សាន្ធប្រទានឥៅកៅ ស្រេចស្ពេចតេចហៅ ឲ្យស្នំមេនំទាំងឡាយ ។
នាំហៅយកឥៅថ្វាត់ថ្វាយ ទេវីធោមធាយ ជាម្ពាយឯនាយប្រញាប់ ។
ហើយទ្រង់ឲ្យជាងផងចាប់ សាងអាងមាសធាប់ ប្រដាប់សម្រាប់ទត្តា ។

ស្រែនំទឹកក្រែសាលអាត្មា ស្រែចថ្ងាត់ក្បត្រែ ចក្រែឲ្យទៅចៅខ្ញុំ ។
ស្តេចផ្តាំឲ្យស្មុំទាសី បំរើក្បត្រី ឃ្មាតខ្ញីមើលប្តីស្រីរត័ន ។
បើមោះឃើញខុសភ្លាំងភ្លាត់ ជូរចោមឡោមព័ទ្ធ ទៅចាប់សម្លាប់ជាមួយ ។
អញឯងនឹងតែងពលផង នាំកូនអញហោង រៀលផ្គងមកនៅកំណាំ ។
អស់ស្មុំប្រណម្យក្បត្រែ បីរាជនត្តា យាត្រាដំរង់ត្រង់ទៅ ។
លុះដល់មណ្ឌលស្រែទៅ ពុំអង់រង់នៅ ចូលទៅថ្វាយបុត្រត័ន្ថៃ ។
ទៅម្នាម្ចាស់លួតដៃ ទទួលបុត្រថ្ងៃ ថ្នមថ្នាក់លើកជាក់លើភ្លៅ ។
ថើបបុត្រវិស្សុតពាលពៅ ក្រសោចនុចទៅ បំបៅផ្ងាប់នៅទុក ។
ឯក្រុមស្រីស្មុំនោះណា បំរើធីតា នៅនាដំណាក់នោះនៃ ។
ទុហាតសង្ឃាតរំពៃ រកទោសដៀស្តីដ្ឋ ឥតបីឃើញអ្វីខុសឡើយ ។
ទើបស្មុំដំទុំគ្នាហើយ គិតថា "រ៉ីអើយ! យើងស្មុំទាំងក្រុមនេះខ្ញុំ ។
សែ្តងទោសបុរសកាឡ ពុំបានសេចក្តី បានអ្វីទៅទូលពាជា ។
ច្នោះភ្លាយើងត្រូវមាយា ធ្វើជាឈ្លោះគ្នា និន្ទាតូដទៅសន្តាន ។
គាត់សោតនឹងក្រោធពុំខាន ពួកយើងនឹងបាន ចាប់ទោសកំហុស
គាត់ហោង" ។
គិតច្នោះទើបអស់ស្មុំផង ដេរគ្នាអឺងកង ដៀងដងដៀមជាមក្បត្រែ ។
ក៏ដេរតាមតែនឹងថា "អាដែងឯងណា កំព្រាព្រាត់ញាតិឃ្មាតផៅ ។
មិនមានទីហានលំទៅ តូដផងហ្មងសៅ កំឡៅដូចជាឆ្កែធ្មា ។
បានតែសូមគេកោក្តា រួចរស់ដីវ៉ា ដោយសារអ្នកផ្សារទេនៃ ។
ដើរលុងតែកុងព្រឹក្សព្រៃ ទើបតែបែរវៃ ឃ្មាតខ្ញីចូលមកស្រុកអាយ ។

ជានសុខស្រណុកសប្បាយ ប្ចកពាលមាល្បាយ ឥតបើនឹងធ្វើការអ្វី ។
ដូចជ្រូកដេកស្ពូកនៅដី ក្លែរស្ពូកចំណី ឃ្មាតឲ្ចីចាំធីប៉ុណ្ណោះ ។
អញ៦ឯងឥតត្រកែងឯងសោះ អាដែងឯងស្មោះ ច្រអូសដេកចាំតែស៊ី ។
ឥតស្គាល់មណ្ឌលទិសទី ឥតចេះរកស៊ី កាប់ធ្កាធ្វើការអ្វីទេ ។
ស៊ីដេកស៊ីដេកផ្ទែកគេ អាខ្មាសគេទេ ចូរគ្នេរពិនិត្យគិតគន់" ។
ព្ទាច្នោះទ្រង់យសហ្លសធន់ ទ្រង់ក្តុកទុក្ខធ្ងន់ ស្រពន់អ្លលអន់ឧរា ។
ភ្ជាំងភ្ជឹកស្រក់ទឹកនេត្រា ទ្រង់ទប់ចិន្តា យាត្រាគេចវេះដៀសឲ្ចី ។
ទើបស្តេចវិលគេចស្រដី ប្រាយប្រាប់មហេសី ថា "ហៃប្អូនស្រីពុំងា ។
ខ្ជូនបងជានរងវេទនា ប្រាសព្រាត់ឃ្ជាតឃ្ជា ផ្ញើខ្ជូននឹងស្ជូនថ្ជើមថ្ជៃ ។
បងជានសុខសាន្តសព្វថ្ជៃ ឥឡូវនេះនៃ មកធន់ទុក្ខធ្ងន់កន្ជង ។
ឥឡូវនេះកូវខ្ជូនបង ខានជានស្នេហ៍ស្នង ស្នេហ៍ស្និទ្ធនឹងមិត្តពិសី ។
ចូរម៉ុមនាងកុំទុក្ខថ្ជី បងលាភ្ជាប្រិយ ដោយក្តីអាល័យក្រែណា ។
ចូរពៅនាងនៅរក្សា ចិញ្ចឹមបុត្រា . នៅត្រាបងឃ្ជាឃ្ជាតទៅ ។
ដ្សិតបងជានរងហ្មងសៅ ពីមុនណាពៅ ពុំសូវក្ជួលក្តៅទ្បើយណា ។
ពេលនេះទុក្ខហ្លសបើថា ដែលបងនេះណា ពុំធ្ជាប់ប្រសព្វមកទ្បើយ ។
បងលាពុំងាសិនហើយ នៅចុះប្អូនអើយ ឲ្យជានសុខសាន្តណាពៅ ។
"ដ្សិតបងមិនអាចនិត្យនៅ ចិត្តអ្លលក្ជួលក្តៅ ទុក្ខធ្ងន់លើសលន់សព្វដង ។
វរមិត្ត ! បើឥតពីបង ចូរស្ជូនន្ជូនល្អង មានប្តីជាថ្ចីចុះណា ។
ដ្សិតបងម្ជហ្មងចិន្តា ខ្មាសមេទាសា ដៀលថាដេដ្ជាកាឲ្យី" ។
កាលណោះវរវ៉ត៍ន៍ក្សត្រី ស្តាប់ស័ព្ទស្វាមី ស្រដីប្រាយប្រាប់ច្នោះឯង ។

នាងអួលក្តៅក្តួលកវល្ហែង ទ្រែង់សោកកន្ធែង ថ្វាថ្វែងទូលថា
"ម្ចាស់អើយ ។
ហេតុម្តេចស្តេចគេចកន្តើយ ចោលខ្ញុំម្ចាស់ហើយ ពុំគិតអាណិតបុត្រា ។
ពុំគួរស្តេចយកវាចា ពួកវាសា ធ្វើជាអារម្មណ៍ដំឡើយ ។
បើថាដេដ្ឋកន្តើយ ពុំគិតខ្ញុំហើយ គួរគិតអាណិតបុត្រថ្លៃ" ។
ស្តេចផ្ទៀងស្តាប់នាងហើយនៃ ឃានក្សាន្តព្រះទ័យ ប្រណីតអាណិត
បុត្រា ។
គិតគួរអាសូរជីតា ពុំចេញចរចា ក្សត្រាស្ងៀមស្ងាត់និត្យនៅ ។
ទាសីកាឡីឃោរឃៅ យល់ស្តេចគេចនៅ ពុំក្រែងពិភេធតិចឡើយ ។
គិតថា "វុ៎! គ្មាយើងអើយ ដៀលតិះម្ល៉ះហើយ គាត់ធ្វើយពុំខឹងដល់តិច ។
ឥឡូវយើងត្រូវធ្វើកិច្ច កំណាល់កលល្បិច ចាប់ទោសគាត់នោះទៀត
ណា ។
មក! មក! យើងយកបុត្រា បង្អត់ក្រយា ឲ្យផ្ទុំស្រែកយំទៅនៃ ។
ហើយនាំគ្នាចាំរំពៃ ពួនមើលគាត់វៃ ក្រែងខុសកំហុសដូចម្តេច ។
យើងនឹងរំលែងរំពេច ទូលដល់សម្តេច ឲ្យស្តេចជ្រាបសេចក្តីហោង" ។
គិតស្រេចក៏គេចជាម្ខាង នាំគ្នាត្រសង ត្រកងបីអង្គបុត្រា ។
យកទៅដាក់នៅឯកា បង្អត់ក្រយា ហើយវាពួនឃ្លាំចាំនៅ ។
ខុរសស្រស់ស្រាលពាលទៅ ធ្លុះត់យូរទៅ ក្លាក់ប្លោណបានដំណើរខ្លី ។
ឃ្លានស្រែកខ្យីរពេកឥតបើ សេះសោះអស់ក្តី ក្សត្រថ្លៃយាសយែក
ស្រែកយំ ។

រីឯពួកមេស្រីស្នំ រាទំសំឯ ពុំធ្វើជឹងឲ្យសោះឡើយ ។
កាលណោះក្សត្រក្សាន្តត្រាណត្រើយ ឲ្យបុត្រយំហើយ ទៅថ្នមបីបម
ត្រកង ។
ល្ងងលោមប្រលោមសាសង មិនឲ្យមានហ្នង នឹងបុត្រពិស្សុតសោកា ។
បីត្រង់ជម្រង់ទៅនា អាងមាសសោកា ជាក់បុត្រពិស្សុតឲ្យស្រង់ ។
កុមារក្រសាលតាមចង់ សប្បាយអស់អង្ក នៅក្នុងអាងមាសនោះណា ។
ទះទឹកក្ងេចនឹកក្រយា ត្រជាក់អាត្មា លោតលេងកញ្ជេងសប្បាយ ។
ស្រាកស្រាន្តកំសាន្តព្រះកាយ ទឹកឲ្យាតឲ្យាត់ឲ្យាយ ស្រោចស្រង់ជល់
អង្ក្ចក្រី ។
ពួកស្នំមេនំអប្រិយ យល់កប់នរបតី ទទឹកអស់អង្ក្ចកាយា ។
រាវក្ងេតនាំហេតុនោះណា ទូលជល់ក្សត្រា បិតាថា "ទ្ងុត្រប់ប្រាណ ។
យល់អ្នកអបល័ក្ខណ៍សាមាន្យ ពុំកោតក្សត្រក្សាន្ត ឈ្ងានពានហ៊ានងូត
ត្ងង្ក ។
នៅក្នុងអាងមាសសោកា សម្រាប់រាជា ម្តេចរាពុំកោតជៀស្ជ័យ ។
សូមទ្រង់ជ្រាបក្នុងព្រះទ័យ ទ្ងុម្ចាស់នេះនៃ ទូលចំពិតពុំមុសា ។
កិន្នុវត្តចមក្សត្របិតា ជ្រាបកាពច្នោះណា រីក្រវក្រោធក្រឡេតឥតបី ។
ស្តេចទ្រង់ឧង្ការថា "រ៉ូ! អស់មុខមន្ត្រី ពេជ្ឈយាជក៍អាមាត្យត្រប់ប្រាណ ។
ចូរផ្ទុំជួបជុំធាប់ថ្ពាន នាំត្នាត្រប់ប្រាណ ឃ្នាតឲ្ងីចាប់ប្ពីធិតា ។
ចងឲ្ងីកុំបីមេត្តា នាំយកមកវ៉ ឃុំទាំងជាក់ឃ្នាងច្រវាក់ ។
ហើយតោងទោកថងវាយជាក់ តាមបុណ្យតាមសក្តិ អាជ្ញាអញ្ញប្រើទៅឲ្ងី ។

អញឯងនឹងតែងសេទ័យ ទៅនាំបុត្រី រួលខ្លួមកកាន់វិញហោង ។
អាមាត្យទុហាតត្រៃសង ទាំគ្នាជាមួង ឆ្ពោះទៅលំនៅយៅវាន ។
លុះដល់មណ្ឌលទីឋាន និមិលកល្យាណ សុទ្ធតែវរតំន័កញ្ញា ។
ទើបចូលទៅទូលនាងថា "បពិត្រធីតា ក្សត្រាធំប្រើយើងខ្ញុំ ។
ឲ្យមកចាប់យកស្វាមី សូមវត្ថុក្សត្រី ជាបច្ចស់ក្នុងព្រៃដំយា" ។
កល្យាណពុំបានដឹងថា ស្វាមីជាយា ពជាយកទោសព្រោះអ្វី ។
ពុំទាន់បានសួរសេចក្តី ពេញ្ញយាដក៏ឃ្លាតខ្លី ប្រញ៉ីចាប់ប្តីកល្យាណ ។
កូនរកតិតញ៉ែតគ្គិច្ចាណ តំយៃត្រៃប្រមាណ ពុំហ៊ានស្រដីអ្វីឡើយ ។
និមិលកល្យាណត្រាណត្រើយ ឃល់អស់ច្បោះហ៊ើយ នាងក្លាមទៅតាម
យ៉ាងឆាប់ ។
និមិលបន្ទូលប្រញាប់ ថា "អ្នកមកចាប់ តើព្រោះកំហុសម្តេចហោង ។
ទើបមកចាប់យកជាម្តង អម្ចាស់ច្បាស់ច្បង យកទោសព៌ព្រោះខុសអ្វី" ។
អ្នកចាប់ប្រញាប់ទូលខ្លី ថា "សូមក្សត្រី ប្រណីសន្តោសទោសា ។
យើងខ្ញុំធ្វើតាមអាជ្ញា ក្សត្រិយ៍បតិ បញ្ជាយើងខ្ញុំត្រប់ប្រាណ ។
ឲ្យមកចាប់យកទៅថ្កាន យើងខ្ញុំពុំបាន ដឹងជានថាព្រោះអ្វីឡើយ" ។
បានជ្រាបសកាពអស់ហ៊ើយ កល្យាណត្រាណត្រើយ ចូលទៅលំនៅ
អាត្មា ។
យកព្រះនុរសស្នេហា ខ្ញុំឃ្លាតយាត្រា ត្រាប់ត្រង់ដំរាំបុរី ។
ទឹងទៅតាល់ហ្វូងក្រឹ ចមកពនរបតី ក្សត្រិយ៍បតិ ព្រះនាង ។
លុះដល់បានយល់ហើយភ្លាង នោះទើបព្រះនាង ក្រាបពាបទៀបបាទ
ក្សត្រកន្ត ។

អន់អួលឱ្យកើតឱ្យសុខសាន្តាន លន់ពន់ប្រមាណ កល្យាណប្រែប្រាណ
កន្ទែង ។
សោយសោកអមោទកណ្តែង ធីតាថ្ងាថ្ងែង ចែងចង់ទូលអគ្គចិតា ។
" កាលមុនស្តេចពុំមេត្តា ដោយហេតុហោក ទៀងថាយទំនាយទូលខ្ញុំ ។
ថាកូនធីងមានស្វាមី កំសត់អប្រិយ ឥតពូជឥតពង្សវង្សជោ ។
ទើបព្រះអម្ចាស់ចមចៅ ពុំទ្រង់សៅដៅ បណ្តេញខ្ញុំចេញជាមួង ។
ឥឡូវនេះត្រូវកន្ទុង ខ្ញុំមានក្តីផង ចំបួនដូចក្បួនហោរពិត ។
សូមមានប្រោសប្រាណជល់ចិត្ត មេត្តាអាណិត ករុណាខ្ញុំជាបុត្រី ។
ដំណើរអំពីស្វាមី មានទោសខុសម្តី ទើបប្រើអាជ្ញាទៅចាប់ ។
បងយកទាំមកប្រញាប់ ពុំទ្រង់ត្រាស់ប្រាប់ ខ្លួវទោសកំហុសឡើយណា ។
ខ្ញុំម្ចាស់សូមព្រះបិតា សន្តោសទោសា ករុណាមេត្តាស្វាមី ។
បើទ្រង់ពុំបង់ប្រណី នោះសូមនរបតី សំឡាប់ចាំង ៣ ទៅហោង ។
ចាំងកូនចាំងខ្លួនខ្ញុំផង ព្រមគ្នាជាមួង សោះរងទុក្ខទោសវេទនា ។
មិនរងកម្មកងវេរ ម្នាក់ឯងកំព្រា ឧកញ៉ាតីងបង្អែត ។
បើកូនធីងមានប្តីទៀត នោះទីងបង្អែត ពូជពង្សព្រះវង្សក្សត្រា ។
ហាក់ដូចស្រីខូចលក្ខណា ច្នេះសូមបិតា មេត្តាករុណាកូនផង " ។
សុទ្ធិវតីបង្គាស់បង្គង់ មានានោះហោង នាងក៏អង្វរស្វាមី ។
" ខ្ញុំម្ចាស់សូមព្រះចក្រី អាសូរប្រណី បុត្រីពិសីគ្រាណាត្រើយ ។
បើថាពុំអាសូរឡើយ ខ្ញុំម្ចាស់បង្គាស់ហើយ លាស្វាប់ទៅចាប់ជាតិថ្មី " ។

កន្ទុវត្តចមក្សត្រៃបុរី ស្តាប់សំពួមហេសី នឹងស្រីបុត្រវរមិត្ត ។
ទ្រង់ជ្រាបស្រាកស្រាន្តក្នុងចិត្ត ទ្រង់គិតអាណិត ទើបត្រាស់ដំរាស់ទៅថា ។
" ហើយ ។ មកវុំយ ! សេនា ចូរឃ្លាតយាត្រា ទៅដោះអ្នកទៅសនោះនៃ ។
នាំវាមកនាំរំងឹជ័យ ប្រញាប់ឆាប់វៃ កុំបីកន្តើយឡើយហោង " ។
អាមាត្យទហាតត្រៃសង ន៎ាំគ្នាជាមួង រៀលទៅដោះនូវក្សត្រក្សាន្ត ។
ដោះស្រែចនាំស្តេចមកជ្រាន ដល់មណ្ឌលឋាន ប្រញ៉ូវច្រាណចង្គំចមទៅ ។
ចមក្សត្រព្រះច្បាទសិសៅរ ទ្រង់គង់ស្ងៀមនៅ ពិតពុំបង្គំស្តេចឡើយ ។
ស្តេចទតយល់ហេតុច្នោះហើយ ពុំអង់លង់ឡើយ កំគ្រោធពិភេធខ្លាំងក្លា ។
បន្ទូលតិះដៀលទៅថា " មឹងឯងនេះណា ជាតិជាមនុស្សខ្វត់អត់ប្បាប់ ។
ឃើញថាអាត្មាឧន៎ស្ងាប់ អញនឹងឲ្យកាប់ ឥឡូវពុំទៅយូរឡើយ ។
មឹងខ្ទុសជាប់ទោសច្នេះហើយ ម្តេចគេចកន្តើយ ជាក់ដៃពុំថ្វាយបង្គំ ។
ឬថាជាការគួរសម ទើបមឹងរឹងដំ - អត់ពុំសំពះអញឡើយ " ។

បទមណ្ឌកគតិ

កាលអើយកាលណោះ សិសៅវ៌ព្រះច្បាកំឡើយ
" បពិត្រក្សត្រអើយ ខ្ញុំទូលបង្គំនេះណា ។
ឧន៎ក្រាបប្រណម្យ បង្គំបរមក្សត្រា
មិនគួរទេណា ព្រោះថាអាត្មាឧនអាប់ ។
មានទោសខុសធ្ងន់ ត្រែះដល់ជីវជន្មសូន្យស្ងាប់
ពុំសមពុំគាប់ ឧន៎ក្រាបថ្វាយថ្វាត់ក្សត្រក្សាន្ត ។
គួរតែសេនីយ អាមាត្យមន្ត្រីត្រាប់ច្បាណ (មានត)

រឿងសាមកុក

កណ្ឌទី ៦៦

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ឯចូធូកាលលើកទ័ពទៅទាំងកណ្តាលយប់នោះ ក៏ដេញទាហានចូលវាយស្រុកសៀវផាយបាន រួចលើកទៅវាយយកស្រុកឈីជីវទៀត ឯបុ-តុក, ប៊ីហង, កាន់យ៉ុង ដែលឡៅពីឲ្យនៅរក្សាស្រុកនោះក៏គិតគ្នាថា "ទ័ពចូធូលើកមកគ្រាំនេះធំពន្ធឹកណាស់ មុខជាយើងតទល់មិនបានទេ" គិតហើយក៏នាំគ្នារត់ចេញពីស្រុកនោះទៅ នៅតែតាន់តេងទាល់ប្រកនឹងរកផ្ទូវរត់ទៅពុំរួច ក៏បើកទ្វារស្រុកចេញទៅទទួលចូធូដើម្បីឲ្យបានសេចក្តីតាប់ប្រសើរ ។ ចូធូឃើញដូច្នោះក៏មានចិត្តត្រេកអរលើកទាហានចូលទៅ ទើបដាក់កំហិតហាមថា "កុំឲ្យនរណាធ្វើអន្តរាយដល់ប្រជាជនដែលនៅក្នុងស្រុកឲ្យបានសេចក្តីទុក្ខក្តៅឡើយ" ហើយប្រឹក្សានឹងសេនាទា-ហានទាំងពួងថា "យើងនឹងលើកកងទ័ពទៅវាយយកស្រុកហែហ្វីទៀត តើអ្នកទាំងឡាយនឹងយល់ឃើញដូចម្តេច? ។

ស៊ីនហុកឆ្លើយថា ខ្ញុំបានឮដំណឹងថាឡៅពីឱ្យគួនអ៊ូទៅរក្សាគ្រួសារក្នុងស្រុកហៃហ្វឺ ដែលលោកនឹងលើកទ័ពទៅជួយនោះគួរណាស់បើបង្អង់ហើយ អ្នកនឹងលើកទ័ពមកជួយ ហើយនឹងនាំយកគ្រប់គ្រួឡៅពីទៅបាន ។ ចូតូតបថា គួនអ៊ូនោះមានថ្វីដៃខ្លាំងពូកែណាស់ ហើយឈ្លាសវៃក្នុងការសឹកសង្គ្រាម យើងចង់បានខ្លួនគួនអ៊ូមកចិញ្ចឹមទុកជាសេនាឯកតទៅ ឥឡូវនេះយើងនឹងប្រើបំរើឱ្យទៅនិយាយបញ្ចុះបញ្ចូលគួនអ៊ូទើបបាន ។ គុយកែឆ្លើយថា ឯចិត្តគួនអ៊ូនោះទៀងត្រង់នឹងឡៅពីណាស់ ដែលនឹងប្រើបំរើទៅនិយាយបញ្ចុះបញ្ចូលនោះ ខ្ញុំបានយល់ថាគួនអ៊ូមុខជាមិនចុះចិត្តផងទេ បើនរណាដែលទៅបញ្ចុះបញ្ចូលនោះ គង់តែគួនអ៊ូសម្លាប់ចោល ។

តៀវលៀវឆ្លើយថា ខ្ញុំបានឮដឹងគួនអ៊ូធ្លាប់ស្គាល់ពាប់អានគ្នាមក គ្រានេះ ខ្ញុំសុំយកអាសាទៅនិយាយបញ្ចុះបញ្ចូលគួនអ៊ូឱ្យបាន ។ ធៀយ៉ុកថា ដែលតៀវលៀវនឹងទួលយកអាសាទៅបញ្ចុះបញ្ចូលគួនអ៊ូនោះមុខជាគួនអ៊ូមិនមកទេ ខ្ញុំបានសូមយកអាសាទៅបញ្ជោតឱ្យគួនអ៊ូចេញពីស្រុកហៃហ្វឺ ហើយបើឃើញគួនអ៊ូអស់ដម្រិះគិតវែលាណា សឹមឱ្យតៀវលៀវទៅនិយាយបញ្ចុះបញ្ចូលជាក្រោយទើបបាន ។

ចូតូក៏សួរធៀយ៉ុកថា អ្នកនឹងគិតទៅបញ្ជោតដូចម្តេចខ្លះ ? ធៀយ៉ុកឆ្លើយថា លោកចាប់ខាហានឡៅពីទុកបានជាច្រើន ត្រូវឱ្យបំណាច់រង្វាន់ឱ្យពេញចិត្តហើយបង្គាប់ឱ្យធ្វើតាមពាក្យយើង គឺលែងខ្លួនឱ្យវិលចូលទៅក្នុងស្រុកវិញ ហើយប្រាប់ថាខ្លួនវាំងនោះសុទ្ធតែរត់ចូច

មក បើយើងនឹងធ្វើការសង្ត្រាមវេលាណា ក៏ឲ្យពួកវាចាំធ្វើកលសឹក
ទាងក្នុង ហើយឲ្យចាត់ទាហានទៅច្បាំងបញ្ជោត បើគួនអ៊ីដេញចេញ
មកដល់ក្រៅស្រុកហើយ ត្រូវឲ្យទាហានដែលពួនបង្កប់ទាំងសងទាងផ្ទូវ
នោះព័ទ្ធទុកឲ្យជាប់ រួចសឹមប្រើអ្នកមានជម្រៃប្រាជ្ញាទៅនិយាយបញ្ចុះ
បញ្ចូល ឃើញថាគួនអ៊ីនឹងព្រមចំណុះយើងដោយងាយ ។ ចូធូយល់
ត្រូវជូចគំនិតខ្ទួន ក៏ឲ្យហៅរកទាហានឡៅពីដែលចាប់ទុកបានប្រហែល
៤០ នាក់នោះមកដល់ចូធូ។ ក៏ឲ្យបំណាច់រង្វាន់ត្រប់គ្នាជាច្រើន រួច
បង្គាប់បញ្ជាតាមពាក្យផៀយ៉ុកថាត្រប់ប្រការ ។ ទាហានទាំងនោះក៏
ចូលទៅរកគួនអ៊ីក្នុងស្រុកហែហ្ទឹ ហើយប្រាប់គួនអ៊ីថា យើងខ្ញុំទាំងអស់
គ្នាបានរត់រួចមកពីក្នុងកងទ័ពចូធូ ។ គួនអ៊ីព្ទហើយក៏គ្មានចិត្តគិតសង្ស័យ
យកទាហានទាំងនោះប្រើប្រាស់តាមត្រូវការ ។

លុះពេលយប់យាម ៣ ចូធូប្រើហែហ្ជុនលើកទាហាន ៥ ពាន់ជា
កងពួនបង្កប់ ហើយបង្គាប់ស៊ីឡុងនឹងទៅធូថា បើគួនអ៊ីដេញហែហ្ជុនុន
ចេញមក ឲ្យអ្នកឯងរាល់គ្នាលើកទាហានចាំស្ការត់គួនអ៊ីទុកកុំឲ្យវិលទៅ
ក្រោយបាន ត្រូវឲ្យតច្បាំងការពារឲ្យល្មមតែកំឡាំងទាំងសងទាងហើយ
កុំធ្វើគួនអ៊ីឲ្យមានសេចក្តីអន្តរាយឡើយ ។ ទាហានទាំង ៣ នាយទទួល
បង្គាប់ហើយក៏លើកទ័ពតម្រង់ទៅស្រុកហែហ្ទឹទាំងយប់នោះ ។ ចូធូក៏
លើកទាហានតាមទៅតាំងនៅពីចម្ងាយ ហែហ្ជុនុនក៏លើកទាហានចូលទៅ
ជិតកំពែងស្រុកហែហ្ទឹ ។ គួនអ៊ីក្រឡេកឃើញកងទ័ពមកតាំងនៅផ្ទាប់
កំពែងជូច្នោះ ក៏សម្ងំមិនបានចេញតតាំងត្រាន់តែប្រើទាហានឲ្យឡើង

រក្សាសែនបន្ទាយដុំវិញ ។ ហៃហ្គុនមិនយើញគួនអ៊ូចេញមកច្បាំង
កំប្រើកូនតាហានទៅស្រែកដេរគួនអ៊ូជាពាក្យទ្រគោះអសុរសុផ្សង ។ ។
គួនអ៊ូឮដូច្នោះក៏ខឹងខ្លាំងណាស់ ទើបប្រមូលតាហានបាន ៣ ពាន់ ចេីក
ទ្វារស្រែកចេញតច្បាំងនឹងហៃហ្គុនបាន ១០ ភ្លេង ។ ហៃហ្គុនភ្លែង
ធ្វើជាចាញ់សេះថយរត់ គួនអ៊ូមិនដឹងកល១ចាយក៏បំផាយសេះដេញ
តាមទៅចម្ងាយប្រហែល ២.០០០ សិន (៨ គ.ម.) គួនអ៊ូក៏ត្រឡប់ចិត្ត
គិតឃើញថា មុខជាតាហានចូធូនឹងលេីកចូលទៅក្នុងស្រុកហៃហ្វឺ, ក៏នាំ
តាហានត្រឡប់ទៅក្រោយវិញ ។ - ខ្ញុលឮសំឡេងផាវពីសងខាងផ្លូវ
គួនអ៊ូក្រែកភ្នែកមើលទៅឃើញទៅធូនឹងស៊ុឡុង លេីកតាហានចេញមក
ស្លាក់ពីមុខតាំងខាងមុខនឹងខាងស្តាំ ។ គួនអ៊ូក៏បរសេះចូលតយុទ្ធជាពន្លឺក,
ទៅធូនឹងស៊ុឡុងក៏ខ្ញុលតទល់តាំងសងខាង គួនអ៊ូគេចត្រឡប់ដំរង់ចូល
ទៅក្នុងស្រុក ប្រទះនឹងហៃហ្គុនលេីកតាហានមកស្លាក់ពីមុខ ស៊ុឡុង
នឹងទៅធូ ក៏ដេញជិតពីក្រោយ គួនអ៊ូងាកមកឃើញ ក៏ពតតាំងមុខនឹង
ក្រោយវិលដុំវិញខ្លួន ព្រួញធ្នូបាញ់ចម្រុះចំពោះទៅលើខ្លួនគួនអ៊ូ។ ក៏យក
ជាវកាច់ការព្រួញមិនឲ្យរត់ចូលដល់ខ្លួនបាន នឹងងាកទៅចូលស្រុកក៏មិន
រួច ងាកគេចទៅខាងឆ្វេងខាងស្តាំក៏មិនបាន តាហានចូធូចេះតែព្រួត
ថែមចូលមកទៀតដុំវិញខ្លួន គិតតែច្បាំងតគ្នាទៅពីនោះគាំងពីព្រលឹម
រហូតដល់ព្រលប់ គួនអ៊ូអស់កំឡាំងណាស់ ក៏នាំតាហានពានំលាយ
កងទ័ពចូធូរត់ទៅដល់ដើងភ្នំ១ ក៏ឡើងទៅឈប់សម្រាកនៅលើភ្នំនោះ ។
ហៃហ្គុន, ស៊ុឡុង, ទៅធូ ក៏លេីកតាហានដេញតាមទៅសំដៅដល់

ដើងកុំ ហើយរាយគាហានឡោមព័ទ្ធជុំវិញកុំនោះ ។ ឯគាហានឡៅពី
ដែលចូលទៅរកគួនអ៊ីនោះ លុះដល់ពេលព្រលប់មិនបានឃើញគួនអ៊ី
វិលត្រឡប់ចូលទៅស្រុកវិញ ក៏នាំគ្នាបើកទ្វារចេញបំណងនឹងទទួល
ចូធូ ។ ប៉ះរើសេះឃើញដូច្នោះ ក៏នាំយកសេចក្តីទៅជំរាបចូធូៗបានដឹង
ដូច្នោះហើយ ក៏មានសេចក្តីត្រេកអរណាស់ លើកពលយោធាចូល
ទៅកូងស្រុកហេហ្វ៉ ហើយឲ្យយកក្ងើងដុតស្រុកនោះធេះឡើង ប្រាថ្នា
ដើម្បីនឹងឲ្យគួនអ៊ីតូចចិត្ត ទើបបង្គាប់ពលទាហានដែលស្មិទ្ធឲ្យទៅរាំង
រក្សាត្រួសារបស់ឡៅពីទុកឲ្យល្អ ហើយចូធូក៏ត្រឡប់មកលើកទាហាន
ណូនចូលទៅបោមព័ទ្ធគួនអ៊ីថែមទៀត ។ គួនអ៊ីឃើញពន្ធឹក្ងើងធេះឡើង
កណ្តាលស្រុក ក៏នឹកតក់ស្ងុតរន្ធត់ចិត្តគិតដល់កវិយាបុត្រឡៅពី ទើប
លើកទាហានចុះមកដល់ដើងកុំ ។ ទាហានចូធូក៏រាស្ថាក់ពីមុខណែនណាន់
នឹងចេញមកមិនបាន ។ គួនអ៊ីក៏វិលត្រឡប់ឡើងទៅលើកុំរួចចុះមកវិញ
ជាច្រើនសា លុះព្រឹកឡើងគួអ៊ីនក៏ដិះសេះនាំទាហានចុះទៅម្ពងទៀត
ទទួលក្រឡេកទៅឃើញតៀវលៀវដិះសេះកាន់ទួនឡើងមក គួនអ៊ីក៏
ស្រែកស្ងរថា អ្នកឯងមកច្បាំងនឹងយើងឬ? ។ តៀវលៀវតបថា
" ខ្ញុំមិនមែនមកច្បាំងនឹងអ្នកទេ . ដែលខ្ញុំឡើងមកនេះប្រាថ្នានឹងមកតប
ស្នងសងគុណអ្នក " ហើយតៀវលៀវក៏លោតចុះពីលើសេះបោះលំពែង
ចេញពីដៃ ចូលទៅគំនាប់គួនអ៊ីៗ ឃើញដូច្នោះក៏ចុះពីសេះមកគំនាប់
តៀវលៀវវិញ ហើយស្ងរសាកតៀវលៀវថា ចូធូប្រើអ្នកឯងមកល្ឈូង
ល្ឈងលោមយើងឬ? ។ តៀវលៀវតបថា " កាលត្រាមុនអ្នកបានជួយ

ដោះទុក្ខឲ្យខ្ញុំរួចអាយុជីវិតម្តងហើយ ត្រានេះយើញថាអ្នកមានទុក្ខជាពន្ធឹកវិញ ខ្ញុំក៏ខំទស្សាហ៍ឡើងមកជួប ដើម្បីនឹងជួយដោះទុក្ខអ្នកជាផ្ទូវកតវេទីតបស្នងសងគុណអ្នក ។ គួនអ៊ីស្សរថា បើអ្នកឯងគិតជល់គុណ្ឯបការរបស់យើង ហើយឡើងមកជួយជាកំឡាំងយើងៗ ក៏ទទួលអរគុណណាស់ ។ តៀវលៀវថា មិនមែនជូច្នោះទេ ។ គួនអ៊ីថា អ្នកឯងថាមិនមែនមកល្ឈួងលួងលោម ហើយថានឹងមកជួយកម្ចាំងក៏មិនមែនទៀត តើដែលឡើងមកនេះដើម្បីប្រយោជន៍អ្វី? ។ តៀវលៀវតបថា ខ្ញុនអ្នកនឹងឡៅពី តៀវហ៊ុយមានសេចក្តីស្រឡាញ់គ្នាស្មើអាយុជីវិតទៅវិញទៅមក ឥឡូវឡៅពីនឹងតៀវហ៊ុយបែកនិរាស្ត្រគ្នាទៅហើយ អ្នកក៏មិនជឹងជំណឹងជារស់ឬស្ទាប់ កាលពីយប់មិញមហាទបរាជលើកកងទ័ពទៅវាយយកស្រុកហែហ្ទីបានហើយ បានទាំងចាត់ប្រើទាហានឲ្យទៅពិតក្តិរក្សាត្រួសារឡៅពី មិនឲ្យនរណាទៅបៀតបៀន ហាមមិនឲ្យធ្វើទុក្ខបុកម្នេញអាណាប្រជានុរាស្ត្រក្នុងស្រុកឲ្យនៅជាសុខក្សេមក្សាន្ត ខ្ញុំយល់យើញថា មហាទបរាជមានចិត្តមេត្តាចងស្ពានមេត្រីនឹងអ្នកជល់ទីនេះ បានជាខ្ញុំនាំហេតុជូច្នេះមកជំរាបអ្នកឲ្យជ្រាប ។

គួនអ៊ីបានស្តាប់ក៏ខឹងណាស់ និយាយនឹងតៀវលៀវថា ពីដើមអ្នកឯងប្រាប់យើងថា ខ្ញុនមិនមែនមកនិយាយល្ឈួងលួងលោមយើងទេ ឥឡូវហេតុម្តេចបានជាខ្ញុនមកនិយាយជូច្នេះ បើមិនមែនជាពាក្យល្ឈួងលួងលោមទេ តើសំដីនេះនឹងប្រាថ្នាប្រយោជន៍អ្វី? ឯខ្ញុនយើងដែលធ្ទាក់មកនៅទីនេះជាទីទាល់ចង្អៀតពិតហើយ តែយើងនឹងដាកមុខទៅចូលនឹង

នរណាគ្រៀតពីឡៅពីនោះ អ្នកកុំបីសង្ស័យឡើយ ខ្ញុំនៅមិនមែនស្រឡាញ់ដំរីតប៉ុន្មានទេ ព្រោះសេចក្តីស្ងប់ចុបមាដូចគេដេកលក់ ហេតុនេះចូរអ្នកវិលទៅច្បាប់ចូរចុះ ថាឲ្យតែមពលទាហានទុកឲ្យត្រមុះវេលានេះយើងចុះទៅច្បាំងតែតែអស់កម្លាំងស្ងប់កណ្តាលរឿនឆ្គួលណ៎ ។

គ្រៀវលៀវបានស្តាប់ក៏អស់សំណើចហើយនិយាយថា ដែលអ្នកមានប្រសាសន៍ដូច្នេះ ទោសនឹងមានដល់ខ្លួនអ្នក ៣ ប្រការ មនុស្សនានានឹងតវោនិន្ទាអ្នកបាន ។ គួនអ៊ូថា ខ្ញុំនៅយើងកាន់សេចក្តីសត្យានុសត្យពិតត្រង់ បានបង់ពាក្យទុកមកហើយថា ទោះបីដល់ខ្ញុំវិសេចក្តីស្ងប់ក៏មិនត្រឡប់ចូលទៅនៅនរណាគ្រៀតពីរូបឡៅពីតែមួយ ដែលអ្នកឯងថាយើងនឹងមានទោស ៣ ប្រការនោះ ដោយហេតុអ្វីខ្លះ? ។ គ្រៀវលៀវឆ្លើយថា "ពីដើមខ្លួនអ្នកនឹងឡៅពីគ្រៀវហ៊ុយបានចូលស្បថស្បានរួមចិត្តជំរិតមួយនឹងគ្នាជាបងប្អូន ថាបើនរណាស្ងប់ក៏ត្រូវស្ងប់ជាមួយគ្នា គ្រានេះឡៅពីនឹងគ្រៀវហ៊ុយបែកនិកសគ្នាទៅហើយ អ្នកក៏មិនបានដឹងជាវស់ប្តូស្ងប់ ឥឡូវទាហានបេស់អ្នកក៏តិចណាស់ ដែលនឹងនាំចុះទៅតតាំងច្បាំងគ្នានោះ បើអ្នកអន្តរាយដល់ជីវិតហើយ ខាងឡៅពីគ្រៀវហ៊ុយគង់ជីវិតរស់នៅ ទឹងស្មើងមករកអ្នកច្បាច្បាទឹងជួយអ្នកគិតការតទៅ ឥឡូវបើអ្នកស្ងប់ទៅហើយ ឡៅពី គ្រៀវហ៊ុយក៏ទឹងស្ងប់តាមទៅផង នោះពាក្យដែលអ្នកបានសច្ចាស្បថស្បានទឹងគ្នា មិនបង់អសារសំត្យទៅទេឬ, មនុស្សទាំងឡាយបានដឹងក៏ទឹងដៀលថា អ្នកគិតខុសព្រោះឥតច្បាប្រការ ១ ។

ប្រការមួយទៀត ទៅពីទុកចិត្តលើអ្នកថា អ្នកជាមនុស្សល្អបរិសុទ្ធ ចានជាប្រគល់កិរិយាបុត្រឲ្យអ្នកពិកភ្ជាក្សា បើអ្នកធ្វើឲ្យអាត្មាឯងស្ងាប់អស់រៅហើយ មាននរណាទៅយទឹងទុកបំរុងកិរិយាបុត្រទៅពីខាងឲ្យដូចខ្លួន សូម្បីបុត្រកិរិយាទៅពីនោះសោតក៏មានរំពឹងតែលើខ្លួនអ្នកហាក់បីដូចជាដៃដើងសម្រាប់ខ្លួន បើអស់ពីអ្នករៅហើយ អន្តរាយផ្សេងៗក៏គង់នឹងមាន, ការដែលទៅពីសន្និដ្ឋានទុកចិត្តអ្នកនោះ ក៏នឹងមិនបង់អស់រៅឬ? ខ្ញុំយល់ឃើញមិនសមគួរ នេះជាប្រការទី ២ ។

ប្រការទី ៣ ខ្លួនអ្នកល្ប៉ិច្ចីដៃខ្ជាំងពូកែ ខាំងចេះដឹងធំទៀមទម្ងន់ប្រាណមកក៏ច្រើន ហេតុម្តេចអ្នកមិនរក្សាជីវិតរបស់ខ្លួនទុកចាំទៅពី នឹងចានជួយគាគិតការទុកបំរុងផែនដីឲ្យបានសេចក្តីសុខក្សេមក្សាន្តរៅឯមុខ ទោះប៉ីខ្លួនអ្នកមកជ្លាក់លើសេចក្តីព្រួយទុក្ខលំបាកប៉ុន្មាន ក៏ជាគ្រោះកាចរកល់ប្រាណ ឧបមាដូចជាដើរលុយឆ្លងលើគំនរក្តើងដែលកំពុងឆេះ ពុំនោះសោតឧបមាដូចគេហែលឆ្លងមហាសមុទ្រដ៏ធំជ្រៅពន្ធឹក ត្រូវតែគិតនឹករកឧបាយនឹងទុកឆ្លងទៅឲ្យរួចបាន ដើម្បីឲ្យមានកេរ្តិ៍ឈ្មោះថាជាមនុស្សមានប្រាជ្ញាចេះរក្សាជីវិតឲ្យគង់នៅ ទើបពេញត្រូវជាជាតិតាហានមានចិត្តសុចរិតទៀតត្រង់នឹងផែនដី ដែលអ្នកស្រែដីកាន់យកមានះ ហើយចុះទៅច្បាំងតតាំងនឹងពលតាហានចូលដ៏ច្រើនលើសលុប អ្នកត្រូវដឹងថាមានតែបរាជ័យ ទោះបីជីវិតអ្នកមិនស្ងាប់គ្រានេះ ក៏នឹងសូន្យឈ្មោះមិនល្បីឮតទៅថាជាអ្នកគិតត្រូវនោះឡើយ ខ្ញុំយល់ឃើញដូច្នេះហើយទើបថា អ្នកនឹងមានទោស ៣ ប្រការយ៉ាងនេះ” ។

(មានត)

ជំណឹងតាមឧស្សល់ក្នុងកាន្តារ:

លោកផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(ភមក)

នាយពាហាន សំឡឹងលោកតាកាអ៊ុងមួយស្របក់ រួចបែរទៅ មីលអ៊ីស្នាអ៊ីលនឹងមុក្តារ ទើបវិលបែរមកចំលោកតាអៃយ៉ាងវិញ ហើយសួរថា

– តើ នៅបណ្តាអ្នកបំរើលោក មានអ្នកណាឈ្នោះតាឡិបដែរ ?

លោកតាកាអ៊ុងមានទឹកមុខរំភើបបន្តិច តែការរំភើបនេះ មានតែអ៊ីស្នាអ៊ីលទេដែលអាចយល់ ។

– អាដែងដែលនាំលោកមកហឹងហើយ ឈ្នោះតាឡិប ។

ខណៈនោះ តាឡិបដែលឈរក្បែរគៅអី ខំប្របៀតខ្ជនទៅខាងក្រោយសសរបម្រុងនឹងឆយទៅរកឡារ ប៉ុន្តែនាយពាហានសំឡឹងតាត់មិនដាក់ក្នែកនឹកស្មានដឹងបំណងរបស់គាត់ ហើយហៅឲ្យចូលមកជិតដោយអាការគំរាម:

– ចុះអាដែងហ្នឹងទៅធ្វើអីឯផ្ទះរស្យីម ពីម្យៀលមិញ?

លោកតាអៃយ៉ាងធ្វើយថា:

– យើងមិនដឹងទេ ។

ខណៈនោះ នាយពាហានបែរទៅសួរតាឡិបថា:

– ឯងទៅធ្វើអី នៅផ្ទះរស្យីមពីម្យៀលមិញ ធ្វើយ?

តាឡិបបុកពោះ ធ្វើអឹមអៀម ចេះតែមួលក្រពេះក្ងក់ចុះឡើងក្នុងដៃរួចលុតជង្គង់ស្រ៊ុប ហើយនិយាយថា:

- ខ្ញុំក្សត់ចៅហ្វាយរបស់ខ្ញុំ! ខ្ញុំបានសន្យានឹងលោករស្សីមថានឹងនាំនាងឡីឡាយកទៅជូនលោក ។

នាយទាហានសួរទៀតថា:

- ចូរនាំខ្ញុំទៅរកនាងឡីឡានោះ!

លោកតាអៃយ៉ាជនិយាយថា:

- លោកតាមខ្ញុំមក ។

ជនទាំងពីរដើរតាមរបៀងក្រាលសុទ្ធ់ឥដ្ឋកម្រាល រួចបានជល់នៅមុខទ្វារឈើមួយ ចម្រឹងមាស គឺជាកន្ទែងនៃក្រុមនារីទាំងឡាយ ។

ចម្រៀងស្លួយស្រែះ បើកបទរាយទំនុកជដែលៗ យ៉ាងពីរោះគួរឲ្យស្រដៅចចិត្ត បើអ្នកណាព្ធហើយ គេថាទីនោះជាកន្ទែងនិរទុក្ខ ។

លោកតាកាអ៊ុជស្រែកតាមទ្វារ ព្រោះអ្នកចំឡែកមិនត្រូវចូលក្នុងស្ទែងក្រុមស្រីក្រមុំរបស់លោកឡើយ លោកស្រែកហៅថា:

- ឡីឡា!

សូរចម្រៀងបាត់ឈឹង គេព្ធសូរស្បែកជើងឈើដើរលើកម្រាលឥដ្ឋ ព្ធសូររហូតមកជល់រនុកទ្វារ រួចឃើញនាងឡីឡាចេញមក ។ នាងឈរដោយស្ទន់មួយស្របក់នៅពីខាងមុខនាយទាហានទួរគី ។ ប៉ុន្តែទឹកមុខអ៊ុស្មាអ៊ីលពេញដោយមេត្តា ធ្វើឲ្យនាងមានសេចក្តីទុកចិត្ត នឹងសេចក្តីក្លាហានបន្តិចឡើងវិញ ។

លោកអនុសេនីយ៍ឯកស្ងរថា:

— នាងនេះត្រូវជាអ្វី?

លោកតាអៃយ៉ាដធ្វើយដោយសំដីយ៉ាងម្ចឹងម៉ាត់ថា:

— នាងឡើឡាជានារីក្នុងកុលសម្ពន្ធនៃលោកតាម៉ាត្រុក អៃលយ៉ាដី ។ រាមកនៅក្នុងទីនេះ តាំងពីប៉ុន្មានថ្ងៃមកហើយ ។

នាយទាហានតួរតីបាប់ថា

— បានហើយ!

រួចនាយទាហានស្ងរទៀតដោយសំឡឹងចំទៅនាងត្រមុំថា:

— តើនាងឯងមានការណ៍ទាក់ទងជាមួយនឹងរស្សីមបេនអាប់ជាឡេ: ដូចម្តេច?

នាងឡើឡាមើលចំពោះលោកអនុសនីយ៍ឯក ហើយធ្វើយដោយសំដីឥតតាន់ថា:

— ខ្ញុំសូមស្បថចំពោះនាមត្រះអាឡស់ គឺឈ្មោះរស្សិមប្រាថ្នាកំហែងចាប់ខ្ជួនខ្ញុំម្ចាស់ ។ លោកនេះបានរកចាប់ខ្ជួនខ្ញុំ តាំងពីកាលដែលខ្ញុំនៅក្នុងកុលសម្ពន្ធរបស់ខ្ញុំឯណោះ ។

នាយទាហានធ្វើដូចជាជញ្ជឹងមួយសន្ទុះ ។ ក្នែកលោកលួចមើលអ៊ីស្មាអ៊ីលហើយឃើញកូនលោកតាកាអ៊ីដ នឹងនាងឡើឡាចេះតែសំឡឹងគ្នាទៅវិញទៅមក ។ ហេកនិកថាដំលោះដែលកើតឡើងរវាងជនទាំងពីរ ប្រាកដជាដំលោះពីកាមគុណ ។ រស្សីមដែលស្ងាប់គឺប្រហែលគ្រាន់តែទទួលបាបគ្រោះអំពីការចំណង់ផងខ្ជួនឯងទេដឹង? ប៉ុន្តែ លោក

រក្សាយោបល់នេះទុកក្នុងចិត្ត ដើម្បីយកទៅជំរាបចៅហ្វាយលោកជាមុន
សិន ។

នាយទាហានឧនគំនាប់លោកតាកាអ៊ីដ ហើយនិយាយថា:

— ខ្ញុំអរគុណនឹងលោកពេក ព្រមទាំងសប្បាយចិត្តដោយយក
ចម្លើយបានត្រឹមត្រូវតាមច្បាប់ នៅក្នុងទីនេះ ។

លោកតាកាអ៊ីដនឹងកូនប្រុសទាំងពីរ នាំគ្នាជូនដំណើរលោក
អនុសេនីយ៍ឯកដល់មាត់ទ្វាររៗង រួចលោកតាអៃយ៉ាដហៅតាឡិបមក ។
តាឡិបមកដល់ លោកតាអៃយ៉ាដងាកទៅរកកូនច្បងហើយនិយាយថា:

— ត្រូវតែតាឡិបថយចេញពីទីនេះ!

ត្រែកនៃលាកុដិក ជោរជន់ដោយទឹកនេត្រ ប៉ុន្តែតាត់ដឹងថា
ចៅហ្វាយនាយដែលផ្ទើជូច្នេះ មកពីចង់បញ្ជៀស បង់រាងទុក្ខធ្ងន់កុំឲ្យ
កើតឡើង ។ តាមពិត ជាតិតួរគីមិនមែនធោតឡើយ ហើយប្រសិនបើ
គេមិនត្រូវការឲ្យបញ្ជេញអនុមតិ ដោយហោច គង់តែត្រូវផ្ទើឲ្យគេ
សុខចិត្តដើម្បីការពារទូវសេចក្តីសងសឹក ។ ករណីនេះ តាឡិបយល់
ទាំងអស់ ហើយតាត់ឧនឧបជង្គង់លោកតាអៃយ៉ាដទាំងយំ រួចនិយាយថា:

— សូមឲ្យការស្ម៉ត្រូវបស់នាយចៅហ្វាយសម្រេចជូចក្តីប៉ុនប៉ង ។ លុះ
ក្រោកឡើងវិញ តាត់ដើរទៅឯក្រោលសេះដើម្បីរៀបចំបង្ខេចខោអាវ ។

* * *

នៅទីនោះ ត្រង់ផុងដែលក្នុងរាត្រីតាត់តែងយកស្មៅក្ងិនប្រហើរដាក់
ឲ្យសត្វស៊ីនឹងត្រង់រង្វាល់ស្មៅនៅមុខក្រោល ដែលសត្វក្រោកឡើងកាល

ណា គាត់ពុស្ទ្ធរដើងដើរលើកម្រាលថ្ងើមថ្ម គាឡិបដូចជាស្ទុតចិត្តរកកម្ចាំងនឹងធ្ងើអ្ងីពុំកើត ។ គាត់ទានបានយើញសេះទាំងនោះហើយ គឺជាសត្វដែលគាត់ទុកដូចជាមិត្រភ័ក្តិ សម្រាប់គាត់សម្តែងសេចក្តីរីករាយ នឹងសេចក្តីទុក្ខប្រាប់ ហើយចួនកាលសត្វអស់នោះសំឡឹងមើលគាត់វិញដូចជាមនុស្សភាព ។ រួចគាត់យំដូចក្មេងដោយសេចក្តីរលឹក ។

មានដែមួយមកស្ទាបស្មាគាត់ដោយមិត្តភាព គឺជាអ៊ីស្មាអ៊ីលដែលនិយាយជាក់ត្រចៀកគាត់ថា:

– គាឡិប គាឯងកុំទៅអី ។ ខ្ញុំមិនចង់ឲ្យគាទទួលនូវទម្ងន់នៃសេចក្តីទុក្ខ, ខ្ញុំទេតើ ដែលត្រូវទទួលទុសត្រូវតែម្នាក់ឯង ។

លាកុដិកដើបមើលអ៊ីស្មាអ៊ីល ហើយនិយាយថា:

– អ្នកទទួលទុសត្រូវ មានតែម្នាក់ឯងទេ គឺចោរនឹងអាក្សត់ដែលចង់ធក់យកស្ត្រីជាទីគាប់ចិត្តពីម្ចាស់របស់ខ្ញុំ ឥឡូវគេយកជីវិតប្តូរជួសកំហុសរួចហើយ សូមឲ្យសន្តិសុខនៃព្រះអាឡស់ស្ថិតនៅជាមួយនឹងគេក្នុងកន្ទែងសម្រាកដ៏ចិរកាលនេះទៅចុះ ។ បពិត្រចៅហ្វាយ, ខ្ញុំត្រូវតែចេញទៅ, លោកគាជាឡពុកចៅហ្វាយមានប្រសាសន៍ត្រូវណាស់ ។ បើខ្ញុំនៅសេចក្តីវិនាសនឹងកើតមានដល់អ្នកទាំងអស់ ។ ណ្ហើយ! ចៅហ្វាយសូមចៅហ្វាយឲ្យតែកាំក្ងើងមួយនឹងអូដ្ឋមួយមកខ្ញុំ បានហើយ ។

អ៊ីស្មាអ៊ីល ចាប់ឧបដៃគត្រាតរបស់គាឡិប ហើយនិយាយទាំងទឹកក្នែកថា:

– គាឡិប នែគាឡិបសំឡាញ់! គាវើសយកអូដ្ឋណាដែលគាប់ចិត្ត

ក្នុងគ្រោលចុះ ចំណែកអារុធក៏តាវើសយកអាណាថ្នីមួយដែរចុះ ។ ហ៉ យកប្រាក់មួយស្សោងនេះទៅផង ។ រួចអ៊ីស្នាអ៊ីលហុចប្រាក់មាសមួយ ស្សោងឲ្យទៅ ព្រោះគេដឹងថា ប្រាក់មួយស្សោងដែលរស្សីមឲ្យពីយប់ មុននេះ តាឲ្យិបទម្ងាក់ចោលទៅក្នុងអណ្ណូងទឹកហើយ ។

ដិណ្ណាលាកុដិកមិនព្រមទទួលយក អ៊ីស្នាអ៊ីលចេះតែជាក់ទាំងបង្ខំទៅ ក្នុងហោប៉ៅខ្សែក្រវាត់ឲ្យ ទើបគេទបតាឲ្យិបនឹងទ្រូងហើយឲ្យពរថា:

— សូមព្រះអាឲ្យស់តាមរក្សាតាជានិច្ចកាលកុំបីឃ្ងាតឡើយ!

មុនព្រះអាទិត្យអស្តង្គត តាឲ្យិបផ្ទើដំណើរចេញទៅ តាមផ្ទូវ កន្ទារៈកណ្ណាលវាលផ្ទូកខ្សាច់ ។

*

* *

កាលដែលរឿងហេតុទាំងនេះ កំពុងប្រព្រឹត្តទៅក្នុងផ្ទះអ៊ីស្នាអ៊ីល លោកអនុសេនីយ៍ឯកអញ្ជើញទៅសុំជួបនឹងររសេនីយ៍ត្រីរបស់លោក ។ លោកមេទ័ពនេះគិតឃើញថា ការល្អត្រូវតែប្រជុំអស់នាយទាហានទាំង ប៉ុន្មានដើម្បីស្តាប់សេចក្តីរាយការណ៍របស់លោកសក្តិបី ។

ពួកនាយទាហានទាំងអស់ក៏នាំគ្នាមកតាមសេចក្តីអញ្ជើញរបស់នាយ ចៅហ្ងាយខ្ទួន គឺជាមហាសន្និបាតមួយដែលតាំងឡើងនៅជុំវិញតុមួយ ក្រាលកម្រាលបៃតង មានកំប៉ុងបារីនឹងកែវសុរាជាក់ពីលើ ដ្យិតថានាយ ទាហានអស់នេះ ពិតមែនជាអ្នកមានអារុធលើកឡើងដើម្បីតយុទ្ធនឹងពួក ទ្មិល ក៏មិនមែនជាជនស្អប់ខ្ពើមសម្បត្តិក្នុងលោកនេះឡើយ នឹងជាជន មិនមែនជាមិនត្រូវការនឹងរសជាតិសុរាឡើយ ។

លុះជួបជុំគ្នាស្រេចហើយ លោកអនុសេនីយ៍ឯក ត្រូវគេអញ្ជើញឲ្យអធិប្បាយ ។

លោកនេះ បាននិយាយរៀបរាប់ ពីដំណើរយ៉ាងម្តេចដែលលោកបានយល់ថា ឈ្មោះតាឲ្យិបមានការទាក់ទងរកគ្នាជាមួយនឹងរស្យីម, យ៉ាងជួចម្តេចដែលនៅក្នុងផ្ទះលោកតាអៃយ៉ាង, លោកបានធ្វើឲ្យយើញច្បាស់នូវការណ៍សមគំនិតគ្នារវាងអ៊ីស្មាអ៊ីលនឹងនាងឲ្យីឲ្យា នាងនេះហើយជាមូលហេតុ ដើម្បីចានឧក្រិដ្ឋទោសនយោបាយ ការបំបែកបំបាក់សម្ពន្ធ-មិត្រដ៏ស្មោះស្ម័ត្រវបស់ឆូរគី ទៅលើការសងសឹកប៉ែកខាងកាមរាតវិញ ប្រហែល លោកអនុសេនីយ៍ឯកសម្រេចសេចក្តីខាងចុងថា:

– ហ្នឹងហើយជាយោបល់របស់ខ្ញុំបាទ ។ បើតាមការយល់ដោយច្បាស់លាស់ ខ្ញុំជឿថា អ៊ីស្មាអ៊ីលបេន-អៃយ៉ាង នឹងអាចឲ្យដំណឹងយ៉ាងជាក់ច្បាស់ដល់យើង អំពីមរណភាពនៃរស្យីម ព្រោះខ្ញុំចូលចិត្តថា គឺគេហ្នឹងហើយត្រូវជាអ្នកមានទោស ។

លុះបានអធិប្បាយចប់សព្វគ្រប់កាលណា លោកអនុសេនីយ៍ឯកអង្គុយចុះ ហើយលើកស្រាពិសាមួយកែវ ។

រហសភាពយ៉ាងធ្ងន់សង្កត់ពីលើពួកអ្នកស្តាប់ទាំងអស់ ព្រោះរឿងនេះ ជាកិច្ចដ៏សុខុមពេក ។

លោកវរសេនីយ៍ត្រីតិតជញ្ជឹងមួយស្របក់ធំ ព្រោះលោកជាទាហានម្នាក់ដែលមានចរិតមិនធេវធាវ ។ ពួកនាយទាហានទាំងឲ្យាយត្រាំចាំយ៉ាងយូរនូវសេចក្តីសម្រេចដែលលោកត្រូវលើកឲ្យើងកាន់ការណ៍ ។

រឿងនេះប៉ះទៅលើក្រលៀតនៃប្រាជ្ញា ហើយការឈ្វាសវៃនៃជាតិ
ត្លូវតែក៏ធ្វើឲ្យមានបាតុកម្មឡើងម្តងទៀត ។

លោកវរសេនីយ៍ត្រីចាប់និយាយថា:

- រាធនកម្មចំពោះលើកូនលោកតាកាអ៊ីដ នឹងអាចបណ្តាលឲ្យកើត
មានការចលាចលយ៉ាងធំក្នុងស្រុក ។ ត្រូវយើងប្រើឧបាយកលយ៉ាងដូច-
ម្តេចឲ្យស្លូលទើបត្លូវ ។ តើអស់លោកត្រូវគិតដូចម្តេចអំពីរឿងនេះ? ។

រួចលោកថ្ងៃងសេចក្តីព្រាងតាមដែលលោកចូលចិត្ត ដើម្បីរលាស់
អ៊ីស្មាអ៊ីលឲ្យខ្ជាតចេញទៅឆ្ងាយ ដោយយករឿងកិត្តិយសខាងចម្បាំងមក
ប្រើ ប្រាប់ចំពោះនាយទាហានរបស់លោកទាំងអស់ ។

* * *

ពេលព្រលប់ហើយ ។ នៅក្នុងបន្ទប់នាងឡីឡា ដៃទាំងពីររបស់
អ៊ីស្មាអ៊ីលចាប់ឧបក្រសោបតូសង្សារ ។ ចុងថនាស្លូចដូចបុប្ជាទើបនឹង
ក្រពុំទុលពីក្នុងអាវសារូយ៉ាងស្តើង ។ បបូរមាត់នឹងបបូរមាត់ជក់ជាប់គ្នា ។

- ឧ អ្នកបងសំឡាញ់ !

- ឧ កែវព្រលឹងថ្ងៃ !

- កុំទៅណាចោលខ្ញុំ ណ៉ាបង ។ ខ្ញុំបានសុខដោយសារតែ
នៅជំតអ្នកបង ។

- បងស្រឡាញ់ប្អូនពេក ទុកស្មើជីវិត ។

* * *

(មានត)

រឿងបល្ស័ង្ពុធិព្យ សាមសិបពីររឿង

រឿងព្រេងតណ្ឌៀ

លោកសមិន ម្ហូត្យនជម:ពែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

និទាននៃរូបទេពនិម្មិតទី ៩

មានកាលមួយថ្ងៃ ព្រះមហាក្សត្រិយ៍ភោជ:ប្តេជ្ញាក្នុងព្រះរាជហ្ហូទ័យ ថានឹងយាងទៅតង់លើបល្ស័ង្ពទិព្យនោះ ដើម្បីនឹងទ្រង់ផ្ទើមុទ្ធាកិសេក ។ ពេលដែលទ្រង់យាងទៅដល់ រូបទេពនិម្មិតទី ៩ ក៏ក្រាបបង្គំទូលថា "ទ! ព្រះមហាក្សត្រិយ៍ភោជ:, សូមទ្រង់ព្រះសណ្ឌាប់, ស្តេចអង្គណាមួយមានគុណសម្បត្តិស្មើនឹងព្រះបាទវិក្រមាទិត្យ; ស្តេចអង្គនោះ ទើបអាចតង់លើបល្ស័ង្ពទិព្យនេះបាន" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ឌាប់ទេវរាចា របស់រូបទេពនិម្មិតទី ៩ ហើយក៏ទ្រង់សួរថា "តើគុណសម្បត្តិព្រះបាទវិក្រមាទិត្យ នោះយ៉ាងណាទ្ធះ?" ។

រូបទេពនិម្មិតនោះក៏ថ្ងៃងថា "សូមទ្រង់ព្រះសណ្ឌាប់, ព្រះបាទវិក្រមាទិត្យ ទ្រង់សោយរាជសម្បត្តិនៅនគរអវន្តី ។

មានយោគីម្នាក់មកដល់ទីក្រុងនោះ ហើយចូលទៅអង្គុយកណ្ឌាលព្រះរាជទ្យាន ។ យោគីនោះចេះដឹងសព្ទគ្មានសល់អ្វី, រាចារបស់

លោកក៏មានអានុភាពអស្ចារ្យ, លោកបានរួចផុតពីកណ្តាប់ដៃនៃតណ្ហា, លែងជាប់ចំពាក់នឹងរាគាទិកិលេសទាំងឡាយ ។ យោគីនោះ បើលោកពោលប្ដូបឆ្គាប់ទៅលើអ្នកណា បានជួចសេចក្តីប្រាថ្នា ។ ព្រះមហារាជទ្រង់បានជ្រាបសព្វគ្រប់នូវអានុភាពនៃយោគីនោះ ដោយមតិមហាជន, ទ្រង់គ្រាស់បឆ្គាប់ឲ្យបណ្ឌិតក្នុងក្រុមព្រះរាជទីប្រឹក្សា អញ្ជើញទៅហៅយោគីនោះឲ្យចូលមកគាល់ព្រះអង្គ ។ ពួកបណ្ឌិតក៏នាំព្រះរាជឧឆ្ការទៅជំរាបយោគីៗមិនព្រមមកហើយពោលតបមកវិញថា "មនុស្សដែលគ្មានកិលេសតណ្ហា ទុកស្ត្រីដែលមានរូបឆោមលោមពណ៌ស្រស់ជាងគេ ជាស្មៅមួយសរសៃ, ចំណែកអ្នកដែលគ្មានបាបអកុសល ទុកយម: (ព្រះយមរាជ) ជួចជាស្មៅមួយសរសៃ, ឯអ្នកដែលគ្មានលោភទុកស្តេចនឹងរាជសម្បត្តិជួចជាស្មៅមួយសរសៃដែរ" ។

ពួកបណ្ឌិតវិលត្រឡប់ទៅក្រាបបង្គំទូលមហារាជ តាមពាក្យដែលយោគីនេះពោល ។ ព្រះអង្គទ្រង់ព្រះសណ្ឌាប់ចប់សព្វគ្រប់ ក៏មានព្រះបន្ទូលថា "យោគីនេះពោលពាក្យពិតមែន, មានមនុស្សមកសូមព្រះអង្គ, ចូលគាល់ជិតព្រះអង្គ, នេះគឺយើងបានចាត់ឲ្យទៅអញ្ជើញយោគីនោះមកតែគាត់មិនមក, យើងសម្រេចថា យោគីនេះពោលពាក្យពិតប្រាកដមែន" ។

ដល់ទ្រង់ព្រះតម្រិះរួចស្រេច ទ្រង់ស្តេចយាងទៅកាន់សំណាក់យោគីនោះដោយព្រះអង្គឯង ។ យោគីកាលបានឃើញបុគ្គលមានគ្រឿងសំលៀកបំពាក់ជាស្តេចពេញយសហើយ ទុកជាបុគ្គលដ៏ប្រសើរ,

មានចិត្តសោមនស្សពន់ពេក ហើយក៏ថ្វាយចំពោះព្រះនរបតីនូវផ្លែឈើនៃទេវនិម្មិតមួយ ហើយក្រាបទូលថា "អ្នកណាបានបរិភោគផ្លែឈើនេះ អ្នកនោះលែងឈឺ, ចាស់, ស្លាប់ហើយ" ។

មហាពដទ្រង់ទទួលយកផ្លែឈើនោះហើយ ក៏វិលត្រឡប់មកកាន់ព្រះពដនិវេសនដ្ឋានវិញ ។ តែស្តេចយាងទៅតាមផ្លូវទ្រង់ជួបប្រទះនឹងបុគ្គលឈឺម្នាក់, ដោយទ្រង់អាណិតអាសូរដល់បុគ្គលនោះ ទ្រង់ក៏ព្រះពដទានផ្លែឈើនោះទៅអ្នកដែលមានជម្ងឺនោះ ។

រួបទេពនិម្មិតទី ៩ ក្រាបបង្គំទូលព្រះបាទកោដៈថា "បើទ្រង់មានគុណធម៌បែបនេះ ទ្រង់អាចគង់លើបល្ល័ង្កទិព្យនេះបាន" ។

ព្រះបាទកោដៈទ្រង់ឈ្វេងយល់សព្វគ្រប់ថា ទ្រង់មិនមានគុណធម៌បែបនេះឡើយ, ទ្រង់ក៏បែរព្រះឋិស្តង្គ (ខ្នង) យាងចេញទៅ ។

* * *

ឥទានដែរូបទេពនិម្មិតទី ๑๐

មានកាលមួយថ្ងៃ, ព្រះបាទកោដៈទ្រង់ស្តេចយាងចូលទៅដិតបល្ល័ង្កទិព្យ ដើម្បីនឹងធ្វើពិធីពដាភិសេក ។

រួបទេពនិម្មិតទី ๑๐ ក៏សើច ហើយក្រាបបង្គំទូលព្រះមហាក្សត្រិយ៍កោដៈថា "បពិត្រព្រះបាទកោដៈ ទ្រង់មិនមានសមត្ថភាពនឹងគង់លើបល្ល័ង្កទិព្យនេះបានទេ, មានតែមហាពដមួយអង្គទ្រង់ព្រះនាមព្រះបាទវិក្រមាទិត្យ ទើបទ្រង់គង់បាន" ។

ព្រះបាទកោជៈទ្រង់មានព្រះបន្ទូលសួររូបទេពនិម្មិតថា "អ្នកណាជាមហាវជិក្រមាទិត្យ? ។ រូបទេពនិម្មិតទី ១០ ដល់បានស្តាប់នូវបន្ទូលព្រះបាទកោជៈសព្វគ្រប់ហើយ ទើបមានទេវវាចាថា "សូមទ្រង់ព្រះសណ្ឋាប់ ទូលបង្គំនឹងថ្វែងថ្វាយទ្រង់នូវគុណសម្បត្តិនៃព្រះបាទិក្រមាទិត្យ ដូចតទៅនេះ ៖

មានមួយថ្ងៃ ព្រះបាទិក្រមាទិត្យជាស្តេចចក្រពត្តិ ទ្រង់បានគ្រងព្រះសុពណិបាទពិសិដ្ឋ ហើយហោះទៅលើអាកាស ដើម្បីនឹងទ្រង់ធ្វើព្រះរាជទស្សនាការនូវផែនប្រថពីទាំងមូល ព្រមទាំងភូមិភាគផ្សេងៗ ។ នៅទីកន្លែងមួយ, ទ្រង់បានទតទៅឃើញក្នុងបាតគុហាភ្នំមួយជ្រៅ នូវរុក្ខជាតិមួយដើមល្អស្រស់បំព្រងប្លែក ដែលទ្រង់មិនធ្លាប់បានឃើញសោះ ។ ទ្រង់ក៏ស្តេចយាងចូលទៅជិតរុក្ខជាតិនោះ។ ជាទីនៅនៃបក្សាប្លែកហៅថា "ទីយាយុបក្សា" (Longue-Vie, ចីរជីវ Cirajiva); ហ្វូងបក្សាជាបរិវារនៃចីរជីវ: ក៏បាននាំគ្នាទៅរកអាហារជាច្រើនកន្លែង ហើយវិលត្រឡប់មកកាន់រុក្ខជាតិនោះវិញ, ហើយហ្វូងបក្សានោះក៏ពោលប្រស្រ័យគ្នាទៅវិញទៅមក ។

ក្នុងពេលនោះ, មានបក្សាមួយពោលថា "ថ្ងៃនេះខ្ញុំមានទុក្ខជាទម្ងន់" ។ ហ្វូងបក្សាឯទ្រៅតក៏ស្សរទៅបក្សានោះថា "តើអ្នកមានទុក្ខដោយហេតុអ្វី?" ។ បក្សានោះក៏ពោលតបមកវិញថា: "ចូរអ្នកស្តាប់ខ្ញុំឲ្យច្បាស់លាស់ហើយចាំទុកកុំភ្លេច អំពីហេតុនៃទុក្ខរបស់ខ្ញុំ: នៅកណ្ឋាលសាគរមានកោះមួយ; ព្រះមហាក្សត្រិយ៍សោយរាជ្យនៅ

ក្រោះនោះជាជាតិយក្ស (ពសស:) ប្រជាពស្ត្រជាមនុស្សជាតិ ។ មានមួយថ្ងៃ ពសស:នោះមានបំណងចង់បរិភោគមនុស្សជាតិនោះតាំងអស់ ។ ពួកប្រជាពស្ត្រភ័យតក់ស្ងុតជាខ្លាំង ប្រជុំគ្នាហើយពោលទៅកាន់ពសស: (អារក្ស) ថា "ព្រះអង្គជាស្តេចរបស់យើងតាំងអស់គ្នា ហើយទ្រង់ចង់សេ យប្រជាពស្ត្ររបស់ព្រះអង្គ មិនសមសោះ ។ ទូលបង្គំតាំងអស់គ្នា សូមថ្វាយក្នុងមួយថ្ងៃមនុស្សម្នាក់ តាមវេនជាលំដាប់តទៅ" ។

តាំងពីនោះមក ពសស:ត្រូវបរិភោគមនុស្សម្នាក់ក្នុងមួយថ្ងៃ ហើយមានចិត្តសោមនស្សពន់ពេក, លោកមិនបានធ្វើបាបអ្នកឯទៀតសោះទ្បើយ ។ ខ្ញុំនឹងទៅលេងកំសាន្តនៅប្រទេសនោះក្នុងថ្ងៃនេះ ។ គឺថ្ងៃនេះហើយដែលត្រូវវេនខាងកល្យាណមិត្តរបស់ខ្ញុំម្នាក់ ប្រគល់មនុស្សម្នាក់ឲ្យជាចំណីដល់ពសស: ប្រហែលជាត្រូវលើបុត្រតាត់ដែលត្រូវយកទៅឲ្យពសស:បរិភោគ" ។ ព្រោះហេតុនេះ ដូចបានជាខ្ញុំកើតទុក្ខពន់ប្រមាណក្នុងថ្ងៃនេះ ។

ព្រះបាទវិក្រមាទិត្ស ទ្រង់គង់នៅទៀបគល់រុក្ខជាតិ, ទ្រង់ព្រះសណ្ឋាប់នូវកចានៃបក្សានោះសព្វគ្រប់, ទ្រង់ហោះទៅលើអាកាសដោយស្បែកព្រះសុពណិបាទពិសិដ្ឋ យាងទៅកាន់ប្រទេសនោះដែលពសស: សោយរាជ្ស ។ បុត្រានៃកល្យាណមិត្របក្សា ដែលត្រូវវេនខ្លួនជាចំណីនៃពសស: មានសេចក្តីភ័យតក់ស្ងុតនឹងសេចក្តីស្ងាប់ពន់ពេក, អង្គុយនៅត្រង់កន្ទែងដែលពសស:បរិភោគអាហារ ។

ព្រះបាទវិក្រមាទិត្ស ទ្រង់យាងទៅដល់ទីនោះមានព្រះបន្ទូលថា

"នែកូន, កូនឯងទៅផ្ទះចុះ, ខ្ញុំមកដំណើរសួរអ្នកឯងហើយ ខ្ញុំបូជារូបជីវិតខ្ញុំចំពោះកាសសៈក្នុងពេលនេះ" ។ កូនក្មេងនោះតបថា: លោកជាអ្នកមានគុណធម៌យ៉ាងនេះ ដែលជាឧកាសឲ្យខ្ញុំស្គាល់លោកក្នុងពេលនេះ, "តើលោកជាអ្វី?" ។

ព្រះបាទវិក្រមាទិត្យ ទ្រង់មានព្រះបន្ទូលថា: "អ្នកឯងមិនចាំស្គាល់ខ្ញុំទេ" ។ កូនក្មេងនោះដល់ឮព្រះពាក្យព្រះបាទវិក្រមាទិត្យមានចិត្តសប្បាយរីករាយពន់ពេក, ហើយក៏លត្បាប់ទៅកាន់គេហដ្ឋានខ្លួនវិញ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ឥតមានខ្វាចអ្វីសោះឡើយ, មានព្រះកត្តិញញឹម គង់នៅក្នុងបន្ទប់ដែលកាសសៈធ្លាប់បរិភោគ ។ ដល់ពេលបរិភោគ កាសសៈចូលទៅក្នុងទីនោះ ហើយបានឃើញអគ្គបុគ្គលក៏ពោលថា "ឧបុគ្គល! ពេលស្ងាប់ដល់ហើយ, ម្តេចក៏អ្នកឯងមិនខ្វាច, មិនតក់ស្លុត. ហើយអ្នកឯងញញឹម, តើអ្នកឯងជាអ្នកណាដែលធ្វើឲ្យខ្ញុំស្គាល់ក្នុងពេលនេះ?" ។ ព្រះបាទវិក្រមាទិត្យ ទ្រង់មានព្រះបន្ទូលថា: "មិនចាំបាច់ស្គាល់ខ្ញុំទេ, ចូរអ្នកបរិភោគខ្ញុំចុះ" ។

កាសសៈ សប្បាយចិត្តណាស់ពោលថា: "ឧបុគ្គលវិសេសអើយ, អ្នកឯងមានគុណធម៌ជ្រៅយ៉ាងវែកលែង, ខ្ញុំសប្បាយចិត្តនឹងអ្នកពន់ពេក ។ ចូរអ្នកសូមអ្វីចំពោះខ្ញុំ, អ្វីដែលអ្នកមានចិត្តបំណងចង់បានចំពោះតែដែលស្ថិតនៅក្នុងវិជ្ជខ្ញុំ" ។ ព្រះមហាក្សត្រិយ៍មានព្រះបន្ទូលថា "បើអ្នកឯងសប្បាយចិត្តនឹងខ្ញុំ, ចូរអ្នកលែងធ្វើបាបប្រជាពលរដ្ឋនៅទីនេះតាំងពីថ្ងៃនេះតទៅ" ។

ភសស: ក៏យល់ព្រមតាមព្រះអង្ត ។ ព្រះមហាក្សត្រិយ៍ទ្រង់ស្តេចហោះទៅតាមអាកាសដោយព្រះសុពណ៌ឃាទពិសិដ្ឋ, រិលត្រឡប់ទៅកាន់ព្រះរាជធានីវិញ, ហើយតាំងពីថ្ងៃនោះមក, ភសស: មិនដែលធ្វើឃាបប្រជារាស្ត្រសោះឡើយ ។

ដល់ក្រាបបង្គំទូលនូវរឿងនេះចប់សព្វគ្រប់, រូបទេពនិម្មិតទី ១០ ក៏ក្រាបបង្គំទូលតទៅទៀត ចំពោះព្រះឃាទកោជ:ថា : "បើទ្រង់មានសមត្ថភាព ឃានជួយស្រោចស្រង់អ្នកដទៃបែបនេះ ទ្រង់ទើបអាចគង់លើបល្ងំង្គទិព្យនេះឃាន" ។ ព្រះឃាទកោជ: កាលទ្រង់ព្រះសណ្ឋាប់នូវនិទាននៃរូបទេពនិម្មិតហើយ ក៏លះបង់នូវពិធីបុណ្យមុទ្ធាភិសេកក្នុងពេលនោះ ។

*

* *

(មានត)

មើលអ្វីប្រពៃជាងការមើលទាំងពួង? មើលសៀវភៅធម៌
មើលទស្សនាវដ្តីពុទ្ធសាសនា មើលព្រះពុទ្ធបដិមាការទើប
ប្រពៃព្រោះអាចនាំឲ្យកើតសេចក្តីត្រជាក់ត្រជំចិត្តជានិច្ច ។

កំណត់ទិវប្រវត្តិការណ៍

ពិធីសម្ពោធបើកសាលាបាលីវង
នៅវត្តព្រះព្រហ្មរ័ត្ន ខែត្រសៀមរាប

ព្រះគ្រូបាសាទសង្ឃអនុគណ កែ-ឈឿន (ភទ្ទិយឬញ្ញោ)

ប្រមូលរៀប

កាលពីថ្ងៃអង្គារ ៤ រោចខែទាសាខ ឆ្នាំមមែសឯកស័ក ព.ស. ២៤៩៨ គឺថ្ងៃទី ១០ ខែឧសភា គ.ស. ១៩៥៥, នៅវត្តព្រះព្រហ្មរ័ត្ន មានធ្វើពិធីសម្ពោធបើកសាលាបាលីវង ។ ក្នុងពិធីនេះមានទស្សនីយភាពល្អអស្ចារ្យ ដូចមានវិធានការតទៅនេះ ៖

នៅក្នុងទ្វារធំមុខវត្ត មានដោតទង់ជាតិទង់សាសនាធំ ១, នៅខាងមុខសាលាបាលី មានបាវចនាមួយខ្នង បណ្តាយ ៦ ម៉ែត្រ ទទឹង ៤ ម៉ែត្រ, សសរបាវចនាមួយ ១ ទិចត្រូវបានស្រោបដោយស្លឹកក្រូចជាតិស្រស់ ១, នៅជម្ពូលបាវចនាប្រាក់ដោយសំពត់ពណ៌ផ្ទួត ទឹងបង្ហាញដោយស្លឹកក្រូចជាតិស្រស់ ព្រមទាំងទង់ជាតិទង់សាសនាតូច ១ ជាច្រើន, នៅជុំវិញបាវចនាយសំពត់ទាបមានសណ្ឋានជាទង់ជាតិសំយុងចុះមក, ខាងក្នុងបាវចនា ត្រាលកន្ទេលត្រហមមានរៀបកៅអីជាជួរ ១ ទឹងកៅអីពិសេសមួយត្រាលព្រ៉ាមត្រោម ជាព្រះទីនាំងសម្រាប់សម្តេចព្រះឧបយុវរាជគង់ ទឹងមានតុ ១ ត្រាលកម្រាលដ៏ស្អាតដាក់ជាបណ្តា, បាវចនាសម្រាប់ទទួលបដិសណ្ឋារៈ: សម្តេចព្រះឧបយុវរាជ ទឹងឥស្សរជនត្រាប់ដំណើរតាមក្នុងខែត្រ ។

នៅយ៉ាសាលាថ្ងៃលី មានធ្វើសុំរចនាដោយស្នឹកទម្រែនធំចង្កេតជាតិ
ទន់សាសនាធំៗនៅតាមស៊ុំនោះ, កណ្តាលស៊ុំចង្កៀរប្លូរធ្វើដោយត្រជាស
ពណ៌ជា ៣ ខ្សែ ចង្កៀរប្រាក់គ្នាមានសណ្ឋានជាទន់ជាតិ ។ ក្នុងខាងក្នុង
សាលាថ្ងៃលីពាំងពីរថ្នាក់ មានរៀបតុសម្រាប់សិស្សអង្គុយរៀន ទឹងតុ
សម្រាប់គ្រូ ក្តារខៀនបញ្ឈរធំ ។ នៅវេលាម៉ោង ៩ ព្រឹក ព្រះសង្ឃ
ជាង ១០០ អង្គ មានព្រះតេជព្រះគុណ ព្រះសុមង្គលសិលាចារ្យមេគណ
ទឹងព្រះគ្រូអនុគណជាប្រធាន ព្រមពាំងពុទ្ធបរិស័ទជាច្រើនមកដេរដាស
តែ្បតែ្ប រង់ចាំទទួលបដិសណ្ឋារកិច្ចសម្តេចព្រះឧបយុវរាជ ទឹងឥស្សរ
ជន ។ វេលាម៉ោង ៩,៣០ នាទី ក្រុមតូរ្យតន្ត្រីកងទេមរភូមិន្ទ ទឹង
ក្រុមកងរក្សាទែ្រតៅរង់ចាំធ្វើតារាវកិច្ច ចំពោះសម្តេច ។ វេលាម៉ោង ១០
សម្តេចទឹងឥស្សរជន យាងទឹងអញ្ជើញទៅដល់ ក្រុមតូរ្យតន្ត្រីប្រគំបទ
ក្លែងនគរាជថ្វាយ, ក្រុមកងរក្សាទែ្រធ្វើតារាវកិច្ចតាមប្រពៃណី, អាចារ្យ
វត្តជ្រាំងកូសថ្វាយ, ចប់បទក្លែងនគរាជហើយ សម្តេចទ្រង់យាងត្រួតពល
រួចទ្រង់យាងចូលទៅកន្លែងបាកាំថ្វាយបង្គំព្រះសង្ឃ ហើយគង់ប្រថាប់នៅ
ក្នុងព្រះទីនាំងកៅអី, បន្ទាប់ពីនោះមក ព្រះគ្រូអនុគណ កែ - អឿន ថ្លែង
សុទ្ធរកថាបំពង់សំឡេង ដោយឧគ្ឃោសនសព្ទដូចមានសេចក្តីតទៅនេះ៖

សុទ្ធរកថា

សូមថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មានព្រះតេជព្រះគុណ
ព្រះសុមង្គលសិលាចារ្យមេគណ ជាប្រធាន!

សូមថ្វាយព្រះពរសម្តេច ព្រះឧបយុវរាជ!

សូមចំរើនពរ អស់លោកជាឥស្សរជនទាំងឡាយ !

អាត្មាភាពមានសេចក្តីត្រេកអរដ៏ពន្លឹក ទឹងមានអំណរព្រះគុណដ៏ក្រៃលែងចំពោះសម្តេច ទឹងលោកជាឥស្សរជនទាំងឡាយ ដែលបានស្តេចយាងទឹងអញ្ជើញមក ជាព្រះរាជាធិបតី សិរីមង្គលក្នុងពិធីបុណ្យសម្ពោធប្រើកសាលាបាលីថ្មីនេះ ។

អាត្មាភាព សូមថ្លែងកិច្ចការសិក្សានៃព្រះពុទ្ធសាសនាក្នុងវត្តព្រះព្រហ្មវ័ត្តន៍នេះ ដោយសង្ខេបដូចតទៅនេះ ៖

វត្តព្រះព្រហ្មវ័ត្តន៍នេះ កាលពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៥០ បានបើករៀនធម្មវិន័យ ដោយបានសេចក្តីអនុញ្ញាតជាបណ្តោះអាសន្នអំពីក្រសួងសម្តេចព្រះសង្ឃនាយកទឹងក្រសួងធម្មការ ដោយការប្រែស្រ័យទាក់ទងជាមួយទឹងព្រះតេជព្រះគុណ ព្រះវិនេវតន៍ មេគណវត្តពោធិ៍វាលខែត្រចាត់ដំបង ព្រោះខែត្រចាត់ដំបងបានបង្កើតការរៀនធម្មវិន័យមកជាយូរឆ្នាំហើយ ។ បន្ទាប់ពីនោះមក ព្រះប្រិយមហាក្សត្រ ទ្រង់មានព្រះរាជានុញ្ញាតទូវព្រះរាជក្រឹត្យលេខ ២១៤ ន.ស. ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ១៩៥០ ថា ទឹងបង្កើតឲ្យមានសាលាធម្មវិន័យគ្រប់វត្តក្នុងព្រះរាជាណាចក្រ, វត្តព្រះព្រហ្មវ័ត្តន៍នេះ បានបើករៀនធម្មវិន័យតាំងពីឆ្នាំ ១៩៥០ នោះមកដល់ឆ្នាំ ១៩៥៥ អស់រយៈកាល ៥ ឆ្នាំមកហើយ, លទ្ធផលនៃសិស្សដែលបានចូលមកសិក្សា ហើយបានប្រឡងជាប់វិញ្ញាបនបំត្រ រួបរួមទាំង ៣ ថ្នាក់ គឺថ្នាក់ ត្រី ទោ ឯក ទាំងសិស្សសាមញ្ញទឹងសិស្សវិសាមញ្ញ មានចំនួនជាង ៥០០ រូប ។ ក្នុងឆ្នាំ ១៩៥៥ នេះ

គណៈកម្មការវត្តបានពិភាក្សាគ្នាថា វត្តយើងនេះ គួរនឹងសុំតាំងជាសាលាបាលីវិនេឡើង, ព្រោះសាលាបាលីអ្នកឧបាសិកា ប្រមនៅជ្រាសៀមពេញ ត្រមាំងបុត្រធីតា មានសទ្ធាជ្រះថ្លាកសាងសម្រេចឡើងហើយ, ការពិភាក្សាក៏មូលមតិជាឯកច្ឆន្ទបានសម្រេចដូចវត្តបំណង ។

ក្នុងថ្ងៃនេះ វត្តព្រះព្រហ្មវ័ន្ត ពេញជាមានកំពូតាប់ប្រសើរលើសលន់ ព្រោះបានតាន់រយៈកាលសម្តេចព្រះឧបយុវរាជ ទ្រង់យាងមកបំពេញព្រះរាជករណីយកិច្ចក្នុងវិស្សត្រសៀមរាបនេះ ហើយទ្រង់ឆ្លៀតព្រះបរមរាជវាសោកាស ទ្រង់យាងមកជាព្រះរាជាធិបតី ក្នុងពិធីសម្ពោធ្យបើកសាលាបាលីនេះ ។

អាត្មាភាពត្រង់អង្គ មានសេចក្តីត្រេកអរនឹងព្រះគុណនេះយ៉ាងវិសេសពេក ទំនងកវត្តអ្វីក្នុងពិភពលោកមកប្រៀបផ្ទឹមថ្លៃឯថ្លឹងពុំបាន ។

ក្នុងកាលជាអវសានៃសុន្ទរកថានេះ អាត្មាភាពសូមសំឃឹងសំរុងដល់គុណព្រះរតនត្រ័យថ្លៃវិសេស នឹងទៅតាំង ๑ ហ្នឺនលោកធាតុ សូមជួយអភិបាលរក្សាសម្តេច ព្រមទាំងព្រះពុទ្ធវង្សានុវង្ស នឹងឥស្សរជនទាំងឡាយ ឲ្យបានប្រកបដោយសុខកាយ នឹងវឌ្ឍនភាព ទាំងមានព្រះជន្មាយុយឺនយូរអង្វែង ដើម្បីបីសួយមាតុភូមិឲ្យអណ្តែតត្រសែតទៅកាន់វឌ្ឍនធម៌ជាកិច្ចការភាព នឹងបំពេញព្រះពុទ្ធិកិត្តិយសចំពោះទ្រង់ជាតិដែលមានក្តីសាទរនត្រេកជាដរាបនិមិត្តរូប ជានិន្នានរៀងទៅកុំបីឃ្លាត ។

លុះចប់សុន្ទរកថាហើយ លោកនាយកក្រុមព្រះនគរបាល ម៉ក-បិក លើកដើងានដម្កល់កន្ត្រៃទៅថ្វាយសម្តេច ។ ទ្រង់គាន់យកកន្ត្រៃ យាង

ទៅកាន់ទ្រឿបូរជានិមិត្តរូបនៃពិធីបើកសាលាបាលី, កាលទ្រឿបូរជាច់ទៅ
សង្ខាងស្ទឹហើយ ព្រះសង្ឆស្វាធ្យាយធម៌ជយន្តោ លុះចប់ហើយ
សម្តេចនឹងឥស្សរជនទ្រង់យាងនឹងអញ្ជើញចូលទស្សនាក្នុងថ្នាក់រៀនទាំង
ពីរថ្នាក់ រួចទ្រង់សន្ទនានឹងព្រះជាមេគណ អនុគណ-ចៅអធិការ តាម
កាលដ៏សមគួរ ហើយថ្វាយបង្គំលាព្រះសង្ឆទ្រង់យាងទៅកាន់ព្រះរាជ-
ដំណាក់វិញដោយស្ទុវត្ថិភាព ។ កិច្ចប៉ុណ្ណោះ សន្ធតថាចប់ពិធីបុណ្យ
សម្ពោធបើកសាលាបាលី ។

មនុស្សឆ្មានកិលេសតណ្ហា ទុកស្រីរូបល្អធើតជាស្មៅ,
មនុស្សឆ្មានធ្វើបាបអកុសល ទុកព្រះយមរាជជាស្មៅ,
មនុស្សឆ្មានលោភ ទុករាជសម្ឆត្តិជាស្មៅ ។

តារុណសុទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៧ ខែតុលា លេខ ១០

ព.ស.២៤៩៧ – គ.ស.១៩៥៥



ធម្ពមសនិយា

ទស្សនាវដ្ដី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា — *ទំព័រ*

— សាសនាមានប្រយោជន៍យ៉ាងណា .... ព្រះបាទលិវង្ស សូរ-ហាយ .. ៣២៣

— បញ្ញាសជាតក ភាគទី ៤ (តមក) .... បណ្ឌិតមហា ឈឹម -ស៊ុម ៣៣៤

— រឿងធម្មទ្ធជបណ្ឌិត (តបប់) ..... ណេក គាំ-ឆុំ ៣៥១

ផ្នែកអក្សរសាស្ត្រ

— ពិធីបំបួសនាគជាតិភូមា ..... ណេក ញៃម -ទឹម ៣៦៩

— រឿងសាមកុក (តមក) ..... ឧកញ៉ា នូ- កន ៣៨២

— ដំណឹងតាមឧស្សល់ក្នុងកន្ទារ: (តមក) ... ណេក ផេង-ជ្រីវ ៣៨៨

— រឿងបល្ស៍ង្កទិព្យ (តមក) ..... ណេក ភ៉យ- ប៊ុក ៣៩២

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: *Page*

— Les Bienfaits de Religion . . . . *Vén. SO-HAY* *723*
— Pannasajataka-vol. 4 (suite.) . *M. CHHIM-SOUM* *734*
— Dhammadhajapandit
(suite et fin) . . . . . *M. KAM-DOUM* *751*

PARTIE LITTERAIRE:

— Cérémonie d'ordination
Birmane . . . . . *M. NHEM-KHEM.* *769*
— Histoire de SAMKOK (suite . . *Okuha NOU-KAN* *782*
— Le souffle du désert (suite) . *M. PHENG-CHRIV* . . . *788*
— Les trente deux récits du
TRONE (suite) . . . . . *M. RAY-BUC* *792*

Prix d'abonnement annuel (comprenant 12 numéros) 210$00

សាសនាមានប្រយោជន៍យ៉ាងណា ?

របស់ព្រះឧបាលីវង្ស សូរ-ហាយ ក្រុមដំនុំព្រះត្រៃបិដក

សាសនាមានប្រយោជន៍ធំទូលាយ ឬមិនធំទូលាយ ដូចដំណើរសេចក្តីដែលត្រូវអធិប្បាយតទៅ ប៉ុន្តែមុននឹងអធិប្បាយអំពីប្រយោជន៍របស់ព្រះពុទ្ធសាសនា សូមចែកប្រភេទសាសនាដែលមាននៅក្នុងលោកមុនសិន ព្រោះសាសនាក្នុងលោកបច្ចុប្បន្ននេះមានច្រើន គឺថា ប្រជាជនគ្រប់ជាតិសុទ្ធតែកាន់សាសនា ឥតមានជនជាតិណាមួយ ដែលមិនមានសាសនាសម្រាប់កាន់នោះឡើយ បើទុកជាសាសនាមិនមានគោលចារឹតយ៉ាងណាក៏ដោយ គង់មានសាសនាព្រៃផ្សៃ ដោយការគោរពជឿខ្មោចបិសាចជាដើមពុំខាន ។

សាសនាទោះបីមានច្រើន តាមចំនួនប្រជាជនគ្រប់ជាតិ ក៏ពិតមែន ប៉ុន្តែបើកប់យកចំពោះសាសនាធំៗ មានតែត្រឹម ៤ ប្រភេទ គឺ

១_ ពុទ្ធសាសនា សាសនាព្រះពុទ្ធ

២_ ព្រាហ្មណសាសនា សាសនាព្រាហ្មណ៍

៣_ គ្រិស្តសាសនា សាសនាគ្រិស្ត

៤_ ឥស្លាមសាសនា សាសនាឥស្លាម ។

សាសនាក្រៅពីនេះ មានច្រើនទៀតជាសាសនាកើតអំពីអ្នកប្រាជ្ញដូចយ៉ាងសាសនានៅប្រទេសចិន ដែលកើតអំពីលោកដ៏ឆ្លាតដ៏ជាដើម ។

ក្នុងទីនេះ សូមអធិប្បាយដោយសង្ខេប ចំពោះសាសនាទាំង ៤ ប្រភេទ ដូចតទៅនេះ ៖

១.— ពុទ្ធសាសនា ជាសាសនាផ្សាយចេញអំពីមហាបុរសមួយរូប ជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទន: នឹងព្រះនាងមហាមាយាទេវី ជាក្សត្រសោយរាជ្យក្នុងក្រុងកបិលព័ស្តុ នាប្រទេសឥណ្ឌា ។ មហាបុរសនេះ ព្រះនាមដើមហៅ សិទ្ធត្ថ: មិនពេញព្រះហប្ចទ័យក្នុងរាជសម្បត្តិ ទើបចេញទៅទ្រង់ព្រះផ្នួស ស្វែងរកអនុត្តរសម្ពោធិញ្ញាណ ដោយព្យាយាមដ៏ទក្រិដ្ឋ ជាទុក្ការកម្មអស់ប្រាំមួយឆ្នាំ បានត្រាស់ដឹងឃើញធម៌ប្រកអស្ចារ្យចំពោះធម៌ដែលមិនធ្លាប់ចេះដឹង ពីកាលមុនមក ហើយស្រាប់តែឃើញច្បាស់ បានទទួលហាន:ថាជាព្រះពុទ្ធ ។ បន្ទាប់ពីនោះមក ទ្រង់ក៏ចេះតែស្តេចយាងទៅសំដែងធម៌ប្រាសប្រជាជនក្នុងស្រុកតូចធំ និតមរាជធានី តាមពុទ្ធអធ្យាស្រ័យ ។ អ្នកដែលមានសទ្ធាបញ្ញាចាស់ក្លា ក៏ប្រតល់កាយថ្វាយទ្រូង ចូលបួសតាមព្រះអង្គ, អ្នកខ្ចះគ្រាន់តែចុះចូលដើតាម ប៉ុន្តែនៅជាភេទគ្រហស្ថ ដោយគ្រាន់តែប្រកាសខ្លួនថាជាឧបាសកឧបាសិកា ។ សាសនារបស់ព្រះអង្គក៏រីកធំទូលាយផ្សព្វផ្សាយជាលំដាប់មក ។

ពុទ្ធសាសនា លើកយកសរណគមន៍ ៣ ជាវត្ថុសក្តិសិទ្ធិដែលហៅថា "ត្រៃសរណគមន៍គឺព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១" ។ មានគម្ពីរ ៣ ជាគោលធំ ហៅថាព្រះត្រៃបិដក គឺព្រះវិន័យបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១" ។ ព្រះត្រៃបិដកនេះមានគម្ពីរចែកចេញជាច្រើនទៅទៀត

ដែលហៅថា "គម្ពីរអដ្ឋកថា, ដីកា" ។ អត្ថរសពុទ្ធសាសនា ក្នុងផ្នែកគម្ពីរ
ទាំងនេះមានសារប្រយោជន៍ជាច្រើន ដែលសម្រាប់ខ្លួនយើងប្រៀនប្រដៅ
ពត៌និស្ស័យសន្តាន របស់ប្រជាជន ឲ្យមានសីលធម៌ល្អឡើង ឱុសពី
ប្រក្រតីដើម ។ ពុទ្ធសាសនាសម្បូណ៌ដោយអត្ថបទល្អច្រើនណាស់
ហើយសុទ្ធតែមានហេតុផលច្បាប់ប្រយោជន៍ដល់បុគ្គលអ្នកប្រតិត្តតាំង
អំពីប្រយោជន៍បច្ចុប្បន្ន ប្រយោជន៍បរលោកនឹងមគ្គផលនិព្វាន ។

๒.— ព្រាហ្មណសាសនា ឬហៅថា ព្រហ្មញ្ញសាសនា
ក៏បាន, សាសនានេះចាស់ជុំជាងសាសនាឯទៀតទាំងអស់ ប៉ុន្តែមិនមាន
បេញ្ញឈ្មោះអ្នកបង្កើតសាសនាព្រាហ្មណ៌ថាឈ្មោះអ្វីទេ ។ សាសនានេះ
គោរពហោកអ្នកសក្តិសិទ្ធិច្រើនអង្គ ប៉ុន្តែដែលធំ ប្រសើរជាងគេនោះ
៣ អង្គ គឺព្រះព្រហ្ម ๑ ព្រះសិវៈ ឬហៅព្រះឥស្សរ ๑ ព្រះវិស្ណុ ឬ
ហៅព្រះនារាយន៍ ๑ ។ ព្រះទាំង ๓ ព្រះអង្គនេះគង់នៅឯឋានសួគ៌
ជានិច្ច ជាព្រះបិតាថែរនៅប្រចាំលោក ពុំចេះប្រួតប្រែប្រួលឬនិព្វានទេ ។
សាសនានេះ មានគម្ពីរ ជាគោលដើមនោះ ๓ គម្ពីរ ហៅថាគម្ពីរវៃត
វេទ (វេទ ๓) គឺគម្ពីរ សាមវេទ សំដែងអំពីពលិកម្ម ការបួងសួង
សូមឲ្យព្រះអគ្គិបាលរក្សាមនុស្សលោក ๑, គម្ពីរឥរុវេទ សំដែងអំពី
តុស្តីសូមឲ្យព្រះប្រទានពរឲ្យបានសម្រេចខាងហត្ថកម្ម ๑, គម្ពីរយជុវេទ
សំដែងអំពីយុទ្ធសង្គ្រាមសូមឲ្យមានជ័យជំនះឲ្យមានជោគជ័យ ๑ ។

គម្ពីរវៃតវេទទាំងនេះបែកចេញជាច្រើនគម្ពីរទៀត ដូចជាគម្ពីរព្រះ
វៃត្រចិដកយើងដែរ ។

៣.— ត្រិស្ទសាសនា ជាសាសនាដែលកើតអំពីបុរសម្នាក់ឈ្មោះ ហ្យ៊ូ-ហ្យ៊ុយ ជាជាតិជ្វិហ្វដែលកើតឡើងក្នុងកាល ព.ស. ៥៤៣ ជាកូនរបស់ជោសែហ្វនឹងនាងម៉ារ៉ី នៅក្រុងបេធលេហេម ជិតក្រុងហ្យ៊ូ-រុយសាឡេម ។ សាសនានេះ ហៅថា "យេស៊ូសាសនា ឬ កាតូលិកសាសនា" ក៏បាន លើកយកវត្ថុសក្តិសិទ្ធិ ៣ យ៉ាងទុកជាគោលធំ គឺព្រះបិតា ១ ព្រះបុត្រ ១ ព្រះវិញ្ញាណបរិសុទ្ធ ១, មានគម្ពីរជាគោលដើម នោះឈ្មោះគម្ពីរ ប៊ីប៊ី (Bible) ។ សាសនានេះ សំដែងថាមានព្រះដែលធំនោះមួយអង្គ ព្រះនាម យ:ហោវ៉ា គង់នៅឋានសួគិ ឯព្រះ ហ្យ៊ូ-ហ្យ៊ុយគ្រិស្តឬហៅថាព្រះយេស៊ូ គ្រាន់តែជាអ្នកប្រដៅសាសនាតំណាងព្រះអង្គប៉ុណ្ណោះ មានបញ្ញត្តិរបស់ព្រះម្ចាស់សួគិ ១០ យ៉ាង មានបទបញ្ញត្តិថា ត្រូវគោរពបូជាព្រះម្ចាស់សួគិជាដើម ។

៤.— ឥស្លាមសាសនា ជាសាសនាដែលកើតអំពីបុរសម្នាក់ឈ្មោះមោហម៉ាត ជាជាតិអារ៉ាប់ កើតក្នុងស្រុកម៉ែកះ ក្នុងកាល ព.ស. ១១១៣ ។ ស្រុកម៉ែកះ នេះ នៅក្នុងប្រទេសអារ៉ាប់ ។ មោហម៉ាតជាមនុស្សក្លាហានអង់អាចហ៊ានពុះពារទបស៉ត្ត ខាងក្រោយមកបានតាំងខ្លួនជាសាស្តាចារ្យប្រដៅសាសនា ដោយអាងថា ខ្លួនបានក្សួនអំពីទេពតា ហើយលើកខ្លួនឯងថាបាននាមថា "ន:ប៊ី" ។ ពាក្យ "ន:ប៊ី" នេះជាពាក្យអារ៉ាប់ ត្រូវនឹងពាក្យបាលីថា "សព្វញ្ញូ" ខ្មែរយើងថា "អ្នកដឹងសព្វ" ។ មោហម៉ាត ចាប់ផ្តើមប្រកាសសាសនាឡើងឲ្យឈ្មោះថា "ឥស្លាមសា-

សនា" បើប្រែមកជាខ្មែរថា "សាសនាស្រោចស្រង់សត្ត,, ។ បរិស័ទ
អ្នកចុះចូលជឿស៊ីប់ក្នុងឥស្លាមសាសនានេះ ឧាននាមថា "មុស្សុលម៉ាន់"
ត្រង់ត្នានឹងពាក្យយើងថា "ឧបាសក ឧបាសិកា" ដែរ ។ ឥស្លាម-
សាសនានេះ ហៅថា "មោហម៉ាសាសនា" ក៏បាន ។ សាសនា
នេះមានគម្ពីរដើមមួយឈ្មោះគម្ពីរកោរ៉ាន ឬកូអាន សំដែងថា "មានព្រះ
ដែលធំនោះតែមួយអង្ត គឺព្រះអាហ្ជា គង់នៅឯឋានសួគិ, ឯព្រះមោហម៉ាទ
ត្រាន់តែជាទេវទូតចុះមកប្រដៅសាសនាតំណាងព្រះអាហ្ជាប៉ុណ្ណោះ" ។
សាសនានេះមានពិធីជាករណីយកិច្ចធំ ៣ យ៉ាង គឺការឧស្សាហ៍សូត្រ
មន្ត ១ ការអត់អាហារតាមកំណត់ថ្ងៃ ១ ការឲ្យទានដល់មនុស្សសត្ត ១ ។

សាសនាទាំងអស់ ក្នុងសកលលោក សុទ្ធតែមានបញ្ញត្តិមានទ្រាទ
មានអត្ថបទសម្រាប់ប្រៀនប្រដៅដើម្បីប្រយោជន៍ឲ្យមនុស្សជឿជាប់ចិត្ត
ទៅជាទំនៀមដោយឥតហេតុផល់ក៏មាន ប្រដៅមនុស្សឲ្យមានសីលធម៌
ក៏មាន ប៉ុន្តែក្នុងទីនេះ យើងអ្នកនិពន្ធ មិនមានបំណងអធិប្បាយអំពី
ប្រយោជន៍របស់សាសនាទាំងនោះទេ សូមអធិប្បាយចំពោះតែប្រយោជន៍
របស់ព្រះពុទ្ធសាសនាមួយប៉ុណ្ណោះ ដូចសេចក្ដីតទៅនេះ ៖

ព្រះពុទ្ធសាសនាមានប្រយោជន៍ដល់ប្រទេសជាតិ

រិជ្ជាស្ថាននៃពុទ្ធសាសនា ជារិជ្ជាដែលមានគុណ តម្លៃគួរអ្នកសិក្សា
បំណាយពេលវេលា ដើម្បីសិក្សាផ្ទូវសាសនាឲ្យយល់គោលបំណងរបស់
លោកអ្នកប្រាជ្ញ ក្នុងសម័យជាន់មុន ព្រមទាំងប្រយោជន៍របស់សាសនា
ក្នុងសកលលោក ព្រោះថា សាសនាសុទ្ធតែជាអនុសាសនី សម្រាប់

ប្រៀនប្រដៅមនុស្ស ឲ្យបែរមុខទៅរកផ្ទូវល្អ ដែលមានប្រយោជន៍ ច្រើនក៏មាន ពុំសូវមានប្រយោជន៍ក៏មាន ប៉ុន្តែទុកជាយ៉ាងណា ក៏យើងគួរសិក្សាឲ្យស្គាល់មូលហេតុនៃសាសនា ដើម្បីជាគ្រឿងស្ទាបស្ទង់ពិចារណាមើល ឲ្យកើតសតិបញ្ញាបរិបូណិសម្រាប់ហានៈនៃខ្លួនជាបុរសស្ត្រីអ្នកសិក្សា អាចយើញប្រយោជន៍ដូចតទៅនេះ ។

១.- ព្រះពុទ្ធសាសនាទុកដូចជាមហាមន្ទីរជាទីកើតនៃសីលធម៌នឹងប្រពៃណីដ៏ល្អ ដែលគួរប្រតិបត្តិតាម ជាផ្ទូវដើម្បីរំលត់ទុក្ខនាំសេចក្តីសុខមកឲ្យដល់មនុស្សអ្នកប្រតិបត្តិ ទុកដូចជាដួងប្រទីបមួយដ៏ធំ ក្នុងលោកសម្រាប់ត្រោលបំភ្លឺឲ្យមនុស្សលោកយើញផ្ទូវប្រតិបត្តិ ដើរកាត់តម្រង់ទៅរកសន្តិសុខទាំងក្នុងបច្ចុប្បន្ននឹងបរលោក ជាសាសនាលូកវាវរកយើញមគ្គផលនិព្វានបាន ។ ព្រះពុទ្ធសាសនាមានគុណភាពប្រកបដោយប្រយោជន៍ជាច្រើនយ៉ាង ដូចយ៉ាងសេចក្តីចំរើនឈានលឿនទៅមុខរបស់មនុស្សលោក ក៏ច្រើនតែកើតមកអំពីព្រះពុទ្ធសាសនាជាដំបូង សូម្បីវេជ្ជសាស្ត្រនឹងវិទ្យាសាស្ត្រដែលរាប់ថាជាវិជ្ជាសម័យថ្មីក៏កើតមកអំពីអ្នកប្រាជ្ញដែលចម្ងងផ្តិតយករបៀបអំពីព្រះពុទ្ធសាសនាខ្ទះ មិនខាន បើមិនច្រើនក៏តិច ។

ត្រប់ប្រទេសទាំងអស់ ច្រើនតែទទួលដឹងថា សេចក្តីចម្រើនក្នុងសិល្ប:វិទ្យាបានទទួលកំណើតអំពិសាសនា ។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រប្រទេសជប៉ុន បានសរសេរចុះក្នុងប្រវត្តិសាស្ត្រថា "ព្រះពុទ្ធសាសនាជាសាសនានាំសេចក្តីចំរើនមកប្រគល់ឲ្យប្រទេសជប៉ុន, ព្រះពុទ្ធសាសនា

បានបើកឡារប្រទេសជប៉ុន ដោយទ្រឹស្តីមុនជំបូងបង្អស់ ឲ្យប្រទេសជប៉ុន ឈមមុខទៅរកសេចក្តីចំរើន ព្រោះហេតុនោះ យើងជាជាតិជប៉ុននៅចុងប៉ូចបូពាិប្រទេស គួរណាស់តែសើរើសិក្សាអនុវត្តព្រះពុទ្ធសាសនាដោយគោរព មិនត្រូវផ្ទេសប្រហែស" ។

៦.- ព្រះពុទ្ធសាសនាជាអនុផ់សម្រាប់កើតនៃការសិក្សា ទោះបីការសិក្សានោះ ពុំបានធំទូលាយក៏អាចចិញ្ចឹមការសិក្សាឲ្យមានជីវិតជាប់ ពូជណារមិនជាប់ ។ ប្រទេសកម្ពុជារបស់យើងដែលមានការចេះដឹងក្នុងផ្នូវលទ្ធិសាសនាក្តី ក្នុងផ្នូវអក្សរសាស្ត្រក្តី សុទ្ធតែកើតអំពីវត្តអារាមរបស់ព្រះពុទ្ធសាសនាជាដំបូង សូម្បីវិជ្ជាពេទ្យក៏ច្រើនតែកើតមកអំពីបពូជិតពុទ្ធសាសនា ទោះបីមានវិន័យហាមមិនឲ្យបពូជិតធ្វើពេទ្យមើលជម្ងឺ ក៏ហាមបានដោយក្រណាស់ ដោយហេតុបពូជិតមើលជម្ងឺឲ្យទទេ មិនបាច់យកថ្ងៃ ។

៣.- វត្តអារាមជាកន្ទែងប្រជុំនៃប្រជាជន ដើម្បីសន្ទនាពីធម៌អាថិ ឬពីព្រឹត្តិការណ៍ណាមួយ តាមសេចក្តីចេះដឹងក្នុងសម័យនិយមនោះ ។ ។ វត្តអារាមទុកជាកេងហត្ថកម្មមួយរបស់ការជាង មានការជាងឈើកសាងវិហារសាលាជាដើម ។ ពូជណារនៃសេចក្តីចម្រើនរបស់ប្រទេសយើងដែលមានឈ្មោះជាប់មក ជាប្រទេសមានអក្សរសាស្ត្រ មានបុរាណវត្ថុជាកេរ្តឺ៍ដំណែល មានប្រជាជាតិជាម្ចាស់ប្រទេស មានមហាក្សត្រសោយរាជ្យ ក៏ដោយអំណាចគុណនៃព្រះពុទ្ធសាសនា ឬថាព្រះពុទ្ធសាសនាជាឃ្នាំងទុកជាក់នូវអក្សរសាស្ត្ររបស់ជាតិ ឲ្យមានជីវិតរស់នៅរហូតមក

រួមសេចក្តីថា "ព្រះពុទ្ធសាសនានាំមកនូវប្រយោជន៍យ៉ាងធំឲ្យប្រទេសកម្ពុជារបស់យើង" ។

๔.- ប្រទេសកម្ពុជារបស់យើង ក៏យើងអាចបានឃើញជាក់ច្បាស់ហើយ គឺថាកាលដែលប្រទេសយើងមិនទាន់មានសាលារៀនអក្សរសាស្ត្រក្នុងផ្លូវការនៅឡើយ មានតែវត្តអារាមហ្នឹងឯង ជាសាលារៀន កាលដែលមិនទាន់មានមន្ទីរពេទ្យព្យាបាលរោគ មានតែវត្តអារាមជាមន្ទីរពេទ្យសម្រាប់មើលជម្ងឺនៃប្រជាជន មិនត្រឹមតែមើលជម្ងឺក្នុងកាយប៉ុណ្ណោះទេ អាចពិនិត្យមើលជម្ងឺក្នុងចិត្តផងទៀត ព្រោះថា ការកើតទុក្ខព្រួយបារម្ភក្នុងផ្លូវចិត្តនេះ ចាត់ជារោគមួយយ៉ាងធំណាស់ វត្តអារាមនៃពុទ្ធសាសនាឈ្មោះថាជាកន្លែងសម្រាប់រម្ងាប់រោគកាយ-ចិត្តដែរ មានទុក្ខឲ្យធូរស្រាលក៏មាន ឲ្យជាសះស្បើយទៅក៏មាន ។

๕.- ប្រទេសកម្ពុជាដែលមានវត្តអារាមធំៗក្នុងភូជាន់ដីគ្រប់ទីកន្លែង វត្តខ្លះណាលោម, វត្តលង្កា, វត្តបទុមវតីជាដើម ជាវត្តទទួលបន្ទុកនៃពួកកិកុ, សាមណេរនឹងក្មេងតូចធំបានច្រើនណាស់ ។ វត្តនីមួយៗមានកិកុសាមណេរ នឹងក្មេងដែលចេញស្រុះពន្លះអំពីស្រុក-ខែត្រផ្សេងៗ មកនៅបញ្ចុះជ្រំជាមួយគ្នា ដើម្បីសិក្សារៀនសូត្រយកចំណេះវិជ្ជា ព្រោះថាក្រុងគ្រប់ពេញជាទីប្រជុំធំសម្បូណ៌ដោយការសិក្សាជាងទីឯទៀត ។ ពួកកិកុដែលមកគង់នៅក្នុងវត្តច្រើនោះបានយូរឆ្នាំ ច្រើនមានសមត្ថភាពគ្រាន់បើហើយបានធ្វើជាមេកុដិ អាចទទួលចិញ្ចឹមកិកុ, សាមណេរនឹងក្មេងឲ្យនៅរៀនសូត្រតាលំដែរសម្រេចការសិក្សា ។ ពួកក្មេងដែលមកនៅអាស្រ័យ

ជ្រកកោន ក្នុងវត្តជាមួយនឹងព្រះសង្ឆនោះ សុទ្ធតែជាកូនអ្នកស្រែចំការ ដែលក្រទ័លទ្រព្យសម្បត្តិ ត្លូវឲ្យអណោជអធម្ម អាណិតអាសូរពួកក្មេង កំសត់ទាំងនេះពន់ពេក បើកុំតែមានវត្តព្រះពុទ្ធសាសនា ប្រហែលជាមិន បានទទួលរស្មីការសិក្សាដូចកូនអ្នកមានទ្រព្យទេ ប្រែសេចក្តីឲ្យច្បាស់ ថា "កូនអ្នកក្រីក្រធនធានរស់នៅដោយសារបាយវត្ត" ទំនៅទ្រនៅ បំពេញការសិក្សាទាំងរហេមរហាម ទាល់តែសប្រេចផលនៃការសិក្សា បានឡើងហានៈទៅជាអ្នកមានជីវកាពខ្ពង់ខ្ពស់តាមសមត្ថរដល់សមត្ថកាព របស់ខ្លួន, ចំណែកទាងកូនអស់លោកឥស្សរជន ឬ កូនគហបតី គេមិន បាច់ត្រូវការមកជ្រកកោននៅអាស្រ័យក្នុងវត្តឡើយ ។

កូនចៅរបស់អ្នកក្រីក្រ បានទទួលសេចក្តីសង្រ្គ្រោះអំពីបព្វជិតពុទ្ធ-សាសនិកក្នុងឆ្នាំនីមួយ ៗ បានច្រើននាក់ណាស់ ដូចយ៉ាងវត្តធំ ៗ មានក្មេង ចំនួន ៣០០ ឬ ៤០០ នាក់ ។ ចំនួនពួកក្មេងទាំងប៉ុណ្ណោះ បើជារដ្ឋាភិ-បាលទទួលយកទៅចិញ្ចឹមនោះ ទាតបង់ប្រាក់ថវិកាជាតិមិនមែនតិចទេ ។ ក្មេងទាំងនេះ ឈ្មោះថារស់នៅ ដោយអាស្រ័យនឹងមូប់ព្រះពុទ្ធសាសនា នៅជ្រកកោនក្រោមមូប់ទង់ជ័យព្រះពុទ្ធសាសនា ទំប្រឹងប្រែងសិក្សាទាល់ តែបានទទួលលទ្ធផលនៃការសិក្សារបស់ខ្លួន ៗ ។ ករណីនេះឃើញថា ព្រះពុទ្ធសាសនា នៅប្រំទេសកម្ពុជាយើង មានប្រយោជន៍ដ៏ធំទូលាយ អាចជួយសង្រ្គ្រោះទំនុកបំរុងដល់ប្រទេសជាតិបាន គឺថាព្រះពុទ្ធសាសនា ទុកជូចជាកន្ទែងអាហារូបករណ៍មួយ ដ៏ប្រសើរបស់ពួកក្មេងអ្នកក្រីក្រ, អាចចិញ្ចឹមមនុស្សក្រទ័ល ដែលមិនមានលំនៅសម្រាប់ជ្រកកោននឹង

អាហារបរិភោគ ។ វត្តពុទ្ធសាសនា ឈ្មោះថាបានជួយសម្រួលការៈ
នៃរដ្ឋាភិបាល ឲ្យធូរស្រាលបានច្រើនណាស់ ។

៦.- បពូជិតពុទ្ធសាសនិក នៅវត្តអារាមគ្រប់ស្រុក មានលោក
ចៅអធិការគ្រូសូត្រជាដើម ដែលភ្ជាប់ខ្លួនក្នុងការសិក្សាធម្មវិន័យហើយ
បានចុះស្នាមក្នុងផ្លូវសិក្សាតាមសម័យនិយម ។ ការសិក្សាច្បាប់ព្រះពុទ្ធ-
សាសនារបស់បពូជិតពុទ្ធសាសនិកនោះ ជាកម្លាំងមួយដែលនាំឲ្យមាន
ប្រាជ្ញាស្មារតីបរិបូណ៌ ក្នុងផ្លូវធម៌ផងផ្លូវលោកផង គឺថាការសិក្សានោះជួយ
ឲ្យមានទុត្តមគតិមានសមត្ថភាពដល់ខ្លួន ដល់ពួកទាសកដើងវត្ត អាច
ដឹកនាំចិត្ត ឲ្យមានសទ្ធាជ្រះថ្លាក្នុងការកសាងសេនាសនៈសម្រាប់បម្រើ
ព្រះពុទ្ធសាសនាផង បម្រើប្រទេសជាតិផង ។ ដូចយ៉ាងសាលា
សិក្សាអក្សរសាស្ត្រដែលកើតមានព្រោងព្រាតក្នុងស្រុក - វែត្រផ្សេង ។
មានវែត្រកណ្តាល - តាកែវ - ស្វាយរៀងជាដើម ច្រើនតែកើតអំពីចំហាយ
នៃការសិក្សាព្រះពុទ្ធសាសនាជាដើមអាទិ៍ គឺថាសាលាសិក្សាទាំងនោះ
កើតឡើងបានដោយសារស្មាដៃរបស់ព្រះសង្ឃមានចៅអធិការឬគ្រូសូត្រ
ជាដើមណែនាំពួកគ្រហស្ថដើងវត្តកសាងដោយឥតមើលបំណាំរដ្ឋាភិបាល
ឡើយ. លុះកសាងហើយជូនប្រគល់សាលាសិក្សានោះ ដល់រដ្ឋាភិបាល
ដើម្បីឲ្យពាជការចាត់ចែងរកគ្រូបង្រៀនតាមផ្លូវការតទៅ ដែលអាចគាំពារ
រដ្ឋាភិបាលជួយកម្លាំងឲ្យរដ្ឋាភិបាលចំណេញថវិកាជាតិបានច្រើនណាស់ ។

ដំណើរនេះសឲ្យឃើញថា "ព្រះពុទ្ធសាសនាកាលបើបុគ្គលណាមួយ
បានអប់រំសិក្សាល្អហើយ អាចនាំឲ្យខ្ចុះបំភ្លឺ ហើញសារប្រយោជន៍ក្នុង

ផ្លូវធម៌ក៏បាន ផ្លូវលោកក៏បាន" ។ ព្រះពុទ្ធសាសនាឈ្មោះថាជា សាសនាជួយប្រជាជនប្រទេសកម្ពុជា ឲ្យចេះស្រឡាញ់ប្រទេសជាតិរបស់ ខ្លួនបានដោយបរិបូណ៌ ជាសាសនាមានទ្រឹស្តីល្អអាចជួយសាងសាមគ្គី របស់ជាតិឲ្យមានវឌ្ឍនធម៌ ។

៧- អក្សរសាស្ត្រខ្មែរសម្រាប់ប្រទេសយើង បើកុំតែមានវត្តអាម នៃពុទ្ធសាសនិក ប្រហែលជាសាបសូន្យអស់ទៅហើយ ព្រោះហេតុនោះ វត្តអាមឈ្មោះថា ជាកន្លែងសម្រាប់ចិញ្ចឹមអក្សរសាស្ត្រ របស់ជាតិទុក ឲ្យរស់នៅ ។ អក្សរសាស្ត្រនេះទុកជាពន្ធឹរស្មើរបស់ជាតិ កាលបើបាត់ អក្សរសាស្ត្រ ជាតិក៏អាប់ឧនសាបសូន្យទៅជាលំដាប់ ដោយហេតុនេះ ពុទ្ធសាសនានៅប្រទេសយើងឈ្មោះថាជាសាសនាជួយជ្រោមជ្រែងរក្សា ទុកនូវអក្សរសាស្ត្រជាតិ ។

បព្វជិតពុទ្ធសាសនិក ដែលបានរៀនក្នុងផ្លូវគន្ថធុរៈគឺរៀនគម្ពីរបាលី ព្រះត្រៃបិដក ចេះចាំយល់ស័ព្ទភាសាបាលីអាចប្រែពីបាលីមកជាភាសា ខ្មែរបានដោយងាយ បានបោះពុម្ពផ្សាយចេញជាសៀវភៅធំតូចគរគោក សូមអញ្ជើញមើល ក្នុងពុទ្ធសាសនបណ្ណិត្យ ទើងឃើញសៀវភៅខ្មែរដេរ ជាស ។ សៀវភៅខ្មែរផ្សាយផ្នែកពុទ្ធសាសនាចេញច្រើនច្រាតចាំង នេះ ច្រើនតែកើតអំពីស្នាដៃព្រះសង្ឃ ដែលបានរៀនក្នុងផ្លូវព្រះពុទ្ធ សាសនា ។ ប្រទេសកម្ពុជាដែលមានវឌ្ឍនធម៌ចំរើនរុងរឿងរហែង ។ មក នេះ ដោយកម្លាំងរស្មីព្រះពុទ្ធសាសនាជាច្រើនជ ។

បញ្ញាសជាតក

ភាគទី ៤

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ
នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

វីរិយបណ្ឌិតជាតក ទី ១៧

លោកអាចារ្យ ឈឹម-ស៊ុម វត្តលង្កាប្រែពីបាលី

ឯកទា កិរ សមយេ បញ្ចាលរាជា ឯករត្តកម្ពលំ មហារដ្ឋស្ស រញ្ញោ លេសេសិ ។

កិរ បានព្ទតរៀង ។ មកថា សម័យមួយ ព្រះរាជាកូងដែនបញ្ចាល ទ្រង់បញ្ជូនសំពត់កម្ពលក្រហម ១ ទៅថ្វាយព្រះរាជាព្រះចៅដែនមហារដ្ឋ ។ ព្រះបាទមហារដ្ឋរាជ ទ្រង់ទស្សនាការយើញសំពត់រត្តកម្ពលនោះហើយ ទ្រង់ត្រាស់ព្រះរាជឧន្ការថា ព្រះបាទបញ្ចាលរាជសម្ចាញ់អញ បានបញ្ជូនសំពត់រត្តកម្ពលមានថ្ងៃប្រើនមកឲ្យអញ; បើដូច្នេះមានតែអញបញ្ជូនរតនវត្ថុមានថ្ងៃប្រើនទៅសងគេវិញ, តើអញនឹងបញ្ជូនរតនវត្ថុអ្វីអេះ ដែលមានថ្ងៃប្រើនបំផុត? ទើបព្រះចមម្ពុជទ្រង់ព្រះយោបល់យល់យើញថា រតនវត្ថុជទៃដែលនឹងមានដំឡៃស្មើនឹងពុទ្ធរតនៈគ្មានទេ, បើដូច្នេះ មានតែអាត្មាអញបញ្ជូនពុទ្ធរតនៈទៅឲ្យគេចុះ ។ លំដាប់នោះ

ព្រះបាទមហារដ្ឋរាជ ទ្រង់ចាត់ឲ្យជាងផ្ទៃដម្បារមាស ហើយឲ្យគូរវាសជា
ព្រះពុទ្ធបដិមា ដ៏ល្អវិថ្ថូថ្ថាគួរជាទីមនោរម្យមានទំហំ ១ ហត្ថ ជាត់ដោយ
ថ្នាំជាតិហិង្គុល មានពណិល្អស្រស់; ការលបើការកសាងព្រះបដិមា
ហើយសព្វគ្រប់ជាស្រេច ស្តេចទ្រង់បូជាដោយគ្រឿងសក្ការ: មាន
ប្រការផ្សេង ៗ ទ្រង់ចាត់ចែងនាវា ជំកល់ព្រះពុទ្ធបដិមា ហើយព្រះរាជា
ទ្រង់ចាត់រាជទូតឲ្យនាំទៅថ្វាយព្រះបាទបញ្ចាល ៗ ការលពួករាជទូត
រៀបនឹងបើកនាវាចេញទៅ ព្រះរាជាទ្រង់ក្រាបថ្វាយបង្គំព្រះពុទ្ធបដិមា
ត្រាស់ព្រះរាជទង្ការថា បពិត្រព្រះអង្គជាលោកនាយក, បពិត្រព្រះ
អង្គជាលោកសរណ:, តាមសេចក្តីពិត ការលព្រះសាស្តាទ្រង់គង់ព្រះ
ជន្មនៅឡើយ ទ្រង់លះបង់នូវសេចក្តីសុខល្អិតក្នុងភាពជាព្រះពុទ្ធ នឹងភាព
ជាក្សត្រទ្រង់ស្វែងកាត់សំដៅទៅកាន់ទី ដែលមានវេនេយ្យជនប្រជុំគ្នា
ព្រះអង្គទ្រង់ធ្វើវេនេយ្យជនទាំងនោះ ឲ្យបានសម្រេចប្រយោជន៍គ្រប់
ប្រការ, សេចក្តីករុណារបស់ព្រះអង្គពីមុនយ៉ាងណា, ក៏ក្នុងថ្ងៃនេះ
សូមឲ្យមានយ៉ាងនោះទៀត បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទបញ្ចាល
រ.ជសម្ចាញ់ខ្ញុំព្រះអង្គ ជាមនុស្សមិច្ឆាទិដ្ឋិ សូមព្រះអង្គទ្រង់ដោះស្តេច
នោះ ឲ្យរួចអំពីមិច្ឆាទិដ្ឋិ បើព្រះអង្គនិមន្តទៅដល់នគរបញ្ចាល ហីយ,
សូមព្រះអង្គធ្វើពុទ្ធបាដិហារ្យបង្ក្រីតសេចក្តីជ្រះថ្ថា ដល់ព្រះបាទបញ្ចាល
នោះឲ្យទាន ៗ ព្រះបាទមហារដ្ឋរាជ ទ្រង់បួងសួងយ៉ាងនេះស្រេចហើយ
ទ្រង់ចុះជូនដំណើរព្រះពុទ្ធបដិមា ត្រាតែដល់ទឹកត្រឹមព្រះសូរង ៗ ខណ:
នោះ មហាសមុទ្ទក៏ពេញដោយទទកធារាគួរនាជូចជាមាស មាន

កង្គាញ់រលកបោកបញ្ចេញឧភាស ភ្ជឹពភ្ជែមលលែមផ្ទេក ៗ, សព្វរតនាការ ដ៏ល្អរុងរឿងមានប្រការផ្សេង ៗ ច្រើនជាអនេក ក៏ផុះអណ្តែតឡើងពីបាត សមុទ្ទ ចេញផុតមកប្រតិស្ឋាននៅលើទឹក ដើម្បីជាពុទ្ធបូជា ផ្ទៃសមុទ្ទ ជលធារ ដែលវិចិត្រដោយកែវ ៧ ប្រការ ក៏រាបសាស្ទើល្អដូចជាផ្ទៃ សុវណ្ណភាជន: មានបទុមជាតិបញ្ចពណ៌ ដុះផុះលេចឡើងដោយល្អជា ជួរជាចន្ទោះ, ពួកនាគរាជទាំងអស់ក៏ចេញអំពីនាគពិភព ជាមួយនឹងពួក នាគជាបរិវារ បូជាដោយគន្ធមាលាច្រៀងសរសើរដោយសំឡេងដ៏ពីរោះ អស្ចារ្យ ហក់ហែលចោមរោមជាបរិវារនៅនាកណ្តាលសមុទ្ទ, ទេព្តាទាំង ឡាយក៏រោយរាយទិព្វបុប្ជា ចុះមកអំពីអាកាស ទ្ទះប្រគំដោយទិព្វតូរ្យតន្ត្រី ទ្ទះបើកធត្រលើកទង់បាំងសំពត់សុទ្ធសឹងវិចិត្រដោយមាស ចោមរោម ពេញទាំងអាកាស គួរជាទីអស្ចារ្យ ។

ធម្មតាពុទ្ធានុភាព ជាសភាពដែលអ្នកផងគិតពុំបាន ប្រមាណមិន កើត; អម្បាលកាលដែលព្រះអង្គទ្រង់ចូលបរមនិព្វានទៅ នៅមានតែ ព្រះពុទ្ធបដិមា ម្តេចទ្រង់មានអានុភាពអស្ចារ្យដល់ម្ទ៉ះ, បើដូច្នោះចាំបាច់ និយាយថ្វីដល់អង្គព្រះជិនស្រីកាលទ្រង់គង់ព្រះជន្មនៅ ! ។

រាជទូតទាំងឡាយ បានដល់នគរបញ្ចាល ក៏ចូលទៅក្រាបបង្គំគាល់ ព្រះរាជា ដំណាលអំពីសេចក្តីអស្ចារ្យ សព្វគ្រប់ប្រការ ។ រាជា តំ អច្ឆរិយំ សុត្វា ព្រះរាជាបានទ្រង់ព្រះសវនាការ ព្ធសេចក្តីអស្ចារ្យដូច្នោះ ក៏ទ្រង់មានព្រះបីតិសោមនស្ស ស្រស់ស្រាយរីករាយក្នុងព្រះរាជហ្ឫទ័យ ទើបព្រះចក្រីទ្រង់ព្រះចិន្តនាការគិតថា សម្ថាញ់អញ ឲ្យជាងគួរព្រះពុទ្ធ-

ឋដំមាធ្វើមហាសក្ការៈហើយ ឋញ្ជូនមកឲ្យអញ; ចំណែកខាងអាត្មាអញ គួរតែធ្វើសក្ការៈឲ្យច្រើនជាងនេះជាទ្វេគុណ ហើយសឹមនាំព្រះពុទ្ធឋដំមា អំពីនាក់មក ។ គ្រានោះព្រះពជាខ្ចង់ចាត់ចែងគ្រឿងសក្ការបូជា ច្រើនជាអនេកប្រការ ក្សត្រាខ្ចង់ចេញអំពីព្រះពជមន្ទីរ មានឋតុរង្គអង្គពលសេនីយ កុងរបាំតួរ្យតន្ត្រី ឧឹងឋណ្ដាជនានាម៉ឺនសព្វមុខមន្ត្រីចោមរោមជាបរិវារ, ឋណ្ដាជនទាំងអស់គ្នា សុទ្ធតែឋញ្ចេញសំឡេងកាថាថ្វាយដំយមង្គល ដរាឋតែដល់មាត់កំពង់ ខ្ចង់ថ្វាយឋង្គំព្រះពុទ្ធឋដំមាដោយឋបញ្ចង្គ-ប្រតិស្ឋានខ្ចង់ឋានឋូជាដោយខៀនធូឋគន្ធមាលា ដោយព្រះពជាខ្ចង់ចុះទៅកុងទឹកឋប្រមាណត្រឹមព្រះសូរង, ខ្ចង់ឃើញព្រះពុទ្ធឋដំមា ក្សត្រាខ្ចង់មានព្រះពជហ្ឫទ័យរីករាយណាស់ ទើឋត្រាស់ព្រះពជឋន្ដាវថា ឋតិត្រព្រះអង្គដ៏ចំរើន ខ្ញុំសូមយកព្រះអង្គជាទីពឹងឋដរាឋដល់អស់ជីវិត, ឋ្ងៃនេះខ្ញុំឋានព្រះអង្គជាទីពឹងស្មើជីវិតហើយ. សូមព្រះដ៏មានព្រះភាគទទួលជាឋ ថាខ្ញុំព្រះករុណាជាឧឋាសក ។

ដោយអំណាចព្រះពជសទ្ធាព្រះឋាទឋបញ្ចាល ឧឹងសេចក្ដីអធិដ្ឋានព្រះឋាទមហាវដ្ដ ក៏ព្រះពុទ្ធឋដំមានោះសំដែងឋាដិហារ្យអណ្ដែតឡើងផ្ដត់ព្រះកែនតែនព្រះឋាទឮដ៏អាកាស; ធម្មណ្ឌរង្សីស្មើតាំង ៦ ពណ៌ គឺខៀវ លឿង ក្រហម ស ហង្សឋាទ ឧឹងពណ៌ចំរុះផ្លែកៗផ្សាយចេញឆ្វេលឆ្វាត់ឋាត់អំពីព្រះពុទ្ធឋដំមានោះ ។ រស្មីខៀវ ចេញមកត្រង់កន្ទែងដែលសមដោយពណ៌ខៀវ ឃើញសុទ្ធតែពណ៌ខៀវដូចគេឋាក់ដោយផ្កាត្រកៀត ឧឹងផ្កានិលុប្បល ។ រស្មីលឿង ចេញមកត្រង់កន្ទែងដែល

សមដោយពណិលឿង; ទិសាភាគទាំងមូលប៉ែកខាងរស្មីលឿង ក៏មានពណិលឿងដូចគេស្រោបដោយទឹកមាស ឬ ដូចគេពាសដោយដម្ការសុវណ្ណ ។ រស្មីក្រហម ចេញមកត្រង់កន្ទែងដែលសមដោយពណិក្រហម; ទិសាភាគទាំងមូលប៉ែកខាងរស្មីក្រហម ក៏ដូចជាគេស្រោបដោយត្របកផ្ការច្យា ។ រស្មីសចេញមកត្រង់កន្ទែងដែលសមដោយពណិស; ទិសាភាគទាំងមូលប៉ែកខាងរស្មីស ក៏មានពណិសដូចគេពាសដោយដម្ការប្រាក់ ។ រស្មីហង្សបាទ ចេញមកត្រង់កន្ទែងដែលសមដោយពណិហង្សបាទ; ទិសាភាគទាំងមូលប៉ែកខាងរស្មីហង្សបាទ ក៏ប្រាកដដូចជាផ្ការនោងព្រៃ ។ រស្មីចំរុះផ្ទេក ។ ចេញមកត្រង់កន្ទែងដែលសមដោយពណិចំរុះផ្ទេក ។; ទិសាភាគទាំងមូលប៉ែកខាងរស្មីចំរុះផ្ទេក ។ ក៏ប្រាកដស្មើដោយផ្ទេកបន្ទោរ ។ ធព្ទណ្ណរង្សីនោះ ក៏ផ្សាយផ្សព្ទចាប់ជាប់ដល់មហាផែនដី ។ មហាប្រថពីមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ក៏មានពន្ធឹដូចជាដម្ការមាស; ទឹកក្នុងទីសមុទ្ទព្រៃកស្ទឹងបឹងស្រះទាំងអស់មានពណិដូចសន្ធឹកមាស ។ រស្មីឧកាសផ្សាយទៅខាងលើ រហូតដល់ធកាមាវចរទេវលោក នឹងព្រហ្មលោក, ផ្សាយទៅជុំវិញ រហូតផុតអនន្តលោកធាតុ ។ ក្នុងទីដម្ឆន់ប៉ុណ្ណោះតតមានពន្ធឹព្រះចន្ទ ពន្ធឹព្រះអាទិត្យ ឬ ពន្ធឹទេវតា ផ្សាយទ្បើងបានសោះ មានត្រឹមតែធព្ទណ្ណរង្សីនៃព្រះបដិមាករនោះទាំងអស់ ផ្សព្ទផ្សាយទៅតតសល់ចន្ទោះទីដម្ឆន់ណាទ្បើយ; ទុកជាមហាព្រហ្ម ដែលអាចផ្សាយពន្ធឹឲ្យភ្ទឹពេញ ១ ម៉ឺនលោកធាតុបានក៏ត្រឲ្យប់ជាតតមានតេជះ ដូចជាអំពឹលអំពែកក្នុងវេលាដែល

ព្រះអាទិត្យរះឡើង ដូច្នោះ ។ គ្រានោះ សម្តេចសក្កទេវរាជ ព្រមទាំងពពួកទេវបុត្តទេវធីតា បូជាដោយគ្រឿងគន្ធមាលា នាំគ្នាផ្គងអញ្ជលីបិតនៅឰដ៏អាកាស ។ ពួកមនុស្សម្នាមហាជន ចេញមកអំពីទិសទីគ្រប់ជម្ពូទ្វីប មូលមកត្រៀបគ្រា, មនុស្សទើងទេវតាបានឃើញគ្នាទៅវិញទៅមកដោយជាក់ច្បាស់ ។

ព្រះរាជាទ្រង់ទស្សនាការ ឃើញឋាដិហារ្យនោះ ក៏មានព្រះរាជហប្ញទ័យរីករាយក្រៃពេក ទើបទិមន្តព្រះពុទ្ធបដិមាថា បពិត្រព្រះអគ្គដ៏ចំរើន, សូមព្រះអង្គទិមន្តមកគង់លើសុវណ្ណសិវិកានេះ ។ ខណៈនោះ ព្រះពុទ្ធបដិមាក៏ទ្រង់ចុះពីអាកាស មកគង់លើព្រះសុវណ្ណសិវិកា ។ ព្រះរាជា ព្រមទាំងពពួកពលសេនា ក៏នាំព្រះពុទ្ធបដិមា ដោយសុវណ្ណសិវិកា ទៅដំកល់ក្នុងព្រះរាជមន្ទីរ ហើយបូជាដោយទៀនធូបគន្ធមាលា; ព្រះរាជាទ្រង់រំពឹងពិចារណាចំពោះព្រះពុទ្ធគុណ ទ្រង់ពោលជាបទព្រះគាថា ថា

យោហំ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ឧបាសកតំ ទេសេមិ សក្យពុទ្ធស្ស សាសនេ
មម បិត្តំ បសាទេត្វា មោចេសិ ភវទុក្ខតោតិ ។

“ខ្ញុំព្រះករុណា សូមយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង, សូមប្រកាសខ្លួនជាឧបាសកក្នុងសាសនានៃព្រះសក្យពុទ្ធ, សូមព្រះអង្គញុំាង

ចិត្តខ្ញុំព្រះករុណាឲ្យជ្រះថ្លា ហើយដោះខ្ញុំព្រះករុណាឲ្យរួចអំពីសេចក្តីទុក្ខ
ក្នុងភព" ។

ព្រះរាជាមានព្រះសរីរៈពញដោយបីតិជ្រាំពណ៌ មានព្រះរាជអំណរ
ក្រៃពេក ទើបទ្រង់ព្រះចិន្តនាគិតថា "សម្ខាញ់អញបានឲ្យជាងសាងព្រះ
ពុទ្ធបដិមា មានសភាពយ៉ាងនេះ បើជូច្នេះគួរតែអាត្មាអញ សាងព្រះ
ពុទ្ធបដិមា យ៉ាងល្អថ្ងៃថ្ងាជាងនេះជាទ្ធេតុណ, ទើបព្រះអង្គបាត់ឲ្យយកខ្ទឹម
ចន្ទន៍ ឲ្យហៅជាងចម្ខាក់មក ទ្រង់ត្រាស់ព្រះរាជបញ្ជាថា អ្នកឯងចូរយក
ខ្ទឹមចន្ទន៍មានជំទ្យេប្រើនេះ ទៅសាងព្រះពុទ្ធបដិមា ។ ជាងចម្ខាក់
ក៏ទទួលព្រះរាជឡន្ការ យកខ្ទឹមចន្ទន៍នោះទៅសាងព្រះពុទ្ធបដិមា រួចសេច
ហើយចូលទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជសម្ការ, ព្រះ
ពុទ្ធបដិមា ទូលព្រះបង្គំជាខ្ញុំបានសាងសេចហើយ ។ ព្រះរាជាទ្រង់ឲ្យ
យកព្រះពុទ្ធបដិមានោះមកជំកល់ទុកលើសាលាចាត់ឲ្យថែរក្សា មិនឲ្យ
ប្រហែសធ្វេស ។ លំជាប់នោះ ព្រះរាជាឲ្យឃោសនាថា មនុស្សអ្នក
ទតរទាំងអស់ នរណាមានមាស សូម្បីតែបន្តិចបន្តួច ក៏ចូរយកមកទឹប
ព្រះពុទ្ធបដិមា ជាមួយនឹងព្រះរាជាតាមសទ្ធាចុះ ។

ត្រានោះ ព្រិះពោធិសត្ទឈ្មោះ រីរិយបណ្ឌិត ជាអ្នកកំសត់ទុគិត
ទីទ័លក្រនៅក្នុងនគរនោះដែរ ។ ភរិយាពោធិសត្ទនោះ ឈ្មោះនាង
សុជាតា, មានកូនប្រុសម្នាក់ឈ្មោះ រេវត្តកុមារ ។ ចំណែកខាងព្រះ
ពោធិសត្ទ បានព្ទសំឡេងឃោសនា ក៏គិតថា "អាត្មាអញ គួរតែធ្វើ
កុសលជាមួយនឹងព្រះរាជាក្នុងត្រាំនេះ, ប៉ុន្តែបើអាត្មាអញទ័លក្រជល់ម្ចុ៉ះ

ផ្ទើម្តេចនឹងបានមាស ! ណ្ហើយចុះអាត្មាអញ់លក់ខ្ជូន យកមាសមកទឹប
ព្រះពុទ្ធបដិមាជាមួយនឹងព្រះរាជាចុះ"; លុះគិតស្រេចដូច្នោះក៏ទៅផ្ទះ
និយាយនឹងកូនប្រពន្ធថា ម្នាលនាងសុជាតា, ហៃបាវេត្ត, ខ្ញុំលាអ្នក
ទាំងឡាយហើយ ។ នាងសុជាតាសួរថា បពិត្រស្វាមី, អ្នកអញ្ជើញ
ទៅណា? ពោធិសត្ត្របាប់ថា ខ្ញុំព្ធសំឡេងយោសនា ក៏ចង់ធ្វើកុសល
ជាមួយនឹងព្រះរាជា, ព្រោះហេតុនោះបានជាខ្ញុំចង់លក់ខ្ជូន យកថ្ងៃមក
ធ្វើកុសល ។ កវិយាព្ធដូច្នោះហើយ ក៏ញាប់ញ៉ីរអស់ដួងហ្ចុទ័យ ដោយ
ហេតុតែខ្ជូនជាស្រីមានចិត្តទន់ ក៏មានទឹកក្នែកហូររហ៍ាម ពុំបណ្តោយតាម
ត្រឡប់ប៉ែរជានិយាយថា បពិត្រស្វាមី, អ្នកមានប្រសាសន៍ម្តេចដូច្នោះ,
ខ្ជូនខ្ញុំ ជាខ្ញុំស្រីរបស់អ្នក, វេត្ត ជាខ្ញុំប្រុសរបស់អ្នកស្រាប់, សូម
អ្នកយកយើងទាំងពីរនាក់នេះទៅលក់ឲ្យអ្នកមានទ្រព្យណាមួយ, យក
សំពត់ក៏ដោយ យកប្រាក់ក៏ដោយ យកមាសក៏ដោយ តាមតែអ្នកប្រាថ្នា,
យកមកចាត់ការធ្វើបុណ្យតាមសេចក្តីសប្បាយចុះ ។ ពោធិសត្ត ក៏
និយាយដដែលៗពីរដងបីដង ក៏នៅតែជំនះមិនឈ្នះកវិយានោះសោះ,
ទើបយល់ព្រមថា "សាធុ សាធុ ល្អហើយនាង, នាងឯង ក៏ប្រហែលជា
កល្យាណមិត្ត ធ្លាប់បំពេញទានបារមី ជាមួយគ្នា ១ ពាន់ជាតិ ១ សែនជាតិ
មកហើយ"; ទើបពោធិសត្តនាំយកកូនប្រពន្ធទៅលក់ឲ្យអ្នកមានទ្រព្យ
យកថ្ងៃជាមាស មកប្រគល់ឲ្យជាងមាសថា ចូរអ្នកផែមាសនេះហើយ
ឲ្យបានដម្បារសន្ធឹកស្ពើងៗឲ្យខ្ញុំ ។ កាលជាងមាសផែមាសស្រេច
ពោធិសត្តចង់ទៅទឹបព្រះពុទ្ធបដិមា ក៏យកដម្បារមាសទៅឯសាលា

និយាយនឹងមនុស្សអ្នករក្សាសាលាថា បពិត្រអ្នកតាំងឡាយដ៏ចំរើន, ខ្ញុំមកនេះដោយបំណងចង់ទឹបមាសព្រះពុទ្ធបដិមា ។ អ្នករក្សាប្រាប់ថា ព្រះរាជាបំរុងនឹងទឹបព្រះពុទ្ធបដិមាក្នុងថ្ងៃឯណោះ, ឥឡូវនេះ អ្នកឯងទឹបមុនព្រះរាជាជួចម្ពេចបាន ។ ពោធិសត្វព្ធសំដីនោះហើយ ក៏តក់ស្ងត់រន្ធត់ក្នុងហ្ឫទ័យ ទើបលាន់មាត់បញ្ចេញសំដីថា ឧ! បំណងរបស់អញ់ខុសទទេទៅហើយតើ, ដំណើរនេះក៏ព្រោះតែអាត្មាអញជាមនុស្សកំសត់, មុខគួរឲ្យអាស្ងរចិត្តណាស់, ស្ងឹលះកូនប្រពន្ធឲ្យទៅនៅនឹងគេ! ឥឡូវនេះបែរជាឥតអំពើសោះ ។ ត្រានោះ ពោធិសត្វទោះបីបានព្ធសំដីអ្នករក្សាសាលាយាត់ជូច្នោះ ដោយហេតុតែមានសទ្ធាខ្ជាំង ក៏ធ្វើហាក់ដូចជាមិនព្ធសោះ ខំបង្រុះចូលទៅកាន់សាលា ។ អ្នករក្សាសាលានិយាយយាត់ចាប់ទាញឲ្យចេញមកវិញ ។ មនុស្សតាំងឡាយដទៃទៀត ខំជួយធ្ងៀតរកឧបាយ និយាយប្រាប់តាមទំនងថា នែអ្នកវីរិយបណ្ឌិត, បើអ្នកចង់ទឹបមាសព្រះពុទ្ធបដិមាហ្នឹងណាស់, ចូរអ្នកឯងទៅក្រាបបង្គំទូលសូមអនុញ្ញាតព្រះរាជាសិន ។ ពោធិសត្វក៏ទទួលពាក្យនោះថា "ពាក្យដែលអ្នកតាំងឡាយនិយាយនេះ ពេញជាត្រូវល្អណាស់," ហើយកាន់ដម្បារមាស ចូរទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំចង់ទឹបមាសព្រះពុទ្ធ-បដិមា, សូមព្រះអង្គទ្រង់ព្រះរាជាអនុញ្ញាត ។ ព្រះរាជា ទ្រង់មានព្រះរាជបំណងបម្រុងនឹងបញ្ជោតពោធិសត្វនោះ ក៏ទ្រង់ត្រាស់ព្រះរាជឧង្ការថា បើព្រះពុទ្ធបដិមា មានព្រះពុទ្ធដីកាចរចាជាមួយនឹងអ្នកឯង សឹម

អ្នកឯងទំបមាសព្រះអង្គចុះ; បើព្រះឥង្គមិនមានព្រះពុទ្ធដីកាទេ, អ្នកឯង
កុំទំបមាសព្រះអង្គឡើយ ។ ពោធិសត្វឮព្រះពាជនុង្ការនោះហើយ ក៏កែ
រយសប្បាយក្នុងចិត្តភ្ញាយបង្គំលាចេញមក យកមាសមកទូលលើក្បាល
ដើរទៅកាន់សាលា; អ្នករក្សាសាលាដឹងថា ព្រះពាជាទ្រង់ព្រះពាជទាន
ឧកាស កំបណ្តាយឲ្យចូលឥតមានហាមឃាត់ ។ ពោធិសត្វយកមាស
ទៅដំកល់ជិតព្រះពុទ្ធបដិមា លុតជង្គង់លើកហត្ថា ថ្វាយបង្គំប្រណម្យ
ក្រែបទាបព្រះបាទា ពោលពណ៌នាសរសើរព្រះពុទ្ធបដិមាថា បពិត្រ
ព្រះអង្គដ៏ចំរើន, ពីមុននេះ ខ្ញុំព្រះអង្គបានឮថា កាលដែលព្រះអង្គទ្រង់
ត្រាច់ន្នាត់កងកពាដ្ឋសង្ក្រា តែកាលដែលព្រះអង្គទៅជាពោធិសត្វទៅ
ឡើយ ព្រះអង្គតែងទ្រង់អនុគ្រោះដល់សត្វទាំងឡាយ, របស់អ្វីដែល
មាន ព្រះអង្គតែងប្រទានឥតមានស្តាយ, ទិយាយតឹមតែព្រះសីរ ដែល
ព្រះអង្គធ្លាប់កាត់ឲ្យទៅជាទាន បើប្រមូលមកគរជាគំនរ ធ្លាកដជាធំ
ជាងកំពូព្រះសុមេរុ; ព្រះនេត្រច្រើនជាងផ្កាយ, ព្រះមំសៈច្រើនជាងផែនដី,
ព្រះលោហិតច្រើនជាងទឹកសមុទ្រ, បើសត្វឯណាសុំសាច់បេះដូងដួង
ហ្អែយ ឬសរីរៈពាក់កណ្តាលក្តី សរីរៈទាំងមូលក្តី ព្រះអង្គតែងទ្រង់
ប្រទានឥតមានសេសសល់ ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធផង ដើម្បី
សេចក្តីសុខដល់សត្វទាំងឡាយផង; បពិត្រព្រះអង្គដ៏ចំរើន, បើពាក្យ
ដែលខ្ញុំព្រះអង្គបានឮមកដូច្នេះជាពាក្យពិតប្រាកដមែន, សូមព្រះអង្គ
ទ្រង់អនុគ្រោះបើកព្រះទ្វារ មានព្រះពុទ្ធដីកាជាមួយនឹងខ្ញុំព្រះករុណាកុំ

ខាន; ប៉ើព្រះអង្គពុំមានព្រះពុទ្ធដីកាជាមួយផងទេ, ខ្ញុំព្រះករុណានឹងស្ទាប់ទៀបព្រះបាទាជាប្រាកដ ។

ខណៈនោះ ទេវតារក្សាផែនដី បានញ្ជសំដីពោធិសត្វហើយ ក៏អត់ទ្រាំពុំបាន, ជ្រែកចូលក្នុងព្រះពុទ្ធបដិមា ធ្វើអង្គព្រះពុទ្ធបដិមាឲ្យកំរើកឡើង ដូចជាកាលដែលគង់ព្រះជន្មនៅដូច្នោះ ។ ធព្ទណ្ណរង្សី (រស្មីទាំង ៦ ពណ៌) ក៏ផ្សាយចេញមក ធ្វៀលធ្វាត់ច្រវាត់សព្វទិស ។ ទើបព្រះអង្គទ្រង់ប៉ើកព្រះឧស្ឆ មានព្រះពុទ្ធដីកាថា ល្អហើយវីរិយបណ្ឌិត, ចូរអ្នកឯងធ្វើតថាគត តាមសេចក្តីពេញចិត្តចុះ ។ ព្រះសូរសៀងព្រះពុទ្ធរូបនោះ ក៏ញ្ជផ្សាយទៅពេញនគរបញ្ចាលទាំងមូល ។ គ្រានោះពោធិសត្វយកមាសមកលៃស្មានមើល ឃើញថាមិនគ្រាន់ ទើបគិតតទៅទៀតថា មាសនេះជាដំឡៃនៃកូននឹងប្រពន្ធ; ឥឡូវនេះប៉ើទឹបមិនគ្រាន់, តើអាត្មាអញធ្វើដូចម្តេចនឹងបានមាសពីណាមកបំពេញ ទៀត; ឧ! ប៉ើតែយ៉ាងនេះសមជាបំណងអាត្មាអញមិនសម្រេច; ឧ! លោកណាអើយមានអានុភាពខ្លាំងពូកែ អាចផែសាច់ខ្ញុំឲ្យទៅជាមាសកើត; ខ្ញុំនឹងប្រគល់ខ្លួនឲ្យពន្ទះសាច់យកទៅផែតាមការ ។ គ្រាដែលព្រះពោធិសត្វកំពុងគិតដូច្នោះ ក៏មហាប្រឹថពីមានកម្រាស់ ៦ សែន ៤ ម៉ឺនយោជន៍ កក្រើករំពើកឡើង បញ្ចេញចំហាយកំសួល ក្តៅរំជួលដល់បណ្ឌុកម្ពល-សិលា ទែនទិព្វអាស្នានៃសម្តេចសក្កទេវរាជ ។ ព្រះឥន្ទទ្រង់អាវជ្ជនាការពិចារណាជ្រាបហេតុនោះហើយ ទ្រង់ហោះផ្ទោះចុះចាកទេវលោកមកមួយរំពេច និម្មិតព្រះអង្គជាជាងមាស ចូលទៅឈរទល់មុខគ្នានឹង

ពោធិសត្វ ។ ពោធិសត្វសួរថា អ្នកឯងជាអ្វី? ព្រះឥន្ទ្រឆ្លើយថា ខ្ញុំជាជាងមាស ។ ពោធិសត្វសួរថា អ្នកជាជាងឯងអាចផ្ទៃសាច់មនុស្សឲ្យកើតជាមាសបានឬទេ? ព្រះឥន្ទ្រឆ្លើយថា ខ្ញុំអាចធ្វើបាន ។ ពោធិសត្វមានចិត្តរីករាយសោមនស្សនិយាយថា បើពិតដូច្នោះមែន, ខ្ញុំនឹងឲ្យសាច់ខ្ញុំ ឲ្យអ្នកជាជាងឯងផ្ទៃក្នុងថ្ងៃនេះ ។ ព្រះឥន្ទ្រឆ្លើយថា សាធុ ល្អហើយ, ខ្ញុំនឹងធ្វើតាមពាក្យអ្នកឲ្យខាងតែបានសម្រេច ។ ពោធិសត្វគិតនឹងឲ្យសាច់ ក៏ដួងជារកកាំបិតពុំបាន, ទើបពោធិសត្វងើបមើលទៅខាងលើអាកាស ឃោសនាចំពោះទេវតាទាំងឡាយថា

ភោន្តោ ភោន្តោ ទេវសង្ឃា សុណន្តុ វចនំ មម
សចេ អនាគតេ កាលេ ពុទ្ធោ ហោស្សាមិ នាយកោ
តិមិនា មំសទានេន មម ចិត្តពលេន ច
មយ្ហំ បុញ្ញតេជេន សត្តំ បតតុ សម្មុខាតិ ។

"បពិត្រពួកទេវតាទាំងឡាយដ៏ចំរើន, សូមទេវតាទាំងឡាយស្តាប់ពាក្យខ្ញុំ, បើខ្ញុំនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលជាអនាគតមែន, សូមឲ្យគ្រឿងសស្ត្រាវុធធ្លាក់ចុះក្នុងទីចំពោះមុខ ដោយតេជៈមំសទាននេះផង ដោយកម្លាំងចិត្តរបស់ខ្ញុំផង ដោយតេជៈបុណ្យរបស់ខ្ញុំផងកុំខាន" ។

លំដាប់នោះ គ្រឿងសស្ត្រាក៏ធ្លាក់ពីលើអាកាស មកប្រតិស្ឋានក្នុងទីចំពោះមុខពោធិសត្វ ។ ពោធិសត្វ ចាប់យកគ្រឿងសស្ត្រា បម្រុងនឹងអាសាច់ ក៏អធិដ្ឋានម្តងទៀតថា "ខ្ញុំសូមទឹបមាសព្រះពុទ្ធបដិមា

ជាបដល់ពេញសព្វគ្រប់, បើមិនទាន់ពេញនៅឡើយទេ, សូមឲ្យខ្ញុំកុំអាលស្លាប់"; លុះអធិដ្ឋានដូច្នោះហើយ ក៏អារសាច់ហុចទៅឲ្យជាងមាស; ជាងមាសទទួលយកសាច់នោះទៅផែកើតជាដម្បារមាស ល្មមបិទពាសព្រះពុទ្ធរូបបានហើយប្រគល់មកឲ្យពោធិសត្វវិញភ្លាម ។ ពោធិសត្វឃើញដុំសាច់របស់ខ្លួន ដែលជាងមាសផែកើតជាដម្បារមាសដូច្នោះ ក៏មានចិត្តរីករាយសោមនស្សជាកិរិយាភាព ទើបគិតថា "បំណងរបស់អាត្មាអញសម្រេចហើយ"; ហើយយកមាសនោះទៅទឹបព្រះពុទ្ធបដិមា; កាលបើការទឹបនោះរួចស្រេចហើយ ក៏ក្រាបចុះទៀបព្រះបាទានៃព្រះពុទ្ធបដិមា សន្ទប់ហុត់សញ្ញានៅក្នុងទីនោះ ។ ទើបសម្តេចព្រះសក្កទេវរាជ យកថ្នាំទុសថវិញ្ញ មកលាបសព្វសរីរៈកាយនៃពោធិសត្វ ហើយស្រោចស្រង់ដោយទឹកអប់វិញ្ញ ។ ដោយអានុភាពព្រះឥន្ទ្រធំអានុភាពបុណ្យ ក៏ពោធិសត្វរស់ពានមានជីវិតឡើងវិញ ។ ព្រះឥន្ទ្រពោលសរសើរពោធិសត្វថា ម្នាលមហាបុរស, ចូរអ្នកដឹងចុះថា អ្នកបានធ្វើបុញ្ញកម្មនេះ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតជាប្រាកដ ។ ពោធិសត្វ ឮពាក្យនោះហើយក៏សួរថា ម្នាលសំឡាញ់, អ្នកមកពីណា? ព្រះឥន្ទ្រឆ្លើយថា ខ្ញុំមកពីឋានសួគ៌, ខ្ញុំជាតួអង្គសក្កទេវរាជ មកកាន់សំណាក់អ្នកព្រោះហេតុតែអ្នកជាបុគ្គលមានសទ្ធាច្រើន ។ ព្រះឥន្ទ្រឆ្លើយតែប៉ុណ្ណោះហើយ ក៏ប្រែកេរជាព្រះឥន្ទ្រវិញ បញ្ចេញរស្មីភ្លឺរុងរឿងទៅឰដ៏អាកាស ដូចជាព្រះអាទិត្យក្នុងពេលពេញពន្លឺធំ, លាពោធិសត្វត្រឡប់ទៅឋានរបស់ព្រះអង្គវិញ ។

ត្រានោះ ព្រះរាជាព្រមទាំងបណ្ណាជនអ្នកនគរទាំងឡាយ មានសេចក្តីរីករាយ ធ្វើសក្ការៈចំពោះពោធិសត្ត ។ ចំណែកខាងព្រះរាជាក៏អញ្ជើញពោធិសត្តឲ្យអង្គុយ លើសុពណិសិវិកាទ្រង់ព្រះរាជទានសម្បត្តិផ្សេងៗ ជាច្រើនប្រការទៀត ។ ពោធិសត្តព្រមទាំងបុត្រកវិយា សោយសម្បត្តិជាសុខត្រប់ប្រការ, មានកូមទេវតា អាកាសទេវតា អភិបាលថែរក្សាសព្វកាលវេលា បុគ្គលមានសេចក្តីសម្រិទ្ធី បរិបូណិដោយភោគសម្បីទត្រប់ជំពូក ឥតមានរោគអាពាធព្យាធិ អស់មួយជីវិត ។

ក្នុងកាលដែលពោធិសត្តជិតអស់ជន្មាយុ ទេវតាទាំងឡាយក្នុងធកាមាវចរសួគិ បានតាំប្រាសាទមាស ៦ ពេញដោយស្រីទេពអប្សរចុះមកអំពីទេវលោកទាំង ៦ ជាន់ មកប្រតិស្ឋាននៅខាងលើអាកាសហើយអញ្ជើញពោធិសត្តថា បពិត្រអ្នកជានិរទុក្ខ, សូមអ្នកអញ្ជើញមក, សូមអ្នកទៅត្រកអរក្នុងទេវលោករបស់យើងឯណោះ ។ ពោធិសត្តសួរថា ចុះពោធិសត្តទាំងឡាយ ដែលបានកសាងពោធិសម្ភារហើយ តែងបានទៅកើតក្នុងបានសួគិជាន់ណា? ទេវតាទាំងឡាយជម្រាបថា តែងបានទៅកើតក្នុងពិភពតុសិត ។ ពោធិសត្តថា បើដូច្នោះ ខ្ញុំនឹងទៅក្នុងពិភពតុសិតនោះឯង ។ ទេវតាទាំងឡាយ ក៏ទទួលលើកយកវិញ្ញាណក្ខន្ធរបស់ព្រះពោធិសត្តនោះ ដាក់លើរាជរថ ។ ពោធិសត្តក៏រំលត់ផ្តាច់ជីវិតិន្ទ្រិយ អំពីមនុស្សលោកនេះ ទៅកើតក្នុងពិមានមាស កំពស់ ១២ យោជន៍ ពេញដោយស្រីទេពអប្សរបវរកញ្ញានៅនាពិភពតុសិតឯណោះ មួយរំពេច ដូចជាគេដេកលក់ហើយភ្ញាក់ឡើងភ្លាមដូច្នោះ ។ សម្បត្តិ

ឯណាដែលពោធិសត្វចង់សោយ, ក៏សឹងសម្រេចឡើងព្រមតតមានខ្ទះ
កន្ទះ ។ ពោធិសត្វបិតនៅក្នុងទិព្វសម្បត្តិនោះដោយសេចក្តីរុងរឿង
ថ្ងៃថ្ងាណាស់ ឈ្នះអស់ទេវតាទាំងពួង ដោយពណិសម្ឃុរដោយយស
បរិវារ ដោយតស្សរភាព ។ ពោធិសត្វសោយសម្បត្តិក្នុងហានសួតិមាន
សភាពដូច្នោះអស់កាលជាយូរអង្វែង, ទើបព្រះអង្គមានចំណង់ចង់បំពេញ
ព្រះបារមី ក៏ច្យុតស្រុតចុះចាកសួតាិលីយ មកទ្រង់សំភពចាប់កំណើត
កើតក្នុងមហារាជត្រកូលមានវ័យវឌ្ឍនាការចំរើនធំឡើង ទ្រង់បានសោយ
រាជសម្បត្តិ ជាស្តេចចក្រពត្តិ ត្រប់សង្កត់សកលមណ្ឌលប្រឹថពី ត្រួត
ត្រាលើបណ្តាជនប្រុសស្រី ដោយទឹកព្រះរាជហ្ឫទ័យប្រកបដោយធមិ
មេត្តា ឥតប្រើអាជ្ញា ឥតប្រើគ្រឿងសស្ត្រាឡើយ, ទ្រង់រក្សាអាណា
ប្រជានុរាស្ត្រ ដោយសង្គហវត្ថុទាំង ៤ ប្រការ, ពួកព្រះរាជា ដែល
ជាប្រទេសរាជក្នុងទិសទាំង ៤ ក៏ព្រះអង្គផ្តល់ឲ្យនូវសេចក្តីសុខក្សេមក្សាន្ត
ឥតឲ្យមានទុក្ខព្ឱយឡើយ, ហើយព្រះអង្គតែងទ្រង់ចំរើននូវពោធិសម្ភារ
ដើម្បីឲ្យបានត្រាស់ប្រាជ្ញាសពិជ្ជតាញាណ ។ តពីនោះមក ព្រះអង្គ
តែងអន្ទោលទៅក្នុងទេវលោកនឹងមនុស្សលោក បំពេញព្រះបារមី
ជរាបជល់បានសម្រេចត្រប់ប្រការ ទ្រង់បានទៅកើតក្នុងពិភពតុសិត,
ច្យុតអំពីពិភពតុសិត បានមកកើតក្នុងសក្យត្រកូលជាអង្គព្រះអាទិច្ចវង្ស
ទ្រង់លះបង់រាជសម្បត្តិ កាត់ព្រះរាជហ្ឫទ័យ ចេញទៅទ្រង់ព្រះផ្ទួសធ្វើ
បធានកិរិយាអស់ ៦ វស្សា ហើយចូលទៅកាន់ពោធិមណ្ឌល ឡើង
គង់លើរតនបល្ថ័ង្ក ជាមង្គល កំចាត់បង់នូវមារព្រមទាំងពលដ៏ច្រើនដេរ

ដាសកម្រាស់ ៣០ យោជន៍ ។ ទើបពពួកទេវតាកុន ១ ម៉ឺនចក្រវាឡ
មូលមកប្រជុំគ្នាកុនចក្រវាឡមួយ បើកធត្រលើកទង់សំយុនកម្រងមាលា
ជាបសាចក្ខ្ជា ពាសពេញទាំងអាកាស ដាសពាសដល់ផែនប្រឹថពី ។
ទេវតានឹងព្រហ្មទាំងឡាយពួកខ្ទះ កាន់ផ្ទិតបាមរពាសលំអដោយផែន
សុវ៉ណ្ណ មានដងសម្រាប់កាន់រ៉ាចិត្រដោយកែវផនួនីល បក់ផាត់ថ្ទាយ
ពីខាងលើអាកាស ។ ត្រឿងបូជាទាំងឡាយប្រើនដេរដាស ចង្អៀត
ពេញទាំងផ្ទៃអាកាសស្ទើរតែគ្មានកន្ទែងសល់ចន្ទោះ ពួកព្រហ្មទាំងអស់
ក៏ផ្គងអញ្ជលីដាក់លើសិរសា នាំគ្នាប្រៀងសរសើរពោធិសម្ភារ ដោយ
សំឡេងដ៏ពីរោះក្បោះក្បាយ ទាំងព្រឹក្សាលតាវល្ទិផងទាំងឡាយ
ក៏បញ្ចេញបុប្ជាផលទាំងចង្ក្រាមទាំងធ្ទាយ ផ្សាយក្ទិនកកាយសាយសព្ទ
ទិសានុទិស ទាំងបទុមជាតិបញ្ចពណ៌ ក៏ជុះផុះទំលាយថ្មដែនប្រឹថពី
រិកស្ទុះស្ទាយផ្សាយក្ទិនទៅសព្ទទិសទី បូជាព្រះជិនស្រី កុនពេលដែល
ព្រះអង្គជិតបានត្រាស់ ។ ព្រះបរមពោធិសត្ទ ទ្រង់បានន្ទូវបុទ្ធិដ៏រិសេស
ត្រប់យ៉ាង ទ្រង់បានន្ទូវសក្ការបូជាដ៏រិសេស ទ្រង់បានន្ទូវសម្បត្តិ
ដ៏រិសេសត្រប់ប្រការ ដោយអានិសង្សនៃការកសាងព្រះពុទ្ធបដិមា ។

សេចក្តីពិតថា បុគ្គលអ្នកកសាងព្រះពុទ្ធបដិមាដែលកំពុងអន្ទោល
ទៅកុនវដ្ពសង្សារ រមែងបានសោយផលអានិសង្សនៃព្រះពុទ្ធបដិមាមិន
ចេះអស់ មិនចេះរលស់ ដរាបតែដល់ព្រះនិព្ទានជាទីបំផុត; ព្រោះហេតុ
នោះបានជាអង្គសម្ពេចព្រះសម្ពុទ្ធ ទ្រង់ត្រាស់សំដែងថា បុគ្គលឯណា
បានកសាងព្រះពុទ្ធរូប, បុគ្គលនោះមិនដែលទៅកើតកុនទុគ្គតិទេ, តែង

ឥតទៅកើតក្នុងសុគតិ ហើយជាអ្នកមានលាភដ៏ប្រសើរ មានសម្បុរស្រស់ មានរូបល្អ ជាទីស្រឡាញ់នៃជនានុជន មានពួកនារីដ៏ប្រសើរ បម្រើ សព្វទិវារាត្រី ជាអ្នកមានសីលាចារវត្ត មានគុណសម្បត្តិ បានជាអ្នក ប្រាជ្ញរាជបណ្ឌិត្យដ៏ក្លៀវក្លា មានយស មានគំនិតប្រាជ្ញាដ៏មុះមុត ទោះបី ប្រាថ្នាជាព្រះពុទ្ធ ឬ សាវ័ករបស់ព្រះពុទ្ធ ក៏នឹងបានសម្រិទ្ធីចំហុតជូច សេចក្តីប្រាថ្នា; នេះជាផលនៃការកសាងព្រះពុទ្ធរូប ។

ទេសនាវសានេ ត្រាកាលសម្តេចព្រះបរមសាស្តា ទ្រង់ត្រាស់ សំដែងព្រះធម៌ទេសនាចប់សព្វគ្រប់ហើយ (១) ទ្រង់ត្រាស់ប្រកាស អរិយសច្ចទាំង ៤ ប្រការ ហើយទ្រង់ប្រជុំជាតកថា ព្រះបាទមហារជ្ជរាជ ចេរវិលវឹងមក បានជាសារីបុត្ត, ព្រះបាទបញ្ចាលរាជ បានជាអានន្ទ, រាជទូតបានជាមោគ្គលាន, ព្រះឥន្ទ បានជាអនុរុទ្ធ, វីរិយបណ្ឌិត បាន ត្រាស់ប្រាជ្ញាសពិជ្ញតាញាណ គឺអង្គតថាគតជាលោកនាថហ្នឹងឯង; អ្នកទាំងឡាយចូរចាំទុកនូវជាតក យ៉ាងនេះចុះ ។

ចប់ វីរិយបណ្ឌិតជាតក ទី ១៧

(មានត)

---

១ ជាតកនេះ ឧសពីជាតកទាំងពួង ព្រោះចាប់និយាយរឿងឡើងតែម្តង មិនប្រាប់ថាអ្នក ណាសំដែងរឿងនោះ, ដល់មកសេចក្តីបញ្ចប់ទើបប្រាប់ថាព្រះបរមសាស្តាសំដែង, ប្រហែល លោកអ្នកតែងជាតកនេះ ភ្លេចថាទេដឹង ?

រឿងធម្មធូជបណ្ឌិត

ក្នុងគម្ពីរខុទ្ទកនិកាយ ទុកនិបាត

លោកគាំ-ឌុំ

លេខាធិការការិយាល័យសារមន្ទីរអាល់ប៊ែរសារូ

ប្រែនឹងរៀបរៀង

(តបប់)

ព្រះពោធិសត្វត្រឡប់ទៅផ្ទះវិញ ដល់ព្រឹកឡើងស្រស់ស្រូបអាហារ រួចហើយក៏ម្ចីម្ចាទៅឯព្រះរាជវាំង ក៏បានយើញនាយខ្មាន់ប្រកេសឈ្មោះ ធត្តបាណីនៅក្នុងទីនោះដែរ ពោធិសត្វសួរទៅបាប់ដែហើយសួរថា នែ ធត្តបាណីសំឡាញ់ ព្ធបាលោកប្រកបដោយអង្ត ៤ មែនឬ? ។

ធត្តបាណី – ចុះនរណាប្រាប់លោកថាខ្ញុំប្រកបដោយអង្ត ៤ ហ្នឹង? ។

ពោធិសត្វ – ព្រះឥន្ទ្ធជាស្តេចទេវតាប្រាប់ខ្ញុំណ៉ាះសំឡាញ់ ។

ធត្តបាណី – ចុះហេតុអ្វីបានជាព្រះឥន្ទ្ធប្រាប់លោក? ។

ព្រះពោធិសត្វអធិប្បាយប្រាប់សព្វគ្រប់តាមដំណើរ រួចហើយ នាយធត្តបាណីក៏ប្រាប់ទៅតាមត្រង់ថា អើសំឡាញ់ យើងប្រកបដោយ អង្ត ៤ មែន ។

រៀលានោះ ព្រះពោធិសត្វក៏បាប់ដែនាយធត្តបាណីនាំទៅក្រាបទូល ព្រះរាជាថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះមហារាជ នាយធត្តបាណី នេះប្រកបដោយអង្ត ៤ បើព្រះអង្គសព្វព្រះទ័យរកឧយ្យានបាល, សូម ព្រះអង្គទ្រង់យកនាយធត្តបាណីនេះធ្វើជាឧយ្យានបាលចុះ ។ ព្រះរាជា

ក៏ត្រាស់សួរទៅនាយឆត្តបាណីថា នែនាយ ឮថាអ្នកប្រកបដោយអង្គ ៤ មែនឬ? ។

ឆត្តបាណី - សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះបង្គំប្រកបដោយអង្គ ៤ មែន ។

ព្រះពុទ្ធ - ចុះអ្នកបានប្រកបដោយអង្គ ៤ ដូចម្តេចខ្លះទៅ? ។

នាយឆត្តបាណីក្រាបបង្គំទូលដោយព្រះគាថាថា:

អនុស្សុយ្យកោ អហំ ទេវ អមជ្ឈបាយកោ អហំ
ឯិស្នេហកោ អហំ ទេវ អក្កោធនរធិដ្ឋាតិ ។

បពិត្រព្រះសម្មតិទេពមហាពុទ្ធ ខ្ញុំព្រះបង្គំពុំឫស្យា គឺមិនច្រណែនច្រពន្ធ ១ ខ្ញុំព្រះបង្គំពុំខ្ជូលព្រះទានចឹកស្រវឹង ១ ខ្ញុំព្រះបង្គំពុំស្រឡាញ់ (របស់ដទៃ) ១ ខ្ញុំព្រះបង្គំពុំចេះក្រោធខឹង ១ ខ្ញុំព្រះបង្គំប្រកបដោយអង្គ ៤ នេះ ដែលបានតាំងចិត្តវៀរជាស្រឡះហើយ ។

ព្រះពុទ្ធ - អើឆត្តបាណី អម្បាញ់មិញអ្នកបាននិយាយថា ខ្ញុំព្រះបង្គំពុំច្រណែនច្រពន្ធទេ មែនឬឆត្តបាណី? ។

ឆត្តបាណី - សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះបង្គំពុំច្រណែនច្រពន្ធមែន ។

ព្រះពុទ្ធ - អើឆត្តបាណី! ចុះអ្នកឃើញហេតុដូចម្តេចបានជាអ្នកមិនច្រណែនច្រពន្ធ? ។

នាយឆត្តបាណី តាលដែលនឹងក្រាបទូលហេតុដែលខ្លួនមិនច្រណែន

ប្រពន្ធឲ្យព្រះពាជាទ្រង់ព្រះសណ្តាប់នោះ បានទាំយកនូវអតីតនិទានរបស់ខ្លួនដោយព្រះគាថាមួយបទថា:

ឥត្ថិយា ការណា រាជ ពន្ធាបេសិ បុរោហិតំ
សោ មំ អត្ថេ និវេសេសិ តស្មាហំ អនុសុយ្យកោតិ ។

បពិត្រព្រះមហារាជ ព្រោះហេតុតែស្ត្រីគឺប្រពន្ធ បានជាខ្ញុំព្រះបង្គំប្រើរាជបុរសឲ្យចាប់បុរោហិតចង (ប៉ងនឹងសំឡាប់) តែបុរោហិតនោះ បានញ៉ាំងខ្ញុំឲ្យតាំងនៅក្នុងប្រយោជន៍វិញ ព្រោះហេតុនោះបានជាខ្ញុំព្រះបង្គំពុំប្រច័ណ្ឌប្រពន្ធ ។

សេចក្តីពិស្តារនៃរឿងនេះថា "បពិត្រព្រះមហារាជ សូមទ្រង់ព្រះមេត្តាប្រោស កាលពីដើមខ្ញុំព្រះបង្គំកើតជាព្រះពាជាឈ្មោះព្រហ្មទត្ត ក្នុងក្រុងពារាណសីនេះ កាលនោះព្រះពោធិសត្វកើតជាបុរោហិតនៃព្រះពាជានោះ ។

ថ្ងៃមួយ ព្រះពាជានោះទ្រង់ព្រះពាជទានពរដល់ព្រះអគ្គមហេសីថា នែនាងទេវី នាងត្រូវការចង់បានអ្វី ចូរនាងនិយាយមកចុះ យើងនឹងឲ្យពរនាងតាមគាប់ចិត្ត ។ នាងទេវីឮហើយមានចិត្តត្រេកអរក៏ក្រាបបង្គំទូលសុំពរថា សូមទ្រង់ព្រះមេត្តាប្រោស ពរដទៃខ្ញុំម្ចាស់ពុំពិបាកនឹងរកឡើយ ខ្ញុំម្ចាស់សុំតែពរមួយយ៉ាង គឺតាំងពីថ្ងៃនេះតទៅសូមកុំឲ្យព្រះអង្គត្រូវការរមិលមើលពួកស្ត្រីដទៃ ដោយអំណាចកិលេសតាមឡើយ ។ ព្រះពាជានោះពុំអាចនឹងទទឹងពាក្យសំដីដែលនាងទេវីនោះទូលសុំបានទេ ទ្រង់ក៏ទទួលព្រមតាម ហើយតាំងពីថ្ងៃនោះទៅព្រះអង្គលែងត្រូវការរាប់រក

ពួកស្ត្រីស្មំតាំង ១៦.០០០ សូម្បីស្រីណាម្នាក់ដោយអំណាចកិលេសកាម
សោះឡើយ ។

សម៍យមួយនោះ មានចោរខ្មាំងបះបោរនៅស្រុកត្រង់ព្រំប្រទល់
ដែនរបស់ព្រះរាជានោះ ពួកយោធាទាហានដែលនៅចាំរក្សាព្រំប្រទល់
ដែនបានផ្ទើសន្ត្រាមតយុទ្ធនឹងពួកចោរតាំងនោះពីរបីត្រាមិនឈ្នះ ទើប
បញ្ជូនសំបុត្រទៅក្រាបទូលព្រះរាជា ។ ដ្រាបហើយទ្រង់មានព្រះរាជ
បំណងនឹងយាងទៅកម្រាបសត្រូវក្នុងទីនោះដោយព្រះអង្គឯង ក៏ទ្រង់រៀប
ចាត់ចែងប្រមូលពួកពល រួចហើយទ្រង់ត្រាស់ហៅនាងទេវីនោះមកមាន
ព្រះបន្ទូលថា នែនាងទេវី យើងនឹងទៅបច្ចន្តត្រាមដើម្បីផ្ទើសន្ត្រាមតយុទ្ធ
នឹងសត្រូវផ្សេង ។ ក្នុងទីនោះ ជាតិជាស្ត្រីនឹងទៅក្នុងទីដូច្នោះផងនាំឲ្យលំ-
បាកគេរក្សាណាស់ បើដូច្នេះ ចូរនាងនៅចុះកុំទៅផងឡើយ ។ នាងទេវី
នោះអង្វរសុំទៅជាមួយផងពុំបានហើយ នាងក៏ក្រាបបង្គំទូលសុំថា បើ
ព្រះអង្គពុំទ្រង់អនុញ្ញាតឲ្យខ្ញុំម្ចាស់ទៅជាមួយផងទេ ខ្ញុំម្ចាស់ក៏ព្រមនៅដែរ
ប៉ុន្តែសូមព្រះអង្គប្រើមនុស្សម្នាក់ ។ ឲ្យត្រឡប់មកសួរឲ្យដឹងសុខទុក្ខរបស់ខ្ញុំ
ម្ចាស់ត្រប់តែព្រះរាជដំណើរ ដែលព្រះអង្គយាងទៅបានចម្ងាយ ១
យោជន៍ ។ ។ ព្រះរាជាក៏ព្រមទទួលតាមពាក្យនាងសុំ ទ្រង់ទុកតែព្រះ
ពោធិសត្វជាបុរោហិតឲ្យនៅចាំព្រះនគរ ទ្រង់ក៏នាំពួកពលជាច្រើនយាង
ចេញទៅហើយបញ្ជូនបុរសម្នាក់ ។ ឲ្យត្រឡប់មកសួរឲ្យដឹងសុខទុក្ខរបស់
នាងទេវីនឹងទូលនាងទេវីឲ្យដឹងអំពីសុខទុក្ខពុំមានរោគរបស់ព្រះអង្គត្រប់ត្រ
ព្រះរាជដំណើរ ដែលទ្រង់យាងទៅបានចម្ងាយ ១ យោជន៍ ។ ។ ចំណែក

ឯនាងទេវី កាលបើបានឃើញបុរសដែល ព្រះរាជាបញ្ជូនទៅហើយនោះ
តែងតែហៅបុរសនោះឲ្យមកធ្វើអសទ្ធម្មនឹងខ្លួនតែគ្រប់ ៗគ្នា ។ ព្រះរាជា
ទ្រង់យាងទៅបម្ចាយផ្ទូរ ៣៦ ឃោជន៍ បានបញ្ជូនបុរសឲ្យទៅស្លូរនាងទេវី
ចំនួន ៣៦ នាក់ដែរ ឯនាងទេវីក៏បានប្រព្រឹត្តធ្វើអសទ្ធម្មជាមួយនឹងបុរស
ទាំងអស់នោះដូចគ្នា ។

ព្រះរាជាលុះបានកំរាបសត្រូវនៅបច្ចន្តគ្រាមរួចហើយ រៀលាដែល
ទ្រង់យាងត្រឡប់មកព្រះនគរវិញបានបញ្ជូនមនុស្ស ៣៦ នាក់ឲ្យមកស្លូរ
នាងទេវីតាមទំនងដូចមុន ឯនាងទេវីក៏បានប្រព្រឹត្តក្បត់ព្រះរាជាជាមួយ
នឹងបុរសទាំងនោះដូចមុនទៀត រួមបុរសទាំងអស់ជា ៦៤ នាក់ ។ ព្រះ
រាជាយាងមក ទ្រង់បញ្ជាប់កងទ័ពពិជ័យយោធានៅខាងក្រៅព្រះរាជរាំង
ទ្រង់ផ្ញើសំបុត្រទៅប្រាប់ព្រះពោធិសត្ត ឲ្យតុបតែងស្អិតស្អាងសំអាតព្រះ
នគរឲ្យស្រេចជាមុន ។

ឯព្រះពោធិសត្តក៏ប្រាសសំអាតព្រះនគរ លុះប្រាសជំរះព្រះរាជ-
និវេសនដ្ឋានរួចហើយទើបទៅប្រាសជល់ទីព្រះដំណាក់នៃនាងទេវីជាខាង
ក្រោយ ។

ឯនាងទេវីបានឃើញព្រះពោធិសត្តបរិបូណិដោយរូបសម្បត្តិសឹងតែ
ល្អធើត នាងអត់សង្កត់ចិត្តំពុំបាន ក៏មានព្រះសវនីយ៍ហៅព្រះពោធិសត្ត
ថា នែព្រាហ្មណ៍ ចូរអ្នកអញ្ជើញទ្បើងមកសម្រាន្តលើទីសយនាជាមួយ
នឹងយើង ។ ព្រះពោធិសត្តយាត់ថា កុំព្រះនាងម្ចាស់, ព្រោះព្រះរាជាជា
ទីគោរពរបស់ខ្ញុំ ខ្ញុំខ្ជាចអំពើអកុសល ខ្ញុំពុំហ៊ានធ្វើអំពើយ៉ាងនេះទ្បើយ ។

នាងទេវី – ចុះព្រះរាជាមិនជាទីគោរពរបស់មហាតលិកទាំង ៦៤ នាក់ទេឬ អ្នកទាំងនោះមិនខ្ចាចអំពើអកុសលទេឬ ព្រះរាជាជាទីគោរពអីតែអ្នកម្នាក់ឯង អ្នកខ្ចាចអំពើអកុសលអីតែម្នាក់ឯង ។

ពោធិសត្ត – អើនាង បើមហាតលិកទាំងនោះបានធ្វើយ៉ាងនេះក៏ស្រេចនៅលើរូបគេចុះ ចំណែកខ្ញុំ ៗ ពុំហ៊ានធ្វើយ៉ាងនេះឡើយ ។

នាងទេវីប្រលោមលោមព្រះពោធិសត្តអស់ចិត្តហើយ ក៏បែរជាតម្រាមទៅវិញថា ចុះអ្នកឯងនិយាយប្រើនអីម្ទ៉ះ បើអ្នកពុំព្រមតាមពាក្យយើងទេ យើងនឹងក្រាបទូលព្រះរាជាឲ្យកាត់ក្បាលអ្នកហើយ ។

ពោធិសត្ត – កុំថាឡើយកាត់ក្បាលខ្ញុំត្រឹមតែមួយជាតិនេះ ទុកជាកាត់ក្បាលខ្ញុំជល់មួយពាន់ជាតិក៏ដោយ ក៏ខ្ញុំពុំធ្វើអំពើយ៉ាងនេះឡើយ ។ នាងទេវីដឹងថាមិនសម្រេចដូចសេចក្តីប្រាថ្នាហើយ ក៏ចូលទៅក្នុងបន្ទប់របស់ខ្លួន ហើយខ្ចារក្តិចខ្ញាំសរីរៈឲ្យមានស្នាមរលាត់ដាច់ដោយកែចក រួចយកប្រេងលាបខ្លួនស្ទៀកសំពត់ដែលសៅហ្មងមិនស្អាតហើយប្រាប់ពួកទាសីថា បើព្រះរាជាសួររកយើងឲ្យក្រាបទូលថា យើងឈឺ ។

ព្រះពោធិសត្តលុះបានតុបតែងសំអាតរួចហើយ ក៏ចញទៅទទួលព្រះរាជា ៗ យាងចូលទៅធ្វើប្រទក្សិណព្រះនគរហើយ ក៏យាងឡើងទៅលើប្រាសាទត្រាស់សួររកនាងទេវី លុះទ្រង់បានឮពួកទាសីក្រាបបង្គំទូលថា នាងទេវីទ្រង់អផ្សុកផូច្នោះ ព្រះរាជាក៏យាងចូលទៅក្នុងបន្ទប់បបោសអង្អែលខ្នងនាងហើយត្រាស់សួរថា នែនាងទេវី ចុះនាងពុំសប្បាយឬអ្វី? ។ នាងទេវីស្ទៀមឈឹងពុំក្រាបទូលតបសោះឡើយ លុះព្រះរាជា

ត្រាស់សួរជាគំរប់ ៣ ដងហើយ ទើបនាងធ្វើឆ្ងែនព្រះទៃត្រាមើលព្រះពារ
ហើយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះករុណាជាម្ចាស់ដ៏វិត
ព្រះអង្គទ្រង់គង់ព្រះជន្មាយុនៅឡើយ អម្បាលស្តេចប្រហែលដូចជាខ្ញុំម្ចាស់
ជាស្ត្រីមានព្រះអង្គជាព្រះស្វាមី ពុំសមបីបុរោហិតដែលព្រះអង្គទុកឲ្យ
នៅរក្សាព្រះនគរ មកប្រោសសំអាតទីព្រះដំណាក់នេះហើយ ហ៊ានមក
ប្រហារប្រកាយប្រគប់ខ្ញុំម្ចាស់ដែលពុំព្រមដោយតាមគាត់គាល់តែបាន
បំពេញសេចក្តីប្រាថ្នារបស់ខ្លួនហើយទើបចេញទៅឡើយ ។

ព្រះពារាឮហើយទ្រង់ព្រះក្រោធប្រឡាតខ្លាំងក្រៃពេក ក្តួហាក់
ដូចដុំអំបិលដែលគេដាក់ទៅក្នុងព្រះអគ្គី ទ្រង់យាងចេញអំពីទីសិរីសយនា
មានព្រះឫទ្ធិត្រាស់ហៅពួកអ្នករក្សាទ្វារទាំងពួកមហាតលិកជាដើមមកថា
ចូរព្រះស្តេចកាល់គ្នាទៅចាប់បុរោហិតចង ស្វាបសេកនាំចេញអំពីនគរទៅឯ
អាយតនដ្ឋានកាត់ក្បាលវាសម្លាប់ចោលទៅ ។ ឯពួកបុរសទាំងនោះក៏នាំ
គ្នាទៅចាប់ព្រះពោធិសត្វចងស្វាបសេក ហើយបណ្តើរអាក្រាសធ្លើរដ្ឋ-
កេរ៉ាចរកតាមជាលំដាប់ព្រះនគរ ។ ព្រះពោធិសត្វពិចារណាយល់ឃើញ
ថា "មុខជានាងទេវីកំណាចញុះញង់ព្រះពារាជាក្រោធដ បើដូច្នោះអញ
នឹងដោះខ្លួនឲ្យរួចដោយកម្លាំងប្រាជ្ញាខ្លួនអញឲ្យបានក្នុងថ្ងៃនេះ" ទើបព្រះ
ពោធិសត្វនិយាយទៅកាន់បុរសទាំងនោះថា អ្នកទាំងឡាយកុំអាល
សម្លាប់ខ្ញុំ, សូមនាំខ្ញុំទៅថ្វាយដល់ព្រះពារាសិនសឹមសំឡាប់ចុះ ព្រោះ
ខ្ញុំជាភត្តិកបុរស មានការងារជាច្រើនដែលខ្ញុំបានធ្វើហើយ ខ្ញុំក៏បាន
ដឹងទីទុកជាក់របស់ជាច្រើន, ខ្ញុំជាអ្នកចាត់ចែងព្រះពារាឲ្យ ប្រសិន

បើអ្នកតំណ្ឌាយ ពុំបាននាំខ្ញុំទៅថ្វាយព្រះរាជាទេ មុខជានឹងវិនាស ទេព្យជាច្រើនពុំខាន កាលបើខ្ញុំបានក្រាបទូលព្រះរាជមតិកថ្វាយព្រះ រាជារួចហើយ សឹមអ្នកតំណ្ឌាយធ្វើតាមអំពើជាខាងក្រោយចុះ ។ ឯរាជបុរសតំណនោះក៏នាំព្រះពោធិសត្វទៅថ្វាយព្រះរាជា ។ បានឃើញ ហើយទ្រង់ត្រាស់សួរថា អើព្រាហ្មណ៍ចុះអ្នកឯងហេតុអ្វីក៏ពុំមានខ្មាសដល់ យើងសោះ ព្រោះហេតុអ្វី បានជាអ្នកហ៊ានធ្វើអំពើអាក្រក់យ៉ាងនេះ? ។

ពោធិសត្ត – សូមទ្រង់ព្រះមេត្តាប្រោស ព្រះមហារាជជាអម្ចាស់ ជីវិតលើត្សូង ទូលព្រះបង្គំកើតក្នុងសោត្ថិយត្រកូល សត្វមានជីវិតសូម្បី ត្រឹមតែស្រមោចឆ្មៅ ស្រមោចក្រហម ក៏ទូលព្រះបង្គំពុំដែលសម្ចាប់, ទេព្យដែលម្ចាស់គេពុំបានឲ្យសូម្បីត្រឹមតែស្មៅមួយទង ក៏ទូលព្រះបង្គំពុំ ដែលយក, ស្ត្រីរបស់អ្នកដទៃ ក៏ទូលព្រះបង្គំពុំដែលបើកក្នែកមើលដោយ អំណាចលោភតណ្ហា, ពាក្យកុហកសូម្បីត្រឹមតែដោយអំណាចប្រាថ្នានឹង សើចលេង ក៏ទូលព្រះបង្គំពុំដែលនិយាយ, ទឹកស្រវឹងសូម្បីត្រឹមតែក្រេប ផឹកដោយចុងស្សូវ ក៏ទូលព្រះបង្គំពុំដែលទទួលព្រះទានឡើយ, ទូល ព្រះបង្គំពុំមានទោសកំហុសអ្វីនឹងព្រះអង្គទេ តឺនាងទេវីទេតើជាស្រីពាល ចិត្តសាហាវចាប់ដៃទូលព្រះបង្គំដោយលោភតណ្ហា ទូលព្រះបង្គំប្រកែក យ៉ាងណា ក៏ពុំព្រមតាមត្រំឡប់ជាតម្រាមទូលព្រះបង្គំវិញ រួចហើយខ្ទារ ខ្ញុំធ្វើអាក្រក់ដោយខ្ជូនឯង សំដែងឲ្យឃើញច្បាស់ប្រាប់ទូលព្រះបង្គំ ហើយចូលទៅសម្ងំនៅក្នុងបន្ទប់ ឯទូលព្រះបង្គំជាអ្នកឥតទោសឡើយ មានតែមហាតលិកតំណ ៦៤ នាក់ ដែលយកសំបុត្រមកថ្វាយនាងទេវីនោះ

ទើបមានទោសកំហុសមែន សូមព្រះករុណាជាអម្ចាស់ជីវិតលើត្សូងទ្រង់ត្រាស់ហៅអ្នកតំងនោះមកសួរឲ្យដឹងថា សំដីអ្នកតំងនោះបានធ្វើតាមនាងទេវីដែរឬពុំបានធ្វើទេ ។ ព្រះរាជាត្រាស់ប្រើឲ្យរាជបុរសចាប់ មហាតលិកតំង ៦៤ នាក់នោះចងហើយត្រាស់សួរនាងទេវីថា នាងឯងបានធ្វើអំពើលាមកជាមួយនឹងមហាតលិកតំងអស់នេះមែន ឬពុំបានធ្វើទេ? ។

នាងទេវី– សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំម្ចាស់បានធ្វើមែន ។

ព្រះរាជាក៏ឲ្យចាប់នាងទេវីចងស្ទាបសេក ហើយត្រាស់បង្គាប់ឲ្យរាជ-បុរសកាត់ក្បាលមហាតលិកតំង ៦៤ នាក់ជាមុន ។

រៀលានោះ ព្រះពោធិសត្វជាបុរោហិត បានក្រាបទូលសូមទោសនឹងព្រះរាជាថា បពិត្រព្រះមហារាជ មហាតលិកតំងនោះពុំមានទោសទេ ព្រោះនាងទេវីបង្គាប់ឲ្យធ្វើអំពើអសទ្ធម្មតាមអធ្យាស្រ័យរបស់នាង ហេតុនោះ សូមព្រះអង្គទ្រង់ព្រះរាជទានទោសដល់មហាតលិកតំងនុ+ះ ចំណែកនាងទេវីក៏ពុំមានទោសដែរ ព្រោះធម្មតាស្ត្រីរមែងមិនផ្ទៃតស្ពប់ស្ពល់ដោយមេថុនធម្មជូចត្នាតំងអស់ ហេតុនោះ សូមព្រះអង្គទ្រង់ព្រះរាជទានទោសដល់នាងផង ។

ព្រះពោធិសត្វបានញ៉ាងព្រះរាជាឲ្យទន់ព្រះរាជហ្ជូទ័យអកយទោសដោះលែងមហាតលិកតំង ៦៤ នាក់នោះ ព្រមតំងនាងទេវីឲ្យរួចចាកទោសដោយប្រការផ្សេង ៗ ហើយឲ្យតាំងនៅក្នុងដំណែងតាមហានៈរបស់ខ្លួនតំងអស់វិញ (១) ។

---

១ រឿងដែលពោលមកនេះ មានពិស្តារក្នុងពន្ធនមោក្ខជាតកហំសិវត្ថ ក្នុងឯកនិបាត, ដែលស្រង់មកនិយាយក្នុងធម្មទ្ធជជាតកនេះជាសេចក្តីសង្ខេប ។

នាយឆត្តបាណីក្រាបទូលព្រះរាជាតទៅទៀតថា បពិត្រព្រះមហារាជ
កាលនោះឯងទូលព្រះបង្គំជាព្រះរាជាទ្រង់ត្រិះរិះថា "យើងបានលះបង់
លើងវរវឹកនឹងស្ត្រី ១៦.០០០ ចេញហើយ នៅសង្ត្រោះចំពោះតែនាង
ទេវីនេះម្នាក់ឯងប៉ុណ្ណោះដោយកិលេសកាម ក៏នៅតែមិនអាចនឹងឲ្យនាង
ទេវីឆ្អែតស្កប់ស្កល់ដោយកាមបាន បើក្រោធខឹងចំពោះពួកស្រីដែលគេ
តែងតែបំពេញសេចក្តីប្រាថ្នាបានដោយក្រយ៉ាងនេះ ក៏ដូចជាក្រោធខឹង
នឹងសំពត់ដែលស្ទៀកដណ្តប់ប្រឡាក់ស្រាហ្ន៍ ហើយបន្ទោសសំពត់ថា
ហេតុអ្វីក៏ប្រឡាក់? ពុំនោះសោត ដូចជាក្រោធខឹងនឹងអាហារដែល
បរិភោគរលួយរលាយទៅជាលាមកហើយបន្ទោសអាហារថា ហេតុអ្វីក៏
រលួយទៅជាលាមក" លុះទ្រង់យល់ដូច្នេះហើយ ទើបទ្រង់អធិដ្ឋានតាំង
ទុកក្នុងព្រះទ័យថា តាំងពីថ្ងៃនេះទៅ បើយើងពុំទាន់បានសម្រេចអរហត្ត
ត្រឹមណាទេ ការបូស្យាប្រចំណ្ឌប្រពន្ធព្រោះតែកិលេស សូមកុំឲ្យកើត
ឡើងដល់យើងបានត្រឹមណោះដែរ ។ តាំងពីកាលនោះមកព្រះរាជានោះ
ក៏លែងប្រចំណ្ឌទៅ ។ បពិត្រព្រះមហារាជ អាស្រ័យហេតុនេះឯងបាន
ជាទូលព្រះបង្គំពុំប្រចំណ្ឌប្រពន្ធ ។

ព្រះរាជាទ្រង់ត្រាស់សួរតទៅទៀតថា អើឆត្តបាណីសំឡាញ់
ចុះអ្នកឃើញអារម្មណ៍ដូចម្តេច បានជាអ្នកពុំផឹកទឹកស្រវឹង? ។

នាយឆត្តបាណី កាលនឹងក្រាបទូលហេតុដែលខ្ជូនមិនផឹកទឹកស្រ-
វឹងឲ្យព្រះរាជាទ្រង់ព្រះសណ្តាប់នោះ បាននាំយកនូវអតីតនិទានរបស់ខ្ជូន
ដោយព្រះគាថាមួយបទថា:

បមណ្ឌោបំ មហារាជ ឃុត្តមំសានិ ខាទសិ
តស្ស សោកេនាបំ ផុដ្ឋោ មជ្ឈបាគំ វីតិវត្តយិត្ថ ។

បពិត្រព្រះមហាក្សត្រ ខ្ញុំព្រះបង្គំជាមនុស្សស្រែវាំងបានស៊ីសាច់កូនរបស់ខ្លួន ខ្ញុំព្រះបង្គំត្រូវសេចក្តីសៅសោកព្រោះកូននោះមកប៉ះពាល់ហើយ ក៏បានវៀរស្រែឲ្យទៅការងើកទឹកស្រែវាំងចោលចេញទៅ ។

សេចក្តីពិស្តារនៃរឿងនេះថា បពិត្រព្រះមហាក្សត្រ កាលពីដើមខ្ញុំព្រះបង្គំកើតជាព្រះរាជាក្នុងក្រុងពារាណសីហ្នឹងដែរ ជាអ្នកងើកទឹកស្រែវាំងពុំអាចវៀរបង់បាន ហើយជាអ្នកស៊ីសាច់ ពុំអាចបរិភោគអាហារដែលគ្មានសាច់បានឡើយ ។ ក្នុងថ្ងៃឧបោសថ អ្នកនគរតែងតែមិនសម្លាប់សត្វជាធម្មតា ឯអ្នកធ្វើព្រះស្នោយបានសំចៃសាច់ទុកខ្លះពីថ្ងៃទី ១៣ នៃបក្ខគឺថ្ងៃ ១៣ កើតឬ ១៣ រោច ឯសាច់នោះឯងដោយហេតុទុកជាក់មិនល្អឆ្អែកំសុីអស់ទៅ ។ អ្នកធ្វើព្រះស្នោយដល់ថ្ងៃឧបោសថហើយរកសាច់ពុំបាន គ្រាន់តែចំអិនព្រះស្នោយមានរសឆ្ងាញ់ផ្សេង ។ រួចហើយពុំហ៊ានយកឡើងទៅលើប្រាសាទថ្វាយដល់ព្រះរាជាឡើយ ក៏ចូលទៅក្រាបទូលនាងទេវីថា បពិត្រព្រះទេពីម្ចាស់ ថ្ងៃនេះខ្ញុំព្រះបង្គំរកសាច់ពុំបាន ខ្ញុំព្រះបង្គំពុំហ៊ានយកព្រះស្នោយដែលពុំមានសាច់ទៅថ្វាយព្រះរាជាទេ បើដូច្នេះឲ្យខ្ញុំព្រះបង្គំធ្វើដូចម្តេច? ។ នាងទេវីក៏ប្រាប់ឲ្យថា នែអ្នកនាយ មិនអីទេ បុត្តរបស់ខ្ញុំជាទីស្រឡាញ់សព្វព្រះរាជហឫទ័យនៃព្រះរាជាណាស់ បើព្រះអង្គបានឃើញហើយមុខជាជាប់ព្រះទ័យតែនឹងក្រសាល

បមត្ថោហំ មហារាជ ឫត្ថមំសានិ ខាទសឹ
តស្ស សោកេនាហំ ផុដ្ឋោ មជ្ជបានំ រិរិជ្ជយិន្តិ ។

បពិត្រព្រះមហារាជ ទូលព្រះបង្គំជាមនុស្សស្រវឹងបានស៊ីសាច់កូនរបស់ខ្លួន ទូលព្រះបង្គំត្រូវសេចក្តីសោសោកព្រោះកូននោះមកប៉ះពាល់ហើយ ក៏បានវៀរស្រឡះនូវការផឹកទឹកស្រវឹងចោលចេញទៅ ។

សេចក្តីពិស្តារនៃរឿងនេះថា បពិត្រព្រះមហារាជ កាលពីដើមទូលព្រះបង្គំកើតជាព្រះរាជាក្នុងក្រុងពារាណសីហ្នឹងដែរ ជាអ្នកផឹកទឹកស្រវឹងពុំអាចវៀរបង់បាន ហើយជាអ្នកស៊ីសាច់ ពុំអាចបរិភោគអាហារដែលគ្មានសាច់បានឡើយ ។ ក្នុងថ្ងៃទុបោសថ អ្នកនគរតែងតែមិនសម្ងាប់សត្វជាធម្មតា ឯអ្នកធ្វើព្រះស្វាយបានសំបៃសាច់ទុកខ្ទះពីថ្ងៃទី ១៣ នៃបក្ខគឺថ្ងៃ ១៣ កើតឬ ១៣ រោច ឯសាច់នោះឯងដោយហេតុទុកជាក់មិនល្អធ្លៃក៏ស៊ីអស់ទៅ ។ អ្នកធ្វើព្រះស្វាយដល់ថ្ងៃទុបោសថហើយរកសាច់ពុំបាន គ្រាន់តែចំអិនព្រះស្វាយមានរសធ្យាញ់ផ្សេង ។ រួចហើយពុំហ៊ានយកឡើងទៅលើប្រាសាទថ្វាយដល់ព្រះរាជាឡើយ ក៏ចូលទៅក្រាបទូលនាងទេវីថា បពិត្រព្រះទេពីម្ចាស់ ថ្ងៃនេះទូលព្រះបង្គំរកសាច់ពុំបាន ទូលព្រះបង្គំពុំហ៊ានយកព្រះស្វាយដែលពុំមានសាច់ទៅថ្វាយព្រះរាជាទេ បើដូច្នេះឲ្យទូលព្រះបង្គំធ្វើដូចម្តេច? ។ នាងទេវីក៏ប្រាប់ទបាយថា នែអ្នកនាយ មិនអីទេ បុត្តរបស់ខ្ញុំជាទីស្រឡាញ់សព្វព្រះរាជហ្ឫទ័យនៃព្រះរាជាណាស់ បើព្រះអង្គបានឃើញហើយមុខជាជាប់ព្រះទ័យតែនឹងក្រសាល

ប្រឡែងថើបជញ្ជប់ព្រះរាជបុត្តពុំដឹងព្រះអង្គថា ព្រះស្វាយមានសាច់ឬពុំ
មានសាច់ឡើយ ណ្ហើយចាំខ្ញុំស្អិតស្អាងព្រះរាជបុត្តឲ្យទៅអង្គុយលើព្រះ
ឧរុ (ភ្លៅ) ព្រះរាជាជាមុនសិន សឹមអ្នកយកព្រះស្វាយទៅថ្វាយក្នុង
រៀលាដែលព្រះអង្គកំពុងក្រសាលលេងជាមួយនឹងព្រះរាជបុត្តចុះ ។ លុះ
ព្រះនាងទេវីនិយាយយ៉ាងនេះ រួចហើយក៏ប្រជាប់ស្អិតស្អាងបុត្តរបស់ខ្ជូន
ដោយគ្រឿងស្អាងជាបិលន្ធនកុមារ រួចនាំយកទៅថ្វាយព្រះរាជា ។ ទ្រង់
ឲ្យអង្គុយនៅលើភ្លៅ ។ ឯអ្នកធ្វើព្រះស្វាយក៏បានឧកាសនាំយកព្រះ
ស្វាយ ទៅថ្វាយក្នុងពេលដែលព្រះរាជាកំពុងក្រសាលជាមួយនឹងព្រះ
រាជបុត្តនោះ ។ ព្រះរាជាកំពុងតែស្រវឹងសុរាខ្ទាំង លុះទ្រង់ទតទៅពុំ
ឃើញមានសាច់ក្នុងចានព្រះស្វាយ ក៏ទ្រង់ត្រាស់សួរថា វ៉ីនាយព្រះ
ស្វាយ ចុះឯណាសាច់? ។ នាយព្រះស្វាយក្រាបបង្គំទូលថា
សូមទ្រង់ព្រះមេត្តាប្រោសថ្ងៃនេះជាថ្ងៃឧបោសថ ទូលព្រះបង្គំរកសាច់ពុំ
បាន ព្រោះគេមិនសម្ងាប់សត្ត ។ ព្រះរាជាត្រាស់ថា "អើវ៉ី! អម្បាល
ប្រហែលអញ្ញហើយនៅតែគេរកសាច់ឲ្យបានដោយកម្រទ្រៃត" ត្រាស់
តែប៉ុណ្ណោះហើយ ក៏ចាប់មួលកព្រះរាជបុត្តសំឡាញ់ដែលអង្គុយនៅលើ
ព្រះឧរុព្រះអង្គ ទាល់តែក្ស័យជីវិត ហើយបោះទៅឲ្យអ្នកធ្វើព្រះស្វាយ
ត្រាស់ថា ចូរឯងយកទៅចំអិនមកឲ្យអញ្ញជាធាប់ ។ ។ អ្នកធ្វើព្រះ
ស្វាយបានយកទៅចំអិនរួចយកមកថ្វាយព្រះរាជា ។ ក៏ទ្រង់សោយព្រះ
ស្វាយ ជាមួយនឹងសាច់បិយបុត្តរបស់ព្រះអង្គក្នុងកាលនោះទាល់តែ
អស់ទៅ ។ ដោយហេតុតែខ្ទាចអំណាចបារមីព្រះរាជាជ្រុលហួស

ប្រមាណ ពុំមានវណ្ណម្នាក់ហ៊ានកន្ទក់កន្ទេញឬគ្រាបទូលរឿងនោះ
សោះឡើយ ។ ឯព្រះរាជាលុះសោយស្រេចហើយក៏ចូលទៅកាន់ទី
ព្រះបន្ទំផ្ទំស្ពប់ស្ពល់ ជល់រៀលាព្រឹកព្រាងបច្ចូសសម័យទ្រង់តើនឡើង
ស្វាងសេចក្តីស្រវឹងដឹងព្រះអង្គហើយ ទ្រង់ត្រាស់នឹងនាងទេវីថា ចូរ
នាងយកព្រះរាជបុត្តមកឲ្យយើង ។ ក្នុងកាលនោះសោតនាងទេវីក៏
ស្រក់ទឹកព្រះនេត្រារអាក់រអួលកន្ទក់កន្ទេញ ចូលទៅគ្រាបទ្រៀបព្រះបាទា
នៃព្រះរាជាៗយើញជូច្នោះហើយ ទ្រង់ត្រាស់ស្ងរថា ចុះនាងកន្ទក់
កន្ទេញអ្វីនាង? ។ នាងទេវីគ្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស
ពីថ្ងៃម្សិលមិញព្រះអង្គសម្ងាប់ព្រះរាជបុត្ត ហើយចំអិនសោយជាមួយនឹង
ព្រះស្វាយទៅហើយ ។ ព្រះរាជាឣហើយក៏ទ្រង់ព្រះកន្សែងសោកស្តាយ
ព្រះរាជបុត្តស្ងុតព្រះទ័យកើតសេចក្តីសង្វេគ ទើបពិចារណាឃើញថា
"វិយោគទុក្ខនេះ កើតឡើងជល់យើងព្រោះតែផឹកសុរា" លុះទ្រង់យើញ
ទោសផឹកសុរាហើយ ក៏ទនចាប់យកកំទេចដីជិតព្រះកក្ត្រាតាំងព្រះចិន្តា
ប្តេជ្ញាថាតាំងពីថ្ងៃនេះទៅ បើយើងនៅមិនទាន់បានសម្រេចព្រះអរហត្ត
ត្រឹមណាទេ យើងក៏នឹងមិនផឹកសុរាដែលជាគ្រឿងផ្ទើឲ្យវិនាសយ៉ាងនេះ
ត្រឹមនោះដែរ ។ ចាប់ដើមតាំងពីកាលនោះមក ព្រះរាជានោះក៏លែង
សោយទឹកស្រវឹងទៅ ។

បពិត្រព្រះមហារាជ អាស្រ័យហេតុនេះឯងបានជាទូលព្រះបង្គំពុំ
ទទួលព្រះទានទឹកស្រវឹង ។

ព្រះពាជាទ្រង់ត្រាស់សួរតទៅទៀតថា អើឆត្តបាណី សំឡាញ់ បុរអ្នកឃើញអារម្មណ៍ដូចម្តេចបានជាអ្នកពុំមានសេចក្តីស្រឡាញ់ ? ។

នាយឆត្តបាណីកាលដែលនឹងក្រាបទូលហេតុដែលខ្លួនពុំមានសេចក្តីស្រឡាញ់ឲ្យព្រះពាជាទ្រង់ព្រះសណ្តាប់នោះ បាននាំយកនូវអតីតនិទានរបស់ខ្លួនដោយព្រះគាថាមួយបទថា

កិតវាសោ នាមាហំ រាជា បុត្តោ បច្ចេកពោធិ មេ
បត្តំ ភិន្ទិត្វា បវិដ្ឋោ និស្នេហោ តស្ស ការណាតិ ។

(សូមទ្រង់ព្រះមេត្តាច្រាស) ទូលព្រះបង្គំកើតជាព្រះពាជាឈ្មោះកិតវាសៈ ព្រះពាជបុត្តរបស់ទូលព្រះបង្គំបានបោកបំបែកបាត្ររបស់ព្រះបច្ចេកពោធិ ហើយក៏ច្បាតស្ងាប់ទៅ ព្រោះហេតុតែបុត្តវិយោគទុក្ខនោះ បានជាទូលព្រះបង្គំពុំមានសេចក្តីស្រឡាញ់ ។

សេចក្តីពិស្តារនៃរឿងនេះថា បពិត្រព្រះមហាពាជ កាលពីដើមទូលព្រះបង្គំកើតជាព្រះពាជាឈ្មោះកិតវាសៈ សោយពាជ្យនៅក្នុងក្រុងពាពណាសី ។ ព្រះពាជានោះមានព្រះពាជបុត្តមួយអង្គ កាលដែលព្រះពាជបុត្តនោះទ្រង់សម្ពព (ប្រសូត) មក ពួកព្រាហ្មណ៍អ្នកទាយលក្ខណៈបានឃើញលក្ខណៈព្រះពាជបុត្តនោះហើយក៏ក្រាបទូលព្រះពាជាថា បពិត្រព្រះមហាពាជ ព្រះពាជកុមារនេះបើពុំមានទឹកសម្រាប់សោយទេនឹងក្សយព្រះជន្មពុំខាន ។ ព្រះពាជបុត្តនោះព្រះនាម ឧដ្ឋកុមារ លុះចំរើនវ័យបានដំណឹងក្តីឡើងកាលណា ព្រះពាជាបានតាំងឲ្យធ្វើជាឧបពាជ ។ ព្រះពាជាទ្រង់សព្វព្រះហឫទ័យនឹងព្រះពាជកុមារនោះណាស់ តែងយាងនាំបណ្តើរ

តាមុខពីក្រោយក្រសាលលេងជាធម្មតា ។ ដោយខ្លាចក្រែងព្រះពជកុមារ
នោះក្ស័យព្រះជន្មព្រោះពុំមានទឹកសម្រាប់សោយ ព្រះពាជាទ្រង់ឲ្យដឹក
ស្រះបោក្ខរណីខាងកើតព្រះនគរទៅប្របក្សាទាំង ៤ ទិស ទើងឲ្យដឹកកើងទឹ
ផ្សេង ។ ជារបៀបខ្លៃត មិនតែប៉ុណ្ណោះទ្រង់គ្រាស់ឲ្យធ្វើមណ្ឌបជារបៀប
ត្រង់ទីមានផ្លូវត្រែឆ្លងកែងជាដើម ហើយឲ្យដំកល់ពាងទឹកទុកសម្រាប់
ទៅគ្រប់មណ្ឌបទាំងអស់នោះផង ។

មានថ្ងៃមួយ ព្រះពជកុមារនោះទ្រង់ស្អិតស្អាងគ្រឿងប្រដាប់ហើយ
នៅវេលាព្រឹកទ្រង់យាងទៅក្រសាលទ្យាន ដល់ពាក់កណ្តាលផ្លូវបាន
ជួបនឹងព្រះបច្ចេកពុទ្ធមួយអង្គកំពុងនិមន្តមកពីទ្រង់បិណ្ឌបាត ។ អស់
ពួកមហាជនដែលតាមបៃហាមព្រះពជកុមារទៅនោះ លុះបានឃើញព្រះ
បច្ចេកពុទ្ធហើយ ក៏នាំគ្នាទៅថ្វាយបង្គំប្រណម្យអញ្ជលីហើយសរសើរតែ
ពាល់គ្នា ។ ឯព្រះពជកុមារឃើញដូច្នោះហើយក៏មានព្រះចិត្តថា "មហា
ជនទាំងអម្បាលនេះសឹងមានដំណើរទៅជាមួយនឹងអញ ពុំសមបើនាំគ្នា
ទៅថ្វាយបង្គំប្រណម្យអញ្ជលីសរសើរ ចំពោះសមណៈត្រង់ណេះទៅ
វិញសោះ" ព្រះពជកុមារនោះក្រោធខឹងហើយក៏យាងចុះអំពីដំរីចូលទៅ
រកព្រះបច្ចេកពុទ្ធហើយសួរថា នែសមណៈ លោកនិមន្តបិណ្ឌបាតបាន
អាហារដែរឬទ្យ ? _ ថ្វាយព្រះពរបាន ។ កាលដែលព្រះបច្ចេកពុទ្ធឆ្លើយ
ដូច្នេះហើយ ស្រាប់តែព្រះពជកុមារនោះកញ្ឆក់យកបាត្រអំពីព្រះហស្ត
ព្រះបច្ចេកពុទ្ធចោកទៅលើផែនដី ហើយជាន់ឈ្លីឈ្លើញញីកំទេច
ទាំងកត្តាហារផង ។ ព្រះបច្ចេកពុទ្ធសំឡឹងមើលព្រះកក្ខ្លៃព្រះពជកុមារ

នោះដោយនឹកក្នុងព្រះទ័យថា ឲ សត្វនេះវិនាសហើយតើហ្នា ! ។ ឯ
ព្រះរាជកុមារក៏និយាយទៅរកព្រះបច្ចេកពុទ្ធវិញថា នែសមណ: យើង
ជាព្រះរាជបុត្តរបស់ព្រះបាទ កិតរាស: ព្រះនាមទុដ្ឋកុមារ លោកខឹង
នឹងយើងហើយបើកក្នែកសំឡក់មើលយើងប៉ងនឹងធ្វើយើងយ៉ាងម៉េច? ។

ឯព្រះបច្ចេកពុទ្ធលុះបានឃើញបាតែបែកខ្ទេចខ្ទីអស់ហើយ លោក
ក៏ហោះទៅតាមអាកាសវេហាស៍ ទៅកាន់ញាកក្នំនន្ទមូលកបពិតជិតព្រៃ
ហិមវន្តទិសខាងជើង ។ ឯបាបកម្មនោះឯងក៏ធេះរោលរាលដល់ព្រះ
រាជកុមារក្នុងខណ:នោះភ្លាម ព្រះរាជកុមារមានសរីរ:ក្តៅក្រហាយដូចជា
គេយកទៅច្រកក្នុងហ៊ីប ស្រែកថាក្តៅណាស់ៗ ហើយក៏ដួលនៅក្នុងទីនោះ
ភ្លាម ។ ឯទឹកទាំងអម្បាលម៉ានដែលមាននៅក្នុងស្រះជាដើមនោះ ៗ ក៏
រីងអស់ទៅ ប្រឡាយទឹកទាំងឡាយដែលហូរទៅកាន់ស្រះនោះ ៗ ទៀត ក៏
រីងស្ងួតហួតហែងអស់ទៅ ឯព្រះរាជកុមារក៏ដល់នូវក្សយជីវិតក្នុងទីនោះ
ភ្លាមហើយទៅកើតក្នុងអវីចិនរក ។

រីឯព្រះរាជាសោតកាលបើបានជ្រាបថាព្រះរាជបុត្តព្រះអង្គក្សយព្រះ
ជន្មជូច្នោះហើយ ទ្រង់ក៏ទទួលក្ពួលក្តៅសោយសោកព្រោះបុត្តវិយោគមក
គ្របសង្កត់ ទើបកំណត់ព្រះទ័យពិចារណាថា សេចក្តីសោយសោក
របស់យើងនេះកើតឡើងព្រោះតែបុត្តដែលជាទីស្រឡាញ់ ប្រសិនបើ
សេចក្តីស្រឡាញ់ពុំមានដល់យើងទេ សេចក្តីសោយសោកក៏ពុំកើតមាន
ឡើយ ទើបទ្រង់អធិដ្ឋានតាំងប្តេជ្ញាថា តាំងពីថ្ងៃនេះទៅសេចក្តីស្រឡាញ់
ចំពោះវត្ថុអ្វីនីមួយ ទោះមានវិញ្ញាណក្តី ឥតវិញ្ញាណក្តីកុំបីកើតមានដល់

យើងឡើយ ។ តាំងពីកាលនោះមក ព្រះរាជានោះក៏លែងស្រឡាញ់
របស់ដទៃ ។

បពិត្រព្រះមហារាជ អាស្រ័យហេតុនេះឯងបានជាទូលព្រះបង្គំពុំ
មានសេចក្តីស្រឡាញ់ ។

ព្រះរាជាទ្រង់ត្រាស់សួរតទៅទៀតថា អើធត្តបាណីសំឡាញ់ ចុះ
អ្នកឃើញអារម្មណ៍ដូចម្តេចបានជាអ្នកមិនចេះក្រោធទឹង? ។

នាយធត្តបាណី កាលដែលនឹងក្រាបទូលហេតុដែលទ្ធូនមិនចេះ
ក្រោធទឹងថ្វាយព្រះរាជាទ្រង់ព្រះសណ្តាប់នោះ បាននាំយកនូវអតីតនិទាន
របស់ទ្ធូនដោយព្រះគាថាមួយបទថា

អរកោ ហុត្វា មេត្តចិត្តំ សត្ត វិស្សានិ ភាវយឹ
សត្តកប្ប្យ ព្រហ្មលោកេ តស្មា អកោធនោ អហន្តិ ។

(បពិត្រព្រះមហារាជ) ទូលព្រះបង្គំកើតជាតាបសឈ្មោះអរក:
បានចំរើនមេត្តាចិត្តអស់ ៧ ឆ្នាំ បានទៅកើតក្នុងព្រហ្មលោកអស់ ៧
កប្បដែរ ព្រោះហេតុនោះបានជាទូលព្រះបង្គំពុំចេះក្រោធទឹង ។

សេចក្តីពិស្តារនៃរឿងនេះថា បពិត្រព្រះមហារាជ កាលពីដើមទូល
ព្រះបង្គំកើតជាតាបសឈ្មោះអរក: បានចំរើនមេត្តចិត្តអស់ ៧ ឆ្នាំ បាន
ទៅកើតក្នុងព្រហ្មលោកអស់ ៧ សំវដ្ដវិវដ្ដកប្បដែរ បានជាទូលព្រះបង្គំពុំ
ចេះក្រោធទឹង ព្រោះបានសាងសន្សំបន្ទំមេត្តាកាវនាមកអស់កាលជាយូរ
អង្វែងយ៉ាងនេះឯង ។

កាលបើនាយធត្តបាណីទ្មាន់ប្រកេស ក្រាបទូលអំពីអង្គតាំង ៤ របស់

ខ្ជួនយ៉ាងនេះហើយ ព្រះរាជាក៏ទ្រង់ឲ្យតង្គិតសញ្ញា (ឧបាយឲ្យស្គាល់ហេតុមានព្រិបត្នែកជាដើមឬឲ្យសំឲ្យិប) ជល់ពួករាជបរិស័ទ ។

ខណៈនោះឯង អស់ទាំងអាមាត្យនឹងព្រាហ្មតហបតីជាដើម នាំគ្នាក្រោកប្រញាប់ឡើងស្រែកសន្ធាប់ទៅរកសេនាបតីថា "រ៉ីអាស៊ីសំណូកអាចារកំណាច អាឯងព្រោះតែមិនបានសំណូក បានជាប៉ងនឹងសំឲ្យាប់ធម្មទ្ធជបណ្ឌិត" លុះពោលដូច្នេះហើយ ក៏ព្ជួតគ្នាចាប់ដៃចាប់ជើងកាឲ្យកសេនាបតី នាំចុះបញ្ចអំពីព្រះរាជនិវេសនដ្ឋាន រាយបំបែកក្សាលដោយដុំថ្មនឹងដំបងដែលកាន់នៅដៃគ្រប់គ្នាទាល់តែក្ស័យជីវិត ហើយចាប់ជើងអូសយកទៅចោលលើគំនរសម្រាម ។

តាំងពីថ្ងៃនោះទៅ ព្រះរាជាក៏ទ្រង់សោយរាជ្យ ប្រកបដោយធម៌ លុះទ្រង់ទិវង្គតទៅក៏បានទៅកើតតាមយថាកម្ម ។

លុះព្រះសាស្តាទ្រង់សំដែងព្រះធម្មទេសនានេះចប់ហើយ ទ្រង់ប្រជុំជាតកថា: កាលនោះ កាឲ្យកសេនាបតី គឺទេវទត្ត, ធត្តបាណីកប្សក: គឺសារីបុត្ត, ឯធម្មទ្ធជបណ្ឌិត គឺអង្គតថាគត ។

(ជាតកនេះ ទ្រង់សំដែងប្រាវត្ត អំពីទេវទត្ត ព្យាយាមនឹងសំឲ្យាប់ព្រះអង្គកាលដែលនៅជាពោធិសត្ត តែពុំអាចនឹងធ្វើពោធិសត្តសូម្បីឲ្យគ្រាន់តែតក់ស្ទុតបានឡើយ) ។ ចប់ ។

ផ្នែកអក្សរសាស្ត្រ

ពិធីបំបួសជាកជាតិភូមា

ដោយ ម៉ុង-ហ្ទិន-អ្ងួ

(Les cérémonies d'initiations birmanes
par Maung Htin Aung)

អ្នកប្រែរៀបរៀង: ព្រែម-ឱម លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យ

សព្វថ្ងៃនេះ នៅប្រទេសភូមាមានពិធីបុណ្យពីរយ៉ាងដែលមានរបៀបច្រហែលគ្នានឹងបុណ្យបំបួសនាគដែរ គឺពិធីស៊ុនយូ (Shinbyu) ១, ពិធីមង្គលចោះត្រចៀក ១ ។ ពិធីស៊ុនយូ ធ្វើនៅពេលដែលយុវជនចូលបួសជាសាមណេរ ។ ពិធីចោះត្រចៀក ធ្វើនៅពេលយុវនារីជាតិភូមាចោះត្រចៀកពាក់កាវ ។

ពួកពុទ្ធិកយុវជន ត្រូវចូលបួសជាសាមណេរ មុនពេលដែលមានអាយុគ្រប់ការ ។ នៅបច្ចុប្បន្នកាលនេះ យុវជនចូលកាន់ផ្នួសជាសាមណេរត្រូវមានអាយុពី ៥ ឆ្នាំ ទៅ ១៥ ឆ្នាំ ។ នៅពេលនោះ គេមានប្រគេនចង្ហាន់លោក, អញ្ជើញបងប្អូនញាតិមិត្តជិតឆ្ងាយមកជាអធិបតី ។ ទុកាសធ្វើបុណ្យបំបួសនាគនេះហើយ ជាទុកាសប្រកបទៅដោយសុខសួស្តីជោគជ័យមង្គលនឹងដោយសេចក្តីរីករឿង ។ មានតួរឫតន្ត្រីលេងបទចរលីលា, ព្រោះបណ្តាបទភ្លេងជាតិភូមា បទចរលីលាជាបទមានចង្វាក់រីករាយ ហើយរុងរឿងផង ។ នៅពេលនោះ យុវជនត្រូវគោរក្សាល រួចគ្រាយពេលដែលគេសូត្រធម៌បំបួសចប់ អ្នកនោះឯងនឹងឡើងពេញជាសាមណេរ

(novice) ។ មកដល់ត្រង់នេះ ទើបបុណ្យនេះ មានសភាពដូចគ្នានឹងបុណ្យ
បំបួសនាគក្នុងព្រះពុទ្ធសាសនាមែនៗ គឺថា កាលណាគ្រហស្ថផ្ទាស់គេ
ទៅជាបព្វជិតគេត្រូវធ្វើពិធីបុណ្យជាពីរផ្នែក : មួយផ្នែកគឺបុណ្យបញ្ចូល
គ្រហស្ថឲ្យទៅជាសាមណេរ, មួយផ្នែកទៀត គឺបុណ្យបំបួសសាមណេរ
ឲ្យទៅជាភិក្ខុ ។ ជាតិភូមាបានយកបុណ្យផ្នែកទីមួយ នៃព្រះពុទ្ធសាសនា
នេះ ទៅក្លាប់នឹងបុណ្យសុិនយូ ។ ឯពិធីខាងក្រោយ មានក្រឹត្យវិន័យតឹង
តែងជាងបុណ្យសុិនយូ ។ បុគ្គលណាក៏ដោយពុំអាចអនុញ្ញាតឲ្យជនដែល
ពុំទាន់មានអាយុគ្រប់ ២០ ឆ្នាំ១បសម្បទាជាភិក្ខុបានឡើយ ។

ដូច្នេះ សឲ្យយើញថាមង្គលប្ដបុណ្យទាំងឡាយរបស់ជនជាតិភូមា
មានសុិនយូជាដើម បើគេពិនិត្យមើលបែបផែនខាងក្រៅនៃបុណ្យយើញ
ថាជាបុណ្យពុទ្ធសាសនាមែនៗ, ប៉ុន្តែនៅកន្ទែងខ្ទះមានរបៀបរៀបចំប្ចែក
ដែលជារបៀបធ្ទាប់មានតាំងពីមុនពុទ្ធសម័យមកទៀត គឺថា យុវជនត្រូវ
នៅផ្ទះយ៉ាងតិចត្រឹមប្រាំពីរថ្ងៃ ក្រោមការត្រួតត្រាយ៉ាងតឹងរ៉ឹងនៃបងៗ មុន
ថ្ងៃធ្វើបុណ្យ, ព្រោះគេយល់ថាខ្មោចបីសាច មានចិត្តច្រណែននឹងអនាគត
កិត្តិគុណនៃយុវជន, ហើយវាមុខជាធ្វើឲ្យយុវជននោះបាក់ដៃបាក់ដើង ប្ដ
របួសខានទៅបំពេញកិច្ចកុសលនេះ ។ បន្ទាប់មក នៅព្រឹកថ្ងៃបុណ្យ
យុវជនត្រូវតែងតួជាស្តេច, បាំងក្ងស់មាស, ជិះសេះ រួចគេដង្ហែព័ទ្ធជុំវិញ
ទីក្រុងប្ដភូមិ ។ នៅពេលដែលក្សួនហែបានចូលទៅក្នុងភូមិយ៉ាងសប្បាយ,
ពួកកម្មោះៗ ដែលជួយដើរដង្ហែក៏ស្រែកថា: "ស៊ីវ" (Shew) បាន
សេចក្តីថា: "ត្រជាក់ត្រជុំ" ។ ជារឿយៗ អ្នកដើរមុខក្សួនស្រែកថា:

- សូមឲ្យស្រែចំការទាំងឡាយមានទឹកបរិបូណិ!

យុវជនទាំងឡាយក៏ស្រែកព្រមគ្នាឡើងថា "ស៊ីវ"

- សូមឲ្យជ្រោះព្រែកមានទឹកបរិបូណិ! ។

- "ស៊ីវ" ។

- សូមឲ្យទឹកដោះម្ពាយនៃយុវជនអ្នកបួសនោះមានទឹកបរិបូណិ!

- "ស៊ីវ" ។

- សូមឲ្យទឹកដោះបងស្រីប្អូនស្រីនៃយុវជននោះមានទឹកបរិបូណិ!

- "ស៊ីវ" ។

លុះក្សួនដង្ហែបានទៅដល់ផ្ទូវចូលពីខាងកើតឬខាងលិចភូមិ, គេត្រូវឈប់ប្រហែលប្រាំនាទី ។ នៅពេលនោះ ប្រុសកំឡោះត្រូវអង្គុយត្រង់ខ្លួនហើយគ្មានផ្ទើចលនាអ្វីទាំងអស់, ព្រោះគេទុកអ្នកនោះជូចជាអ្នកតាចាស់ស្រុក ។ មកដល់ត្រង់នេះ ផ្នែកពិធីនេះហៅថាជាពិធីគោរពអ្នកតាណាត (Nat) ។

បន្ទាប់មក គេក៏ដង្ហែបុរសនោះតម្រង់ទៅផ្ទះឪពុកម្ពាយ ។ ក្រោយពេលដែលយុវជនទៅដល់ផ្ទះ កំឡោះ ៗ ក៏តាំងបបួលគ្នាឃ្ទាំចាំលួចយកបុរសនោះ, បើកាលណាគេលួចបានហើយ គេក៏នាំបុរសនោះយកទៅលាក់ទុក លុះត្រាតែឪពុក - ម្ពាយនៀយណាយនឹងអំពើនេះក៏យកលុយទៅលោះកូនយកមកវិញ ។

លុះប្រទេសភូមាត្រូវរួបរួមគ្នាជាមួយនឹងចក្រភពអង្គគ្រេស, ការផ្ទាស់ប្តូរផ្សេង ៗ ក៏កើតមានឡើងនៅគ្រប់សង្គម ។ ពិធីស៊ុនយូក៏ក្លាយ

ទៅជាបុណ្យសង្គមមួយយ៉ាងជាក់ច្បាស់ គេតែងធ្វើឡើងនៅពេលដែលកូនក្មេងមានអាយុ ១៥ ឬ ១៦ ឆ្នាំ ។ នៅសម័យនោះ វត្តទាំងឡាយនៅក្នុងភូមិ សម្រាប់ព្រះសង្ឆគង់នៅផង សម្រាប់ធ្វើជាសាលារៀនផង ។ ដូច្នេះ យុវជននោះមិនមែនជាក្មេងដទៃពុំដែលស្គាល់វត្តរ៉ានោះឡើយ ។ នៅប្រទេសភូមាក្មេងអាយុ ៦ ឆ្នាំ ត្រូវទៅនៅវត្ត, ពេលថ្ងៃ រៀនមេទន្ទេញ, ពេលព្រឹកតាមលោកបិណ្ឌបាតតាមវិថីក្នុងភូមិ, ពេលល្ងាចលេងប្រឡែងជាមួយនឹងក្មេងឯទៀត ក្នុងទីធ្វាវត្ត ។ ពេលរៀបពិធីធ្វើបុណ្យបួសគឺជាពេលដែលក្មេងឈប់ទៅសាលា, ឬពេលក្មេងបញ្ចប់ការសិក្សា ។ ពួកកញ្ញាទាំងឡាយ ពុំបានចាប់ភ្ជឹកដល់បុរសរបៀបនោះសោះ ស្រាប់តែឃើញរៀបពិធីស៊ីនយូតែម្តង, ប៉ុន្តែឥឡូវនេះមិនមែនមានកញ្ញាតែម្នាក់ពីរទេ ដែលរង់ចាំមើលផ្ទូវបុរសបែបនេះដែលត្រឡប់មកពីវត្តវិញ ព្រោះយុវតីមានសេចក្តីសង្ឃឹមផ្សងៗ ដូចមានទំនុកច្រៀងមួយនៅជាប់ដល់សព្វថ្ងៃ ដូចតទៅនេះ:

" នៅមុខគេហស្ថាននារិ

" មានមែកផ្កាសត្ថា - ភូ (Sattha-phu) មួយពីរកំពុងផ្កា

" សត្វសេកទាំងឡាយខំខូល់ខ្វាយចឹកពាំស៊ី ។

" ឧសត្វសេកពណិលឿងទុំ ! ខ្ញុំសូមអង្វរឲ្យអ្នកទុកផ្កានេះខ្ជះ

" ពីព្រោះបុប្ជានេះត្រូវនៅចាំប្រុសស្នេហ៍ខ្ញុំត្រឡប់មកពីវត្តវិញ

" នៅពេលនោះខ្ញុំនឹងបេះផ្កាទៅចងលំអតាត់ " ។

យុវជនកាលធ្វើបុណ្យរួច ក៏ទៅបួសជាសាមណេរអស់រយៈមួយ ឬ

ពីរវិ, លុះសឹកមកជាគ្រហស្ថ, អ្នកក៏ធ្វើខ្ជូនជូចជាយុវជនឯទៀត ៗ ដែរ គឺដើរលេងសប្បាយហ្ចឹហាតាមធម្មតា ។ ស្រីជំទង់ ៗ ក៏លបលួចស្រឡាញ់បណ្ឌិតថ្មីនេះលាន់ ។ ចាប់ពីពេលនោះមក បុរសក៏ទំរកស៊ីចិញ្ចឹមជីវិតខ្ជូន, បង ៗ ក៏បង្ខំឲ្យរកប្រពន្ធកូន ដើម្បីនឹងបង្កើតគ្រួសារថ្មី ។ ប៉ុន្តែ បើធៀបទៅនឹងក្មេងនៅក្នុងភូមិជាមួយគ្នា ឃើញថាបុរសនេះនៅវ័យក្មេងណាស់ គួរតែទៅបួសម្ពងទៀត ។

បើសិនជាពិធីសុិនយូ ជាគ្រឿងសំគាល់ប្រាជ្ញានឹងតំនិតមារយាទរបស់យុវជននោះ ពិធីទីពីរ ក៏ជាគ្រឿងសំគាល់នៃសេចក្តីក្លាហាននឹងសេចក្តីជាច់ចិត្តរបស់គេសុទចិត្តទៅធ្វើជាបព្វជិត ។ ពិធីទីពីរនេះ គឺ ពិធីសាក់ខ្ជូន ។ ជាតិភូមាមានរបៀបសាក់ពីរយ៉ាង ម្យ៉ាងសាក់ជាការលំអ, ម្យ៉ាងសាក់មន្តអាគម គឺថា ទីមួយជាការបង្ហាញនូវអត្តពល, ទីពីរជាការបង្ហាញនូវការខ្លាំងពូកែកាប់មិនមុតជុតមិនធេះ ។ ចំពោះពួកកំឡោះ សាក់លើកដំបូង គ្រាន់តែជាការលំអនឹងជាការនិយមរបស់សង្គមប៉ុណ្ណោះ, ឯសាក់លើកទីពីរដែលនឹងមានធ្វើឡើងនៅពេលខាងក្រោយ ទើបពេញជាសាក់ប្រកបដោយមន្តអាគមមែន ។ ការសាក់នេះបណ្ណាលឲ្យឈឺចាប់ជាខ្លាំង យុវជនត្រូវទាំមាត់អត់ទ្រាំមិនស្រែក ទោះឈឺយ៉ាងណាក៏ដោយ, ព្រោះថាបើសិនជាយុវជនក្លាត់មាត់ថ្ងូរ ឬស្រែក ពួកភ្ជឿនដែលនៅជុំវិញមុខជានឹងសើចគិលឡើង ហើយមុខជានឹងនិយាយកំប្ចុកកំប្ចែងធ្វើត្រាប់សើចលេងអស់ពេលជាច្រើនវិញ ។

ចុះហេតុអ្វីបានជាយុវជនចាំបាច់ស្លៀកពាក់ជូចស្តេច ចាំបាច់ជិះលើ

ខ្នងសេះនៅពេលធ្វើពិធីសុិនយូ? មុននឹងធ្វើយនូវបញ្ហានេះ, យើងសូមបញ្ជាក់ឲ្យដឹងថា បើពួកយុវជនជាតិភូមាជិះសេះនៅពេលដែលស្តេចកំពុងគង់លើសេះដែរ. ប្តតែងខ្លួនជូចជាស្តេចដែរនោះ។ មិនត្រឹមតែប្លែកក្នែកអ្នកជទៃទេ គឺថែមទាំងខុសនឹងច្បាប់អាណាចក្រទៀតផង ។ សង្គមជាតិភូមាជាសង្គមគ្មានវណ្ណៈ, គ្មានពួក, ជាសង្គមមានស្តេចគ្រងរាជ្យនឹងគណៈរដ្ឋមន្ត្រីសម្រាប់ត្រួតត្រាកិច្ចការផ្សេង ។ ប៉ុន្តែ ព្រះមហាក្សត្រិយ៍ប្រទេសភូមាចូលជ្រៃតជ្រែកក្នុងការរដ្ឋបាន លុះត្រាតែមានបរិយាកាសស្អុះស្អាប់រវាងព្រះអង្គនឹងគណៈរដ្ឋមន្ត្រី, ប្តរវាងគណៈរដ្ឋមន្ត្រីនឹងប្រជារាស្ត្រ ។ ដោយហេតុនេះហើយ, បានជាសំលៀកបំពាក់ស្តេចនឹងសំលៀកបំពាក់អ្នកហែហមមានពណិខុសគ្នា ។ កាលណាស្តេចយាងទៅគង់ប្រថាប់មុខប្រជាជន, ព្រះអង្គឥតត្រូវការគង់លើសេះ ប្ត ដំរី ប្ត លើវមាសទ្បើយ ព្រះអង្គយាងដោយព្រះបាទផ្ទាល់ទ្រង់គ្រឿងដោយពាក់កងមាស, កាន់ជាវរំលេចដោយក្បាច់រចនាផ្សេង។, ពាក់ព្រះសុពណិបាទមាសជាសញ្ញានៃនគរ ។ មិនតែប៉ុណ្ណោះ មានមន្ត្រីបាំងខ្ទស់ថ្ទាយទៀត ។ នរណាមួយស្ទៀកពាក់រប្រៀបនេះនឹងត្រូវមានទោសទ្រកិដ្ឋ, លើកលែងតែយុវជនដែលត្រូវធ្វើពិធីសុិនយូ, នឹងពួកលេងល្ខោន ទើបមានច្បាប់អនុញ្ញាត ។

ដើម្បីនឹងដោះស្រាយសំនួរថា: ហេតុអ្វីបានជាយុវជនត្រូវស្ទៀកពាក់ជូចស្តេចគ្រងរាជ្យ? ប្រជាជនភូមាបានធ្វើយថា បានជាយុវជនធ្វើជូចនេះព្រោះយុវជនចង់ធ្វើតាមព្រះសិទ្ធត្ថ: ដែលជាស្តេចមួយព្រះអង្គ

បានរត់ចោលជីវកាពរុងរឿងឧត្តុងឧត្តមដើម្បីទៅបំពេញផ្ទួស, លុះត្រាតែ
បានត្រាស់ជាព្រះពុទ្ធ ។ ហេតុនេះ យុវជនដែលស្វែកពាក់ជូចស្តេច
ត្រងរាជ្យ គឺជាអ្នកលេងតួរឿងនៃព្រះសិទ្ធត្ថ: ។ ប៉ុន្តែ សេចក្តីអធិប្បាយ
មកប៉ុណ្ណោះ គឺជាគំនិតកើតមានមកខាងក្រោយទេ ព្រោះគេចង់ញ្ចាំង
បុណ្យព្រះពុទ្ធសាសនាមែនៗ ឲ្យទៅជាបុណ្យមុនពុទ្ធសម័យ ។ ជូច្នោះ
បានជានៅប្រទេសភូមា គេមានធ្វើបុណ្យព្រះពុទ្ធសាសនាជាច្រើន
ដែលមានលំនាំទៅតាមបុណ្យដែលកើតឡើងមុនពុទ្ធសម័យទៅទៀត ។

ពាក្យ "សុិន" ប្រែថា "ភិក្ខុ" ប៉ុន្តែបើប្រែថា ត្រូ, នាយ,
ចៅហ្វាយ ឬ ម្ចាស់ផែនដី ក៏បាន ។ ដោយពិត បើតាមក្បួនអក្ខរា-
វិរុទ្ធសព្ទថ្ងៃនៃពាក្យ សុិន, អ្នកប្រាជ្ញភូមាបានបដិសេធពាក្យនេះថា
មិនមែនមានន័យថាស្តេចផងទេ, គឺមានន័យតែមួយគត់គឺ "ភិក្ខុ" ។
ប៉ុន្តែអក្ខរាវិរុទ្ធនេះជាពាក្យទើបតែនឹងបង្កើតថ្មី, បើតាមសំដីគេនិយាយ
ធម្មតា, ពាក្យនេះមានន័យថា ភិក្ខុ ក៏បាន, ស្តេច ក៏បាន ។ ជូចនេះ
ពាក្យ "សុិនយូ" បានសេចក្តីថា "ធ្វើជាភិក្ខុ, ធ្វើជាស្តេច" ។ យុវជន
ដែលទើបនឹងបួសរួចបានឈ្មោះថា "សុិន-ឡូង" (Shin-Laung) គឺ
អ្នកដែលចង់ទៅជាភិក្ខុ ឬអ្នកដែលចង់ទៅជាស្តេច ។ អ្នកនិពន្ធបាន
អធិប្បាយរួចម្តងមកហើយថា: សង្គមភូមាគ្មានប្រកាន់វណ្ណ: ប្រកាន់
ប័ក្សពួកទេ ។ ពិតមែនតែម្ចាស់ផែនដីនឹងរដ្ឋមន្ត្រីព្រះអង្គទ្រង់គង់, នឹងឱត
នៅខ្ពស់លើប្រជាជនទាំងអស់ ប៉ុន្តែប្រជាជនទាំងឡាយអាចសង្ឃឹមថា
ថ្ងៃណាមួយនឹងបានទៅជាស្តេចផែនដី ។ ម្យ៉ាងទៀត ដោយពួកមន្ត្រី

មហាក្សត្រសុទ្ធតែជាអភិជនជ្រើសតាំងឡើងដោយចំណេះជ្ញា, មិនមែនជ្រើសតាំងឡើងតាមពូជអំបូរនោះទេ, ហេតុនេះ ជនណាក៏ដោយឲ្យតែមានសមត្ថភាពគ្រប់គ្រាន់ ក៏អាចទៅជាអ្នកជាន់ខ្ពស់ម្នាក់សម្រាប់ដឹកនាំប្រជាជន ។ សៀវភៅប្រវត្តិសាស្ត្រកូមា (folklore) មានទិយាយពីសាវតារក្មេងកំសត់ទុគ៌តជាច្រើនដែលបានទៅជាស្តេចផែនដី, ទិយាយពីពួកតែងសាវតារផ្សេង ។ ដែលគ្មានជាប់ពូជអំបូរស្តេចសោះក៏បានទៅជាស្តេចផែនដីដែរ ។ មួយទៀត ក្នុងពង្សាវតារកូមាមានទិយាយថា ស្តេចផែនដីត្រូវប្រជាជនចោះឆ្នោតរើសជាសាកល ។ របៀបនេះ មានធ្លាប់ហូតមកទល់នឹងការរៀបចំសារបៀបគ្រប់គ្រងនៃអាណាចក្រកូមាក្នុង គ. ស. ១៨៨៦ ។ ដូច្នេះ កាលណាយុវជនកូមាណាមានវ័យគ្រប់ការ, យុវជននោះអ្នកផងអាចរំពឹងថាមុខជាបានទៅជាស្តេចនគរខ្លួនទៅពេលណាមួយ ។ ឯអាវរៃសម្រាប់ស្តេចដែលគេពាក់ទៅពិធីស៊ុនយូ ជានិមិត្តដែលគេសំគាល់បានថាកូនក្មេងមានវ័យគ្រប់ការហើយ ។

ពិធីធ្វើបុណ្យគោរពទេវតា, អារ័ក្សបីសាច (ណាគ) មានដើមកំណើតមុន ព. ស. ទៅទៀត ។ ឥឡូវនេះទៅក្នុងភូមិភាគជាច្រើននៃប្រទេសកូមាផ្នែកខាងលើ យុវជនឈប់ចង់គោរពអ្នកតា (ណាគ) ឈប់គោរពបូជាគតជាហើយ ។ តែមុនពេលដែលអ្នកប្រាជ្ញ អាណាវ៉ាតា (Anavratha) បានផ្សាយព្រះពុទ្ធសាសនាឲ្យទៅជាសាសនារបស់រដ្ឋពេញទី, ប្រជាជនកូមាគោរពប្រណិប័តន៍រូបតំណាងអ្នកតាណាគ

ទំង៣ស់នាគភជណាស់ ព្រោះគេទុកប្រូបទាំង ២ នេះដូចជាទៅតា ឬជា ព្រះបេស់គេ ។ នៅផ្លូវពីខាងកើតដែលចូលទៅកាន់កូមិមួយ ។ មានសង់ រូបណាតជាធ្នាំឮរទើងរូបនាគភជ ពីព្រោះណាតមានកំណើតជាប់ទាក់ទង ជាមួយទំងនាគភជ ។ អំណើះពីអ្នកប្រាជ្ញអាណាវ៉ាតា៧, រូបនាគភជ កំរលាយបាត់អស់ទៅ នៅសល់តែរូបណាតដែលជាប់ទាក់ទងលាយឡំ ទំងព្រះពុទ្ធសាសនា ។ ក្រោយមក ដើម្បីទុកកន្លែងសង់វិហារនៅពី ខាងកើតកូមិវិញ, រូបណាតធ្នាំឮរក៏លើកយកទៅសង់ពីទិសខាងលិច វិញ ។ ដោយហេតុតែរូបតំណាងនោះវិនាសទៅ, បានជាយុវជនត្រូវ ឈប់ឈរទ្រឹង ១ ស្របក់នៅផ្លូវចូលទៅកងកូមិពីខាងកើត ដើម្បីធ្វើជា តំណាងរូបដែលគេបំបាត់ចោលនោះ ។

ពាក្យ "ស៊ីវ" ដែលពួកយុវជនតែងស្រែកនៅពេលជង្គើស៊ុនយូ ជាពាក្យមានដើមកំណើតមកពីសំស្ក្រឹតថា ស្រី (SRI) ។ ពួកហោក-សាស្ត្រឥណ្ឌា ដែលបានចូលមកថ្វាយបង្គំស្តេចកូមាពីសតវត្សរ៍ទី ១ នៃ គ.ស. បានយកពាក្យនេះមកប្រើនៅគ្រប់ពេលរៀបធ្វើពិធីផ្សេង។ តែដោយឡែងតាត់បំផុត គឺពេលអភិសេកស្តេចផែនដី ។ ពាក្យនេះ បានសាយចេញពីក្នុងព្រះពជកំង រហូតដល់យកទៅប្រើពាសពេញក្នុង ពិធីសុំនយូ ហើយគេទុកពាក្យនេះជាពាក្យថ្លៃថ្នូរមានសិរីសួស្តីផង ។ ពួកហោរាសាស្ត្រឥណ្ឌាបានកំណត់ថ្ងៃខែឲ្យជាតិកូមាធ្វើបុណ្យសុំនយូ ។ ហេតុដូច្នេះ គេអាចធ្វើបុណ្យសុំនយូបាន លុះណាតែពួកហោរាសាស្ត្រ បានគន់គូរកំណត់ពេលឲ្យជាមុនសិន ។

ពាក្យ "ស៊ីវ" មានន័យថា "ត្រជាក់ត្រជំ" ប៉ុន្តែនៅក្នុងជំបន់រីងស្ទូត ខ្ទះ នៃប្រទេសភូមាផ្នែកខាងលើ គឺអាណាចក្រនៃប្រជាជនដើមជាតិភូមា ជីសើមៗ នឹងជីមានជីវជាតិ ពីដើមជូចម្តេច ឥឡូវនៅតែជដែល ។ ពិធីស៊ុនយូតាមទំលាប់មក ច្រើនធ្វើនៅខែតាបូង (កុម្ភៈ, មីនា) នៃប្រក្រតិទិនភូមា គឺនៅពេលគេច្រូតកាត់រួច ដែលព្រះធរណីកំពុងហួតហែង ហើយគេសង្ឃឹមថា មុខជានឹងមានភ្លៀងធ្លាក់នៅពេលប្រាំបួនប្តជប់អាទិត្យ ក្រោយមក ។ ជូច្នេះពាក្យ "ស៊ីវ" គឺជាសេចក្តីអង្វរបន់ស្រន់ឲ្យភ្លៀងធ្លាក់ ហើយពាក្យនេះក៏ទៅជាពាក្យទិព្វមួយតែងផ្តល់ផលប្រយោជន៍ឲ្យ ។

តាំងពីមុនកើតពង្សាវតារម្ទើះ, ស្រី ៗ មានចោះត្រចៀកត្រប់គ្នា, ប្រុស ៗ ក៏មានធ្វើជូច្នោះដែរ ប៉ុន្តែមិនមែនជាទំនៀមទំលាប់ជាច់ខាតទ្ធ ទៅនោះទេ ពួកខត្តិយវង្សទើបត្រូវតែចោះត្រចៀក : នេះជាការតម្រូវរបស់ស្តេច ។ នៅក្នុងភូមិ ការចោះត្រចៀកឥតមានរៀបធ្វើពិធីអ្វីទេ, ប៉ុន្តែនៅក្នុងព្រះបរមរាជវាំង ពិធីនេះត្រូវតែមានជាការចាំបាច់ ។ ក្សត្រិយ៍ទាំងឡាយ អាចរៀបអភិសេកឡើងសោយរាជ្យបាន លុះត្រាតែបានបំពេញពិធីនេះសិន ចំណែកស្តេចដែនជីត្រូវធ្វើពិធីនេះនៅមុនពេលអភិសេក ។ តាមទំនៀមទំលាប់ស្តេច, ត្រួសារស្តុកស្តមត្រូវធ្វើពិធីនេះនៅក្នុងព្រះរាជធានី មិនមែនធ្វើនៅតាមភូមិទេ ហើយកិច្ចនេះត្រាន់តែប្រជុំនារីកូនអ្នកមានៗ ដែលមានត្រចៀកចោះនឹងម្ជុលមាស មកអង្គុយនៅមុខភ្យៀវទាំងឡាយ ។ ក្នុងពិធីនេះត្មានជាប់ទាក់ទងនឹងសាសនាទេ ។

ប៉ុន្តែក្រោយមក លុះអ្នកប្រាជ្ញអាណាវរ៉ាតា បាននាំលទ្ធិព្រះពុទ្ធ-
សាសនាចូលមកផ្សាយក្នុងប្រទេសភូមា ។ ក៏ទទួលស្គាល់សាសនានេះ
តាមផ្ទូវការដោយពិតប្រាកដ ។ រួចគេក៏សង្កេតឃើញមានធ្វើពិធីបំបួស
ស្ត្រីដែរ ។ សាវតារមាននៃយាយថា ពួកយុវនារី, មុននឹងរៀបការត្រូវ
បញ្ជូនទៅកន្ទែងសមណៈអារីស (Aris) សិន, ព្រោះសមណៈនេះគេ
គ្រាន់តែយកឈ្មោះព្រះពុទ្ធមកធ្វើជាកស្ត្ពុតាងប៉ុណ្ណោះទេ តែគេបាន
ប្រកាសខ្ជូនគេជាមនុស្សខូចកាច ។ ពួកនេះប្រើច្បាប់ស្តេចត្រាញ់, ស្ត្រី
ណាមួយក៏ដោយមុននឹងការ ត្រូវទៅវិហារសិនដើម្បីជំរះចិត្តក្រមុំចេញ ។
ទំលាប់នេះហៅថាពិធីផ្ការដំបូង (Première fleur) ឬ ពិធីទៅព្រះវិហារ ។
ការនេះឃើញថាពិតមែន, តែបើតាមគំនិតខ្ញុំជាអ្នកនិពន្ធយល់ថាអំពើនេះ
ជាសេចក្តីឃោសនានយោបាយនៃលោកអាណាវរ៉ាតាទេ ដើម្បីបំបាត់ពួក
អារីសចោល ។

ពួកសមណៈអារីសរៀនអំពើអាបធ្មប់, ច្នៃថ្មហើយនឹងហោរាសាស្ត្រ ។
ឯសាសនារបស់គេ លាយឡំជាមួយនឹងព្រះពុទ្ធសាសនាបន្តិច ជាមួយនឹង
កិច្ចការផ្សង ។ នៃរូបអ្នកតានាគរាជបន្តិច ហើយគេគោរពរូបភាពអារ៉ក្ស
បីសាចណាតបន្តិច ។ មិនតែប៉ុណ្ណោះ ពួកនេះធ្វើការជំទាស់នឹងលោក
អាណាវរ៉ាតានឹងលទ្ធិព្រះពុទ្ធសាសនា ដែលគាត់បានយកមកផ្សាយ ។
គាត់ក៏ត្មានមធ្សាបាយអ្វីក្រៅពីធ្វើទុក្ខពួកនោះ ហើយនឹងចុះដៅក្នុង
សាវតារនៃការជាន់ឈ្ទីព្រះពុទ្ធសាសនានូវពួកកំណាចនោះ ។ ប៉ុន្តែពួក
អារ៉ីសបានទៅជាចៅហ្វាយនៃប្រជាជនភូមា, ចៅហ្វាយដោយចរិយា

សាស្ត្រនឹងសាសនាអស់ពេលជាច្រើនសតវត្សរ៍ ។ អត្ថបទសាវតារចិន នៅឆ្នាំ ៨០០ ក្រោយ គ.ស. បានអធិប្បាយពីអាណាចក្រផ្នែកខាងលើ នៃប្រទេសកូមា ដែលជាកំណើតសីលធម៌, កំណើតក្បួនហោរាសាស្ត្រ ហើយដែលជាកន្លែងមានព្រះវិហារពប់រយ នៃព្រះពុទ្ធសាសនាសង់ នៅនោះ ។

អត្ថបទដដែលនេះ បានបន្ថែមសេចក្តីទៀតថា: ពួកកុមារីកាលអាយុបានប្រាំពីរឆ្នាំ ក៏ការសក់ក្បាលរួចត្រៀមទៅនៅវត្តដែរ ។

ការប្រតិបត្តិនេះចេះតែមានអានុភាពឡើង លុះត្រាតែពួកអ៊ីសត្រូវផ្ញាស់ប្តូរយកពួកពុទ្ធសមណ: ប៉ែកខាងត្បូងមកជំនួសវិញ, ប៉ុន្តែដោយសារតែការយោសនាចាក់ជ្រៅនឹងការអន្តរាយផ្សេង ។ សមណ: ទាំងនោះក៏កាន់វិន័យតឹងតែងលែងទទួលយុវនារីឲ្យនៅអាស្រ័យក្នុងវត្តទៀត ។

តាមសេចក្តីដែលខ្ញុំបានអធិប្បាយតាំងពីដើមមកនេះ, ចំពោះបុណ្យបំបួសនាគកូមា, ខ្ញុំសូមជូនយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំដូចតទៅនេះ ៖

๑) ជាតិកូមាក៏ដូចជាជាតិឯទៀតដែរ មានពិធីធ្វើបុណ្យបួសជាប់ទាក់ទងជាមួយនឹងមន្តអាគមផង ជាមួយនឹងសាសនាផង ។ ប៉ុន្តែមានពិធីមួយទៀតសម្រាប់ស្ត្រីផ្សេង សម្រាប់បុរសផ្សេង, ពិធីនេះមានសភាពស្មុគស្មាញហើយកំប៉ិកកំប៉ុកណាស់ ដូចគ្នានឹងពិធីពីជំនាន់បុព្វសម័យ ។

๒) ចំណែកពួកសមណ: អ៊ីស នៅទីក្រុងប៉ាកាន (Pagan) ដោយសារការរុករានរបស់គេនៅក្នុងនគរភ្យូ (Phu) ពិធីជាន់ចាស់របស់

គេក៏បានកែប្រែទៅជាពិធីពុទ្ធសាសនា ។ ប៉ុន្តែនៅមានពិធីសម្រាប់ស្ត្រីផ្សេងបុរសផ្សេងដដែល ។

៣) ក្រោយការសង្កត់សង្កិននៃសមណៈ អារីស, ពិធីបំបួសស្ត្រីក៏បាត់ត្រឹមនោះទៅ ។ ឯពិធីចោះត្រចៀក ត្រាន់តែនៅមានតែមិនរីកសាយទេ ចំណែកឯពិធីស៊ុនយូវិញទើបនៅជាប់ដល់សព្វថ្ងៃនេះ ។

អ្នកមានទ្រព្យរាប់ជាអ្នកប្រសើរ

៦ - សេចក្តីពិត, ក្នុងលោកនេះ កិច្ចការណាដែលមិនសម្រេចដោយទ្រព្យ កិច្ចការនោះមិនមានសោះឡើយ ព្រោះហេតុនោះ អ្នកមានប្រាជ្ញាគប្បីប្រសិទ្ធីទ្រព្យសម្បត្តិឲ្យកើតឡើងដោយសេចក្តីខ្នះខ្នែង ។

នរជនណាមានទ្រព្យ នរជននោះឈ្មោះថាមានមិត្ត, ឈ្មោះថាមានផោពង្ស, ឈ្មោះថាជាមនុស្សក្នុងលោក, ឈ្មោះថាជាបណ្ឌិត ។

រឿងសាមកុក

កណ្ឌទី ៦៦

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រៃជ្រៀបជ្រៀង

(តមក)

ជ្រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងដៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ត្លនអ៊ូបានស្តាប់ក៏ត្រិះរិះយូរណាស់ លុះយល់ឃើញត្រូវក៏ធ្វើយថា អ្នកនិយាយនោះត្លរហើយ ឯទោសដែលមាន ៣ ប្រការលើខ្លួនខ្ញុំនោះ អ្នកនឹងឲ្យខ្ញុំធ្វើយ៉ាងម្តេច? ។ គៀវលៀវធ្វើយថា "មហាឧបរាជឲ្យ ទាហានឡោមព័ទ្ធអ្នកជាប្រើនតម្លួតណាស់ បើអ្នកមិនស្ម័គ្រចូលទៅផង ទេ ឃើញជាជីវិតអ្នកនឹងអន្តរាយក្នុងគ្រានេះជាអសារឥតប្រយោជន៍ សុំ ឲ្យអ្នកទៅនៅនឹងមហាឧបរាជសិនចុះ អ្នកនឹងបានប្រយោជន៍ ៣ ប្រការ:

ប្រការ ១– ដែលអ្នកបានស្បថស្បាន់ទុកនឹងឡៅពី, គៀវហ៊ុយថា នឹងជួយគ្នាទំនុកបំរុងផែនដី សេចក្តីស័ត្យក្នុងខនេះ ក៏នឹងបានគង់នៅបិត ថេរបេរកាលតទៅ ។

ប្រការ ២.– ខ្លួនអ្នកក៏នឹងបានទៅពិតក្តិរក្សាបងថ្ងៃទាំង ២ នាក់មិន ឲ្យមានសេចក្តីអន្តរាយដោយហេតុផ្សេង ៗ ។

ប្រការ ៣ — ខ្ញុំនឹងកាន់មានថ្លៃដែរ ដ៏មានសេចក្តីបញ្ញា នឹងបានគិតការទំនុកបំរុងព្រះចៅហ្លួងតែឲ្យសោយរាជសម្បត្តិតទៅ ខ្ញុំយើញមានប្រយោជន៍ ៣ ប្រការដូច្នេះ ទើបមករំលឹកសេចក្តីអ្នក ចូរអ្នកត្រិះរិះតាមគួរចុះ” ។

គួនអ៊ូឆ្លើយតបថា ដែលអ្នកថាមានប្រយោជន៍ដល់ខ្លួនយើង ៣ ប្រការនោះក៏មែនពិតហើយ តែយើងសុំប្តេជ្ញាទុក ៣ ប្រការ បើមហាឧបរាជយល់ព្រម យើងនឹងសុំដោះគ្រឿងចេញ ហើយនឹងចុះទៅតំនាក់មហាឧបរាជ តែថាបើសេចក្តីដែលយើងសុំប្តេជ្ញានោះខ្លះតែឯណាមួយ យើងក៏ស៊ូស្លាប់ក្នុងគ្រានេះ ទោះបីនរណាគរហានិន្ទាថាដូចម្តេច យើងក៏អស់គិតហើយ តាមចិត្តចុះ ។

តៀវលៀវសួរថា មហាឧបរាជនោះចិត្តជាអ្នកធ្ងន់ខ្លាយរោះរាយនឹងមនុស្សពាំងឆ្ងាយណាស់ រមែងតប់សមាគមនឹងអ្នកមានដំរេះប្រាជ្ញា បើអ្នកនឹងនិយាយប្រការម្តេច មុខជាមហាឧបរាជនឹងព្រម តើខ្លះប្តេជ្ញារបស់អ្នក ៣ ប្រការ គឺអ្វីខ្លះ ?

គួនអ៊ូឆ្លើយតបថា “ពីដើមយើងបានស្បថសច្ចាន់គ្នាជាមួយនឹងខ្លាពី តៀវហុយថានឹងជួយទំនុកបំរុងព្រះចៅហ្លួងតែ ខ្លួវអាណាប្រជារាស្ត្រឲ្យបានទៅជាសុខក្សេមក្សាន្តតទៅ ឥឡូវបើយើងនឹងទៅនៅធ្វើការជាមួយនឹងមហាឧបរាជនោះ យើងត្រូវសុំឲ្យខ្លួនយើងនឹងនៅជាខ្ញុំព្រះចៅហ្លួងតែដដែល ប្រការ ១ ។

មួយទៀត យើងសុំប្រណិបត្តន៍រក្សាបងថ្លៃយើងពាំង ២ នាក់ នឹងកុំឲ្យអ្នកឯណាចូលចេញជាទីមើលងាយឲ្យដល់មាត់ទ្វារទីលំនៅបាន ហើយ

នឹងសុំបៀវត្សរបស់ឡៅពីដែលឆ្លាប់បានព្រះរាជទាននោះ មកឲ្យបងថ្ងៃ
យើងទាំង ២ តទៅ នេះប្រការទី ២ ។

"ប្រការទី ៣ បើយើងបានជឹងឆ្ងថា ឡៅពីទៅនៅទីឯណា ទោះបី
យើងមិនបានជួបលោកមហាឧបរាជក្តីណា យើងក៏សុំទៅរកឡៅពី
វេលានោះ សូម្បីមហាឧបរាជនឹងឃាត់ហាមយើង ។ ក៏ពុំព្រមស្តាប់ឈប់
ខានឡើយ ។

រីសេចក្តីទាំង ៣ ប្រការនេះ ចូរអ្នកនាំទៅជំរាបស្នើនឹងមហាឧបរាជ
ចុះ បើយល់ព្រមតាមខប្តេជ្ញានេះហើយ យើងនឹងរៀបខ្លួនទៅនៅផង
ក្នុងវេលានេះ" ។

ត្រៀវលៀវក៏លាគួនអ៊ូឡើងសេះចុះទៅជួបនឹងចូធូ ហើយពណ៌នា
រឿងរ៉ាវដែលបាននិយាយនឹងគួនអ៊ូនោះឲ្យស្តាប់គ្រប់ប្រការ ។

ចូធូបានស្តាប់គ្រប់ប្រការក៏អស់សំណើច ហើយនិយាយនឹងត្រៀវ
លៀវថា ដែលគួនអ៊ូមិនព្រមនៅនឹងយើងនោះ ព្រោះយើងគ្រាន់តែជាទី
មហាឧបរាជ គួនអ៊ូព្រមជាខ្ញុំព្រះចៅហ្វានតេក៏ជូចជាបាវយើងដែរ បើ
យើងបង្គាប់បញ្ជាការអ្វីជាផ្លូវរាជការ គួនអ៊ូក៏មិនត្រូវទទឹងទាស់បាន ១
ដែលគួនអ៊ូថា នឹងសុំប្រណិបីតន៍រក្សាបងថ្ងៃទាំង ២ មិនឲ្យអ្នកឯណាប្ងៃក
ប្ងឹមចូលទៅជល់ទ្វារទីលំនៅនោះយើងក៏ព្រម សព្វថ្ងៃនេះកុំថាតែកវិយា
ឡៅពីឡើយ សូម្បីកវិយាតូចចុះទៅ យើងក៏មិនត្រូវចូលចិត្តឲ្យផ្ទើផ្តស
ផ្តាសសោះ ដែលគួនអ៊ូសុំបៀវត្សរ៍ឡៅពីមកឲ្យបងថ្ងៃចាយវាយប្រើ
ប្រាស់នោះ យើងនឹងឲ្យទ្វេឡើងទៀត, តែ១ដែលគួនអ៊ូជឹងថាឡៅពី

នៅទីណាតំបន់ណា ហើយគួនអ៊ូនឹងទៅរកគ្នាមិនចាប់លាយើងនោះ (ចូរឆ្លូ
គ្រីក្បាល) យើងមិនយល់ព្រមសោះ បើគួនអ៊ូសុំប្តេជ្ញាយ៉ាងនេះហើយ
យើងយកមកចិញ្ចឹមរក្សាទុកឲ្យមានកំឡាំងនឹងបានជាប្រយោជន៍អ្វី ។

តៀវលៀវធ្វើយថា "មហាឧបាសិកាមិនជ្រាបទេឬ ក្នុងនិទានអ៊ីយៀងដែល
មានមកពីបុរាណថា "ពីដើមអ៊ីយៀងនៅនឹងតុងហាងទៅហ្វាយស្រុក,
"តុងហាងចិញ្ចឹមរក្សាអ៊ីយៀងជាដំណូងសុខ្លួនប្រិតប្រៀប លុះនៅមកមាន
"ឈ្មោះយីប៉ែកទៅហ្វាយស្រុកមួយនោះលើកកងទ័ពទៅសម្លាប់តុងហាង
"ស្លាប់ យីប៉ែកក៏បានអ៊ីយៀងទៅចិញ្ចឹមរក្សា ហើយតាំងអ៊ីយៀងឲ្យធ្វើ
"នាហ៊ីនទីប្រឹក្សា អ៊ីយៀងក៏បានសេចក្តីសុខជាយូរតមក ក្រោយនោះ
"សៀងជូទៅហ្វាយស្រុកហាន់កុក លើកទ័ពទៅចាំងសម្លាប់យីប៉ែកស្លាប់
"អ៊ីយៀងមានកំហឹងចងអាឃាតជាប្តាច់នឹងសៀងជូក៏ទៅដល់ស្រុកហាន់
"កុក ហើយចូលទៅលាក់ខ្លួនតួនកងទីកំពាំង ប្រាប់ដើម្បីនឹងធ្វើសៀងជូ
"ឲ្យដល់នូវសេចក្តីស្លាប់ សៀងជូចាប់បានអ៊ីយៀងដល់ ២ គ្រាមិនបាន
"យកទោស ឲ្យលែងអ៊ីយៀងទៅវិញ លុះខាងក្រោយមកអ៊ីយៀងកំលប
"ចូលទៅនៅលាក់ខ្លួនដល់ទីខាងក្នុង ប្រាប់នឹងសម្លាប់សៀងជូឲ្យបាន
"សៀងជូក៏ចាប់ខ្លួនបានទៀត ទើបសួរចំអៀយអ៊ីយៀងថា អ្នកឯងមកធ្វើ
"ប្រទូសក៉ាយយើងៗចាប់បានដល់ ២ គ្រាហើយ យើងមិនបានយកទោស
"លែងខ្លួនទៅវិញ ខ្លួនមិនបានចូលក្នុងគុកឬ បានជាមកធ្វើយើងទៀត
"យើងក៏ចាប់បាន, ដែលខ្លួនមកចងចិត្តគិតព្យាបាទយើងតាំងម្ល៉េះ ពីព្រោះ
"ហេតុអ្វី? ។ អ៊ីយៀងធ្វើយថា ពីដើមខ្ញុំបាទនៅទីពឹងតុងហាងៗចិញ្ចឹម

"ខ្ញុំបាទជាដំនួសគ្រែគ្រាស់ លុះយើញក៏លើកទ័ពទៅសម្លាប់តុងហាងយី-
"បើកកំយកខ្លួនខ្ញុំបាទទៅតាំងជានាហ្មឺនទីគ្រែក្បា បានសេចក្តីសុខជា
"អង្វែងតមក គ្រានេះលោកលើកទ័ពទៅសម្លាប់យីបើកជាចៅហ្វាយមាន
"គុណលើខ្ញុំ បានជាខ្ញុំចាំចិត្តគិតខឹងនឹងលោក ទំរិះរកចំនងនឹងប្រទូសក៏យ
"លោកឲ្យបាន ប្រយោជន៍នឹងតបស្នងសងគុណយើបើកជាចៅហ្វាយខ្ញុំ
"ដែលលោកចាប់ខ្លួនខ្ញុំបាន ៤ ដងហើយលែងទៅវិញ ខ្ញុំក៏មិនអស់សេចក្តី
"ក្តៅ បានជាលបចូលមកនៅចាំធ្វើអន្តរាយលោកទៀត លោកក៏ចាប់
"បាន ខ្ញុំក៏ដឹងថាទោសខ្ញុំដល់ស្លាប់ហើយ តាមតែលោកនឹងគ្រាស
"មេត្តាចុះ ។ សៀងជូថា យើងនឹងលែងខ្លួនឲ្យរួចទៅវិញវេលានេះ ខ្លួនឯង
"នៅធ្វើយើងទៀតឬទេ ? ។ អ៊ីយៀងថា បើលោកលែងខ្ញុំទៅទៀត ខ្ញុំក៏
"នៅចាំចិត្តនឹងគិតធ្វើលោក គ្រាតែសម្រេចទើបខ្ញុំបាត់ខឹង បើលោក
"អាណិតខ្ញុំ ។ សុំអាវលោកដែលពាក់នៅខ្លួននោះឲ្យគានចុះ ទើបខ្ញុំអស់
"កំហឹងនឹងមិនធ្វើលោកទៀតឡើយ, ។ សៀងជូបានស្តាប់ដូច្នោះ
"ហើយក៏គិតថា អ៊ីយៀងនេះមានសេចក្តីសត្យាកតញ្ញូ កំចង់បាន
"អ៊ីយៀងទុកទើបដោះអាវឲ្យអ៊ីយៀង ។ ក៏គំនាប់ទទួលយកអាវមកហើយ
"ក៏ហូតគ្រប៊ីចេញរួចក៏កាប់អាវនោះដាច់ជា ៣ កំណាត់ ហើយដំរាប
"សៀងជូថា ខ្ញុំបាទបានតបគុណយើបើករួចហើយ, អ៊ីយៀងក៏យក
"គ្រប៊ីនោះ អាវកខ្លួនឯងស្លាប់នៅទីនោះ" ។ ឯចិត្តគួនអ៊ីនោះបើ
អ្នកឯណាមានគុណហើយ ក៏មានកតញ្ញូនឹងអ្នកនោះដូចចិត្តអ៊ីយៀង

ឯឡៅពីនឹងគ្ជនអ្ហ៊ីនោះមិនមែនបងប្អូនបង្កើតនឹងគ្នាក៏មែន តែមានសេចក្តីរាប់អានស្រឡាញ់គ្នាដូចបងប្អូនរួមឧទរជាមួយ ព្រោះបានស្បថស្បាន់នឹងគ្នា គ្រានេះឡៅពីក៏នៅជាអ្នកតូចចិញ្ចឹមគ្ជនអ្ហ៊ីមិនពេញខ្នាត គ្ជនអ្ហ៊ីក៏នៅមានកតញ្ញូនឹងឡៅពី បានជាជាប់ចិត្តដិតដោយមិនបានបោះបង់ចោល ដូចយ៉ាងមហាឧបរាជមានរាសនាជាជាងឡៅពីជាប្រើន បើបានគ្ជនអ្ហ៊ីមកទុកទំនុកបំរុងឲ្យដល់ខ្នាត មុខជាគ្ជនអ្ហ៊ីនឹងមានចិត្តកតញ្ញូដល់លោកជាប្រើនឡើងទៀត" ។

ចូធូនិយាយនឹងតៀវលៀវថា ដែលអ្នកនាំសេចក្តីមកប្រៀបធៀបដូច្នេះត្រូវណាស់ ចូរអ្នកស្រួតប្រញាប់ទៅប្រាប់គ្ជនអ្ហ៊ីចុះ ថាដែលសុំប្តេជ្ញាសេចក្តីទាំង ៣ ប្រការនោះយើងព្រមតាមហើយ អ្នកចូរនាំយកខ្ជូនគ្ជនអ្ហ៊ីចុះមកជួបនឹងយើងជាប្រញាប់ ។ តៀវលៀវក៏លាចូធូឡើងទៅប្រាប់គ្ជនអ្ហ៊ីៗ គ្ជនអ្ហ៊ីឆ្ជើយថា បើមហាឧបរាជយល់ព្រមដូច្នោះហើយ អ្នកចូរវិលទៅប្រាប់ឲ្យកងទ័ពដែលឡោមព័ទ្ធយើងទុកនោះ ឲ្យថយទៅវិញឲ្យអស់ យើងនឹងចុះទៅឲ្យដំណឹងបងវិថ្ជយើងទាំង ៦ នាក់សិន បើមិនមានសេចក្តីអន្តរាយទេ សិមចូលទៅគំនាប់មហាឧបរាជជាក្រាយ ។ តៀវលៀវក៏ចុះទៅជំរាបចូធូតាមសំដីគ្ជនអ្ហ៊ី ។ ចូធូបានស្តាប់ដូច្នោះក៏ប្រើបំរើសេះទៅបង្គាប់ទាហានដែលឡោមព័ទ្ធគ្ជនអ្ហ៊ីនោះឲ្យលើកកងទ័ពថយមកវិញ ។

(មានត)

ដំណឹងតាមខ្សែក្នុងកន្លែង:

លោក ផេង-ជ្រើរ សង្គ្រោះបង្ហូរឈាមសាលាគរុជ្ជាភ្នំពេញ

ប្រែពីភាសាចាក់ឌីមកជាភាសាខ្មែរ

(តមក)

លុះពេលមកដល់ គេឮស្រែកសន្ធឹកស្បែកដើងទឹងគ្រឿងអាវុធនាគ្រាលថ្ងៃមកក្នុងផ្ទះរបស់លោកតាអៃយ៉ាដ ចំណែកនៅក្បែរបងពួកចាហានប្រចាំការក្នុងក្រុងតាសិ-តាវចូលី ដិះសុទ្ធតែសេះមកគំនាប់ចៅហ្វាយថ្មីដោយចាញ់តាំក្លើងជារឿនណាត់ ។

អ្នកបំរើម្នាក់មកជូនដំណឹងលោកតាកាអ៊ីដ ដែលចេញពីភូមិដើម្បីស្នឹងស្មាធ៌ដំរេះចិត្ត ខ្លាងគ្រោយថ្ងៃសៅហ្មងកន្ទុងទៅថា:

– នាយចាហានតួរគឺមកច្រើនណាស់ ។

លោកតាអៃយ៉ាដឲ្យសញ្ញាដល់កូនចាំងពីរ រួចទើបជនចាំងបីនាក់នាំគ្នាដើរទៅទួលលោកមួហាម្មេតណាប៊ីប៊ី ។ លោកនេះមានអនុសេនីយ៍ឯកម្នាក់អនុសេនីយ៍ទោពីរនាក់ អនុសេនីយ៍តូចបីនាក់ជូនមកផង ។

លោកមានចំណងសំដែងការអ៊ុកធឹក ដ៏សមគួរចំពោះយោបល់របស់លោក ដ្បិតក្នុងក្រចាជ្រលោក គឺជាការស្ទុះស្ទួលដើម្បីបញ្ជូនកូនប្រុសច្បង នៃលោកតាកាអ៊ីដទៅកាន់សេចក្តីស្លាប់ ។

លោកវរសេនីយ៍តូចមាំងបីរូបនាំគ្នាចូលទៅកាន់សាលកិត្តិយស។ នៅខាងក្រៅ ពួកចាហានចាញ់តាំក្លើងបន្តឥតឈប់ ។ លោកវរសេនីយ៍តូចនិយាយដោយសំដីយ៉ាងខ្លាំង ហើយបែរចំពោះមកកាមុក្តារថា:

– គឺក្រុមគាហានប្រចាំការនាកាសិ ការាបូលីបាញ់កាំភ្លើងគំនាប់ឯង ។

មុក្ការសួរថា:

– រឿងនេះដូចម្តេច? តើមាន...

– ប្រាកដមែន មុក្ការបេន-អៃយ៉ាដ! ពួកគាហានគាំងនោះ បញ្ចោញមតិយកឯងជានាយរបស់គេ អញគាំងឯងជាមេតម្លួតទ័ពចំនួសរស្សីមបេន-អាប់ជាឲ្យ:ដែលអាក្សត់សម្ងាប់ពីថ្ងៃមុន ។ រួចឈប់ជកដង្ហើមឲ្យស្រួល ទើបលោកវរសេនីយ៍ត្រីចាប់ជាវតម្លួត ដែលនាយគាហានហុចមកឲ្យប្រគល់ចំពោះអ្នកកំឡោះជាកូនលោកតាកាអ៊ីដអៃយ៉ាដ ហើយស្រែកដោយសំឡេងរំពងអស្ចារ្យថា:

– លោកអនុសេនីយ៍គោ មុក្ការបេន-អៃយ៉ាដលោកត្រូវអញ្ជើញ ទៅកាន់កងទ័ពវេលាព្រឹកស្អែកជាកុំខាន ។

រួចលោកបែរមករកអ៊ីស្មាអ៊ីល ហើយប្រាប់ថា:

– ចំណែកឯណេះ អនុសេនីយ៍ឯក អ៊ីស្មាអ៊ីល-បេន-អៃយ៉ាដ លោកត្រូវនាំកងទ័ពអូដ្ឋទៅបន្ទាយមួយឈ្មោះកស្សាម៉ុត ។

លោកវរសេនីយ៍ត្រីគំនាប់លោកតាអៃយ៉ាដតាមរបៀបគាហាន រួចក៏ជំរាបលាទៅកាន់បន្ទាយមួយអន្ទើនឹងនាយគាហានវិញ ចំណែកកាំភ្លើងមិនគាន់ឈប់បាញ់នៅឡើយ ។

ខណ នោះ កាលលោកតាអៃយ៉ាដ នៅតែឯងជាមួយនឹងបុត្រគាំងពីរដែលជោគវាសនាអាក្រក់ ធក់កន្ត្រាក់ចេញពីដើមទ្រូង លោកមានមុខជ្រប់ស្រពោនរកថាអ៊ីមិនកើត ។ លោកនឹកឃើញថាខ្ជួនលោក

ជាបុគ្គលឯកោ អនាថាអស់សង្ឃឹមលើបុត្រសំឡាញ់ពាំងពីរដែលបំរុងនឹងផ្ញើដើមគំនិតនឹងជីវិតពាំងមូល សេចក្តីទុក្ខគ្មានទីបំផុតរុករានទន្ទ្រានដួងព្រលឹងរបស់លោក ។ លោកត្រៀបលើស្មានៃអ៊ីស្មាអ៊ីល រួចពាញមុក្ការមកឧបនាដើមទ្រូងហើយតាំងបង្ហូរទឹកភ្នែកដោយស្ងៀមស្ងាត់ ។ ក្នុងផ្ទះដែលធ្លាប់ជាទីអាស្រ័យនៅដោយសិរីសួស្តី ឥឡូវស្រមោលនៃសេចក្តីទុក្ខចាំងចូលមកហើយ ។

វគ្គទី ៨

បន្ទាយកស្សាម៉ុត

កងពាហានអ៊ីស្មាអ៊ីលផ្ទើជំណើរចេញពៅក្នុងវេលាយប់ ។

អ៊ីស្មាអ៊ីលចេញពៅពាំងទុក្ខធំគេដូចជារសេះរសោះខ្ជូនប្រាណដោយទុក្ខវេទនាខ្ចាំងក្រៃពេក គេរកតែកម្ចាំងនឹងពៅចួបគូស្នេហាមិនកើត ។

ឧ! គួរឲ្យរហែកដើមទ្រូងពេកណាស់ នៅក្នុងទីលានក្រាលថ្មកែវកាលសត្វអូដ្ឋ គេរៀបចំចងគ្រឹងប្រជាប់ជាក់កែបរួចហើយ ៗគេនឹងឡើងជិះវេលាណា គេបានព្ទស័ព្ទចម្រៀងរបស់នាងឡើឡាស្រួយស្រែះថា:

– "សេចក្តីស្នេហារបស់ស្ត្រី គឺជាម្ចប់នៃគ្មាតលើរាលឡាច់...

ប្រាកដមែន គឺជាការរយៈថ្ងៃមប្រមាត់ដោយពិត រួចជលនេត្រហៀរហូរមួយរំពេច ប៉ុន្តែគេត្រឡប់សង្កត់ចិត្តពៅវិញ គេមិនត្រូវកាន់តម្រាប់អ្នកទន់ខ្សោយមិនគួរជល់រង្សត្រកូលរបស់គេ ។ កាលដែលសត្វអូដ្ឋចេញដើរត្រើកៗពៅ គ្មានអារម្មណ៍អ៊ីដ៏ធំមកសំដែងឲ្យឃើញក្នុងដួង

វិញ្ញាណ ក្រៅពីធម្មជាតិមួយដ៏អស្ចារ្យគឺឡឺឡាឡើយ ។ ម្ល៉ោះហើយ ចិត្តខុសគាត់របស់គេក៏ត្រឡប់លិចចុះទៅក្នុងសេចក្តីអន់ខ្សោយវិញ ។

ត្រូវចេះស្រឡាញ់ដើម្បីឲ្យជឿជាក់ថា ការបាត់មុខបែបយ៉ាងណាៗ ។

ខ្ញុំមានអ្នកខ្លះត្រៃលែ ចូលចិត្តថាការបែកចេញពីគ្នាជាចំណុចយ៉ាងប្រសើរដល់សេចក្តីស្នេហា ហើយថាគេមិនសូវឃើញគ្នា គេតែស្រឡាញ់គ្នាណាស់ ។ បើគេប្រទះម្តង ទើបគេនឹងដឹងថា ... ។

មានស្រីជាច្រើន លុះបានគ្នាភ្លាម តាមសេចក្តីខាងលើ ទៅឯខាងផ្លុះផ្តុកម្តាយជុំបីថ្ងៃ ស្រាប់តែសេចក្តីស្នេហាយ៉ាងប្រសើរទៅឯណាបាត់អស់រកមិនឃើញ ។

មានប្តីជាច្រើន គិតតែត្រៀមខ្លួនទៅកងត្រៀមការហូបក្នុងពួកបាបមិត្តដែលគិតតែក្សត់ចិត្តគ្នាឯង បានទៅចួបនឹងប្រពន្ធដោយពេលដោយខណៈ ហើយមិនបានរួមសមគ្គីសង្វាសដោយញឹកញាប់ នុប្រសិទ្ធិ៍តិចសត់ ។ ការបាត់មុខជាទុក្ខកំណាចជាងទុក្ខទាំងពួង ។ ពាក្យទំនៀមរបស់ភរិយាលិតនេះ ត្រូវជានិច្ច ប៉ុន្តែចំពោះបុគ្គលណាដែលស្រឡាញ់គ្នាទៅវិញទៅមក ។

អ៊ីស្មាអ៊ីល មិនយូរប៉ុន្មាន ក៏ជ្រាបថាកសេចក្តីសោកស្រណោះព្រោះការលំបាកតាមផ្លូវនឹងសេចក្តីខ្សឹយហត់ក្នុងដំណើរ តែងតែគាញចិត្តគេឲ្យប្រែងប្រយ័ត្នជានិច្ច ។

(មានត)

រឿងបល្ស័ង្ឆគិព្យ សាមសិបពីររឿង

រឿងព្រេងតណ្ឌៀ

លោកសមិន ម្ចាត្យ៉ងជម: តែង

លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

និទានដៃរូបទេពនិម្មិតទី ១១

មានមួយថ្ងៃ, ព្រះបាទកោជ: ទ្រង់មានព្រះរាជបំណងចង់ធ្វើបុណ្យរាជាភិសេក ទ្រង់ស្តេចចូលទៅជិតបល្ស័ង្ឆគិព្យដើម្បីនឹងគង់ ។ ក្នុងខណ:នោះ រូបទេពនិម្មិតទី ១១ ក្រាបបង្គំទូលថា "បពិតព្រះបាទកោជ: សូមទ្រង់ព្រះសណ្ឋាប់ ស្តេចអង្គណាដែលនឹងគង់នៅលើបល្ស័ង្ឆគិព្យនេះបាន លុះត្រាតែស្តេចអង្គនោះមានកិត្តិនាមដូចព្រះបាទវិក្រមាទិត្យ ។ ព្រះបាទកោជ: ទ្រង់មានព្រះបន្ទូលសួរទៅរូបទេពនិម្មិតថា: "តើកិត្តិនាមព្រះបាទវិក្រមាទិត្យនោះ យ៉ាងណាទៅ?" ។ រូបទេពនិម្មិតក៏ក្រាបបង្គំទូលថា:

នៅក្នុងរដ្ឋព្រះបាទវិក្រមាទិត្យ មានមន្ត្រីធំម្នាក់នាម ភទ្រសេន (Bhadrasena) ដែលអនិច្ចកម្មក្រោយបានប្រមូលនូវកោតទ្រព្យមករក្សាទុកជាប្រើន ។ លោកមានបុត្រម្នាក់ឈ្មោះ បុរន្ទរ: (Purandara) បុត្រនេះបានចាយទ្រព្យសម្បត្តិនោះអស់ត្មានសល់ ។ ពួកអ្នកនៅជិតខាងមិនបានឃាត់ហាមបុត្រាលោកនោះ ថាកុំឲ្យចាយទ្រព្យសម្បត្តិ

បែបនេះសោះឡើយ ។ មានកល្យាណមិត្តនៃបិតាបុត្រានោះម្នាក់ បានមកជួបនឹងបុរន្ទរ:ហើយពោលថា: "ឧបុត្រានៃមិត្តខ្ញុំ សម្បត្តិទ្រព្យដែលមិត្តខ្ញុំបានរក្សាទុក ដោយសេចក្តីព្យាយាមផ្សង ៗ សម្បត្តិទ្រព្យទាំងនេះមិនស្ថិតស្ថេរ (តាមធម្មជាតិរបស់វា) ទេ ឯងយកទ្រព្យសម្បត្តិនេះ ទៅចាយដោយឥតបើគិត ។ កិត្តិយសនៃមនុស្សគឺត្រូវរក្សាទុកនូវទ្រព្យសម្បត្តិនោះ, ព្រះនាងលក្ស្មី (Laxmi) បានទូន្មានប្រៀនប្រដៅតាមសៀវភៅសាស្ត្រ:ថាឲ្យរក្សាទ្រព្យសម្បត្តិ, ព្រះវិស្ណុបានជាត្រូព្រះនាងលក្ស្មីដោយពលភាព ហើយទៅជាមហាវាជពិភពលោក, ព្រះនាងលក្ស្មីបដិសន្ធិកើតពីសមុទ្រ, បានជាសមុទ្រនោះឈ្មោះថារតនាករ (Ratnâkar អណ្ណូងរតន:) ។ គន្ធ៍ព្វកើតពីឈទរព្រះនាងលក្ស្មីដោយហេតុនេះ បានជាគន្ធព្វគោរពព្រះនាងលក្ស្មី ស្មើនឹងព្រះព្រហ្មនឹងអាទិទេពឯទៀត ។ ចូរឯងគិតឲ្យមែនទែន; ត្រូវឯងយល់ថាកិត្តិយសបន្ទិចបន្ទួចនៃមនុស្ស នៅក្រោមបង្គាប់បញ្ជានៃព្រះនាងទេពធីតាលក្ស្មីទាំងអស់ ។ ព្រោះហេតុនេះ ខ្ញុំថាសម្បត្តិទ្រព្យនោះគឺជាព្រះនាងលក្ស្មីនោះឯង, យើងមិនត្រូវចាយទ្រព្យនោះឲ្យហួសហេតុទេ" ។

បុរន្ទរ: បានស្តាប់នូវឧវាទព្រាហ្មណ៍ ក៏ពោលតបទៅវិញថា: "ឧព្រាហ្មណ៍,ចូរអ្នកស្តាប់ខ្ញុំ, អ្វីដែលត្រូវតែមកដល់ ក៏ត្រូវតែមកដល់ដូចទឹកដូង ទោះបីសេចក្តីព្យាយាមឃាត់ខាំងយ៉ាងណាក៏ដោយ ។ ដូចយ៉ាងទ្រព្យសម្បត្តិដែលត្រូវវិនាស, ក៏ត្រូវតែអស់ទៅ ៗ តើទ្រព្យសម្បត្តិនោះអស់ទៅតាមផ្លូវណា? ត្មានអ្នកណាអាចបញ្ជាក់បាន; ដូចត្រាប់ផ្ទៃ (ទ្ធិត)

(Kapitha) ដែលដំរីបរិភោគ ។ បើទុកណាជាគេញ្យាយាមរក្សាទុកនូវ
ទ្រព្យសម្បត្តិនោះយ៉ាងណាក៏សេចក្តីញ្យាយាមនោះឥតប្រយោជន៍" ។

ឬរន្ធរ: ក្រោយដែលមិនព្រមស្តាប់ឧរាទព្រាហ្មណ៍, ក៏តាំងតែ
ចាយទ្រព្យសម្បត្តិនោះតទៅទ្រិតរាល់តែថ្ងៃ ទាល់តែធ្លាក់ខ្លួនក្រលំបាក
ដុនដាប; ត្មានអ្នកណាទៅជិតតាត់, យល់តាត់ថាជាអ្វីឡើយ ។
ឬរន្ធរ: ត្រូវគេប្រមាថមើលងាយគ្រប់ៗត្មា, តាត់ព្រួយលំបាកខ្លាំង ទើប
គិតថា: "ព្រៃដែលខ្លានឹងសត្វសាហាវនៅ, ព្រៃដែលមានតល់ឈើជា
ទីនៅ, មានស្លឹកឈើផ្ទៃឈើជាអាហារ, មានសម្បកសម្រាប់ធ្វើគ្រឿង
ស្លៀកពាក់, មានស្មៅជាគ្រែដេក គឺជាកន្ទែងដែលមនុស្សត្មានភោគ-
ទ្រព្យនៅអាស្រ័យ, មនុស្សបែបនេះនឹងមានជម្ងៃអ្វី បើនៅជិតបងប្អូន
ញាតិមិត្ត ដែលក្រអើតក្រទមដោយមានភោគទ្រព្យ" ។ ដល់គិតយ៉ាង
ដូចនេះ ឬរន្ធរ: ក៏ធ្វើដំណើរទៅកាន់បរទេសទៅ ។

ឬរន្ធរ: កាលត្រាច់ទៅតាមភូមិភាគ ក៏បានទៅដល់ទីក្រុងមួយ
ដែលនៅជិតភ្នំ លាលយ: (Malaya) ហៅថា នគរបិតបុរ: (pitapura)
នៅក្នុងនគរនោះ ពេលយប់គេបានព្ធនូវស្សរសព្ទ នៃស្រីយំស្រែកគ្ឆរ
ឲ្យអាស្សរពន់ពេក ។ ដល់ព្រឹកឡើង ឬរន្ធរ:ក៏ស្សរអ្នកនៅក្នុងក្រុងថា
ពីយប់មិញ ខ្ញុំព្ធស្ត្រីយំស្រែក តើដោយហេតុអ្វី? ។ ពួកអ្នកនៅក្នុង
ភូមិតបថា: "យើងបានព្ធស្ត្រីយំស្រែកដែរ តែយើងមិនដឹងជាហេតុអ្វី
បានជាស្ត្រីនោះស្រែកយំ ។ កាលស្ត្រីនោះយំស្រែករាល់យប់យ៉ាងនេះ,
យើងខ្លាចក្រែងមានគ្រោះថ្នាក់ដល់យើង, យើងក៏ភ័យជានិច្ច" ។

កាលណាបុរនូរៈវិលត្រឡប់មកកាន់ប្រទេសខ្លួនវិញ, ២-៣ ថ្ងៃ
ក្រោយមក ក៏ចូលទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យអំពីរឿងនេះ ។
ព្រះអង្គទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់មានព្រះរាជហ្ស៊ូម៉ង់ជ្រាបនូវរឿ
នេះឲ្យច្បាស់លាស់, ហើយដើម្បីនឹងឲ្យស្គាល់ជាក់លាក់នូវហេតុនៃទុក្ខ
ស្ត្រីនេះ ទ្រង់ក៏ហោះទៅតាមអាកាសដោយព្រះសុពណ្ណាបាទពិសិដ្ឋទៅ
កាន់ទីក្រុងបិតបុរៈ នាំយកបុរនូរៈទៅជាមួយផង ។ ដល់ទ្រង់ស្តេច
យាងទៅដល់ ទ្រង់ក៏ដែរនរកស្ត្រីនេះ ។ ទៅឆ្លាយបន្ទិចពីទីក្រុង, ក្នុ
ងព្រៃធំ, ទ្រង់បានទតទៅឃើញស្ត្រីនោះយំ ។ ក្នុងពេលដែលស្ត្រីនោះ
ដែរកទ្រហោយំ, ទ្រង់ក៏ស្តេចយាងទៅក្នុងព្រៃនោះកាន់ទាំងព្រះទ្យា
ស្តេចយាងឆ្ពោះទៅកាន់ស្ត្រីនោះ ។ ដល់ទ្រង់ស្តេចយាងទៅជិតស្ត្រី,
ទ្រង់បានទតឃើញកសស: មានមុខសម្បើមអស្ចារ្យ, បានកាយស្ត្រី
នោះយ៉ាងខ្ចាំងដោយឥតមេត្តា ។ ព្រះបាទវិក្រមាទិត្យទ្រង់បានទត
ឃើញ, ទ្រង់មានព្រះរាជហ្ស៊ូម៉ង់អាណិតអាសូរដល់ស្ត្រីនោះពន់ពេក,
ក៏មានព្រះរាជឆន្ទារៈទៅកាន់កសសៈថា នៃកសសៈកំណើ ហេតុម្ដេច
ក៏ឯងកាយស្ត្រីឲ្យាយនេះ? តើឯងជាអ្វី? មកនេះ, កាយនឹងអញ,
បើឯងចិត្តគ្រាន់បើ ។ កសស បានស្តាប់នូវព្រះបន្ទូលព្រះមហាក្សត្រិយ์
ក៏ទ្រឹងជាខ្ចាំង ហើយស្ទុះចេញមកច្បាំងនឹងទ្រង់ ។ ដល់ទ្រង់តយុទ្ធ
នឹងកសសមួយស្រៃបក់, ទ្រង់ក៏កាត់ក្បាលកសសៈនឹងព្រះខ័ន្ធាធ
បាន ។ ក្នុងមួយរំពេច, ស្ត្រីនោះសប្បាយចិត្តជូចជាស្ងាប់ហើយមានជីវិត
រស់ឡើងវិញ ក៏ចូលទៅជិតទ្រង់ធ្វើអញ្ជលិកម្មហើយសរសើរទ្រង់ថា:

"បពិត្រមហារាជ, ដែលព្រះអង្គទ្រង់ពិយាតរាសសៈនេះ, ដោយ
សម្ងាប់ពស់, ដូចជាត្រុឌ ដែលសំដែងសេចក្តីល្អ ព្រះអង្គឈ្នោះថា
ជាន ព្រះរាជទានន្ធវជីវិតឲ្យដល់ខ្ញុំម្ចាស់ ។ តើខ្ញុំម្ចាស់នឹងធ្វើអ្វីដើម្បីតបស្នង
ន្ធវព្រះតេជៈព្រះគុណ ព្រះអង្គ? ខ្ញុំម្ចាស់គ្មានកូនប្រុស, គ្មានកូនស្រីទេ ។
បើខ្ញុំម្ចាស់មានកូនប្រុសស្រី ខ្ញុំម្ចាស់នឹងថ្វាយ ព្រះអង្គជាខ្ញុំបម្រើ ព្រះជាទា
ព្រះអង្គ" ។ ក្រោយដែលជាន ក្រាបបង្គំទូលថ្វាយខ្ជូនចំពោះ ព្រះអង្គ,
ស្ត្រីនោះក៏ ក្រាបជិត ព្រះជាទា ព្រះអង្គ ។ ដល់នាងក្រោកឡើង, នាង
ក្រាបបង្គំទូលទ្រង់ថា: "តាំងពីថ្ងៃនេះទៅ, សូម ព្រះអង្គទុកខ្ញុំម្ចាស់ជា
ទាសីរបស់ ព្រះអង្គ, ខ្ញុំម្ចាស់មានថ្ងៃមាសជ្រាំបួនរយ, ខាងក្នុងថ្ងៃនោះ
ពេញទៅដោយដុំមាស, សូម ព្រះអង្គទុកសម្បត្តិនេះជា ព្រះរាជទ្រព្យ
របស់ ព្រះអង្គ" ។ ព្រះជាទវិក្រមាទិត្យ ទ្រង់ ព្រះសណ្តាប់ន្ធវរាចាចុះ
ចូលបេស់ស្ត្រី, ទ្រង់ ព្រមទទួលន្ធវសម្បត្តិទាំងនេះ តែ ទ្រង់ជាន ប្រគល់
ឲ្យដល់ ស្ត្រីនឹងបុរន្ធរៈនោះវិញ ។ ដល់ ទ្រង់ជានចាត់ចែងបុរន្ធរៈឲ្យជាន
ន្ធវស្ថានភាពបែបនេះ, ទ្រង់ក៏ហោះទៅលើអាកាសដោយ ព្រះសុពណ៌
ជាទពិសិដ្ឋ រីលត្រឡប់មកកាន់ ព្រះរាជនិវេសនដ្ឋានវិញ ។

រូបទេពនិម្មិតទី ១១ កាលជាន ក្រាបបង្គំទូលព្រះជាទភោជៈន្ធវនិទាន
នេះ រួចទូលថា: "បពិត្រ ព្រះជាទភោជៈ ទ្រង់ជាន ជ្រាបន្ធវសប្បុរិសធម៌
នៃ ព្រះជាទវិក្រមាទិត្យហើយ បើ ទ្រង់មានសប្បុរសបែបនេះ, ទើប
ទ្រង់អាចនឹងគង់លើបល្ងង្គទិព្យនេះជាន ។ ព្រះមហាក្សត្រភោជៈ

ដល់ទ្រង់ព្រះសណ្តាប់នូវភាពនៃរូបទេពនិម្មិត ទ្រង់ក៏ចោះបង់មិនបាន ធ្វើពិធីរាជាភិសេកក្នុងថ្ងៃនេះ ។

និទានរឿងរូបទេពនិម្មិតទី ១២

មានកាលមួយថ្ងៃ ព្រះមហាក្សត្រិយ៍កោរព្យទ្រង់ស្តេចយាងចូលទៅជិតបល្ល័ង្កទិព្យដើម្បីនឹងធ្វើរាជាភិសេក ។ រូបទេពនិម្មិតទី ១២ ពោលថា "នុព្រះបាទកោរព្យ: បើទ្រង់មានព្រះរាជបំណង នឹងគង់លើបល្ល័ង្កទិព្យនេះ, ត្រូវទ្រង់មានព្រះរាជហ្ឫទ័យទូលាយស្មើនឹងព្រះបាទវិក្រមាទិត្យ" ។ ព្រះបាទកោរព្យ:តបថា "តើព្រះបាទវិក្រមាទិត្យទ្រង់មានសប្បុរិសធម៌យ៉ាងណាខ្លះ?" ។ រូបទេពនិម្មិតក្រាបបង្គំទូលថា: "សូមព្រះបាទកោរព្យ: ទ្រង់ព្រះសណ្តាប់ ។

មានកាលមួយថ្ងៃ ព្រះបាទវិក្រមាទិត្យ ទ្រង់ស្តេចហោះទៅលើអាកាសដោយព្រះសុពណ៌បាទពិសិដ្ឋ ទ្រង់យាងតបទេសជាច្រើន ។ ទ្រង់យាងទៅដល់កន្លែងមួយ, ទ្រង់ទតឃើញនូវមាត់ទន្លេ មិនឆ្ងាយពីទន្លេនោះប៉ុន្មាន មានព្រះវិហារព្រះអាទិត្យមួយ, ឃើញពួកព្រាហ្មណ៍បណ្ឌិតអង្គុយសន្ទនាគ្នាទៅវិញទៅមកអំពីសាស្ត្រ: ។ ព្រះបាទវិក្រមាទិត្យទ្រង់យាងចូតចូលទៅជិត ដើម្បីនឹងទ្រង់សណ្តាប់ នូវការសន្ទនានេះ ។

ក្នុងពេលដែលបណ្ឌិតទាំងនោះ សន្ទនាគ្នាទៅវិញទៅមក, បណ្ឌិតម្នាក់ៗ ខំព្យាយាមតាំងយោបល់តែរៀងខ្លួន, ហើយញែកអត្ថបទនីមួយៗដើម្បីនឹងបំបាត់នូវពាក្យពិតនៃសាស្ត្រទាំងនោះ ។ ព្រះមហាក្សត្រិយ៍ដល់ទ្រង់ផ្ទៀងនូវព្រះស្រោតស្តាប់នូវការបុច្ឆា - វិសជ្ជនា ទ្រង់ក៏មាន

ព្រះបន្ទូលថា "ឧបណ្ឌិត, ចូរលោកស្តាប់ខ្ញុំ. ការស្វែងរកន័យឲ្យជាក់លាក់នៃសាស្ត្រ: គឺជាគោលការណ៍នៃបណ្ឌិត, បើកាលណាគេចោះបង់ចោលនូវន័យដ៏ពិតប្រាកដនៃសាស្ត្រ ហើយគេខំព្យាយាមស្ថាបនានូវយោបល់របស់ខ្លួនថាត្រូវថាមែនទៅវិញ ផ្ទើបែបនេះគេមិនទុកលោកថាជាបណ្ឌិតទេ ។ អ្នកណាជាបណ្ឌិតពោលនូវពាក្យមិនពិត ដើម្បីឲ្យគេជឿនូវយោបល់របស់ខ្លួន ហើយលះបង់ចោលន័យដ៏ពិតប្រាកដនៃសាស្ត្រ: អ្នកនោះឯងវង្វេងលែងរកអ្ទិយើញ ហើយនាំឲ្យបាត់បង់ថយចំនួននូវសាវ៉ក ដែលអង្គុយជុំវិញខ្លួនថែមទៀត" ។ ពួកបណ្ឌិតលុះបានស្តាប់ព្រះបន្ទូលមហារាជ ក៏គិតរៀងខ្លួនថា: "បណ្ឌិតគឺអ្នកណាដែលមានសមត្ថភាពញែកឲ្យច្បាស់លាស់នូវន័យពិតនឹងមិនពិតនៃសាស្ត្រ: ឯន័យមិនពិតដែលយើងពោល គឺអ្នកនេះយល់ជាក់ច្បាស់, ព្រោះហេតុនេះ យើងគួរទុកថាអ្នកនេះជាបណ្ឌិតទីមួយ ។ ដល់គិតយ៉ាងនេះហើយ, ពួកបណ្ឌិតទាំងអស់ក៏អៀនខ្មាសលែងផ្ទើបុច្ឆា វិសជ្ជនាគ្នាទៅវិញទៅមក ។

ក្នុងពេលនោះ, មានបុរសម្នាក់ មានរូបធោមល្អពន់ពេក, លុះមកដល់មាត់ទន្ទេ, បុរសនោះជិតនឹងមរណៈទៅហើយ ។ បុរសនោះកដ្ឋ៏លក្រាបទៅលើដី, ពោលទៅរកអ្នកទាំងអស់ដែលនៅជិតនោះថា: "ចូរអ្នកអញ្ជើញមកធាប់, លោកអ្នកឃើញទេ, តើខ្ញុំយ៉ាងណាក្នុងពេលនេះ? ។ តែបើទុកជាបុរសនោះស្រែកហៅយ៉ាងណា, ក៏គ្មានបុគ្គលណាមួយចូលទៅជិតសោះឡើយ ។

ព្រះបាទវិក្រមាទិត្យទ្រង់ទតឃើញយ៉ាងនេះ, ទ្រង់មានព្រះរាជហ្ហ-

ទ័យអាណិតអាសូរដល់បុរសនោះពន់ពេក; ទ្រង់ក៏យ៉ាងចូលទៅជិតបុរស
ហើយទ្រង់ថែទាំរក្សាបីបាច់ដូចជាព្រះញាតិរបស់ព្រះអង្ត ។ បុរសនោះ
ត្រេកអរពន់ពេក ហើយក្រាបបង្គំទូលព្រះនរបតីថា "បពិត្រលោកជា
សប្ឋុរស, លោកជាញាតិសាលោហិតរបស់ខ្ញុំ (ប្រហែលបុរសនោះមិន
ដឹងថា បុរសដែលថែទាំនេះជាព្រះបាទវិក្រមាទិត្យទេ); ព្រោះថាជន
ដែលជាញាតិពិត គឺអ្នកដែលមកជួយស្រោចស្រង់ក្នុងពេលដែលខ្ញុំកំពុង
មានទុក្ខលំបាក ។ ព្រោះហេតុនេះ ក្នុងគេហដ្ឋានខ្ញុំ មានទិព្វភណ្ឌៈមួយ
ឈ្មោះមូលិកា, ទិព្វភណ្ឌៈនោះខ្ញុំជូនលោក, ចូរលោកយកទៅ, របស់នេះ
បើអ្នកប្រាថ្នាចង់បានអ្វី ។ នឹងបានដូចបំណងភ្លាម ។" ។ លុះពោលពាក្យ
យ៉ាងនេះហើយ បុរសនោះក៏ថ្វាយទិព្វភណ្ឌៈនោះទៅមហារាជ, រួច
អនិច្ចកម្មក្នុងពេលនោះទៅ ។ ក្នុងមួយរំពេចនោះស្រាប់តែមានស្ទូមម្នាក់
ចូលទៅជិតព្រះនរបតី ហើយសូមមូលិកានោះថា "បពិត្រមហារាជ,
ព្រះអង្គទ្រង់ជ្ញាប់ជាអ្នកព្រះរាជទានន្ធូរអំណោយគ្រប់យ៉ាងអ្នកដល់ទុរគត;
ទូលព្រះបង្គំសូមព្រះអង្ត ព្រះរាជទានន្ធូរអំណោយអ្វីមួយ ដែលជា
ហេតុឲ្យផុតពីសេចក្តីក្រលំបាក ។ កាលស្ទូមនោះក្រាបបង្គំទូលសូម
ព្រះភូមិន្ទយ៉ាងនេះហើយ ព្រះរាជាទ្រង់ក៏ព្រះរាជទានមូលិកានោះដល់
ស្ទូមនោះទៅ, រួចទ្រង់ហោះទៅតាមអាកាសដោយព្រះសុពណិបាទ
ពិសិដ្ឋ វិលត្រឡប់ទៅកាន់ព្រះរាជធានីវិញ ។

រូបទេពនិម្មិតទី ១២ ក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា "បពិត្រ
ព្រះមហាក្សត្រិយ៍កោជ: "បើព្រះអង្គទ្រង់មានព្រះទ័យសប្ឋុរសទូលាយ

បែបនេះទើបទ្រង់អាចគង់លើបល្ល័ង្ក៧ទិព្វនេះបាន" ។ ព្រះបាទភោជ:
ទ្រង់ព្រះសណ្ឋាប់នូវវាចារូបទេពនិម្មិត ក៏លះបង់នូវពិធីបុណ្យមុទ្ធាភិសេក
ក្នុងពេលនោះទៅ ។

*

* *

(មានត)

មានទ្រព្យរាប់ជាមានស្នេហ៍មុខ

៦— វិជ្ជា ទាន, សិល្សសាស្ត្រ នឹងសេចក្តីក្លៀវក្លាហាននៃ
អ្នកមានទ្រព្យ អ្វីមួយដែលអ្នកក្រីក្រទាំងឡាយមិនសរសើរ?
សេចក្តីពិត, ក្នុងលោកនេះ អ្នកមានទ្រព្យ សូម្បីអ្នកកន្ទ្រៀត
ក៏ក្លាយមកជាញាតិមិត្ត ឯអ្នកក្រីក្រ សូម្បីញាតិមិត្តខ្លួនឯង
ពិតៗ ក៏ជិតប្រែក្លាយទៅជាសត្រូវវិញ (មិនមានហេតុអ្វី)
ក្រៅពីការខ្សត់ទ្រព្យទេ ។

ធម្មសន្ទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែវិប្ជិកា លេខ ១១

ព.ស.២៤៩៣ – គ.ស.១៩៥៥



ភន្តមុសនិយា

ទស្សនាវដ្ដី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា — *ទំព័រ*

— យរាវាសធម៌ ..... ព្រះបាឡាត់ឧត្តមលិទិត សុង-ស៊ីរ. ... ៨០៣

— ប្រស្នាធម៌ ..... យុនបណ្ណានុវ៍ក្ស ប៊ូ-ប៊ូ ៨១៩

— បញ្ញាសជាតក ភាគទី ៤ (តមក) .... បណ្ឌិតមហា ឈឹម -ស៊ីម ៨២៦

ផ្នែកអក្សរសាស្ត្រ

— ទំនៀមហុបស្ថាម៉ាត់ ..... អ្នកស្រី សារីយ៉ាន់ ៨៣៥

— រឿងសាមកុក (តមក) ..... ឧកញ៉ា ន្ទ- កន ៨៤១

— រឿងបល្ស៍ង្កទិព្យ (តមក) ..... លោក វ៉ាយ- ប៊ុក ៨៤៩

កំណត់នឹងប្រវត្តិការណ៍

— មហាធជ្ជសង្គាយនានៃព្រះពុទ្ធសាសនា .. លោក ញ៉ែម -ទឹម ៨៥៨

— ពិធីបុណ្យពុទ្ធាជយន្តិនៅប្រទេសតំណ្ឌៀ . លោក ទៀង - តៃ - ឈុន ៨៧៥

— បញ្ជីរាយនាមបៅអធិការដែលតាំងថ្មី(តមក) ក្រសួងធម្មការ ៨៧៩

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Gharavasadharma	*Vén. SONG-SIV*	751
— Prasnadharma	*M. BOU-PO*	
— Pannasajataka-vol. 4 (suite.) .	*M. CHHIM-SOUM*	

PARTIE LITTERAIRE:

— Coutume de chique de bétel dans le mariage	*Mme SRIN-SARIS-YANN* .	
— Histoire de SAMKOK (suite). .	*Oknha NOU-KAN*	782
— Les trente deux récits du TRONE (suite)	*M. RAY-BUC*	792

NOTES ET CHRONIQUES:

— Sixième Concile Bouddhique .	*M. NHEM-KHEM*	769
— Cérémonie " BUDDHA JAYANTI" en Inde	*M. TIANG-TAY-CHHUN* .	723
— Nomination des nouveaux chau Adhikars (suite)	*Ministère des Cultes*	734

Prix d'abonnement annuel (comprenant 12 numéros) 210$00

ផ្នែកសាសនា

យភាសធម៌

ព្រះបាឡាត់ឧត្តមលិទិត សុង-ស៊ីវ រត្តលង្ការ

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការ ចំពោះព្រះកគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះសង្ឃដោយគោរព) ។

រៀលានេះអាត្មាភាពសូមសំដែងនូវពុទ្ធកាសិតមួយកន្ទែង ដែលមាននៅក្នុងគម្ពីរ សំយុត្តនិកាយ សគាថវគ្គ ជាធម្មស្សវនាការ ដូចតទៅនេះ:

ពុទ្ធកាសិតនោះព្រះបរមគ្រូសម្មាសម្ពុទ្ធ ទ្រង់សំដែងចំពោះនឹងអាឡវកយក្សថា:

យស្សេតេ ចតុរោ ធម្មា សទ្ធស្ស
យរមេសិនោ សច្ចំ ទមោ ឋិតិ ចាគោ
ស វេ បេច្ច ន សោចតិ ។

"បុគ្គលដែលមានសទ្ធាគ្រប់គ្រងផ្ទះ ត្រូវមានធម៌ ៤ ប្រការនេះ គឺ សច្ចៈ (ពាក្យពិត) ១, ទមៈ (ការទូន្មាន) ១, ឋិតិ (សេចក្តីអត់ធន់) ១, ចាគៈ (ការបរិច្ចាគ) ១, រមែងមិនសោយសោកក្នុងលោកខាងមុខដោយពិត" ។

ទី ១ _ សច្ចៈ = សេចក្តីពិត គឺ មិននិយាយបំផ្ទើសឲ្យលើស ឬឲ្យថយចុះពីសការៈពិត បើយើញថាយើញ, ឧសថាឧស, ត្រូវថាត្រូវ

ដូច្នេះជាដើមហៅថា សច្ចៈ សេចក្តីពិត; ចើសំដែងដោយទ្រឹដ្ឋបានដល់អរិយសច្ចទាំង ៤ ។ ពាក្យថាអរិយសច្ច នេះ ប្រែថា "សេចក្តីពិត្ររបស់អរិយបុគ្គល, សេចក្តីពិតឥតល្អៀង មាន ៤ យ៉ាង គឺ ទុក្ខៈ សេចក្តីព្រួយលំបាក; សមុទយៈ កំណើតទុក្ខ ឬហេតុដែយនាំឲ្យកើតទុក្ខ; និរោធៈ សេចក្តីរលត់ទុក្ខ ឬ ធមិសម្រាប់រំលត់ទុក្ខ; មគ្គ ផ្លូវ ឬ ឧបាយនៃសេចក្តីរលត់ទុក្ខ; ទាំង ៤ យ៉ាងនេះជាសច្ចពិតឥតមានល្អៀង នឹងប្រែរថាជាមិនពិតទៅវិញពុំបានឡើយ ។

ក៏សច្ចធមិនេះ ព្រះសម្ចាសម្ពុទ្ធទ្រង់សំដែងដោយពិស្តារមាននៅក្នុងគម្ពីរ មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ ត្រង់ចង្ក៊ីសូត្រ, ក្នុងសូត្រនោះមានសេចក្តីដំណាលថាៈ មានមាណពម្នាក់ ឈ្មោះកាបទិកៈ មានក្សាលកោរ មានអាយុ ១៦ ឆ្នាំ ពីកំណើត ចេះបប់ត្រៃវេទ្រពមទាំងគម្ពីរយណ្ឌុនឹងគម្ពីរកេដុកៈ ព្រមទាំងអក្ខរប្យកេទ គឺសិក្ខានឹងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកស្គាល់នូវបទនឹងវេយ្យាករណ៍ ជាអ្នកមិនអូនថយគឺស្ទាត់ដំនាញក្នុងលោកាយតសាស្ត្រ នឹងមហាបុរិសលក្ខណ-ព្យាករណសាស្ត្រ បានស្ទារកធមិដែលនាំឲ្យកើតសច្ចៈ ចំពោះព្រះមានព្រះភាគ ។ ទ្រង់ផ្លើយតបថាៈ ម្នាលមាណព សច្ចៈគឺសេចក្តីពិតត្រង់ កើតឡើងដោយអាស្រ័យសេចក្តីព្យាយាម ។ កើតឡើងដោយអាស្រ័យការប្រឹងប្រែង ។ កើតឡើងដោយអាស្រ័យឆន្ទៈសេចក្តីពេញចិត្ត ។ កើតឡើងដោយអាស្រ័យសេចក្តីចូលចិត្តធមិក្នុងតំនិត ។ កើតឡើងដោយការពិចារណានូវអត្ត ។ កើតឡើងដោយការចេះចាំនូវធមិ ។ កើតឡើងដោយ

អាស្រ័យការស្តាប់ធម៌ ។ កើតឡើងដោយការផ្ចង់ត្រចៀកប្រុងស្តាប់ ។ កើតឡើងដោយការចូលទៅអង្គុយជិត ។ កើតឡើងដោយអាស្រ័យការចូលទៅរក ។ កើតឡើងដោយអាស្រ័យសទ្ធាសេចក្តីជឿ ; បើបុគ្គលណាគ្មានសទ្ធាហើយ ការចូលទៅរកក៏មិនមាន, បើការចូលទៅរកមិនមានហើយ ការចូលទៅអង្គុយជិតក៏មិនមាន, បើការចូលទៅអង្គុយជិតមិនមានហើយ ការផ្ចង់ត្រចៀកប្រុងស្តាប់ក៏មិនមាន, បើការផ្ចង់ត្រចៀកប្រុងស្តាប់មិនមានហើយ ការស្តាប់ធម៌ក៏មិនមាន, បើការស្តាប់ធម៌មិនមានហើយ ការចេះចាំនូវធម៌ក៏មិនមាន, បើការចេះចាំនូវធម៌មិនមានហើយ ការពិចារណានូវអត្ថក៏មិនមាន, បើការពិចារណានូវអត្ថមិនមានហើយ សេចក្តីប្តូលចិត្តធម៌កង៏គំនិតក៏មិនមាន, សេចក្តីប្តូលចិត្តធម៌កង៏គំនិតមិនមានហើយ ឆន្ទៈសេចក្តីពេញចិត្តក៏មិនមាន, បើឆន្ទៈ សេចក្តីពេញចិត្តមិនមានហើយការប្រឹងប្រែងក៏មិនមាន, បើការប្រឹងប្រែងមិនមានហើយ ការពិចារណាក៏មិនមាន, បើការពិចារណាមិនមានហើយ សេចក្តីព្យាយាមក៏មិនមាន បើសេចក្តីព្យាយាមមិនមានហើយ សច្ចៈសេចក្តីពិតត្រង់ក៏មិនមាន ។

បើសច្ចៈសេចក្តីពិតត្រង់មិនមានហើយ, បុគ្គលនោះលែងស្គាល់ទុស្សត្រូវ គុណ, ទោស, បុណ្យបាប, តែងតែលុះទៅកង៏អំណាចនៃលោភៈទោសៈ, មោហៈ; ការណ៍ដែលមិនពិតហ៊ានថាពិត, សេចក្តីទុស្សហ៊ានថាត្រូវ គិតយើញតែប្រយោជន៍ផ្ទាល់ខ្លួន មិនយើញសេចក្តីទុក្ខរបស់អ្នកដទៃ; មនុស្សបែបនេះ នឹងលុះទៅកង៏តម្រានៃសេចក្តីវិនាសមិនខាន ។

ដូចជាមាតាបិតា ទើបបុត្រាបុត្រី ឬស្វាមីទើបភរិយា ឬក៏គ្រូឧបជ្ឈាយាចារ្យទើបសិស្សានុសិស្ស បើគ្មានសច្ចៈពិតត្រង់ទៅវិញទៅមកទេ សេចក្តីវិនាសតែងតែកើតឡើងជាមិនខាន, ព្រោះសច្ចៈនេះជាគុណធម៌ដ៏ប្រសើរបំផុតក្នុងលោក, ហើយជាព្រះសម្មុទ្ធជាអគ្គបុគ្គលទ្រង់សំដែង មាននៅក្នុងគម្ពីរមហាបដ្ឋានថា:

សច្ចំ ហិ បរមំ លោកេ សច្ចំ លោកេ បជានកំ
ស ច្ចម្ហិ វិជ្ជមានស្មិំ សព្ពបុញ្ញា បវិជ្ជតិ

"សច្ចៈជាធម៌ដ៏ឧត្តមក្នុងលោក សច្ចៈជាប្រធានក្នុងលោក បុណ្យទាំងអស់រមែងមានក្នុងសច្ចៈ" ។

ព្រោះហេតុនោះ សេចក្តីសរសើរតម្កើងសច្ចៈ គឺសេចក្តីពិតត្រង់ ឲ្យកើតមានឡើងគ្រប់ៗគ្រា ។

ទី ២ — ទមៈ = ការទូន្មាន, ចានដល់ការហាត់ពត់ដុសខាត់កាយ វាចា ចិត្ត របស់ខ្លួនឲ្យមានសណ្តាប់ធ្នាប់សមរម្យល្អ ។ ក្នុងទីនេះ, សំដៅយកសីលទាំង ៥ ដែលហៅថា និច្চសីល ។ នេះបានដល់សិក្ខាបទដែលគួរប្រតិបត្តិកាន់រក្សាដោយទៀងទាត់អស់កាលជានិច្ច ពុំតំណត់កាលវេលា ។ មានន័យខ្លះលោកហៅសីល ៥ ថា បុព្វណ្ហសីល គឺជាសណ្តាប់ធ្នាប់របស់បុព្វបុរសដែលធ្លាប់រក្សាមកក្នុងកាលពីព្រេងនាយ មុនពុទ្ធសម័យ ។ ន័យខ្លះទៀត លោកហៅសីល ៥ ថាកុរុធម៌ គឺជាប្រពៃណីធម៌ ឬ ជាអរិយធម៌ របស់អ្នកជនកុរុដែលធ្លាប់ប្រតិបត្តិកាន់មកតាម

សណ្ណាប់ គោត្រតត្រកូល ។ ព្រះសម្មាសម្ពុទ្ធកាលនៅជាពោធិសត្ត
បានជាព្រះរាជាក្នុងនគរឥន្ទបត្រ ដែនកុរុ ព្រះអង្គបានរក្សាសីល ៥ ជាប់
ទៀងទាត់ជរាបមក ។ ព្រោះហេតុនោះ សីលទាំង ៥ នេះ ទើបលោក
ហៅថា កុរុធម្មិក្នុងកាលណោះ ។ លុះព្រះអង្គបានត្រាស់ដឹងឡើង
ក្នុងលោក ក៏ទ្រង់បញ្ញត្តសំដែងសើរើរៀបបន្ទែមឡើងជាថ្មី ដើម្បី
អនុគ្រោះសត្វលោកឲ្យមានសន្ធិកាព ឲ្យមានអរិយធម្មិច្ឆាប់សម្រាប់
ទូន្មានខ្ជូន មានត្រណមឲ្យកើតប្រយោជន៍ដល់បព្វជិតនឹងគ្រហស្ថ ចាត់
ជាវិន័យក្នុងព្រះពុទ្ធសាសនាជាជំនួយដល់ផ្ទូវលោក សម្រាប់ប្រជាករ
ជរាបមក ។

ត្រណមក្នុងសិក្ខាបទរបស់ឥប្ទសីល

សិក្ខាបទទី ១ ហាមអំពីការសម្ចាប់សត្វទ្ធូទៅ ។ ពាក្យថាសត្វ ៗ នេះ
សំដៅយកទាំងមនុស្ស ទាំងតិរច្ឆានដែលមានជីវិត ពុំកំណត់ថាប្រុសស្រី
ឬក្មេងចាស់ ទោះបីពួកសត្វល្អិតតូច ៗ ឬ សត្វនៅក្នុងគភិក្តី ក្នុងអណ្ឌ:ក្តី
ក៏ឈ្មោះថាសត្វ រាប់ចូលក្នុងត្រណម ដែលត្រូវតមទាំងអស់ ។

សិក្ខាបទនេះ ព្រះអង្គបញ្ញត្តតាំងឡើង ដើម្បីជាប្រយោជន៍នឹង
បណ្ណុះធម្មិមេត្តា ករុណា ចំពោះពួកសត្វ ធ្វើពួកសត្វទាំងសាកលពុំឲ្យ
មានពៀរដល់គ្នានឹងគ្នា ។

សិក្ខាបទទី ២ ហាមអំពីការលួចទ្រព្យ ដែលម្ចាស់គេពុំបានឲ្យ ។
ពាក្យថាទ្រព្យនេះ សំដៅយកទ្រព្យ ជាសវិញ្ញាណក: នឹងអវិញ្ញាណក:
គឺទ្រព្យមានវិញ្ញាណនឹងទ្រព្យឥតវិញ្ញាណ ទោះបីទ្រព្យនោះថ្ថៃ ថោក

ប្រើន តិច ឬ ទ្រព្យដែលគេទ្ទិសបូជាចំពោះសង្ឆ ចំពោះសាសនា ក៏ឈ្មោះថាទ្រព្យនៅក្នុងត្រណមរបស់សិក្ខាបទនេះតាំងអស់ ។

សិក្ខាបទនេះ ព្រះអង្គបញ្ញត្តតាំងឡើងដើម្បីបណ្ដុះសម្មាអាជីវ: (ការចិញ្ចឹមជីវិតដោយប្រពៃ) ពុំឲ្យមានការបៀតបៀនគ្នាឲ្យមានចិត្តស្មោះត្រង់ដឿចិត្តស្រឡាញ់រាប់រកគ្នាទូទៅ ។

សិក្ខាបទទី ៣ ហាមអំពីការប្រព្រឹត្តិខុសក្នុងកាមតាំងឡាយ ។ ពាក្យថាកាមនេះ សំដៅយកកិរិយាដែលស្រឡាញ់កូចកាន់ ឬ ប្រាថ្នាក្នុងផ្ទូវបរវណី ដែលពុំត្រូវប្រាថ្នា ពុំត្រូវប្រព្រឹត្ត ជាហេតុឲ្យសៅហ្មងមានតំនុំនឹងគ្នាក្នុងរវាងត្រកូលទូទៅ ។

សិក្ខាបទនេះ ព្រះអង្គបញ្ញត្តតាំងឡើងដើម្បីបណ្ដុះសំវរ: គឺការសង្រួមនឹងសទារសន្តោស: គឺសេចក្តីត្រេកអរចំពោះតែកិរិយារបស់ខ្លួន ។

សិក្ខាបទទី ៤ ហាមអំពីការកុហក គឺនិយាយចំកន្ទអ្នកស្តាប់ឲ្យចូលចិត្តខុសឲ្យយល់ខុស មិនចំពោះតែនិយាយដោយវាចាទេ សូម្បីត្រាន់តែធ្វើសញ្ញាដោយកាយ ក៏រាប់ចូលក្នុងមុសាវាទដូចគ្នា ទោះបីអ្នកនិយាយកុហកដើម្បីសើចលេង ក៏ឈ្មោះថាជាពាក្យនៅក្នុងត្រណមរបស់សិក្ខាបទនេះដែរ ។

សិក្ខាបទនេះ ព្រះអង្គបញ្ញត្តតាំងឡើង ដើម្បីបណ្ដុះសច្ចធម៌ក្នុងសន្តាន ឲ្យមានការទៀងទាត់ស្មោះត្រង់ដល់គ្នានឹងគ្នា ពុំឲ្យមានការវិវាទចាប់ចោទប្រកាន់គ្នា ។

សិក្ខាបទទី ៥ ហាមអំពីការផឹកទឹកស្រវឹង គឺសុរានឹងមេរ៉យ ។

ពាក្យថាសុរានេះ ជាឈ្មោះទឹកដែលកើតមកអំពីគ្រឿងគ្រាំផ្ទៃឈើ ឬធញ្ញជាតិផ្សេង ៗ ដែលគេគ្រាំទុកយូរទាល់តែទឹកនោះជូរផ្អូមខ្ទាំង ក្លាយរស់ជាតិជាទឹកស្រវឹងក្តី គេយកធញ្ញជាតិស្វាវរម្ទាស់បិទយកដំណក់ទឹកញើសនោះក្តី ធ្វើដោយបែបផ្សេង ៗ ក្រៅពីនេះក្តី ទាំងនេះហៅថាសុរា ។

ចំណែកមេរ៉យ គឺជាទឹកតម្រាំដែលគេជាក់មេជាតិស្រវឹងគ្រាំទុកឲ្យបេញរសជាតិ ជូចទឹកត្នោតជូរជាដើម ។ សុរានឹងមេរ៉យនេះជាទឹកស្រវឹងជាទីតាំងនៃសេចក្តីប្រមាទ ទោះបីខ្ទាំងឬទ្យាយ ក៏រាប់ចូលក្នុងត្រណមរបស់សិក្ខាបទនេះទាំងអស់ ។

សិក្ខាបទនេះ ព្រះអង្គបញ្ញត្តតាំងឡើងដើម្បីបណ្តុះអប្បមាទធមិឬសតិសំវរ: ឲ្យជុះលូតលាស់ល្អនៅក្នុងសន្តានពុំឲ្យមានការប្រមាទក្នុងកិច្ចទាំងពួង ។

បុគ្គលណា រ៉ៀរចាកវត្ថុជាពុទ្ធបញ្ញត្តិប្រតិបត្តិតាមត្រណមក្នុងសិក្ខាបទទាំង ៥ ប្រការនេះបាន បុគ្គលនោះឈ្មោះថាជាអ្នកមានសីល ។

សីលនេះ ជាទឹកឧសថវិសេសផុតឧសថក្នុងលោកអាចលាងជម្រះនូវមន្ទិល គឺសេចក្តីទុក្ខសោកអពមង្គលដែលជុះក្រាំងជាប់នឹងជួងចិត្តរបស់សត្វក្នុងលោកបាន, សមជូចពុទ្ធគាសិតមួយកន្ទែងក្នុងគម្ពីរវិសុទ្ធិមគ្គថា:

ន គង្គា យមុនា វាបិ សរភូ វា សរស្សតិ
និន្នគា វាបិរវតី មហី វាបិ មហានទី
សក្កុណន្តិ វិសោធេតុំ តំ មលំ ឥធ បាណិនំ
វិសោធយតិ សត្តានំ យំ ឥ សីលជលំ មលំ ។

"ទឹកមហានទីតង្គាក្តី យមុនាក្តី សរភូក្តី សរស្សតីក្តី អចិរវតីក្តី មហីក្តី សុទ្ធតែជានទីយ៉ាងធំ ៗ ក៏មិនអាចដើម្បីនឹងជម្រះនូវមន្ទិលរបស់សត្វពាំងឡាយក្នុងលោកនេះបានឡើយ មានតែទឹកគឺសីលនេះឯង ទើបអាចជម្រះនូវមន្ទីលរបស់សត្វពាំងឡាយបាន" ។

មួយទៀត:

ន ពំ សជិលជា វាតា ន បាបិ ហរិបន្ធនំ
ទេវិ ហារា ន មណាយោ ន បន្ធកិរណាង្កុរា
សមយន្ធីធ សត្តានំ បរិឡាហំ សុរក្ខិតំ
យំ សមេតីទំ អរិយំ សីលំ អប្ចន្ធសីតលំ ។

"ឲ្យល់ពាំងឡាយដែលប្រកបដោយទឹកក្តី ឲ្វឹមចន្ទន៍ក្រហមក្តី កែវមុត្តាហារក្តី កែវមណីក្តី រស្មីនៃព្រះចន្ទ្រដ៏ទន់ក្តី ពុំអាចនឹងរម្ងាប់នូវសេចក្តីក្រហល់ក្រហាយ របស់សត្វពាំងឡាយក្នុងលោកនេះបានឡើយ មានតែសីលដ៏ប្រសើរ ដែលបុគ្គលរក្សាហើយដោយប្រពៃ ជាគុណត្រជាក់យ៉ាងក្រៃលែង នេះទើបអាចនឹងរម្ងាប់បាន" ។

មួយវិញទៀត:

យា មនុស្សេសុ សម្បត្តិ យា ច ទេជិសុ សម្បទា
ន សា សម្បន្នសីលស្ស ឥប្ជតោ ហោតិ ទុល្លភា ។

"សម្បត្តិក្នុងស្ថានមនុស្សក្តី ក្នុងស្ថានទេវតាក្តី កាលបើបុគ្គល

ដែលមានសីលបរិបូណ៌ ត្រូវការចង់បានហើយ សម្បត្តិទាំងនោះមិនជាគ្រឿងសោះឡើយ” ។

ន័យនេះសមនឹងពុទ្ធភាសិតមួយកន្លែងទៀតថា:

ឥច្ចេតំ ឋិ ភិក្ខវេ សីលវតោ បេតោបណិធិ ។

“ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដែលតាំងនៅក្នុងចិត្តរបស់បុគ្គលអ្នកមានសីល រមែងបានសម្រេចដូចបំណង” ។ ហេតុនេះ សប្បុរសទាំងឡាយគួររក្សាសីលនេះគ្រប់រូប ។

ទី ៣— បិតិ=សេចក្តីអត់ធន់, សេចក្តីអត់ធន់នេះលោកចែកជាបីយ៉ាង គឺ:

១— អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើត លោភៈ,

២— „ . . , ... „ . . . . . „ ទោសៈ,

៣— „ . . , ... „ . . . . . „ មោហៈ ។

ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតលោភៈនោះ បានខាងការអត់ទ្រាំនឹងចំណង់ផ្សេងៗ ដែលកើតឡើងក្នុងទ្វារទាំង ៦ ។ ពាក្យថា អត់ទ្រាំ គឺមិនប្រព្រឹត្តទុច្ចរិតតាមចំណង់ឬសេចក្តីស្រេកឃ្លាននោះ ។ ។ បុគ្គលជំពូកខ្លះ ព្រោះតែមិនចេះអត់ទ្រាំនឹងចំណង់ឬសេចក្តីស្រេកឃ្លាន បានជាហ៊ានលួចឆក់ដណ្តើមបំបាត់ប្រវាញ្ជន៍ឲ្យសម្បត្តិរបស់គេ, កាលបើប្រព្រឹត្តទុច្ចរិតដូច្នោះ រមែងជួបប្រទះនឹងសេចក្តីទុក្ខព្រួយដែលជាផលរបស់ទុច្ចរិតនោះ ។ មានត្រូវទោសជាប់គុកច្រវាក់ជាដើម ។ បុគ្គលណាជាមនុស្សមិនសូវរវៃរវាមពេក ចេះអត់ទ្រាំបាន

បុគ្គលនោះឯងតែងប្រកបដោយសុខភាពនឹងអនាម័យដ៏ល្អ ។ ឋិតិ
សេចក្តីអត់ធន់បែបនេះ ហៅថាអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យ
កើតលោភ: សូម្បីអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតរាគ:
ក៏គួរសង្ត្រោះចូលក្នុងឋិតិនេះដែរ ។

ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតទោស:នោះ
ជានខាងសេចក្តីអត់ធន់ចំពោះពាក្យបរប្បរាទ ដែលបុគ្គលដទៃស្តីថា រិះគន់
ឬ ត្មះតិះដៀល ឬ អត់ធន់នឹងអំពើដែលបុគ្គលដទៃប្រៀតប្រៀនដែលជា
ប្រភពរបស់ទោស: ។ ធម្មតាមនុស្សកើតមកក្នុងលោកសន្និវាសនេះ
ដែលថាមិនឲ្យគេស្តីថាមិនឲ្យគេរិះគន់ ឬ ត្មះតិះដៀលសោះនោះគ្មានទេ,
អម្បាលព្រះមាទិត្យព្រះចន្ទ្ធដែលធ្ងុះបំភ្ងឺលោកជាប្រក្រតី ម្តេចគង់មានគេ
តិះដៀលខ្ងះដែរ, ចំណង់បើមនុស្សក្នុងលោកនឹងរកនរណាឲ្យជាមនុស្ស
ឥតគេតិះដៀលនោះពុំមានឡើយ, ទុកជាព្រះសាស្តាបរមគ្រូជាម្ចាស់ដែល
ប្រកបដោយមហាករុណាទិគុណ ម្តេចក៏គង់មានគេតិះដៀល ។ បើ
យល់ជាក់យ៉ាងនេះហើយគួរឲ្យមានការអត់ធន់ កុំក្រោធខឹង ។ បុរាណ-
ចារ្យទាំងឡាយ លោកសំដែងប្រាប់ឧបាយ គឺយោបល់ជាគ្រឿងរំលត់
សេចក្តីក្រោធខឹងថា: "ទុកជាមានក្នែកភ្ងឺ ក៏ត្រូវធ្វើដូចជាងងឹត, មាន
ត្រចៀកស្តាប់ព្ង ក៏ត្រូវធ្វើដូចជាថ្ងង់" ដូច្នេះទើបអត់ធន់សេចក្តីក្រោធ
ខឹងនោះបាន ។ ប្រសិនបើធ្វើជាមនុស្សក្នែកទិព្ធត្រចៀតទិព្ធ ចេះតែ
ឃើញ ចេះតែព្ង ហើយនៅជាបថុជ្ជនចិត្តស្រាលផង ក៏នឹងរក្សាសេចក្តី
អត់ធន់នោះបានដោយកម្រណាស់ ។

ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតមោហៈនោះ ជានខាងសេចក្តីអត់ធន់នឹងទុក្ខវេទនាផ្សង ។ ដែលកើតឡើងក្នុងកាយនឹងចិត្ត មិនលុះក្នុងអំណាចទុក្ខវេទនាហើយទៅប្រព្រឹត្តទុច្ចរិតឡើយ ។

សូម្បីការដែលអត់ទ្រាំនឹងទុំក្ខវេទនាក្នុងវេលាឈឺថ្កាត់នោះសោត ក៏ជាហេតុជួយឧបត្ថម្ភឲ្យមានសតិសម្បជញ្ញៈ គឺការភ្ញាក់រព្ចកនឹងសេចក្តីដឹងខ្លួន ដែលជាគុណវិសេសគួរឲ្យមានគ្រប់កាលទាំងពួង ។ ពុំនោះសោតក្នុងវេលាមានព្យាធិដែលជាហេតុឲ្យដល់មរណៈ ក៏គួរតែមានសេចក្តីអត់ធន់យ៉ាងមាំមួន ។

ឧបាយដែលនឹងឲ្យកើតសេចក្តីអត់ធន់ក្នុងវេលានោះ គឺត្រូវគិតឲ្យឃើញតាមសេចក្តីពិតថា: ព្យាធិនឹងមរណៈនោះជាទុក្ខដែលសត្វទាំងឡាយ ត្រូវតែជួបប្រទះរាល់ៗ ត្នា គេចមិនរួចឡើយ ។ ក្នុងអភិណ្ហ-ប្បច្ចវេក្ខណ ដែលព្រះបរមសាស្តាទ្រង់ប្រដៅឲ្យនឹករំពឹងជារឿយ ៗ ថា: ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ "អាត្មាអញ់មានជម្ងឺជម្ពាត់ជាធម្មតានឹងចៀសរាងជម្ងឺជម្ពាត់មិនបានឡើយ" ដូច្នេះនោះ ក៏ដើម្បីឲ្យប្រុងខ្លួនអំពីកាលដែលនៅជានៅឡើយ, បើចាំទៅនឹករំពឹងក្នុងពេលដែលជម្ងឺជម្ពាត់មកដល់តែម្តង ក៏មុខជាកម្រនឹងនឹកឃើញបាន, ព្រោះវេលាដែលឈឺនោះ តែងមានទុក្ខព្រួយលំបាកច្រើនយ៉ាងណាស់ ។ កាលបើអត់ទ្រាំទុក្ខវេទនាពុំបាន សតិសម្បជញ្ញៈក៏នឹងត្រេតត្រាតទៅពុំតាំងនៅខ្ជាប់ឡើយ ដូចជនជំពូកខ្ទះ ដែលមិនបានហាត់ចិត្តទុកអំពីកាលនៅជានោះ លុះវេលាដែលមានជម្ងឺយ៉ាងធ្ងន់មកដល់ ក៏ច្រើនតែមានចិត្តរវើរាយ

ផ្សេង ។ ជាបដល់ធ្វើអំពើទុច្ចរិតមានសម្ងាប់សត្វជាដើម ដើម្បីបូជាគ្រោះ ដោយចង់រស់តែខ្លួនឯង ពុំគិតអាណិតសត្វដទៃក៏មាន ។

ព្រោះហេតុដូច្នោះ ការដែលបង្ហាត់ចិត្ត បង្ហាត់ស្មារតីដើម្បីឲ្យគេចសេចក្តីអត់ធន់នោះ ជាកិច្ចដែលយើងត្រូវការគប់ ។ ឮបាណសម្ងាប់តយុទ្ធនឹងសត្រូវ គឺព្យាធិទុក្ខ ក្នុងវេលាដែលដឹងនឹងជល់មរណទុក្ខនោះ ។

ចំណែកអ្នកដែលមានឮបាថ្នាវៀនវកខ្លះគោគទ្រឹឡនឹងវិទ្យាសាស្ត្រ ក្សេត្រសាស្ត្រ នឹងពាណិជកម្ម កសិកម្មជាដើម បើមានសេចក្តីអត់ធន់ខ្លួនការស្រេកឃ្លានមានគ្រ ក្តៅត្រជាក់ជាដើមហើយ រឿងនឹងគោគទ្រឹឡក៏រមែងសម្រេចដល់បុគ្គលនោះ ដោយមុហុត្តកាល, បុគ្គលនោះនឹងធ្វើខ្លួនឲ្យទៅជាមនុស្សចំរើនលោកបាន ។

ហេតុនេះ គួរចំរើនបិតិគឺសេចក្តីអត់ធន់ឲ្យមានគ្រប់ ។ ឮបាណ ។

ទី ៤ — បាគៈ ប្រែថា "ការលៈ" គឺលៈខ្លួមច្ចរិយៈសេចក្តីកំណាញ់, ចាគៈនេះ ជាគួរនឹងទានៈគឺការឲ្យ ។

ចាគៈនឹងទានៈពាក្យទាំងពីរនេះ បើសំដៅយកសេចក្តីយើញថាផ្សេង ។ គ្នា តែបើដោយលក្ខណៈក៏ស្រដៀង ។ គ្នា ។ តាមសេចក្តីអធិប្បាយចំពោះពាក្យថាចាគៈនេះមានន័យ ៤ យ៉ាង គឺ:

១ — ចាគៈ ការលៈវត្តុណាមួយចំពោះបដិគ្គាហកៈ ដើម្បីលៈបង់សង្កត់សង្កិនខ្លួលោភៈ នឹងមច្ចរិយៈឲ្យស្រាលស្តើងចាកសន្តាន គឺចំណាយទ្រព្យដើម្បីទុកជាអលង្ការ ឬ ជាកល្យាណវត្តរបស់ចិត្ត ពុំបណ្តោយឲ្យចិត្តជ្រលក់ជាប់នៅក្នុងកិលេស ។

២ - ចាគ: ការលះឲ្យដែលមិនជាប់ចំពាក់ដោយតណ្ហា គឺឲ្យ
ដោយមានបំណងចំពោះនិរាមិសសុខ ដើម្បីធ្វើចិត្តឲ្យបរិសុទ្ធ បើក
ទ្វារសឲ្យបញ្ញារបស់ខ្លួនមានកំឡាំងលូតលាស់ចំរើនឡើងផង ដើម្បីជា
ប្រិយោជន៍នឹងសេចក្តីសុខថ្កំថ្កើង ជាតម្រាប់ដល់បច្ចាជនតាជនជាន់
ក្រោយផង ដូចយ៉ាងការចំណាយទ្រព្យទំនុកបំរុងព្រះពុទ្ធសាសនា
កសាងសេនាសន: លើកថ្នល់ សង់ស្ពាន ជីកអណ្តូង សង់សាលាបំរុងការ
សិក្សា ឬ សាលាសំណាក់ទុកសម្រាប់ជាសាធារណ: មិនបានចំពោះ
បដិគ្គាហក: ។

៣ - ចាគ: ការលះឲ្យវត្ថុដ៏ប្រសើរក្រៃលែង លើសរិស័យរបស់
មនុស្សសាម័ញ្ញក្នុងលោកគ្ឆរឲ្យស្មើច ដែលរាប់ថាជាការបរិច្ចាគយ៉ាងខ្ពង់
ខ្ពស់បំផុត កម្រអ្នកផងយកតម្រាប់តាមបាន ដូចយ៉ាងមហាបរិច្ចាគរបស់
ព្រះបរមពោធិសត្ត ។

៤ - ចាគ: ការលះ កាត់អាល័យក្នុងជីវិតនឹងសេចក្តីសុខក្នុងទ្រព្យ
សម្បត្តិរបស់ខ្លួនម្នាក់ឯង ដើម្បីស្ទះស្ទែងរកទុបាយ ជួយជ្រោមជ្រែង
ប្រជាករក្នុងលោកឲ្យលះបង់ទ្រព្យសម្បត្តិ ដើម្បីរោយរាយចែកចាយឲ្យ
ក្លាយទៅជាប្រយោជន៍ ផ្តល់សេចក្តីសុខសេចក្តីចំរើនរុងរឿងដល់មហាជន
ទុកជាកេរ្តឹ៍ដំណែលតទៅ ។ នេះជាសេចក្តីអធិប្បាយរបស់ពាក្យថា
ចាគ: ។

ចំណែកខាងទាន: ក៏មានសេចក្តីអធិប្បាយចែកចេញជា ៤ យ៉ាងដែរ គឺ:

១ - ទាន: ការឲ្យវត្ថុណាមួយដែលនៅជាប់ជំពាក់ដោយមច្ចរិយ:

ឬឲ្យដោយស្លាក់ស្ទើរពុំជ្រះស្រឡះចាគមច្ចរិយៈ ឬក៏ឲ្យតាមទំនៀមពុំលាប់
របស់ត្រកូល ពុំមែនជាកិច្ចអស្ចារ្យចំឡែកជាងត្រកូលដែលធ្លាប់ធ្វើមក
ប៉ុន្មាន ។

២- ទានៈការឲ្យដែលជាប់ដោយតណ្ហា គឺបុគ្គលអ្នកឲ្យទានគ្រាថ្នា
យកសិរីសួស្តីនឹងផលច្រើនយោជន៍មកខ្លួនវិញ ចំពោះសាមិសសុខក្នុងភព
នេះឬភពមុខ ។

៣- ទានៈការឲ្យពុំសមគួរ គឺបុគ្គលណាមានសម្បត្តិច្រើនមានវត្ថុ
ថ្លៃថ្លាច្រើន លុះត្រៃការចាត់ចែងទានក៏ចាត់ចែងដោយរលើបរលាច ស្តួច
ស្តើងនឹងត្រៃដ៏ថោកទាបតាមធម្មតា, ទានរបស់បុគ្គលនោះ ឈ្មោះថាជា
ទានពុំសមតាមស័ក្តិតាមកំឡាំងនៃទ្រព្យដែលខ្លួនមាន ។

៤- ទានៈការឲ្យចំពោះមុខបជិគ្គាហកៈអ្នកខ្លួលផ្លាស់ ដែលជា
បុគ្គលខ្សត់ខ្សោយ ដោយគុណធម៌ ទន្ទឹងកោតទ្រព្យ ឬខ្ពង់ខ្ពស់ដោយ
គុណធម៌ ទន្ទឹងកោតទ្រព្យ ។ នេះជាសេចក្តីអធិប្បាយរបស់ពាក្យថា ទានៈ។

ពាក្យថា ចាគៈទន្ទឹងទានៈមានសេចក្តីផ្សេងគ្នា ដូចពណ៌នាមកនេះ
ឯង ។ កាលបើសង្កេតមើលតាមដំណើរសេចក្តីកន្លងមកនេះ គង់
យើញច្បាស់ថាៈចាគៈ មានកំឡាំងជាងទានៈ ឬថា ជាធម៌ខ្ពង់ខ្ពស់លើច
សេចក្តីខ្ជិលច្រអូសជាងទានៈ ។

មួយទៀតចាគៈទន្ទឹងទានៈនេះ បើពោលតាមលក្ខណៈបូរម្ចក់គឺការឲ្យ
ការបែកចែកលែកកោតទ្រព្យចំពោះសត្វ ឬបុគ្គលដទៃប៉ុណ្ណោះឯង តែបើ
រាប់តាមហេតុផលវិញ ចាគៈជាឈ្មោះចេតនាដែលជាចេតៈមិកសំកប់

លះ, ទាន: ជាឈ្មោះបវិក្ខារវត្ថុ ដែលគេត្រូវឲ្យ; ចាគ: ចាត់ជាហេតុ, ទាន: ចាត់ជាផល, អាស្រ័យគ្នាជូបព្រះអាទិត្យនឹងពន្លឺរស្មីនៃព្រះអាទិត្យ ។ មួយវិញទៀត ចាគ: ជូបជាដើមឬទងនៃរុក្ខជាតិ, ទាន: ជូបជាផ្លែផ្កាដែលលេចបេញចាកដើមឬទង ។

ចាគ: ឬទាន:នេះទុកជូបជាជណ្តើរសម្រាប់ឡើងទៅកាន់ស្ថានសួគិ, ជូបកាសិតថា:

"ទានំ សគ្គស្ស សោបាណំ ទានជាជណ្តើរបស់ស្ថានសួគិ" ។

ហេតុនេះ សប្ឋរសទាំងឡាយគួរបំរើនចាគ: នឹងទាន: នេះ ឲ្យមានឡើងគ្រប ៗរូប ។

សំដែងមកក្នុងផ្ទៃនៃពុទ្ធកាសិតនេះ ក៏សន្មតថាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

បន្ទាប់អំពីនេះនឹងសំដែងនូវពុទ្ធកាសិតនេះ ជានិគមវចន:បន្ថែមម្តងទៀត:

ធម្មទេសនា ដែលសំដែងមកអម្បាញ់មិញនេះ គឺ សំដែងអំពីពុទ្ធកាសិតថា:

យស្សេតេ បតុធា ធម្មា
សទ្ធស្ស ឃរមេសិនោ
សប្ចំ ទមោ ឋិតិ ចាគោ
ស ធ៉ បេប្ច ន សោបតិ ។

"បុគ្គលដែលមានសទ្ធាគ្រប់គ្រងផ្ទះត្រូវមានធម៌ ៤ ប្រការនេះ គឺ សច្ចៈ សេចក្តីពិត ១, ទមៈ ការទូន្មាន ១, ឱតិ សេចក្តីអត់ធន់ ១, ចាគៈ ការបរិច្ចាគ ១; រមែងមិនសោយសោកក្នុងលោកខាងមុខដោយពិត" ។

ក្នុងផ្ទៃនៃពុទ្ធកាសិតនេះ មានគោលប្រតិបត្តិយ៉ាងសំខាន់ ៤ យ៉ាង គឺៈ សច្ចៈ សេចក្តីពិត ១, ទមៈ ការទូន្មាន ១, ឱតិ សេចក្តីអត់ធន់ ១, ចាគៈ ការបរិច្ចាគ ១; ហើយបានលើកឡើងកាន់សេចក្តីអធិប្បាយម្តងមួយ ៗ ដរាបគ្រប់ទាំង ៤ ។

សាធរោ! បពិត្រសប្បុរសទាំងឡាយ គ្ឆរពុទ្ធបរិសីទខំប្រតិបត្តិ ចំរើនន្ធូវធម៌ទាំង ៤ យ៉ាងនេះឲ្យបានបរិបូណិគ្រប់ ៗ ប្រាណ ។

ធម្មទេសនានុភាវេន សុខិតា ហោន្តុ បាណិនោ
ទ្វីសុ អត្ថេសុ តិដ្ឋន្តិ សហ សព្វេហិ ញាតិភិ ។

ដោយអំណាចនៃធម្មទេសនានេះ សូមឲ្យសត្វនិករទាំងឡាយបានប្រកបដោយសេចក្តីសុខ ហើយស្ថិតនៅក្នុងប្រយោជន៍ទាំងពីរ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា!

ប្រស្នាធម៌ (១)

ឃុនបណ្ណានុវក្ស ប៊ូ-ប៉ូ រៀបរៀង

សំនួរ ទី ១.– ទានឲ្យផលដល់លោកុត្តរបានឬទេ? បើបានតើត្រូវធ្វើដូចម្តេច? សូមអធិប្បាយ ។

ចម្លើយ – ទានឲ្យផលដល់លោកុត្តរបាន ប៉ុន្តែត្រូវអាស្រ័យការធ្វើចិត្តឲ្យបរិសុទ្ធក្នុងវេលាបរិច្ចាគ ដូចអធិប្បាយតទៅនេះ គឺ ៖

ក) ឲ្យទានដោយតាំងចិត្តមិនចង់បានផល មិនមែនដូចជាចង់បានចំណេញក្នុងការដួញជាដើមទេ ។

ខ) ឲ្យទានដោយគ្មានចិត្តជាប់ចំពាក់នឹងវត្ថុដែលខ្ជូនឲ្យ ដូចជារបស់ទ្រព្យដែលផ្ញើទុកនឹងគេ ។

គ) ឲ្យទានដោយមិនតាំងចិត្តសន្សំ (ដ៏ជាកម្មក្តិលេស) ដូចសន្សំទ្រព្យសម្បត្តិទុកជាដើម ។

ឃ) ឲ្យទានដោយមិនតាំងចិត្តថា យើងស្ងាប់ពីលោកនេះទៅហើយនឹងបានបរិភោគវត្ថុដែលខ្ជូនបរិច្ចាគនោះ ។

ង) ឲ្យទានដោយគិតយើញថា ការបរិច្ចាគ ជាការល្អជាការត្រូវតែប៉ុណ្ណោះ ។ រួមជា ៥ ប្រការ ។

ទាន ការបរិច្ចាគ ដោយធ្វើចិត្តឲ្យបរិសុទ្ធ ដូចពោលមកនេះ ចូលចិត្តថា ឲ្យផលដល់លោកុត្តរបាន ដូចពុទ្ធភាសិតដែលត្រាស់ចំពោះព្រះ

---

១ ប្រែជ.កច្ឆាប់ធម្មចក្ស ព.ស. ២៤៣៣ ។

សារីបុត្តត្រេកត្រអរក្នុងសត្តកនិបាត អង្គុត្តរនិកាយថា "ឥធ សារីបុត្ត ឯកច្ចោ សាបេក្ខោ ទានំ ទេតិ, បដិពទ្ធចិត្តោ ទានំ ទេតិ, សន្និធិ-បេក្ខោ ទានំ ទេតិ, ឥមំ បេច្ច បរិភុញ្ជិស្សាមីតិ ទានំ ទេតិ

ជាដើម សេចក្តីថា "ម្នាលសារីបុត្ត ! ពាយកញ្ជកខ្ទះ ក្នុងលោកនេះ ជាអ្នកសម្ធឹង (ប្រាថ្នាផល) ឲ្យទានក៏មាន, ជាអ្នកមានចិត្តជាប់ចំពាក់ក្នុងវត្ថុដែលខ្ជួនឲ្យទៅហើយ ឲ្យទានក៏មាន, ជាអ្នកសម្ធឹងសេចក្តីសន្សំ មិនសម្ធឹងបុណ្យកុសល ឲ្យទានក៏មាន, ឲ្យទានដោយគិតថា យើងលះបង់លោកនេះទៅហើយ នឹងបានបរិភោគវត្ថុដែលខ្ជួនបរិច្ចាគនេះ ក៏មាន ។ ល ។ ពាយកនោះលុះឲ្យទានជូច្នោះហើយ ទាងមុខអំពីមរណៈ ព្រោះកាយបែកធ្លាយ រមែងចូលដល់ភាពជាពួកនៃទេវតាពួកចាតុម្មរាជ លុះអស់កម្ម អស់រិទ្ធិអស់យស អស់ភាពជាធំហើយ រមែងត្រឡប់ដល់ភាពប្រែប្រួលទៅជាយ៉ាងដទៃទៀតបាន ។ ចំណែកអ្នកដែលឲ្យទានដោយមិនសម្ធឹង, មានចិត្តមិនជាប់ចំពាក់, មិនសម្ធឹងសេចក្តីសន្សំ, មិននឹកថាយើងលះលោកនេះទៅហើយ នឹងបានបរិភោគវត្ថុដែលខ្ជួនបរិច្ចាគ, ឲ្យដោយគិតថា ការបរិច្ចាគ ជាការល្អ ជាការត្រូវ ។ ពាយកនោះលុះឲ្យទានយ៉ាងនោះហើយ ទាងមុខអំពីមរណៈ ព្រោះកាយបែកធ្លាយ រមែងចូលដល់ភាពជាពួកនៃទេវតាពួកព្រហ្ម លុះអស់កម្ម អស់រិទ្ធិអស់យស អស់ភាពជាធំនោះ ។ ហើយ មិនត្រូវត្រឡប់មក (អនាគាមី) មិនត្រូវដល់ភាពប្រែប្រួលទៅជាយ៉ាងដទៃទៀត" ។

តាមព្រះពុទ្ធកាសិតនេះ មានសេចក្តីគួរនឹងវិនិច្ឆ័យថា ទេវតាពួក

ព្រហ្មដែលពោលថា អស់កម្ម អស់ឫទ្ធិ អស់យស អស់ភាពជាធំហើយ មិនត្រូវត្រឡប់មក មិនត្រូវដល់ភាពប្រែប្រួលទៀតជាយ៉ាងដទៃទៀត នោះ តើបានដល់ព្រហ្មចំពូកណា ? តាមផ្លូវសន្និដ្ឋានថា គួរនឹងបានដល់ព្រហ្មពួកដែលបានសម្រេចលោកុត្តរធម៌ជាន់ខ្ពស់ ពាក់ថាជាព្រះអរិយៈជាន់អនាគាមីដែលចុតិចាកកពនេះហើយទៅកើតក្នុងជាន់សុទ្ធាវាស ៥ ប៉ុណ្ណោះ ព្រោះជាន់សុទ្ធាវាស៥នេះ លោកថាជាទីនៅរបស់អ្នកបរិសុទ្ធ, ព្រហ្មពួកដទៃមិនប្រាកដថានៅក្នុងជាន់នោះទេ ។ ព្រហ្មក្នុងជាន់សុទ្ធាវាស ៥ នោះ កាលបានសម្រេចព្រះអរហត្តហើយ និព្វានក្នុងកពដែលកើតនោះក៏មាន ឬដួងកាលលឿនទៅកើតហើយនិព្វានក្នុងជាន់ខ្ពស់ឡើងទៅខ្ទុះក៏មាន ។ ព្រហ្មក្នុងជាន់សុទ្ធាវាសទាំង ៥ នេះ មិនត្រូវត្រឡប់មកកាន់កាមកពទៀតជាដាច់ខាត ។ ព្រោះហេតុនេះ ទើបយល់ឃើញថា ទានដែលប្រកបដោយការតាំងចិត្តឲ្យបរិសុទ្ធក្នុងវេលាបរិច្ចាគ មានន័យដូចសំដែងមកហើយក្នុងខាងដើម នោះអាចឲ្យផលដល់លោកុត្តរបាន ។

សំនួរទី ២.- អ្វីជាតួបុណ្យ ?

ចម្លើយ.- ពាក្យថា បុណ្យ ។ នេះ ជាពាក្យដែលគេនិយាយរត់មាត់ស្ទាត់ក្នុងចិត្តគ្រប់គ្នាហើយ, បុណ្យនេះជាកំពូលនៃសេចក្តីប្រាថ្នារបស់សាធុជន ។ ធ្វើអ្វីក៏ចង់បានឲ្យជាបុណ្យទាំងអស់; បរិច្ចាគទាន, រក្សាសីល, ស្តាប់ទេសន៍ក៏ថាបានបុណ្យ; សាងវត្ត, វិហារ, កុដិ, សាលា, គម្ពីរក្សួនប្បាប់, សាងព្រះពុទ្ធរូប ក៏ថាបានបុណ្យ យ៉ាងនេះជាដើម ។

យើងគួរតែពិចារណាឲ្យយល់ច្បាស់ជាមុនថា អ្វីជាតួបុណ្យ, បុណ្យគឺអ្វី, មានប្រយោជន៍ដូចម្តេច? តាមដែលលោកសំដែងពុកមកនោះ ពាក្យថា "បុណ្យ" នេះបើសំដៅយកបុណ្យជាហេតុ ជានដល់ធម្មជាតិដែលចាំជម្រះចិត្តឲ្យស្អាតផូរផង់ជ្រះថ្លា ។ បើសំដៅយកបុណ្យជាផល ជានដល់សេចក្តីសុខកាំងកាយចិត្ត ជាសុចរិតគ្រប់គ្រាន់ ។ ន័យមួយទៀត ឫសគល់របស់បុណ្យ គឺសេចក្តីមិនលោភ, មិនក្រោធ, មិនវង្វែង, ជាកុសលមូល ។ អ្នកស្វែងរកបុណ្យ ព្រោះតែយល់ឃើញប្រយោជន៍ថា បុណ្យជាសេចក្តីល្អ ហាត់ពត់ដុសខាត់អធ្យាស្រ័យដែលសៅហ្មងដោយកិលេសធម៌ឲ្យស្អាតផូរផង់ ។ អធ្យាស្រ័យដែលនៅសៅហ្មង មិនបញ្ចេញផលឲ្យបានសេចក្តីសុខដូចប្រាថ្នាទេ មានតែឲ្យបានខ្ទុកខ្ទួលបាកជាទីតាំង ។ អ្នកចង់បានសេចក្តីសុខ គួរតែអប់រំបំពេញបុណ្យកុសលជានិច្ចទៅ មិនគួរធ្វើបាបអកុសលឡើយ ។

សំនួរទី ៣ .— ចុះបុណ្យនោះតើមាននៅក្នុងទីណា?

ចម្លើយ.— បុណ្យនោះមិនមែនមាននៅក្នុងព្រះពុទ្ធរូប, ព្រះធម៌, ព្រះសង្ឃ, ឬវត្តវិហារកុដិសាលាទីឯក្នុងកិកុសាមណេរអង្គណាទេ ។ តាមការពិត បុណ្យប្រាកដជានៅត្រង់ចិត្តរបស់យើងនេះឯង មិនមែននៅក្នុងទីដទៃឆ្ងាយឡើយ ។ ព្រោះហេតុនោះការស្វែងរកបុណ្យ ត្រូវរើសរកក្នុងខ្លួនយើង ត្រូវធ្វើខ្លួនយើងឲ្យជាបុណ្យ គឺធ្វើខ្លួនយើងឲ្យរួចផុតពីសេចក្តីអាក្រក់ផ្សេងៗចេញឲ្យអស់ ឲ្យសល់នៅតែសេចក្តីបរិសុទ្ធិទើបបានបុណ្យ ។ បើទៅស្វែងរកក្នុងទីដទៃ ក៏ទុំងបានតែរបស់ដទៃ

មិនបានបុណ្យទ្បើយ ។ លក្ខណាការផ្សេងៗដែលព្រះពុទ្ធទ្រង់បញ្ញត្តថា ជាការបំពេញបុណ្យ ដូចឲ្យទានរក្សាសីលជាដើមនេះមិនមែនជាតួបុណ្យ ទេ ត្រាន់តែជាហេតុដែលនឹងជ្រៀតជ្រែកកើចជកសង្ក្ដិលេសត្រឿង សៅហ្មងចេញ នាំឲ្យសម្រេចផលគឺបុណ្យពិតប្រាកដបាន ព្រោះហេតុ ផ្សេងៗមានទានសីលជាដើមនោះ ចាំជម្រះដុសខាត់ឲ្យជ្រះរបស់សៅហ្មង ចេញ, បើមិនបានដាច់ទាំងអស់ ក៏ឲ្យបានស្រាលស្ពើងខ្ទះ រហូតដល់ អធ្យាស្រ័យបរិសុទ្ធផូរផង់ជាតួបុណ្យពិតប្រាកដតាមលំដាប់ភូមិ ។

សំនួរទី ៦.- ធម៌អ្វីខ្ទះជាគោលនៃការបំពេញបុណ្យ? មានប៉ុន្មាន យ៉ាង? ចូរពាប់តែឈ្មោះមកមើល?

ចម្លើយ.- មានច្រើនប្រភេទណាស់ នឹងរាប់ក្នុងទីនេះមិនចប់ទេ ។ ប៉ុន្តែ បើសំដៅយកធម៌ជាគោលបំពេញបុណ្យខាងដើមបំផុតនោះ សំដៅ យកបុញ្ញកិរិយាវត្ថុ ១០ យ៉ាង គឺ ការបរិច្ចាគទាន ១, ការរក្សាសីល ១, ការចំរើនការនា ១, ការប្រព្រឹត្តទ្ធនលំទោនចំពោះមនុស្សចាស់ ប្ត អ្នកធំ ១, ការជួយខ្ទល់ខ្ទាយក្នុងកិច្ចដែលត្រូវ ១, ការឲ្យចំណែក បុណ្យ ១, ការអនុមោទនាចំណែកបុណ្យ ១, ការស្តាប់ធម៌ ១, ការសំដែងធម៌ ១, ការយល់ឃើញត្រូវត្រង់ ១ ។ បណ្តាបុញ្ញកិរិយាវត្ថុ ទាំង ១០ នេះ សូម្បីតែបុញ្ញកិរិយាវត្ថុមួយៗសុទ្ធតែជាគោលនៃការបំពេញ បុណ្យបានពិតប្រាកដ ។

សំនួរទី ៥.- ក្នុងអរិយសច្ចពោលថា អរិយសច្ចបានដល់ ទុក្ខ, សមុទ័យ, និរោធ, មគ្គ ។ ក្នុងមគ្គអង្គទី ១ ពោលថា សម្មាទិដ្ឋិ=បញ្ញា

ឃើញត្រូវ គឺឃើញអរិយសច្ច ៤ ។ អរិយសច្ចអាងដល់មគ្គ, មគ្គអាងដល់អរិយសច្ចយ៉ាងនេះ ខ្ញុំស្តាប់មិនបូលចិត្តសោះ សូមអធិប្បាយឲ្យឃើញថាមានសេចក្តីសំគាល់ដូចម្តេច ឬបានជាអាងផ្ទាស់ប្តូរគ្នាដូច្នោះ?

ចម្លើយ.— មុនដំបូង គួរជ្រាបតួមគ្គនឹងអង្គមគ្គជាមុនសិនឲ្យឃើញថា ផ្សេងគ្នាដូចម្តេច ។ សេចក្តីឃើញត្រូវ (សម្មាទិដ្ឋិ) ថា នេះទុក្ខ នេះសមុទ័យ នេះនិរោធ នេះមគ្គ ឈ្មោះថាជាតួមគ្គ ។ ចំណែកអង្គ ៨ មានសេចក្តីឃើញត្រូវ (សម្មាទិដ្ឋិ) ជាដើម មានការតាំងចិត្តត្រូវ (សម្មាសមាធិ) ជាទីបំផុត នេះជាអង្គរបស់មគ្គ ។ ទុក្ខ, សមុទ័យ, និរោធ, មគ្គ ដែលតួមគ្គឃើញ ក៏គឺអរិយសច្ច ៤ នុ៎ះឯង ។ ប៉ុន្តែដែលនឹងកើតជាតួមគ្គឡើងបាន ក៏ជាប់មកអំពីអង្គរបស់មគ្គទៀត គឺអង្គមគ្គរួមបូលគ្នាតែមួយ មានកម្លាំងស្មើគ្នាធ្វើកិច្ចក្នុងអរិយសច្ចបានកន្លះណៈជាមួយគ្នា ដែលហៅថា ឯកសមង្គី, អង្គមគ្គទាំងអស់រមែងមករួមគ្នានៅត្រង់សម្មាទិដ្ឋិ ធ្វើកិច្ចសម្មាទិដ្ឋិសេចក្តីឃើញត្រូវ គឺឃើញអរិយសច្ចដែលមានអង្គមគ្គនៅជាមួយផង បានសេចក្តីថា សម្មាទិដ្ឋិ ដែលជាតួមគ្គ បានឃើញមគ្គក្នុងអរិយសច្ច ព្រមទាំងតួមគ្គនឹងអង្គរបស់មគ្គ ។ មគ្គក្នុងអរិយសច្ចជាត់ជាតួក្នុងដែលសម្មាទិដ្ឋិគប្បីឃើញ កាលមានសេចក្តីឃើញដូច្នោះក៏បានឈ្មោះថាឃើញត្រូវដោយត្រង់ក៏គឺឃើញខ្លួនឯង ដឹងខ្លួនឯង ដែលចាត់ជាបញ្ញាយ៉ាងខ្ពស់ប្រៀបដូចអ្នករៀនអក្សរ ដឹងថាខ្លួនរៀនអក្សរផង ដឹងស្គាល់លក្ខណៈរបស់អក្សរ ដឹងអានបានផង បើគ្រាន់តែដឹងខ្លួនថារៀនអក្សរប៉ុណ្ណោះ ក៏នៅមិនទាន់ធ្វើប្រយោជន៍អ្វីឲ្យសម្រេចបានដែរ

ត្រូវតែដឹងស្គាល់សព្វគ្រប់ ទើបនឹងញ៉ាំងកិច្ចឲ្យសម្រេចប្រយោជន៍បាន ដូចយ៉ាងក្អែកឃើញធម៌ មិនមែនសំដៅយកក្អែកសាច់ឃើញទេ ដោយត្រង់សំដៅយកធម៌ឃើញធម៌ គឺថា ធម៌ឃើញខ្លួនឯងនៅតែដូចគ្នា ។ ហេតុនោះ សម្មាទិដ្ឋិ=សេចក្តីឃើញត្រូវ ទើបថ្កាថ្កាយកឃើញខ្លួនឯង បើឃើញខ្លួនឯង ដឹងខ្លួនឯង មិនទាន់បានទេ ក៏ចាត់ថាខ្វះសតិសម្បជញ្ញៈ កាលបើខ្វះដូច្នេះ ទឹងចាត់ជាសេចក្តីឃើញត្រូវមិនទាន់បានដែរ ។ ដែលទឹងចាត់ថាជាសេចក្តីឃើញត្រូវបាននោះ ត្រូវតែថ្កាថ្កាយកឃើញខ្លួនឯង ដឹងខ្លួនឯងគឺមគ្គឃើញមគ្គ ។

សំនួរ ទី ៦ .- ព្រះយោគាវចរដែលប្រតិបត្តិតាមពោធិបក្ខិយធម៌គ្រប់សព្វហើយ ប៉ុន្តែលោកុត្តរមគ្គកើតឡើងមិនបាន តើព្រោះមានអ្វីជាគ្រឿងរាំងរក ? បើមិនអាងបុព្វេកតបុញ្ញតា ទឹងសត្វដែលជាអតេកិច្ចទេ ។

ចម្លើយ .- ការដែលលោកុត្តរមគ្គកើតឡើងមិនបាន ព្រោះនៅមិនទាន់អប់រំធម៌ទាំងនោះឲ្យចំរើនពេញទី កាលបើអប់រំឲ្យបានពេញទីហើយ លោកុត្តរមគ្គត្រូវតែកើតឡើងជាជាក ។ ព្រោះតឹមតែអានិសង្សរបស់ពោជ្ឈង្គ ៧ ដែលជាចំណែកមួយនៃពោធិបក្ខិយធម៌ ក៏លោកសំដែងថា "សត្តពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិ បរិបូរេន្តិ ពោជ្ឈង្គ ៧ ដែលបុគ្គលចំរើនធ្វើឲ្យច្រើនហើយ រមែងធ្វើវិជ្ជានឹងវិមុត្តិឲ្យចរិបូណ៌" ។

បញ្ញាសជាតក

ភាគទី ៤

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

ទៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រៃហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលទៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

ធម្មសោណ្ឌាកជាតក ទី ១៨

លោកអាចារ្យ ឈឹម-ស៊ុម ប្រៃពីបាឡី

កស្សបទសពលស្ស ពុទ្ធសាសនេ ន បិរស្សេវ អន្តរធានគតេ ពារាណសីរញ្ញោ បុត្តោ ធម្មសោណ្ឌាកកុមារោ នាម បិតុ អច្ចយេន រជ្ជេ បតិដ្ឋាសិ ។

កាលពុទ្ធសាសនា នៃព្រះទសពលទ្រង់ព្រះនាមកស្សប អន្តរធានទៅមិនយូរប៉ុន្មាន មានព្រះរាជបុត្រព្រះបាទពារាណសីមួយព្រះអង្គ ទ្រង់ព្រះនាមធម្មសោណ្ឌាកកុមារ; លុះអំណើះឥតអំពីព្រះវររាជបិតាទៅ ទ្រង់បានសោយរាជសម្បត្តិតព្រះរាជវង្សរៀងមក ។ ព្រះរាជាអង្គនោះ ទ្រង់ប្រកបដោយសក្តានុភាពថ្ងៃថ្ងា ឧបមាដូចជាស្តេចចក្រពត្រាធិរាជ រុងរៀងដោយព្រះរាជសិរី ឥន់ក្នុងព្រះនគរពារាណសី បុរីរាជធានី ជាទីគួរត្រេកអរ ដូចទេវនគរ, ព្រះអង្គទើបតែនឹងសោយរាជសម្បត្តិ អស់រវលាប្រហែល ១ ឆែ ក៏សោប់តែមានព្រះរាជហ្ចុទ័យនឹកមមៃចង់ស្តាប់ធម៌

ប៉ុន្តែក្នុងព្រះរាជនគរឥតមាននរណាអាចសំដែងធម៌បានសោះ, ទើបទ្រង់ព្រះបិន្ពនាការគិតថា រាជសម្បត្តិ នឹងរាជានុភាព របស់អាត្មាអញ ទូលំទូលាយគ្ឆរ៉ីកកយណាស់ដែរ, ប៉ុន្តែប្រាសចាកធម៌ ក៏ត្រឡប់ទៅជារបស់មិនល្អវិញ ដូចជាអាកាសប្រាសចាកព្រះអាទិត្យ, ដូចជាកត្រីងងឹត ប្រាសចាកព្រះចន្ទនឹងផ្ការយតាកករ, ដូចជានាគរាជ ឥតចង្ក្រម, ដូចជាសមុទ្ទឥតទឹកវិប, ដូចជាការទុកជាក់ទ្រព្យសម្បត្តិ ប្រាសចាកបុគ្គលមានក្នែក, ដូចជាផ្ការបារិច្ចត្តកព្រឹក្ស ប្រាសចាកក្ខិនសុគន្ធា, រាជសម្បត្តិរបស់អាត្មាអញ ប្រាសចាកធម៌ទេសនា ក៏មិនល្អដូច្នោះឯង ។ ព្រះរាជាទ្រង់ព្រះបិន្ពនាការយ៉ាងនេះហើយ ទ្រង់ចាត់ឲ្យយកប្រាក់ ១ សែនកហាបណ: ដាក់ក្នុងប្រអប់មាស ដំកល់លើពោងដំរីមង្គលហត្ថីរាជពាហន: ហើយទ្រង់ឲ្យគោះគងទូងកេរី ឃោសនាតាមមហាវិថី ក្នុងក្រុងពារាណសីថានរណាបេះធម៌ ១ បទ ២ បទ ៣ បទ ៤ បទ, យើងនឹងឲ្យទ្រព្យក្នុងប្រអប់មាសនេះដល់អ្នកនោះ ។ ទុកជាឃោសនាដូច្នោះក៏ឥតមានប្រទះអ្នកបេះធម៌ សូម្បីតែ ១ បទព្រិះគាថាសោះ; ទើបទ្រង់បង្ក្រើនព្រះរាជទ្រព្យនោះដល់ពីរពាន់ បីពាន ប្ជនពាន់ មួយមុឹន មួយសែន មួយកោដិ ពីរកោដិ បីកោដិ ប្រាំកោដិ ប្រាំមួយកោដិ មួយរយកោដិ, មួយពាន់កោដិ, ទ្រង់ចាត់រាជបុរសឲ្យឃោសនា ផ្សាយដំណឹងនេះ គ្រប់ស្រុកតូចស្រុកធំនិគមជនបទ ផុតកំណត់ប្រិទេសដែលមានមនុស្សនៅទាំងប៉ុន្មាន ក៏ឥតបានធម៌សោះ; ទ្រង់លះបង់ស្ទេតច្ចត្រៃរាជសម្បត្តិ ព្រមទាំងឲ្ជនព្រះអង្គប្ជូរយកធម៌ទេសនាទ្រៀត ក៏នៅតែឥតមាននរណាអាចសំដែងថ្វាយបាន;

កាលបើរកធមិទេសនាមិនបានយ៉ាងនេះ, ទ្រង់មានវិបដិសារី សេចក្តីក្តៅក្រហាយក្នុងព្រះរាជហ្ឫទ័យ ព្រះបក្រីទ្រង់ព្រះចិន្តាគិតថា "មិនសមបើត្រូវការដោយរាជសម្បត្តិ ដែលប្រាសចាកធមិដូច្នេះសោះ" ទើបព្រះអង្គទ្រង់ប្រគល់រាជសម្បត្តិ ដល់ព្រះអង្គម្ចាស់ជាយុវរាជ ហើយទ្រង់ចូលទៅកាន់ព្រៃដើម្បីស្វែងរកធមិ ។

ក្នុងខណៈដែលព្រះបាទធម្មសោណ្ឌកមហារាជ ចូលទៅកាន់ព្រៃ ក៏កើតសេចក្តីក្តៅរំជួល ដល់ពិភពសម្តេចសក្កទេវរាជ ។ ព្រះឥន្ទកាលពិចារណារកហេតុនោះ ទ្រង់លាន់ព្រិះឧស្ឋថា យើ! នរណាហ្ន៉ ជាអ្នកចិញ្ចឹមមាតាបិតាត្រូអាចារ្យឬ? ឬជាអ្នកឲ្យទាន ឬជាអ្នកប្រព្រឹត្តព្រហ្មចរិយធមិ បានជាញ្ចាំងអញឲ្យកក្រើកចាកអាសនាដល់ម្ទ៉ះ? ព្រះឥន្ទលាន់ព្រះឧស្ឋដូច្នេះ ក៏ទ្រង់បើកសហស្សនេត្រ សង្កេតប្រមើលមើលមកក្នុងមនុស្សលោក, ទ្រង់បានឃើញព្រះបាទធម្មសោណ្ឌកៈកំពុងស្វែងរកព្រះធមិ ហើយចរចូលទៅក្នុងព្រៃ ទើបសម្តេចព្រះសហស្សន័យទ្រង់ព្រះចិន្តាគិតថា "ថ្ងៃនេះត្រូវតែអាត្មាអញ និម្មិតខ្ជូនទៅសំដែងអំពីជាតិ ជរាព្យាធិ មរណៈ សំដែងទោសក្នុងសកលសរីរៈ ដើម្បីបំភ្ជឺនូវអនិច្ចតាធមិ, សំដែងធមិផ្សង ៗ ទ្រៃត ដើម្បីបំភ្ជឺនូវអនិច្ចលក្ខណៈដល់ស្តេចនោះ ហើយ នាំទៅដំកល់ដល់ទីហានរបស់ព្រះអង្គវិញ; កាលទ្រង់ព្រះចិន្តាដូច្នេះស្រេចទើបស្តេចនិម្មិតខ្ជូនទៅជាយក្ស មកបិតនៅក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ។ ព្របាទធម្មសោណ្ឌករាជ ទ្រង់ព្រះចិន្តាថាយក្សនេះ ប្រហែលជាចេះធមិ; ហើយទ្រង់ចូលទៅបិតនៅក្នុងទីជិតគ្នា ទ្រង់ត្រាស់

ព្រះរាជឡង្ការចរចារាក់ទាក់ជាមួយនឹងយក្ស ហើយសួរយក្សថា បពិត្រ
អ្នកមានបញ្ញា អ្នកនៅនាជងព្រៃនេះ ចេះធមិដែរឬទេ? យក្សធ្វើយ
ថា បពិត្រមហារាជ ខ្ញុំចេះដែរ ។ ពោធិសត្វថា បើដូច្នោះ សូម
អ្នកសំដែងធមិឲ្យខ្ញុំស្តាប់ផងបានឬទេ? យក្សថា ខ្ញុំសំដែងឲ្យស្តាប់បាន
ប៉ុន្តែព្រះអង្គបូជាអ្វីដល់ខ្ញុំជាអ្នកសំដែង? ពោធិសត្វថា បើអ្នកត្រូវការ
ដោយត្រឹងសក្ការបូជា, ខ្ញុំស៊ីបូជាសាច់ឈាមរបស់ខ្ញុំ, បើដូច្នេះចូរអ្នក
សំដែងធមិឲ្យខ្ញុំស្តាប់មុនសិន រួចហើយសឹមអ្នកពិសាសាច់ខ្ញុំចុះ ។
យក្សត្អូញត្អែរថា បពិត្រមហារាជ ខ្ញុំឃ្ងានណាស់ មិនអាចសំដែងធមិ-
កើតទេ ។ ពោធិសត្វថា បពិត្រមហាយក្ស, បើអ្នកពិសាខ្ញុំមុនទៅហើយ
គើនរណានឹងស្តាប់ធមិ ។ យក្សត្អូញត្អែរចៃ ៗ ដដែល ៗ ថា ខ្ញុំឃ្ងាន-
ណាស់ សំដែងធម៌មិនកើត ។ ពោធិសត្វទំអង្វរការយក្សថា បពិត្រ
យក្ស បើដូច្នេះចូរអ្នកលៃសម្រួលដូចម្តេច ឲ្យខាងតែខ្ញុំបានស្តាប់ធមិផង
ឲ្យអ្នកបានសាច់ផង ។ ទើបសម្តេចសក្កទេវរាជ ដែលនិម្មិតខ្ជួនជាយក្ស
ទទួលព្រះរាជឡង្ការពោធិសត្វថា "ស្រួលហើយមហារាជ", ហើយ
ក៏និម្មិតជាក្នុំធំស្ទឹមស្តែកំពស់ ៣ តាវុត សុទ្ធសឹងថ្មជាដូចជ្ពាអញ្ជ៉ន ទើប
ត្រាស់ទៅកាន់ព្រះពោធិសត្វថា បពិត្រមហារាជ, ចូរព្រះអង្គឡើង
លើកំពូលក្នុំនេះ ហើយលោតមកតាមអាកាស ទម្ងាក់ខ្ជួនឲ្យចំមាត់ខ្ញុំ,
កាលដែលព្រះអង្គលោតមក, ខ្ញុំក៏សំដែងធមិឲ្យព្រះអង្គស្តាប់ដែរ, ក្នុង
រវាងដែលព្រះអង្គលោតពីកំពូលក្នុំមកដល់ម៉ាត់ខ្ញុំ ខ្ញុំសំដែងធមិបាន
ប៉ុន្មានមាត់ ធមិប៉ុណ្ណោះដែលព្រះអង្គត្រូវបានស្តាប់ ទាំងខ្ជួនខ្ញុំក៏បាន

សាច់បរិភោគភ្លាមបន្ទាន់ពេលជាមួយគ្នា ។ ព្រះបាទធម្មសោណ្ឌក-
មហារាជ ឭពាក្យយក្សនោះហើយក៏ទ្រង់ព្រះចិន្តាថា ក្នុងសង្សារវដ្ត
ដែលមិនមានកំណត់ខាងដើមខាងចុង រមែងមានសេចក្តីសូន្យចាកធមិ
មិនមានការគពប្រសប់ដោយធមិ, ព្រោះហេតុតែមិនបានសេពគប់នឹងធមិ
បានជាបណ្តាជនទាំងឡាយ តែងប្រព្រឹត្តអំពើទុច្ចរិតផ្សង ។ គឺសម្លាប់
សត្ត លួចប្លន់ធបំបាត់ទ្រព្យគ្នា ប្រព្រឹត្តកាមេសុមិច្ឆាចារ ពោលពាក្យ
មុសា សេពសុរានឹងមេរ៉ៃយ ខ្ទះមានចិត្តអាក្រក់ឥតមេត្តាត្រាប្រណី ហ៊ាន
សម្លាប់ជ្រូក សម្លាប់ទ្រាយ សម្លាប់ម្រឹត សម្លាប់បក្សី ហ៊ានចាប់
អម្រត់ប្រពន្ធអ្នកជទៃឥតកោតក្រែងរអែងចិត្ត; ជនបែបនេះ បើគិតត្រឹម
តែដំណក់លោហិត ដែលធ្លាក់អន្ទោលស្លាប់កើតក្នុងវដ្តសង្សារ ប្រាកដ
ជាច្រើនជាងទឹកក្នុងមហាសមុទ្ទទាំង ៤, ពុំនោះសោតទេ បើគិតត្រឹមតែ
ទឹកភ្នែក នៃមាតាបិតា ដែលធ្លាប់កើតក្នុងវដ្តសង្សារ សែក់ក្នុងវេលាយំ
សោកស្តាយកូនជាទីស្រឡាញ់ពេញចិត្តម្តង ។ ក៏ប្រាកដជាច្រើនជាងទឹក
មហាសមុទ្ទទាំង ៤ ដែរ, ដែលអន្ទោលទៅវិងធ្លាយយ៉ាងនេះ ព្រោះតែ
មិនបានស្តាប់ធមិ, បើដូច្នេះគួរតែអាត្មាអញលះបង់ជីវិត ដើម្បីឲ្យបាន
ស្តាប់ធមិ; ព្រោះជនអ្នកមានប្រាជ្ញាល្អ កាលដែលរលឹកនឹកឃើញថា
ធមិមានផលមានអានិសង្សច្រើន គេស៊ូលះបង់ទ្រព្យ ដើម្បីរក្សារាងកាយ,
លះបង់រាងកាយ ដើម្បីរក្សាជីវិត, លះបង់ទាំងទ្រព្យទាំងរាងកាយទាំង
ជីវិត ដើម្បីស្តាប់ធមិ ។ កាលព្រះបាទធម្មសោណ្ឌកមហារាជ ទ្រង់
ព្រះចិន្តាគិតដូច្នេះស្រេចហើយ ទ្រង់ឡើងក្នុំទៅបិតនៅចំខាងលើកំពូល-

ខ្ពស់សន្ធឹមត្រដឹមត្រដួច រួចទ្រង់ប្រកាសទៅគាថា ភោគ្គេ ទេវសង្ឃា បពិត្រពួកទេវតាដ៏ចំរើន, សូមអ្នកទាំងឡាយស្តាប់ពាក្យខ្ញុំ, ដ្បិតខ្ញុំបានប្រគល់ខ្លួនឲ្យយក្សដើម្បីស្តាប់ធម៌, ក៏កិច្ចដែលខ្ញុំធ្វើយ៉ាងនេះ ខ្ញុំមិនប្រាថ្នាសម្បត្តិមនុស្ស សម្បត្តិឥន្ទ សម្បត្តិព្រហ្ម សម្បត្តិសក្រ សម្បត្តិព្រះបច្ចេកពុទ្ធ សម្បត្តិចតុលោកបាល សម្បត្តិស្តេចចក្រពត្តិ សម្បត្តិទេវតាកន្លងកាមាវចរ ឬសម្បត្តិសោឡសព្រហ្មទេ, ឯការលះបង់ខ្លួនដើម្បីស្តាប់ធម៌នេះ ខ្ញុំប្រាថ្នាឲ្យបានត្រាស់ជាព្រះពុទ្ធតែម្យ៉ាង ។

គ្រានោះ ព្រះឥន្ទដែលនិម្មិតខ្លួនជាយក្ស តឿនកង្វើញដោយរួសរាន់ថា លោតមកមហាពាជ! ចូលព្រះអង្គលោតឲ្យចំមាត់ខ្ញុំមកកុំពាស់ឡើយ ។ ព្រះបាទធម្មសោណ្ឌកមហាពាជ ទ្រង់ត្រាស់ព្រះពាជនុផ្ការថា "បពិត្រមហាយក្ស, ចូរអ្នកសំដែងធម៌ចុះ ខ្ញុំនឹងជូនជីវិតខ្ញុំព្រមទាំងពាជ-សម្បត្តិដល់អ្នកឥតមានរួញរា ឲ្យតែបានស្តាប់ធម៌ទេសនា"; ក្សត្រទ្រង់មានព្រះពាជប្បាទ័យប្រកបដោយបីតិសោមនស្ស លោតហក់មកតាមអាកាសដោយឥតមានស្តាយជីវិតន្ទ្រិយ ។ សម្តេចសក្កទេវរាជិយ ពុំអាចដើម្បីទប់ទល់ព្រះអង្គបាន ទ្រង់ផ្សាយសម្ផស្សទិព្វទៅលើអាកាស ទទួលនូវព្រះពោធិសត្វជាប់ឮដ៏ព្រះឧក ហើយទ្រង់នាំព្រះពាជទៅកាន់ទេវលោក យកទៅដាក់ឲ្យគង់លើបណ្ដុកមណ្ឌលសិរោអាស្នាទិព្វ ទៀបគល់បារិច្ឆត្តកព្រឹក្ស ទ្រង់បូជាដោយទិព្វមាលា គ្រឿងសុគន្ធាផ្សេងៗ ហើយទ្រង់សំដែងធម៌ទេសនា ថ្វាយព្រះបាទធម្មសោណ្ឌកមហាពាជថា

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សង្ខារទាំងពួង ពិតជាមិនទៀងសោះ មានកិរិយាកើតឡើង នឹងសូន្យទៅជាធម្មតា កើតឡើងហើយរលត់ទៅវិញ, កិរិយារំលត់បង់នូវសង្ខារទាំងពួងនោះ ជាការនាំមកនូវសេចក្តីសុខ ។

អនិច្ចា សព្វសង្ខារា យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា[1]

បុគ្គលពិចារណាឃើញដោយប្រាជ្ញាថា "សង្ខារទាំងពួងមិនទៀង" កន្លងកាលឯណា, ក៏ខឿយណាយចំពោះសេចក្តីទុក្ខ កន្លងកាលនោះ; ការពិចារណាឃើញនូវសង្ខារ នឹងការខឿយណាយចំពោះសេចក្តីទុក្ខនេះ ជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធិ ។

អនិច្ចា សព្វសង្ខារា យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ភវេ ឯស មគ្គោ វិសុទ្ធិយា

បុគ្គលពិចារណាឃើញដោយប្រាជ្ញាថា "សង្ខារទាំងពួងមិនទៀង" កន្លងកាលឯណា, ក៏ខឿយណាយចំពោះភព កន្លងកាលនោះ; ការពិចារណាឃើញនូវសង្ខារនឹងការខឿយណាយចំពោះភពនេះ ជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធិ ។

---

๑ សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយាតិ វិសុទ្ធិមគ្គេ អាគតា ។

សម្តេចសក្កទេវរាជ សំដែងធម៌ថ្វាយព្រះបាទធម្មសោណ្ណកមហា-ពរាជហើយទ្រង់បង្ហាញសម្បត្តិទេវលោកសព្វគ្រប់ប្រការ ទ្រង់ត្រាស់ចំពោះព្រះបាទធម្មសោណ្ណកមហារាជថា "សេចក្តីប្រាថ្នារបស់ព្រះអង្គសម្រេចហើយ", ហើយទ្រង់សរសើរព្រះបាទធម្មសោណ្ណកតទៅទៀតថា បពិត្រមហារាជ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក មានព្រះនាមថាព្រះសមណគោតមបរមនាយក នឹងបម្រុងប្រជាជនឲ្យរួចចាកកក់ក្នុងអន្ធនរកឥតវង្គសង្សារ, ឥឡូវនេះសូមព្រះអង្គត្រឡប់ទៅកាន់មនុស្សលោកវិញចុះ ទៅរក្សាអាណាប្រជានុកស្តេចឲ្យបានសេចក្តីសុខសព្វ ៗ កាល, សូមព្រះអង្គមានសេចក្តីប្រតិបត្តិស្មើតាមគន្ធងមិ មានសេចក្តីសង្រួម មានការចំនាន់ខ្លួន, មិនយូរប៉ុន្មានទេទ្រង់នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតពុំខាន នឹងបានជាប្រយោជន៍ដល់សត្វទាំងអស់; សូមព្រះអង្គធ្វើបុណ្យដែលជាហេតុនាំមកនូវប្រយោជន៍ ដល់សត្វទាំងឡាយ, សូមព្រះអង្គរក្សាអាណាប្រជានុកស្តេចឲ្យបានសេចក្តីសុខសប្បាយ សព្វ ៗ កាលជាដរាបរៀងទៅ ។

សម្តេចសក្កទេវរាជ ត្រាស់ព្រះពរដូច្នេះហើយ ទ្រង់នាំព្រះបាទធម្មសោណ្ណកមហារាជ ចុះអំពីទេវលោក មកប្រតិស្ឋានក្នុងពរាជ-សម្បត្តិរបស់ព្រះអង្គវិញ ហើយទ្រង់ថ្វាយពរស័ព្ទសាធុការថា "ព្រះចន្ទនឹងព្រះអាទិត្យ បិតនៅដរាបណា, សូមឲ្យព្រះពរាជបិតនៅរក្សាពរាជសម្បត្តិដរាបនោះចុះ" ហើយព្រះឥន្ទ្រាធិពរាជ ទ្រង់ត្រាស់ព្រះពរាជឪ-

ចំពោះព្រះបាទធម្មសោណ្ឌកៈនោះត្រង់អប្បមាទធមិ រួចស្រេចទៃប
ស្ពេចត្រឡប់ទៅទេវលោកវិញ ។

តមត្ថំ បកាសេន្ពោ សត្ថា អាហ អង្គសម្ពេចព្រះបរមស្ថាស្ពាចារ្ស
កាលទ្រង់ប្រកាសសេចក្តីនោះទ្រង់ត្រាស់ថា សម្ពេចមយរា ជាធំជាង
ទេវតា សំដែងធមិទេសនាប្រៀនប្រដៅព្រះបាទធម្មសោណ្ឌកៈរួចហើយ
ទ្រង់ត្រឡប់ចូលទៅកាន់ទេវលោកវិញ ។ ចំណែកខាងព្រះរាជាធម្ម-
សោណ្ឌកៈ ត្រង់ធ្វើបុណ្យឲ្យទានមានប្រការផ្សង ៗ ជរាបដល់អស់ព្រះ
ជន្មាយុ ទ្រង់សោយព្រះទិវង្គតរលត់ព្រះជន្មទៅ បានទៅកើតក្នុង
ពិភពតុសិតស្ថរទេវលោកនាយ ។

អង្គសម្ពេចព្រះបរមសពេជ្ជសាស្ពាចារ្ស ទ្រង់នាំធមិទេសនានេះមក
សំដែងចប់សព្វត្រប់ហើយ ទ្រង់ប្រកាសនូវអរិយសច្ចទាំង ៤ ប្រការ,
ត្រាដែលចប់អរិយសច្ចទេសនា ក៏ពួកមនុស្សនឹងទេវតាជាច្រើន បាន
លុះមគ្គផលទីទៃ ៗ ផ្សង ៗ ត្នា, ទើបព្រះសាស្ពាទ្រង់ប្រជុំជាតកថា
សម្ពេចព្រះវររាជមាតាក្នុងកាលនោះ លុះចរិលរឹងមក បានជាព្រះសិរី-
មហាមាយា, ព្រះវររាជបិតា បានជាព្រះបាទសុទ្ធោទន, ព្រះឥន្ទ
បានជាអនុរុទ្ធ, ព្រះរាជមហេសី បានជានាងយសោធរា, រាជបរិសទ្យ
ទាំងឡាយ បានមកជាពុទ្ធបរិសទ្យ, ព្រះបាទធម្មសោណ្ឌកមហារាជ
គឺតថាគតជាលោកនាថ, អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ ធម្មសោណ្ឌកជាតកទី ១៨

ផ្នែកអក្សរសាស្ត្រ

ឧទ្រៀមហុចស្វាម៉ាត់

និង

ឧទ្រៀមរុំដើផស្រីចិនជាន់ដើម

អ្នកស្រីពេជ្រ-សល់ ហៅសារិះយ៉ាន់ ក្រុមជំនុំទំនៀមទម្លាប់

ប្រៀបរៀង

ឧទ្រៀមហុចស្វាម៉ាត់

ក្នុងពង្សាវតារវៀត-ណាម មានដំណាលថា នៅនគរអាណ្ណាម ក្នុងរាជ្យព្រះបាទ ហ៊ុង-យៀង មានបុរសពីរនាក់ជាបងប្អូននឹងគ្នា បុរសទាំង ២ នាក់នេះល្អដូចទេវតា ហើយស្រឡាញ់គ្នា យល់អធ្យាស្រ័យគ្នាដូចសត្វលលកញីឈ្មោល ។

ក្រោយមក បុរសច្បងមានប្រពន្ធ, ដោយស្រឡាញ់ប្រពន្ធពេក ក៏ក្រូចប្អូនដែលជាសាច់ឈាមជាមួយគ្នា ។ បុរសប្អូនអាក់អន់ចិត្តនឹងបងដែលលែងរវល់នឹងខ្លួន ក៏ដើរចេញពីស្រុកនោះ ដើម្បីនឹងទៅរកកន្លែងណាស្វាត់នៅជ្រកអាស្រ័យឲ្យសមតាមកាពដែលខ្លួនកើតទុក្ខ ។ បុរសនេះចេះតែដើរទាំងថ្ងៃទាំងយប់គ្មានឈប់សម្រាក ក្រូចបាយក្រូចទឹក មិនយូរប៉ុន្មានក៏ដួលស្លាប់នៅតាមផ្លូវ ។ យូរមកសាកសពនេះក៏រលួយនៅសល់តែធ្មឹងមួយគំនរតូច ធ្មឹងនោះក្លាយទៅជាថ្មកំបោរទៅ ។

ឯបុរសច្បងដែលមានប្រពន្ធ លុះបាត់ប្អូនមិនឃើញមកក៏មានសេចក្ត

ព្រួយពន់ពេក យូរមកក៏ដឹងខ្លួនថាខុស ទើបចេញចាកលំនៅទៅតាមរកប្អូន ។ ហាក់ដូចជាមានអ្វីមកបណ្តាលចិត្តឲ្យបុរសច្បងដើរទៅតាមផ្លូវដែលប្អូនទៅនោះ ។ ប្អូនច្បិ៉ាថ្ងៃក្រោយមក បុរសនេះអស់កម្លាំងដាច់អាហារដាច់ទឹក ក៏ដួលស្លាប់នៅជិតកន្លែងប្អូននោះដែរ ។ ប៉ុន្តែមុនទីងផុតជីវិត បុរសទំលួនគាល់តែទៅដល់ដុំថ្មកំបោរដែលជាជាតុរបស់ប្អូន ។ នៅកន្លែងដែលបុរសបងដួលស្លាប់ មានដុះដើមឈើមួយដើមមានស្លឹកទៅត្រង់ចុងដូចជាធ្នែ គឺជាដើមស្វា ។

រឯនាងច្បៃតន្ទាំប្តីយូរទៅ។ មិនឃើញប្តីត្រឡប់មកវិញ ក៏ដើរតាមទៅរកប្តី ។ លុះទៅដល់កន្លែងប្តីដែលអនិច្ចកម្ម នាងនោះអស់កម្លាំងខ្លាំងពេកដួលស្លាប់ទៅទៀត ។ នៅកន្លែងដែលនាងស្លាប់ គេឃើញដុះវល្លិមួយដើមតូច វល្លិនោះវារឡើងលើដើមស្វា គឺជាដើមម្លូនោះឯង ។

ក៏ប៉ុន្តែការណ៍ដែលថ្លែកគួរឲ្យធ្លុះក្នុងសាវតានេះ គឺថាមានឆ្នាំមួយនោះ កំឯរកភ្លៀងមួយដំណក់គ្មានសោះ ព្រៃឈើតំងអំបាល្ម៉ាន ស្មោកត្រៃម ខ្ចោចអស់ ដោយអំណាចកំដៅថ្ងៃ ។ ចុះហេតុអ្វីដើមស្វាហើយនឹងដើមម្លូនៅមានជីវិតស្រស់ញញឹម ស្លឹកនៅមានពណ៌ខ្ចីវក់ធ្វើឲ្យឃើញភាពផុយគ្នាស្រឡះអំពីព្រៃឈើផងតំងពួង ។

ន៥ ការថ្លែកនេះធ្វើឲ្យអ្នកស្រុកជិតឆ្ងាយធ្លុះ ហើយនាំគ្នាផ្តើលទៅមើលកុះករតំងច្រាសតំងស្រី ។ ដំណឹងថ្លែកនេះមិនសូវស្ងាត់ក៏ជាបទៅដល់ព្រះបាទហ៊ុន-យឿង ។ ទ្រង់មានព្រះទ័យចង់ទតឲ្យឃើញច្បាស់នឹងព្រះនេត្រ ទើបបង្គាប់ឲ្យរៀបក្បួនដង្ហែព្រះអង្គឆ្ពោះទៅកន្លែងនោះ ។

កាលទ្រង់យាងទៅដល់កន្លែងនោះហើយ ទ្រង់គ្រាស់បង្គាប់ឲ្យយាយតាចាស់ៗ និងនរឿងហេតុនៃដើមឈើនោះថ្វាយទ្រង់ស្តាប់ ។ ដើម្បីនឹងបញ្ជាក់ឲ្យច្បាស់ទ្រង់បង្គាប់ឲ្យបេះស្វឹកមួយ នឹងផ្លែស្វា នឹងកំបោរថ្មបន្តិចមកបុកលាយគ្នា ស្រាប់តែមានចេញពណ៌ក្រហម អំពីវត្ថុទាំងបីមុខនោះ ។ លុះទ្រង់យល់ច្បាស់ដូច្នោះ ព្រះអង្គក៏គ្រាស់បង្គាប់ឲ្យអ្នកស្រុកជាំដើមស្វានឹងមួយនៅគ្រប់មុខផ្ទះ ព្រោះដើមនោះជាតំណាងនៃសេចក្តីស្នេហាមួយយ៉ាងស្មោះ ។

មិនតែប៉ុណ្ណោះទ្រង់បង្គាប់ដល់បណ្តាជនទាំងឡាយថា បើអ្នកណារៀបមង្គលការកូនចៅ ត្រូវឲ្យអ្នកសាមីខ្លួនទាំងប្រុសទាំងស្រីប្តូរស្វាម៉ាត់គ្នាទៅវិញទៅមក ជាប្រស្នាមួយឲ្យយល់ថាថ្ពីប្រពន្ធត្រូវមានសេចក្តីស្នេហា ហើយមានចិត្តសន្តោសគ្នាទៅវិញទៅមក ។ ក្រោយមករឿងនេះក៏ទៅជាទំនៀមទំលាប់របស់អ្នកស្រុកមួយទៅ ។

ទំនៀមហុចស្វាម៉ាត់ក្នុងពេលរៀបមង្គលការនៃជនជាតិយួននេះប្រហែលគ្នានឹងទំនៀមខ្មែរយើង ក៏ប៉ុន្តែក្នុងទំនៀមខ្មែរ ស្វាម៉ាត់ជារបស់បញ្ជាំចិត្ត នឹងតំណាងពាក្យសត្យទៅវិញ ។ តែដោយបុរសសម័យឥឡូវមិនចេះបរិភោគស្វា ចាស់ៗក៏អនុញ្ញាតឲ្យយកថ្មារមកជំនួសវិញ ។

ចំពោះរឿងស្វាម៉ាត់ខ្មែរ មានតំណាលថា កាលដែលព្រះថោងបានមកតាំងនៅលើកោះគោកចក ព្រះថោងបានជួបនឹងស្រីម្នាក់ដែលជាព្រះរាជបុត្រីស្តេចកុជង្គនាគ ។ នាងនឹងព្រះថោងក្រោយដែលបានសាកសួរគ្នាទៅវិញទៅមក ក៏សុខចិត្តព្រមស្ម័គ្រទទួលគ្នាជាគូដំរែត ។ តែព្រះនាង

ដោយមិនហ៊ានកន្ធងប្រវេណី ក៏សុំលាព្រះថោងទៅទូលព្រះបិតាវិញ ។ ព្រះថោងមិនជឿក្រែងនាងកុហក មិនព្រមលែងឲ្យនាងទៅសោះ ទាល់តែនាងទូលព្រះអង្គថា "បើព្រះអង្គមិនជឿបិត្តខ្ញុំម្ចាស់ ។ សូមទុកស្ទាមួយម៉ាត់ជាពស្ត្ថាង ម្យ៉ាងទៀតសូមទ្រង់ជ្រាបថាពួកអ្នកនគរខ្ញុំម្ចាស់ឯណោះគេកាន់ពាក្យសត្យណាស់ បើពុំជូច្នោះទេ នគរនឹងសាបសូន្យជាពុំខាន" ព្ធជូច្នោះហើយទើបព្រះថោងសុខចិត្តឲ្យនាងទៅតែឯង ។

ទំនៀមរុំដើងស្រីកិនជាន់ដើម

មានជំណាលថា កាលណោះព្រះបាទជេអ៊ូបានរៀបអភិសេកព្រិះនាងតា-គី ដែលជាបុត្រីនៃព្រះអង្គម្ចាស់ស៊ូ ។ អគ្គមហេសីនោះជាក្សត្រីកាច ព្រះទ័យអាក្រក់ នាំឲ្យព្រះស្ទាមីប្រព្រឹត្តអំពើអយុត្តិធមិ នឹងអំពើលាមកជាច្រើនយ៉ាងចំពោះអ្នកអមព្រះអង្គនឹងអាណាប្រជានុរាស្ត្រ ។ ព្រះនាងតាគី ចេះតែនឹករកបង្កើតគ្រឿងប្រហារគ្រប់យ៉ាងគួរឲ្យខ្ទាចក្រៃពេក មានតាំងពីឆ្នាំងអ៊ុតកាន់ទៅរលាករលួយដៃ ដល់ទៅសសរសំរិទ្ធជុតឲ្យទាល់តែក្រហមសំរាប់គាបរដ្ឋមន្ត្រីណាក្សត់ ។ មានរណ្តៅពស់ពឹសសំរាប់ទម្ងាក់ស្រីក្រសាលរបស់ព្រះរាជាដែលមានទោស ។ ជួនកាលដោយចង់ឃើញទារក ដែលនៅក្នុងផ្ទៃមាតានៅទ្បើយ ព្រះនាងតាគីបង្គាប់ឲ្យស្ទេចវះពោះស្រីដែលមានគភិថែមទៀតផង ។ ពួកប្រជារាស្ត្រក្តៅក្រហាយទ្រំពុំបាន ក៏នាំគ្នាបះបោរប្រឆាំងនឹងព្រះរាជា ហើយព្ធួតគ្នាចាប់ស្ទេចយកទៅជុតទាំងរស់ ព្រមទាំងកាត់ព្រះសូរងព្រះអគ្គមហេសី

ចោលផង ។ រូបបណ្ណាកស្ត្រក៏ប្រតល់អំណាចទៅជូនលោកអ្ហ-ក៉ង ដែលជាអ្នកផ្តើមបង្កើតព្រះកជវង្សដែអ្ហ ។

ព្រះនាងតា-គី កាលពីមិនទាន់មានព្រះស្វាមី ជាក្សត្រីកុមុំមួយ ព្រះអង្គ មិនមែនត្រាន់តែប្រកបដោយរូបធោមល្អធើតប៉ុណ្ណោះទេ ព្រះនាងជាក្សត្រីប្រកបដោយគុណធមិល្អវិសេស ខាងមើលការខុសត្រូវក្នុងត្រួសារ ។ ចុះហេតុដូចម្តេចបានជាព្រះនាងដល់បានធ្វើជាឯកអគ្គ-មហេសី ក៏ទៅជាកើតចិត្តបុស្សាត្មានមេត្តាករុណាដល់បណ្ណាជន ទាល់តែមានជាប់ឈ្មោះជាស្រីចិត្តអាក្រក់ដល់សព្វថ្ងៃនេះ? ។

ការណ៍ដែលនាំឲ្យមានរឿងក៉វយ៉ាងនេះ មាននិទានថា កាលមុន នឹងរៀបអភិសេកព្រះនាងតាគីជាអគ្គមហេសី, ព្រះបាទដែអ្ហ បានស្តេចយាងទៅបូជនីយស្ថានឯវត្តព្រះអាទិទេព នៀ-មូអា គឺព្រះអាទិទេពនេះ ហើយដែលបានបង្កើតលោកឲ្យមានសការៈដូចសព្វថ្ងៃនេះ ។ ព្រះកជា កាលស្តេចយាងទៅដល់ទេវរូបដែលមានភាព ហាក់ដូចជារូបរស់នោះ ព្រះអង្គក៏មានព្រះទង្ការ ក្រសាលដោយត្មានសេចក្តីគោរពបន្ទិចបន្ទួចសោះ ថែមទាំងប្រាថ្នាចង់បានព្រះអាទិទេពនេះ មកនៅក្នុងរង្គសាល (រាងកំ) របស់ព្រះអង្គផង ។

សំដីអកុសលនេះធ្វើឲ្យមហាក្សត្រ ដែលត្មានសេចក្តីពិចារណាបាត់នូវម្ភុជកជ្ស ។ ដើម្បីនឹងសងសឹកដល់សំដីមើលងាយបែបនេះ ព្រះអាទិទេពប្រើកញ្ជោងទេព្តាមួយឲ្យទៅស៊ីព្រលឹងរបស់ក្សត្រី តា-គីនៅពេលដែលគេដង្ហែព្រះនាងពីដំណាក់ព្រះបិតាទៅព្រះបរមរាជកំង ។ ចាប់តាំងពីពេល

នោះមក អាត្ថ្នូនរបស់កញ្ជោងទេព្តាដែលជាអ្នកសង់សឹក រស់នៅក្នុងរូប
របស់ព្រះនាង តា-ឥ ។ ឯព្រះនាង តា-ឥ ពិតមែនជាក្សត្រីប្រកប
ដោយគុណសម្បត្តិល្អវិសេសនៅស្រុកតូហូនោះ ស្ទាប់ជាត់ទៅហើយ
ដោយព្រះអាទិទេពប្រើកញ្ជោងទេព្តាឲ្យមកស៊ីព្រលឹងនាង ។ ការ
សង់សឹកនេះមិនមែនធ្វើត្រឹមតែរូបព្រះនាង តាឥ ១ នេះទេ អាទិទេពមួយ-
ទៀតជានមកក្លែងខ្លួនជាស្រីបំរើនៃព្រះរាជា ឈ្មោះហូ-ហ៊ុ-មី ជាស្រី
ដែលមានឈ្មោះល្បីមួយក្នុងសាវតារចិនមកជាជំនួយផង ស្រីនេះជាមាន់
ព្រៃទេព្តា ។ ដើម្បីនឹងបង្ហាញចិត្តអាក្រក់នៃអាទិទេពម្នាក់ ហើយនឹង
អំពើមាយារបស់អាទិទេពមួយទៀត ពង្សាវតារឲ្យដារទៅអ្នកទីមួយថា
"កញ្ជោងទេព្តា" ទៅអ្នកទី ២ ថា "មាន់ព្រៃទេព្តា" ។ ព្រះអាទិទេព
ដែលក្លែងខ្លួនជាមនុស្សស្រីមកបំរើព្រះរាជានោះ មានដើងជាមាន់ព្រៃ
ជាសត្វកញ្ជោង ។ ស្រីទេពនិម្មិតនេះ ដោយចង់លាក់កុំឲ្យគេដឹង
ថាខ្លួនមានដើងយ៉ាងនេះ ទើបយកខ្សែសំពត់ព្រៃមករុំបំជាត់តាង ។ ស្រី ។
ចិនកាលជានឃើញហើយក៏សំគាល់ការរុំដើងនោះ ថាជារបៀបមួយ
ធ្វើឲ្យមានលំអ សម្រាប់ស្ត្រីជាន់ខ្ពស់ ទើបនាំគ្នារុំដើងតាម ជាប់តជា
ទំនៀមមក ។ នៅសព្វថ្ងៃនេះ ជនជាតិចិនតែងទុកសត្វកញ្ជោង ថាមិន
មែនជាសត្វលោកធម្មតាដែលយើងស្គាល់នេះទេ គឺជារូបទេវតាទៅវិញ ។
តាមរឿងព្រេងចិន កញ្ជោងជាសត្វអាថិកំជាំងដែលគេតែងតែខ្ទាប
ដោយរាធ្វើឲ្យកើតអន្ពរាយ ជាសត្វដែលមានជីវិតដល់ទៅមួយពាន់ឆ្នាំ
ដល់គំរប់អាយុប៉ុណ្ណោះ កញ្ជោងនឹងត្រូវជានទៅនៅទេវលោក ។

ឧឿងសាមកុក

កណ្ឌទី ៦៦

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រែជៀបជៀង

(តមក)

ជឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងដ៉ៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ទានស្នេហាជាតិ ។

ស៊ុនហុកជំរាបចូធូថា ដែលគួនអ៊ូព្រមទទួលប្តេជ្ញានឹងលោកគ្រានេះ ខ្ជាបជាកលឧបាយទេដឹង ។ ចូធូតបថា គួនអ៊ូជាមនុស្សមានសេចក្តីសត្យសុចរិតត្រង់ណាស់ ទោះបីយ៉ាងណា ក៏មិនមែនគិតជាកលឧបាយបញ្ជោតយើងទេ ។

ខណៈកាលកងទ័ពចូធូថយអស់ទៅ គួនអ៊ូក៏នាំទាហានរបស់ខ្លួនចូលទៅក្នុងស្រុកហេហ្ជឺ ឃើញបណ្តាកស្រ្ពទាំងឡាយនៅជាប្រក្រតី ក៏ចូលទៅគំនាប់បងថ្ងៃទាំង ៦ ហើយថា ខ្ញុំបាទថ្ងៃះការគ្រានេះ ធ្វើឲ្យបងទាំង ៦ កិតក័យបានសេចក្តីព្ឌួយរំខាននោះ ទោសខ្ញុំបាទខុសជាទម្ងន់ណាស់ ។

បងថ្ងៃទាំង ៦ ក៏ស្ងរថា ប្អូនបានព្ធជំណឹងថា បងប្រុសអ្នកខ្ជាត់ក្ជាត់ទៅនៅឯណា ? ។ គួនអ៊ូធ្វើយថា ខ្ញុំបាទមិនបានដឹងព្ធសោះឡើយ ។

បងថ្លៃក៏សួរថា ចូតូបានស្រុកហៅហ្នឹងហើយប្អូននឹងរិះគិតយ៉ាងម៉េច? ។ គួនអ៊ូក៏អធិប្បាយសេចក្តីឲ្យបងថ្លៃទាំង ២ ស្តាប់គ្រប់ប្រការ ហើយថាឥឡូវនេះខ្ញុំបាទចូលមកប្រឹក្សាផងតើបងទាំង ២ នឹងយល់ឃើញដូចម្តេច? ។ នាងកាំហ៊ូមិនឆ្លើយថា កាលពីយប់មិញចូតូចូលមកកន្លែងស្រុកបាន បងក៏ទឹកភ័យខ្លាចក្រែងនឹងមានអន្តរាយផ្សេងៗតែថាគេដុះបុណ្យវាសនារបស់យើងបណ្តាលឲ្យចូតូមានចិត្តឈឺឆ្អាលកំជាប់សេនាគាហាន មិនឲ្យចេញចូលមកប្លែកមិនបានទេ ត្រានេះបងនឹងប្អូនក៏នៅកន្លែងកណ្តាប់ដៃចូតូហើយ បើប្អូននឹងព្រមចូលនៅនឹងគេក៏នៅចុះតែដោយសេចក្តីពាល់ ប៉ុន្តែបារម្ភខ្លួយ ថាបើយើងដឹងជាបងអ្នកនៅទីឯណា យើងនឹងនាំគ្នាទៅរកបង ខ្លាចចូតូមិនព្រមបើកឲ្យទៅ ។

គួនអ៊ូតបថា "ឯនេះកុំឲ្យបងទាំង ២ ព្រួយបារម្ភឡើយ បើប្រសិនជាយើងដឹងថាឡៅពីជាបងនៅទីឯណា យើងក៏ត្រូវនាំគ្នាទៅរក ពោះបីចូតូនឹងឃាត់ខាំងខឹងតស៊ូយ៉ាងម្តេច ខ្ញុំបាទនឹងរិះគិតកែវឲ្យត្រាតែបាន" ហើយគួនអ៊ូក៏លាបងថ្លៃទាំង ២ នាំគាហានប្រហែល ៣០ នាក់ ចេញទៅជល់មុខបន្ទាយចូតូ។ ឃើញគួនអ៊ូមកជល់ ក៏មានសេចក្តីត្រេកអរណាស់ ចេញទៅទទួលគួនអ៊ូចូលមក គួនអ៊ូក៏គំនាប់ចូតូហើយថា ខ្ញុំបាទជាស្នើយលោកៗមិនសម្ងាប់ជីវិតហើយចេញទៅទទួលខ្ញុំបាទដល់ត្រើយបន្ទាយទៀតព្រះគុណនឹងរកទីបំផុតគ្មាន ។

ចូតូបានស្តាប់ដូច្នោះក៏និយាយនឹងគួនអ៊ូថា យើងក៏បានដឹងច្បាស់ថាអ្នកជាមនុស្សមានសេចក្តីសត្យាតញ្ញូប្រសើរណាស់ ឥឡូវយើងនឹងអ្នក

ឋានមកយើញមុខគ្នា យើងក៏មានសេចក្តីត្រេកអរ ។ ឆ្លងអ៊ីតបថា
តៀវលៀវទៅ ឲ្យាប់ខ្ញុំបាទថា មហាឧបាជទទ្លួលបដិញ្ញាណតាំង ៣
ប្រការហើយ ខ្ញុំបាទក៏ទទ្លួលត្រេកអរជាទីបំផុត ព្រោះថា អំណើះយូរ
ទៅ មហាឧបាជក៏មិនភ្ងេចពាក្យសំដី ។

ចូធូថា ខ្ញុជ្ញារបស់អ្នកនោះ យើងបានចេញវាចាទទ្លួលព្រមហើយ
ទោះបីយ៉ាងណាយើងក៏មិនឲ្យបង់វាចា ។ ឆ្លងអ៊ីបានស្តាប់ហើយក៏មាន
សេចក្តីត្រេកអរណាស់ ហើយថា បើខ្ញុំបាទឌ្ឍដំណឹងថា ឲ្យៅពីនៅទីឯ
ណា ទោះបីជាផ្ទូវជាច់ស្រយាលត្រូវហែលធ្ងងមហាសមុទ្រប្ដលុយភ្ងើងក្តី
ខ្ញុំបាទនឹងព្យាយាមតាមទៅរកឲ្យៅពីឲ្យឃើញ ទោះបីខ្ញុំបាទមិនទាន់លា
មហាឧបាជក្តី ក៏សុំឲ្យមហាឧបាជអភ័យទោសខ្ញុំបាទ កុំមានសេចក្តី
ប្រកួតប្រកាន់ត្រង់ខនេះឲ្យើយ ។ ចូធូថា "បើអ្នកដឹងដំណឹងឲ្យៅពី
ហើយនឹងទៅរកក៏ទៅចុះ ឥតត្រូវឲ្យត្រិះរិះមើលឲ្យឃើញកល់ការគ្លរទៅ,
សឹមទៅ" និយាយហើយចូធូក៏ឲ្យរៀបតុលៀងអាហារឲ្យឆ្លងអ៊ីបរិភោគ
ហើយថា ព្រឹកនេះយើងនឹងលើកកងទ័ពត្រឲ្យប់ទៅក្រុងហ្ចីតោវិញ ។

ឆ្លងអ៊ីចូលទៅដំរាបបងថ្ងៃហើយ ក៏រៀបចំរបស់ទ្រព្យបំរុងការជា
ស្រេចហើយត្រឲ្យប់មកវិញ ។ លុះពេលព្រឹកព្រហាម ចូធូក៏លើកទ័ព
ចេញទៅ ឆ្លងអ៊ីក៏រៀបចំឲ្យបងថ្ងៃតាំង ៦ ឲ្យើងជិះរថតាមកងទ័ពចូធូទៅ,
រវលាយប់បានទៅដល់ឈប់នៅទីសំណាក់តំបន់ណា ចូធូក៏ឲ្យឆ្លងអ៊ីនឹង
ការិយាឲ្យៅពីតាំង ៦ នាក់នោះដេកនៅក្នុងផ្ទះសំណាក់ជាមួយគ្នា ប្រាថ្នា

ទឹងឲ្យគួនអ៊ូធ្វើអាក្រែកន់ទឹងបងថ្លៃ ដើម្បីឲ្យប្រែចិត្តលែងគិតអាល័យឡៅពី ទឹងបានជាទឹកមុខស្រឡះដល់ខ្លួន ។

ឯគួនអ៊ូឲ្យបងថ្លៃតាំង ២ ដេកលែងខាងក្នុង ខ្លួនអង្គុយដុតទៀនមើលសំបុត្ររាំងរក្សាបងថ្លៃនៅព័ត្រែកែវ្យាគាល់តែភ្លឺ មិនមានធ្វេសប្រមាទដល់ ១ វេលាឡើយ ។ លុះឡៅដល់ក្រុងហ៊ូគោ ចូរួចដឹងដូច្នោះក៏ខ្វាចចិត្តគួនអ៊ូថា មានសេចក្តីសត្យកតញ្ញូដល់ឡៅពីជាច្រើនណាស់ ។ ចូរួចក៏ចាត់ឲ្យគួនអ៊ូនឹងការយាឡៅពីទៅនៅលើផ្ទះតឹក ២ ខ្នង មានស្ថានដើរឆ្ងាយកណ្តាល ។ គួនអ៊ូក៏រៀបចំឲ្យបងថ្លៃតាំង ២ នៅកងតឹក ១ ហើយឲ្យទាហានដែលចាស់ជំពូកនៅយាមរក្សាប្រហែល ១០ នាក់ ខ្លួនគួនអ៊ូនៅតឹក ១ រាំងរក្សាបងថ្លៃតាំង ២ ។

លុះនៅមកកងថ្ងៃ ១ នោះ ចូរួចក៏នាំគួនអ៊ូចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេ ហើយយកសេចក្តីក្រាបបង្គំទូលស្ទើសរសើរថា គួនអ៊ូនេះមានថ្វីដៃខ្លាំងពូកែលុមសមគួរទឹងឲ្យធ្វើជានាយទាហានបាន ។ ព្រះចៅហៀនតេ ក៏មានព្រះពាជហ្ឬទ័យសោមនស្សត្រាស់តាំងគួនអ៊ូជានាយទាហាន ។ ចូរួចទឹងគួនអ៊ូថ្វាយបង្គំលាមកទីលំនៅវៀងខ្លួន រួចចូរួចក៏ឲ្យអញ្ជើញគួនអ៊ូទៅបរិភោគអាហារ ចាត់ចែងទីមង្គុយឲ្យគួនអ៊ូអង្គុយខ្ពស់ជាងមន្ត្រីតាំងពួងហើយឲ្យចំណាប់ជាគ្រឿងមាសទឹងគ្រឿងច្រាក់ទឹងវែយ៉ាងល្អដល់គួនអ៊ូជាច្រើន ។ គួនអ៊ូទទួលយកវបស់តាំងនោះហើយ ក៏លាចូរួតឡប់មកកាន់ទីតេហដ្ឋាន បាននាំសេចក្តីនោះទៅលាស្រាយកងរឿងច្រាប់បងថ្លៃស្តាប់ ហើយប្រគល់វបស់ទ្រព្យតាំងអស់ឲ្យទៅបងថ្លៃ ។

ឯចូធូទំនុកបំរុងគួនអ្ហិមិនឲ្យអនាទរ ៣ ថ្ងៃរៀបអាហារកោជនយក
ទៅឲ្យគួនអ្ហិម្ពង ៥ ថ្ងៃឲ្យម្ពង ហើយចាត់ស្រីក្រមុំរូបល្អស្អាត ១០ នាក់
ឲ្យទៅនៅបដិបត្តិបំរើគួនអ្ហិ ប្រាថ្នានឹងចងចិត្តគិតឲ្យគួនអ្ហិវង្វេងដោយកាម-
គុណ ។ គួនអ្ហិក៏នាំស្រីទាំង ១០ នាក់ទៅប្រគល់ឲ្យបងថ្ងៃប្រើប្រាស់
លុះគំរប់ ៣ ថ្ងៃទើបគួនអ្ហិទៅសួរសុខទុក្ខម្ពង អង្គុយពីក្រៅមាត់ទ្វារហើយ
សួរថា បងបានសេចក្តីសុខសប្បាយជាទេឬប្រការម្តេច? ។ បងថ្ងៃថា
សុខសប្បាយជាទេ ចុះប្អូនបានព្ធដំណឹងឡៅពីបងអ្នកឯងនៅឯណា? ។
គួនអ្ហិថា មិនដឹងទេ ហើយក៏គំនាប់បងថ្ងៃវិលមកវិញ ។ ចូធូព្ធដំណឹង
ថា គួនអ្ហិប្រតិបត្តិបងថ្ងៃដោយសុចរិតជូច្នោះក៏សរសើរគួនអ្ហិថា មាន
សេចក្តីសត្យពិតត្រង់នឹងរកនរណាស្មើគ្មាន ។

ថ្ងៃមួយ ចូធូឲ្យអញ្ជើញគួនអ្ហិទៅបរិភោគអាហារ ឃើញគួនអ្ហិពាក់
អាវរហែក ចូធូក៏យកអាវ ១ យ៉ាងល្អមកឲ្យគួនអ្ហិ គួនអ្ហិទទួលយកអាវ
នោះមកពាក់ពីក្នុងអាវចាស់ ផ្ទាស់យកអាវចាស់ពាក់ពីលើ ។ ចូធូឃើញ
ជូច្នោះក៏អស់សំណើច ហើយសួរថា ហេតុម្តេចបានជាយកអាវថ្មីទៅ
ពាក់ពីក្នុង ឬខ្វាចអាវថ្មីធាប់ចាស់ ។ គួនអ្ហិជំរាបថា អាវចាស់នេះជា
របស់ឡៅពីឲ្យ ឥឡូវឡៅពីខ្ចាត់ក្ខាត់មិនដឹងជាទៅទីណា ខ្ញុំបាទមិនដឹង
សោះ បានជាពាក់អាវនេះពីក្រៅដើម្បីនឹងមើលជំនួសខ្ជួនឡៅពី បើ
នឹងយកអាវថ្មីពាក់លុបពីក្រៅ មនុស្សទាំងពួងនឹងគរហានិន្ទាថាបានថ្មី
ចោលចាស់ ។ ចូធូបានព្ធជូច្នោះក៏សរសើរគួនអ្ហិថា មានសេចក្តីកតញ្ញូ
ណាស់ ត្រនឹកតូចចិត្តនឹងខ្ជួនឯង ។ គួនអ្ហិលាត្រឡប់ទៅផ្ទះវិញ ។

លុះនៅមកថ្ងៃ ១ ស្រីបំរើមកប្រាប់គួនអ៊ូថា ឥឡូវបងថ្ងៃទាំង ២ កំពុងវៃយំសោកស្រណោះគ្នា ដោយហេតុអ្វីមិនបានដឹងច្បាស់ ។ គួនអ៊ូភ័យណាស់ក៏សួរទៅស្ងរពីក្រៅទ្វារថា បងទាំង ២ យំសោកដោយហេតុអ្វី? ។ នាងកាំហ៊ូយិនធ្វើយតបថា ពីយប់មិញបងយល់សប្តិឃើញឡៅពីធ្នាក់អន្ទុងដួលចុះ លុះភ្ញាក់ឡើងក៏ភ័យស្ទុតចិត្ត ទើបដាស់នាងប៊ីហ៊ូយិនឲ្យជួយស្រាយនិមិត្តនោះ ក៏យល់ព្រមគ្នាថាឡៅពីស្ទាប់ហើយបានជាបងយំសោក ។ គួនអ៊ូបានស្តាប់ដូច្នោះក៏ពិគ្រោះឃើញថាយល់សប្តិនោះវ្ងែកក៏សំគាល់ថាឡៅពីនឹងអន្តរាយជាប្រាកដក៏យំសោកជាមួយគ្នា ហើយគួនអ៊ូក៏គិតឧបាយនិយាយប្រាប់បងថ្ងៃទាំង ២ ដើម្បីនឹងឲ្យរសាយសេចក្តីទុក្ខសោក ទើបថានិមិត្តនេះនឹងសំគាល់យកជាប្រាកដមិនបាន ព្រោះបងទាំង ២ មានចិត្តគិតនឹកដល់ឡៅពីមិនភ្ងេច ទើបបណ្តាលឲ្យនិមិត្តមិនល្អដូច្នេះ មិនមែនឡៅពីនឹងអន្តរាយដូចយល់សប្តិដូច្នោះទេ បងទាំង ២ កុំសៅសោកជាទុក្ខពេកឡើយ ។ ទទួលមានបំរើចូធូមកប្រាប់គួនអ៊ូថា មហាឧបរាជប្រើខ្ញុំឲ្យមកអញ្ជើញលោកទៅ ។ គួនអ៊ូក៏លាបងថ្ងៃទៅរកចូធូ ។ ឃើញគួនអ៊ូមានទឹកមុខសៅហ្មង ក៏ស្ងរថាថ្ងៃនេះឃើងឃើញអ្នកមិនសប្បាយ តើអ្នកមានព្ឱយពីហេតុអ្វី? ។ គួនអ៊ូជំរាបថា បងថ្ងៃខ្ញុំបាទទាំង ២ នឹការលឹកដល់ឡៅពី ព្រោះមិនបានដឹងថាជារស់ឬស្ទាប់ បបួលគ្នាយំ ខ្ញុំបាទក៏អត់ត្រាំពុំបានស្រក់ទឹកភ្នែកតាមទៅ ។ ចូធូបានព្ទដូច្នោះក៏និយាយលួងលោមគួនអ៊ូ ហើយបបួលឲ្យបរិភោគអាហារ ប្រាថ្នានឹងឲ្យរលាយទុក្ខសោក ។ គួនអ៊ូផឹកស្រាស្រវឹង

មនស្សវ៉ៃគាតភ្ញាចប្អូន យកដៃចាប់ប្អូតពុកមាត់របស់ខ្លួនហើយថា តើត មកជាប្រុសមិនបានទំនុកបំរុងផែនដី សូម្បីឡៅពីជាបងក៏មានគុណ-បការជាមួយ បើនឹងប្រែចិត្តគិតក្បត់ទៅវិញក្នុងគ្រានេះ ក៏អស់មាន នរណានឹងរាប់អានថាជាប្រុសតទៅ ។ ប្អូនបានស្តាប់ពុក៏គិតថា "គួនអ៊ូ នៅមានចិត្តសុចរិតពិតត្រង់ឯណាឡៅពីណាស់" ប្អូនធ្វើជាមិនឮហើយ ក្លែងសួរគួនអ៊ូថា ពុកមាត់របស់អ្នកប្រហែលប្រមាណសរសៃ ។ គួនអ៊ូ ថាពុកមាត់ខ្ញុំបានប្រហែល ៣០០ សរសៃ តែដល់ដូរវាងាកក៏ដុះទៅខ្លះ ខ្ញុំបានក៏មានធ្មេចង់ជាក់ ។ ប្អូនបានស្តាប់ក៏ចូលទៅយកកែសយ៉ាងល្អ ឲ្យធ្មេចង់ហើយយកមកឲ្យគួនអ៊ូជាក់រងពុកមាត់ ។ គួនអ៊ូទទួលយកចង់ មកហើយក៏លាប្អូនត្រឡប់ទៅផ្ទះវិញ ។

លុះវេលាព្រឹក គួនអ៊ូចូលទៅគ្រាបបង្គំគាល់ព្រះចៅហៀនតេ។ ទ្រង់ទតព្រះនេត្រឃើញគួនអ៊ូព្យរចង់រងពុកមាត់ដូច្នោះ ក៏ត្រាស់សួរថា ចង់ជាក់របស់អ្វីព្យរទៅកនោះ? ។ គួនអ៊ូក្រាបទូលថា "ចង់នេះមហា-ឧបរាជឲ្យទូលព្រះបង្គំជាខ្ញុំសម្រាប់ជាក់រងពុកមាត់" ហើយគួនអ៊ូក៏ដោះថ្វាយ ។ ព្រះចៅហៀនតេទតឃើញពុកមាត់គួនអ៊ូវែងដល់ដើមទ្រូង សរសៃស្អិតល្អស្មើគ្នា ក៏ត្រាស់សរសើរថា "អ្នកឯងមានពុកមាត់ល្អ ណាស់" ទើបព្រះរាជទានឈ្មោះហៅថា "ប៊ុយយ៉ែងកុង" ប្រែថា "អ្នកពុកមាត់ល្អ" ហើយស្តេចយាងចូលទៅវិញ ។

ប្អូនទីឯនាហ៊ីនមុខមន្ត្រីខ្លួវគួនអ៊ូ ក៏ចេញចាកទីតំនាល់មកដល់ទ្វារព្រះបរមរាជវាំង គួនអ៊ូក៏ឡើងសេះដើរតាមប្អូនទៅ, លុះទៅដល់មុខផ្ទះ

គួនអ៊ីក៏លាចូឆួចូលទៅផ្ទះរបស់ខ្លួន ។ ចូឆួឃើញសេះគួនអ៊ីស្គមក៏សួរថា ហេតុម្តេចបានជាសេះនេះស្គមម្ល៉េះ? មិនសមនឹងខ្ញុំអ្នកជិះសោះ ។ គួនអ៊ីឆ្លើយតបថា សេះនេះខ្សោយជននឹងកម្លាំងខ្ញុំមិនបាន។ ជាស្គម ។ ចូឆួបានស្តាប់ក៏ប្រើឲាហានទៅនាំយកសេះសឹកថាវិមក ហើយសួរគួនអ៊ីថា សេះនេះរបស់អ្នកណា អ្នកឯងស្គាល់ឬទេ? ។ គួនអ៊ីថា សេះនេះរបស់លីចាំ ខ្ញុំបាទបានស្គាល់ច្បាស់ ។

ចូឆួក៏ឲ្យរៀបចងគ្រឿងប្រដាប់សព្វគ្រប់ រួចប្រគល់ឲ្យគួនអ៊ី។ ត្រេកអរណាស់ ចុះពីលើខ្នងសេះលុតជង្គង់គំនាប់ចុះហើយថា ដែលមហាឧបរាជឲ្យខានសេះនេះមកខ្ញុំបាទនោះ ព្រះគេជះគុណធ្ងន់រកអ្វីប្រៀបមិនបាន ។ ចូឆួបានស្តាប់ដូច្នោះក៏ទឹកឆ្អល់កង់ចិត្តហើយសួរថា យើងឲ្យមាសច្រាក់ទឹងរបស់ឲ្យដល់អ្នកជាច្រើនណាស់ហើយ អ្នកក៏មិនដែលទទួលអរគុណដូចជាយើងឲ្យសេះម្តងនេះសោះ ដោយហេតុអ្វីបានជាអ្នកស្រឡាញ់សេះជាសត្វតិរច្ឆាន លើសជាងឲ្យរបស់មាសច្រាក់ទៅវិញ ។ គួនអ៊ីឆ្លើយថា ខ្ញុំបាទដឹងថាសេះសឹកថាវិនេះមានកម្លាំងច្រើន ដើរផ្លូវ ១ ថ្ងៃបាន ១ ហ្មឺនសិន (៤០០ គ.ម.) ប្រសិនបើខ្ញុំបាទដឹងដំណឹងឲ្យពីនៅឯណា ទោះបីផ្លូវឆ្ងាយប៉ុន្មានក៏ទៅបានដោយឆាប់រហ័សហេតុដូច្នេះ ទើបខ្ញុំបាទមានសេចក្តីត្រេកអរចំពោះគុណមហាឧបរាជជាច្រើន ជាងឲ្យខានរបស់ឲ្យមាសច្រាក់ទាំងពួង ។

(មានត)

រឿងបល្ស័ង្ក្ដិព្ធ សាមសិបពីររឿង

រឿងព្រេងតណ្ឌៀ

ណោកសមិន ម្ចុត្សនជម:ពែង

ណោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

និទាននៃរូបទេពនិម្មិតទី ១៣

មានមួយថ្ងៃ, ព្រះមហាក្សត្រិយ៍កោជ:ទ្រង់ស្តេចយាងចូលទៅជិតបល្ស័ង្ក្ដិព្ធ ដើម្បីនឹងគង់ឲ្យគេធ្វើពិធីបុណ្យរាជាភិសេក ។ ក្នុងពេលនោះរូបទេពនិម្មិតទី ១៣ ក្រាបបង្គំទូលទ្រង់ថា បពិត្រព្រះបាទកោជ: អ្នកណាដែលនឹងគង់លើបល្ស័ង្ក្ដិព្ធនេះបាន លុះត្រាតែអ្នកនោះមានកិត្តិយសខ្ពង់ខ្ពស់ដូចព្រះបាទវិក្រមាទិត្យ ។ ដល់ទ្រង់ព្រះសណ្ណាប់ដូចនោះហើយ ព្រះបាទកោជ: ទ្រង់មានព្រះបន្ទូលសួរថា "ឧរូបទេពនិម្មិត, តើកិត្តិយសនៃព្រះបាទវិក្រមាទិត្យនោះមានអ្វីខ្ទះ?" ។ រូបទេពនិម្មិតក្រាបបង្គំទូលព្រះបាទកោជ:ថា: "បពិត្រព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្ណាប់, ទូលព្រះបង្គំនឹងថ្វែងនូវសប្ឃុរិសធម៌ នៃព្រះបាទវិក្រមាទិត្យក្នុងកាលឥឡូវនេះ" ។

មានមួយថ្ងៃ, ព្រះបាទវិក្រមាទិត្យទ្រង់ហោះទៅតាមអាកាសដោយព្រះសុពណិបាទពិសិដ្ឋ, ហើយទ្រង់បានត្រាច់ទៅកាន់ប្រទេសជាច្រើនទៅដល់ព្រៃមួយ ជិតក្រុងមួយ ។ នៅកណ្ណាលព្រៃនោះ មានព្រះ

វិហារមួយមានសិទ្ធ:(១) (អ្នកដែលបានសម្រេច, អ្នកដែលបានដល់សុក្រិតកាពគឺ អសេខបុគ្គល) ម្នាក់ឯតនៅទីនោះ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ទតទៅឃើញសិទ្ធ: ទ្រង់ក៏ថ្វាយបង្គំដោយព្រះរាជសទ្ធាយ៉ាងវិក្រលែង ។ សិទ្ធ:ក្រាបបង្គំទូលថា "បពិតព្រះបាទវិក្រមាទិត្យ ហេតុដូចម្តេចក៏ទ្រង់យាងមកកាន់ទីនេះ? ព្រះនរបតីទ្រង់មានព្រះបន្ទូលថា: "ឧយោគី, យើងនេះហើយឈ្មោះ វិក្រមាទិត្យ, ហេតុម្តេចក៏អ្នកស្គាល់ឈ្មោះយើង?" សិទ្ធ:ក្រាបបង្គំទូលថា: "ទូលបង្គំបានឃើញព្រះអង្គនៅនគរអវន្ទី គង់លើរាជបល្ថ័ង្ក; ទ្រង់ចេញពីព្រះរាជណាចក្ររបស់ព្រះអង្គ ត្រាច់ទៅបរទេស; ព្រះរាជអាកប្បកិរិយានេះមិនល្អទេ ។ កាលណាព្រះមហាក្សត្រិយ៍ ទ្រង់គង់នៅក្នុងប្រទេសរបស់ព្រះអង្គ បំពេញព្រះរាជករណីយកិច្ច ដោគរាសនាស្ថិតនៅដោយស្មោះស្មំត្រ ។ ព្រោះហេតុដូចនេះ, ព្រះមហាក្សត្រិយ៍មិនត្រូវត្រាច់កំសាន្តតាមភូមិកាគបរទេស, ព្រោះថា បើទ្រង់នៅក្រៅរដ្ឋព្រះអង្គកង៉ទ័ពបច្ចាមិត្តនឹងរកឧកាសវាយដណ្តើមយកប្រទេសរបស់ព្រះអង្គជាពុំខាន ។ ព្រះបាទវិក្រមាទិត្យ ទ្រង់មានព្រះបន្ទូលតបថា: អ្វីដែលត្រូវមកដល់, គ្មានឧសថអ្វីដែលអាចមកកែបាន ។ បើមានតែឧសថណាមួយ ព្រះបាទនល:នឹងព្រះមហាត្សត្រិយ៍ឯទ្រៀត មិនអាចរងទោសទុក្ខវេទនាទ្បើយ ។ ព្រោះហេតុដូចនេះ ទាំងអស់សុទ្ធតែនៅ

---

១ សិទ្ធិ:នេះជាពាក្យវេចន:នឹងយោគី

ក្រោមអំណាចជោគវាសនា ។ យើងមិនត្រូវគិតពីរឿងនោះទេ ។ ចំពោះរឿងនេះ, យើងនឹងនិទានរឿងមួយឲ្យលោកជ្រាប :

"នៅនគរមួយនាម បទ្មនេសត: (Padmanéshat) មានព្រះមហាក្សត្រិយ៍មួយព្រិះអង្គទ្រង់ព្រះនាមព្រះបាទជយសេខរ: (Jayaçekhara) ទ្រង់សោយរាជសម្បត្តិ, មិនយូរប៉ុន្មាន ពួករហស្សមិត្ត ព្រះរាជទីប្រឹក្សា, ព្រះរាជវង្សានុវង្ស នឹងព្រះរាជសម្ពន្ធមិត្តបានព្រួតដៃនាំបះបោរ ដេញព្រះមហាក្សត្រិយ៍ព្រមទាំងអគ្គមហេសីចេញពីប្រទេស ។ ព្រះរាជានឹងព្រះមហេសី ទ្រង់យាងដោយព្រះបាទទេទៅកាន់ភូមិកាគជាប្រើន, ពេលយប់ទ្រង់ជួំក្នុងទីក្រុងមួយ នៅក្បែរគល់ឈើ ។ នៅលើរុក្ខជាតិនោះ, មានយក្សប្រាំស្ថិតនៅ, កំពុងសន្ទនាគ្នាទៅវិញទៅមក ។ មានយក្សមួយពោលថា: "ព្រះមហាក្សត្រិយ៍នៃនគរនេះទ្រង់ទិវង្គតក្នុងពេលព្រឹកស្អែកនេះ, ទ្រង់គ្មានព្រះរាជបុត្រទេ, តើបានអ្នកណានឹងសោយរាជសម្បត្តិនៅនគរនេះ ។ មានយក្សមួយទៀតតបថា: "អ្នកណាដែលដេកជិតគល់ឈើនេះ, អ្នកនោះឯងនឹងសោយរាជ្យនៅនគរនេះ ។ ព្រះមហាក្សត្រិយ៍ ទ្រង់គង់នៅទៀបគល់រុក្ខជាតិនោះ ទ្រង់ព្រះសណ្ពាប់នូវរាចារបស់យក្សសព្វគ្រប់ ។ ព្រឹកឡើង, ទ្រង់បាននាំឯកអគ្គមហេសីយាងទៅគង់កណ្ពាលនគរ ។ ថ្ងៃនោះមហារាជនៅនគរនេះសោយព្រះទិព្វជង្គត ។ ដើម្បីនឹងឲ្យព្រះរាជអាណាចក្រមានអ្នកឧបត្ថម្ភតទៅមុខទៀត, ព្រះរាជទីប្រឹក្សាបានចាត់ឲ្យយកព្រះទីនាំងហត្ថីលែងទៅក្នុងនគរ ឲ្យស្វែងរកមនុស្សណាដែលត្រូវធ្វើជាព្រះមហាក្សត្រិយ៍ សោយរាជសម្បត្តិនៅនគរនេះ ។

ព្រះទីនាំងហត្ថក៏ទៅយកព្រះបាទជយសេខរៈហើយដាក់ឲ្យគង់លើខ្នងខ្លួន នាំមកកាន់ពាជបល្ល័ង្ក ។ ព្រះពាជពិធីក្សត្រក៏បានចាត់ឲ្យធ្វើពិធីបុណ្យាភិសេក ។ ព្រះបាទជយសេខរៈទ្រង់បានមុទ្ធាភិសេកជាមួយនឹងព្រះអគ្គមហេសី សោយរាជ្យជាសុខនៅនគរនោះតមក ។

តពីនោះបន្តិចមក, មានព្រះមហាក្សត្រិយ៍ ដែលគង់នៅជិតខាង, (ស្តេចសាមន្តរាជ) បានស្តេចយាងទៅប្រជុំគ្នា លើកកងទ័ពទៅព័ទ្ធដុំវិញនគរនៃព្រះបាទជយសេខរៈ ។ ក្នុងពេលនោះ, ទ្រង់កំពុងតែក្រសាលបៀក្នុកជាមួយនឹងព្រះអគ្គមហេសី, ទ្រង់ចោះបង់ចោលកិច្ចការក្នុងព្រះរាជអាណាចក្រ ។ ខណៈនោះ, ព្រះអគ្គមហេសីក្រាបបង្គំទូលព្រះរាជស្វាមីថា: "បពិត្រមហារាជ ខ្ញុំម្ចាស់គិតថា បើបច្ចាមិត្តនាំកងទ័ពមកព័ទ្ធព្រះនគរនេះ, ប្រទេសនេះមុខជាមិនបានស្ថិតស្ថេរ នៅក្រោមព្រះអង្គយូរឡើយ ។ ព្រោះហេតុដូចនេះ ខ្ញុំម្ចាស់មានបំណងចង់ឲ្យបានសុខស្រួល ខ្ញុំម្ចាស់សូមអភ័យទោស ក្រាបបង្គំទូលព្រះអង្គថា បើព្រះមហាក្សត្រិយ៍អង្គណាមួយ បង្អោនព្រះអង្គទៅក្នុងបាបធម៌ខុសច្បាប់, បើពុំជាស្តេចអង្គនោះមានព្រះពាជទ្រព្យ, មានព្រះរាជ្យ, មានព្រះសម្បត្តិភាពគាំទ្រយ៉ាងណាក៏ដោយ, មុខជារាជសម្បត្តិនោះរលត់រលាយដោយឆាប់រហ័សមិនខាន ។ បាបធម៌នេះមានដប់ប្រាំបីយ៉ាង, បណ្តាបាបធម៌ទាំង ១៨ បាបធម៌ដប់យ៉ាងកើតអំពីសេចក្តីស្នេហា, បាបធម៌ប្រាំបីកើតអំពីសេចក្តីក្រោធ; ព្រោះហេតុដូចនេះព្រះមហាក្សត្រិយ៍ ត្រូវតាំងព្រះទ័យកុំឲ្យមានសេចក្តីស្នេហា, កុំឲ្យមានសេចក្តីក្រោធគ្របសង្កត់ព្រះទ័យបាន ។

ឯបាបធម្មិតាំងដប់យ៉ាងដែលកើតឡើងពីសេចក្តីស្នេហានោះ គឺ: ការ
ប្រាថ្នាបំរបាញ់សត្វជាទី ១, ការជាប់ជំពាក់នឹងល្បែងស៊ីសងមានបៀ
ក្ខុកជាដើមជាទី ២, ការនិន្ទ្រាពេលថ្ងៃជាទី ៣, ការពោលពាក្យញុះញ៉ង
ឲ្យគេស្អប់មនុស្សដែលគេស្រឡាញ់ (បេសុញ្ញវាទ) ជាទី ៤, មានតណ្ហា
ប្រាថ្នានូវស្ត្រីកាពជាទី ៥, អត្តទត្ថកាព (ការកំណាញ់ គិតតែប្រយោជន៍
ខ្លួន) ជាទី ៦, ការប្រាថ្នាទៅលើរបាំជាទី ៧, ការប្រាថ្នាចង់ស្តាប់ចម្រៀង
ជាទី ៨, ការប្រាថ្នាស្តាប់ក្ខេងតូរ្យតន្ត្រីយ៍មហោស្រពជាទី ៩, ការដើរ
លេងមិមានវត្ថុបំណងជាប្រាកដជាទី ១០, ព្រះមហាក្សត្រិយ៍អង្គណា
ប្រព្រឹត្តនូវបាបធម្មិតាំងដប់យ៉ាង ដែលកើតពីស្នេហា ព្រះមហាក្សត្រិយ៍
អង្គនោះ ទ្រង់នឹងឃើញនូវសេចក្តីវិនាសនៃទ្រព្យខាងក្រៅ ព្រមតាំង
ទ្រព្យប្រកបដោយសីលធម៌ (សីលទ្រព្យ ឬអរិយទ្រព្យ) ។ ខ្ញុំម្ចាស់
សូមក្រាបទូលទ្រង់ សូមទ្រង់ជ្រាបក្រាមល្អងធូលីព្រះបាទ នូវបាបធម្មិ
ប្រាំបីយ៉ាងដែលកើតឡើងពីទោមនស្សចិត្ត: ឥរុសវាទ ការពោលពាក្យ
លាមក អាស្រូវកាសទៅកាន់ជនដទៃជាទី ១, ការតំនុំតុំគួនគ្នានហេតុ
ចំពោះពួកសប្ឋុរសជាទី ២, បំណងសម្ងាប់អ្នកឥតទោសជាទី ៣, ការមាន
បំណងយ៉ាងមាំចង់ឲ្យអ្នកដទៃសសើរខ្លួនជាទី ៤, ការរិះរកទោសអំពីពួក
ឧត្តមបុគ្គលជាទី ៥; សកម្មកាពលួចយកកោតទ្រព្យអ្នកដទៃ ហើយមិន
ព្រមឲ្យនូវរបស់ដែលគួរឲ្យជាទី ៦; ការពោលលើកទោស, ពោល
ពាក្យអាក្រក់ទៅរកជនដទៃជាទី ៧; ការវាយតប់ឬធ្វើបាបអ្នកដទៃជាទី ៨;
ព្រះមហាក្សត្រិយ៍ ដែលទ្រង់ជាប់ជំពាក់ព្រះរាជហ្ឋុទ័យនឹងបាបធម្មិតាំង

ជ្រុំបីប្រការដែលកើតពីពោមនស្សចិត្តនេះ មុខជានឹងវិនាសព្រះអង្គព្រម
ទាំងធ្វើឲ្យអន្តរាយព្រះរាជអាណាចក្ររបស់ព្រះអង្គមិនខាន; ហើយ
ទ្រង់ស្រេងមានព្រះរាជហ្ជុទ័យស្មោះស្ម័ត្រចំពោះព្រះរាជការណ៍យកិច្ចរបស់
ទ្រង់ ។

ចំណែកខាងព្រះអង្គ ដែលជាព្រះមហារាជ បដិសន្ធិពីព្រះរាជ-
ត្រកូលមហាស្ទាលទ្រង់ប្រែរ៉ៅជាក្រសាលល្បែងប្រ៉ាក្ជុកជាមួយនឹងព្រះ
អគ្គមហេសីព្រះអង្គហួសប្រមាណ, ទ្រង់លះបង់កិច្ចការទាំងឡាយក្នុងព្រះ
រាជអាណាចក្រ ព្រោះហេតុដូចនេះ ខ្ញុំម្ចាស់គិតឃើញថា យើងគង់នឹង
មានទុក្ខទាំងអស់ឆ្នាក្នុងពេលឆាប់ៗ នេះពុំខាន ។

ព្រះអគ្គមហេសីទ្រង់បានមានព្រះបន្ទូលជាស់គ្រឿន នូវព្រះមហា-
ក្សត្រិយ៍ជាមុន ដោយទ្រង់ព្ជួយព្រះរាជហ្ជុទ័យពន់ពេក ។ ព្រះមហា
ក្សត្រិយ៍ទ្រង់មានព្រះឧង្ការទៅកាន់ព្រះអគ្គមហេសីថា នែអូនមាសស្នេហ៍
អូនកុំភ័យឲ្យសោះ បើរាជសម្បត្តិរបស់យើងសាបសូន្យ, រក្ខជាតិធំមួយ
ដើមដែលបងនិត្រាពីកាលមុននោះ ស្ថិតនៅទីនោះដដែល, ចំណែក
ឯយក្សទាំងជ្រុំដែលស្ថិតនៅលើរុក្ខជាតិនោះ ក៏ស្ថិតនៅលើរុក្ខជាតិ
ដដែល, ដោយសេចក្តីអនុគ្រោះនៃយក្សទាំងជ្រុំ បានជាបងបាន
សោយរាជសម្បត្តិនៅព្រះរាជអាណាចក្រនេះ ។ ព្រោះហេតុដូចនេះ
អូនស្ទួនមាសបង ចូរនាងគិតថា អ្វីដែលត្រូវមកដល់, នឹងមកដល់មិនខាន,
ចូរនាងមកលេងប្រ៉ាក្ជុកនឹងបងចុះ ។ ព្រះមហាក្សត្រិយ៍, ក្រោយ

ដែលបានមានព្រះរាជឧត្តារ, ទ្រង់ក៏តាំងចាប់ផ្តើមលេងបៀក្ខុកនឹងព្រះអគ្គមហេសីតទៅទៀត ។

ចំណែកយក្សតាំងប្រាំបានដឹងដំណឹងថា ព្រះមហាក្សត្រិយ៍មុខជាទ្រង់នឹងត្រូវទទួលទុក្ខជាទម្ងន់, ក៏សន្ធនាការគ្នាទៅវិញទៅមកថា: យើងបានថ្វាយព្រះរាជអាណាចក្រនេះទៅព្រះមហាក្សត្រិយ៍អង្គនេះ តែទ្រង់ជាបុគ្គលគ្មរជាទីស្អប់ខ្ពើមពន់ពេក ទ្រង់មិនមានសមត្ថភាព, ព្រះរាជអាណាចក្រនេះនឹងធ្លាក់ទៅក្នុងកណ្តាប់ដៃបច្ចាមិត្ត មិនខាន ។ បើក្នុងពេលនេះយើងមិនទៅជួយទ្រង់ទេ, ទ្រង់នេះនឹងវិនាសហើយយើងមុខជានឹងខ្មាស់គេមិនខាន ។ សេចក្តីថ្កុំថ្កើងរបស់យើងនឹងត្រូវរីកធំឡើងក្នុងពិភពលោក, មិនត្រូវឲ្យថយចុះវិញសោះឡើយ ត្រូវតែយើងរងចាំការពារព្រះអង្គរក្សាព្រះរាជកិត្តិយសក្នុងពេលនេះ ។ យើងត្រូវតែតយុទ្ធនឹងសត្រូវហើយបំផ្ទាញសត្រូវព្រះមហាក្សត្រិយ៍ឲ្យសាបសូន្យ ។

ក្នុងមួយរំពេច, ព្រះអគ្គមហេសីទ្រង់បានទតទៅឃើញពួកបច្ចាមិត្តជាច្រើន វិនាសក្នុងពេលនោះ. ទ្រង់ក៏ជ្រាបថាសកម្មភាពនេះ គ្មរឲ្យស្រប់ស្រែងពន់ពេក, ហើយក្រាបបង្គំទូលព្រះរាជស្វាមីថា "មហារាជនេះចំជាអស្ចារ្យ; ហេតុម្តេចក៏កងទ័ពបច្ចាមិត្តសម្បើមយ៉ាងនេះ ដល់ទូវសេចក្តីវិនាសដោយធាប់រហ័ស? ។ ពាក្យនេះក៏ព្ធដល់ទៅពួកយក្សតាំងប្រាំ ។ ក៏ក្រាបបង្ខំទូលព្រះអគ្គហេសីថា: "ឧព្រះនាងប្រកបដោយកល្យាណធម៌ ចូរព្រះនាងទ្រង់ជ្រាបនូវហេតុដែលបច្ចាមិត្តរបស់ព្រះមហាក្សត្រិយ៍ត្រូវវិនាសនេះ យើងពីដើមជាត្រីប្រាំ ក្នុងធ្នាំមួយ បឹងដែល

យើងស្ថិតនៅ ត្រូវកំដៅថ្ងៃយ៉ាងខ្ទាំង, ក៏វីងស្ងួតអស់ត្មានទឹក ។ ព្រះ
មហាក្សត្រិយ៍អង្គនេះ, ពីអតីតជាតិជាស្ទ្ចនឆ្នាំង តែងតែយកដីអិដ្ឋអំពី
ទីបឹងនេះទៅធ្វើឆ្នាំង ។ ដល់ឃើញយើងកន្ទល់ពន់ពេក, ស្ទ្ចនឆ្នាំងនោះ
ក៏ជីកដីបឹងនោះជាអន្ទង់ម្ជុយ ជាក់ទឹកចិញ្ចឹមបីបាច់ថែរក្សាយើងៗ ក៏បាន
រស់រួចជីវិតក្នុងពេលនោះ ។ លំជាប់តមក, យើងជាត្រីប្រាំ ក៏បាន
មកកើតជាយក្សប្រាំនៅទីនេះ ហើយស្ទ្ចនឆ្នាំងក៏បានសោយរាជ្យជាព្រិះ
មហាក្សត្រិយ៍អង្គនេះ ទ្រង់ព្រះនាមថាព្រះបាទជយសេខរៈ ។ ដោយ
ពីអតីតជាតិទ្រង់បានជួយស្រោចស្រង់ជីវិតដល់យើង, យើងត្រូវសំដែង
កតញ្ញូកតវេទីក្នុងពេលនេះ ដោយធ្វើឲ្យទ្រង់បានទៅជាព្រះមហាក្សត្រិយ៍
សោយរាជ្យនៅប្រទេសនេះ ។ សូមទ្រង់សោយរាជ្យសម្បត្តិ នឹង
ព្រះនាងប្រកបដោយសេចក្តីសុខចុះ កុំឲ្យមានទុក្ខមកបៀតបៀនសោះ
ឡើយ" ។ ដល់យក្សទាំងប្រាំថ្ងៃងរៀងចប់សព្វគ្រប់ហើយ ក៏វិល
ត្រឡប់ទៅកាន់ទីលំនៅខ្លួនវិញ ។

មហារាជវិក្រមាទិត្យ ទ្រង់មានព្រះបន្ទូលថា "ឧយោគី, អ្វីដែល
ត្រូវតែមកដល់ ខានមិនបាន មិនអាចប្រែប្រួលយ៉ាងណាបានឡើយ? តើ
សេចក្តីព្យាយាមនៃមនុស្សយើងអាចប្រែកែអ្វីបានទេ? ។ យោគីក្រាប
បង្គំទូលតបថា ឧមហារាជ, ដែលទ្រង់មានព្រះរាជឧត្តារនេះ មានសភាព
ផ្ទុយនឹងនីតិសាស្ត្រ ។ បើតាមច្បាប់នីតិសាស្ត្រ មនុស្សណាព្យាយាម
ជានិរន្តរ៍គេទុកជាមនុស្សពិសេស ។ ចំណែកទ្រង់មានព្រះបន្ទូលថា អ្វី
ដែលត្រូវមកដល់ នឹងមកដល់ បើទុកជាអ្នកណាមានព្យាយាមយ៉ាងណា

ក៏ដោយ, នេះជាពាក្យពោលតាមមនុស្សថោកទាប (ហីនជាតិ); ព្រោះ
ថាសកម្មណាគ្មានអ្វីក្រៅពីវត្ថុបំណងរបស់មនុស្សសោះឡើយ, ហើយអ្នក
ណាដែលអួតថាខ្ជួនគ្មានធ្វើអ្វី, អ្នកនោះឯងជាទីសំអប់ជនជៃ ។ ត្រូវ
តែខំព្យាយាមជានិច្ច រាតនូវសកម្មភាពខ្ជួនឲ្យរីកធំឡើង ។ តែទូលបង្គំ
យល់ថា ព្រះអង្គទ្រង់ជាមហាសន្តបុគ្គលមែនពិត; ទូលបង្គំត្រេកអរនឹង
ទ្រង់, ទូលបង្គំសូមថ្វាយនូវរតនវត្ថុល្អអស្ចារ្យនេះគឺ ចិន្តាមណី ។.

ព្រះមហាក្សត្រិយ៍ទ្រង់ទទួលនូវចិន្តាមណី ទ្រង់មានព្រះរាជហ្ឫទ័យ
សោមនស្សពន់ពេក, ទ្រង់បានពោលនូវសេចក្តីសរសើរជាអនេកបរិ-
យាយ, ទ្រង់ធ្វើបដិសណ្ឋារៈចំពោះសិទ្ធៈ រួចទ្រង់វិលត្រឡប់មកព្រះរាជ-
និវេសនដ្ឋានវិញ ។ ក្នុងពេលនោះមានមនុស្សក្រម្នាក់ដែលទ្រង់ជួប
ប្រទះតាមផ្ទូវ. មកសូមទានព្រះអង្គ ។ ទ្រង់ប្រោសព្រះរាជទាននូវចិន្តា
មណីទៅមនុស្សនោះ, រួចទ្រង់ព្រះសុពណិបាទពិសិដ្ឋវិលត្រឡប់មកកាន់
ព្រះបរមរាជវាំងវិញ ។

រូបទេពនិម្មិតក្រាបបង្គំទូលព្រះបាទភោជៈថា "ឧព្រះបាទភោជៈ
នេះហើយជាសភាពដ៏ឧត្តុង្គឧត្តមនៃព្រះបាទវិក្រមាទិត្យ បើទ្រង់មាន
ចរិយាដ៏ឧត្តុង្គឧត្តមបែបនេះ ចូរទ្រង់ស្តេចយាងទៅគង់លើបល្ល័ង្កទិព្វនោះ
ចុះ ហើយទ្រង់ឲ្យគេធ្វើពិធីមុទ្ធាភិសេកតទៅ" ។

ព្រះបាទភោជៈដល់ទ្រង់ព្រះសណ្តាប់នូវពាក្យនៃរូបទេពនិម្មិត, ក៏
ទ្រង់ថយចេញពីបល្ល័ង្កទិព្វនោះទៅ ។

(មានត)

កំណត់ដឹងប្រវត្តិការណ៍

មហាធជ្ជសង្គាយនានៃព្រះពុទ្ធសាសនា

លោក ឡា-ហ្ជុយអង៍ត៍ អគ្គលេខាធិការនៃមិត្តព្រះពុទ្ធសាសនា

អ្នកនិពន្ធចុះផ្សាយក្នុងទស្សនាវដ្ដីហ្ជូង-អាស៊ី លេខ ១០៨ ឆ្នាំ ១៩៥៥

អ្នកប្រែជៀបជៀង : ញ៉ែម-ខឹម លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យ

នៅថ្ងៃពេញបូណ៌មីនៃខែវិសាខ ត.ស. ១៩៥៦, នៅធានីវង្ឌនប្រទេសកូមា មានធ្វើបុណ្យវិសាខបូជាដ៏ឧឡារិកវំលឹកដល់ថ្ងៃដែលព្រះពុទ្ធអង្គទ្រង់ប្រសូត, ទ្រង់បានត្រាស់ដឹង នឹងទ្រង់ព្រះបរិនិព្វាន ។ រីឯមហាធជ្ជសង្គាយនាក៏ធ្វើតាំងពីថ្ងៃនោះមកដែរ ហើយក្នុងរវាងមួយឆ្នាំគត់តទៅមុខទៀត ទើបពិធីនេះបានបប់ស្រេច គឺបប់នៅខែវិសាខ ត.ស. ១៩៥៦ (គំរប់ជា ២.៥០០ ឆ្នាំនៃព្រះពុទ្ធសករាជ) ។

មហាសារសំខាន់នៃព្រឹត្តិការណ៍នេះ បានលេចឡូឡើងដល់ពុទ្ធិកជនក្នុងពិភពលោក ក៏ព្រោះតែធជ្ជសង្គាយនានេះដែលបានធ្វើមកក្នុងពុទ្ធ-សករាជ ២៦៩៩ ឆ្នាំ ។ តាមច្បាប់ព្រះពុទ្ធសាសនាពោលថា លុះដល់គំរប់ ព.ស. ២.៥០០ ឆ្នាំ គិតតាំងពីព្រះពុទ្ធអង្គបរិនិព្វានមក, សាសនារបស់ព្រះអង្គនឹងបានសាយពាសពេញពិភពលោកទាំងមូល ។ គឺនៅពេលនេះហើយ ដែលជាពេលាមានដំណើរឈមទៅរកការបដិវត្តន៍នៃធម្មចក្រ ។ ប៉ើតាមព្រះពុទ្ធដីកានៃព្រះអង្គថា ធម្មវិន័យព្រះអង្គត្រូវប្រែប្រួលសាបសូន្យបន្តិចម្តងៗ ក្នុងរវាង ២៥០០ ឆ្នាំទៅមុខទៀត ធ្វើឲ្យ

មនុស្សលោកក្ងេចក្ងាំងអស់ រហូតទៅទល់នឹងមានព្រះពុទ្ធមួយព្រះអង្គមក
ត្រាស់ទៀត ។ ព្រះពុទ្ធអង្គទាងក្រោយនេះ ក៏ទ្រង់ត្រាស់ដឹងដោយ
ព្រះអង្គឯងនូវធម៌សម្រាប់ប្រោសសត្វលោក ហើយក៏ផ្សាយសាសនធម៌
នេះ ដល់ជនណាដែលមានធូលីនៅក្នុងចក្ខុតែបន្ទិចបន្ទួច ។

នេះគឺជាកស្ពុតាងបង្ហាញឲ្យយើញនូវការរស់នៅ នឹងកម្ងាំងដ៏មោះ
មុតក្នុងជំនឿនៃប្រជាជនកូមាដែលបានប្រជុំធ្វើធដ្ឋសង្គាយនា ដោយមាន
បំណងនឹងរើផ្ទៀងសាជាថ្មី នូវគម្ពីរព្រះត្រៃបិដកដែលបានរៀបរៀងនឹង
ចោះពុម្ពរួចមកហើយនៅប្រទេសកម្ពុជា, ប្រទេសលង្កា, ប្រទេសអង្ខេស,
នឹងប្រទេសសៀម ។ មិនតែប៉ុណ្ណោះ ធដ្ឋសង្គាយនានេះមានបំណង
នឹងប្រមូលគម្ពីរទាំងនោះមកប្រៃរួបរួមមកជាកាសាតែមួយ ។ លុះតែធ្វើ
ដូច្នេះ ទើបគម្ពីរនេះទៅជាសៀវភៅមានន័យដ៏ត្រឹមត្រូវ, មានអត្ថសព្ទ
ត្រប់តាមដើមកំណើតច្បាស់ប្រាកដ គឺ តាមច្បាប់សង្ស ។ គោល
បំណងនៃសង្គាយនាលើកនេះ ក៏ដូចជាគោលបំណងនៃសង្គាយនា ៥
លើកមុនៗ មកដែរ គឺសើរើផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់នូវអត្ថបទជាថេរវាទ
ដើម្បីឲ្យអត្ថបទនោះរក្សានូវពុទ្ធសាសនាទាំងស្រុង ដែលព្រះអង្គបាន
ទ្រង់ទេសនាប្រោសពួកសាវ័កទាំងឡាយ ។

នៅទីនេះ យើងសូមរំលឹកថា ក្នុងកំឡុងពេល ៤៩ ឆ្នាំដែលព្រះ
អង្គស្ពេចនិមន្ទប្រោសសត្វនោះ ព្រះអង្គតតដែលមានពុទ្ធដីកាទៅកាន់
ជនដែលដើរត្រពីសត្រពាសទេ, ព្រះអង្គតែងទ្រង់ទេសនានៅក្នុងទីប្រជុំ
ជនដែលមានសាវ័ក នៃព្រះអង្គនៅព័ទ្ធជុំវិញ, ហើយនឹងទ្រង់ទេសនា

ជ្រោសតែជនដែលចូលមកតាល់ព្រះអង្គដើម្បីពិភាក្សាពីរឿងរ៉ាវផ្សេងៗ ។ ហេតុនេះហើយបានជាព្រះត្រៃបិដក មានអត្ថបទវែងជ្រាលជ្រៅណាស់ ហើយនៅក្នុងអត្ថបទទាំងនោះយើងឃើញភាគជាច្រើន ដែលមានតោលគតិតែមួយ អធិប្បាយចេញទៅជាច្រើនយ៉ាង, ព្រោះព្រះពុទ្ធជាម្ចាស់យើង ព្រះអង្គទ្រង់ស្គាល់និស្ស័យសត្វទាំងអស់ ដូច្នេះតែកាលណាព្រះអង្គមានពុទ្ធដីកាទៅកាន់ជនជទៃថ្មីទ្រៀត ដែលមានអធ្យាស្រ័យផ្សេង ព្រះអង្គមានពុទ្ធដីការឲ្យផ្សេងពីមុនដែរ ដើម្បីឲ្យត្រូវទៅតាមអធ្យាស្រ័យជនខាងក្រោយនេះ ។ លំដាប់មក ក្រោយព្រះអង្គបរិនិព្វានទៅ, ពួកសាវ័កព្រះអង្គក៏ប្រជុំគ្នាជាលើកដំបូងបង្អស់ ដើម្បីសម្រេចថាតើយើងត្រូវរក្សាទុកព្រះពុទ្ធដីកាណា ទាន់យើងនៅចាំគ្រប់គ្នា ។ ការនេះជាភស្តុតាងមួយបង្ហាញឲ្យយើងឃើញ នូវសេចក្តីបរិសុទ្ធិស្មោះត្រង់ចំពោះព្រះពុទ្ធអង្គ នៃពួកសាវ័កទាំងឡាយ ។ ក្នុងពេលប្រជុំនោះមានយោបល់ខ្វែងគ្នាជាច្រើន ប៉ុន្តែទោះបីដូច្នោះក៏ដោយ តោលបំណងនោះក៏នៅតែបានសម្រេច ។ ព្រះមហាថេរៈព្រះនាម កស្សបៈ ដែលជាអ្នកស្នងការជំនួសព្រះអង្គនឹងជាបិតានៃព្រះសង្ឆ ហើយដោយមានការឧបត្ថម្ភពីព្រះបាទអជាតសត្ថុផង ក៏បានបង្កើតមហាសង្គាយនាទីមួយនៅក្រុងរាជគ្រឹះ ជិតមហាវិទ្យាល័យនាលទ្ធាសព្ទាថ្ងៃនេះ ក្នុងដំបន់បត្នៈ ។

ធម៌របស់ព្រះពុទ្ធជាច្បាប់ ស់មាប់ប្រៀនប្រដៅមួយយ៉ាងខ្ពង់ខ្ពស់, ជាវិន័យពឹងផ្អែកទៅលើគុណសម្បត្តិខាងផ្លូវចិត្តនឹងខាងផ្លូវប្រាជ្ញា, ជាគ្រឿងជំរះនូវមន្ទិលសង្ស័យដែលកើតមានឡើងរាល់ថ្ងៃ នឹងជាគ្រឿង

ពិចារណាមួយយ៉ាងពិតប្រាកដនូវអំពើផ្សេងៗ ។ ព្រះថេរ:ទាំងឡាយ
ដែលមកប្រជុំនៅកន្ទែងត្ស៊ីសាននៃប្រទេសឥណ្ឌា បានដើរតាមលំអាន
ព្រះពុទ្ធជាម្ចាស់ទាំងអស់ ។ ព្រះថេរ:ទូះជាបុរាណព្រាហ្មណបណ្ឌិត
ព្រឹទ្ធាចារ្យ ។ ជូច្នេះព្រះថេរ:ទាំងនោះយល់ច្បាស់ណាស់នូវព្រះពុទ្ធដីកា
ព្រះអង្គទាំងអស់ ។ ឯកិច្ចការដែលព្រះថេរ:ទាំងនោះបានធ្វើហើយក្នុង
ពេលនោះ, បាននៅសល់ដល់យើងរហូតមកសព្វថ្ងៃនេះ ។ ពេល
ប្រជុំបើកកាលណា, ព្រះថេរ:ទាំងអស់ក៏ទូលសុំឲ្យព្រះអានន្ទ ដែលជា
អ្នកបាននៅតាល់បំរើព្រះអង្គជានិច្ចកាលជាងគេនោះ ហើយដែលជា
សាក្សីឯកនៃជីវិតព្រះអង្គ, ឲ្យសូត្រព្រះពុទ្ធដីកាព្រះអង្គទាំងប៉ុន្មាន ដែល
ព្រះអានន្ទបានស្តាប់ចាំមក ។ ព្រះអានន្ទក៏អធិប្បាយ មួយកន្ទែងម្តងៗ
យ៉ាងសព្វគ្រប់អំពីពុទ្ធទ្រាទផ្សេងៗ, អំពីការពន្យល់ណែនាំនៅពេល
ដែលព្រះអង្គតើន ឬនៅពេលដែលព្រះអង្គនិមន្តធ្វើដំណើរទៅទីឆ្ងាយៗ,
អំពីបដិសណ្ឋារកិច្ចដែលគេរៀបទទួលព្រះអង្គ ។ កិច្ចការទាំងអស់នេះ
ក៏ទៅជារឿងរ៉ាវទាំងអស់ ។ នៅពេលនោះ ព្រះថេរ:ទាំងអស់ក៏ស្រុះ
ស្រួលគ្នាជាពួកៗ ទន្ទេញធម៌ទាំងប៉ុន្មាននេះ យ៉ាងចាំរត់មាត់ដូចជាវិន័យ,
ទស្សនវិជ្ជា ហើយព្រះភិក្ខុសង្ឆទាំងនោះក៏នាំរឿងទាំងនេះ ទៅផ្សាយ
ដល់ពួកសាវ័ករៀងៗ ទ្ធូន ។ លុះបានស្តាប់សព្វគ្រប់ហើយពួកកានក:
ក៏បានរក្សាទុកទាំងស្រុង នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងប៉ុន្មាន
ដែលទ្រង់សំដែងកាលគង់ព្រះជន្មនៅ ។ ស្មារតីដ៏រឹងប៉ឹងនៃព្រះថេរ:
ទាំងនោះ យើងមិនបាច់ឆ្ងល់ទេ ព្រោះនៅសព្វថ្ងៃនេះក៏ដោយ យើងគង់

ឃើញ ព្រះភិក្ខុសង្ឆសូត្រធមិយ៉ាងវែងៗ ដោយឥតចាំបាច់មើលសៀវភៅ ឡើយ ។ ការសូត្រជាចង្វាក់, នឹងការសូត្រផ្ទួនៗ, ដូចជាសូត្រ ធ្វើបទបែបផ្សងៗ ដែលមាននៅក្នុងបាលីនោះ ត្រាន់តែជាជំនួយស្មារតី ប៉ុណ្ណោះឯង ។ ត្រង់នេះក៏យើងពុំបាច់សង្ស័យទេ, ព្រោះនៅក្នុង សាសនាអិស្លាម ក៏យើងបានឃើញពួកអ្នកកាន់សាសនានោះសូត្រធមិ សុរ៉ាត ដែលមាននៅក្នុងគម្ពីរកូរ៉ង់យ៉ាងស្ទាត់ជំនាញដែរ ។

បើតាមលោក អ. បារ៉ូ (M. A. Bareau) បានមានប្រសាសន៍នៅក្នុង សេចក្តីថ្លែងការរបស់លោកកាលពីឆ្នាំ ១៩៥០ ទៅកាន់បណ្ឌិតសភាខាង អក្សរសាស្ត្រនៅឯក្រុងប៉ារិសថា "ព្រះសុត្តន្តបិដកមិនអាចកើតឡើង ភ្លាមបានក្រោយព្រះអង្គបរិនិព្វានទេ, តាមពិត គឺបានកើតឡើងបន្តិច ម្តងៗ អស់រយៈវេលាជាច្រើនសតវត្សរ៍, ដោយប្រមូលមកបន្ទែមនូវ អត្ថបទដែលមាននៅក្នុងពេលសង្គាយនា ក្រោយដែលសមាជបានជជែក, បកប្រែ នឹងបញ្ចេញមតិផ្សងៗ ។ ហេតុនេះ បានជាសៀវភៅបិដក កើនចំនួនជាច្រើន ដូចយើងបានឃើញសព្វថ្ងៃនេះ ។ ប៉ុន្តែបើតាម សេចក្តីសង្កេតរបស់លោក បារ៉ូថា: "បើសិនជាក្រុមពុទ្ធនិកាយទាំងឡាយ នៃពួកហីនយាន មានព្រះសុត្តន្តបិដក យ៉ាងហោចណាស់ក៏ ១ ក្សាល, នៅក្នុងចំណោមបិដកនានា នោះក្រុមពុទ្ធនិកាយមួយៗ នឹងមានព្រះ អភិធម្មបិដកពិសេស ដែលមានបទបញ្ញត្តិលាយឡំជាមួយសិក្ខាបទចម្ងង ចេញមកពីព្រះសុត្តន្ត ។ ប៉ើកាលណាគេប្រៀបធៀបសុត្តបាលីទៅនឹង គម្ពីរចិនផ្សងៗ ទោះជាគម្ពីរនោះប្រែចេញជាផ្នែកៗ ប្ដត្រាន់តែអធិប្បាយ

ការតូចតាច នោះគេក៏នឹងឃើញច្បាស់ថាមានសេចក្តីជូចគ្នានឹងសៀវកៅ
ពំងពីរនេះ ដែលស្រង់ចេញមកពីព្រះសុត្តន្តតែមួយ, ហើយបើសិនជា
មានអត្ថបទខ្ទះដែលមិនជឹងប្រាកដជាចម្ងងចេញមកពីបិដកណា, សៀវ-
កៅពំងនោះក៏មាននិយាយពីអត្ថបទនោះតែបន្ទិចបន្ទួចដែរ ។ ត្នាន
សង្ស័យអ្វីទេ, ការកែប្រែពំងនេះមានខុសសេចក្តីគ្នាមែន, ប៉ុន្តែការ
ប្រែពំងនេះជាប្រយោជន៍មួយយ៉ាងសំខាន់ខាងអក្សរសាស្ត្រ តែគ្នាន
ប្រយោជន៍អ្វីខាងវិន័យទេ មានតែតួអក្ខរៈប៉ុណ្ណោះដែលខុសគ្នា, ឯតំនិត
មិនមែនខុសគ្នាទេ ។

ព្រះពុទ្ធជាម្ចាស់ព្រះអង្គឥតបានបញ្ញត្តឲ្យពួកសាវ័កព្រះអង្គតង់តែក្នុង
វត្តអារាមទេ, ព្រះអង្គបានទូន្មានថា "ឲ្យទៅនៅក្នុងព្រៃព្រោមតល់ឈើ,
ឲ្យរកចង្ហាន់ដោយការដើរបិណ្ឌបាត ហើយឲ្យផ្សាយតែធម្មវិន័យព្រះ
អង្គ" ។ ជូចនេះ, ប្រទេសឥណ្ឌាមានព្រះកិក្ខុសង្ឆជាច្រើននិមន្តទៅ
មកពាសពេញក្នុងផ្ទៃប្រទេស, ហើយនៅពេលដែលព្រះសង្ឆពំងនោះ
បែកខ្ញែកគ្នាទៅកន្ទែងទីទៃ ។ តំនិតផ្ទុយគ្នាក៏កើតមានឡើងដោយសារ
អានុភាពនៃទំនៀមទំលាប់ស្រុកខ្ទះ, ដោយអានុភាពនៃយោបល់យល់
ផ្ទាល់ខ្លួនខ្ទះ ។

មហាសង្គាយនាលើកទីពីរចាប់ផ្ទើឡើងនៅឆ្នាំ ៤៤៣ មុនគ្រិស្ត
សករាជ នៅឯក្រុងវេសាលី ក្នុងរាជ្យព្រះបាទ កាលាសោក ដោយមាន
គោលបំណងនឹងប្រមូលធម្មវិន័យ ដែលឃ្ងាតចាកគោលដើមអស់ ដោយ
សារមានបែកបក្សពួកផ្សេងៗ ។ មួយចំណែកទៀត មហាសង្គាយនានេះ

មានចំណងនឹងពីគ្រោះពិភាក្សាពីរឿងប្រែព្រឹត្តទុសនឹងវិន័យ ១០ យ៉ាង ដែលពួកវជ្ជីបុត្តកកិក្ខុជាអ្នកធ្វើទុស ។

មហាសង្គាយនាលើកទី ៣ ប្រជុំនៅទីក្រុងបាតលិបុត្តនៅឆ្នាំ ៣០៨ មុនគ្រិស្តសកពជ ដោយមានព្រះបាទអសោកជាអ្នកផ្តើមគំនិត ព្រោះព្រះអង្គចង់ញុំាងលទ្ធិព្រះពុទ្ធសាសនាឲ្យមានឥទ្ធិពញ្ជោចឡើង, ចង់លាតត្រដាងឲ្យប្រទេសចាំងឡាយក្នុងពិភពលោក ទទួលស្គាល់ព្រះពុទ្ធសាសនានៅសម័យនោះផង ។ គឺនៅពេលសង្គាយនានោះហើយ ដែលមានកើតគម្ពីរកថាវត្ថុមួយឡើង ដែលជាសៀវភៅមានប្រស្នាចោទឆ្លើយដើម្បីផ្ចាញ់ទូវជំនឿផ្សេង ។ ដែលពួកថេរវាទយល់ថាជាអំពើមិច្ឆាទិដ្ឋិ ។ ប៉ុន្តែសៀវភៅនេះ ឬហៃលជាមានការកែប្រែតមកទៀត ព្រោះអត្ថបទនោះបានបដិសេធចោលទូវការយល់ចាំងឡាយ នៃអ្នកចូជ្ជជាន់ក្រោយដែលនៅពាជ្យព្រះបាទអសោកពុំជាន់មានអ្នកចូជ្ជដូច្នេះនៅឡើយទេ ។

មហាសង្គាយនាលើកទី ៤ ធ្វើឡើងនៅប្រទេសលង្កាកន្លះរយៈឆ្នាំ ២៩-១៣ មុនគ្រិស្តសកពជ នៅក្នុងពាជ្យស្តេចវដ្តគាមនី ។ សង្គាយនាលើកទី ៤ នេះ, មានគោលបំណងកត់ត្រាសរសេរចំឡងទុកទូវពាក្យប្រៀនប្រដៅចាំងអស់របស់ព្រះពុទ្ធ មិនមែនគ្រាន់តែបន្តការៈនេះដោយសំនួរវ៉ាចាៈទេ ។ ដូច្នេះគឺនៅក្នុងវត្តអាលុវិហារ ជាទីក្រុងម៉ាតាល (Matale) ដែលគេប្រជុំធ្វើកិច្ចការលុះត្រាតែបានសម្រេច ។ ពេលនោះការប្រឹងប្រែងធ្វើមហាសង្គាយនាគ្មានអ្វីក្រៅពីផ្ទៀងអត្ថបទដែលសរសេរបួចស្រែចយ៉ាងប្រិតប្រៀតបំផុតនោះឡើយ ។

បិដកបី គឺព្រះវិន័យ, ព្រះសូត្រ, ព្រះអភិធម្មក៏កើតឡើង ។ សៀវភៅកំណត់ជាផ្នែកៗ ពំនរនោះដែលចារនៅលើស្ទឹកវិត ហើយដែលមានចំនួនជាច្រើនលើសលប់ក៏បានឈ្មោះថា "ព្រះត្រៃបិដក" ។ ការធ្វើឲ្យកើតព្រះត្រៃបិដកនេះ ជាការមួយធ្វើដោយសេចក្តីព្យាយាមអំណត់ឧស្សាហ៍បំផុត ហើយឥតគិតប្រយោជន៍ផ្ទាល់ខ្លួនផង ។ ដូច្នេះ តើមានពួកអ្នកសរសេរ, អ្នកសូត្រនឹងអ្នកប្រាជ្ញពឺត្ថាចារ្យប៉ុន្មាននាក់នៅរួបរួមធ្វើការនេះ? ត្រង់នេះយើងពុំដឹងសោះឡើយ ទោះឈ្មោះក្តី, ទោះចំនួនមនុស្សក្តី, ប៉ុន្តែបើកាលណាគេដើរតាមផ្ទូវថ្នល់ពីកន្ទី (Kandy) ទៅអនុរាធបុរ: (Anuradhapura) រួចគេឈប់នៅត្រង់វត្តអាលុវិហារ ដែលសង់នៅលើដីរៀបស្មើ គេនឹងឃើញបណ្ឌិតភិក្ខុឡើងកាំជណ្តើរថ្មមួយម្តងៗ ហើយភិក្ខុសង្ឆពំនរនោះគង់នៅតែក្នុងរូងថ្មធ្វើការអស់ចំនួន ៦៥ ឆ្នាំទំរាំតែនឹងបានបញ្ជូនបែកនូវព្រះពុទ្ធដីកាពំនមូល មកដល់យើងពំនឡាយ ។ ពួកពុទ្ធិកជនពំនឡាយដែលបានទៅដល់អាលុវិហារ តែងកើតមានមនោគតិនឹកគុណយ៉ាងគោរពដល់កន្ទែងនោះ ។

លុះសតវត្សរ៍កន្ទងមក ការរាតត្បាតពីប្រទេសជិតខាងក៏កើតមានឡើង ប៉ុន្តែសៀវភៅដ៏មានជម្ងៃនេះចេះតែផ្សាយចេញពីប្រទេសមួយទៅប្រទេសមួយឥតឈប់ឈរ ។ សៀវភៅនេះ ចូលទៅដល់ប្រទេសណាអ្នកប្រាជ្ញប្រទេសនោះកត់-ចម្ទង ប្រែរួចយកទៅរក្សាទុក ។ ធ្វើដូច្នេះ ជាការងាយដល់ពួកសាវ៉កព្រះពុទ្ធដែលចង់សៀវជ្រាវច្បាប់ដើម ដូចជាព្រះពុទ្ធដីកាដែលព្រះអង្គបានថ្វែងនៅសម័យកំពង់វិវតន៍ជាដើម ។

មហាសង្គាយនាលើកទី ៥ ធ្វើនៅក្រុងមណ្ឌាលប្រទេសកូមាកាល ពីឆ្នាំ ១៨៧១ ដោយសេចក្តីនិមន្ត - អញ្ជើញនៃព្រះបាទពិនដុង (Bindon) នឹងព្រះបាទអសោកមហារាជ (AsoKa Le grand) ។ ការប្រជុំលើកនេះ មានបំណងនឹងចារិកការប្រៀនប្រដៅព្រះពុទ្ធពាំងអស់នៅលើថ្មដើម្បីកុំឲ្យ រលុបបាន ។ នៅលើផ្ទៃធំមួយមានថ្មកែវ ៧២៩ ផ្ទាំងដែលមានកំពស់ មួយដំហរមនុស្សបញ្ឈរពាសពេញលើកន្ទែងនោះ ។ បន្ទះថ្មនីមួយ ៗ សុទ្ធតែមានធ្វើរោងបង្ហាត្រប់ពីលើ មានសរសរ ៤ ទ ។ នៅលើផ្ទាំងសីលា នោះ ពួកជាងតំនូរយ៉ាងធើត ៗ នៅក្រុងមណ្ឌាលេ បានចារិកសេចក្តីក្នុង ព្រះត្រៃបិដកតាំងពីដើមរហូតដល់ចប់ ។ ពួកទស្សនិកជនដែលដើរតាម ប្រកជ្ជរប្រាសាទតូច ៗ ពាំងនោះអាចមើលបានដោយស្រួលនូវអត្ថបទពាំង អស់ដែលចារិកនៅលើផែនសិលាពាំងសងខាង ។ នៅពេលដែលកើត សង្ត្រាមមួយយ៉ាងសម្បើម នៅត្រង់កន្ទែងជូចពោលខាងលើនេះ, ក្រោយមហាសង្ត្រាមលោកលើកទី ២, ត្រាប់បែកកាំជ្ជួចបានផ្ទោងធ្លាក់ ទៅជិតកន្ទែងនោះ ជាមោតុបណ្ណាលឲ្យថ្មកែវខ្ទះបាក់បែកប្ដក្រឡាប់ផ្តាប់ ផ្ទារអស់ ។ បន្ទិចមក, សង្ត្រាមក៏រលត់ទៅ ។ នៅពេលនោះ ថ្មណា ដែលបាក់បែកល្មមជួសជុលបាន គេក៏បានជួសជុលឡើងវិញ ។ ប៉ុន្តែ សព្វថ្ងៃនេះថ្មពាំង ៧២៩ ផ្ទាំង ក៏បានរៀបចំលើកបញ្ឈរឡើងវិញអស់ ហើយ ។ គឺដោយសារការជឿជាក់ចំពោះព្រះធម៌ នឹងការអង់អាចដែល កើតមានឡើងពីកម្ទាំងសទ្ធា, ប្រទេសកូមាបានខំប្រមូលកំឡាំងដើម្បីរុំមុខ របួសដែលបណ្ណាលមកពីសង្ត្រាម, តែវិសេសទៅទៀតដើម្បីបង្ត្រាប

សង្គ្រាមយោរយៅគឺសង្គ្រាមស៊ីវិល (សង្គ្រាមទំនាស់គ្នាឯង) ។ ដូច្នេះ អំណាចនៃព្រះពុទ្ធសាសនា ក៏បានជួយស្រោចស្រង់ប្រទេសកូមាឲ្យរួចពីសេចក្តីលំបាកវេទនា ។

នៅថ្ងៃ ១ តុលា ១៩៩១, សភាសហរដ្ឋកូមា បានមូលមតិគ្នាធ្វើញត្តិមួយ តាមសេចក្តីស្នើនៃរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដូចតទៅនេះ៖

"មិនសប្បាយចិត្តនឹងវិធានការ ដែលប្រជាជនទំនើរដ្ឋាភិបាលកូមិនពិតពរលោកធ្លើល្បងឡើង ដើម្បីដោះស្រាយបញ្ហាពាំងឡាយដែលមនុស្សជាតិកំពុងប្រឈម ដោយយកជំនួយសម្ភារៈមកជាក់ពីមុខមនុស្សក្នុងការរស់នៅជូចសព្វថ្ងៃនេះ ហើយថាធ្វើដូច្នេះមានរបៀបនឹងជួយបន្ថយសភាវៈនៃការរស់នៅ នឹងជួយបន្ថយស្ថានភាពខាងគ្រឿងសម្ភារៈនៃមនុស្ស ហើយបើសិនជាគំនិតនេះដុះជាប់នឹងខ្លួន នោះឃើញថាវិធានការបៀបនោះដោះស្រាយបានតែផ្នែកបញ្ហាបន្តិចបន្តួចទេ ។

"សភាជាដែលនេះ ប្រកាសសេចក្តីយល់មួយយ៉ាងជាលក្ខណៈថា គឺជាការចាំបាច់ត្រូវតែសម្រេចហើយនឹងបានផ្តើមវិធានការយ៉ាងណាដើម្បីឲ្យបានសេចក្តីសុខដល់ប្រជាជន, ហើយវិធានការនេះអាចកំចាត់នូវបញ្ហាពាំងនេះ ហើយអាចជួយមនុស្សលោកឲ្យបានច្បាស់ថាតក លោក: ទោស: មោហ: ដែលជាឫសគល់នៃការយោរយៅ, ការរំនាសអន្តរាយនឹងជម្ងឺផ្សេងៗ ដែលដុតបំផ្លាញពិភពលោក" ។

អាស្រ័យហេតុនេះហើយ បានជាមហាឧដ្ឋសង្ឃាយនាកើតឡើង ដោយមានបំណងនឹងធ្វើឲ្យបានសម្រេចតាមផែនការនេះ ។ មួយចំណែក

ទៀតដោយយល់ឃើញថា គម្ពីរព្រះត្រៃបិដកក៏បានបោះពុម្ពរួចប្រើន ណាស់ហើយ, ជាការចាំបាច់ ត្រូវការតែរើផ្ទៀងជាថ្ម្ពីម្ពងទៀត ព្រោះ មានអ្នកប្រាជ្ញខ្ទះរំលោភកែច្បាប់ព្រះពុទ្ធនេះ ហើយយកយោបល់យល់ ឃើញផ្ទាល់ខ្លួនមកជំនួស ។ ការយល់នេះ ជួនកាលមានកំរិតតឹងតែង ហួសប្រមាណ ជួនកាលទូលំទូលាយពេក ផ្ទែងហួសពីបទដើម ។

ផ្ទៃនការនៃការសង្គាយនា មានដូចតទៅនេះ

មុនដំបូង, ចែកអត្ថបទបាលីទាំងមូលជា ១០ ភាគ គឺ ក. ទីឃ និកាយ, – ខ. មជ្ឈិមនិកាយ, – គ. សំយុត្តនិកាយ, – ឃ. អង្គុត្តរ-និកាយ, – ង. ខុទ្ទកនិកាយ, – ច. ខុទ្ទកនិកាយ, – ឆ. ខុទ្ទកនិកាយ, – ជ. ខុទ្ទកនិកាយ, – ឈ. ខុទ្ទកនិកាយ អភិធម្ម, – ញ. ខុទ្ទកនិកាយ អភិធម្ម ។

បន្ទាប់មក, ចែកភាគនីមួយៗ ជា ៣ ផ្នែកទៀត ក្នុង ១ ផ្នែកៗ មាន ភិក្ខុ ១០ រូបសម្រាប់ផ្ទៀងហើយទទួលខុសត្រូវក្នុងការពិនិត្យ, ការផ្ទៀង នេះថែមទៀតផង ក្រោយពេលដែលផ្ទៀងរួចដោយព្រៀបធៀបទៅនឹង អត្ថបទដើមនឹងសេចក្តីអធិប្បាយក្នុងនោះ ។ ក្រុមនីមួយៗ មិនមែនមាន ការៈតែប៉ុណ្ណោះទេ គឺមានមុខការខាងរៀបជួសជុលប្ដូលប់ចោលនូវសេចក្តី កន្ទែងខ្ទះដែលភ្ជាំងភ្ជាត់ពីពេលមុន, កែផ្ទៀងផ្ទាត់អដ្ឋាធិប្បាយនឹងអនុដ្ឋា-ធិប្បាយផ្សេងៗ ។

លុះធ្វើការនេះរួច, ក្រុមនីមួយៗ យកអត្ថបទដែលខ្លួនទទួលធ្វើទៅ

ប្រគល់ឲ្យក្រុមមួយទៀតធ្វើសេចក្តីបញ្ជាក់, រួចកំបាំងសេចក្តីនេះទៅ
ប្រធាននៃមហាសង្គាយនាដើម្បីសម្រេចតាមការ ។

ក្នុងសេចក្តីព្រាងទី ១ មានគ្រហស្ថអ្នកប្រាជ្ញជាតិភូមាចំនួន ៤០ នាក់
ចូលជួយធ្វើការនេះផង, ឯគ្រហស្ថទាំងនេះជាអ្នកចេះចាំអត្ថបទទាំងនោះ
យ៉ាងជ្រៅជ្រះ ហើយធ្លាប់ធ្វើការចោះពុម្ពទឹងបកប្រែស្រាប់ ។

សេចក្តីព្រាងទី ១ នេះ ទឹងប្រគល់ប្រគេនព្រះកិក្ខុសង្ឃដែលជ្រើស
រើសយកពីបណ្តាកិក្ខុសង្ឃដែលកាន់ធម្មវិន័យដូចគ្នាឲ្យពិនិត្យ ដូចជាព្រះ
សង្ឃនៅប្រទេសលង្កា, សៀម, កម្ពុជាទឹងលាដែលបាននិមន្តទៅរួម
ប្រជុំធ្វើសង្គាយនានេះ ។ ឯគ្រហស្ថទទួលបន្ទុកខាងប្រែភាសាបាលី
មកជាភាសាភូមា ។

សៀវភៅព្រះត្រៃបិដកមានចំនួន ៥៨ ក្បាល ហើយត្រូវចោះពុម្ព
បង្ហើយទៀតចំនួន ៥០ ក្បាល ។ ក្បាលទីមួយ ។ មានកម្រាស់ ៤០០
ទៅ ៥០០ ទំព័រ ។ ក្នុងអត្ថបទដើម មានសេចក្តីនិយាយច្រើនដែល។ ជា
ច្រើនណាស់ ដូច្នេះការចោះពុម្ពខាងក្រោយនេះអាចលប់ការច្រើនដែលនេះ
ចោលចេញ ។ ចំណែកឯមូលដ្ឋានសំខាន់។ នៃការប្រែច្រៀងរបស់
ព្រះពុទ្ធទឹងរួបរួមចោះពុម្ពជា ២ - ៣ សៀវភៅដែលមានកម្រាស់ចំនួន
៥០០ ទំព័រ ។ សៀវភៅនេះទឹងមានលំនាំជាសៀវភៅព្រះត្រៃបិដក
សង្គ្រោះ សមទៅតាមសេចក្តីអំពាវនាវ នៃពិភពលោក ។

មានកិក្ខុសង្ឃ ២៥០០ រូប ដែលសុទ្ធជាអ្នកប្រាជ្ញចេះដឹងជ្រៅជ្រះ
ក្នុងធម្មវិន័យ បានមករួមប្រជុំរៀបចំធ្វើសង្គាយនាដែលបានបើកពីថ្ងៃ ១៧

មេសា ១៩៥៦ (ព.ស ២៤៩៨) ។ ធ្វើការអស់រវាង ៣ ឆ្នាំនៅក្នុងព្រះវិហារ ដើម្បីរៀបចំកិច្ចការទាំងឡាយដែលនឹងត្រូវធ្វើ; ក្នុងពេលឆដ្ឋសង្គាយនា កម្មវិធីមួយក៏កើតមានឡើងដូចតទៅនេះ ៖

- ចោះពុម្ពអត្ថបទចាលីជាអក្សរភូមា ដោយមានអត្ថាធិប្បាយសព្វត្រប់ ។

- ចោះពុម្ពព្រះត្រៃបិដកសង្ខេប ។

- ចោះពុម្ពព្រះត្រៃបិដកដែលមួយក្បាល ។ ប្រែចេញជាបីភាសាគឺ ភូមា, ឥណ្ឌៀ និង អង់គ្លេស ។

- ចោះពុម្ពព្រះត្រៃបិដកចាលីជាអក្សរទេវនាគរី (រ៉ូម៉ាំង) ។

កម្មវិធីដ៏ធំទូលាយនេះ សព្វថ្ងៃកំពុងតែធ្វើសកម្មភាព ។ រាល់ថ្ងៃព្រះភិក្ខុសង្ឃចំនួន ៥០០ អង្គ, ចែកជាក្រុម ។ ទំប្រឹងធ្វើការនេះឲ្យបានពិតប្រាកដឡើង ។ កិក្ចការក៏បានចំរើនឡើងជាលំដាប់ឆ្ពោះទៅរកទីបំផុតព្រោះអ្នកធ្វើសុទ្ធតែបុគ្គលប្រកបដោយទឹកចិត្តថ្ងៃថ្នូរ, ដោយវិទ្យាសាស្ត្រហើយម្នាក់ ។ ឥតគិតដល់ស្នាដៃ ដល់កិត្តិគុណផ្ទាល់ខ្លួនឡើយ ។ ប៉ុន្តែយើងនៅពុំទាន់ដឹងច្បាស់ តើនៅមណ្ឌលអឺរុបគេអាចប្រជុំអ្នកប្រាជ្ញ ២៥០០ រូបបម្រុងធ្វើការក្នុងរវាង ៥ ឆ្នាំតាមលំក្ខខ័ណ្ឌនេះបានឬទេ តែថាការនេះ ទោះបីដូចម្តេចក៏ជាមេរៀននឹងជាគំរូមួយសម្រាប់ពួកបស្ចិមប្រទេសរួចស្រេចទៅហើយ ។

ការណ៍នេះតម្រូវឲ្យគេរកកន្ទែងមួយយ៉ាងធំល្មម ដើម្បីធ្វើឆដ្ឋសង្គាយនា ។ យោបល់ភាគច្រើនក៏សម្រេចឲ្យសង់មហាអាគារមួយ មាន

សណ្ឋានដូចជាគុហាកុំ ហើយដែលអាចថិតនៅជាកស្ពុតាងមួយនៃការ
ប្រឹងប្រែងនេះផង ។ គុហានេះសង់នៅជិតវត្តសន្ធិកាពពិកពលោក
នៅលើទីធ្លាមួយដ៏ទូលាយចម្ងាយ ២ គីឡូម៉ែត្រពីក្រុងវង្ហួន ។ មហា
អាគារនេះ សង់ឡើងក៏ដើម្បីដម្ពល់ព្រះសារីរិកធាតុរបស់ព្រះសាវ៉កព្រះ
ពុទ្ធពីរអង្គ គឺ ព្រះសារីបុត្រ នឹងព្រះមហាមោគល្លាន ។

រដ្ឋាភិបាលកូមា ក៏បានយល់ព្រមឲ្យខ្ចីប្រាក់ជាប្រើនសម្រាប់ធ្វើការ
ប៉ុន្តែពេលវេលាជិតពេក កិច្ចការនេះក៏ត្រូវការបំណាយយ៉ាងសម្បើម ។
តើគេត្រូវធ្វើដូចម្តេច ដើម្បីរកប្រាក់មកបំណាយធ្វើការ ហើយឲ្យបាន
ក្នុងពេលធាប់ៗ ផង? ត្រង់នេះ ធ្វើឲ្យយើងនឹកឃើញដល់មហាសតវត្សរ៍
ប្រកបដោយចិត្តសទ្ធានៃអ្នកកសាងវិសាលវិហារយើង ។ ប្រជាជនដែល
យល់ច្បាស់នូវសេចក្តីព្រាងធ្វើការនេះ ក៏បចូលគ្នាមកពីគ្រប់ខែត្រនានា
មានចំនួនរាប់ម៉ឺនសែននាក់ចូលរួមធ្វើការដោយចិត្តស្ម័គ្រ; មានតាំងពីជន
គេទៀយដូចជាមនុស្សចាស់, ស្ត្រី, ក្មេង, រហូតដល់ជនដែលមាន
កំឡាំងបរិបូណ៌ ។ ជនចំពួកទីមួយជញ្ជូនដីឲ្យាប់ដោយកញ្ជ្រោងតូចៗ
ជនចំពួកទីពីរជញ្ជូនថ្មធ្ងន់ៗ ។ ជនទាំងអស់គ្មានចង់បានអ្វីក្រៅពីបាយ
ទទួលទានមួយផ្អែតម្នាក់ទេ ។ ក្រោយដែលមានការទំលាក់គ្រាប់បែក,
មានទ័ពបច្ចាមិត្តដើររាតត្បាតចុះឡើង ៗ ពាសពេញនៅលើកន្ទែងនោះ,
ប្រជាជនក៏ទទួលរងទុក្ខវេទនាជាក្រៃលែង, ប៉ុន្តែដោយសេចក្តីព្រាងធ្វើ
ការនេះមានគោលបំណងដ៏ខ្ពង់ខ្ពស់ បានធ្វើឲ្យប្រជាជនភ្លេចនឹកដល់ការ
ទុក្ខលំបាក, ភ្លេចមានគំនិតសងសិក ។ ដូចនេះ រដាភិបាលប្រទេស

កូមាដែលមាន ឯកឧត្តម អ៊ូ-ឌូ ជាអ្នកដឹកនាំមួយយ៉ាងប្រសើរបាន ធ្វើឲ្យប្រជាជនលោកប្រកបដោយឧត្តមគតិថ្លៃថ្នូរ ឧត្តមដោយស្មារតីជាមនុស្សជាតិ ។ ទីបំផុតកិច្ចការទាំងនោះក៏បានរៀបចំហើយស្រេចត្រូវតាមកាលវេលា ។ ទោះព្រះកិត្តិសង្ឃខ្វះមានការគាំពុះសខ្វះក៏ដោយ, ក៏ខំប្រឹងប្រែងរៀបចំឲ្យមានរបៀបធំធ្ងៃសៀវភៅព្រះត្រៃបិដកនេះលុះត្រាតែបានសម្រេច ។

នៅថ្ងៃបុណ្យសម្ពោធមហាអាគារនេះ, មានប្រជាជនចំនួន ២០០.-០០០ នាក់ ឈរនៅទីវាលធំមួយ, រង់ចាំមើលព្រះកិត្តិសង្ឃ ២៥០-អង្គ ធំឃរវាស់អ្នកមានឯកសិទ្ធិ ២០០០ នាក់ និមន្ត-អញ្ជើញចូលជាភ្ញៀវនៅកងគុហានេះ ។ នៅពេលនោះ, ស្ពារសំកោធំងតែស័ង្កក់ប្រគំលាន់ញ្ជរំពងអឺងកង, ស្ទុះបាញ់ភ្លើងកំលាន់ឮពេញអាកាសវេហាស៍ ។ ពួកអ្នកឈរមើលទាំងឡាយក៏មានសេចក្តីសប្បាយជាខ្លៃលែង ព្រោះគេយល់ថា នេះហើយជាសញ្ញានៃសេរីភាព ដែលប្រទេសកូមាប្រគល់សាជាថ្មីដល់ប្រជាជនកូមា ជាបឋមកិច្ចនៃការរើរៀបចំប្រជាជាតិគ្មានកម្មាំង គ្រប់គ្រាន់ដើម្បីបំពេញចិត្តបំណងចង់ប្រើប្រាស់តាមបែបរបស់ខ្លួន ។

មេរៀនដែលប្រទេសកូមាបានបង្ហាញដល់ពិភពលោក បានធ្វើឲ្យពិភពលោកយល់ច្បាស់ ដូចជាមានសារលិខិតជាច្រើនបានអានទៅកងមហាបាសាណគុហា ។ សារលិខិតទាំងនោះមិនមែនផ្ញើមកតែពីប្រទេសដែលមានលទ្ធិព្រះពុទ្ធសាសនាជាសាសនារិសេសវិសាល ដូចជាកម្ពុជា,

លង្កា, ជប៉ុន, សៀម, យៀកណាមនោះទេ គឺមានសារលិខិត ផ្សងទៀតផ្ញើមកពីរដ្ឋាភិបាលមហាក្សត្រិយានីប្រទេសអង្គគ្លេស ពី ៦.ឧ. នាយករដ្ឋមន្ត្រីនឹងរដ្ឋមន្ត្រីទីមួយនៃប្រទេសឥណ្ឌា, ពី ៦.ឧ. រដ្ឋមន្ត្រីទី ១ នៃប្រទេសអីស្រាអែល, ពីគណៈប្រតិភូនៃប្រទេសបាគិស្ថាន ។ល។

ដូច្នេះ កាលណាទៅបានពួកបច្ចិមប្រទេសយល់ថាមនុស្សមិនមែនរស់នៅដោយសារជំនួយសម្ភារៈទេ, ប៉ុន្តែមនុស្សត្រូវការរកផ្លូវណាដែលអាចញ៉ាំងជីវភាពមនុស្សឲ្យបានថ្ងៃថ្ងូរ, រស់នៅដោយស្មូល ។ ពួកអ្នកធ្វើការនៅប្រទេសបស្ចិមទិសជាអ្នកចេះជឹងសមគួរ ល្មមយល់ថាខ្លួនបានក្រេបរស់ជាតិសិទ្ធិនឹងសេចក្តីសុខនៅក្នុងប្រទេសរបស់ខ្លួន ត្រាន់បើជាជាងនៅក្នុងប្រទេសដែលមានរបបត្រប់ត្រងផ្តាច់ការ, ប៉ុន្តែជនទាំងនេះនៅតែពេញចិត្ត ងាកបែរទៅរកមនុស្សក្រុមណាដែលអាចជួយលើកជីវភាពខ្លួនសព្វថ្ងៃដែលរស់នៅតែដោយត្រឹងសម្ភារៈ ឲ្យរឹតតែស្មូលទៀតដោយឲ្យមានគតិរស់នៅរួមគ្នា ព្រោះជនទាំងនោះយល់ថាមានតែគំនិតរស់នៅរួមគ្នានេះហើយដែលអាចប្រាន មនុស្សឲ្យផុតពីសេចក្តីលោភ ។...

គំនិតដើរទៅរកឧត្តមគតិនេះ ព្រះពុទ្ធសាសនាបាននាំយកមកផ្សាយពាស់ពេញលើទ្វីបអាស៊ីទៅហើយ ។ ធ្វើឲ្យរីកធំមិនមែនក្តោបគំនិតមនុស្សលោក ព្រះពុទ្ធសាសនាបានជ្ជួតជ្រាបទៅនឹងខួរក្ស្យាលមនុស្សត្រប់សាសន៍ ត្រប់ប្រទេសដែលបិតនៅក្នុងចន្ទោះប្រទេសជប៉ុននឹងប្រទេសលង្កា ។ ត្រង់នេះ ក៏ប្រហែលជាប្រទេសបស្ចិមទិសយល់មិន

សូវច្បាស់នូវព្រះពុទ្ធចិន្តានេះ ដែលបានបំភ្ជឹមនុស្សលោកឲ្យយល់ច្បាស់អស់ជាឯពាក់កណ្តាលពិភពលោកទៅហើយ ។

សេចក្តីអំពាវនាវរបស់ខ្ញុំ គឺថាការបង្កើតពិធីនេះនៅប្រទេសភូមាជាគំរូមួយអាចពង្រីកសន្តិភាពពាសពេញពិភពលោក ហើយអាចផ្សាយចូលដល់ប្រទេសយៀកណាមផង ។ យើងសូមឲ្យពួកអ្នកកាន់ព្រះពុទ្ធ-សាសនានៅប្រទេស យៀកណាមរិះរកនូវបណ្តាការ ប្រៀនប្រដៅរបស់ព្រះពុទ្ធនេះ នូវមធ្យោបាយមួយសម្រាប់សម្រុះសម្រួលការប្រែះធា នឹងទុក្ខរវៃនាទាំងឡាយ ព្រោះប្រទេសភូមានឹងប្រទេសយៀកណាមបានទទួលការទុក្ខលំបាក ការឈឺចាប់នេះប្រហែលគ្នា ដើម្បីឲ្យយើងអាចសង្ឃឹមថានឹងឃើញមានការធូរថយមែន ដែលកើតមានឡើងក្រោយពេលដែលប្រទេសភូមាបានល្បងធ្វើការនេះ ។

ទីបំផុត តើយើងមានសេចក្តីសប្បាយទេ បើយើងឃើញព្រះពុទ្ធ-សាសនាភ្ជាយទៅជាស៊ីម៉ង៍ត៍ សម្រាបផ្សារថ្នគឺការប្រែះធាទាំងឡាយឲ្យបានដិតស្ងួលនៅក្នុងផែនដីអាស៊ី? យើងសប្បាយបានលុះត្រាតែប្រ-ទេសអាស៊ីភ្ជាយទៅជាព្រះវិហារ, មិនមែនជាបន្ទាយទាហានឡើយ ។

អ្នករក្សាធម៌ ។ ដ្ឋយឲ្យសុ១ អ្នកគ្មានធម៌ទុក្ខឃើញទាន់ហាន់

យ. អិ.

ពិធីបុណ្យ ពុទ្ធាជយន្តិ នៅប្រិនេសឥណ្ឌា

លោក ទៀង-ត្រៃ-ឈុន ក្រុមការដើមវ៉ៃ្យលេខ ២

ប្រែពីសារពតិមានកាំបូជ

ការចំណាយប្រាក់ប្រមាណ ១០ លាន រូបីយ

នៅវេលាឆ្នាំក្រោយ ដើម្បីរៀបចំពិធីបុណ្យនេះ

រដ្ឋាភិបាលឥណ្ឌាបានធ្វើដោយខ្នះខ្នែង នូវការរៀបចំតាំងឡាយ ដើម្បីធ្វើបុណ្យក្នុងពុទ្ធសករាជគំរប់ ២.៥០០ វស្សា នៅខែឧសភា ត.ស. ១៩៥៦ ។

នៅឧកាសបុណ្យនោះ គេចំណាយប្រាក់ប្រមាណ "១០ លាន រូបីយ" សម្រាប់ផ្តល់នូវការរៀបចំពុទ្ធបូជនីយដ្ឋានតាំងឡាយ ដើម្បីចាយវាយចាត់ចែងការបុណ្យនោះឲ្យតែខាងបានល្អ ព្រោះគេស្មានថាមុខជាមានអ្នកស្រុកនឹងអ្នកដំណើរបរទេសមកទស្សនាជាច្រើន ។

ដើម្បីរៀបចំបុណ្យនេះឲ្យបានស្រួលល្អ គេបានបង្កើតគណៈកម្មាធិការជាន់ខ្ពស់មានលោកបណ្ឌិត ស. រ៉ាដាគ្រិស្ហានណន ជាប្រធាន, នាយករដ្ឋមន្ត្រីសហភាពប៉ាគិស្ហាន ប៉ីហារ ភោប៉ាល់ នឹងម្ចាស់ សិក-គីមជាសមាជិក សម្រាប់ត្រួតត្រាការនេះ ឲ្យបានម៉ត់ចត់ត្រឹមត្រូវ ។ នាយករដ្ឋមន្ត្រីឥណ្ឌាក៏ចូលធ្វើការជាមួយគណៈកម្មាធិការខាងលើនេះដែរ ។

រដ្ឋាភិបាលយល់ឃើញថា មុខជាមានអ្នកស្រុកនឹងពុទ្ធជនានាប្រទេសជាច្រើននាក់មកទស្សនាមន្ទីរតាំងព្រះពុទ្ធរូបនោះ ។ ដូច្នេះ

ដើម្បីរើធ្វើឡើងវិញ គេបានគ្រោងរួចជាស្រេចនូវផ្ទូវថ្នល់នានា ព្រម
ទាំងកន្ទែងដែលបិតនៅជិតបូជនីយដ្ឋានសំខាន់ៗ ឲ្យបានល្អឡើង គ្រង់
ដំបន់ជូចតទៅនេះ

– សញ្ជិនៅកោប៉ាល់

– ពុទ្ធតយា រ៉ាតហ្សៀរ ហើយនឹងនាលន្ទានៅប៉ីហារ.

– សារនាថ កុសិនារា សាហេត មហេត ហើយនឹងសាន្ធិស្សា
នៅសហភាពប៉ាតិស្ថាន ។

ក្រៅអំពីការរើធ្វើផ្ទូវថ្នល់ដែលមានស្រាប់ ហើយនឹងការស្ថាបនា
ផ្ទូវថ្នល់ថ្មីដែលជាការគួរធ្វើឡើងនោះ គេកំពុងតែតុបតែងឲ្យល្អនូវទីកន្ទែង
ដែលនៅជិតពុទ្ធបូជនីយដ្ឋាន ។ គេកំពុងតែរៀបចំសង់គេហស្ថាន
សម្រាប់ទទួលពុទ្ធបរិស័ទ ដែលមកទស្សនានៅទកាសបុណ្យនោះ គេ
កំពុងរៀបចំផ្ទត់ផ្ទង់ឲ្យមានទឹកគ្រប់គ្រាន់ ហើយនឹងរៀបចំការផ្សេងៗ
ដើម្បីនឹងផ្តល់ឲ្យពុទ្ធបរិស័ទទាំងនោះបានសេចក្តីសុខស្រួល ។

តមកទៀត គេយល់ថាគួរតែសំអាតនឹងរើធ្វើឡើងវិញ នូវកន្ទែង
ដែលព្រះពុទ្ធទ្រង់ប្រសូតហៅថាលុម្ពិនី ដែលបិតនៅប្រទេសណេប៉ាល់
ហើយគេបានស្នើនឹងរដ្ឋាភិបាលណេប៉ាល់ ដោយច្បាស់លាស់អំពីរឿង
ដឹកនាំពួកពុទ្ធបរិស័ទ ដែលទៅពីប្រទេសឥណ្ឌាឲ្យបានស្រួល ។

ការចំណាយធំៗ ទាំងប៉ុន្មាន ក្នុងការរើធ្វើផ្ទូវថ្នល់ រាជការឥណ្ឌា
រ៉ាប់រងទាំងអស់ តែរឿងសង់គេហស្ថានបណ្តោះអាសន្នហើយនឹងការផ្តល់
នូវកិច្ចការគ្រប់ជំពូកផ្សេងៗ ជល់អ្នកដំណើរទាំងឡាយ ត្រូវរដ្ឋាភិបាល

របស់រដ្ឋអាណាខែត្ររួមគ្នានៅប្រទេសឥណ្ឌា ទទួលបន្ទុកលើខ្លួន
ទាំងអស់ ។

នៅឧកាសបុណ្យនោះ រដ្ឋមន្ត្រីក្រសួងយោសាសការ ត្រូវទទួល
ការៈផ្សាយបេញនូវសៀវភៅ ២ មុខ គឺវិទ្យាសាស្ត្រ ឬ អក្សរសាស្ត្រស្តីអំពីរឿង ២.៥០០ វស្សារបស់ព្រះពុទ្ធសាសនា ១ មុខ, រូបភាពខាងព្រះ
ពុទ្ធសាសនានឹងភាពយន្តរឿងព្រះពុទ្ធសាសនា ១ មុខ ។ រដ្ឋាភិបាល
ប្រុងនឹងជួយប្រាក់ដល់វិជ្ជាស្ថានបាលី នៅនាលន្ទា ដើម្បីឲ្យផ្សាយនូវ
គម្ពីរព្រះត្រៃបិដកខ្ទះជាអក្សរទេវនាគរី ។

រដ្ឋាភិបាលកណ្តាល បំរុងនឹងអញ្ជើញអ្នកប្រាជ្ញនៅប្រទេសពុទ្ធ-
សាសនានានា នឹងអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនានៅអឺរុបជាប្រើននាក់
មកទស្សនាពិធីបុណ្យនោះនៅឥណ្ឌា ។ គេបំរុងនឹងបន្ទយថ្ងៃសំបុត្រ
រថភ្លើងឲ្យពួកពុទ្ធបរិស័ទដែលមកពីប្រទេសក្រៅ ។

គេបំរុងនឹងបង្កើតសន្ទិបាតមួយនៅទីក្រុងញូដែល្លី ក្នុងសិសិរៈ
រដូវឆ្នាំ ១៩៥៦ ដើម្បីជជែកពីរឿងព្រះពុទ្ធសាសនា ហើយនៅឧកាស
នោះ គេនឹងអញ្ជើញអ្នកប្រាជ្ញបរទេសមកពិភាក្សាផង ។ គេបំរុងនឹងធ្វើ
ពិព័ណ៌អន្តរជាតិ ដើម្បីតាំងសិល្បពុទ្ធសាសនានៅវេលានោះដែរ ។
នៅឧកាសនោះ ដើម្បីនឹងលើកកិត្តិយសឲ្យជាក់ស្តែងជល់ពិធីបុណ្យខាង
លើនេះ គេបំរុងនឹងចាត់ឲ្យពួកភ្នាក់ងារនឹងសិស្សានុសិស្សនៅវិទ្យាល័យ
"វិស្សាវ៉ាបាទីរ" ឲ្យលើករឿង "តាតាណ៌" "ណាទារពុយសារ"
យកមកលេងឲ្យពួកពុទ្ធបរិស័ទមើលជាកំសាន្ត ។

គេបំរុងនឹងសាងសិលាចារិកមួយ ទុកជាអនុស្សាវរីយ៍តំណាងព្រះបាទអសោក ។ គេបំរុងនឹងបង្កើតតែមប៉ុស្តិ៍សម្រាប់ប្រើប្រាស់ក្នុងប្រទេសទុកជាអនុស្សាវរីយ៍ដល់បុណ្យពុទ្ធាជយន្តិផង ។

រដ្ឋាភិបាលសហរដ្ឋបានបង្គាប់ ឲ្យក្រសួងសាធារណការនៅទីក្រុង "លុច-ណូរ" ឲ្យរើធ្វើមុនគេជាជាច់ខាតនូវផ្ទូវថ្នល់ណាដែលកាត់តម្រង់ទៅកន្ទែងពុទ្ធបូជនីយដ្ឋានសំខាន់ៗ ដូចជាសារនាថ ហើយនឹងកុសិនារា ។ ការទាំងអស់នេះ ត្រូវធ្វើឲ្យហើយស្រេចក្នុងកិរិយបរិច្ចេទឆ្នាំនេះ ដើម្បីឲ្យស្រួលដល់ការដឹកនាំពួកពុទ្ធបរិស័ទ ដែលមកជួយតុបតែងការបុណ្យ "ពុទ្ធាជយន្តិ" ។

រដ្ឋាភិបាលកណ្តាល យល់ព្រមឲ្យប្រាក់អំណោយពី ២៤ ដល់ ២៩.០០០ រូបីយ ទៅរដ្ឋាភិបាលសហរដ្ឋ ដើម្បីចាត់ចែងនូវសេចក្តីព្រាងខាងលើនេះ ។

* * *

ក្នុងឆ្នាំតំរប់ពុទ្ធសករាជ ២៥០០ ព្រះវស្សានោះ នៅប្រំទេសកម្ពុជាយើង ប្រំហែលនឹងធ្វើពិធីបុណ្យ បញ្ចុះព្រះសារីរិកធាតុ នឹងព្រះអរហន្តធាតុ ក្នុងព្រះចេតិយអនុស្សាវរីយ៍ព្រះសារីរិកធាតុ ដែលគេទើបនឹងសាងនៅមុខស្ថានីយ៍អយស្ម័យយាន ភ្នំពេញ ជាបុណ្យមួយដ៏ធំអស្ចារ្យដែរ ។

បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ១១៥៩ ចុះថ្ងៃសុក្រ ៣ កើតខែបេត្រធ្នាំថោះ ទោស័ក ព.ស. ២៤៩៤ តាំងលោកគ្រូ គង់-វ៉ា នាមធាយាធម្មជោតត្ទេរ កើតធ្នាំមមី អាយុ ៦៩ វស្សា ៤៩ ជាចៅអធិការ វត្តចុងកោះទកញ៉ាតី ស្រុកខ្សាច់កណ្ណាល ខេត្តកណ្ណាល ។

សញ្ញាប័ត្រលេខ ១២០០ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ប៉ុល-កង នាមធាយា ពុទ្ធត្ទេរ កើតធ្នាំធ្ងូវ អាយុ ៥១ វស្សា ២៩ ជាចៅអធិការ វត្តសុខារាម ឃុំត្រាចទង ស្រុកទត្តុង ខែត្រកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ១២០១ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ សែម-ង៉ាន នាមធាយា ជុតិធម្មោ កើតធ្នាំកុរ អាយុ ២៩ វស្សា ៨ ជាចៅអធិការ វត្តស្រះក្រូច ឃុំភ្នំលៀប ស្រុកទឹកជោរ ខែត្របាត់ដំបង ។

សញ្ញាប័ត្រលេខ ១២០២ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ មួង-ជា នាមធាយា ព្រហ្មមុនី កើតធ្នាំវក អាយុ ៣២ វស្សា ៨ ជាចៅអធិការ វត្តថ្មី ឃុំទឹកជោរ ស្រុកទឹកជោរ ខែត្របាត់ដំបង ។

សញ្ញាប័ត្រលេខ ១២០៣ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ពៃ-ប្រាមោទ្យ នាមធាយា ធម្មបញ្ញា កើតធ្នាំមមី អាយុ ៤៦ វស្សា ២៦ ជាចៅអធិការ វត្តពោធ៌ិកវ ឃុំប្រនេតព្រះ ស្រុកទឹកជោរ ខែត្រ បាត់ដំបង ។

សញ្ញាប័ត្រលេខ ១២០៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាប-ដួង នាមធាយ ធម្មសុវិញ្ញាយ្យោ កើតឆ្នាំកុរ អាយុ ៤១ វស្សា ២២ ជាចៅអធិការ វត្តខានខ័ណ្ឌ ឃុំរនាល ស្រុកទឹកជោរ ខេត្តបាត់ដំបង ។

សញ្ញាប័ត្រលេខ ១២០៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ងាំ-រឿ នាមធាយ សធម្មត្តេរោ កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៦ ជាចៅអធិការ វត្តដូនច្រែង ឃុំប្រនេតព្រះ ស្រុកទឹកជោរ ខេត្តបាត់ដំបង ។

សញ្ញាប័ត្រលេខ ១២០៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់-ហាន នាមធាយ ឥន្ទត្តេរ កើតឆ្នាំថោះ អាយុ ២៥ វស្សា ៤ ជាចៅអធិការ វត្តវិហារសួគ៌ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១២១០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សួង-សែម នាមធាយ ឥន្ទសរបញ្ញោ កើតឆ្នាំឆ្លូវ អាយុ ៣៨ វស្សា ១៩ ជាចៅអធិការ វត្តកំពែង ឃុំកំពែង ស្រុកកៃពកប្បាស ខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ១២១១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៀត-ចេង នាមធាយ សុធម្មបញ្ញោ កើតឆ្នាំ ១៩២៣ អាយុ ២៧ វស្សា ៧ ជាចៅអធិការ វត្តពោធិវង្ស ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

(មានត)

ភគ្គមសុទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៧ ខែ ធ្នូ លេខ ១២

ព.ស.២៤៩៨ – គ.ស.១៩៥៥



កម្ពុសន្ទិយា

ទស្សនាវិដ្ឋី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ

ចោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា		ទំព័រ
— មជ្ជរិយៈគឺអ្វី	ព្រះទេពសត្តា កិម - ត្ថ	៨៨៣
— បិត្តកថា	ព្រះបាឡាត់ឧត្តមលិទិត សុង - ស៊ីវ	៨៩០
— បញ្ញាសជាតក ភាគទី ៤ (តមក) . .	បណ្ឌិតមហា ឈឹម - ស៊ីម . . .	៩០៥
ផ្នែកអក្សរសាស្ត្រ		
— សង្ត្រាមកំបាំង	ឃុនបណ្ណានុវ៍ក្ស ប៊ូ - ប៉ូ	៩១៣
— សាលារៀននៅប្រទេសជប៉ុន	អ្នកស្រី សារិះយ៉ាន	៩២០
— រឿងសាមកុក (តមក)	ឧកញ៉ា នូ - កន	៩៣១
— ដំណឹងតាមឡល់ក្នុងកន្ទារៈ (តមក) .	លោក ផេង - ជ្រីវ	៩៣៩
— រឿងបល្ស៍ង្កទិព្យ (តមក)	លោក ភ៉យ - ប៊ុក	៩៤៧
កំណត់នឹងប្រវត្តិការណ៍		
— ពិធីបំបួសកុលបុត្រជាតិបាភំងសែសម្នាក់ នៅវត្តឧណ្ណាលោម	ពុទ្ធសាសនបណ្ឌិត្យ	៩៥៤

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២១០រ,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Macchariya ou l'Avarice . . .	*Vén. KEM-TO*	*883*
— Cittakatha	*Brah Balat SONG-SIV* . .	*890*
— Pannasajataka-vol. 4 (suite) . .	*M. CHHIM-SOUM*	*905*

PARTIE LITTERAIRE:

— La lutte psychologique . . .	*M. BOU-PO*	*913*
— L'éducation au Japon	*Mme SRIN-SARIS-YANN* .	*920*
— Histoire de SAMKOK (suite) . .	*Okuha NOU-KAN*	*931*
— Le souffle du désert (suite) .	*M. PHENG-CHRIV* . . .	*939*
— Les trente deux récits du TRONE (suite)	*M. RAY-BUC*	*947*

NOTES ET CHRONIQUES:

— Gérémonie d'ordination d'un bonzé français à la pagode d'Unnalom	*Institut Bonddhique*	*954*

Prix d'abonnement annuel (comprenant 12 numéros) 210$00

ផ្នែកសាសនា

មច្ចរិយ: គឺអ្វី ?

ព្រះទេពសត្ថា កិម-ត្ថូ ចន្ទមង្គលោ

ក្រុមដំនំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

មច្ចរិយ: គឺ សេចក្តីកំណាញ់ ។ សេចក្តីកំណាញ់នេះ មានដំណើរដែលគ្មរទ្យសង្កេតដឹង ៣ យ៉ាង គឺ មានការលាក់លៀមទុកនូវសម្បត្តិរបស់ខ្លួនជាលក្ខណៈ ១ មានការមិនចេះអត់ធន់ចំពោះសម្បត្តិរបស់ខ្លួនដែលសាធារណៈដល់ជនដទៃជាកិច្ច ១ មានការជូរមុខ ឬ ស្ងួញមុខ ចំពោះសម្បត្តិរបស់ខ្លួនដែលជាច់បង់ទៅជាផល ឬ ត្រើងប្រាកដ ១ ។ មច្ចរិយ:នេះមានប្រភេទចែកចេញជា ៥ យ៉ាង គឺ:

១ - អាវាសមច្ចរិយ	សេចក្តីកំណាញ់អាវាស
២ - កុលមច្ចរិយ	សេចក្តីកំណាញ់ត្រកូល
៣ - លាភមច្ចរិយ	សេចក្តីកំណាញ់លាភ
៤ - វិណ្ណមច្ចរិយ	សេចក្តីកំណាញ់ការសរសើរ
៥ - ធម្មមច្ចរិយ	សេចក្តីកំណាញ់ធម៌

មច្ចរិយ: ពាំង ៥ យ៉ាងនេះ ពិតមែនតែព្រះសម្មាសម្ពុទ្ធទ្រង់សំដែងចំពោះបព្វជិត (អ្នកបួស) ក្នុងព្រះពុទ្ធសាសនា ប៉ុន្តែត្រហស្ថ (អ្នកត្រប់ត្រងផ្ទះ) អាចផ្ទេរសេចក្តីនោះមកជាវត្តសម្រាប់ប្រតិបត្តិចំពោះខ្លួនផងដែរ ដូចសេចក្តីអធិប្បាយជាលំដាប់តទៅនេះ :

អាវាសមច្ចរិយ = សេចក្តីកំណាញ់អាវាស, អាវាម (វត្ត) ជាទីនៅរបស់សង្ឆពាំងមូលក្តី ទីបរិវេណ (ថែវ) ក្តី បន្ទប់មួយ ៗ ក្តី ទីផ្សេង ៗ ក្តី មានកុដិសាលាសម្រាប់សម្រាកនៅក្នុងវេលាយប់ជាដើមក្តី ទីពាំងអស់នេះហៅថា អាវាស ។ មួយទៀត ភិក្ខុពាំងឡាយនៅជាសុខ ពាំងបាននូវបច្ចុយពាំងឡាយក្នុងទីណា ទីនោះក៏ហៅថា អាវាស ដែរ ។ ភិក្ខុជទៃឯណាដែលជាអ្នកប្រាជ្ញចេះដឹងក្តី ជាអ្នកកាន់សីលជាទីស្រឡាញ់នឹងបរិបូណិដោយវត្តប្រតិបត្តិល្អក្តី ភិក្ខុណាមួយហួងហែងអាវាសមិនចង់ឲ្យភិក្ខុនោះចូលមកកាន់អាវាសរបស់ខ្លួនឡើយ ឬមានតំនិតតិតថា "ភិក្ខុដែលមកហើយ ចូរត្រឡប់ចេញទៅវិញឆាប់ ៗ" យ៉ាងនេះជាដើម ភិក្ខុនោះឈ្មោះថា ជាអ្នកកំណាញ់អាវាស ។ ប៉ុន្តែបើបែរជាមិនចង់ឲ្យពួកភិក្ខុអលជ្ជី (អ្នកមិនមានសេចក្តីអៀនខ្មាស) ដែលមានមារយាទអាក្រក់ ជាអ្នកហៃបង្ក៏ហេតុមានជំលោះជាដើម ចូលមកនៅក្នុងអាវាសនោះទេ មិនហៅថាអ្នកកំណាញ់អាវាសឡើយ ។

កុលមច្ចរិយ = សេចក្តីកំណាញ់ត្រកូល, ត្រកូលនៃជនជាឧបដ្ឋាកក្តី ត្រកូលនៃជនជាញាតិ ឬជាសាលោហិតក្តី ហៅថា ត្រកូល

ក្នុងវិនេះ ។ កិក្ខុមិនចង់ឲ្យបុគ្គលដទៃចូលទៅកាន់ត្រកូលនោះ។ ទេ ហៅថាជាអ្នកកំណាញ់ត្រកូល ប៉ុន្តែបើមិនចង់ឲ្យបុគ្គលអាក្រក់មានគំនិតរបៀបបុញ្ចូលទៅកាន់ត្រកូលនោះ ក៏មិនហៅថាជាអ្នកកំណាញ់ត្រកូលទេ ព្រោះបុគ្គលអាក្រក់នោះ កាលបើចូលទៅហើយវាមិនធ្វើត្រកូលនោះឲ្យខូចសទ្ធានឹងសេចក្តីជ្រះថ្លា ។ តែប៉ុបុគ្គលណាចូលទៅហើយអាចរក្សាសទ្ធានឹងសេចក្តីជ្រះថ្លារបស់ត្រកូលនោះឲ្យនៅគង់វង្សដដែល ឬ អាចញុំាងត្រកូលនោះឲ្យចំរើនដោយគុណមានសីលគុណជាដើម ហើយមិនចង់ឲ្យបុគ្គលនោះចូលទៅកាន់ត្រកូលនោះទេ ឈ្មោះថាជាអ្នកកំណាញ់ត្រកូល ។

លាភមច្ឆរិយ=សេចក្តីកំណាញ់លាភ,ចច្ចុយតីរបស់សម្រាប់បរិភោគប្រើប្រាស់ទាំង ៤ យ៉ាងមានចីវរនិងបិណ្ឌបាតជាដើម ហៅថាលាភ ក្នុងវិនេះ ។ កាលបើកិក្ខុដទៃជាអ្នកមានសីល ឬជាអ្នកមានវត្តប្រតិបត្តិល្អ ដែលត្រូវបានទូវលាភនោះ កិក្ខុណាមានគំនិតគិតថា សូមកុំឲ្យលោកនោះបានទូវលាភនោះទៀយ កិក្ខុនោះឈ្មោះថាជាអ្នកកំណាញ់លាភ ។ ប៉ុន្តែបើកិក្ខុណាធ្វើសទ្ធារបស់ខ្លួនឲ្យថយចុះ ឬឲ្យខូចដោយអំណាចដែលបានរបស់ផ្សេង។ មានគ្រឿង១បរិភោគនឹងគ្រឿងបរិភោគជាដើម មកទុកដាក់ហួងហែងមិនបរិភោគប្រើប្រាស់ដោយខ្លួនឯង ទាំងមិនចែករំលែកឲ្យអ្នកដទៃផងទៀត របស់ទាំងនោះក៏ពុកផុយស្អុយរាយអស់ទៅ កិក្ខុឯទៀតឃើញកិក្ខុនោះប្រព្រឹត្តដូច្នេះ ក៏គិតថា

ភិក្ខុនេះមិនគប្បីបានន្ធវវត្ថុនេះឡើយ, ភិក្ខុដទៃជាអ្នកមានសីលគប្បីបានន្ធវវត្ថុនេះបរិភោគប្រើប្រាស់ចុះ ដូច្នេះជាដើមវិញ ភិក្ខុនោះឈ្មោះថាជាអ្នកមិនកំណាញ់លាភទេ ។

វិណ្ណាមប្ជរិយ = សេចក្ដីកំណាញ់ការសរសើរ, ការនិយាយសរសើរសរីរៈក្ដី ការនិយាយសរសើរគុណក្ដី ហៅថា ការសរសើរក្នុងទីនេះ ។ ភិក្ខុអ្នកកំណាញ់ការនិយាយសរសើរសរីរៈនោះ កាលបើមានអ្នកណាមួយនិយាយសរសើរជនដទៃថា អ្នកឯណោះគេមានរូបរាងល្អសមរម្យទាំងសម្ឡរសាច់ឈាមក៏ស្អាតបាត ឆ្ងរជាទីជ្រះថ្ងាណាស់យ៉ាងនេះជាដើម ភិក្ខុនោះក៏អាក់អន់ចិត្ត មិនចង់និយាយចូលជាមួយនឹងជននោះតទៅទៀត នេះហៅថា អ្នកកំណាញ់ការនិយាយសរសើរសរីរៈ ។ ឯភិក្ខុអ្នកកំណាញ់ការនិយាយសរសើរគុណនោះ គឺមិនចង់ឲ្យឮអំពីអ្នកណាមួយនិយាយសរសើរគុណសម្បត្តិរបស់អ្នកដទៃ ឬកាលបើមានគេនិយាយសរសើរជនដទៃចំពោះមុខខ្លួនថា ភិក្ខុឯណោះ ឬឧបាសកឯណោះ មានសីលបរិសុទ្ធល្អ, ប្រព្រឹត្តកាន់ធុតង្គតឹងរ៉ឹងល្អ, មានសេចក្ដីប្រតិបត្តិល្អ មានចរិយាបុកពាសណ្ណាប់ធ្នាប់ល្អ មានការចេះដឹងច្រើន យ៉ាងនេះជាដើម ភិក្ខុនោះមិនចង់ឲ្យគេនិយាយសរសើរអំពីគុណសម្បត្តិរបស់អ្នកដទៃ ទាំងខ្លួនឯងក៏មិនចង់និយាយសរសើរដូច្នោះដែរលោកហៅថា អ្នកកំណាញ់ការនិយាយសរសើរគុណ ។

ធម្មមប្ជរិយ = សេចក្តីកំណាញ់ធម៌, ពាក្យថា ធម៌ ក្នុងទីនេះ
សំដៅយកបរិយត្តិធម៌ និងបដិវេធធម៌ ។ អរិយសាវ័កទាំងឡាយ មិន
កំណាញ់នូវបដិវេធធម៌ទេ លោកចង់ឲ្យមនុស្សលោកព្រមទាំងទេវលោក
បានត្រាស់ដឹងធម៌ ដែលខ្លួនលោកបានត្រាស់ដឹងហើយនោះដែរ មិនតែ
ប៉ុណ្ណោះលោកចង់ឲ្យអ្នកដទៃចេះយល់នូវបដិវេធធម៌នោះផងទៀត និង
មិនបាច់និយាយថ្វីដល់ទៅបរិយត្តិធម៌នោះ ។ ភិក្ខុណា ចេះដឹងធម៌អាថិ
ហើយ មិនចង់សំដែងប្រាប់ដល់បុគ្គលដទៃ ដោយគិតខ្ជាចក្រែងគេចេះ
ដឹងលើសខ្លួនឬស្មើនឹងខ្លួនក្តី កាលបើមានគេត្រូវការរកខ្ចីក្ស្លួនច្បាប់គម្ពីរដី
កាអ្វីយកទៅមើលរៀនសូត្រហើយមិនចង់ឲ្យគេខ្ចីឬ លាក់ទុក ដោយគិត
ខ្ជាចគេរៀនសូត្រទៅមានការចេះដឹងលើសខ្លួនឬស្មើនឹងខ្លួនក្តី ភិក្ខុនោះ
ឈ្មោះថាជាអ្នកកំណាញ់ធម៌ ។ ប៉ុន្តែបើមិនចង់សំដែងប្រាប់ ឬ មិនចង់
ឲ្យខ្ចីគម្ពីរដីកា ដោយយល់ឃើញច្បាស់ថា មនុស្សនោះជាអ្នកបិញ្ញរបុញ
មានចិត្តសាវ៉ មិនចេះថែទាំទុកដាក់បើទុកជាអាត្មាអញ់សំដែងប្រាប់ ឬ
ឲ្យខ្ចីទៅ ក៏មិនយកចិត្តទុកដាក់រក្សាគោរពប្រតិបត្តិតាមធម៌នោះដែរ ភិក្ខុ
នោះមិនឈ្មោះថាជាអ្នកកំណាញ់ធម៌ទ្បើយ ។ មួយទៀត ភិក្ខុណា
មិនសំដែងប្រាប់ ព្រោះពិចារណាឃើញនូវបុគ្គល ហើយអនុគ្រោះដល់
ធម៌ ឬ មិនសំដែងប្រាប់ ព្រោះពិចារណាឃើញនូវធម៌ហើយអនុគ្រោះ
ដល់បុគ្គល ភិក្ខុនេះមិនឈ្មោះថាជាអ្នកកំណាញ់ធម៌ទេ, បានសេចក្តី
ថា បុគ្គលខ្ជះជាអ្នកបិញ្ញរបុញមានចិត្តសាវ៉ ជួនកាលធ្វើជាសមណ:

ជួនកាលធ្វើជាព្រាហ្មណ៍ ជួនកាលធ្វើជានិគ្រន្ថ ក៏ក្ខុណាមិនសំដែង
ប្រាប់ដោយជឹងថា បុគ្គលនេះ កាលបើអាត្មាអញសំដែងធម៌ប្រាប់
ទៅ មុខជានឹងបំបែកបំផ្ទាញនូវធម៌ដ៏ល្អិតសុខុម ជាធម៌មានបែប
ដែនល្អជាប់ជាបវេណីមកឲ្យល្អក់កកវខូចពុំខាន ហើយមិនសំដែងប្រាប់
ព្រោះពិចារណាឃើញនូវបុគ្គលហើយអនុគ្រោះដល់ធម៌ ក៏ក្ខុនេះឈ្មោះ
ថាជាអ្នកមិនកំណាញ់ធម៌ឡើយ ។ ក៏ក្ខុណាមិនសំដែងប្រាប់ដោយជឹង
ថា ធម៌នេះល្អិតសុខុមល្អណាស់ ប្រសិនបើបុគ្គលនេះរៀនទៅ មុខ
ជានឹងព្យាកវគឺពោលអួត់មគ្គផល ហើយលើកតំកើងខ្លួនឯងថាជាបុគ្គល
វិសេសនឹងដល់នូវសេចក្តីវិនាសខ្លួនពុំខាន ហើយមិនសំដែងប្រាប់ព្រោះ
ពិចារណាឃើញច្បាស់នូវធម៌ហើយអនុគ្រោះដល់បុគ្គល ក៏ក្ខុនេះឈ្មោះ
ថាជាអ្នកមិនកំណាញ់ធម៌ឡើយ ។ មួយទៀត បុគ្គលណា ជាអ្នកមាន
ចិត្តស្មោះត្រង់ប្រាថ្នាចង់ចេះចង់ដឹង ដើម្បីនឹងយកធ្វើជាវត្តប្រតិបត្តិរបស់
ខ្លួនដោយពិត ក៏ក្ខុមិនសំដែងប្រាប់ឬមិនឲ្យដោយគិតខ្ទាចថា បុគ្គលនេះ
បើនឹងឲ្យរៀនធម៌នេះទៅ មុខជានឹងបានចេះដឹងហើយនឹងថ្កោលទោស
ឬបំបែកនូវលទ្ធិរបស់អាត្មាអញវិញពុំខាន ក៏ក្ខុនេះទើបឈ្មោះថាជាអ្នក
កំណាញ់ធម៌ ។

ទោសនៃសេចក្តីកំណាញ់

បណ្តាសេចក្តីកំណាញ់ទាំង ៥ យ៉ាង ដូចដែលបានពោលមកហើយ
នោះ សេចក្តីកំណាញ់អាវាស ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅ
កើតជាយក្សឬជាប្រេតទូលទៅសំរាមក្នុងអាវាសដែលខ្លួនជ្ជាប់នៅនោះ ។

សេចក្តីកំណាញ់ត្រកូល ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យរងទុក្ខ, បុគ្គលនោះកាលបើឃើញជនដទៃគេកំពុងឲ្យទាន ឬគេរាប់អានគ្នាជាដើម ក្នុងត្រកូលនោះ ក៏ប៉ែរជាគិតថាត្រកូលរបស់អាត្មាអញនេះបែកបាក់គ្នាហើយតើ! ក៏ក្អួតឈាមចេញអំពីមាត់ខ្ទះ ឈឺពោះបុះរាកខ្ទះ ពោះរៀនជាប់ជាកំណាត់តូចកំណាត់ធំលៀនចេញមកខាងក្រៅខ្ទះ ។ សេចក្តីកំណាញ់លាភ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាយក្សឬជាប្រេត ឬជាពស់ថ្ទាន់ បរិភោគតែរបស់ជាដែលនៃជនដទៃ ។ ការកំណាញ់សេចក្តីសរសើរសរីរ: នឹងការកំណាញ់សេចក្តីសរសើរគុណ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះ ឲ្យទៅកើតជាមនុស្សមានសម្ឋុរអាក្រក់ផង ជាមនុស្សល្ងីល្ងើផង ។ សេចក្តីកំណាញ់ធម៌ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាមនុស្សមានសម្ឋុរអាក្រក់ឬជាមនុស្សល្ងីល្ងើ ។

ន័យមួយទៀត សេចក្តីកំណាញ់អាវាស ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅធេះនៅក្នុងលោហនរក ។ សេចក្តីកំណាញ់ត្រកូលជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាមនុស្សខ្សត់ខ្សោយលាភ ។ សេចក្តីកំណាញ់លាភ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតក្នុងកូដនរក ។ ការកំណាញ់សេចក្តីសរសើរ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាមនុស្សមានសម្ឋុរអាក្រក់ ។ -សេចក្តីកំណាញ់ធម៌ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យកើតក្នុងនរក ។

ចិត្តកថា

ព្រះបាឡាត់ឧត្តមលិទិត សុង - សុីរិ វត្តលង្កា ភ្នំពេញ

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការ ចំពោះព្រះភគវន្តមុនី អរហំ សម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឆដោយសេចក្តីគោរព) ។

វេលានេះ អាត្មាភាព សូមសំដែងនូវពុទ្ធភាសិតម្ជយកន្ទែង ដែលព្រះបរមគ្រូសម្ពុទ្ធ ទេងសំដែងចំពោះព្រះចក្ខុបាលត្ថេរ មាននៅក្នុងសុត្តន្តបិដក គម្ពីរខុទ្ទកនិកាយ. ជាធម្មស្សវនាការដូចតទៅនេះ ។

ពុទ្ធភាសិតនោះថា:

មនោបុព្វង្គមា ធម្មា ។ មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ បក្កំវិ វិហតោ បទំ ។

សេចក្តីថា: ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត បើបុគ្គលណា មានចិត្តដែលទោសប្រទូស្តហើយ ទោះពោលក្តី ធ្វើក្តី (គិតក្តី) នូវទុច្ចរិតទាំងបីប្រការ, ផលជាទុក្ខតែងជាប់តាមបុគ្គលនោះ ព្រោះអំពើទុច្ចរិតទាំងបីប្រការនោះឯង ដូចជាកង់រទេះ ដែលវិលទៅតាមជើងគោ កាលកំពុងនាំទៅនូវនឹម ។

ពុទ្ធភាសិតនេះ ជាគូនឹងពុទ្ធភាសិតមួយកន្លែងទៀត ដែលព្រះបរមគ្រូទ្រង់សំដែងចំពោះមជ្ឈកុណ្ឌលីទេវបុត្រ មាននៅក្នុងគម្ពីរខុទ្ទកនិកាយនោះដែរ ។ ពុទ្ធភាសិតនោះថា:

មនោបុព្ពង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា បេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

សេចក្តីថា ធម្មិតាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត បើបុគ្គលណាមានចិត្តជ្រះថ្លាហើយ ទោះពោលក្តី ធ្វើក្តី (នឹកក្តី) នូវអំពើសុចរិតទាំងបីប្រការ, ផលជាសុខតែងជាប់តាមបុគ្គលនោះ ព្រោះអំពើសុចរិតទាំងបីប្រការនោះឯង ដូចស្រមោលតែងអន្ទោលតាមអត្តភាព ។

រួបរួមសេចក្តីកន្លៃនៃពុទ្ធភាសិតទាំងពីរនេះ ឲ្យខ្លីមកនៅត្រឹមតែពីរយ៉ាងគឺ: ចានទុក្ខក៏ព្រោះចិត្ត ចានសុខក៏ព្រោះចិត្ត ។

សូមអធិប្បាយអំពីពាក្យថា ចិត្ត នេះជាមុន ។

ចិត្ត - សព្ទនេះប្រែថា "ធម្មជាតសម្រាប់សន្សំអារម្មណ៍, សម្រាប់គិត, សម្រាប់ជ្រើសរើសនូវអារម្មណ៍" គឺធម្មជាតល្អិតប្រកបដោយបរមាណុភាពល្អិតយ៉ាងក្រៃលែង ឥតមានរូបកាយសណ្ឋានទ្រង់ទ្រាយឡើយ, គ្រាន់តែជានាមធម៌ប៉ុណ្ណោះ, បើនិយាយខាងបញ្ចក្ខន្ធក៏គឺវិញ្ញាណនោះឯង, ជារបស់ប្រែប្រួលឃ្លេងឃ្លោង, ក្រឡាប់ក្រឡុកទៅមក

ដោយធាប់រហ័សបួន កាលយ៉ាងនេះ បួនកាលយ៉ាងនោះ បានជា
លោកសំដែងអំពីប្រភេទរបស់ចិត្ត ក្នុងគម្ពីរព្រះអភិធម្ម ដោយពិស្តារថា
មាន ១៦១ ចិត្ត, ដោយសង្ខេប មាន ៨៩ ចិត្ត ។ ប៉ុន្តែចិត្តនេះជា
ធម្មជាតតែមួយទេ, ដែលបានជាប្រើនជូច្នោះ ព្រោះបែកតាមប្រភេទ
នៃការប្រព្រឹត្តទៅ, កាលបើប្រព្រឹត្តទៅយ៉ាងណា ក៏ឲ្យឈ្មោះតាម
អាការៈដែលប្រព្រឹត្តទៅយ៉ាងនោះ ។

ចិត្តនេះជាធម្មជាតមិនរើសអារម្មណ៍; ក៏ក្នុងអារម្មណ៍ទាំង ៦ នោះ
តាមតែអារម្មណ៍ណាក៏ដោយ ចិត្តតែងត្រូវការគិត, ត្រូវការដឹង, ត្រូវ
ការសន្សំទាំងអស់; បើរូបារម្មណ៍មកកាន់រង្ខង់ភ្នែកហើយ ចិត្តក៏កើត
ឡើងភ្ជាមទទួលឃើញ, ទទួលដឹងថានេះរូប; បើសទ្ទារម្មណ៍, គន្ធា
រម្មណ៍, ផោដ្ឋព្វារម្មណ៍, ធម្មារម្មណ៍, ចូលមកកាន់រង្ខង់ត្រចៀក, ច្រមុះ,
អណ្តាត, កាយ, ចិត្តហើយ វិថីចិត្ត ក៏កើតឡើងភ្ជាម ទទួលព្ទ, ទទួល
ហិត, ជញ្ជក់ជញ្ជាប, គិត, ដឹងថា នេះសំឡេង, នេះក្ងិន, នេះរស,
នេះសម្ផស្ស, នេះធម៌ ដោយពិតឥតមានអាក់ខានឡើយ ។

ត្រង់ពាក្យថា "បានទុក្ខ ក៏ព្រោះចិត្ត បានសុខក៏ព្រោះចិត្ត" នោះ
អធិប្បាយថា: បុគ្គលនឹងធ្វើកិច្ចការអ្វី ៗ ដោយកាយក្តី ដោយវាចាក្តី
ក៏ព្រោះចិត្តរិះគិតផ្តើមឡើងជាមុនទើបធ្វើបាន, កាលបើចិត្តគិតខុសហើយ
កិច្ចការនោះ ៗ ក៏មិនល្អ, ថែមទាំងមានសេចក្តីទុក្ខកើតឡើងផង; បើ
ចិត្តរិះគិតត្រូវ ទើបមានផលល្អ ជាគុណឲ្យបានសេចក្តីសុខចំរើនដល់
ខ្លួន ។ ព្រោះកម្មគឺអំពើដែលសត្វធ្វើគ្រប់យ៉ាង ដែលនឹងមានផលក្ងៀវ

ក្នា ក៏អាស្រ័យនឹងចេតនា, ឯចេតនាគឺជាតួកម្ម, បានជាព្រះមានព្រះភាគទ្រង់សំដែងថា ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតតែងថា ចេតនា ជាតួកម្ម ។

ការលបើសត្វទាំងឡាយធ្វើអំពើណាមួយប្រកបដោយសេចក្តីលោភ, សេចក្តីក្រោធ, សេចក្តីវង្វេង អំពើនោះចាត់ជាអកុសលកម្ម ។ កម្មទាំងពីរនេះឲ្យផលផ្សេងគ្នា គឺកុសលកម្មឲ្យផលជាសុខ, អកុសលកម្មឲ្យផលជាទុក្ខ ។ បានជាមានភាសិតមួយកន្លែង លោកសំដែងប្រៀបកម្មធៀបគ្នានឹងការបណ្ពុះពូជវត្ថុទាំងពួងថា:

យាទិសំ វិប្បតេ ពីជំ តាទិសំ លភតេ ផលំ
កល្យាណការី កល្យាណំ បាបការី ច បាបកំ ។

សេចក្តីថា: មនុស្សក្នុងលោក គេសាបព្រោះបណ្ពុះពូជបែបណា, តែងជុះកើតបានជាដើមបញ្ចេញផ្ការផ្ទែមកជាបែបនោះវិញ មានឧបមាជូចម្តេចមិញ; កល្យាណជនអ្នកធ្វើអំពើល្អតែងបានល្អ, បាបជនអ្នកធ្វើអំពើអាក្រក់តែងបានអាក្រក់ មានឧបមេយ្យជូច្នោះដែរ ។

ភាសិតនេះសំដែងចុចបំផុសសេចក្តីឲ្យឃើញថា: បើសត្វណាបានធ្វើអំពើល្អឬអាក្រក់, អំពើនោះឯង ក៏បែងចែកវលែកឲ្យសត្វនោះ។ បានល្អឬអាក្រក់តាមបែបដែលធ្វើ; អំពើអាក្រក់នាំសត្វទៅកាន់ទុគ្គតិ, អំពើល្អនាំសត្វទៅកាន់សុគតិ ។ ទាំងនេះក៏សម្រេចមកតែអំពីចិត្តជាប្រកពនាំអាទ៍ជាមុនទាំងអស់ ។

សូមលើកឧទាហរណ៍ ជាបុគ្គលាធិដ្ឋានមកសំដែងឲ្យឃើញផល
របស់អំពើល្អនឹងអំពើអាក្រក់ ដូចតទៅនេះ ។

អំពើល្អឲ្យផលជាសុខ, ដូចរឿងធម្មិកឧបាសក:, ធម្មិកឧបាសក
នោះ ជាអ្នកបរិបូណិដោយកល្យាណធម៌ច្រើនយ៉ាង, រៀលាមានជម្ងឺ
ទៀបនឹងដល់មរណ: ឲ្យកូនទៅនិមន្តភិក្ខុទាំងឡាយមកស្វាធ្យាយសតិ-
បដ្ឋានសូត្រ; កំពុងតែស្តាប់ធម៌, បានឃើញទេវតាក្នុងធកាមវចរសួគិ
ទាំង ៦ ជាន់ យកនូវរថ ៦ មកអញ្ជើញ ឲ្យទៅកើតក្នុងពិភពរបស់
ខ្ជូន ។ ។ ធម្មិកឧបាកសកលុះច្យុតពីមនុស្សលោកនេះទៅ បានទៅ
កើតក្នុងតុសិតសួគិ ។ នេះក៏មកតែពីចិត្តដែលយល់ត្រូវ ហើយបានធ្វើ
អំពើល្អទើបបានផលជាសុខយ៉ាងនេះ ។

អំពើអាក្រក់ឲ្យផលជាទុក្ខ, ដូចរឿងប្រេតទាំង ១០ នាក់ ដែលរង
ទុក្ខវេទនា នៅក្សែរភ្នំគិជ្ឈកូដ, រឿងនេះមានសំដែង នៅក្នុងគម្ពីរសំយុត្ត-
និកាយ ត្រង់លក្ខណសំយុត្ត អដ្ឋិសង្ខលិកវគ្គ; ក្នុងសូត្រនោះសំដែងថា:

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវ៉ន ជិតក្រុង
រាជគ្រឹ: ។ សម័យនោះឯង, ព្រះមោគ្គល្ចានត្ថេរ នឹងព្រះលក្ខណត្ថេរ
គង់នៅលើភ្នំគិជ្ឈកូដ ។

ថ្ងៃមួយ ព្រះថេរ:ទាំងពីរអង្គ នាំគ្នាចុះពីភ្នំគិជ្ឈកូដ ក្នុងបុព្ធណ្ហ-
សម័យ ដើម្បីទៅបិណ្ឌបាតឯក្រុងរាជគ្រឹះ ។ កាលដែលកំពុងចុះពីភ្នំ
នោះ, ព្រះមោគ្គល្ចានបានឃើញប្រេតទាំង ១០ នាក់កំពុងរងទុក្ខវេទនា;
លោកក៏បានធ្វើនូវការញញឹម ។ ព្រះលក្ខណត្ថេរ ឃើញព្រះមោគ្គល្ចាន

ញញឹមដូច្នោះ ក៏សួរថា ម្នាលអាវុសោ, ហេតុដូចម្តេចបានជាលោក ញញឹម? ព្រះមោគ្គល្ចានតបថា: ម្នាលអាវុសោ, កាលនេះខ្ញុំពុំគួរ ប្រាប់លោកទេ, លោកចាំសួរខ្ញុំក្នុងទីចំពោះព្រះភ័ក្ត្រព្រះសាស្តាចុះ ។

លុះត្រឡប់មកពិបិណ្ឌបាតវិញ, ក្នុងវេលាក្រោយភត្ត, ព្រះថេរ ទាំងពីរអង្គ ក៏ចូលទៅតាល់ព្រះមានព្រះភាគ, ថ្វាយបង្គំហើយអង្គុយក្នុង ទីដ៏សមគួរ ។ ព្រះលក្ខណត្ថេរ ក៏សួរព្រះមោគ្គល្ចានថា: ហេតុដូច ម្តេចបានជាលោកញញឹមក្នុងកាលនោះ? ព្រះមោគ្គល្ចានប្រាប់ថា ក្នុង កាលនោះខ្ញុំបានឃើញប្រេត ១០ នាក់មានអាការប្លែកៗ គ្នា គឺ:

ទី ១ – ខ្ញុំឃើញអដ្ឋិសង្ខលិក គឺរាងធ្មឹងកំពុងអណ្តែតទៅតាម អាកាស, ពួកត្មាតក្អែករអាតដេញតាមធាប, ចោមចិកចោះ, តើបជញ្ជែង នូវរាងធ្មឹងទាំងនោះ; រាងធ្មឹងនោះចេះតែស្រែកថ្ងូរ; ម្នាលអាវុសោ ទើបខ្ញុំ គិតថា អើ! ហ្ន៉ ! អស្ចារ្យណាស់, យីអើ! មិនធ្លាប់ឃើញសោះ យីអើ! ការបានអត្តភាពបែបនេះមានដែរតើ; ដោយហេតុនេះបានជាខ្ញុំញញឹម ។

ត្រានោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា: ម្នាល ភិក្ខុទាំងឡាយ, សត្វនោះ តថាគត ធ្លាប់ឃើញមកអំពីមុនដែរ, ប៉ុន្តែ តថាគត មិនទាន់សំដែង ព្រោះថាបើតថាគតសំដែងរឿងសត្វន៉ុះទៅ ជនទាំងឡាយណាដែលមិនជឿពាក្យតថាគត, សេចក្តីមិនជឿរបស់ជន ទាំងនោះនឹងនាំឲ្យខានបានប្រយោជន៍, នាំឲ្យបានតែសេចក្តីទុក្ខអស់ កាលជាយូរអង្វែង; ប៉ុន្តែវេលានេះ សាវ័ករបស់តថាគតមានចក្ខុបាន ឃើញដែរហើយ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់សំដែងប្រាប់ផលកម្មរបស់សត្វ
នោះថា ម្នាលភិក្ខុទាំងឡាយសត្វន៉ុះ, កាលពីដើមជាគោឃាដក: គឺ
អ្នកសម្ចាប់គោ នៅក្នុងក្រុងរាជគ្រឹះនេះឯង; ដោយវិបាករបស់កម្មនោះ
ក៏ទៅធេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន, សេសសលពីវិបាកនៃកម្ម
នោះ, ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្ចានប្រាប់ព្រះលក្ខណាត្ថេរតទៅទៀតថា:

ទី ២ - ខ្ញុំបានឃើញ មំសបេសិ គឺចំរៀកសាច់ កំពុងអណ្តែតទៅ
តាមអាកាស, ញ្ជកត្មាត ក្អែក - រអាត ដេញតាមធាប, ចោមចិកចោះ
ភើចជញ្ជែងនូវចំរៀកសាច់នោះ ចំរៀកសាច់នោះក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វ
នោះទៀតថា: ម្នាលភិក្ខុទាំងឡាយ, សត្វន៉ុះ កាលពីដើមជាគោឃាដក:
គឺអ្នកសម្ចាប់គោ នៅក្នុងក្រុងរាជគ្រឹះនេះឯង ។

ព្រះមោគ្គល្ចានប្រាប់ព្រះលក្ខណាត្ថេរតទៅទៀតថា:

ទី ៣ - ខ្ញុំបានឃើញ មំសបិណ្ឌ: គឺដុំសាច់កំពុងអណ្តែត ទៅ
តាមអាកាស, ញ្ជកត្មាត ក្អែក - រអាត ដេញតាមធាប, ចោមចឹកចោះ
ភើចជញ្ជែងនូវដុំសាច់នោះ ដុំសាច់នោះក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វ
នោះទៀតថា: ម្នាលភិក្ខុទាំងឡាយ សត្វន៉ុះកាលពីដើមជាព្រានបក្សី
នៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅធេះក្នុង

នរកអស់សែននៃឆ្នាំជាច្រើន, សេសសល់វិបាករបស់កម្មនោះ ក៏ត្រឡប់
មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលកូណត្ថេរតទៅទៀតថា:

ទី ៦ – ឱ្យុំបានឃើញនិច្ចវិបុរស គឺបុរសមិនមានស្បែកខាងក្រៅ
កំពុងអណ្តែតទៅតាមអាកាស ពួកត្មាត-ក្អែក រអាត ដេញតាមធាប
ឯបាមចឹកបោះ គើចជញ្ជែងនូវបុរសត្មានស្បែកនោះ។ ក៏ចេះតែស្រែកថ្ងូ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់សំដែងប្រាប់បុព្វកម្មរបស់
សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយ សត្វនុ+ះកាលពីដើមជាអ្នក
សម្លាប់ចៀមនៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ
ក៏ទៅធេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន, សេសសល់វិបាករបស់កម្ម
នោះក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលកូណត្ថេរ តទៅទៀតថា

ទី ៥ – ឱ្យុំបានឃើញ អសិលោមបុរស គឺបុរសមានរោមដូចដាវ
កំពុងអណ្តែតទៅតាមអាកាស, ដាវទាំងនោះក៏អណ្តែតធ្លាក់ ។ មកត្រូវ
កាយបុរសនោះ។ ក៏ចេះតែស្រែកថ្ងូ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វ
នោះទៀតថា: ម្នាលភិក្ខុទាំងឡាយ សត្វនុ+ះកាលពីដើមជាអ្នកសម្លាប់
ជ្រូកនៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅធេះ
ក្នុងនរកអស់សែននៃឆ្នាំជាច្រើន, សេសសល់វិបាកនៃកម្មនោះ ក៏ត្រឡប់
មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានច្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៦ - ខ្ញុំបានឃើញ សត្តិលោមបុរស គឺបុរសមានរោមដូចលំពែងកំពុងអណ្តែតទៅតាមអាកាស, លំពែងទាំងនោះក៏អណ្តែតជាប់ៗមកត្រកាយបុរសនោះ ក៏ចេះតែស្រែកថា ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងច្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយ, សត្វនុ៎ះ កាលពីដើមជាព្រានម្រឹគនៅក្នុងក្រុងពជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះក៏ទៅធ្លាក់ក្នុងនរកអស់រាប់សែននៃឆ្នាំជាច្រើន សេសសល់វិបាកនៃកម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានច្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៧ - ខ្ញុំបានឃើញ ឧសុលោមបុរស គឺបុរសមានរោមដូចព្រួញកំពុងអណ្តែតទៅតាមអាកាស, ព្រួញទាំងនោះក៏អណ្តែតជាប់ៗមកត្រកាយបុរសនោះ ក៏ចេះតែស្រែកថា ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងច្រាប់បុព្វកម្មរបស់សត្វនោះទៀត ថា: ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ កាលពីដើមជាតេជ្ឈឃាដនៅក្នុងក្រុងពជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅធ្លាក់ក្នុងនរកអស់រាប់សែននៃឆ្នាំជាច្រើន សេសសល់វិបាកនៃកម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានច្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៨ - ខ្ញុំបានឃើញ សូចិលោមបុរស គឺបុរសមានរោមដូចដែក

ស្ងួច កំពុងអណ្តែតតាមអាកាស, ដែកស្ងួចទាំងនោះ ក៏អណ្តែត ជ្ជាក់ ៗ មកត្រូវកាយបុរសនោះ ៗ ក៏ចេះតែស្រែកថ្ងូ ៗ

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វ នោះទៀតថា ម្នាលភិក្ខុទាំងឡាយ, សត្វន៉ុះ កាលពីដើមជាអ្នកបរ (បំបោល) គោ នៅក្នុងក្រុងរាជគ្រឹះនេះឯង ៗ ដោយវិបាករបស់កម្ម នោះ ក៏ទៅធេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន សេសសល់វិបាក របស់កម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ៗ

ព្រះមោគ្គល្ជានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៩ – ខ្ញុំបានឃើញ សូចិលោមបុរស គឺបុរសមានរោមដូចដែក ស្ងួច កំពុងអណ្តែតតាមអាកាស, ដែកស្ងួចទាំងនោះ ក៏ដោតចូល ទៅក្នុងក្បាល ជ្ជាយចេញមកតាមមាត់, ដោតចូលទៅក្នុងមាត់ជ្ជាយចេញ មកតាមទ្រូង,ដោតចូលទៅក្នុងទ្រូង ជ្ជាយចេញមកតាមពោះ, ដោត ចូលទៅក្នុងពោះ ជ្ជាយចេញមកតាមភ្លៅ, ដោតចូលទៅក្នុងភ្លៅ ជ្ជាយ ចេញមកតាមស្មង, ដោតចូលទៅក្នុងស្មង ជ្ជាយចេញមកតាមបាត ជើង; បុរសនោះ ក៏ចេះតែស្រែកថ្ងូ ៗ

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វ នោះទៀតថា: ម្នាលភិក្ខុទាំងឡាយសត្វន៉ុះ, កាលពីដើមជាអ្នកចាក់ ដោត គឺញុះញង់គេ នៅក្នុងក្រុងរាជគ្រឹះនេះឯង ៗ ដោយវិបាក របស់កម្មនោះ ក៏ទៅធេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន, សេសសល់ វិបាករបស់កម្មនោះ ក៏មកបានអត្តភាពបែបនេះឯង ៗ

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណាត្ថេរតទៅទៀតថា:

ទី ១០ - ខ្ញុំបានឃើញ កុម្ភណ្ឌបុរស គឺ បុរសមានអណ្ឌៈប៉ុនក្អម កំពុងអណ្តែតតាមអាកាស, កាលបុរសនោះដើរទៅ លុះតែលើកអណ្ឌៈដាក់លើកលីទើបដើរទៅបាន, កាលអង្គុយក៏អង្គុយសង្កត់លើអណ្ឌៈនោះឯង, ពួកត្មាត - ក្អែក រអាត ដេញតាមឆាប, ចោមចោះចឹក, ភើចដញ្ជែងនូវបុរសនោះ ៗ ក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះ ព្រះមានព្រះភាត ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្មាលភិក្ខុទាំងឡាយ, សត្វនុ៉ះ កាលពីដើបជាអ្នកកាន់អំពើវៀចក្នុងស្រុក, ជាអ្នកវិនិច្ឆីយក្តីដោយទុច្ចរិត នៅក្នុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះក៏ធេះក្នុងនរក អស់សែននៃឆ្នាំជាច្រើន, សេសសល់វិបាកនៃកម្មនោះ ក៏មកបានអត្តភាពបែបនេះឯង ។

សាធរៅ បពិតសប្បុរសទាំងឡាយ នេះក៏មកតែពីចិត្តដែលយល់ខុសហើយធ្វើអំពើអាក្រក់ ទើបបានផលជាទុក្ខមានអាការៈផ្ទែក ៗ យ៉ាងនេះ ។

កាលបើចិត្តជាធម្មជាតសំខាន់បំផុតដូច្នេះហើយ, សាធុជនដែលមានប្រាថ្នាសេចក្តីសុខសេចក្តីចំរើន, គួរតែរក្សាចិត្តតាមពុទ្ធភាសិតដែលទ្រង់ជាស់គឿនរំលឹកថា:

សុទុទ្ធសំ សុនិបុណំ យត្ថកាមនិបាតិនំ
បិត្តំ រក្ខេថ មេធាវី បិត្តំ ទន្តំ សុខាវហំ ។

សេចក្តីថា: បុគ្គលជាបណ្ឌិតមានប្រាជ្ញា គួរខំបីបាច់រក្សាចិត្តដែល

ឃើញបានដោយកម្រ, ដែលល្អិតពន់ពេក ដែលលង់ទៅក្នុងអារម្មណ៍ ឯណាហើយ មិនងាយនឹងទាញឲ្យងាកចេញមកវិញបាន; ចិត្តដែលអ្នកមានប្រាជ្ញាបានរក្សាហើយ តែងនាំសុខមកឲ្យជាអនេក ។

ឯការរក្សាចិត្តនោះ ក៏គឺប្រយ័ត្នចិត្តមិនឲ្យប្រឡាក់ដោយគ្រឿងសៅហ្មង, ឲ្យជូរផង់នៅជាប្រកតីនោះឯង ។

ចិត្តនេះ ព្រះមានព្រះកាតទ្រង់សំដែងថា: បភស្សរមិទំ ភិក្ខុផ ចិត្តំ តញ្ច ខោ អាគន្ទុកេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ។ ម្នាលកិក្ខុទាំងឡាយ ចិត្តនេះជាធម្មជាតស្អាតជូរផង់ ប៉ុន្តែរមែងសៅហ្មងដោយឧបក្កិលេសទាំងឡាយដែលចូលមកថ្មី ។ គួរនាជូចវត្ថុគ្រឿងប្រើប្រាស់ទាំងពួង មានសំពត់ជាដើមដែលនៅថ្មី សុទ្ធតែជារបស់ស្អាតទាំងអស់, ប៉ុន្តែវត្ថុទាំងនោះរមែងសៅហ្មង ដោយគ្រឿងពុំស្អាតទាំងឡាយមានធូលីជាដើម ដែលចូលមកប៉ះពាល់ខាងក្រោយ ។ ឯឧបក្កិលេសនោះសោត ក៏ជាអកុសលជាតដែលកើតមកអំពីចិត្ត ហើយត្រឡប់ប្រទូស្តចិត្តឲ្យសៅហ្មងវិញ ដូចប្រែះដែលកើតអំពីដែក ហើយត្រឡប់ស៊ីដែកឲ្យខូចជូច្នោះឯង ។

ឧបក្កិលេសគ្រឿងសៅហ្មងចិត្តនោះ ព្រះមានព្រះកាតសំដែងថាមាន ១៦ យ៉ាង គឺ: ១ – អភិជ្ឈាវិសមលោក: "ល្មោភវំវិពចង់បានទ្រព្យគេ", ២ – ទោស: "ប្រទូស្ត", ៣ – កោធ: "ក្រោធ", ៤ – ឧបនាហ: "ចងក្រោធទុក", ៥ – មក្ខ: "លុបគុណគេ",

๖- បុលាស "រ៉ៃកែអែបអប", ๗- ឥស្សា "ច្រណែន", ๘- មច្ឆរិយៈ "កំណាញ់", ๙- មាយា "លាក់ពុត", ๑๐- សាឋេយ្យៈ "អួតអាង", ๑๑- ថម្ភៈ "រឹងត្អឹង", ๑๒- សារម្ភៈ "ប្រកែងវាសនា", ๑๓- មានៈ "ច្រកាន់ខ្លួន" ๑๔ អតិមានៈ "មើលងាយគេ", ๑๕- មទៈ "ស្រវឹង", ๑๖- បមាទៈ "ធ្វេសច្រហែស" ។ អកុសលធម៌ទាំង ๑๖ ប្រការនេះ សូម្បីណាមួយ កាលបើបណ្តោយឲ្យវុកវានចូលមកកន្លងចិត្តហើយ សុទ្ធតែធ្វើចិត្តឲ្យសៅហ្មងពុំថ្លាស្អាតទាំងអស់; ព្រោះហេតុដូច្នោះ ចានជាលោកហៅថា ឧបក្កិលេស ។ ឧបក្កិលេសនោះ ទោះបីច្រើនដល់ទៅ ๑๖ ក៏ពិតហើយ ប៉ុន្តែពុំកើតកន្លងវេលាមួយជាមួយគ្នាទេ រមែងផ្ទាស់ប្តូរគ្នាកើត ។

ម្យ៉ាងទៀត ចិត្តតែមួយទេ តែកាលបើមានកុសលធម៌ណាមួយមកសណ្ឋិតនៅដូចជាម្ចាស់ផ្ទះហើយ, ឧបក្កិលេសដែលជាអកុសលធម៌ ក៏ពុំអាចលុកលុយចូលមកបាន, កាលបើមានអកុសលធម៌ណាមួយចូលមកសណ្ឋិតនៅដូចជាម្ចាស់ផ្ទះហើយ, កុសលធម៌ ក៏រកឱកាសចូលមកពុំបាន ។ ព្រោះហេតុនោះ សាធុជនដែលមានបំណងនឹងធ្វើចិត្តរបស់ខ្លួនឲ្យថ្លែថ្លាថ្លាស្អាត, គួរតែខំញ៉ាំងកុសលធម៌ឲ្យកើតមានឡើងជាប់នៅកន្លងចិត្តជានិច្ចកាល ។

ឯកុសលធម៌នោះ កាលបើលើកយកតែកុសលដែលគួរឲ្យកើតបានកន្លងចិត្តខានពុំបាន, ហើយមានឧបការៈច្រើនផងមកសំដែង, ក៏គឺសតិសម្បជញ្ញៈ ព្រោះលោកសរសើរថា ធម៌ពីរប្រការគឺសតិនឹងសម្បជញ្ញៈ

ជាធម៌មានឧបការ:ច្រើន ។ សតិគឺសេចក្តីរលឹក, សម្បជញ្ញ:គឺសេចក្តីដឹងខ្លួន; គុណធម៌ទាំងពីរនេះប្រព្រឹត្តទៅក្នុងកិច្ចជាមួយគ្នា ផ្សងតែអាការ: គឺសតិជាក្នាក់ងារខាងការនឹកឃើញក្នុងវេលាដែលធ្វើហើយ, និយាយហើយ, គិតហើយ, សូម្បីកន្ទងទៅយូរហើយ ក៏នឹកឃើញបាន; សម្បជញ្ញ: ជាក្នាក់ងារខាងការដឹងខ្លួនក្នុងវេលាដែលកំពុងធ្វើ, កំពុងនិយាយ, កំពុងគិត ។ ឯចិត្តបើឥតសម្បជញ្ញ:គ្រប់គ្រងហើយ តែសូះបម្រះនម្រៀលទៅរកវិសភាគារម្មណ៍ផ្សង ៗ តាមតែប្រទះ, សេចតែនឹងប្រាថ្នាមិនរើសថាជូចម្តេចគួរ ពុំគួរឡើយ ។

ចំណែកចិត្តដែលមានសតិសម្បជញ្ញ:គ្រប់គ្រង រមែងចេះរើសរកតែចំណែកដែលល្អ ៗ ឥម្មតារថទឹមសេះដែលគ្មានសារថីបរ, សេះតែងនាំបោលទៅតាមទំនើងចិត្តរបស់វា រមែងសូះទៅផ្តសផ្តាស, ជល់នេះ ជល់នោះរៀងទៅតាមផ្លូវ ធ្វើឲ្យកើតសេចក្តីអន្តរាយតាមតែប៉ះ ជលទង្គិចអ្វីក៏ដោយ ពុំបានស្រួលឡើយ ។

ចំណែករថដែលមាននាយសារថីអ្នកឈ្ទាស់វៃនៅគ្រប់គ្រងរក្សា រមែងលឿនទៅត្រង់តាមរបៀបនៃមាគា, ពុំធ្វើឲ្យកើតសេចក្តីអន្តរាយជល់នរណា ឬអ្វីមួយឡើយ, ញ្ចាំងប្រយោជន៍នៃការប្រើរថឲ្យសម្រេចដោយល្អ សេចក្តីនេះមានឧបមាយ៉ាងណាមិញ, ឯការប្រព្រឹតទៅរបស់មនុស្សក៏យ៉ាងនោះដែរ, គឺបុគ្គលអ្នកមិនមានសតិសម្បជញ្ញ: រមែងមានកាយ វាចា ប្រព្រឹត្តខុស ៗ ភ្ជាត់ ៗ ធ្វើឲ្យកើតសេចក្តីអន្តរាយជល់ខ្លួននឹងអ្នកដទៃ ។ ចំណែកបុគ្គលអ្នកមានសតិសម្បជញ្ញ: រមែងមានកាយ, វាចា

ប្រព្រឹត្តទៅត្រង់តាមផ្លូវ ដែលល្អ ។ ជាហេតុឲ្យបានសេចក្តីសុខដល់ខ្លួន និងអ្នកដទៃ ។ ហេតុនេះសប្ប្យុរសទាំងឡាយគួរឲ្យមានសតិសម្បជញ្ញៈ តាំងនៅក្នុងត្រប់ ។ កាល ។

ធម្មិទេសនាដែលសំដែងមកក្នុងវេលានេះ សន្ធត់ថាចប់ដោយសង្ខេបតាមកាលវេលា ។

ធម្មទេសនានុភាវេន សុខិតា ហោន្តុ បានិនោ
ទ្វីសុ អត្ថេសុ តិដ្ឋន្តុ សហ សព្វេហិ ញាតិភិ ។

ដោយអានុភាព នៃធម្មទេសនានេះ សូមឲ្យសត្វនិករទាំងឡាយបានប្រកបដោយសេចក្តីសុខ ហើយស្ថិតនៅក្នុងប្រយោជន៍ទាំងពីរ គឺ ប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ព្រមទាំងញាតិទាំងឡាយត្រប់ឆ្នា ។

មានទ្រព្យរាប់ថាប្រសើរ

៧ – អ្នកមានទ្រព្យកាលពីក្រីក្រ គេមិនគោរពបូជា ក៏ត្រឡប់គោរពបូជា, គេមិនសេពគប់ ក៏ត្រឡប់សេពគប់, គេមិនថ្វាយបង្គំ ក៏ត្រឡប់ថ្វាយបង្គំ នេះជាអានុភាពនៃទ្រព្យសម្បត្តិ ។

ការងារទាំងអស់ ដែលលុះដល់ក្តីសម្រេចទៅបាន មកពីទ្រព្យសម្បត្តិ ព្រោះហេតុនោះទ្រព្យសម្បត្តិជាផ្លូវនាំឲ្យធ្វើអ្វីសម្រេចបានទាំងអស់ ។

បណ្ឌិតមហា ឈឹម-សុីម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឬប្រែហើយពិនិត្យរៀងរាត់ដោយខ្លួនឯង

កាលដែលនៅជាគោចរបច្ចុប្បន្នភាព ព.ស. ២៤៨៦, គ.ស. ១៩៤៣

(ត្រមក)

សុធនុសុនមហាកជាតក (១) ទី ១៩

លោកអាចារ្យ ឈឹម-សុីម ប្រែជាភាសា

អតីតេ ពារាណសីនគរេ ឯកោសេដ្ឋី បដិវសតិ ។

ក្នុងកាលដ៏កន្លងនៃលងទៅហើយ មានសេដ្ឋីម្នាក់ នៅនគរពារាណសី ។ គ្រានោះព្រះពោធិសត្វ ចាន់អន្លោលមកចាប់កំណើត កើតក្នុងត្រកូលគហបតីសេដ្ឋីនោះ ។ កាលដែលព្រះពុទ្ធកស្សប ទ្រង់គង់ជរាមាយុទៅឡើយ, មានព្រះថេរៈមួយព្រះអង្គ ចង់ធ្វើវិវេកនៅក្នុងព្រៃដើម្បីឲ្យកើតសេចក្តីស្ងប់ស្ងាត់; ដូនជាព្រះពោធិសត្វ ចូលទៅកាន់ព្រៃរំពៃមើលនាយមើលការ ក៏ស្រាប់តែប្រទះឃើញព្រះថេរៈនោះ មានឥរិយាបថស្រគត់ស្រគំសមរំជាអ្នកប្រព្រឹត្តធម៌, ពោធិសត្វមានសេចក្តីត្រេកអរក៏ចរចូលសំដៅទៅគាចថ្វាយបង្គំ អង្គុយនៅទីសមគួរហើយសួរព្រះថេរៈថា លោកម្ចាស់គង់នៅដីនេះឬ? ព្រះថេរៈឆ្លើយថា ចំពោះពារ ។

---

១ ជាតកនេះ តែងតាមទំនង មហាសុទស្សនសូត្រ ក្នុងគម្ពីរទីឃនិកាយមហាវគ្គ និង មហាបរិនិព្វានសូត្រ ក្នុងគម្ពីរទីឃនិកាយ ជាដំរិវគ្គ ដោយអនុវត្ត ។

ពោធិសត្វតិតថា "កាលនេះ ជាកាលគួរនឹងធ្វើបុណ្យ" ហើយក៏ចោះ
បង់ការង់ារបស់ខ្លួន បែរទៅធ្វើបណ្ណសាលា ធ្វើទីចង្ក្រម ជីកអណ្ណូង
រាយដីខ្សាច់ជុំវិញ បូជាដោយវត្ថុទាំងឡាយមានទានធូបគ្រឿងក្រអូប
កម្រង់ផ្កាជាដើម ហើយវេរនូវវិហារទាន មានទាំងគ្រឿងបរិក្ខារសព្វគ្រប់
ប្រការរួចស្រេច ទើបថ្វាយបង្គំលាព្រះថេរៈចូលទៅស្រុកវិញ ។ ចាប់
ដើមអំពីថ្ងៃនោះមក ពោធិសត្វនោះ តែងផ្គត់ផ្គង់ទំនុកបំរុងព្រះថេរៈ
ប្រគេនត្រៃចីវរ ប្រគេនចង្ហាន់បិណ្ឌបាត ប្រគេនបង្អែមគ្រប់មុខ ប្រគេន
ទ្រនាប់ព្រះបាទ ឈើច្រត់ ពាងទឹក គោម ចង្កៀង ត្រែតាំង គ្រឿង
កម្រាល នឹងបញ្ចគោរសទាំង ៥ ប្រការ ។ ព្រះថេរៈកាលធ្វើអនុ-
មោទនា បានសំដែងធម៌ទេសនាថា

អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ
យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ (១) ។

បុគ្គលអ្នកឲ្យនូវបិណ្ឌបាតបច្ចុយ មានបាយជាដើម ឈ្មោះថាឲ្យ
កម្ទាំង, បុគ្គលអ្នកឲ្យនូវគ្រឿងសំលៀកបំពាក់ មានសំពត់ជាដើម
ឈ្មោះថាឲ្យពណិសម្ស្យរ, បុគ្គលអ្នកឲ្យនូវយានជំនិះ ឈ្មោះថាឲ្យ
សេចក្តីសុខ, បុគ្គលអ្នកឲ្យប្រទីបជ្វាល្វា ឈ្មោះថាឲ្យភ្នែក ។

ពោធិសត្វនោះប្រគេនគ្រឿងបរិក្ខារសព្វគ្រប់ប្រការ ហើយជាំគុម្ព
បន្ទាជារបងព័ទ្ធពីក្រៅ, ខាងក្នុងរបងនោះ ជាំដើមត្នោត មានរបៀប

---

១ គាថានេះ ស្រង់មកពីគម្ពីរសំយុត្តនិកាយ សគាថវត្ត ។

ជាជូរៀងរាយ ជាទីរហោស្ថានក្សេមក្សាន្តសប្បាយ សមជាទីលំនៅនៃ
បព្វជិតអ្នកស្វែងរកវិវេក ។ ពោធិសត្ត និមន្ត្រពះថេរៈឲ្យគង់ចាំវស្សា
នៅក្នុងទីនោះ, ដល់ថ្ងៃចាតុទ្ទសីនឹងថ្ងៃបណ្ណរសី ក៏តែងនៅរក្សា
ឧបោសថក្នុងទីនោះដោយខ្ជួនឯងផង ។ ដល់រៀលាចេញវស្សា ពោធិ-
សត្ត និមន្ត្រពះថេរៈឲ្យទៅជ្ជះ ឲ្យពះថេរៈគង់លើបញ្ញត្តាសនៈ, បាន
ស្តាប់ធមិអាថិរបស់ពះថេរៈហើយ ប្រគេនចង្ហាន់បិណ្ឌបាតនឹងសំពត់មួយ
គូទៀត ។ ពោធិសត្ត្រនោះទំនុកបំរុងពះថេរៈ នឹងធ្វើបុណ្យមានសកាព
ជូច្នេះអស់កាលមួយជីវិត, លុះអស់ជន្មាយុច្យុតិអំពីអត្តភាពនោះទៅ បាន
ទៅកើតក្នុងទេវលោក សេពសោយសម្បត្តិក្នុងស្ថានសួគ៌ ប្រកបដោយ
អាយុទិព្ធ យសទិព្ធ សយនាទិព្ធ សម្ជស្សទិព្ធ ឧជារសទិព្ធ ភោជន
ទិព្ធ ត្ថរ្យតន្ត្រីប្រកបដោយអង្គ ៥ ប្រការក៏ជាទិព្ធ របាំក៏ជាទិព្ធ ចម្រៀង
ក៏ជាទិព្ធសព្ធប្រការ, ទ្រង់កំសាន្តនៅក្នុងទេវលោកនោះ អស់កាលជាយូរ
អង្វែង; កាលពះអង្គអស់ពះទិព្ធជន្មាយុ ច្យុតអំពីទេវលោកនោះមក
ទ្រង់បានមកសម្ភពចាប់កំណើតកើតក្នុងកុសាវតីមហានគរ ជាបរមក្សត្រ
ដ៏បវរ ទ្រង់ពះនាមពះបាទសុទស្សនៈ បានឡើងហានន្ទរៈជាសម្តេច
ពះបរមចក្រព័ត្រាធិរាជ ប្រកបព្រមដោយកែវ ៧ ប្រការ គឺចក្ករតន៍
ហត្ថីរតន៍ អស្សរតន៍ ឥត្ថីរតន៍ មណីរតន៍ គហបតិរតន៍ បរិនាយករតន៍ ។
ចក្ករតន៍ មកអំពីសមុទ្រ, ហត្ថីរតន៍ មកអំពីត្រកូលជំរីធទ្ធន្ត, អស្សរតន៍
មកអំពីត្រកូលសេះ ពលាហកៈ, ឥត្ថីរតន៍ មកអំពីឧត្តរកុរុទ្វីប, មណីរតន៍

មកអំពីក្នុងវិបុលបពត៌, គហបតីវគ្គ៌ កើតក្នុងកុសាវតីមហានគរ, បរិនាយកវគ្គ៌ មកអំពីជម្ពូទ្វីប ។

មានពាក្យបុច្ឆាចោទដល់ធ៌ិសូរថា សម្បត្តិនេះ កើតឡើងដោយផលអ្វី? វិសជ្ជនាថា កើតឡើងដោយផលនៃកុសលកម្ម ។ មិនត្រឹមតែវគ្គ៌ ៧ ប្រការប៉ុណ្ណោះទេឬយ, មានសម្បត្តិដទៃទៀត។ កើតឡើងជារូបិន គឺឃ្វាំង ๘ ម៉ឺន ๔ ពាន់ កើតឡើងដោយផលនៃបណ្ណាហារភូជមួយ ។ មានកែវមណីជោតិ ๘ ម៉ឺន ๔ ពាន់ កើតឡើងដោយផលនៃប្រទិបមួយ ។ មានព្រះរាជបុត្រ ๙ ហ្មឺន ๔ ពាន់ កើតឡើងដោយផលនៃឈើច្រត់មួយ, ព្រះរាជបុត្រមួយព្រះអង្គ។ សុទ្ធតែជាវីរបុរស អាចញ៉ាំញីនូវសេនានៃស្តេចដទៃបាន មានដំយះដ៏ធំនៃឈ្មោះរៀបក្នុងមណ្ឌលសកលជម្ពូទ្វីប ។ មានដំរី ๘ ម៉ឺន ๔ ពាន់ កើតឡើងដោយផលនៃដំគ្រែមួយ ។ មានសេះ ๘ ម៉ឺន ๔ ពាន់ កើតឡើងដោយផលនៃដើងកាំជ្រួយ ។ មានរាជរថ ๘ ម៉ឺន ๔ ពាន់ កើតឡើងដោយផលនៃគ្រែនាប់ព្រះឃ្នង ๑ សម្រាប់ ។ មានកែវ ๗ ប្រការ ๘ ម៉ឺន ๔ ពាន់ កើតឡើងដោយផលនៃកម្រាលមួយ ។ មានឃ្វាំងសំពត់ ๘ ម៉ឺន ๔ ពាន់ កើតឡើងដោយផលនៃគ្រែចំវែ, សំពត់ទាំងនោះមានសាច់ល្អ ។ គឺជាសំពត់កោសេយ្យកំសុ កប្បាសិកំសុ ទុឆំសំពត់ន័លកម្ពល ក្តេកម្ពល ដែលកើតឡើងក្នុងមណ្ឌលកុសាវតីមហានគរ ។ មានកំណប់ ๘ ម៉ឺន ๔ ពាន់កន្លែង កើតឡើងដោយផលនៃពាងទឹកជំមួយ ។ មានដង្កែកស្រូវ ๘ ម៉ឺន ๔ ពាន់ កើតឡើងដោយផលនៃចង្ក្រានបិណ្ឌបាត ។ មានបញ្ជាគោរសជាតិផ្អែម ๘ ម៉ឺន ๔ ពាន់

កើតឡើងដោយផលនៃបញ្ចគោរស ។ មានស្រះ ៨ ម្ទឹន ៤ ពាន់ ពេញ
ដោយកែវ ៧ ប្រការ កើតឡើងដោយផលនៃអណ្ណ្ឌងទឹកមួយ ។ មាន
ឧជ្យានព្រមទាំងស្រះបោក្ខរណី ៨ ម្ទឹន ៤ ពាន់ កើតឡើងដោយផលនៃ
ឧជ្យាន ។ មានទិព្ធកោជនប្រកបដោយឧជារស ៨ ម្ទឹន ៤ ពាន់ កើត
ឡើងដោយផលនៃបង្ហាន់ ។ មានកំពែង ៧ ជាន់ កើតឡើងដោយផល
នៃការដាំបន្ទារបងទាងក្រៅ កំពែង ១ ជាន់សុទ្ធសឹងមាស, កំពែង ១ ជាន់
សុទ្ធសឹងប្រាក់, កំពែង ១ ជាន់សុទ្ធសឹងទង់ដែង, កំពែង ១ ជាន់សុទ្ធ
សឹងកែវប្រពាឡ, កំពែង ១ ជាន់សុទ្ធសឹងកែវមណី, កំពែង ១ ជាន់
សុទ្ធសឹងកែវទទឹម កំពែង ១ ជាន់សុទ្ធសឹងកែវ ៧ ប្រការ, ។ មាន
កំពែងដើមត្នោត ៧ ជាន់ កើតឡើងដោយផលនៃការដាំដើមត្នោត,
កំផែងដើមត្នោត ១ ជាន់ សុទ្ធសឹងមាស, ដើមត្នោតមួយជាន់សុទ្ធសឹង
ប្រាក់, ដើមត្នោត ១ ជាន់សុទ្ធសឹងទង់ដែង, ដើមត្នោត ១ ជាន់សុទ្ធសឹង
កែវទទឹម, ដើមត្នោត ១ ជាន់ សុទ្ធសឹងកែវប្រពាឡ, ដើមត្នោត ១
ជាន់សុទ្ធសឹងកែវផលិក ដើមត្នោត ១ ជាន់ សុទ្ធសឹងកែវ ៧ ប្រការ;
ត្នោតទាំងនោះ មានស្ទឹក ១ ជាងជាមាស, ស្ទឹក ១ ជាងជាប្រាក់ ស្ទឹក
១ ជាងជាទង់ដែង, ស្ទឹក ១ ជាងជាកែវប្រពាឡ, ស្ទឹក ១ ជាងជាកែវ
មណី, ស្ទឹក ១ ជាងជាកែវទទឹម, ស្ទឹក ១ ជាងជាកែវ ៧ ប្រការ; ក្នុង
ត្នោត ១ ដើមៗ មានផ្ទៃ ៧ ជ្ជាយ, ផ្ទៃ ១ ជ្ជាយជាមាស, ផ្ទៃ ១ ជ្ជាយ
ជាប្រាក់, ផ្ទៃ ១ ជ្ជាយជាទង់ដែង, ផ្ទៃ ១ ជ្ជាយជាកែវប្រពាឡ,
ផ្ទៃ ១ ជ្ជាយជាកែវផលិក, ផ្ទៃ ១ ជ្ជាយជាកែវទទឹម, ផ្ទៃ ១ ជ្ជាយជាកែវ

៧ ប្រការ ។ ស្ងឹកភ្នែតនឹងផ្លែត្នោតទាំងអស់នោះសឹងដុំរុងរឿងក្តី ផ្ទេរនៅលើច្រាលផ្លែ, កាលបើត្រូវខ្យល់បក់មកត្រសៀក ។ រំតើយ ។ ក៏ឮសូរលេងល្បើយ ស័ព្ទសាន់ធាំ ដូចគេប្រគំបញ្ចេតូរ្យតន្ត្រី ពួកមនុស្សម្នាមហាជនតាំងប្រុសតាំងស្រី តាំងពីស្តេតាំងនាម៉ឺនសព្វមុខមន្ត្រី បាននេចក្តីសុខក្សេមក្សាន្ត ឥតមានសេចក្តីទុក្ខរំខានព្រួយកង្វល់កិត តិតតែស៊ីផឹកលេងសប្បាយពាល់ខែពាល់ឆ្នាំ ខ្លះកំខ្លះប្រឡែង ខ្លះខេះដៃបន្ទរ ខ្លះមានចិត្តរីករាយសប្បាយត្រេកអរ កៀកកកាន់ដៃគ្នាដើរជាពួក ។ ។ ក្នុងកុសាវតីមហានគរ ឮតែសូរទ្រហឹងខ្ទរខ្ទារ ស្ទើរតែនឹងបែកត្រចៀកស្រួតផែនច្រឡំ ដោយសន្ធឹកដីរ សន្ធឹកសេះ សន្ធឹករទេះ នឹងសូរគង សូរគាំង សូរស្គរ ។ ក្នុងកុសាវតីមហានគរជានគរដ៏ធំមាំមាំស្តុកស្តម្ភបរិបូណ៌ដោយវត្ថន៍ ៧ ប្រការ ព្រះពាជាមហាសុទស្សនៈទ្រង់គង់សោយពាជសម្បត្តិនៅនាននគរនោះ ទ្រង់មានមហិទ្ធិរិទ្ធិក្រៃវិសេ បរិបូណ៌ដោយឃ្លាំងមាសឃ្លាំងប្រាក់ ឃ្លាំងរបស់ប្រើនប្រការ ណាឆ្ងៃខ្ញុំរាជាយពួកចម្រើង ពួករាប់ពួកតូរ្យតន្ត្រី ប្រគំថ្វាយសព្វទិវាពតី ឥតលោះថ្ងៃមួយខ្លើយ ។ តេន វុត្តំ ព្រោះហេតុនោះបានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងថា បុរសស្ត្រីឯណា បានឱ្យថ្វាយក្តី ទឹកក្តី សំពត់ក្តី យានជំនិះក្តី ផ្ការម្រងក្តី គ្រឿងលាបក្តី ទីដេកក្តី ទីសំណាក់អាស្រ័យក្តី ប្រទីបជ្វាលាក្តី, បុរសស្ត្រីនោះរមែងបានខ្ជូវសម្បត្តិមានសភាពដូច្នេះក្នុងលោកនេះ ។

បុច្ឆាសួរថា ព្រះចាតុមហាសុទស្សនៈនោះ មានព្រះជន្មប៉ុន្មានឆ្នាំ ?

វិសជ្ជនាថា ព្រះអង្គជាពជកុមារ ក្រសាលល្បែងកីឡាអស់ ៨ ម៉ឺន ៤ ពាន់ឆ្នាំ, បានសោយសម្បត្តិជាស្តេចចុបពាជ ៨ ម៉ឺន ៤ ពាន់ឆ្នាំ បានសោយពាជ្យជាចក្កពត្តិរាជ ៨ ម៉ឺន ៤ ពាន់ឆ្នាំ, ទ្រង់ប្រព្រឹត្តព្រហ្មចរិយធម៌ ៨ ម៉ឺន ៤ ពាន់ឆ្នាំ រួមទាំង ៤ កាល ត្រូវជា ៣ សែន ៣ ម៉ឺន ៦ ពាន់ឆ្នាំ ។ ព្រះជន្មាយុចំនួនប៉ុណ្ណេះ មិនមែនព្រះវរពាជមាតាបិតាទ្រង់ព្រះពាជទានមកឡើយ គឺជាផលនៃបណ្ណសាលាមួយ នាំព្រះជន្មាយុនេះមកថ្វាយព្រះអង្គ ។ តេនាហ ភគវា ព្រោះហេតុនោះបានជាអង្គសម្តេចព្រះភគវន្តាចារ្យ ទ្រង់ត្រាស់ព្រះពុទ្ធដីកាថា

សទ្ធាបុព្វង្គមំ ទានំ អប្បំ វា ពហុំ បិយេ ភវំ
បសន្នា តីសុ កាលេសុ លភតិ តិវិធំ សុខំ
សុខមានុស្សយំ ទេតិ សគ្គេសុ ច បរមំ សុខំ
តតោ ច និព្វានសុខំ សទ្ធាទេន លភតិ

ការឲ្យទានមានសទ្ធាជាប្រធាន, ទានវត្ថុសូម្បីបន្តិចបន្តួច ដែលបុគ្គលឲ្យចំពោះបដិគ្គាហកជាទីស្រឡាញ់ ហើយបុគ្គលនោះមានសេចក្តីជ្រះថ្លាក្នុងកាលទាំង ៣ ក៏រមែងបានទទួលសេចក្តីសុខទាំង ៣ ប្រការ គឺសេចក្តីសុខក្នុងមនុស្សលោក ទីដ៏សេចក្តីសុខក្នុងឋានសួគ៌ទៅលោកទីដ៏សេចក្តីសុខក្នុងព្រះនិព្វាន; សេចក្តីសុខទាំងនេះ បុគ្គលតែងបានដោយការឲ្យទានគ្រប់ជំពូក ។

ព្រះពោធិសត្វធ្វើនូវការកុសលគ្រប់ជំពូក ដរាបដល់ទីបំផុតព្រះ

ជន្មាយុទ្រង់ច្យុតអំពីអត្តភាពនោះ ទ្រង់បានទៅចាប់បដិសន្ធិកំណើត កើត
ក្នុងពិមានមាស ឲ្យដ៏ពិភពតាវតឹង្សទេវលោកសួគិនាយ មានពពួកស្រី
ទេពអប្សរទាំងឡាយ ចោមរាមគាល់បំរើជាប្រើនសព្វកាលវេលា ។
ចំណែកខាងពួកមហាជន អ្នកនគរទាំងអស់គ្នាបានធ្វើការកុសលគ្រប់
ប្រការ ដល់ទីបំផុតអាយុ ក៏បានទៅកើតក្នុងទេវលោកដែរ ។
តេនាហ ភគវា ព្រោះហេតុនោះបានជាអង្គសម្តេចព្រះភគវន្តាចារ្យទ្រង់
ត្រាស់ព្រះធម៌ទេសនាថា

សាធឈា សុទកាមា យេ បដ្ឋេត្វា សគ្គមោក្ខមគ្គំ
ទានំ ទត្វា សាមគ្គិយា បុតា ឥប្ជន្តិ តេ សគ្គន្តិ

ម្នាលសប្ប្យរសអ្នកចង់បានទូវសេចក្តីសុទាំងឡាយ, ជនទាំង
ឡាយឯណា ប្រាថ្នាទូវផ្ទូវនៃហានសួគិនឹងព្រះនិព្វាន បានឲ្យទានដោយ
សាមគ្គី ជនទាំងឡាយនោះ លុះច្យុតអំពីលោកនេះរមែងដល់ទូវហាន
សួគិនឹងព្រះនិព្វានដោយពិត ។

ចប់ សុទស្សនមហាភដិភាតក្ខ ទី ១៩

ផ្នែកអក្សរសាស្ត្រ

សង្ត្រាមកំចាំង

យុនបណ្ណានុវត្ស ប្ប៊ូ-ប្ប៉ូ រៀបរៀង

ការច្បាំងគ្នាជណ្តើមយកជ័យជំនះ ហៅថា សង្ត្រាម ។ នេះមាន ៤ ប្រភេទ គឺ សង្ត្រាមដែលអ្នកផងទាំងពួងមើលឃើញច្បាស់នឹងភ្នែកដូចយ៉ាងប្រទេសមួយលើកវេហ៍ពលសកលយោធាជាកងទ័ព មានគ្រឿងសស្ត្រាវុធយុទ្ធភ័ណ្ឌសព្វគ្រប់ ទៅច្បាំងជណ្តើមយកជ័យជំនះក្នុងប្រទេសជទៃ ហៅថា សង្ត្រាមមិនកំបាំង (អប្បដិច្ចន្នសង្គាមោ); សង្ត្រាមមួយប្រភេទទៀត ដែលឥតជនណាម្នាក់មើលឃើញច្បាស់នឹងភ្នែកខ្លួនសោះ ទាំងចិត្តគំនិតរបស់អ្នកនោះសោតទៀត ក៏សំគាល់ថាខ្លួនបានសុខសាន្តត្រាណណាស់ កើតមកជាតិនេះមានភ័ព្វវាសនាល្អ មិនដែលទៅចូលច្បាំងក្នុងសមរភូមិម្តងទេ ប៉ុន្តែ គំនិតរបស់អ្នកនេះបែរជាខុសផ្ទុយគ្នាស្រឡះទៅវិញ ព្រោះថាតាមការណ៍ពិត ខ្លួនអ្នកមិនដែលឃើញសង្ត្រាមសោះនោះ តែងស្ថិតនៅក្នុងយុទ្ធភូមិជានិច្ច តតាំងច្បាំងនឹងសឹកសត្រូវរាល់វេលា តែភ្នែកម្នកនោះមិនឃើញ ក៏សំគាល់ថាខ្លួនបានសុខណាស់ មិនដែលធ្វើចម្បាំងទេ ។ សង្ត្រាមដែលគ្មានអ្នកណាមើលឃើញនឹងភ្នែកយ៉ាងនេះ ហៅថា សង្ត្រាមកំបាំង (បដិច្ចន្នសង្គាមោ) ។

សង្ត្រាមមិនកំបាំង មិនបាច់សរសេរក្នុងទីនេះទេ ព្រោះអស់លោក

ឆ្លាប់ជ្រាបស្រាប់ហើយ ។ សូមសរសេរចំពោះតែសង្ត្រាមកំបាំងដូចត
ទៅនេះ ៖

សង្ត្រាមកំបាំង កើតមានឡើងដំណាលគ្នានឹងកំណើតរបស់មនុស្ស, មានមនុស្សកើតឡើងកាលណា សង្ត្រាមកំបាំងក៏មានកាលនោះដែរ ។ មានមនុស្សនៅក្នុងទីកន្លែងណា ទោះម្នាក់ឯងក្តី ច្រើននាក់ក្តី សង្ត្រាមកំបាំងក៏មាននៅទីកន្លែងនោះដែរ ។

ចុះអាងហេតុអ្វី បានជាហ៊ានសរសេរយ៉ាងនេះ?

អាងហេតុថា សង្ត្រាមកំបាំងកើតមាននៅក្នុងខ្លួនមនុស្សគ្រប់រូបទាំងប្រុសទាំងស្រី មិនមែនកើតមាននៅទីកន្លែងណាមួយដោយឡែកក្រៅពីរូបមនុស្សទេ ។ ព្រោះហេតុនេះ ត្រូវសន្និដ្ឋានថា រូបមនុស្សម្នាក់ៗ ឈ្មោះថាជាទីយុទ្ធភូមិមួយៗ ។ គ្រប់មនុស្សក្នុងលោកនេះទោះបីប្រុសឬស្រី ក្មេងឬចាស់ សុទ្ធតែតតាំងច្បាំងនឹងសឹកសត្រូវ (កិលេស) ក្នុងខ្លួនទាំងអស់គ្នា គ្មានអ្នកណាខានច្បាំងបានឡើយ ហើយច្បាំងជានិច្ចរាល់ថ្ងៃខ្មាំទៀត ច្បាំងតាំងពីកើតមករហូតដល់ស្លាប់ទៅវិញទើបឈប់ ។ សូមជ្រាបរឿងសង្ត្រាមកំបាំងតាមឧទាហណ៍តទៅនេះ ៖

ទារកកើតមកភ្លាម ស្រែកយំភ្លាម ទារកខ្លះសន្លប់បាត់មាត់យូរបន្តិចទៅទើបស្រែកយំ ។ ម្តាយឲ្យសូរកូនយំ ក៏បញ្ចុកដោះទៅក្នុងមាត់រាៗ ជញ្ជក់ទឹកដោះលេបចូលទៅក្នុងពោះរាទាល់តែឆ្អែតហើយ រាលែងឃ្មៅទៀត ។ អាការដែលទារកស្រែកយំដោយស្រេកឃ្លានយ៉ាងនេះ ឈ្មោះថាមានសឹកសត្រូវ គឺសេចក្តីស្រេកឃ្លានកើតឡើងដល់រា លុះរា

ឡៅដោះឆ្នែតហើយ រាឈប់យំ រាដេកស្ងៀម នេះឈ្មោះថារាចាំងនឹង
សេចក្តីស្រេកឃ្ងាន (ចិបាសសន្ត្តាមោ) ។

លុះតារកនោះចំរើនវ័យធំឡើង រាងអាយុ ៦ ឬ ៧ ឆ្នាំ ដឹងក្តីហើយ
ក៏តាំងចាប់ផ្តើមចូលសាលារៀនសូត្រចំណេះវិជ្ជាផ្សេង ។, លោកអ្នក
ឆ្ងាប់រៀនសូត្រពីក្មេងតង់តែនៅចាំមិនភ្លេចថា ក្នុងត្រាកំពុងរៀននោះតើ
មានសេចក្តីទុក្ខលំបាកយ៉ាងណាខ្លះ? នឿយហត់ដូចម្តេចខ្លះ? ទើស
ទាក់នឹងឧបស័ត្តបែបណាខ្លះ? ខ្ញុំមិនបាច់សរសេរក្នុងទីនេះទេ ។ សូម
ជ្រាបថាកុមារ-កុមារី ដែលរៀនសូត្របានដល់ត្រើយនៃវិជ្ជាតាមប្រាថ្នា
នោះ មិនមែនជាអ្នកធ្វើចម្បាំងតិចតួចទេ ជាអ្នកចូលប្រយុទ្ធយ៉ាងខ្ជាំង
ត្រប់កាលវៀរលែងតែដេកលក់ គឺប្រយុទ្ធនឹងចិត្តខ្ជិល, ចិត្តចង់ឆ្ងាញ់ពិសា,
ចិត្តចង់លេងសើចសប្បាយ ។ ល ។ ទាល់តែចាំងឈ្នះសត្រូវទាំងនេះ
ទើបរៀនបានចេះដឹងដូចបំណង នេះឈ្មោះថាធ្វើសង្គ្រាមក្នុងត្រារៀន
សូត្រ (សិក្ខាសន្ត្តាមោ) ។

លុះកុមារ-កុមារី អ្នករៀនសូត្របានចេះដឹងហើយទាំងនោះមាន
អាយុប្រើនឡើង រាប់ពីត្រឹមអាយុ ១៨ ឆ្នាំ ឡើងទៅ តាមច្បាប់សម្រាប់
ស្រុកទេសបញ្ញត្តថាជាមនុស្សត្រប់ការ ឬពេញការ, បានការ ។
ពួកមនុស្សត្រប់ការទាំងនេះ បើសម្រេចចិត្តថាឈប់រៀនសូត្រហើយ
ក៏នៅស្ងៀមស្ងាត់តែឯកឯងពុំបានដែរ ត្រូវតែរកផ្ទះសម្បែង គឺត្រូវមាន
ប្រពន្ធឬប្តី ។ បើបានប្រពន្ធឬប្តីហើយ ត្រូវធ្វើការងារផ្សេង ។ តាម
សមត្ថភាពរបស់ខ្លួន ដើម្បីនឹងចិញ្ចឹមខ្លួនព្រមទាំងត្រួសារឲ្យបានសុខ

ស្រួល ។ ឯកិច្ចការគ្រប់ចំពូក ដែលស្វាមីប្ដកវិយាត្រូវធ្វើនោះ ជា
ការធ្ងន់ស្រាលក្រដាយយ៉ាងណាខ្លះ? ខ្ញុំមិនបាច់រៀបរាប់ទេ ព្រោះដឿ
ថា លោកអ្នកសុទ្ធតែធ្លាប់បានចូលប្រយុទ្ធផ្ទាល់ខ្លួនក្នុងការនេះរួចមក
ហើយផង កំពុងតែប្រយុទ្ធសព្វថ្ងៃនេះផង ។ លោកអ្នកដែលតាំងខ្លួនឲ្យ
កើតជាមនុស្សពេញលក្ខណៈច្បាប់បាន ដូចពាក្យចាស់ហៅថា "មនុស្ស
មានមុខមាត់ ប្ដមនុស្សស្ពុកស្ពម្ភ" នោះ សុទ្ធតែជាអ្នកច្បាំងឈ្នះសឹក
សត្រូវគ្រប់ចំពូក មានការកូតកុហកបោកប្រាសគេជាដើម ដែលជា
សត្រូវនៅចាំប្រទូសរ៉ាយខ្លួនគ្រប់ខ្យល់ជង្ហើម ។ ការធ្វើចម្បាំងតយុទ្ធ
នឹងរបរចិញ្ចឹមជីវិតគ្រប់ចំពូកនោះ ជាចម្បាំងយ៉ាងធំសម្បើមអស្ចារ្យ
ណាស់ ជាចម្បាំងដ៏ស្ងិតស្ងាញលើសសង្ត្រាមកំពុងរៀនសូត្រទៅទៀត
មនុស្សគ្រប់រូបមិនមែនចេះតែច្បាំងឈ្នះគ្រប់គ្នាទេ ។ ប្រសិនបើច្បាំង
ឈ្នះទាំងអស់គ្នានោះ ប្រហែលជាក្នុងប្រទេសមួយ ៗ គ្មានចោរលួចទេ
គ្មានមនុស្សត្រូវទោសជាប់គុកទេ ។ ពួកចោរទាំងនោះឈ្មោះថាជាអ្នក
ច្បាំងចាញ់សឹកសត្រូវ (ទុច្ចរិត) ក្នុងខ្លួន នេះឈ្មោះថាធ្វើសង្ត្រាមក្នុង
របរចិញ្ចឹមជីវិត (អាជីវសង្គាមោ) ។

មនុស្សគ្រប់រូប មិនរើសថាអ្នកមានប្ដអ្នកទាល់ក្រ អ្នកមាន
បណ្ណាស័ក្តិប្ដ ឥតបណ្ណាសក្តិទ្បើយ តែកើតមកជាមនុស្សហើយ តែងមាន
ជម្ងឺឈឺចាប់ដូចគ្នា ប្ដែកតែច្រើនតិចធ្ងន់ស្រាល នឹងមើលសះជាប្ដមិន
សះជាប៉ុណ្ណោះ ដែលថាឥតអ្នកណាឈឺសោះនោះ មិនធ្លាប់មានទេ
ក្នុងលោកសព្វថ្ងៃនេះ ។ ជម្ងឺឈឺចាប់នេះជាសឹកសត្រូវមួយប្រភេទ មាន

ឫទ្ធានុភាពដ៏ខ្លាំងក្លាបំផុត មានរេហ៍ពលក៏ច្រើនណាស់ ទាល់តែត្រូពេទ្យ
យ៉ាងស្ទាត់ជំនាញរាប់ឈ្មោះមិនអស់ ចំណាំមុខមិនបាន កងពលទាំង
នោះ សុទ្ធតែជាអ្នកខ្លាំងពូកែមានថ្លីដៃយ៉ាងធើត ចេះកលយុទ្ធជ្រាលជ្រៅ
ត្រូពេទ្យចេះដឹងស្ទើរៗ ដេញរកពុតរាមិនទាន់ទេ ។ ជម្លឺឈឺចាប់នេះ
រាតែងលើកកងទ័ពរុករានទន្ទ្រានលុកលុយក្នុងនគរកាយ នៃបណ្តាជន
ប្រុសស្រីក្មេងចាស់ទាំងអស់ឥតរើសមុខ ត្មានអ្នកណាម្នាក់អាចតេចវេះ
ឲ្យផុតពីមុខទ័ពរាទេ រានៅស្ទាក់ត្រប់ផ្ទូវច្រកល្ហក់ ត្រប់ពេលវេលា ។
បើអ្នកណាមានមាសប្រាក់ច្រើនឬមានចំណេះវិជ្ជាច្រើន អ្នកនោះអាច
ទប់ទល់នឹងរាបានខ្លះដែរ ធាប់ដឹងឈ្នះចាញ់ក្លាមៗ ។ បើអ្នកទាល់ក្រ
ឬល្ងង់ខ្លៅវិញ ច្បាំងមិនស្ទាឈ្នះរាទេ ច្រើនតែចាញ់ថ្លីដៃរា បើមិនធាប់
ក៏យូរដែរ ។ លោកអ្នកទាំងពួងដែលរស់នៅតាំងពីក្មេងរហូតដល់ចាស់
នោះ ធ្លាប់ឈឺចាប់ផ្ទាល់ខ្លួនស្រាប់មកហើយ បើមិនធ្ងន់ក៏ស្រាលៗដែរ
គង់ជ្រាបឥទ្ធិពលរបស់ជម្លឺនោះថាមានទំហំប៉ុណ្ណា ? លោកអ្នកចំណាយ
ធនធានចាត់ការតតាំងច្បាំងនឹងជម្លឺនោះអស់ប៉ុន្មានៗ ស្ទាមជ្រាបតាម
ធ្លាប់ចូលប្រយុទ្ធក្នុងសមរភូមិនោះចុះ នេះឈ្មោះថាផ្ទើសត្ត្រាមនឹងជម្លឺឈឺ
ចាប់ (រោគសង្គាមោ) ។

នៅមានសត្ត្រាមមួយប្រភេទទៀត ដែលមានតេជានុភាពយ៉ាង
ពន្ធឹក ត្ឋរឲ្យស្រប់ស្រែងជាទីបំផុតមានឫទ្ធិអំណាចខ្លាំងពូកែលើសសត្ត្រាម
ទាំងអស់ដែលបានរៀបរាប់ខាងដើមនោះ ឈ្មោះថាមរណសត្ត្រាមជា
សត្ត្រាមត្រាទីបំផុតក្នុងជីវិតរបស់មនុស្សត្រប់រូប ។

សេចក្តីស្លាប់ចាត់ជាមរណៈសង្គ្រាម។ នេះពួកមនុស្សបុថុជ្ជនដូចគ្នា គ្មានអ្នកណាម្នាក់ច្បាំងឈ្នះទេ ទើបបានជាទ្រង់មានបន្ទូលថ្វាយដល់មនុស្សសាម័ញ្ញ សូម្បីព្រះបាទសម្តេចព្រះបរមចក្រពត្តិធិរាជ ដែលព្រះអង្គមានឫទ្ធានុភាពគ្រប់លើសកលលោក មានសេនាយោធាពាហនៈមិនអស់ម៉ែចក៏នៅតែព្រះអង្គចាញ់ថ្លើដែរ ណាសង្គ្រាមដែរ គឺព្រះអង្គខ្ចីខ្ចាត់ឥតអស់ព្រះជន្ម ដូចជាមនុស្សសាម័ញ្ញ ។ រឿងស្លាប់នេះ ខ្ញុំមិនបាច់សរសេរឲ្យវែងឆ្ងាយទេ ព្រោះអស់លោកអ្នកធ្លាប់ជ្រាបស្រាប់ហើយថា គ្មានមនុស្សណាចាស់សកឡើយ សុទ្ធតែស្លាប់ទាំងអស់គ្នា ប្លែកតែមុនក្រោយ យូរធាប់ប៉ុណ្ណោះ ។

ពួកមនុស្សបុថុជ្ជនគ្រប់រូប ទោះបីលោកអ្នកមានឫទ្ធានុភាពច្រើនយ៉ាងណាក្តី មានវេហ៍ពលច្រើនពាប់មិនអស់ក្តី មានគ្រឿងយុទ្ធោចករណ៍សព្វគ្រប់ឥតខ្វះក្តី មានចំណេះចេះមន្តវិជ្ជាការនុមអាមអាគមយន្តគាថាកាប់មិនមុតដុតមិនឆេះ ឬក៏ចេះមន្តច្រៀសម់មនុស្សស្លាប់ហើយឲ្យរស់ឡើងវិញក្តី ទើបចេះក្បួនតេទ្យស្ថិតល្អន់ស្ទាត់ជំនាញយ៉ាងណាក្តី ក៏នៅតែច្បាំងចាញ់ស្តេចមច្ចុពាជគឺសេចក្តីស្លាប់នេះដែរ មិនដែលឃើញមានលោកអ្នកណាច្បាំងឈ្នះដល់ម្នាក់ឡើយ ។ ប្រសិនបើមាន មុខជាព្រះបាទជម្ពាសោកគង់ព្រះជន្មនៅរហូតមកដល់សព្វថ្ងៃនេះទៅហើយ ។ ចុះហេតុអ្វីបានជាពួកបុថុជ្ជនសុទ្ធតែច្បាំងចាញ់ស្តេចមច្ចុ (សេចក្តីស្លាប់)? ហេតុថា ពួកនេះស្លាប់ហើយកើត ។ ហើយស្លាប់ ផ្លាស់ប្តូរគ្មានចេះចប់ ទោះទៅកើតជាអ្វីក៏ដោយ ក៏នៅតែស្លាប់មិនខាន ។ មានតែព្រះអរិយៈ

ជាម្ចាស់មួយពួកប៉ុណ្ណោះទេ ដែលលោកច្បាំងឈ្នះស្តេចមច្ចុ ។ ចុះព្រះអរិយៈលោកក្រុយព្រះជន្មដែរឬទេ? លោកក្រុយដែរ ។ ចុះចើលោកក្រុយដែរម៉េចក៏ថាលោកច្បាំងឈ្នះស្តេចមច្ចុ? ឆានជាថាយ៉ាងនោះព្រោះលោកក្រុយព្រះជន្មហើយ លោកលែងកើតតទៅទៀត ដែលហៅថាលោកបូលនិព្វាន ។ បើទុកជាមានព្រះអរិយៈអង្គខ្លះត្រូវកើតទៀត ក៏កើតតែត្រឹម ៧ ជាតិប៉ុណ្ណោះជាយ៉ាងច្រើនចំផុត ។

បើពួកមនុស្សបុថុជ្ជនចង់ច្បាំងឲ្យឈ្នះស្តេចមច្ចុនោះត្រូវតែខំប្រតិបត្តិធម៌តាមលំអានលោកជាព្រះអរិយៈ គឺត្រូវព្យាយាមលះបង់ចិត្តអាក្រក់អំពើទុច្ចរិតចាំងពួងឲ្យរលោះស្រាលស្តើងបន្តិច ។ ម្ល៉ង ទាល់តែជះស្រឡះផុតអស់ពីសន្តានចិត្ត ទើបឈ្មោះថាច្បាំងឈ្នះស្តេចមច្ចុ ដូចពួកព្រះអរិយៈមិនខាន ។ ឯឈ្មោះព្រះអរិយៈនេះ មិនមែនកើតមកពីណាទេ ក្រោកដជាកើតមកពីខ្លួនជាបុថុជ្ជនោះឯង ដូចជាព្រះអង្គុលិមាលត្មេរកាលលោកកំពុងធ្វើជាមេចោរសម្លាប់អ្នកស្រុកនោះ ខ្លួនលោកនៅជាបុថុជ្ជនដែរ លុះលោកបានជួបនឹងព្រះពុទ្ធអង្គ ឆានស្តាប់ធម៌ទេសនាយល់ផ្លូវខុសត្រូវហើយ លោកផ្ទាស់ចិត្តចោរកំណាចនោះចេញបានពេលណា ពេលនោះហើយខ្លួនលោកបានព្រះនាមថ្មីថា ព្រះអរិយៈគឺព្រះអរហន្ត ។

សង្ក្រាមកំចាំង សង្កេបប៉ុណ្ណោះ ។

សាលារៀននៅប្រទេសជប៉ុន

អ្នកស្រី ពេជ្រ-សល់ ហៅ សារិះយ៉ាន

ប្រៀបធៀង

នៅប្រទេសជប៉ុន ទោះជាអ្នកទេសចរមានចិត្តរាយមាយមិនសូវយកចិត្តទុកជាក់នឹងពិនិត្យការផ្សេងៗ ក៏ដោយ ក៏ឆង់តែជៀសមិនរួចអំពីការប្រស្រ័យទាក់ទងផ្ទាល់នឹងសាលារៀនជប៉ុនដែរ ព្រោះសាលារៀននៅស្រុកជប៉ុន គេសង់ជាប់នឹងផ្លូវដើរតែម្តង ។ ហើយអ្នកជំណើរតែងប្រទះឃើញសាលារៀននៅតាមផ្លូវ តាំងតែពីតំបន់ធំៗ រហូតដល់ទៅកន្លែងគៀនកោះ ក្នុងជនបទផ្សេងៗ តាមជំណាក់រថទេសចរ ជូចជានៅក្នុងតំបន់យ៉ាម៉ាតូ នៅក្នុងវិហារពុទ្ធសាសនាយ៉ាងចាស់នៃបូរាណទេត្តមួយ ។

ចូរអ្នកដើរទៅតាមផ្លូវកាត់ភូមិតម្រង់ទៅសួនណារ៉ា ដែលជាទីអស្ចារ្យមួយ សំបូរណ៍ដោយសត្វប្រើសនឹងថ្ម ដែលគេតែងរាប់អានបូជាគឺនៅទីកន្លែងនេះហើយ ដែលលេចអណ្តែតឡើងនូវអភិចរិយានឹងសេចក្តីក្សេមក្សាន្ត ។ នៅពីមុខអ្នក សុទ្ធតែពួកសិស្សតូចៗ ដើរជាពីរជួរប្រមាណប្រហែលជាងរយនាក់ លោតរត់លេងហុយធូលីទ្រលោម ។ គ្រូបង្រៀនពីរនាក់ដើរអមសិស្ស ហើយជួនកាលគេនាំគ្នាឈប់នៅមុខផ្ទះលក់របស់ក្មេងលេង ឬនាំគ្នាឈប់សម្រាកនៅរបៀងកោជនីយស្ថាន ។ មួយសន្ទុះក្រោយមកគេនាំគ្នាចេញជំណើរតទៅទៀតយ៉ាងស្វាហាប់, ក្នុងចំណោមនេះ សិស្សស្រីនឹងសិស្សប្រុសសឹងស្មើកាតគ្នា ស្លៀកពាក់ជាឯកសណ្ឋានតាមរបៀបស្រីប្រុស ។

មានសិស្សជាច្រើននាក់នាំគ្នានឹកស្តាយកូយ៉ា - សាន ដែលអន្តរាយ
ដោយអគ្គីភ័យ ។ កូយ៉ា សានទេះ ជាវិហារចាស់មួយនៃព្រះពុទ្ធសាសនា
ដែលកូនក្មេងទាំងនោះតែងនាំគ្នាមកពីទីជទៃ តាំងពីចម្ងាយ ១៥០
ប្ត ២០០ គីឡូ ម៉ែត្រ ដើម្បីមកឡើងលេង ។ គេធ្លាប់ឃើញក្មេងទាំង
ហ្ជូង ។ ចុះឡើងលេងលើព្រះវិហារ កាម៉ាគុរ៉ា ដែលមានរូបអាទិទេព
ក្ងានុនសុទ្ធសឹងទិបដោយទឹកមាស ឈរលើផ្ទាំងសិលាដែលមានសណ្ឋាន
ជូចជាក្សាលទូក លេចលយចេញផុតអំពីស្ទឹកឈើនឹងសន្ធុះរលកទឹក ។
ជួនកាលពេលល្ងាចទៅហើយ គេឃើញក្មេងខ្ចះទៀត ទើបនឹងត្រឡប់
មកពីផ្ទើដំណើរប្រឡាក់សុទ្ធតែធូលី ដើរបណ្តើរ ច្រៀងបណ្តើរ តាមផ្ទូរ
មួយចាស់នៅក្រុងតូក្យូ ហើយក្មេងដែលដើរជាជួរនោះមានគោមផ្ទើអំពី
ក្រជាសរចនាអក្សរពណ៌ក្រហមបំភ្ទឺផ្ទូរមើលទៅគួរឲ្យសប្បាយណាស់ ។
ហេតុជូច្នេះហើយ បានជាពួកជនទេសចរតែងយល់ថា ពួកសិស្សា-
នុសិស្សជប៉ុនទោះមានវ័យក្មេង ក៏គង់មានមនោសញ្ចេតនាចំពោះធម្មជាតិ
ដែលក្មេងនៅស្រុកឯទៀតពុំសូរចេះផង ។ នៅក្នុងសួនណារ៉ានឹងនៅ
លើផ្នាឡាច់មីយ៉ាស៊ីម៉ា គេតែងប្រទះឃើញក្មេងអង្គុយនៅកន្ទែងមួយ
យ៉ាងស្រួលមានប្រជាប់សំរាប់គូរមួយសំបៀតតូច ។ ការញ្រាងលើផ្ទាំង
ក្រជាសពុំសូវស្អប៉ុន្មានទេ ប៉ុន្តែការជ្រើសលំនាំនឹងគូរនោះដាយស្រួល
ហើយច្បាស់ណាស់ ជូចជាដើមស្រល់មួយជុះរមួលលើផ្ទាំងសិលា, សិលា
មួយជុំនៅក្សែរគល់ឈើមួយ ដោយមានទឹកសមុទ្រសស្អាប់ជាផ្ទៃនៃគំនូរ
នោះ ។ ទម្ងាប់ឲ្យក្មេងដើរមើលទេសភាពដែលគេបានដៅទុក ទម្ងាប់

ឲ្យដើរហាលថ្ងៃក្រោមម្ងប់ឈើ តាំងតែពីតូចបែបនេះ នាំឲ្យយុវជនជប៉ុន
ស្គាល់ជម្ងៃធម្មជាតិ ចេះស្រឡាញ់ប្រទេសជាតិ ហើយចេះមាន
មនោសញ្ចេតនាដ៏ក្លៀវក្លាមួយយ៉ាងពិសេសប្រពៃចំពោះជាតិ ។

ប៉ុន្តែបើគ្រាន់តែបាននាំសិស្សមើលរបៀបអនាម័យ ខាងការលំអរ
សប្បាយប៉ុណ្ណោះក៏គេពុំទាន់ពេញចិត្តដែរ ។ គេថែមទាំងនាំសិស្សទៅ
មើលរោងចក្រគ្រប់បែបជាញយៗ ទៀត ទៅមើលឃ្លាំងទុកទំនិញ មើល
កំពង់ជំនួញ ហើយការបង្រៀនវត្ថុស្វាធ្យាយ ប្រើនធ្វើចំពោះវត្ថុតែម្តង ។
ត្នាក់ឆារក្រុមហ៊ុននាវាចរម្នាក់ នៅយោកូហាម៉ាបាននិយាយថា មាន
ត្រូបង្រៀនជប៉ុនជាប្រើនរូប មកសុំច្បាប់គាត់ឲ្យសិស្សឡើងមើលកប៉ាល់
ដែលគេបញ្ចូលមកក្នុងព្រែកជីក ។ ព្រះអង្គម្ចាស់ គីគូជី (Kikuchi)
អតីតរដ្ឋមន្ត្រីក្រសួងសិស្សាធិការ ក្នុងសន្ទិសិទមួយ ដែលទ្រង់បានថ្ងៃង
នៅក្រុងឡុង កាលពី ត. ស. ១៩០៧ បានថ្ងៃងថា:

"ទម្លាប់នេះសឹងជាទម្លាប់សាកលទៅហើយ ដែលគេទម្លាប់ឲ្យនាំ
សិស្សធ្វើដំណើរទៅមើលទីផ្សងៗ ឬធ្វើដំណើរទៅស្រុកឆ្លាយតែម្តង ។
របៀបទាំងពីរយ៉ាងនេះសឹងស្របគ្នា ឬថាធ្វើដូចគ្នាបាន ។ របៀបមួយគឺ
ធ្វើដំណើរក្នុងពេលវិស្សមកាលដើម្បីកំសាន្ត ឬដើម្បីហាត់ប្រាណ; របៀប
មួយទៀត គឺរៀនដោយវិធីដើរទៅមើលជល់ទីកន្ទេងដែលមានប្រយោជន៍
ខាងសាវតារក្តី ខាងកូម៉ឺសាស្ត្រក្តី ឬខាងការប្រតិបត្តិក្តី ។ ទោះជាទៅ
សាលាបថមសិក្សាក៏ដោយ ក៏ត្រូវធ្វើដំណើរទៅមើលកន្ទេងផ្សងៗដែរ ។
នៅសាលាមធ្យមសិក្សា ពួកយុវជនធ្វើដំណើរទៅបួនឬប្រាំថ្ងៃ ទើប

ត្រឡប់មកវិញ ។ នៅសាលាមធ្យមសិក្សាជាន់ខ្ពស់ដែលមានបន្ទែម
វិជ្ជាខាងទាហានផងនោះ សិស្សចេញទៅរៀនបាញ់យូរ ៗ ម្តង ។
អារម្មណ៍ក្នុងការត្រួតត្រាឲ្យបានល្អ នាំឲ្យលោកនឹករកកិច្ចការពារណា
ដែលមានប្រយោជន៍ទុកជាមុន ។ ប៉ុន្តែដើម្បីនឹងបង្រៀនអំពីជីវអាព
ជល់ក្មេង ឬដើម្បីនឹងញ៉ាំងក្មេងទាំងនោះឲ្យស្គាល់នូវជម្ងៃជាតិរបស់ខ្លួន,
ការដែលនាំសិស្សានុសិស្សដើរមើលកន្ទែងផ្សេង ៗ ជូចជាកប៉ាល់ធំមក
ពីប្រទេសអឺរ៉ុប ព្រះវិហារដែលគេតែងគោរពបូជា កាំភ្លើងធំ សំណល់
កប៉ាល់ចម្បាំងរុស្សី ឬសំណល់កប៉ាល់ចម្បាំងជប៉ុន ដែលចោលនៅក្នុង
ព្រៃជាអនុស្សាវរីយ៍នៃជ័យជំនះ នោះជាការចាំបាច់មួយមានប្រយោជន៍
ហើយគេពុំជំទាស់ទេ ។

ម្យ៉ាងទៀត របៀបបង្រៀនអំពីច្បាប់ពលរដ្ឋ នឹងច្បាប់មាតុប្រទេស
មិនមែនជាការឥតប្រយោជន៍ទេ ។ នៅពេលថ្មីៗនេះ គេបានឃើញ
ត្រូបង្រៀននាំសិស្សដើរមើលកន្ទែងចម្បាំងនៅកូរ៉េ ។ កាលពីខែកញ្ញាធ្នាំ
មុន គេបានធ្វើពិពីរណ៍អាណានិគមនៅក្រុងតូក្យូ ។ ពិធីនេះធ្វើនៅមុខ
ផ្ការឈូក នៃបឹងស៊ីណូបាស៊ុយ ក្នុងគេហស្ថានមួយ ធ្វើអំពីថ្មសក្សុះនៅ
កណ្តាលថ្ងៃ មើលទៅជូចជាវាំងចៅហ្វាយក្រុងក្នុងអាណានិគមណាមួយ
នៅស្រុកក្តៅ ។ នៅមុខទ្វារចូល មានទង់ជាតិពីរធ្វើអំពីស្ថានសំពត់ស
ហើយមានរូបព្រះអាទិត្យពីរធំ ៗ ក្រហមរន្ទាលផុះចេញអំពីស្ថានសំពត់
ពណិសនោះ ។ ទង់ជាតិនោះជាក់ខ្ទែងគ្នាតែមានសំពត់ខ្មៅស្តើងរុំពីក្រៅ
ជាមរណសញ្ញាចំពោះព្រះអធិរាជម៉ុជី (Meiji) ។ មានបណ្តាជនជាច្រើន

ប្រជ្រៀតចូលទៅស្តាប់ក្ងេងក្នុងតូបមួយតូច ដែលអ្នកលេងគ្នាតិចសោះ
តែលេងហាក់ដូចជាមិនចេះហត់; អ្នកស្តាប់ ស្តាប់ទាល់តែពួកអ្នកក្ងេង
លេង "បទលា" ទើបដើរចេញ ។

គេបានផ្សាយតាមវិទ្យុយ៉ាងខ្ចរខ្ចារណាស់ អំពីពិព័រណ៍អាណានិគម
ដែលកើតឡើងយ៉ាងរុងរឿងដោយមានការជប់លៀងអាហារ និងការថ្ងៃង
សុន្ទរកថាផង ។ គេបាននាំយកមកតាំងនូវសត្ត រុក្ខជាតិ ហើយនឹង
ផលិតផលផ្សេងៗ ក្នុងព្រះរាជអាណាចក្រតាំងពីហ្វ៉ាម៉ូស រហូតដល់
សាក្ខាលីន ។ គេបានទាំងនាំពួកព្ធណូស ដែលមានសក់ក្រញាញ់ក្រាប
ជាប់នឹងក្បាលស្ងៀកពាក់ខោអាវពណិធើតៗ យកមកឲ្យឈរនៅពីមុខ
ខ្ទមរបស់ខ្លួនផង ដើម្បីជាកស្តុតាងអតីតកាលដែលមានជីវភាពទៅតាម
ប្រជាជាតិជាន់ដើម ។ នៅក្បែរនោះមានពួកជននៅកោះហ្វ៉ាម៉ូសដែល
សប្បាយចិត្តនឹងឃើញគេទៅចាមរោមមើលខ្លួន គេឃើញជនទាំងនេះ
ដើរទៅមើលរហូតដល់ថែវមន្ទីរមហោស្រពនៃព្រះអធិរាជ ដែលគេនាំ
ទៅឲ្យមើល ដើម្បីឲ្យកោតសរសើរវឹតតែខ្ចាំងទៅទៀត និងដើម្បីញ៉ាំង
ជនទាំងនោះឲ្យមានមនោសញ្ចេតនា កតញ្ញូ ដែលត្រូវប្រព្រឹត្តចំពោះអ្នក
ត្រួតត្រាផង ។ នៅក្នុងរបងពិព័រណិ មានបញ្ចាំងខ្សែភាពយន្តផ្សាយ
អំពីតេជានុភាពនៃប្រទេសជប៉ុន ហាក់ដូចជារូបរស់មែន ។

ការនេះមិនមែនធ្វើត្រាន់តែជាការសម្តែងឲ្យសប្បាយ ដល់ក្នុក
អ្នកមើលនឹងជាការបំភ្ងឹសតិបញ្ញានោះទេ គឺជាការបង្ហាញផ្ទូវការ ១ អំពី
អានុភាពអារ្យធមិផង ជាការបង្ហាញនូវគុណសម្បត្តិនៃរាជរដ្ឋាភិបាល

ផ ។ តាមមតិរបស់អ្នកផ្តើមបុណ្យ ពិធីនេះជាការប្រៀនប្រដៅមួយ
យ៉ាងខ្ពង់ខ្ពស់នៃព្រះអធិរាជ ។

យុវជនជប៉ុនជាជនត្រូវបានមើលពិធីនេះមុនគេបង្អស់ ។ មួយថ្ងៃ ។
គេឃើញតែក្មេងដើរហូរហែ ទាំងហ្វូង ។ តាំងពីក្មេងតូចរហូតដល់ក្មេងជំទង់
មានសិស្សានុសិស្សធំ ។ ដែលចូលទៅមើលនូវពិព័ណ៍នេះ យ៉ាងរីករាយ
ដោយមានរបៀបរៀបរយល្អ ក្នុងទីនោះគេឧស្សរតែសន្ធឹកស្បែកជើង ។
យុវជនទាំងនោះដើរពាសពេញតែក្រោមម្ងប់អុិយអេណូ ដែលជុះនៅមាត់
ប៊ឹងហើយនាំគ្នាចុះតាមជណ្តើរមួយធំផ្ងើអំពីថ្ម ដែលមានពណិចំរុះគ្នាគ្រប់
យ៉ាងជូចជាពណិមេអំបៅ រួចទើបនាំគ្នាទៅមើលអីវាន់ដែលគេជាក់តាំង
ក្នុងទូកញ្ចក់ទៅប្រជ្រៀតក្នុងចំណោមមនុស្សច្រើន ។ យុវជនខ្ទះមាន
ពាក់រូបផ្ការឈូករត្នលឿង រូបផ្ការអ្ងីឯទៀត ឬក៏រូបអ្ងីផ្សេងជាគ្រឿង
សំតាល់ ។ ក្មេង ។ ទាំងនោះសុទ្ធតែចុះអំពីរថក្ងើងដែលគេបម្រុងទុកឲ្យ
ដោយមានជំណើរលឿនរហ័ស ។ តែគួរឲ្យអស្ចារ្យណាស់ គេឃើញ
មានយុវជនមកតាំងតែពីស្រុកឆ្ងាយ ។ ដោយមានគ្រូបង្រៀនមកជាមួយ
ផង ដើម្បីមើលការទុសត្រូវ ណែនាំក្នុងការផ្ងើជំណើរនោះ ។ មាន
យុវជនពួកខ្ទះផ្ងើជំណើរដោយជើង ចូលទៅសំណាក់ក្នុងភោជនីយស្ថាន
ដែលជួបនៅតាមផ្ងូវ ហើយអ្នកម្ចាស់ផ្ទះទាញជញ្ជាំងចេញដើម្បីឲ្យមាន
កន្ទែងអាស្រ័យជំណេកគ្រប់គ្រាន់ ។ យុវជនបែបនេះច្រើនតែមាន
គ្នាច្រើន ។ ហើយហាក់ជូចជាគ្មានការបង្ខំឲ្យប្រព្រឹត្តតាមវិន័យសោះ តែ
ហាក់ជូចជាចេះផ្ងើឲ្យមានរបៀបរៀបរយដោយខ្លួនឯងតែម្តង ។ ក្មេង

ពាំងនោះ ហាក់ដូចជាមានចិត្តគិតចង់ក្រេបតែសេចក្តីសប្បាយក្នុងការ
រស់នៅ នឹងចង់ឃើញចង់ស្តាល់តែប៉ុណ្ណោះ ។ ការពិតគឺក្មេងពាំង
ម៉ុនពាំងសែននាក់នោះនាំគ្នាមកពីត្រប់ដំបន់ ដើម្បីកោតសរសើរដល់
មាតុភូមិថ្មីរបស់ខ្ជូន ដែលជាមហាអំណាចម្ជយយ៉ាងធំ ហើយដែល
រាជការបំរុងនឹងប្រាប់រឿងនេះ ដល់ក្មេងប្រកបដោយចិត្តល្មោភចង់ដឹង
នឹងចង់មើល ។

កម្មវត្ថុផ្សេង ៗ ដែលត្រូបង្រៀនជប៉ុនព្រាងទុកក្នុងការនាំសិស្សដើរ
ជាការសិក្សានោះ គឺអនាម៉យចំពោះរាងកាយ អនាម៉យខាងផ្ទូវចិត្ត
អនាម៉យខាងផ្ទើរាងកាយឲ្យល្អ (ព្រោះគេយល់ថាខ្ជូនយើងតែងមានសុខ-
ភាពដោយចំណង់ ហើយដោយអាងទៅលើកំឡាំងផ្ទាល់នឹងធម្មជាតិតែ
ម្តង) ការបង្រៀនខាងចំណេះវិជ្ជាបច្ចេកទេស នឹងការរៀនខាងប្រតិបត្តិ
ការ ការហាត់ហ្វឹកហ្វឹនខាងកីឡា នឹងខាងការហាត់ទាហាន ការ
បណ្តុះបញ្ញា នឹងវីរភាពដែលមានន៍យសបគ្នា ។

ប៉ុន្តែយើងត្រូវយល់ថា របៀបបង្ហាត់បង្រៀនយ៉ាងសប្បាយរីករាយ
បែបនេះ គឺមកអំពីបណ្តាជនជប៉ុនមានបទបញ្ញត្តិពិសេសដោយឡែក
សំរាប់ការសិក្សា ។ ប៉ើទោះជានៅប្រទេសឯទៀតដែលមានរបៀបរៀប
រយល្អជាងប្រទេសជប៉ុន ក៏គ្មានរាស្ត្រដែលមានសន្តានចិត្តសប្បាយរីក
រាយ នឹងដើរលេងដូចប្រជាជនជប៉ុនដែរ ។ ដើម្បីជាទាហណ៍ យើង
ត្រាន់តែលើកយករឿងបូជនីយេស ដែលពួកអ្នកក្រីក្រនាំគ្នាផ្ទើដំណើរទៅ
ដោយដើងយ៉ាងសប្បាយផ្តោះទៅកាន់ក្នំខ្ពស់ៗ ដូចជាក្នំណានតែ-សានប្ម

ទៅកាន់ទីអាសន:ដែលនៅក្សែរមាត់សមុទ្រ ដូចជាអ៊ីសេជាដើម . . . ។ ប៉ុន្តែជនជាតិជប៉ុន មិនចាំបាច់តែមានការប្រែកទើបបានទៅទេ គឺថាជប៉ុនចូលចិត្តដើរទៅមើលកន្លែងផ្សេងៗ ក្នុងស្រុកខ្លួនឲ្យស្គាល់ ដូចជាពួកទេសចរបរទេសដែរ ។ គេចូលចិត្តទ្បើងទៅលើកំពូលភ្នំខ្ពស់ៗ ដើម្បីមើលទេសភាពដ៏ល្អ ។ នៅតាមផ្លូវទ្បើងភ្នំ មានជំរំតូចៗ ជាច្រើនដែលពួកអ្នកដំណើរជប៉ុនចូលចិត្តឈប់សំរាក ផឹកតែមួយពែង - ពីរពែងរួចទើបបន្តដំណើរទៅទៀត ។

ជនជាតិជប៉ុនក្នុងវ័យកណ្តាលមានចិត្តចង់ដឹង ចង់ឆ្ម ចង់ឃើញ ចង់ស្គាល់មិនចេះផុត មិនចេះអស់វិស័យដូចកូនក្មេង ។ នេះហើយជាទម្លាប់មួយ ប្ចជាលក្ខណ:ជាតិមួយដ៏ពិតប្រាកដ ដែលជាសេចក្តីពន្យល់ជាការទ្រទ្រង់នូវគរុកោសល នៃការដើរមើលទីកន្លែងផ្សេងៗ ។

ម្យ៉ាងទៀត ប្រទេសជប៉ុន ដែលប្រកបដោយភ្នំតូចធំស្រស់ញញឹមដោយកន្លែងមានទឹកណ្ដាក់ ដោយភោជនាគារយ៉ាងរុងរឿង ដោយផ្លូវដើងតូចៗ សំរាប់អ្នកថ្មើរដើង ហាក់ដូចជាទាញចិត្តមនុស្សឲ្យដើរលេងឲ្យដើរទៅមើលកន្លែងផ្សេងៗដោយទ្រាំពុំបាន ។ ប៉ុន្តែរថយន្តវិញមិនអាចនឹងបើកទៅតាមនោះបានទេ បើទោះជាទៅបានក៏គេមិនសប្បាយចិត្តនឹងទទួលដែរ គឺថាវិថីសំរាប់តែអ្នកដើរលេងនឹងសំរាប់ក្មេង តែរទេះគោរទេះសេះក៏ពុំសូវមានដែរ ។ ផ្ទះជប៉ុនក៏ផ្ទើអំពីឈើនឹងក្រជាស ហើយមានរាងដូចជាចំហរទៅរកផ្លូវទាំងអស់ ថែមទាំងមានលក្ខណ:មិនជាប់លាប់មិនប្រាកដ ដែលគេតែងប្រារព្ធទៅលើជនជាតិជប៉ុនតែម្តង ផ្ទះនោះ

ហាក់ដូចជាហៅអ្នកនៅឱ្យចេញទៅគ្រា ។ ហេតុដូចនេះបានជាយើង
មិនគួរឆ្ងល់ ទើឯអ្នកនិពន្ធ វ៉ុលស្តូរេ ដែលបានសរសេរថា "ជីវភាព
គ្មានទីកំណត់ ជាជីវភាពដែលខ្ញុំត្រូវការ ។ ការធ្វើដំណើរដោយដើរ
ដោយឥតប្រញាប់នៅពេលត្រជាក់ល្អ ទៅក្នុងស្រុកមួយប្រកបដោយ
ទេសភាពស្រស់ញញឹម ដើម្បីទើឯទៅមើលវត្ថុអ្វីមួយយ៉ាងល្អ នេះហើយ
ដែលជាការរស់នៅយ៉ាងពេញលេញ ដែលខ្ញុំចូលចិត្តជាទីបំផុត ។
ជីវភាពគ្មានទីកំណត់នេះហើយដែលជាឧត្តមគតិរបស់ជប៉ុន ដែលចាប់
កំណើតឡើងក្នុងផ្ទៃស្រុក ហើយអ្នកដើរលេងត្រូវតែឃើញវត្ថុអ្វីមួយល្អ
នៅទីបំផុតនៃការដើរនោះ" ព្រោះអ្នកនិពន្ធជាប់ជាតិជប៉ុន ។

ក្រោយមកទៀត នៅពេលដែលពួកបច្ចឹមប្រទេស ទើឯពួកអាមេ
រិកាំងនាំនាវធំៗគ្រឿងសៀកពាក់ ទើឯឧស្សាហកម្មចូលមកដោយខ្លួនឯង
ជនជាំងនេះបានពង្រីកនូវធម្មជាតិល្បិចចង់ដឹងចង់ឃើញថែមទៀត ។
ដូច្នេះ ប្រជាជាតិនេះមានឯកសិទ្ធិខ្លួនឯងបានឃើញច្បាស់នូវក្បែកនូវ
បុព្វណវត្ថុតែមួយ នៃអារ្យធម៌នៅចុងបូព៌ាប្រទេស ហើយទើឯវឌ្ឍធម៌
យ៉ាងឆើត ដែលឧស្សាហកម្មយ៉ាងខ្លាំងនើបបំផុតនិយមធ្វើបានប្រាកដ ។
ពួកសិស្សដែលដែលបានទៅទស្សនាវិហារណាក៏ ហើយបានឃើញ
កន្លែងមួយដូចជាជង្រែកនេះ គឺជាឃ្លាំងចាស់របស់ព្រះអធិរាជ សូស្ញ
អ៊ុន ។ ក្រោយពីបានមើលវត្ថុទាំងនោះរួចមកទៀត ពួក
សិស្សទៅមើលកំពង់ផែកូបេ ទៅមើលគ្រឿងទុរេតូរនៅលើនាវាមួយ
ធំឈ្មោះ "តូយ៉ូតាសេនកៃសា" ។ ពួកសិស្សនើងមានអនុស្សាវរីយ៍

អំពីអាវ្យធមិសាកលលោកតាំងពីបុរាណកាលផង អំពីផលនៃអាវ្យធមិ
ដែលថ្មីបំផុតផង ។ ត្មានៈយីញអ្ហីចម្លែកក្រៅអំពីការមើលដោយមាន
ចិត្តចង់សប្បាយក្នុងល្បែងនោះ ហើយការដែលចង់យើញនោះទៀត
ទោះជាមានមនសិការប្រើនក្តីតិចក្តី ក៏ចេះតែធ្វើឲ្យកើតកម្ចាំងថ្មីជ៏រាប ។

សតិសម្បជញ្ញៈ របស់ប្រជាជនជប៉ុនញ៉ាំងឲ្យយើញច្បាស់ថា ការ
សិក្សាដោយដើរមើល នឹងដោយធ្វើដំណើរនៅស្រុកជប៉ុន គេទុកជូច
ទម្ចាប់ទំនៀម ជាអត្ថកាពទូទៅ នឹង ជាការចាំបាច់ ។ ក្នុងកិច្ចនេះ
សតិសម្បជញ្ញៈមានលក្ខណ តែតាមស្មាក់ធម្មតា ត្មានការបង្ហាប់បង្ខំអ្ហី
ដែលតាំងជាកម្មវិធីហើយស្រេចនោះទេ ។ សតិសម្បជញ្ញៈនេះ ចង្ហាប់
មជ្ឈស្ថានសិក្សាទៅនឹងជីវកាពធម្មតានៅក្រៅសាល គឺថាជាក់យុវជន
ទាំងនោះចំពោះអនាគតដែលនៅរង់ចាំខ្លួនទៅថ្ងៃក្រោយ ។ ទាំងនេះ
បង្ហាញឲ្យយើញថា ហើសិនជាគេអាចបង្កើនការដើរលេងរបៀបសាសន៍
ជប៉ុននេះ ឲ្យកាន់តែបានប្រើនឡើង ហើយញ៉ាំងការដើរលេងនេះកុំឲ្យ
មានរបៀបជាការសិក្សាពេក តែឲ្យមានន័យច្បាស់លាស់; ម្យ៉ាងទៀតបើ
គេចង់ធ្វើការពិនិត្យឲ្យបានហ្មត់ចត់ទូវបូរាណវិហារ ឬវិមានណាមួយ
ដែលជាកន្ទែងបូជនិយេសនោ.ៗ ការដើរលេងយើញថា មានប្រយោជន៍
យ៉ាងសម្បើមជល់សាលាវៀន ឬវិទ្យាល័យ ជូច្នេះក្នុងការដើរលេងនេះ
មានការសិក្សា (ការអប់រំ) មួយយ៉ាងប្រសើរ នៃការចង់ដឹងចង់ស្គាល់ ។
ចំណែកខ្ញុំ ៗ ក៏បានធ្វើល្បងបង្ហាញរួចហើយថា គើគេត្រូវធ្វើរបៀបណា
ដើម្បីឲ្យការដើរលេងនេះ មានអានុភាពទៅលើប្រជាជន ដែលបានយក

មធ្យោបាយនេះទៅច្រើនរួចទៅហើយ ប៉ុន្តែប្រជាជននោះក៏បានយកវេបនេះទៅតែប្រែខ្មែរជាច្រើនដែរ ។ មួយវិញទៀត បើសិនជាចង់ឲ្យការដើរលំហែ នឹងការធ្វើដំណើរទាំងនោះប្រព្រឹត្តទៅតាមក្បួនខ្នាតពិតប្រាកដ ឲ្យសមតាមគំនិតរបស់ព្រះគេន្ត្រូស៊ូស គីគូជី (Kikuchi) នោះ ។ ត្រូវមានគ្រូបង្ហាត់ គ្រូបង្រៀន ឬសាស្ត្រាចារ្យជាអ្នកដឹកនាំ ហើយអ្នកដឹកនាំទាំងនោះត្រូវមានចិត្តចេះចង់សួរ ចេះចង់ស្គាល់វេបស៊ែលជួបប្រទះនៅតាមផ្លូវផង ត្រូវចេះធ្វើឲ្យមានបរិយាកាសយ៉ាងជិតស្និទ្ធរវាងសិស្សទាំងគ្រូ ។ ធ្វើដូច្នេះ ទើបទុំយល់ថាការសិក្សាដោយដើរមើលវត្ថុផ្សេង ។ ប្រសើរជាងហើយគ្រាន់តែជាងការសិក្សា ដែលធ្វើនៅក្នុងសាលាដោយគ្មានសកម្មភាព គឺធ្វើនៅក្នុងសាលាធម្មតា ។

បាស់ទៅតែទុកជានៅក្លែង

១— នរជនណាស្ងួមបាស់តែមានទ្រព្យច្រើន នរជននោះកំឈ្មោះថានៅកំលោះ; នរជនណាស្ងួមនៅក្លែងតែខ្សត់ទ្រព្យ នរជននោះកំឈ្មោះថាបាស់ដែរ ។

ឧបាយនៃបុរសអ្នកស្វែងរកទ្រព្យ ដើម្បីកសាងខ្លួនជាអ្នកមានទ្រព្យ មាន ៦ ប្រការ គឺការស្ងួមមានគេ ១, ធ្វើដាសេរីភាពនៃព្រះន្ទបតី ១, ការធ្វើស្រែចំការ ១, ការបានឪវាទ្ធិដ្ឋា ១, ធនាគារ (ធនាគារ) ១, និងពាណិជ្ជកម្ម ១ ។ បណ្តាការងារទាំង ៦ ប្រការនេះ ឧបាយដ៏ប្រសើរដែលនាំឲ្យបានទ្រព្យច្រើននោះ គឺពាណិជ្ជកម្ម ។

រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវិជ្ជាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ទានស្នេហាជាតិ ។

កណ្ឌទី ២៣

តាំងពីបូជ្ជនឹកតូបចិត្តដ្សិតបានទំនុកបំរុងគួនអ្ហិដល់ឆ្នាត ហើយគួនអ្ហិមិនប្រែចិត្តពីឡៅពីសោះ រហូតដល់គួនអ្ហិបានទទួលសំបុត្រឡៅពីពីតាន់ជិនដាបំរើ ក្នុងសេចក្តីសំបុត្រនោះ និយាយរំលឹកនឹងពីការអន់ចិត្តនឹងគួនអ្ហិ ។

ចូជ្ជបានស្តាប់ជូប្នោះក៏រិតតែមានសេចក្តីតូចចិត្ត ហើយគិតថាយើងបង់ត់និតដែលតាំងចិត្តនឹងទំនុកបំរុងគួនអ្ហិ ដោយយសស័ក្តិស្រិង្គារបរិវារគួនអ្ហិក៏នៅតែរលឹកអាល័យឡៅពីមិនក្ខេច ។ គួនអ្ហិលាចូជ្ជទៅកាន់គេហដ្ឋាន ។ ចូជ្ជក៏សួរតៀវលៀវថា យើងបានចិញ្ចឹមរក្សាគួនអ្ហិក៏ដល់ឆ្នាតប៉ុណ្ណោះហើយ គួនអ្ហិនៅតែមានចិត្តគិតអាឡោះអាល័យឡៅពីជរាបមិនក្ខេច យើងនឹងរិះគិតប្រការម្តេចទើបគួនអ្ហិនឹងប្រែចិត្តបេញពីឡៅពី? ។ តៀវលៀវធ្វើយថា សំុឲ្យលោកបង្អង់ឈប់គិតការណ៍នេះ ១ ពេល

៦ ពេលសិនចុះ ចាំខ្ញុំបាទទៅល្ហួងនិយាយមើលកល់គួនអ្ហិឲ្យដឹងថា នឹង
មានសុចរិតពិតត្រង់នឹងឡៅពីទៀងទាត់ ឬគិតកេវប្រប្រការម្តេចខ្ទះ ។

លុះវេលាព្រឹកថ្ងៃ ១ គៀវលៀវទៅស្ហរគួនអ្ហិ អ្នកទាំង ៦ ក៏គំនាប់
ត្នាទៅវិញទៅមក គៀវលៀវនិយាយនឹងគួនអ្ហិថា តាំងពីមហាឧបរាជបាន
អ្នកមកទុកជាកំឡាំង លោកក៏មានសេចក្តីសោមនស្សត្រេកអរបានទំនុក
បំរុងអ្នកជាច្រើន ពីព្រោះមានមេត្តាជល់អ្នក ។ គួនអ្ហិក៏ថា សព្វថ្ងៃនេះ
មហាឧបរាជបានជប់លៀងខ្ញុំ បានជាខ្ញុំបានសេចក្តីសុខជរាបមក គុណ
មហាឧបរាជក៏មានលើខ្ជួនខ្ញុំច្រើនណាស់ តែខ្ញុំនឹងបានភ្ជេចពីឡៅពីក៏ទេ ។
គៀវលៀវតបថា ធម្មតាកើតមកជាប្រុសឲ្យដឹងច្បាស់ការធ្ងន់នឹងស្រាល
បើអ្នកឯណាមិនដឹងមិនស្គាល់ហើយ មនុស្សទាំងពួងក៏រមែងត្មះតិះដៀល
ថា អ្នកនោះជាមនុស្សល្ងង់អំប្បឥតប្រាជ្ញា ឯមហាឧបរាជនេះក៏មានចិត្ត
អាណិតមេត្តាអ្នក បានទំនុកបំរុងលើសជាងឡៅពីទៅទៀត ហេតុម្តេច
អ្នកក៏នៅតែគិតដល់ឡៅពីមិនជាប់? ។

គួនអ្ហិធ្ជើយថា ដែលមហាឧបរាជមានព្រះគុណនឹងខ្ញុំនោះក៏មែន
ហើយ តែនឹងប្រៀបធៀបឲ្យស្មើឡៅពីមិនបានទេ ព្រោះឡៅពីមានគុណ
នឹងខ្ញុំមុន, ប្រការ ១ ខ្ញុំបានស្បថស្បាន់ទុកជាបន្ទាល់គឺយកត្នាជាបងប្អូន
បានជាខ្ញុំតាំងចិត្តរក្សាសេចក្តីសត្យកតញ្ញូនៅក្នុងចិត្តសព្វថ្ងៃ ខ្ញុំក៏មានគិត
តបគុណមហាឧបរាជសិនទើបបានចេញទៅ ដើម្បីទុកកេរ្តិ៍ឈ្មោះជា
មនុស្សកតវេទី ។ គៀវលៀវបានស្តាប់ដូច្នោះក៏ស្ហរគួនអ្ហិថា បើឡៅពី
ជល់នៅសេចក្តីមរណភាពហើយ អ្នកនឹងនៅជាប់នឹងមហាឧបរាជ ឬ ។

នឹងគិតក្រការម្តេច? ។ គួនអ៊ូតបថា ខ្ញុនខ្ញុំកើតមកជាប្រុសរក្សាសេចក្តីសត្យពិតត្រង់មិនឲ្យបង់រាចា ប្រសិនបើឡេាពីក្យ៉យជន្មាមែន ខ្ញុំក៏ត្រូវស្លាប់តាមគ្នាដោយរាចាដែលបានស្បថស្បាន់ទុកនោះជាប្រាកដ ។

តៀរលៀវយើញគួនអ៊ូមានសេចក្តីសត្យពិតត្រង់ នឹងឡេាពីពិតប្រាកដដូច្នោះក៏លាចុះទៅវិញ ទើបនាំយកសេចក្តីទាំងពួងថ្វែងឲ្យចូធូស្តាប់គ្រប់ប្រការ ។ ចូធូបានស្តាប់ហើយក៏ជកដង្ហើមធំមានតែសេចក្តីវិតក្ក ព្រោះនឹងយកគួនអ៊ូទុកឲ្យជាច់ពីឡេាពីមិនបានដូចប្រាថ្នា ហើយសរសើរគួនអ៊ូថាជាមនុស្សមានសេចក្តីសត្យពិតត្រង់ល្អមែន ។ ស៊ុនហុកជំរាបចូធូថា ឯគំនិតនឹងចិត្តគួនអ៊ូនោះ ប្រុងនឹងតបស្នងសងគុណមហាឧបរាជឲ្យរួចទើបត្រឲ្យប់ទៅវិញ បើដូច្នោះកាលណាមានសឹកសង្ត្រាមក៏កុំអាលឲ្យគួនអ៊ូចេញយកអាសា បើគួនអ៊ូមិនទាន់ផ្ទើការឲ្យមានបំណាច់តាប់ប្រសើរទេក៏គង់នឹងនៅដោយសារមហាឧបរាជតទៅទៀត ។ ចូធូបានស្តាប់ ក៏ចាប់ចិត្តគិតយល់ឃើញត្រូវផង ។

ឯឡេាពីនោះ កាលទៅនៅអាស្រ៉យក្នុងស្រុកគីជីវនោះ ក៏ចេះតែគិតនឹកលឹកដល់គួនអ៊ូតៀវហ៊ុយ នឹងគ្រប់គ្រូដែលខ្ជាត់ក្ជាត់ព្រាត់ពីគ្នាមិនបានដឹងថាជារស់ឬស្លាប់ប្រការម្តេច តែងតែជាទុក្ខពុំសុខសប្បាយ មានកាយនោះស្គមថមថយកំឡាំង ទាំងបរិកោគអាហារនឹងនិទ្រាក៏ពុំសូវបានដូចប្រក្រតី ។ អ៊ូនសៀវយើញមុខឡេាពីសៅហ្មងក៏ស្លូរថា អ្នកមានបើព្រួយទុក្ខវិតក្កពីរឿងអ្វី ។ ឡេាពីធ្វើយតបថា ខ្ញុនខ្ញុំបាទបែកមកនៅនឹងលោក បានទីពឹងលោកក៏ផុតអំពីក៉យអស់ហើយ តែនៅគិត

ដល់បុត្រតរៀយនឹងប្អូនតាំង ២ ដែលព្រាត់និងសង្គាទៅនោះ មិនបានដឹងដំណឹងថាជារស់ឬស្លាប់ប្រការម្តេច ប្រការ ១ ខ្ញុំបានកើតមកជាកូនប្រុសហើយគិតនឹងជួយទំនុកបំរុងផែនដីឲ្យបានសេចក្តីសុខ ការដែលគិតខុកនោះក៏មិនបានសម្រេច ព្រួយនឹងការកើតមកបានធ្លាជាខ្ញុំស្តេចហើយ តែគ្មានប្រយោជន៍នឹងផែនដីសោះ ហេតុដូច្នោះបានជាខ្ញុំចាំមិនសប្បាយ ។

អ្នកនឹងសៀវបានស្តាប់ដូច្នោះក៏ឆ្លើយថា ចូរធ្លាក់ការពុំប្រតែងអាក្រក់នឹងផែនដី យើងលើកកងទ័ពទៅដល់ដំបន់លិយ៉ុងប៉ងនឹងកំចាត់ចូរចេញឧទ្ទលទេសៈកាលៈវង្សា ឲ្យបានជាឲ្យងាន់លៀងនាំពលពាហនទៅតាំងបន្ទាយនៅចុងដែនស្រុកហ៊ូគោ ខ្ញុំក៏លើកកងទ័ពត្រឡប់មកវិញ គ្រានេះជារដូវត្តៅហើយ អ្នកកុំបីតែក្តៅឡើយ យើងនឹងលើកកងទ័ពទៅច្បាំងម្តងទៀត រាយយកស្រុកហ៊ូគោឲ្យបាន ឯការយោបុត្រនឹងប្អូនអ្នកតាំង ២ នោះ ទោះបីស្លាប់រស់ប្រការម្តេចក៏គង់តែដឹងដំណឹងពុំខាន ។

ខៀនហង់បានឮអួនសៀវថាដូច្នោះក៏ថា កាលចូរធ្លាលើកទ័ពទៅរាយស្រុកឈើដីវនោះ ខ្ញុំបានដំរាបលោកឲ្យលើកកងទ័ពទៅរាយស្រុកហ៊ូគោ លោកមិនយល់ព្រមសោះ ឥឡូវនេះ ចូរធ្លាបានស្រុកឈើដីវហើយក៏លើកកងទ័ពត្រឡប់ទៅរក្សាស្រុកហ៊ូគោវិញ ដែលលោកនឹងលើកទ័ពទៅកំចាត់ចូរធ្លាគ្រានេះ ខ្ញុំបាទយល់ថាមុខជាមិនបាន ព្រោះសេនាពាហនរបស់គេព្រមមូលតាំងអស់ សុំឲ្យលោកពិគ្រោះវង់ស្តាប់ដំណឹងសិនបើឮថាចូរធ្លាលើកទ័ពទៅញាក់ស្រុកណា សឹមយើងលើកទ័ពទៅខ្ទប់រាយយកស្រុកហ៊ូគោឲ្យបានដោយងាយ ។

អ្នឧសៀវបានស្តាប់ក៏និយាយនឹងខ្លៅពីថា ពាក្យខៀនហង៍ឱ្យស់ ឃាត់ទុកដូច្នេះ អ្នកនឹងយល់ឃើញប្រការម្តេច? ។ ខ្លៅពីតបថា ចូធូធ្វើការទុច្ចរិតអាក្រក់មិនមានកោតខ្លាច អំណាចព្រះចេស្តាព្រះចៅហៀន-តេសោះ បណ្តាមនុស្សក្នុងស្រុកហ៊ូតោ នឹងអាណាខែត្រក្រៅក៏បានសេចក្តីឈឺក្តៅពន់ប្រមាណ បណ្តាពស្តេសព្វទីឋានក៏បានដឹងថា លោកមានសេចក្តីសត្យាកត្តញ្ញូនឹងផែនដី រំលោនេះលោកក៏បានជ្រាបសេចក្តីអស់ហើយ នឹងនៅព្រងើយកន្តើយមិនគិតកំចាត់អាសត្រូវពាជសម្បត្តិជាប្រញាប់ចេញនោះមិនគួរសោះ ប្រការ១ ទៀត ចូធូនោះក៏មានចិត្តគុំគួនក្លាឡើង ព្រះចៅហៀនតេក៏បានសេចក្តីព្រួយ ព្រះទ័យណាស់ សុំឱ្យលោកត្រិះរិះមើលតាមការគួរ ។ អ្នឧសៀវបានស្តាប់ខ្លៅពីក៏យល់ឃើញតាម ទើបឱ្យត្រៀមភាហានទុកព្រម បើបានឫក្សជោគជ័យរំលោណានឹងលើកពលយោធាចេញទៅ ។ ខៀនហង៍ក៏ហាមឃាត់អ្នឧសៀវទៀតថា គ្រានេះលោកកុំអាលលើកទៅ លោកចូរស្តាប់ពាក្យខ្ញុំបាទចុះ ។

អ្នឧសៀវបានឮដូច្នោះក៏ខឹងណាស់ ធ្វើយតបទៅខៀនហង៍ថា យើងគិតនឹងទំនុកបំរុងផែនដី ហេតុម្តេចខ្លួនមកហាមឃាត់យើងដូច្នេះ ឬខ្លួននឹងចង់ឱ្យព្រះចៅហៀនតេបានសេចក្តីអន្តរាយ ។ ខៀនហង៍ឃើញអ្នឧសៀវខឹងក៏តាំងតែកិតក័យ ទើបលុតដង្គង់ចុះហើយជំរាបថា ខ្ញុំបាទឃាត់ហាមលោកដោយគំនិតយល់ឃើញតាមសុចរិត មិនមែននឹងគិតឱ្យអន្តរាយដល់ព្រះចៅហៀនតេទេ បើលោកខំមាន:លើកកងទ័ពទៅ មុខជានឹងថ្កោះការដោយដៃចូធូជាប្រាកដ ។ អ្នឧសៀវបានឮខៀនហង៍ថែម

ថាដូច្នោះ ក៏រឹតតែខឹងកាំងឡើង សុំទាញក្រចឹចចេញទៅប្រជងនឹងកាប់ខ្មៀនហាង ។ ឡៅពីក៏ឃាត់ហាមអ្នឧនសៀវថា លោកនឹងលើកកងទ័ពទៅធ្វើការរឿណរង្គសង្គ្រាម នឹងមកធ្វើអន្តរាយទីប្រឹក្សាចេញនោះមិនគួរ ។ អ្នឧនសៀវក៏ស្រាកខឹងព្រោះស្តាប់ឡៅពី ទើបឲ្យយកខ្លួនខ្មៀនហាងទៅដាក់គុកទុក ។

ចស៊ីវឃើញអ្នឧនសៀវយកខ្មៀនហាងទៅដាក់គុកដូច្នោះ ក៏ទឹកភ្នែកចិត្តពន់ពេក ទើបយកទ្រព្យរបស់ទាំងពួងដែលជារបស់ខ្លួន ចែកដល់បុត្រកវិយាញាតិកាបងប្អូនអស់ ហើយថា អ្នឧនសៀវនឹងលើកទ័ពទៅគ្រានេះ ទោះបីមានជ័យជំនះក៏មិនមែននឹងឲ្យបំណាច់ផ្លាន់ដល់យើងឡើយ បើទៅធ្វើការសង្គ្រាមនោះថ្មោះការនឹងចូធ្ង យើញថាជីវិតយើងនឹងមិនរួចវិលមកវិញបាន អ្នកទាំងឡាយចូរនៅឲ្យសុខសប្បាយចុះ ។ កវិយានឹងគណៈញាតិបងប្អូនឮដូច្នោះ ក៏មានចិត្តគិតអាឡោះអាល័យចស៊ីវពន់ប្រមាណ ។

អ្នឧនសៀវមានសំបុត្រទៅដល់ផ្លាន់លៀង ដែលតាំងទ័ពនៅតំបន់ល័យ៉ុងនោះឲ្យលើកជាកងហ្មួងខាងមុខ លើកចូលទៅលុកស្រុកហ៊ូគោ ។ ចស៊ីវក៏ឃាត់ហាមអ្នឧនសៀវថា ដែលលោកនឹងឲ្យផ្លាន់លៀងលើកទាហានជាកងមុខទៅតែម្នាក់ឯងនោះ ខ្ញុំបាទឃើញថាមិនគួរសោះ ព្រោះផ្លាន់លៀងជាមនុស្សម្នាម្នុះមិនបានដឹងច្បាស់ខឹបដំខ្មីបាន ។ អ្នឧនសៀវឮដូច្នោះក៏ខឹងណាស់ ធ្វើយតបទៅចស៊ីវថា ផ្លាន់លៀងនោះជាសេនាឯករបស់យើង ហេតុម្តេចអ្នកឯងមកជំនៀលដូច្នេះ ។ ចស៊ីវមិនធ្វើយ

ឥបសោះ អ្ជិនសៀវក៏ចាត់បំរើសេះឲ្យយកសំបុត្រទៅឲ្យឆាន់លៀងៗ ទទួលមើលដឹងការណ៍ហើយ ក៏លើកទ័ពវាយកន្ធងចូលទៅក្នុងដែនស្រុកហ្ចូតោ ដល់តំបន់ប៉ែះប៉ែក៏ឲ្យតាំងបន្ទាយនៅទីនោះ ។ អ្ជិនសៀវក៏នាំទ្បៅពីលើកទាហានណូនទៅទៀត ។

ទណៈនោះ ទ្បៅអៀនចៅហ្ចាយស្រុកឌងគុន ដឹងថាកងទ័ពអ្ជិនសៀវលើកមកដល់តំបន់ប៉ែះប៉ែ ក៏ផ្ញើសំបុត្រចាត់បំរើឲ្យនាំចូលទៅជំរាបចូធូ ។ ដឹងសេចក្តីក៏ឃ្មាតឱ្ងឲ្យលើកទាហានចេញទៅ ។ ឆួនអ្ចិញ្ចដំណឹងក៏ចូលទៅជួបនឹងចូធូហើយថា ត្រានេះលោកនឹងលើកទ័ពទៅច្បាំងនឹងអ្ជិនសៀវ ខ្ញុំបាទនឹងសុំអាសាលើកទាហានទៅជាទ័ពស្ងួច ។ ចូធូថា ការសឹកបន្ទិចបន្ទួចប៉ុណ្ណោះមិនល្មមនឹងក្តៅដល់អ្នកទេ ប៉ើសិនណាយើងទៅផ្ញើសត្រាមនឹងអ្ជិនសៀវហើយទុញទាល់ប្រការម្តេច សិមឲ្យមកអញ្ជើញនាក់ទៅជួយជាក្រោយ ។ ឆួនអ្ចិបានញ្ចដូច្នោះក៏លាចូធូត្រឡប់មកផ្ទះវិញ ។

ចូធូចាត់ការឲ្យប្រមូលកេណ្ឌទាហានបាន ១៥ ម៉ឺន ញែកចេញជា ៣ កង ហើយលើកចេញចាកក្រុងហ្ចូតោ ទៅដល់កណ្ណាលផ្ទូវទទួលបំរើសេះនាំពតិមានមកប្រាប់ថា ឥឡូវកងទ័ពមុខអ្ជិនសៀវលើកចូលមកដល់តំបន់ប៉ែះប៉ែហើយ ។ ចូធូញ្ចដូច្នោះក៏បង្គាប់ទ័ព ២ កងនោះថា ឲ្យស្រូតកាត់តម្រង់ផ្ទូវលើកចុះទៅតទល់នឹងទ័ពអ្ជិនសៀវទុកកុំឲ្យលើកធ្ងងចូលមកទៀត យើងនឹងលើកទ័ពណូនទៅតទល់ជាក្រោយ ហើយចូធូក៏លើកពលទាហាន ៥ ម៉ឺនស្រូតរូតទៅដល់តំបន់ប៉ែះប៉ែ ក៏តាំងបន្ទាយព័ទ្ធជុំវិញ

ជាប់ជិតនឹងកងទ័ពងាន់លៀងចម្ងាយពីគ្នាប្រហែល ៥០ សិន (៦ ត.ម.) រួចចូធូក៏ឡើងទៅលើកូនសំឡឹងមើលទៅឃើញទាហានងាន់លៀងប្រហែល ១០ ម៉ឺនជ្ងាយតាំងបន្ទាយជាយ៉ាងមាំ ចូធូនិយាយនឹងសុងហ្ជានថា កាលអ្នកឯងនៅជាមួយនឹងលីជ្យ៉ានោះ យើងបានព្ធដំណឹងថ្ងៃដែខ្ងាំងពូកែណាស់ ឥឡូវត្រូវអ្នកឯងលើកទាហានទៅច្បាំងនឹងងាន់លៀង ។

សុងហ្ជានក៏ទទួលបង្គាប់ចូធូឡើងសេះកាន់ទួន លើកទាហានចុះទៅដល់មុខបន្ទាយងាន់លៀង ។ ក្រឡេកឃើញ ក៏លើកទាហានចេញមកតច្បាំងនឹងសុងហ្ជានបាន ៣ ក្ងេង ងាន់លៀងយកដាវកាប់សុងហ្ជានធ្ងាក់ពីលើសេះ ។ ចូធូឃើញដូច្នោះក៏ភ័យណាស់ថា សេនាអ្ជីនសៀវម្នាក់នេះមានថ្ងៃដែខ្ងាំងពូកែមែន ។ ឡុយសុកធ្ងើយថា ងាន់លៀងសម្ងាប់សំឡាញ់ខ្ញុំបាទស្ងាប់ហើយ ខ្ញុំបាទសុំយកអាសាលោកទៅសម្ងាប់ងាន់លៀងឲ្យបានវិញទើបអស់កំហឹង ។ ចូធូក៏យល់ព្រមប្រគល់ទាហានឲ្យឡុយសុក លើកចេញទៅតនឹងងាន់លៀង បាន ១ ស្របក់ងាន់លៀង យកដាវកាប់ឡុយសុកដាច់ពាក់កណ្ណាលខ្ជូនជា ៦ ក៏ណាត់ស្ងាប់ ។ ទាហានឡុយសុកក៏បែកខ្ចាត់ខ្ចាយរត់ត្រឡប់មកវិញ ។ ចូធូឃើញសេនាទាហានរបស់ខ្ជូនបរាជ័យទាំង ៦ លើកក៏នឹកតូចចិត្តណាស់ ពិនត្រាះនឹងនាយកងនាយទ័ពថាងាន់លៀងនេះ មានថ្ងៃដែក្ងាហានខ្ងាំងពូកែណាស់សម្ងាប់សុងហ្ជាននឹងឡុយសុកស្ងាប់ហើយ នរណានឹងយកអាសាទៅចាប់ខ្ជូនងាន់លៀងបាន ។

(ម ឧត)

ដំណឹងតាមខ្សែក្នុងកញ្ចាស់

លោក ផេង-ជ្រៃ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាចាំងមកជាភាសាខ្មែរ

(តមក)

បន្ទាយកស្សាម៉ុត នៅឆ្ងាយពីភូមិភាសិ កាព-ប៊ូលីណាស់ ហើយ អ៊ីស្នាអ៊ីលមិនសូវស្គាល់ផ្លូវផង តាមប្រកបង្ខៀត លើវាលផ្សារខ្សាច់ធំ លើខ្នងភ្នំ ។ ស្បៀងអាហារនឹងស្មៅសម្រាប់សត្វអូដ្ឋយកទៅបំរុងតែត្រឹមប្លន់ថ្ងៃ ។ ម្យ៉ាងទៀត គឺសត្វអូដ្ឋយកបានតែចំនួនប៉ុណ្ណឹង ។ អ៊ីស្នាអ៊ីលប្រយ័ត្នមិនហ៊ានឲ្យឃ្លាតពីត្រសំយ៉ាយទេ, វត្តគួចនេះ ជាប្រជាប់មួយយ៉ាងឯកសម្រាប់ជួយសង្គ្រោះកងទ័ពហោស្ថាន គឺជាទីដែលជាតិអាប៉ាប់នៅក្បែរច្រាំងសមុទ្រមិនហ៊ានលូកដើងចូលមក ។

ខ្នងកំសុទ្ធតែជុំថ្ម ប្លែង គួរឲ្យស្ញែប ។ ខ្នងកំនេះលាតសន្ធឹងជាបន្ទោះកំពីរ គឺកំ អ៊ូអាឌី-បេទ៍-អ៊ូលិជ នឹងកំអ៊ូអាឌី-សែមសែម ។ ផុតពីខ្នងកំនេះទៅ ទើបគេបានដល់បន្ទាយកស្សាម៉ុត បន្ទាយនេះនៅជាប់ប៉ែកទិសខាងកើតនៃទីលូដ៏ប្រទេសទីប៊ូលីតែន ជិតខ្ទង់នេះស្រុតចុះទៅក្នុងសមុទ្រជានាគួច ។ នៅបណ្តាថ្មកអន្ទង់ម៉ាកឈ្មោះតាអាយ៉ា សព្វថ្ងៃទៅជាដីគោកស្រឡះហើយ ។

ពួកសេះនឹងអូដ្ឋដែលជំពប់នឹងជុំថ្មធំ ។ ដួលមុតរបួសជាធម្មតា ។ ជួនពួកអ្នកជិះ តោងតែចុះដើរដើងទេ ព្រោះផ្លូវនៅក្បែរមាត់ច្រោះ

ពេក ខ្ទាចក្រែងរិលមុខ ។ ផ្ទូវអាក្រក់សម្បើមជាងគេ ត្រង់ច្រកភ្នំ
អាក្រីម៉ា អាគេរូ ធ្ពាស់ទុយឡា គឺជាផ្ទូវឡើងចុះ ។ ម្ទ៉ោះហើយគេតោង
តែបន្ពិចរើអីរ៉ាន់ចុះ បន្ពិចផ្ទុកឡើងលើខ្នងអូជ្ជវិញ ។ ព្យុះខ្យាច់កណ្ណាល
កន្ពារះឈ្មោះតាឡា ឃុំឃាំងអ្នកដំណើរអស់ដប់ម៉ាង ។

សេចក្តីទុក្ខថ្មីចូលមកទៀត គឺផុតស្បៀង ។ អ៊ីស្មាអ៊ីលនឹកថាខ្ជូន
គេ ព្រមទាំងកូនទាហានទៀងជាជាប់ពោះស្ទាប់មុនដល់បន្ទាយមិនខាន ។
ប៉ុន្តែនៅវេលាល្ងាចថ្ងៃទីប្រាំមួយ គេស្រាប់តែឃើញបន្ទាយលេចឡើង
លឹម ។ ឯដើងមេឃ ។

ប្រាសាទបុរាណទាំងឡាយនៅទីក្រុងកស្យាមុិត ជាប្រាសាទល្អ
ជាប់គេនៅទ្រីប៉ូលីតែន ។

មុនដំបូង អ៊ីស្មាអ៊ីលភ្ញាក់ដោយឃើញសុទ្ធកំពែងធំ។ ។ គ្រិះស្ថាន
នេះមានកំពស់ពីប្រាំមួយទៅដប់ម៉ែត្រ សង់សុទ្ធតែអំពីថ្មបួនជ្រុងតូច។
រៀបជាជួរយ៉ាងត្រឹមត្រូវ ។ មានគ្រឹះស្ថានធំសម្បើមចំនួនម្ភៃសង់នៅ
តាមត្រើយខាងធ្ងេងនៃទន្ទេអ៊ូអាឌ៊ីកស្យាមុិត ចម្ងាយប្រហែលបីរយម៉ែត្រ
ពីមាត់ពាម ក្នុងទន្ទេសែមសែម ។

ផ្ទះទាំងនោះមានថ្នាក់យ៉ាងតិចត្រឹមពីរជាន់ សុទ្ធតែមានកំពែងព័ទ្ធ
ជុំវិញ ។ មានផ្ទះខ្ទះ មានប៉មយ៉ាងជាប់មាំមួននៅក្បែរខាង ។

នៅកស្យាមុិត ទីក្រុងកសាងយ៉ាងមាំជាប់លាប់ តែគ្មានត្រឿង
លំអអ្វីឡើយ ។ បន្ទាយនេះ គេសង់ឲ្យតែជាប់ស្រួលប៉ុណ្ណោះ ។ គឺ
ជាបន្ទាយលេចឡើងនាកណ្ណាលរាលសុទ្ធតែថ្មរាងក្រឡូម ដូចជាកំពូល

បពិត្រ ។ កម្រាស់កំពែងនឹងត្រូវដែលធ្លើនៅនាទីជ្រាទាំងកន្លះ ទុកជាផ្លូវឲ្យពួកទ័ពអាចតស៊ូនឹងបច្ចាមិត្តបានយូរ ។ ហេតុដូច្នេះ ទីនេះនៅឆ្ងាយពីច្រាំងសមុទ្រចំនួនមួយរយហាសិបគីឡូម៉ែត្រ ប៉ុន្តែជាទ័ព្រំដែនមុំដំរាយបន្ទាយនេះណាស់ ព្រោះគេអាចលៃពេលដើម្បីបញ្ជូនទ័ពពីទីក្រុងមួយជួយបាន់ ដ្បិតតាំងពីកាលណាមក បន្ទាយកស្សាម៉ុត គេទុកជាកន្លែងតទ័ពដ៏រស់រវើយមួយ ។ ដោយអាស្រ័យរឿងនេះទើបពួកសាសន៍តួរគីមកតាំងទ័ពនៅទីនេះ ។

ម្យ៉ាងទៀត នៅទិប៊ូពារីតែន គេទុកបន្ទាយកស្សាម៉ុតជាស្ថានតាំងទ័ពប្រកបដោយសេចក្តីទុក្ខព្រួយជាងបន្ទាយឯទៀតៗ រាបសាតួរគី ។ រង្វាកប៉ាលកុងស្តង់ទីណុបតែងបញ្ជូននាយទាហាន ទឹងទាហានណាដែលមានចរិតរឹងរូសមិនប្រព្រឹត្តតាមច្បាប់ព្រះចៅសុលតង់ ទៅឯបន្ទាយកស្សាម៉ុតជាធម្មតា ។

តាំងពីពេលកើតសង្គ្រាមមក គេនិយាយថា មានទាហានជាច្រើនត្រូវអាជ្ញាសិទ្ធិពីកុងស្តង់ទីណុប បង្គាប់ឲ្យនាយទាហានសម្លាប់ចោលកងស្មាមភ្នែកជាច្រើនដងរួចមកហើយ ។ គេបានឲ្យឈ្មោះបន្ទាយកស្សាម៉ុតថា “យមបន្ទាយ” បើអ្នកណាចូលកងបន្ទាយនេះហើយ ត្រូវការនាធម៌ឲ្យហើយទៅ មុខជាអស់សង្ឃឹមហើយ ។

អ៊ីស្មាអ៊ីលគ្មានដឹងរឿងនេះសោះ ។ គេចូលកងបន្ទាយដោយទាំងស្រមោលរូបនាងឡីឡាទៅផង ហើយមានការទុកចិត្តយ៉ាងមាំថា ថ្ងៃណាមួយមិនយូរក៏ឆាប់ គេនឹងត្រឡប់បានជួបមុខគូសង្សារវិញមិនខាន ។

ទ្រ! គួរអនិច្ចាពេក! គេមិនបាត់ការស្រមាក់ស្រមៃនូវរូបនាង
ឡីឡាពីក្នែកសោះ ។

នាយឥហានអែបរឋសំលោកមេទ័ពមកទទួលអ៊ីស្មាអ៊ីល ។ នាយ
ឥហាននេះជាមនុស្សកំឡោះ មានអាយុស្រុតក់ស្រុបាលនឹងអ៊ីស្មាអ៊ីល
ដែរ ។ ដោយទម្លាប់តវ៉ាណាតែងធ្វើមនុស្សជាតិផ្សេងសាសន៍ពីគ្នា
ឲ្យមានសេចក្តីមេត្រីរាក់គ្នាទៅវិញទៅមក ។

នាយឥហានតួរគីនេះ គេធ្លាប់បានឃើញអាការដ៏ស្រស់ស្រង់យ៉ង់
ឃ្នង់នឹងក្នែកជាច្រើនលើកមកហើយ ហាក់ដូចជាគិតពុំជាមុនអំពីវាសនា
ដែលវង់ចាំអ៊ីស្មាអ៊ីល ។ កាលដែលលោកនេះមកទទួលលោកអនុ-
សេនីយ៍ឯក មានវាចាសួរថា.

— លោកអនុសេនីយ៍ឯក! ពួកទ័ពធ្វើប្រតិបត្តិការ លើកសំដៅទៅ
សម្រុកហើយ ហេតុម្តេចក៏លោកអញ្ជើញមកខាងឯណេះវិញ?

អ៊ីស្មាអ៊ីលឆ្លើយថ្លែងថា:

គឺជាបទបញ្ជា .. ខ្ញុំត្រូវតែធ្វើតាម!

ខណៈនោះ នាយឥហានតួរគីសួរដោយមានទឹកចិត្តអាណិតយ៉ាង
ខ្លាំងថា:

លោកមិនដឹងទេឬ ការណ៍ដែលវង់ចាំលោកនៅឯកសារ៉ាម៉ុត?

មុនដែលអ៊ីស្មាអ៊ីលនឹងឆ្លើយតបទៅវិញ នាយឥហានបើកទ្វារសម្ងាត់
ហើយនាំអ៊ីស្មាអ៊ីលចូលកន្លែងមួយពាក់ក្រឡម ដែលមានសពមនុស្ស
ម្នាក់ស្លៀកពាក់អស្សុកសុស្ណានថង់ព្យួរនៅទីនោះ ។ រួចលោកថ្លែងថា:

ហ្នឹងហើយ ឃើញឬទេ?

ក្នុងពេលនោះ អ៊ីស្មាអ៊ីលចូលចិត្ត អំពីនយោបាយរបស់លោកមេ-ទ័ពនៅក្រុងកាសិ-ការាបូលីក្ខាម គឺលោកមេទ័ពនេះមិនហ៊ានធ្វើបាបនូវកូនរបស់លោកការអ៊ីដ លោកប្រើកលរបេចបង្វែងដាន ដើម្បីឲ្យបានសម្រេចការណ៍ដូចគ្នា ។

អ៊ីស្មាអ៊ីលសំឡឹងទ្មោចចងកសញ្ញ ។ រួចសំឡឹងមកលោកនាយទាហានទើបនិយាយដោយវាចាឥតរន្ធត់ថា:

សូមការស្ម័គ្រនៃព្រះអាឡស់សម្រេចចុះ!

វេលានោះ លោកមេទ័ពមានបំរើឲ្យមកហៅគេចូល ។

*

* *

លោកវរសេនីយ៍ឯក ហ្ការរេនឌីន-ប៊ីមេទ័ពប្រចាំបន្ទាយកស្សាម៉ុតជាមនុស្សចំណាស់មួយក្នុងការសង្ត្រាម ហើយគេស្គាល់លោកច្បាស់អំពីគំនិតមារយាទ ក្នុងកិច្ចចាត់ចែងបទបញ្ជា ។

ត្រូវទទួលការ:ជាអ្នកបង្ត្រាបចំណែកកូមិកាគមួយ ក្នុងទ្រីប៉ូលីតែនដែលមានកូមិខ្ទះបះបោរ មិនព្រមបង់ពន្ធ ហ្សែរជារកវាយតមកវិញ ហើយដើរយោសនាឲ្យកើតចលាចលពាសពេញទាំងស្រុក លោកមេទ័ពប្រើមហាមធ្យោបាយដោយគ្មានរួញរា គឺលោកផ្តើមឲ្យចាប់សម្ងាប់អ្នកស្រុកជាច្រើន ។

មាននាយទាហានរបស់លោកម្នាក់ ត្រូវគេសម្ងាប់ ជាប្រផ្នូលនៃការបះបោរ ។ ដើម្បីសងសឹក វេលាណាមានពិធីបុណ្យអាវ៉ាប់ គឺជាថ្ងៃ

បុណ្យរៀបជូនដំណើរដល់បូជនិយដ្ឋាយិក ដើម្បីទៅកាន់ព្រះវិហារមើតប្ម
ជាថ្ងៃបុណ្យដែលបូជនិយដ្ឋាយិកវិលត្រឡប់មកវិញ នោះលោកចាត់ឲ្យ
ពួកតាហានបាញ់កាំភ្លើងធំចេញពីបន្ទាយ តាមទំនៀមទម្លាប់ ទោះបីកាំ-
ភ្លើងបាញ់តែម្យវទទេ ក៏គង់មានមនុស្សស្លាប់ជាច្រើន ព្រោះម្យវដែល
ចេញទៅលាយនឹងត្រាប់ប្រាយដែលជាក់ជុំក្លួសចំនួស ។

រដ្ឋាភិបាលកុងស្តង់ទីណុប ក៏មិនហាមឃាត់លោកមេទ័ព អំពីបទ
កំហុសនេះ ព្រោះរាជការតួរគីគិតថា មានតែឧបាយមួយនេះទេ ដែល
ប្រើសម្រាប់ត្រួតស្រុក: គឺឧបាយយង់ឃ្នង ។ ជាតិអង់គ្លេសក៏ប្រើ
នយោបាយជូច្នេះដែរ ។ ចំណែកពួកបារាំងសែសប្រើនយោបាយផ្ទុយ
ពីសាសន៍ខាងលើនេះ ។ នឹកឡើងគួរឲ្យស្រងេះស្រងោចអំពីទុច្ចរិតកម្ម
ដែលលោកមេទ័ពនៅ (កូតឌីវ) បានធ្វើ គឺជុតភូមិចោលទាំងមូល ។

ដោយហេតុតែចិត្តគ្មានមេត្តាជូច្នេះ បានជាព្រះចៅ សុលតង់ តាំង
នាយទាហាននេះជាវរសេនីយឯក ហើយបញ្ជូនមកបន្ទាយជាប់តែឯង
កណ្តាលកន្ទារ:ប្រកបដោយប្រាសាទបុរាណសុទ្ធតែពស់ ក្អែប ព្រមទាំង
អ្នកស្រុកក៏ប្រើនតែចិត្តរឹងរូសជាជាងមនុស្សក្នុងភូមិធំ ។ ។ លោកមេទ័ព
នេះមកនៅបន្ទាយកស្សាម្ពិតមិនទាន់បានមួយសប្តាហ:ផង ស្រាប់តែមាន
គេបញ្ជូននាយទាហានចិត្តរឹងរូសមកកាន់ទីនេះភ្លាម ។ ពួកនាយទាហាន
ដែលគេបញ្ជូនមកនេះ រស់នៅមិនបានយូរឡើយ គេសម្រេចកិច្ចឲ្យធាប់
រួសរាន់ណាស់ ។ ទាហានណាដែលគេបញ្ជូនទៅកស្សាម្ពិតហើយ គឺគេ
បញ្ជូនទៅរកសេចក្តីស្លាប់ ។

លោកវរសេនីយ៍ឯកអង្គុយលើកៅអីរង់ចាំអ៊ីស្មាអ៊ីល ។ គឺជាមនុស្ស
អាយុប្រហែលហុកសិបឆ្នាំ សម្បុរក្រហមអុចៗ ពោះកំប៉ោ៉ងពុកមាត់
ទ្រុបសស្គុះ មានអាការជ្ជុយគ្នានឹងមុខក្រហមទុំជូចសំបកក្តាមស្ងោរ ។

លោកស្ងៀកពាក់ឯកសណ្ឋានតាមសម័យបុរាណ អាវខ្មៅគ្របពី
លើខោសំពត់ឱបតង ស្បែកជើងរុំជិតទាំងកំភួនជើង ដែលធ្វើឲ្យជើង
មានសភាពតូចមូល មិនជូចជាពេលកាលមិនទាន់ពាក់ ។

ក្នែកខៀវល្អក់ ព្រុយខូងចុះក្នុងរន្ធ ចិញ្ចើមក្រាស់ហើយសព្រោង ។
លោកមេទ័ពមានភាពជាអ្នកលក់កម្រាលតុ ក្នែងភេទ ។ បើនៅឯប្រ-
ទេសបារាំងសែសវិញ គេអាចប្រជូចលោកនេះទៅនឹងនាយទាហាន
ចាស់ជាន់ខ្ពស់មុនសង្គ្រាម ។

អ៊ីស្មាអ៊ីលចូលទៅបង្ហាញខ្លួនទៅចំពោះមុខលោកមេទ័ពនេះ ។
លោកសំឡឹងកូនលោកតាកាអ៊ីជតាំងពីក្បាលចុះមកជល់ជើង ។ លោក
បានទទួលដំណឹងសព្វគ្រប់ដែលក៉យក៉ប់អំពីលោកអនុសេនីយ៍ឯកកំឡោះ
តាមសំបុត្រមួយដោយឡែកតែឯង ។

អ៊ីស្មាអ៊ីលឈរត្រង់ខ្លួនក្រអឹត ក្នុងឯកសម្ណាន ជាក់ជើងត្រឹមគ្នា ។
លោកវរសេនីយ៍ឯកដែសកបង្គាប់ដោយសំដីទ្រគោះថា:

– សម្រាក!

រួចបើកប្រអប់បារី លោកជកយកមួយហុចឲ្យមកលោកអនុសេនីយ៍
ឯកដោយទឹកមុខពេបជ្រាយ ។

អ៊ីស្មាអ៊ីលធ្វើយថា:

– អរគុណ !

ខណៈនោះ នាយទាហានជាន់ខ្ពស់សើចញ៉ឹមៗរើសយកបារីមួយយ៉ាងខ្ចាំង យ៉ាងក្រអូប ឆូសឈើគូសដុតដោយអាការមិនប្រញាប់ប្រណ្តាយឲ្យឆេះយ៉ាងស្រួល រួចក៏ទំលាក់ខ្ជូនដេកទៅលើកៅអីវិញហើយសួរថា:

– អើ យើងឥឡូវនៅក្នុងកស្សាម្ចិតហើយ មែនឬទេ លោកអនុសេនីយ៍ឯក? ។ ហើយពួកមនុស្សទាំងប៉ុន្មានដែលមកជាមួយនឹងលោកក៏មកជួបជុំគ្នាអស់ហើយ ។

លោកមេទ័ពមានអាការជូចជាឥពុកចិត្តសុចរិត រួចស្រាប់តែផ្ទាស់សំដីភ្ទាម ហើយស្រែកដោយសំរែកជូចគេកាប់ថា:

– លោកអនុសេនីយ៍ឯក លោកនិយាយច្រើនពេក! យើងបានសម្ចាប់ចោលនាយទាហានជាច្រើនណាស់ហើយ ដែលនិយាយតិចជាងលោកទៅទៀត ។

អ៊ីស្មាអ៊ីលឆ្ងើយដោយសំដីឥតរំកើបថា:

– ខ្ញុំបាទដឹងហើយ! ខ្ញុំបាទឃើញប្រជាប់សម្រាប់ចងកហើយ! ។

លោកវរសេនីយ៍ឯកក្អក ឃឹតបារីមួយក្សឹតវែង ហើយនិយាយទៀតថា:

– លោកជូចជាមានសមានចិត្តចំពោះពួកទ្មិល ។

(មានត)

រឿងបល្ប៉ង្ហង្ហិញ សាមសិបពីររឿង

រឿងព្រេងជណ្ឌៀ

លោកសមិន ម្ចាត្យនជម: តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

និទានដ៏នៃរូបទេពនិម្មិតទី ១៤

កាលណោះព្រះបាទកោជ:ទ្រង់យាងចូលជិតបល្ប៉ង្ហទិព្ធ ដើម្បីនឹងចាត់ឲ្យធ្វើពិធីមុឌ្ធាភិសេកចំពោះព្រះអង្គ ។ រូបទេពនិម្មិតទី ១៤ ក្រាបបង្គំទូលព្រះបាទកោជ:ថា:

"សូមព្រះអង្គទ្រង់ព្រះសណ្ឌាប់, ព្រះមហាក្សត្រិយ៍ក្រមាទិត្យទ្រង់សោយរាជសម្បត្តិនៅនគរអវន្ទី ។ ទ្រង់មានកល្យាណមិត្តម្នាក់ឈ្មោះ សុមិត្រ (Sumitra) ដែលបានចេញពីគេហដ្ឋានរបស់ខ្ជូនដើម្បីធ្វើដំណើរទៅកាន់សែះពិសិដ្ឋ ។ ក្រោយដែលបានទស្សនាការនូវសែះទាំងនោះ, សុមិត្របានចូលទៅជិតសែះមួយឈ្មោះ សក្រាវតារ (çakravatâr) ដែលជារបស់នាងទេវធីតាមួយរូបព្រះនាមនាង យុតាទិទេវា (Yugâdidevâ), ក្រោយដែលបានធ្វើសក្ការ:បូជា សូត្រសេចក្តីសរសើរចំពោះព្រះនាង, លោកក៏បានចូលទៅក្នុងនគរមួយ, នៅទីនោះលោកបានឃើញជិតព្រះវិហារអាទិទេពមួយ នូវធ្នាំងខ្ជះមួយពេញទៅដោយប្រេងក្តៅនៅលើដើងចង្ក្រានត្ត មានក្ងើងធេះខ្ជាំង ។ លោកបានសាកសួរ

មនុស្សនៅទីនោះ ។ គេធ្វើយថា: នៅទីនេះមាននារីម្នាក់ មានអវយវ: ជើងដៃមានសម្ជស្សជាទិព្ធ នាមព្រះនាង មទនសញ្ជីវនី (Madanasanjivani) ជាព្រះរាជិនីនៃប្រទេសនេះ, ធ្នាំងខ្ទះនេះជារបស់ព្រះនាង ។ បុរសណា អាចចូលទៅក្នុងធ្នាំងខ្ទះដែលពេញដោយប្រេង ហើយមិនស្ទាប់ បុរសនោះជាស្ទាមីរបស់ព្រះនាង ។

ដល់បានដំណឹងនេះហើយ សុមិត្របានឃើញព្រះនាងមទនសញ្ជីវនី, លោកបានពិចារណាទ្រង់ទ្រាយ, កំពស់, លំអ, សុការម្មណ៍ ហើយទៅជាធ្ពូតដោយចិត្តស្នេហាជាយ៉ាងក្រៃលែងចំពោះព្រះនាង ។ ដល់រិលត្រឡប់ទៅកាន់ទតរអវន្ទិវិញ; លោកបានយករឿងនេះទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្ស ។ ក្រោយដែលទ្រង់ព្រះសណ្ណាប់នូវរឿងនៃសុមិត្រ ព្រះរាជាទ្រង់មានបំណងចង់ឃើញព្រះនាង, ទ្រង់ស្តេចយាងទៅជិតធ្នាំងខ្ទះដែលពេញទៅដោយប្រេងក្តៅ ហើយក៏លោតទៅក្នុងប្រេងនោះ ។ ព្រះនាងក៏ទ្រង់ជ្រាបនូវព្រឹត្តិការណ៍នោះទ្រង់យាងមកដល់, កាលណាព្រះនាងទ្រង់បានទតឃើញនូវមហារាជវិក្រមាទិត្ស, ទ្រង់យកទឹកអម្រឹតមកប្រោះព្រំ, ព្រះរូបមហារាជដែលរលាយដោយភ្លើងក៏ជាសះស្បើយដូចដើម, ត្មានស្នាមរលាក, ត្មានឈឺចាប់អ្វីឡើយ ។ ព្រះនាងក្រាបបង្គំទូលព្រះនរបតីថា: បពិតមហារាជ ព្រះអង្គមានគុណសម្បត្តិដ៏ធ្នើមចំពោះមហាក្សត្រិយ៍ ដែលទ្រង់ចេះទទួលនូវសេចក្តីទុក្ខឈឺចាប់ត្រប់យ៉ាង តើទុក្ខឈឺចាប់ណាដែលស្មើនឹងទុក្ខឈឺចាប់ ដែលត្រូវលោតចូលទៅក្នុងធ្នាំងខ្ទះពេញទៅដោយប្រេងក្តៅយ៉ាងនេះ? តឺដើម្បីនឹងបញ្ជាក់

នូវព្រះរាជចរិយាពេញជាមនុស្សធមិ បានជាខ្ញុំម្ចាស់នេះយកឆ្នាំងខ្ទះនេះ មកជម្ពល់នៅទីនេះ ខ្ញុំម្ចាស់យល់ថា: សភាពជាមនុស្សធមិរបស់ព្រះអង្គនេះ មានអានុភាពសម្បើមអស្ចារ្យណាស់ ។ ព្រោះហេតុនេះ ខ្ញុំម្ចាស់សប្បាយចិត្តនឹងព្រះអង្គពន់ពេក ។ សូមព្រះអង្គតង់នៅនឹងខ្ញុំម្ចាស់ ទុកព្រះអង្គជាព្រះមហាក្សត្រិយ៍នៃប្រទេសរតនវតី (Ratnavati) ។

ក្រោយដែលព្រះនាងបានប្រើនូវមធ្យោបាយគ្រប់យ៉ាង ដើម្បីឲ្យព្រះមហាក្សត្រិយ៍តង់នៅទីនោះ ដោយប្រើវិធីក្រាបបង្គំទូលដោយសំដីដ៏ពីរោះអស្ចារ្យ, ព្រះនាងក្រាបបង្គំទូលព្រះចក្រីតទៅទៀតថា: "បពិត្រមហារាជ, ទ្រង់មានព្រះរាជទ្រព្យប្រើនទៅក្នុងសង្សារនេះ; ព្រោះទ្រង់ចេះរក្សាទុកនូវព្រះរាជហ្ហូទ័យឲ្យស្ថិតនៅឆ្ងាយពីវិសមឃោក, ចំពោះនារីដែលមានលំអជូចខ្ញុំម្ចាស់ ព្រមទាំងមានពូជជាព្រះរាជវង្សានុវង្សផង ។

ក្នុងពេលនោះ, ព្រះមហាក្សត្រិយ៍ ទ្រង់ក៏បានព្រះរាជទានជល់កល្យាណមិត្រឈ្មោះសុមិត្រ នូវរាជសម្បត្តិនៃប្រទេសនេះ ព្រមទាំងព្រះនាងមទនសញ្ជីវនី, រួចទ្រង់ស្តេចយាងវិលត្រឡប់ទៅកាន់ព្រះរាជធានីវិញ ។

រូបទេពនិម្មិតទី ១៤ ក្រោយដែលបានថ្ងៃងនូវរ្យឹងក៉វនេះថ្វាយចំពោះព្រះបាទកោជ: បានក្រាបបង្គំទូលទ្រង់តទៅទៀតថា បើទ្រង់មានព្រះរាជចរិយាបែបនេះ ទ្រង់អាចតង់នៅលើបល្ថ័ង្ពទិព្ធនេះបាន ។

ព្រះបាទកោជ: ទ្រង់បានស្តាប់នូវពាក្យនៃរូបទេពនិម្មិតទី ១៤, ក៏យាងចេញពីទីនេះក្នុងថ្ងៃនោះ ។

ជាតកនៃរូបទេពធីតាទី ១៥

មានកាលមួយថ្ងៃព្រះបាទកោដៈ ទ្រង់យាងចូលទៅដាក់បល្ល័ង្កទីព្រះអង្គដើម្បីនឹងចាត់ពិធីពិជាភិសេក ។ រូបទេពធីតាទី ១៥ ដល់បានឃើញព្រះអង្គទ្រង់យាងមកដល់ ក៏ក្រាបបង្គំទូលថា:

"ទូលព្រះបាទកោដៈ, សូមទ្រង់ព្រះសណ្តាប់, តើមានលក្ខណៈយ៉ាងណា អ្នកដែលមានសិទ្ធិអាចគង់លើបល្ល័ង្កទីព្រះនេះបាន?" ។

ព្រះមហាសត្វតែយ៍ ទ្រង់មានព្រះបន្ទូលទៅកាន់រូបទេពធីតាទី ១៥ ថា: "ចូរអ្នកពណ៌នាអំពីលក្ខណៈនោះមកមើល!" ។ រូបទេពធីតាក៏ក្រាបបង្គំទូលព្រះបាទកោដៈថា:

"មហាពាជារិក្រមាតិត្យ ក្រោយដែលទ្រង់ប្រមូលកងទ័ពមានបួនកង គឺកងហត្ថី, កងអាជ, កងព្រះទីនាំងពាជរថ, កងពលថ្មើរជើង ទ្រង់បានវាយតយុទ្ធកូមិភាគទាំងអស់, ហើយទ្រង់ធ្វើឲ្យស្តេចទាំងប្រាំនាក់ស្ថិតនៅក្រោមបង្គាប់បញ្ជាព្រះអង្គ ។ មានសម័យថ្ងៃមួយ ទ្រង់ស្តេចយាងទៅជាព្រះពាជាធិបតីភាពកងមហាសន្និបាតគណៈរដ្ឋមន្ត្រី ជាមួយនឹងពួកពាជទីប្រឹក្សាខាងធម្មសាស្ត្រ, ពួកក្តាក់ជារ៉ាក្រោមព្រះពាជបញ្ជា, ពួកវិញ្ញាជនទឹងឥស្សរជនឯទៀតជាច្រើន ។ ក្នុងពេលនោះ នាយទ្យានបាលចូលមកគាល់ព្រះអង្គ, ថ្វាយបង្គំអញ្ជលីរួចក្រាបបង្គំទូលទ្រង់ថា: "បពិត្រមហាពាជ, ព្រះអង្គទ្រង់ជាព្រះមហាពាជគ្រប់រដ្ឋវ, និងាយ:រដ្ឋវ (រដ្ឋវក្តៅ) បានចូលមកស្ថិតនៅកងគុម្ពតឈើ ដូចជាល្មោនពាំសប្បាយពន់ពេក ។

ឆុម្ពោតរុក្ខានឹងផ្ទុវណ្ឌា, ព្រឹក្សាមានត្រួយពន្ធក. មានផ្ទៃផ្ការក្ងឹបៃងចាំងឆ្លុវ
ឲ្យមនោរម្យ ។ នៅត្រពាំងតាំងអស់មានផលជាតិជុះបេញក្ងឹស្ទាងសៃង;
ពួកឃ្មុំជូបកងផ្ការ, សៃវឹងដោយទឹករបស់ខ្លួន, បានបញ្ចេញស្សូរសៀង
ជឹពីរោះ, បក្សាកោកិល (Kokila តារ៉ា) យំដោយសម្ទៃងស្រទន់ជិតឆ្លូវ ។

ដោយនាយទយ្យានបាលក្រាបបង្គំទូលទ្រង់យ៉ាងនេះ, ទ្រង់ក៏បាន
ស្តេចយាងទៅកាន់រាជទ្យាននោះជាមួយនឹងព្រះរាជបរិពារ ទ្រង់បាន
កំសាន្តព្រះរាជហឫទ័យជាប្រើនបែបប្រើនយ៉ាង ។

នៅកណ្តាលត្រៃ, កណ្តាលទេវបូជនីយស្ថាន ទ្រង់ក៏បានឆង់លើ
បល្ថ័ង្កមាសមួយ មានរំលេចដោយត្សូង ជាមួយនឹងព្រះរាជបណ្ឌិត,
ហើយទ្រង់ក៏សិក្សាអំពីសស្ត្រៈ ។ ក្នុងពេលនោះ មានរាជបណ្ឌិតម្នាក់
ជាចៅក្រំ បានពិនិត្យនូវសស្ត្រៈមួយកន្ទៃង ហើយក្រាបបង្គំទូលថា:
"បពិត្រមហារាជ សូមទ្រង់ព្រះមេត្តាំប្រោស, ទូលបង្គំនឹងក្រាបបង្គំ
ទូលថា: "សេចក្តីសប្បាយក្នុងរាជសម្បត្តិ, ក្នុងវេលា, ក្នុងតំបន់ណាក៏
ដោយ មិនប្រកបដោយស្ថិរវន្តទេ; រូបកាយនេះមានឈាម, សាច់, លាមក,
បស្សាវៈ, តែទ្រឌុត្រោមពិការមិនប្រកបដោយស្ថិរវន្តដែរ; ជូបជាបុត្រា,
មិត្ត, ភរិយាតាំងអស់ ក៏មិនស្ថិតស្ថេរចិរកាល តែងតាំងនៅក្នុងអនិច្ច-
ធម៌ ។ ព្រោះហេតុជូបនេះ សេចក្តីស្រឡាញ់ហួសប្រមាណមិនសម
ជល់ពួកបណ្ឌិតទេ ជូបជាសេចក្តីស្រឡាញ់នាំឲ្យសប្បាយប្រើន, កាល
ណាប្រាសចាកសត្វនឹងសង្ខារ, សេចក្តីស្រឡាញ់នោះនាំមកនូវទុក្ខធំ ។

ដោយហេតុនេះហើយ ចានជាពួកបណ្ឌិតត្រូវតែខំប្រឹងតែងចិត្តឲ្យពិចារណាចំពោះជីវភាពជាអនន្តរកាល ។

តែគ្មានជីវភាពជាអនន្តរកាល ក្រៅពីបុរសដ៏ឧត្តម(១) ដែលជាទម្រង់ដ៏ប្រសើរទេ ។ បើមនោមានសភាពទន់ជ្រាយចំពោះចំណុចនេះ មនោនេះតែងច្រាសចាកពីគុកសង្សារបាន ។ កាលណាចៅក្រមបានក្រាបបង្គំទូលដូចនេះ មហាភជ្ឈន៍តង់ជម្រះមួយស្រេចក់, ហើយមានព្រះបន្ទូលថា "បើកាលណាខ្យល់អស្សាសៈ បស្សាសៈ ស្ថិតនៅក្នុងរូបកាយដែលមានទ្វារជារន្ធច្រើន គឺជាជីវភាពនៃបុគ្គលដែលរស់នៅសព្វថ្ងៃ; កាលណាខ្យល់អស្សាសៈបស្សាសៈចេញអស់ពីរូបកាយ គឺសេចក្តីស្លាប់នៃបុគ្គលដែលរស់, ព្រោះហេតុនេះ ជីវិតជាអច្ចរិយវត្ថុ ។ អ្វីទាំងអស់ដែលស្ថិតនៅក្នុងសង្សារវដ្ត ត្រូវតែកើតស្លាប់ ហើយអាចគន់វង់ឯាន លុះតែវត្ថុជាតុមានសភាពគួរខ្ពើម ឬជីវិតស្ថិតនៅ ។ ក្រៅយសេចក្តីស្លាប់, ការខាត់ធន៌ (ដែលមានបច្ច័យតាក់តែងទាំងអស់) គ្មាន ។ អ្នកណាមួយដឹងវត្ថុជាតុទាំងអស់នេះដូចជាបានឃើញចំពោះភ្នែក, តែនៅស្រឡាំងកៃតែតម្រង់តាមកម្មវត្ថុកាម ទន្ទឹងតិលេសកាម, អ្នកនោះស្ថិតនៅក្នុងស្ថានភាពជាអ្នកលង់ខ្លៅពិតច្បាស់ជា; ព្រោះហេតុថា ពិតមែនតែចំណេះមិនបានវិនាស ចំពោះបុគ្គលនោះ ។ មិនមានហេតុបច្ច័យតាក់តែងនឹង "បុគ្គលជាអនន្តរកាល" ។ អ្នកណាដែលខុសជា

---

១ បរមៈបុរុស – Parama-Purusha ប្រែថា "បុរសឧត្តម" នៅទីនេះត្រូវរក្សាទុកពាក្យអាំងឆីយាងថាបុរស ដែលប្រែថា «ប្រុស» ព្រោះបុរសជាពាក្យខាងទស្សនវិជ្ជាដ៏សុខុម ។

បុរស គឺអ្នកដែលព្យាយាមបំបាត់អវិជ្ជាឲ្យបេញចាកសន្តាន អ្នកនោះឯង ជាឧត្តមបុរសមែនពិត ។

ក្រោយដែលបានធ្វើព្រះរាជសន្ធនាការអំពីវិជ្ជា ព្រះបាទវិក្រមាទិត្យ មានព្រះរាជហ្ហ្ហ ទ័យសោមនស្សពន់ពេក នឹងចៅក្រមរបស់ព្រះអង្ត, ទ្រង់ បានព្រះរាជទានន្ធវអំណោយមាស ៨ លក្ស (Lacks) ។

ព្រះបាទកោជ: កាលទ្រង់ព្រះសណ្តាប់ន្ធវសេចក្តីពណិនានៃ រូបទេពនិម្មិតទី ១៥ យ៉ាងនេះហើយ ទ្រង់ក៏មិនបានធ្វើរាជាភិសេក ក្នុងថ្ងៃនោះ ។ (មានត)

ពាណិជ្ជកម្មជាអំពើឲ្យបានជាសេដ្ឋី

១៦ – សេចក្តីពិត បណ្តាឧបាយរកទ្រព្យទាំងអស់ មានតែឧបាយមួយទេ ដែលអាចកញ្ចនទ្រព្យសម្បត្តិ គេសរសើរ ក្នុងលោកនេះគឺពាណិជ្ជកម្ម, ឧបាយរកទ្រព្យឯទ្រៅតមិនទ្រៅងទាត់ទេ ។

ពាណិជ្ជកម្ម ដើម្បីកសាងខ្ជួនជាសេដ្ឋី មានវិធី ៧ យ៉ាង គឺជំនួញគ្រឿងក្រអូប ១ បញ្ជូលទំនិញទុកក្នុងឃ្ទាំង ១ សមាគម ជាមួយអ្នកជំនួញ ១ ការចូលមកប្រើនៃអ្នកទិញជ្ជាប់ទិញ ១ ការប្រាប់ដំឡៃលក់ខុស ១ ការលក់ដោយត្រាជូកោង ១ នឹង ការដឹកទំនិញពីប្រទេសក្រៅចូលមក ១ ។

កំណត់ទឹងប្រវត្តិការណ៍

ពិធីបំបួសកុលបុត្រជាតិចាវាំងសែសម្នាក់

នៅវិត្តឧណ្ណាលោម

របស់ពុទ្ធសាសនបណ្ឌិត្យ

កាលពីថ្ងៃអាទិត្យទី ១៦ តុលា ១៩៥៥ វេលាម៉ោង ៣ កន្ទះរសៀល នៅព្រះវិហារវត្តឧណ្ណាលោម សង្កាត់លេ ៣ ក្រុងភ្នំពេញ មានពិធីបុណ្យបំបួសកុលបុត្រម្នាក់ជាតិចាវាំងសែសឈ្មោះ ឡូវ៉ងត៍ ប៉ូតែល អាយុ ២៥ ឆ្នាំ បួសជាសាមណេរ ដោយមានសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត សង្ឃនាយកគណៈមហានិកាយជាព្រះឧបជ្ឈាយ៍ នាកណ្ណាល ជំនុំព្រះភិក្ខុសង្ឃរាជាគណៈហានានុក្រមជាប្រើនរូប មានព្រះតេជព្រះគុណព្រះពោធិវង្សចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត និងព្រះតេជព្រះគុណព្រះសាសនមុនីជាចៅអធិការវត្តពិភទ្រវង្សីជាដើម ។ សាមណេរនេះមានពុទ្ធិកនាមថា អានន្ទ ។

ពិធីបុណ្យនេះ ក្នុងវេលាមុនម៉ោង ១៦ គេសង្កេតឃើញពួកមន្ត្រីបរទេសទាំងឡាយគឺលោកវេជ្ជបណ្ឌិតបិកកូត (Pegcot) ជាពុទ្ធជនដែលជាពុំនឹងរបស់សាមណេរនោះ, លោកចារតេស (Barthes) ទីប្រឹក្សានៅក្រសួងឃោសនាការជាតិ និងអស់លោកជាអង្គទូតបរទេសប្រចាំប្រទេសកម្ពុជា លោកអូវ៉ែរតុន (Overtoon) និងលោកម៉ារតាំងហ៉ារ្ស (NartinHary)

នៅស្ថានឯកអគ្គរដ្ឋទូតអាមេរិកាំង, លោកលេខាធិការនឹងអនុពន្ធនៃឯក
អគ្គរាជទូតជប៉ុន, លោកកុងស៊ុលនៃម្រទេសចិន, លោកស្រីរ៉ាម (Shri-
Ram) នាយកទាហានអនុពន្ធនៃគណៈកម្មធិការអន្តរជាតិប្រទេសឥណ្ឌ
ជាដើម ព្រមទាំងមន្ត្រីនឹងឥស្សរជនជាតិវ្មែរទាំងឡាយមានលោកស៊ុន-
រ៉ាន់ ក្រុមប្រឹក្សាព្រះរាជអាណាចក្រ, លោកសឹន-សាប់ អតីតហៅ-
ហ្វាយខេត្ត, លោកវិសេសកោតា (ទា-ជាវលី) នឹងលោកគហបតី
ហេ-យានជាដើម មួយអន្ទើដោយលោកអ្នកពុទ្ធបរិស័ទជាតិយៀកណាម
នឹងជាតិវ្មែរជាច្រើនទៀត ដែលយើងសូមអក័យទោសដោយមិនបានរាប់
នាមឲ្យសព្វគ្រប់ក្នុងទីនេះ សឹងបានអញ្ជើញមកជល់មហាកុដិនៃសម្តេច
សង្ឆនាយកមហានិកាយ និយាយដោយរួបរួមគឺថាមានបណ្តាជនច្រើន
កុះករប្រជ្រៀតគ្នាទាំងក្នុងព្រះវិហារទាំងខាងក្រៅព្រះវិហារ ដោយចង់ដឹង
ចង់យើញកុលបុត្រជាតិទរូប ដែលចូលមកសូមផ្ទួសក្នុងព្រះពុទ្ធសាសនា
ជាលើកដំបូងបង្អស់នៅប្រទេសយើង ។

បន្ទាប់មក សម្តេចសង្ឆនាយកជួន-ណាត បានអញ្ជើញឥស្សរ:
ជនទាំងនោះឲ្យកាន់ត្រឹងបរិក្ខារសំខាន់ ៗ - ម្នាក់មួយមុខ ៗ ដើរតម្រង់
ទៅប្រទក្សិណជុំវិញព្រះវិហារ ។ លុះចូលទៅក្នុងព្រះវិហារហើយ ឧបា-
សកបាននមស្សការព្រះរតនត្រ័យ ។ រួចពីនោះ នាគក៏បានសូត្របាលី
សុំផ្ទួសហើយប្រគេនន្ទូវត្រៃចីវរទៅឧបជ្ឈាយ៍ ដើម្បីឲ្យលោកបំពាក់មក
ខ្ជួនវិញ ។

សម្តេចសង្ឃនាយកដែលគ្រប់គ្រងកិច្ចការទាំងនោះ, ហើយ
បំពាក់អង្រឹកនៅកន្លែងប្រជុំសម្រាប់ចំពោះមុខឲ្យយកទៅសូត្រតាក់
នៅទីកន្លែងកំពង់ក្នុងព្រះវិហារ ហើយត្រឡប់មកថ្វាយបង្គំព្រះបាទ-
ជ្រាយវិញ ។ រួចអំពីកិច្ចខាងលើនេះហើយ ទើបជ្រាយក៏សូត្រសិក្ខាប-
ទាំង ១០ ប្រការ ឲ្យនាគសូត្រតាមលុះត្រាតែចប់ ។

កិច្ចខាងលើដែលបានធ្វើរួចស្រេចហើយនេះ ទុកជាកិច្ចបញ្ចប់ពិធី
បុណ្យចំបួសនៅឧកាសនេះ ។ ព្រះពុទ្ធសាសនាក្នុងប្រទេសយើងក៏បាន
បព្វជិតជាតិអ៊ីរ៉ុបមួយរូប ។

សាមណេរឡ្រ៉ង់ត៍ប៊ូតែល លុះបានទទួលបព្វជ្ជារួចហើយ, បាន
សូត្រសុន្ទរកថាជាភាសាបារាំង ថ្លែងអំណរគុណចំពោះគណៈសង្ឃមាន
សម្តេចព្រះសង្ឃនាយកជាប្រធានដែលបានទទួលការៈនៃកិច្ចបព្វជ្ជា ព្រម
ទាំងចំពោះពុទ្ធមាមកជនទីឯមិត្រនៃពុទ្ធសាសនាទាំងអស់ ដែលបាន
អញ្ជើញមកជួយអបអរសាទរបំពេញកិត្តិយសជាក្បៀវ ក្នុងពិធីបព្វជា
នោះ។បន្ទាប់មក, លោក ញូង - សឿង លេខាធិការនៅក្រុមពុទ្ធសាសន
បណ្ឌិត្យ បានថ្លែងសុន្ទរកថាជាដែលនោះជាភាសាខ្មែរ ដែលលោកគ្រូព្រះ-
គ្រូសង្ឃសត្តា ប៉ុណ្ណ - សម្ភាជ បានប្រែសម្រួលមកពីភាសាបារាំង ។

លុះរួចកិច្ចនេះសព្វគ្រប់ហើយ មានការជប់លៀងតេស្ដ:ចំពោះ
ក្បៀវជាបព្វជិតនឹងគ្រហស្ថ នៅទីលានខាងមុខព្រះវិហារជាកិច្ចបង្ហើយ
បុណ្យ ។

ឯសុន្ទរកថា ដែលប្រែមកជាភាសាខ្មែរនោះ យើងសូមយកមក
ចុះផ្សាយជូនជូចតទៅនេះ ៖

សុន្ទរកថាប្រែសម្រួលសេចក្ដីពីបារាំងមកជាខ្មែរ

ខ្ញុំព្រះករុណា, អាត្មាភាព សូមថ្វៃងអំណរគុណដ៏ជ្រាលជ្រៅចំពោះ
សម្តេចជាសង្ឆនាយកគណៈមហានិកាយ នឹងព្រះថេរានុត្ថេរៈគ្រប់អង្គ,
ទ្រង់, ឯកឧត្តមរដ្ឋមន្ត្រីនៃព្រះរាជរដ្ឋាភិបាល ឯកឧត្តមសមាជិកនៃអង្គទូត
ព្រមទាំងអស់លោក អស់អ្នក ជាឥស្សរជនជាតិខ្មែរនឹងបរទេស ដោយ
រួបរួមគឺ ចំពោះពុទ្ធមាមកជន នឹងមិត្តនៃព្រះពុទ្ធសាសនា ដែលមានមេត្តា
ចំពេញកិត្តិយសដ៏ប្រសើរ ជល់ខ្ញុំព្រះករុណា, អាត្មាភាពក្នុងពិធីនេះ ។

ខ្ញុំព្រះករុណា, អាត្មាភាព សូមពុំប្រើរោហារលែបខាយយកមក
អធិប្បាយហេតុផលប្រគេន-ថ្វាយ-ជូនក្នុងទីនេះទេ ។ ហេតុនៃផ្ទួសនេះ
មានតែម្យ៉ាង ហើយជាសេចក្ដីពិតឥតចំផ្ទើស ដែលបើកបង្ហាញនូវ
ចិត្តគំនិតរបស់ខ្ញុំព្រះករុណា, អាត្មាភាព ប្រគេន-ថ្វាយ-ជូនឲ្យបានជ្រាប
ច្បាស់ជូចតទៅនេះ ៖

ខ្ញុំព្រះករុណា, អាត្មាភាពមានកំណើតនៅប្រទេសបារាំង បានចំរើន
វ័យវឌ្ឍនៈធំឡើងក្នុងមជ្ឈដ្ឋានកម្មករថ្នាក់មធ្យម, មាតាបិតាពុំមែនជាអ្នក
កាន់សាសនាគ្រឹស្តទេ ជាមជ្ឈធាតុកបុគ្គលសុទ្ធសាធ គឺជាអ្នកឥតប្រកាន់
សាសនាណាមួយឡើយ ។ អាស្រ័យហេតុនេះ, បឋមវ័យរបស់ខ្ញុំព្រះ
ករុណា, អាត្មាភាព ក៏បានកន្ទងទៅក្នុងមជ្ឈដ្ឋានប្រាសចាគការប៉ះពាល់

នឹងសាសនាណាមួយដោយពិត ។ ខ្ញុំព្រះកុណា, អាត្មាភាពពុំមានទោមនស្សទេ ព្រោះការណ៍នេះបែរជានាំឲ្យមានទស្សនៈយ៉ាងបរិសុទ្ធក្នុងជីវភាព ដ៏ប្រាសស្រឡះចាកការស្រវាក់ស្រវ៉ណ្ឌកន្ត្រចឡំត្រប់យ៉ាង ។

ចាប់តាំងពីអាយុតំរប់ ២០ ឆ្នាំ គឺបន្ទាប់អំពីពេលឈប់សិក្សាមក, ខ្ញុំព្រះកុណា, អាត្មាភាព ក៏ចាន់ហាត់រៀនសង្កេតត្រួស ៗ នូវសាសនាធំ ៗ ហើយចាន់ទាក់ជាប់ចិត្តនៅចុងក្រោយបំផុត ដែលឃើញមានតែមួយគត់ បើនិយាយដោយចំពោះគឺ ព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនាពុំមែនជូចជាសាសនាជទៃ ដែលប្រើនតែជាលទ្ធិប្រើអាការបង្ខំនោះទេ ទាំងពុំមែនជាជំនឿតតហេតុផលផង គឺពេញទីជា ឥបឧមិ, តាមសេចក្តីយល់របស់ខ្ញុំព្រះកុណា, អាត្មាភាព គឺជារបៀបនៃការសិក្សាដែលមានទំនងជូចជាវិទ្យាសាស្ត្រសម្រាប់ជុសខាត់ចិត្តឲ្យបរិសុទ្ធផ្ទូរផង ។

ហេតុតែមួយយ៉ាងនេះឯងហើយ ដែលនាំឲ្យខ្ញុំព្រះកុណា, អាត្មាភាព មិនជ្រើសយកជំនឿនឹងលទ្ធិជទៃ ត្រឡប់មកជឿកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ ។ ខ្ញុំព្រះកុណា, អាត្មាភាព ចានរាវរកមើលសៀវភៅក្ស្ជនច្បាប់ពុទ្ធសាសនាជាច្រើន ទើបកើតគំនិតយ៉ាងខ្ជាប់ខ្ជួនមួយឡើងថាត្រូវបេញមកកាន់បូពាទិស រស់នៅក្នុងទីនេះ ព្រមទាំងសង្កេតមើលនូវជីវភាពរបស់ប្រជាជនពុទ្ធសាសនិក ដើម្បីនឹងយកជាបែបផែនសិក្សាព្រមទាំងប្រតិបត្តិតាមវិធីនៃប្រជាជនទាំងនេះ ដ៏ជាការស្រាវជ្រាវរកផ្ទូវ

ចេះដឹង ប្រយោជន៍នឹងបណ្តុះបញ្ញាឲ្យបានសម្រេចផល ដើម្បីនឹងផ្សាយ
នូវសុកមង្គលចំពោះសព្វសត្វទាំងអស់ ។

នេះពុំមែនជាការដើរផ្សងព្រេងដ៏អស្ចារ្យមួយឬ? ចំពោះអ្នកដែលធុញ
ទ្រាន់នឹងជីវកាពទាងសម្ភារនិយម នឹងជំនឿបង្ខំដែលឥតផលប្រយោជន៍
ហើយទំស្រាវជ្រាវរកទៅក៏យើញជាក់ថា មានតែវិបស្សនាកម្មដ្ឋានក្នុង
ព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ដែលប្រកបដោយតម្លៃពិតប្រាកដ ។

គឺហេតុតែមួយយ៉ាងហ្នឹងឯង ដែលបណ្តុះបំណងឲ្យខ្ញុំព្រះករុណា,
អាត្មាភាពចង់ស្វែកដណ្តប់កាសាវពស្ត្រ ដែលជាមធ្យោបាយដ៏ល្អតែ
មួយក្នុងការប្រតិបត្តិ នឹងការសម្រេចទាងផ្ទូវវិបស្សនាកម្មដ្ឋាន ដើម្បីឲ្យ
បានទៅជាបុគ្គលមួយរូប ដែលឥតទ្រព្យសម្បត្តិ ឥតមានហានៈវិជ្ជាខ្ពង់ខ្ពស់
ក៏អាច នៅជាសុខស្ងប់ បាន ។

ខ្ញុំព្រះករុណា, អាត្មាភាព សូមបញ្ចប់សេចក្តីនេះ, ដោយសូមថ្ងៃន
អំណរគុណចំពោះអស់លោកអ្នករាជការ នៃព្រះរាជអាណាចក្រខ្មែរឯក-
រាជ្យ ដែលបានអនុញ្ញាតឲ្យខ្ញុំព្រះករុណា, អាត្មាភាពបានសម្រេចផ្ទួស
ដោយងាយ ហើយដែលជាហេតុឲ្យមានពិធីបុណ្យនេះឡើង ។ ខ្ញុំព្រះ
ករុណា, អាត្មាភាពសូមថ្ងៃនអំណរគុណក្នុងទីនេះ ចំពោះលោកវេជ្ជបណ្ឌិត
ប៉ីអ្សូត៍ ដែលសមានទេសិក (ជាតិបារាំងជូចគ្នា), លោកស៊ីន្ធូរ - វ៉ណ្ណ
សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ នឹងលោកសឺន - សាប់ អតីត
ចៅហ្វាយខេត្ត ទាំងជាអតីតកូឈ្លួយរដ្ឋមន្ត្រីក្រសួងសិក្សាធិការជាដើម
ដែលបានជួយ ឧបត្ថម្ភបាត់ចែងពិធីបុណ្យបួសដ៏ឧឡារិកនេះ ។

ខ្ញុំព្រះករុណា, អាត្មាភាពមានអំណរណាស់ ដោយបានសង្កេត ឃើញ:លោកម៉ារតាំង ហ៉ារ្សរដ្ឋទូត នៅស្ថានឯកអគ្គរដ្ឋទូតអាមេរិក, ដែលជាអ្នកមានសេចក្ដីខ្នះខ្នែងក្នុងការស្ថាបនាមេត្រីភាព រវាងអ្នកកាន់ព្រះពុទ្ធ-សាសនានៃប្រទេសកម្ពុជានឹងសហរដ្ឋអាមេរិក បានអញ្ជើញមកក្នុងទីនេះផង ។

នៅទីបំផុត ខ្ញុំព្រះករុណា, អាត្មាភាព សូមប្រគេន-ថ្វាយ-ជូន នូវពរតាមគន្ធងព្រះពុទ្ធសាសនា, ដ៏ស្មោះចំពោះពីដួងហទយវត្ថុថា:

សូមសម្ពេច, ព្រះថេរានុត្ថេរ:, ទ្រង់, ឯកឧត្តម នឹងអស់លោកអ្នកគ្រប់រូប បានប្រកបដោយ សុខភាព នឹង សន្ធិភាព អស់កាលជាអង្រឹងរៀងទៅ ।

ឌ្យរ៉ង៍ត - ប៉ូតែល

មានពុទ្ធិកនាមថា អាឌឌ:

ប្រែដោយព្រះគ្រូសង្ឈសត្ថា

ប៉. ស. ធម្មារាម